Janvier–Juin 1968

១

# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤០ ខែ មករា

ព.ស. ២៥១១ គ.ស. ១៩៦៨

–ភ្នំពេញ–

5736 BIBLIOTHEQUE

១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ | ផ្នែកសាសនា | ទំព័រ

១– កបិលកថាសង្ខេប សម្ដេចព្រះពោធិវ័ង្ស រៀបរៀង . . . . . ១
២– ព្រះពុទ្ធសាសនា និង សមភាពនៃមនុស្ស ( ព្រះមហា អេង-វេមី ) . ១១
៣– រឿងព្រះពោធិរាជកុមារ ( លោក ប៊ូ-ប៊ូ ) . . . . . . . . ៣៩

ផ្នែកអក្សរសាស្ត្រ

៤– វចនានុក្រមសំស្ក្រឹត-ខ្មែរ ( ព្រះមហា ប៉ាង.ខាត់ ) . . . . . ៤៧
៥– ការស្រាវជ្រាវ ប្រវត្តិលោកវិសេស នូង ( បណ្ឌិតមហា ឈឹម.ស៊ុម ) ៥១
៦– រឿងសាមកុក ( ត ) . . . . . . . . . . . ៦០
៧– ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត ( លោក ញ៉ុក.ថែម ) . . . . ៧០
៨– ល្បងសិក្សា ប្រវត្តិអក្សរសាស្ត្រខ្មែរ ( សហ. លាង.ហ័បអាន ) . . ៨៩
៩– ជីវប្រវត្តិ លោកគ្រូ ធម្មសុវោ ឯក-ញឹម . . . . . . . . ១០៣

ផ្នែកកំណត់ប្រវត្តិការណ៍

១០– អនុស្សាវរីយ៍មហាសន្និបាតនៃមន្ត្រីសង្ឃ លើកទី ២៤ . . . . . ១១៣

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ។

# កឋិនកថាសង្ខេប

## បុព្វហេតុនៃកឋិន

សម្ដេចព្រះពោធិវង្ស ហួត-តាត រៀបរៀង

សួរ : កឋិនចីវរ កើតមានពីក្នុងសម័យណាមក ?

ឆ្លើយ : កើតមានតាំងពីក្នុងសម័យពុទ្ធកាល គឺព្រះសម្មាសម្ពុទ្ធទ្រង់បានអនុញ្ញាតនូវកឋិនចីវរ ដោយព្រះអង្គឯង ។

ស. ចុះកឋិនចីវរ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឲ្យមានឡើងដោយមានបុព្វហេតុ (ហេតុដើម) ដូចម្ដេចខ្លះ ?

ឆ. ដោយមានបុព្វហេតុ ដូចតទៅនេះ គឺមានភិក្ខុ ៣០ រូបនៅក្នុងដែនបាឋេយ្យៈ ធ្វើដំណើរទៅកាន់ក្រុងសាវត្ថី ដើម្បីក្រាបថ្វាយបង្គំគាល់ព្រះសម្ពុទ្ធ ដែលគង់នៅក្នុងវត្តព្រះជេតពន, នៅក្នុងពេលចេញវស្សាដែលជារដូវនៅមានទឹកភ្លៀងជោកជាំ នាំឲ្យភិក្ខុ ៣០ រូបនោះមានស្បង់ចីពរសង្ឃាដទទឹកជោកអស់ មានការលំបាកតាមផ្លូវយ៉ាងខ្លាំង ។ លុះទៅដល់, ភិក្ខុទាំង ៣០ រូប ក៏បានចូលទៅក្រាបថ្វាយបង្គំព្រះសម្ពុទ្ធ ។ នៅពេលនោះ ព្រះសម្ពុទ្ធ ព្រះអង្គមានព្រះបន្ទូលស្រាយត្រាស់សួរអំពីសុខ-ទុក្ខចំពោះភិក្ខុទាំង ៣០ រូបនោះ ហើយព្រះអង្គបានជ្រាបពីសេចក្ដីលំបាកខ្លាំង ក្នុងការធ្វើដំណើរមកនៃភិក្ខុទាំងនោះ រួចព្រះអង្គសំដែងនូវធម្មីកថា នាំឲ្យភិក្ខុទាំង ៣០ រូបនោះបានសម្រេចព្រះអរហត្តផលគ្រប់អង្គ ។

លំដាប់ពីនោះមក ព្រះសម្ពុទ្ធទ្រង់មានព្រះពុទ្ធចិន្តាថា "ប្រសិនបើតថាគតបានអនុញ្ញាតនូវកឋិនត្ថារកិច្ច ដល់ភិក្ខុទាំងឡាយរួចហើយ ភិក្ខុទាំង ៣០ រូបនេះ នឹងអាចទុកចីវរ ១ នៅកន្លែងរបស់ខ្លួន ហើយមកដោយមានតែស្បង់ ១ ចីពរ ១ ប៉ុណ្ណោះ នឹងមិនលំបាកតាមផ្លូវយ៉ាងនេះឡើយ, រីឯកឋិនត្ថារកិច្ចនេះសោត ព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គ ក៏ធ្លាប់តែទ្រង់អនុញ្ញាតមកដែរ" ។

លុះព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះពុទ្ធចិន្តាយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុទាំងឡាយ ហើយទ្រង់អនុញ្ញាតនូវកឋិនត្ថារកិច្ច ដល់ភិក្ខុទាំងឡាយថា:

អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ

"ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយ ដែលនៅចាំវស្សារួចហើយ ទទួលក្រាលកឋិនបាន; ម្នាលភិក្ខុទាំងឡាយ, អានិសង្ស ៥ ប្រការ នឹងសម្រេចដល់ភិក្ខុទាំងឡាយ ដែលបានក្រាលកឋិនរួចហើយ" ។

សេចក្តីសង្ខេបខាងលើនេះ ជាបុព្វហេតុនៃកឋិន ។

## អានិសង្ស ៥

សរ. អ្វីជាអានិសង្ស ៥ ? ចុះអានិសង្ស ៥ នោះ តើមានសម្រេចដល់ភិក្ខុទាំងឡាយ ដែលបានក្រាលកឋិនរួចហើយ ដូចម្តេចខ្លះ?

ឆ. ការរំលស់កំហុសក្នុងសិក្ខាបទខ្លះ ឲ្យភិក្ខុបានធូរស្រួលផង ឲ្យភិក្ខុបានលាភដោយងាយផង ហៅថា អានិសង្ស ៥ របស់ភិក្ខុ ៗ ឯអានិសង្ស ៥ នោះគឺ អនាមន្តចារោ ១ អសមាទានចារោ ១ គណភោជនំ ១ យាវទត្ថចីវរំ ១ យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ ១ រួមជា ៥ ៗ

អធិប្បាយនូវអានិសង្សទាំង ៥ ប្រការ ដូចមានតទៅនេះ៖

### ទី ១ អនាមន្តចារោ

អានិសង្សទី ១ នេះ អាចធ្វើឲ្យភិក្ខុដែលបានក្រាលអនុមោទនាកឋិនរួចផុតអាបត្តិក្នុងចារិត្តសិក្ខាបទទី ៦ ក្នុងអចេលកវគ្គនៃសុទ្ធិកបាចិត្តិយៈបាន ៗ ក្នុងអដ្ឋកថា មានសេចក្តីពន្យល់ថា[1] កឋិនទៅមិនទាន់ដោះដរាបណា ការដែលភិក្ខុមិនបានលាភិក្ខុផងគ្នាសិន ហើយត្រាច់ទៅទីដ៏គួរ គឺជាទីដែលមិនមានអាបត្តិក្នុងចារិត្តសិក្ខាបទ ដរាបនោះ ៗ

១ អដ្ឋកថាភេទ ហៅ កឋិន ៥ ខន្ធវិយត្តិ ៣ អនាមន្តេត្វា ចារោ កប្បិស្សតិ ចារិត្តសិក្ខាបទេ អនាបត្តិ ភវិស្សតីតិ អត្ថោ។

ក្នុងគម្ពីរធម្មសម្មុហវិន័យ[១] បានបំពេញសេចក្ដីថែមទៀតថា ការដែលភិក្ខុបានទទួលនិមន្តទាយក ដោយគេជនណាមួយក្ដីគេផងទាំង ៤ រូបហើយ មិនបានលាភិក្ខុដទៃដែលមាននៅក្នុងទីនោះសិន ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយ យ៉ាងនេះហៅថា អនាមន្តចារោ ។

ក្នុងគម្ពីរវិនយាលង្ការដីកា[២] ថា ការត្រូវអាបត្តិបាចិត្តិយៈដោយចារិត្តសិក្ខាបទ មិនមានដល់ភិក្ខុដែលបានគ្រាលកឋិនឡើយ" ។

## ទី២ អសមាទានចារោ

អានិសង្សទី ២ នេះ អាចធ្វើឲ្យភិក្ខុដែលបានគ្រាល បានអនុមោទ-នាកឋិន រួចចាកអាបត្តិក្នុងទុតិយកឋិនសិក្ខាបទទី ២ ក្នុងចីវរវគ្គ នៃនិស្ស-គ្គិយបាចិត្តិយៈបាន ។ ក្នុងអដ្ឋកថាពន្យល់សេចក្ដីថា[៣] ការដែលភិក្ខុមិនបានកាន់យកនូវត្រៃចីវរ "ចីវរ ៣" គឺស្បង់ ១ ចីពរ ១ សង្ឃាដី ១ ហើយត្រាច់ទៅ ហៅថា អសមាទានចារោ បានសេចក្ដីថា ការនៅ

---

១ ធម្មសម្មុហវិន័យនេះជា បករណ៍ពិសេស នៃព្រះវិន័យ ជាគម្ពីរកើតមានក្នុងបច្ឆាកាល ប៉ុន្តែមានអត្ថន័យគួរដល់អ្នកសិក្សាវិន័យដែរ ។ ២ វិនយាលង្ការនេះ ជាដីកាវិនយសង្គហៈ គឺជាដីកានៃគម្ពីរបាលិមុត្តក វិនយវិនិច្ឆ័យ ជាបករណ៍ពិសេស ព្រោះជាគម្ពីរកើតមានក្នុងបច្ឆាកាលដែរ ។ ៣ អសមាទានចារោតិ តិចីវរំ អសមាទាយ ចរណំ, ចីវរវិប្បវាសោ កប្បតីតិ អត្ថោ ។

ប្រាសចាកចីវរ ទិនគួរ គឺថាទិនមិនមានអាបត្តិឡើយ (ដល់ភិក្ខុដែលបានក្រាល-អនុមោទនាកឋិន) ។

ក្នុងគម្ពីរពេម្ពសម្ពូហវិន័យ ពន្យល់សេចក្តីកាន់តែច្បាស់ថែមទៀតថា ការដែលភិក្ខុ មិនបានកាន់យកនូវចីវរ ៣ ដែលខ្លួនបានអធិដ្ឋានហើយ ហើយត្រាច់ទៅ ហៅថា អសមាទានចារោ បានសេចក្តីថា ការដែលភិក្ខុទុកចីវរ ៣ ដែលខ្លួនអធិដ្ឋានតាមឈ្មោះហើយ, ចីវរណាមួយ, ក្នុងទីណាមួយ ហើយត្រាច់ទៅញុំាងអរុណឲ្យរះឡើងក្នុងទីឯទៀត ។

ក្នុងគម្ពីរវិនយាលង្ការដីកា មានសេចក្តីបន្ថែមថា ការដែលភិក្ខុវៀរ-បង់នូវត្រៃចីវរណាមួយក្តី ទាំងអស់ក្តី មិនធ្វើឲ្យនៅក្នុងហត្ថបាស ហើយញុំាងអរុណឲ្យរះឡើង ហៅថានៅប្រាសចាកចីវរ ។ ភិក្ខុអ្នកក្រាល-អនុមោទនាកឋិនហើយ ទុកជាធ្វើយ៉ាងនេះ ក៏មិនត្រូវអាបត្តិដោយទុតិយ-កឋិនសិក្ខាបទឡើយ ។

## ទី ៣ គណភោជនំ

អានិសង្សទី ៣ នេះ អាចធ្វើឲ្យភិក្ខុដែលបានក្រាល បានអនុមោទនាកឋិន រួចចាកអាបត្តិក្នុងគណភោជនសិក្ខាបទទី ២ ក្នុងភោជនវគ្គ នៃសុទ្ធិ-កបាចិត្តិយៈបាន ។ ក្នុងអដ្ឋកថា ថា[១] គណភោជន ទិនគួរ គឺថាមិន

---

១ គណភោជនន្តិ គណភោជនម្បិ កប្បតិ ។

មានអាបត្តិឡើយ (ដល់ភិក្ខុដែលបានក្រាល-អនុមោទនាកឋិន) ។

ក្នុងមហាវគ្គ និងក្នុងគម្ពីរផ្សេងៗ ដែលនិយាយពីគណភោជនមាន សេចក្តីពន្យល់ថា ភិក្ខុទាំងឡាយ៤រូបឡើងទៅ ដែលទាយកគេនិមន្តដោយ ភោជន៥, ភោជនណាមួយ, ទទួលនូវភោជនណា ភោជននោះហៅថា គណភោជន ។ គណៈក្នុងទីនេះ សំដៅយកភិក្ខុ៤រូប ឬច្រើនជាង៤រូប ឡើងទៅ ។ សរុបសេចក្តីថា ការដែលភិក្ខុទាំងនោះទទួលភោជន ៥ មានបាយជាដើម, ភោជនណាមួយ, ក្នុងទីជាមួយគ្នា ដោយការសូម ខ្លួនឯងក្តី ដោយការនិមន្តរបស់ទាយកក្តី ហៅថាគណភោជន ។ ការ ដែលភិក្ខុសូមគេថា «ចូរអ្នកប្រគេនបាយដល់អាត្មាទាំងឡាយ» ដូច្នេះក្តី ទាយកគេនិមន្តដោយអកប្បិយវោហារថា « សូមលោកទាំងឡាយទទួល បាយរបស់យើងខ្ញុំ» ដូច្នេះក្តី ហើយភិក្ខុ៤រូប ឬច្រើនជាង៤រូប ទៅ ទទួលបាយនោះជាមួយគ្នាយកមក ទោះឆាន់ភោជននោះក្នុងទីជាមួយគ្នា ក្តី ឆាន់ក្នុងទីផ្សេងគ្នាក្តី ហៅថា គណភោជន ។ ព្រោះសិក្ខាបទនេះ ហាមត្រង់ការទទួលព្រមគ្នា ។ សម្រេចសេចក្តីថា អានិសង្សទី ៣ នេះ អាចធ្វើឲ្យអ្នកក្រាល-អនុមោទនាកឋិន រួចចាកអាបត្តិ ដោយគណ ភោជនសិក្ខាបទបាន ។

## ទី៤ យាវទត្ថចីវរំ

អានិសង្សទី៤នេះ អាចធ្វើឲ្យភិក្ខុដែលបានក្រាល បានអនុមោទនាកឋិន រួចផុតអាបត្តិក្នុងបឋមកឋិនសិក្ខាបទទី១ ក្នុងចីវរវគ្គ នៃនិស្សគ្គិយ-បាចិត្តិយៈបាន ។ ក្នុងអដ្ឋកថា ថា(១) សេចក្តីត្រូវការដោយចីវរចំនួនប៉ុន្មាន ចីវរចំនួនប៉ុណ្ណោះ ទោះបីមិនបានអធិដ្ឋាន មិនបានវិកប្ប ក៏គួរ គឺថាមិនមានអាបត្តិឡើយ ។

ក្រៅពីអដ្ឋកថា មានគម្ពីរផ្សេងៗជាច្រើន ពន្យល់សេចក្តីឲ្យកាន់តែច្បាស់ឡើងទៀតថា សេចក្តីត្រូវការដោយចីវរចំនួនប៉ុន្មាន ការទ្រទ្រង់ចីវរដែលមិនបានអធិដ្ឋាន មិនបានវិកប្បចំនួនប៉ុណ្ណោះបាន គឺថាទុកដាក់ចីវរទាំងនោះឲ្យកន្លង ១០ ថ្ងៃបាន មិនត្រូវអាបត្តិដោយបឋមកឋិនសិក្ខាបទឡើយ ។

## ទី ៥ យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ

អានិសង្សទី ៥ នេះ អាចធ្វើឲ្យភិក្ខុដែលបានក្រាល បានអនុមោទនាកឋិន មានអំណាចទទួលចំណែកលាភ ដែលកើតឡើងក្នុងអាវាសដែលខ្លួនចាំវស្សា ។ ក្នុងអដ្ឋកថាមានសេចក្តីពន្យល់ថា (២) ចីវររបស់ភិក្ខុ-

---

១ យាវទត្ថចីវរន្តិ យាវតកេន ចីវរេន អត្ថោ តាវតកំ អនធិដ្ឋិតំ អវិកប្បិតំ កប្បិស្សតីតិ អត្ថោ ។

២ យោ ច តត្ថ ចីវរុប្បាទោតិ តត្ថ កឋិនត្ថតសីមាយំ មតកចីវរំ វា ហោតុ សង្ឃំ ឧទ្ទិស្ស ទិន្នំ វា សង្ឃិកេន តត្រុប្បាទេន អាភតំ វា យេន កេនចិ អាការេន យំ សង្ឃិកំ ចីវរំ ឧប្បជ្ជតិ តំ តេសំ ភវិស្សតីតិ អត្ថោ ។

សាមណេរដែលធ្វើមរណកាលក្តី ចីវរដែលគេប្រគេនចំពោះសង្ឃក្តី ចីវរដែលគេនាំមកដោយទ្រព្យរបស់សង្ឃ ដែលកើតឡើងក្នុងឧបចារសីមានោះក្តី រួមសេចក្តីទៅគឺថា ចីវរណាជារបស់សង្ឃ កើតឡើងក្នុងសីមាដែលក្រាលកឋិននោះ ទោះបីកើតឡើងដោយអាការបែបណាក៏ដោយ ចីវរទាំងនោះ នឹងត្រូវបានដល់ភិក្ខុដែលបានក្រាល បានអនុមោទនាកឋិនគ្រប់រូបនោះឯង ។

ក្រៅពីអដ្ឋកថា មានគម្ពីរផ្សេង ១ ទៀត គឺគម្ពីរវជិរពុទ្ធដីកា នឹងធម្មសមុហាវិន័យ បានពន្យល់សេចក្តីបន្ថែមថា ទោះបីគណៈដទៃមានបាត្រជាដើម ទាំងសំពត់ដែលសង្ឃចាត់ឱ្យគេប្តូរ ដោយអង្ករជាដើម ដែលកើតឡើងក្នុងឧបចារសីមានោះ ឬអង្ករជាដើមដែលសង្ឃចាត់ឱ្យគេប្តូរជាយសំពត់វិញ ក៏ត្រូវបានដល់ភិក្ខុដែលបានក្រាល បានអនុមោទនាកឋិនទាំងនោះដែរ ។

※

※ ※

សួ- អានិសង្ស ៥ ប្រការខាងលើនេះ ដែលបានសម្រេចដល់ភិក្ខុអ្នកបានក្រាល បានអនុមោទនាកឋិន តើមានរយៈកាលប៉ុន្មាន ?

ឆ. មានរយៈកាល ៥ ខែ គឺតាំងពីថ្ងៃ ១ រោច ខែអស្សុជ ដល់ថ្ងៃ ១៥ កើតខែផល្គុណ ប៉ុន្តែរយៈកាល ៥ ខែនេះ ចំពោះតែបានក្រាល-អនុមោទនាកឋិន ពុំថ្ងៃ ១ រោចខែអស្សុជ ។ ក្នុងរយៈកាល ២៩ ថ្ងៃ គឺពីថ្ងៃ ១ រោចខែអស្សុជ ដល់ថ្ងៃ ១៥ កតខែកត្តិក ដែលជាកាលនៃកឋិនទាន បើភិក្ខុបានក្រាល អនុមោទនានឋិកក្នុងថ្ងៃណា អានិសង្ស ៥ ក៏កើតមានគិតតាំងពីថ្ងៃនោះរហូតដល់ថ្ងៃ ១៥ កើតខែផល្គុណ ។

ស. ភិក្ខុដែលបានក្រាល-អនមោទនាកឋិន មានចំនួនច្រើនរូប ។ ចុះបើភិក្ខុ ១ រូប ឬ ២ រូប បានធ្វើឲ្យកឋិនដោះ គឺធ្វើឲ្យអានិសង្សកឋិនរបស់ខ្លួនដាចអស់ហើយ តើកឋិនរបស់ភិក្ខុដទៃ នឹងដោះទៅតាមគ្នាដែរ គឺឲ្យភិក្ខុដទៃអស់អានិសង្សកឋិនដូចខ្លួនដែរឬដូចម្ដេច ?

ឆ. ទេ, កឋិនមិនដោះទៅតាមគ្នាទេ បើភិក្ខុណា ធ្វើឲ្យកឋិនៈដោះ ក៏ដោះតែម្នាក់ឯងទៅ អានិសង្ស ៥ របស់ភិក្ខុនោះក៏រលាយអស់តែម្នាក់ឯងទៅ, ចំណែកភិក្ខុឯទៀត ៗ នៅតែមានកឋិន នៅតែមានអានិសង្ស ៥ ដដែល ។ ( រឿងកឋិនដោះនឹងមានសំដែងក្នុងមាតិកា ៨ ខាងមុខ ) ។

ស. ប្រសិនបើភិក្ខុអ្នកក្រាល - អនុមោទនាកឋិន ធ្វើឲ្យកឋិនដោះក្នុងថ្ងៃណាមួយ មុនថ្ងៃ ១៥ កើតខែផល្គុណ តើអានិសង្ស ៥ របស់ភិក្ខុនោះនឹងអាចនៅមានរហូតដល់ថ្ងៃ ១៥ កើតខែ ផល្គុណដែរឬទេ ?

ង. ទេ, អានិសង្ស ៥ នឹងអាចឋិតនៅបាន តែដោយសារកឋិន បើកឋិនដោះក្នុងថ្ងៃណា អានិសង្ស៥ក៏អស់ទៅក្នុងថ្ងៃនោះដែរ ។

ស. អានិសង្ស ៥ ដែលបានសួរ-ឆ្លើយរួចមកហើយ ជាអានិសង្ស ដែលត្រូវមានដល់ភិក្ខុសង្ឃ ដែលបានក្រាល អនុមោទនាកឋិន ។ ចុះ ចំណែកពុទ្ធបរិស័ទជាទាយក ដែលជាអ្នកចាត់ចែងធ្វើកឋិនទានយកទៅ វេរប្រគេនសង្ឃ ឲ្យក្រាលគ្រង់អនុមោទនា តើត្រូវបានទទួលអានិសង្ស អ្វីខ្លះដែរ ឬដូចម្តេច ?

ង. ពុទ្ធបរិស័ទជាទាយក ដែលបានធ្វើកឋិនទានវេរប្រគេនសង្ឃ ត្រូវទទួលផលានិសង្សច្រើនណាស់ ជាអានិសង្សដទៃផ្សេងពីអានិសង្ស ៥ របស់ភិក្ខុសង្ឃ ។ ផលានិសង្សនោះ ពុំអាចនឹងនាំយកមកសំដែងក្នុងទីនេះ បានឡើយ ព្រោះផលានិសង្សនោះទាក់ទងដល់ផ្លូវចិត្ត ដែលមានចែង ក្នុងគម្ពីរព្រះសូត្រ មានការទាក់ទងដល់សង្ឃគតា ទក្ខិណាទាន និង កាលទាន ហើយទូលំទូលាយណាស់ផង ។

អានិសង្ស ៥ ចប់

នៅមាន ត

# ព្រះពុទ្ធសាសនានិងសមភាពនៃមនុស្ស

ព្រះមហា អេង-ខេមី រៀបរៀង

មនុស្សក្នុងលោកនេះ បើពិចារណាឲ្យបានល្អិតល្អន់ដល់ជាតិកំណើត និងរូបកាយអវយវៈទៅហើយ ក៏ឃើញថាមានសភាពស្មើគ្នា ដូចគ្នាទាំងអស់ មិនគួរនឹងមានការប្រកាន់មើលងាយគ្នា បន្តុះបង្អាប់គ្នាសោះ តែដោយអាស្រ័យទិដ្ឋិមានះ ការឃើញប្រយោជន៍ផ្ទាល់ខ្លួនដោយប្រាសចាកហេតុផលហួសពេក ទើបមនុស្សទាំងនេះញែកពួកបែកបក្សមានថ្នាក់មានជាន់ខ្ពស់ទាប ដែលហៅថាការបែកវណ្ណៈ ហើយក៏មើលងាយបន្តុះបង្អាប់គ្នា ប្រកាន់មិនចូលរួមជាមួយគ្នាយ៉ាងតឹងរ៉ឹង ។ ការប្រកាន់វណ្ណៈនេះជារឿងដ៏សំខាន់មួយកើតជាបញ្ហាស្មុគស្មាញ ក្នុងលោកមកជាយូរអង្វែងណាស់ហើយ, មនុស្សដែលគាំទ្រការប្រកាន់វណ្ណៈ និងមនុស្សដែលខំព្យាយាមបំបាត់ការប្រកាន់វណ្ណៈ ក៏មានការតស៊ូប្រឆាំងគ្នាតាំងពីបុរាណកាលរហូតមកដល់បច្ចុប្បន្នកាលនេះដែរ ។

នៅប្រទេសឥណ្ឌាមានការបែងចែកវណ្ណៈជាបួនជាន់ ដែលហៅថាវណ្ណៈ ៤ គឺវណ្ណៈក្សត្រ វណ្ណៈព្រាហ្មណ៍ វណ្ណៈវេស្សៈឬវៃស្យៈនិង វណ្ណៈសូទ្រៈ ។ បណ្ដាវណ្ណៈទាំង ៤ នេះ វណ្ណៈក្សត្រ ជាវណ្ណៈខ្ពស់បំផុត បន្ទាប់មកគឺវណ្ណៈព្រាហ្មណ៍ តពីនោះគឺវណ្ណៈវេស្សៈ ជាន់ទាបបំផុតគឺ

វណ្ណៈសូទ្រៈ ។ មនុស្សអ្នកកើតក្នុងវណ្ណៈខ្ពស់ណាមួយ ហើយទៅសេពសមរួមរសជាមួយអ្នកដែលកើតក្នុងវណ្ណៈ ដែលទាបជាងវណ្ណៈក្សត្រ និងព្រាហ្មណ៍ កាលបើមានបុត្រធីតាកើតឡើង បុត្រធីតានោះ គេកប់ថាជាមនុស្សចណ្ឌាល គឺជាមនុស្សដែលអ្នកដទៃគេមើលងាយបន្តុះបង្អាប់ ហេតុដល់គេប្រកាន់ថា ជាមនុស្សចង្រៃ ដែលអ្នកដទៃគេមិនហ៊ានប៉ះពាល់ ឬសូម្បីគ្រាន់តែមើល ក៏គេមិនហ៊ានមើលផង ។

រឿងការប្រកាន់វណ្ណៈ ប្រកាន់ជាតិត្រកូលនេះ ជាបញ្ហាស្មុគស្មាញក្រៃលែង អស់លោកដែលចាប់អារម្មណ៍ក្នុងព្រឹត្តិការណ៍ផ្សេងៗនៃសាកលលោកក៏គង់ជ្រាបបានថា រឿងនេះមានការប្រព្រឹត្តទៅបែបណាខ្លះ ? នៅសហរដ្ឋអាមេរិក ការប្រកាន់ពណ៌សម្បុរស្បែកបានកើតជាបញ្ហាដ៏ធំបំផុតបណ្តាលឲ្យមានការប្រេះឆាក្នុងចំណោមជ ជាតិអាមេរិកាំងផងគ្នា ព្រោះពួកអាមេរិកាំងដែលមានពណ៌សម្បុរស្បែកសប្រកាន់ថា អាមេរិកាំងស្បែកខ្មៅជាពួកថោកទាប ទើបមានការកំណត់ព្រំដែន គឺពួកអាមេរិកាំងស្បែកស ទៅបរិភោគអាហារនៅភោជនីយដ្ឋាន ឬធ្វើដំណើរដោយរថភ្លើងជាដើម ហាមមិនឲ្យពួកអាមេរិកាំងស្បែកខ្មៅចូលទៅលាយឡំជាមួយនឹងពួកខ្លួនឡើយ ។ ឯពួកអាមេរិកាំងស្បែកខ្មៅវិញ ក៏ប្រកាន់ថា ខ្លួនក៏ជាជនជាតិអាមេរិកាំង មានសិទ្ធិសេរីភាពស្មើនឹងជនជាតិអាមេរិកាំងឯទៀតដែរ ។

អាស្រ័យហេតុនេះ ទើបកើតជាបញ្ហាកាប់សម្លាប់គ្នាបង្ហូរឈាមគ្នា រវាងជនជាតិអាមេរិកាំងដូចគ្នា រហូតមកដល់សម័យបច្ចុប្បន្ននេះ ។

ឯនៅប្រទេសឥណ្ឌាវិញ រឿងការប្រកាន់វណ្ណៈនេះមានតាំងពីសម័យមុនពុទ្ធកាលម៉្លេះ ។ ដើម្បីនឹងបញ្ជាក់ឲ្យឃើញថា ការប្រកាន់វណ្ណៈមានផលអាក្រក់យ៉ាងណា ហើយព្រះពុទ្ធសាសនាមានសកម្មភាពក្នុងរឿងនេះយ៉ាងណាខ្លះនោះ សូមនាំយករឿងរ៉ាវខ្លះដែល មានមកក្នុងគម្ពីរខាងព្រះពុទ្ធ-សាសនាមកពណ៌នាដោយសង្ខេប ដូចតទៅនេះ :

ក្នុងសម័យដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ដឹងឡើង ក្នុងលោកនេះហើយ មានព្រះរាជាមួយព្រះអង្គគ្រប់គ្រងរដ្ឋកោសល ទ្រង់ព្រះនាមព្រះបាទបសេនទិកោសល ទ្រង់មានអាណាខេត្តនៃការគ្រប់គ្រងទាក់ទងរហូតទៅដល់រដ្ឋកាសីនិងរដ្ឋសក្កៈ ។ រដ្ឋសក្កៈនេះមានរដ្ឋធានីឈ្មោះ កបិលពស្តុ ពួកសាក្យៈដែលអាស្រ័យនៅក្រុងកបិលពស្តុនេះ គឺជាព្រះញាតិរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ ឯព្រះបាទបសេនទិកោសលទ្រង់ជាពុទ្ធសាសនិកមានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ទ្រង់គោរពព្រះពុទ្ធជាម្ចាស់យ៉ាងស្និទ្ធស្នាលបំផុត រហូតដល់ពេលខ្លះដែលស្តេចយាងទៅគាល់ ព្រះអង្គទ្រង់បន្ទាបព្រះកាយយកព្រះហស្ត ចាប់កព្រះបាទរបស់ព្រះពុទ្ធជាម្ចាស់រែតត្រួតប្របាច់ថ្វាយ ដើម្បីទ្រង់សំដែងសេចក្តីគោរពដ៏ស្មោះអស់ពីព្រះរាជ

ហឫទ័យ ។ ដើម្បីនឹងឲ្យការគោរពរាប់អានរបស់ព្រះអង្គចំពោះព្រះពុទ្ធជាម្ចាស់មានសភាពជិតស្និទ្ធរឹតតែខ្លាំងឡើងនោះ ព្រះបាទបសេនទិកោសលទើបទ្រង់សព្វព្រះរាជហឫទ័យបញ្ជូនរាជទូតទៅក្រុងកបិលព័ស្តុ សុំដណ្តឹងរាជធីតានៃក្សត្រសាក្យវង្សមួយអង្គ មករៀបអភិសេកជាអគ្គមហេសីរបស់ព្រះអង្គ ។ ឯក្សត្រខាងក្រុងកបិលព័ស្តុមានការប្រកាន់ជាតិវង្សត្រកូលជាខ្លាំង កាលបើបានទទួលពត៌មាននេះ ក៏ប្រជុំគ្នាជាបន្ទាន់ដើម្បីដោះបញ្ហានេះ ព្រោះមិនប្រាថ្នានឹងថ្វាយរាជធីតានៃសាក្យវង្សទៅរួមអភិសេកជាមួយនឹងព្រះបាទបសេនទិកោសលទេ តែបើនឹងមិនថ្វាយដោយអាងថាពួកសាក្យៈមិនធ្លាប់រួមអភិសេកជាមួយវង្សត្រកូលដទៃក៏មិនបាន ព្រោះសាក្យវង្សធ្លាប់អភិសេកជាមួយក្សត្រខាងកោលិយវង្សដែរ ហើយបើនឹងមិនថ្វាយដោយត្រង់តែម្តងទៅ ក៏ខ្លាចព្រះទ័យព្រះបាទបសេនទិកោសល ។ ហេតុនេះ បរិយាកាសនៃការប្រជុំទើបមានសភាពតឹងតែងបន្តិច ។ តែក្នុងខណៈនោះ ក្សត្រមួយព្រះអង្គទ្រង់ព្រះនាម មហានាម ជាក្សត្រសាក្យវង្ស ទ្រង់ស្នើថា ព្រះអង្គមានស្ត្រីអ្នកបម្រើផ្ទាល់ព្រះអង្គម្នាក់ ហើយព្រះអង្គមានធីតាជាមួយនឹងស្ត្រីអ្នកបម្រើនេះមួយ ឈ្មោះនាង វាសភខត្តិយា ជាស្ត្រីមានរូបឆោមលោមពណ៌ល្អល្មមនឹងថ្វាយបាន, ដូច្នេះគួរបញ្ជូននាងនេះទៅថ្វាយព្រះបាទបសេនទិកោសលដើម្បីដោះស្រាយបញ្ហានេះឲ្យបានស្រួលដោយមិនប៉ះពាល់ដល់វង្សសាក្យៈ ។ ទីប្រជុំក៏យល់ស្រប ។ ក្សត្រសាក្យវង្ស

ទើបថ្វាយនាងវាសភខត្តិយា ទៅព្រះបាទបសេនទិកោសល ដោយទូលថា ជាព្រះធីតារបស់មហានាមសាក្យៈ ។ ព្រះបាទបសេនទិកោសល ដោយពុំទ្រង់ជ្រាប ក៏ទ្រង់ទទួលយកនាងវាសភខត្តិយា មកអភិសេកជាព្រះអគ្គមហេសី ។ តមក នាងវាសភខត្តិយា បានឧរសជាមួយនឹងព្រះបាទបសេនទិកោសលមួយអង្គ ព្រះនាមវិឌូឌភៈ ។ លុះមានវ័យចម្រើនឡើង វិឌូឌភៈក៏បានសិក្សាសិល្បវិជ្ជាតាមប្រពៃណី ហើយបានទទួលព្រះរាជទានតំណែងជាសេនាបតី ។ សម័យមួយវិឌូឌភៈ មានប្រាថ្នាចង់ទៅសួរសុខទុក្ខព្រះញាតិខាងមាតា ទើបសុំអនុញ្ញាតនាងវាសភខត្តិយាជាមាតា ដើម្បីចេញដំណើរទៅ ។ ដោយដឹងច្បាស់ថា ក្សត្រសាក្យវង្សបានចាត់ទុកវិឌូឌភៈថាជាមនុស្សជាន់ទាប មិនសមគួរនឹងអង្គុយ ឬបរិភោគអាហារជាមួយ ទើបនាងវាសភខត្តិយាបញ្ជូនពត៌មានទៅក្រុងកបិលពស្តុមុនឲ្យក្សត្រសាក្យវង្សបានដឹង ដើម្បីចៀសវាងព្រឹត្តិការណ៍មិនល្អដែលនឹងអាចកើតឡើងក្នុងរឿងនេះ ។ ក្សត្រសាក្យវង្សកាលបើបានពត៌មានដូច្នេះភ្លាម ក៏មានការប្រជុំគ្នាម្តងទៀត ប្រឹក្សាអំពីការប្រុងប្រៀប ធ្វើបដិសណ្ឋារកិច្ចទទួលវិឌូឌភៈដើម្បីការពារកុំឲ្យមានការប៉ះពាល់ដល់កិត្តិយស របស់សាក្យវង្ស ។ នៅទីបំផុតទីប្រជុំក៏យល់ស្របគ្នាថាត្រូវបញ្ជូនក្សត្រសាក្យៈដែលមានអាយុតិចជាងវិឌូឌភៈឲ្យទៅកាន់ជនបទឲ្យអស់ ព្រោះបើនៅក៏ត្រូវតែ

គោរពសំពះវិឌូឌកៈ ដែលជាហេតុឲ្យខូចកិត្តិយស ហើយទុកឲ្យនៅតែក្សត្រសាក្យៈដែលមានអាយុច្រើនជាងវិឌូឌកៈប៉ុណ្ណោះ ។ កាលបើវិឌូឌកៈព្រមទាំងបរិវារធ្វើដំណើរទៅដល់ ក៏ជួបតែពួកក្សត្រសាក្យៈដែលមានវ័យចាស់ជាងខ្លួន ហេតុនោះ វិឌូឌកៈទើបត្រូវសំពះគោរពគេជាដរាបទៅ ដោយគ្មាននរណាមួយសំពះខ្លួនវិញសូម្បីតែម្នាក់ឡើយ ។ លុះចប់ទស្សនកិច្ចហើយ វិឌូឌកៈព្រមទាំងសហការី ក៏ធ្វើដំណើរនិវត្តទៅកាន់រដ្ឋកោសលវិញ ។ នៅពេលដែលវិឌូឌកៈចេញដំណើរនិវត្តបានបន្តិច ពួកសាក្យៈក៏ប្រមូលមនុស្សម្នាឲ្យយកទឹកដោះស្រស់ ទៅលាងក្តារដែលវិឌូឌកៈអង្គុយជាការលាងចង្រៃ ។ ដោយការនឿយហត់ក្នុងការដុសលាង ពួកមនុស្សទាំងនោះខ្លះពោលរអ៊ុរអ៊ូថា វិឌូឌកៈមក នាំឲ្យតែគេលំបាកដោយសារខ្លួន ស្ត្រីខ្លះក៏ជេរពប់រៀបថា វិឌូឌកៈជាកូនស្ត្រីទាសី ។ ជួនពេលនោះសហការីរបស់វិឌូឌកៈម្នាក់ភ្លេចអាវុធត្រឡប់ទៅយកវិញ ក៏បានឃើញហេតុការណ៍ និងបានឮពាក្យពោលផ្សេងៗសព្វទាំងអស់ ។ លុះត្រឡប់មកវិញ សហការីរូបនោះ ក៏ដំណាលរឿងនោះប្រាប់ពួកបរិវារផងគ្នា ទីបំផុតរឿងក៏លាន់ឮទៅដល់វិឌូឌកៈ ដែលជាហេតុឲ្យវិឌូឌកៈកើតសេចក្តីឈឺចាប់យ៉ាងខ្លាំងក្រៃលែងរកពេលរលត់គ្មាន ទើបលាន់វាចាដោយការចងគំនុំថា មិនអីទេរឿងនេះ ទុកមួយអន្លើសិនចុះចាំពេលដែលយើងបានសោយរាជ្យជាស្តេចផែនដី

មានគំណាបយើងនឹងលើកទ័ពទៅសម្លាប់ពួកសាក្យៈឲ្យអស់ដោយយកកាំបិតកាត់យកឈាមបំពង់កលាងក្តារដែលពួកទេះលាងដោយទឹកដោះស្រស់នោះជាការសេងសឹកវិញ ឲ្យទាល់តែបានដូចសេចក្តីប្រាថ្នា ។ ចំណែកខាងព្រះបាទបសេនទិកោសល កាលបើទ្រង់ជ្រាបពត៌មានថា នាងវាសភខត្តិយាជាកូនទាសីដូច្នោះ ក៏ទ្រង់ព្រះពិរោធយ៉ាងខ្លាំង ហើយទ្រង់បញ្ជាឲ្យផ្តាច់គ្រឿងរាជូបភោគផ្សេង ៗ ដែលធ្លាប់ប្រោសប្រទានដល់នាងព្រមទាំងវិឌូឌភៈ ដោយត្រឡប់ប្រោសប្រទានត្រឹមតែគ្រឿងបរិភោគប្រើប្រាស់ប្រភេទសម្រាប់ជាន់មនុស្សជនទាសទាសីប៉ុណ្ណោះ កន្លងពីនោះមកមិនយូរប៉ុន្មានព្រះពុទ្ធជាម្ចាស់ស្តេចយាងទៅកាន់ព្រះបរមរាជវាំង ។ ព្រះបាទបសេនទិកោសល កាលបើស្តេចយាងទៅគាល់និងក្រាបថ្វាយបង្គំព្រះបរមគ្រូរួចស្រេចហើយ ក៏ទ្រង់ក្រាបបង្គំទូលថា ខ្ញុំព្រះអង្គបានបញ្ជូនទូតទៅសុំដណ្តឹងធីតានៃព្រះញាតិរបស់ព្រះអង្គខាងក្រុងកបិលព័ស្តុ មកអភិសេកជាអគ្គមហេសី ដើម្បីឲ្យបានជិតស្និទ្ធនឹងគ្នាឡើង តែព្រះញាតិរបស់ព្រះអង្គត្រឡប់ជាក្លែងបោកបញ្ឆោតឲ្យកូនទាសីមកទូលព្រះបង្គំ, ឥឡូវនេះ ទូលព្រះបង្គំបានផ្តាច់គ្រឿងរាជូបភោគទាំងម្តាយទាំងកូនចេញអស់ហើយ ទុកឲ្យត្រឹមតែគ្រឿងឧបភោគបរិភោគសម្រាប់ជាន់ទាសទាសីប៉ុណ្ណោះ ។ ព្រះ

បរមសាស្ដាបានទ្រង់ត្រាស់តបសម្រួលថា ពួកសាក្យៈធ្វើយ៉ាងនេះជាការ
មិនសមគួរទាល់តែសោះ ពួកសាក្យៈគួរតែថ្វាយធីតាដែលទាំងមានជាតិ
ស្មើគ្នាដល់ព្រះអង្គ ៗ ប៉ុន្តែតាមការពិតនាងវាសភខត្តិយាក៏ជាខត្តិយរាជធីតា
ហើយបានទទួលរាជាភិសេកក្នុងព្រះបរមរាជវាំងទៀតផង, ឯវិឌូឌភៈសោត
ក៏ប្រសូតមកដោយអាស្រ័យព្រះរាជាម្ចាស់ផែនដីដែរ ថ្វាយព្រះពរមហា·
បពិត្រ គោត្តខាងមាតាគ្មានសំខាន់អ្វីទាល់តែសោះ ឯគោត្តខាងបិតានោះ
ទើបសំខាន់ ហើយទ្រង់ត្រាស់សំដែងប្រវត្តិសាស្ត្រស្ដីពីព្រះបាទកដ្ឋវាហ·
នរាជ ដែលជាបុត្ររបស់ស្ត្រីអ្នកទាល់ក្រ រកទទួលទានដោយការកាប់ឧស
លក់ តែក្រោយមក ព្រះរាជាក្រុងពារាណសី ទ្រង់សព្វព្រះរាជហឫទ័យ ក៏
ទ្រង់អភិសេកជាព្រះអគ្គមហេសីឡើង ហើយនាងមានបុត្រមួយព្រះអង្គ
ដែលតមកបានសោយរាជសម្បត្តិ មាននាមថា ព្រះបាទកដ្ឋវាហនរាជ ជា
ម្ចាស់ផែនដីក្រុងពារាណសី បានជាមហាក្សត្រអង្គសំខាន់មួយរហូតមក ៗ
ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ប្រវត្តិរឿងនេះ ជាគ្រឿងបញ្ជាក់ឲ្យ
ឃើញច្បាស់ថា ខាងមាតា សូម្បីជាមនុស្សជាន់ទាបក្រខ្សត់រហូតដល់មាន
ឋានៈជាអ្នកកាប់ឧសលក់ចិញ្ចឹមជីវិតក៏ដោយ ក៏គ្មានការសំខាន់អ្វីដែរ កាល
បើខាងបិតាមានឋានៈខ្ពង់ខ្ពស់ជាម្ចាស់ផែនដីហើយ បុត្រដែលប្រសូតមកក៏

ទើងបានខ្ពង់ខ្ពស់ ដូចព្រះបាទកដ្ឋវាហនរាជ ដែលជាកូនស្រីកាប់ឧសលក់ ហើយសោយរាជ្យជាព្រះមហាក្សត្រដ៏ធំ នៅក្រុងពារាណសីនេះឯង ។ កាលបើទ្រង់ព្រះសណ្ដាប់ ឮព្រះពុទ្ធតម្រាស់នេះចប់ហើយ ព្រះបាទបសេនទិ-កោសល ក៏ទ្រង់មានព្រះហឫទ័យជ្រះថ្លាយល់ស្របតាមក្រសែព្រះពុទ្ធ-តម្រាស់ហើយ ទ្រង់សព្វព្រះហឫទ័យប្រោសព្រះរាជទានគ្រឿងរាជូប-ភោគដល់នាងវាសភខត្តិយា ព្រមទាំងវិឌូឌភៈដូចប្រក្រតីវិញ ។

លុះគ្រាជាខាងក្រោយមក ពេលដែលវិឌូឌភៈបានសោយរាជសម្បត្តិដូចបំណង ក៏រឭកឃើញនូវហេតុការណ៍និងវាចាដែលបានលាន់ចេញទៅដោយចេតនាចងគំនុំទុកនោះ ក៏ទ្រង់លើកទ័ពយ៉ាងធំចេញទៅធ្វើសង្គ្រាមកាប់សម្លាប់ពួកសាក្យៈតាមដែលបានតាំងព្រះទ័យទុក ។ ពេលនោះព្រះសាស្ដា កាលបើទ្រង់ជ្រាបរឿងនេះ ទើងដើម្បីសង្គ្រោះដល់ព្រះញាតិ-វង្សនោះ ទើបពេលថ្ងៃរសៀល ស្ដេចយាងចេញទៅកាន់ព្រំដែននៃក្រុងកបិលពស្ដុ និងរដ្ឋកោសល ហើយទ្រង់ប្រថាប់គង់ក្រោមដើមឈើមួយដើមរង់ចាំវិឌូឌភៈ ។ លុះវិឌូឌភៈលើកទ័ពមកជួបព្រះពុទ្ធជាម្ចាស់ ក៏លើកទ័ពវិលត្រឡប់វិញដោយសេចក្ដីគោរព ។ វិឌូឌភៈបានលើកទ័ពចេញទៅពីរលើកក្រោយទៀតបានជួបព្រះពុទ្ធជាម្ចាស់ ក៏វិលត្រឡប់វិញទាំងពីរលើក ។

លុះលើកទី៤ ព្រះពុទ្ធជាម្ចាស់ដោយទ្រង់ជ្រាបថា ជារឿងនៃកម្មដែលមិនអាចនឹងកែខៃបាន ក៏មិនស្ដេចយាងទៅដូចមុន, វិឌូឌភៈក៏លើកទ័ពចេញទៅបានដូចប្រាថ្នា ហើយកាប់សម្លាប់ពួកសាក្យៈ ដោយមិនទុកសូម្បីតែទារកក្នុងអង្រឹងឡើយ ហើយអារកយកឈាមលាងក្ដារដែលពួកសាក្យៈឲ្យមនុស្សលាងដោយទឹកដោះស្រស់នោះ ជាការសងសឹកវិញ សមដូចបំណង ៗ

រឿងមួយទៀតមានមកក្នុងអដ្ឋកថាមាតង្គជាតក សំដែងអំពីការប្រកាន់វណ្ណៈជាហេតុឲ្យខូចប្រយោជន៍យ៉ាងធំ ដែលមានសេចក្ដីដូចតទៅនេះ

មានបុរសម្នាក់ឈ្មោះមាតង្គៈ ជាមនុស្សមានរូបរាងអាក្រក់មិនគួរជាទីពិតពិលរមិលមើលនៃជនដទៃ ហើយអាស្រ័យនៅទីងខ្ទមដែលប្រក់ដោយស្បែកសត្វនៅក្រៅទីក្រុង ៗ បុរសនេះកើតក្នុងត្រកូលចណ្ឌាលគឺត្រកូលដែលមាតាបិតា ឬបុរសជាមនុស្សផ្សេងវណ្ណៈគ្នា ដូចពោលខាងដើម ៗ ដោយហេតុកើតក្នុងត្រកូលចណ្ឌាលដូច្នេះ ទើបបុរសមាតង្គៈប្រកបការងារចិញ្ចឹមជីវិតអ្វីពុំបាន បានត្រឹមតែសុំទានគេទទួលទានប៉ុណ្ណោះ ៗ ថ្ងៃមួយមានការប្រកាសនក្ខត្តឫក្ស គឺជាពិធីបុណ្យធំហោឡារិក មានការជប់លៀងផឹកសុកសប្បាយរីករាយទូទៅ ដែលតាមទំនៀមអ្នកស្រុក គេ

តែងចំណាយពេលវេលាទៅលេងពិធីនេះ ពួកអ្នកដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ក៏ប្រុងប្រៀបអាហារភោជនផងស្រាមេរ័យ ដឹកដោយយានជំនិះទៅជប់លៀងគ្នាតាមសេចក្តីគាប់ចិត្ត ។ ក្នុងឱកាសនោះ មានកូនស្រីសេដ្ឋីម្នាក់មានវណ្ណៈជាព្រាហ្មណ៍មហាសាល ឈ្មោះនាងទិដ្ឋមង្គលិកា អាយុប្រមាណ១៦ឆ្នាំ ជាស្រីមានរូបឆោមលោមពណ៌ល្អក្រៃលែង ។ កូនស្រីសេដ្ឋីនេះបានបញ្ជាឲ្យប្រុងប្រៀបគ្រឿងបរិភោគផ្សេងៗ ដាក់រទេះដើម្បីនឹងចេញទៅលេងកំសាន្តសប្បាយក្នុងពិធីនក្ខត្តឫក្សនោះ ឯនាងជិះរទេះដែលទឹមដោយសេះសសុទ្ធ ចេញដំណើរទៅកាន់ទីក្រុងដោយមានបរិវារហែហមហោមរោមទៅផង និងមានមនុស្សមួយក្រុម សម្រាប់ដេញពួកមនុស្សជាន់ទាបកុំឲ្យចូលទៅជិតកន្លែងដែលនាងទៅ ។ ឯបុរសឈ្មោះមាតង្គៈដែលជាមនុស្សចណ្ឌាល តាមធម្មតា ពេលដើរទៅមកតែងមានឈើសម្រាប់គោះជាសញ្ញាឲ្យមនុស្សដឹងថាខ្លួនជាអ្នកសុំទាន អ្នកដែលមានមេត្តាចិត្ត ក៏នឹងឲ្យទានដល់ខ្លួនផង និងជាការប្រកាសថាខ្លួនជាមនុស្សចណ្ឌាលមកហើយ អ្នកដែលមានសេចក្តីប្រកាន់តឹងរ៉ឹងមិនប៉ះពាល់ចូលជិតមនុស្សចណ្ឌាល ក៏នឹងបានចៀសចេញឲ្យឆ្ងាយទៅ ។ ខណៈដែលបុរសមាតង្គៈកំពុងគោះឈើប៉ុកៗដើរទៅនោះ ក៏ទទួលនឹងក្បួនរថដែលកូនស្រីសេដ្ឋីព្រមទាំងក្នាក់

ការសម្រាប់ដេញមនុស្សជាន់ទាបក៏មកដល់ដែរ ហើយនាងកូនស្រីសេដ្ឋី ក្រឡេកទៅឃើញមាតង្គៈ ក៏សួរគេថា ចុះនរណានោះ? កាលបើបានឮថា មនុស្សនោះជាមនុស្សចណ្ឌាល ទាំងរូបរាងក៏អាក្រក់គួរខ្ពើមឆ្អើមផង នាងជាស្ត្រីប្រកាន់តឹងរឹងក្នុងរឿងនេះផង គឺប្រកាន់ថា កាលបើជួបប្រទះឃើញ មនុស្សអាក្រក់មិនជាទីគាប់ចិត្តដូច្នេះ នឹងកើតសេចក្ដីចង្រៃអពមង្គលរកសេចក្ដីចម្រើនលូតលាស់គ្មាន នោះនាងក៏សម្រេចចិត្តលែងទៅលេងក្នុងពិធីបុណ្យនក្ខត្តឫក្ស ហើយបញ្ជាជាបន្ទាន់ឲ្យក្បួនរថហែនាងវិលត្រឡប់ទៅទីលំនៅនាងវិញ ថែមទាំងទាររកទឹកអប់មកលាងភ្នែកជាប្រញាប់ដើម្បីឲ្យជ្រះចង្រៃ ៗ ការដែលកូនស្រីសេដ្ឋីវិលត្រឡប់មកផ្ទះវិញនេះជាហេតុឲ្យមនុស្សជាច្រើនមិនសប្បាយចិត្ត ដ្បិតខុសបំណង ព្រោះខ្លួននឹងបានទៅលេងកំសាន្តបរិភោគអាហារមានរសឆ្ងាញ់ពិសាផឹកសុរាមេរ័យសប្បាយរីករាយមិនចាំបាច់អស់លុយកាក់ ក៏ដោយអាស្រ័យកូនស្រីសេដ្ឋីជាអ្នកចំណាយប្រាក់ជប់លៀង កាលបើនាងវិលត្រឡប់ទៅផ្ទះវិញដូច្នេះ ក៏ហាក់ដូចជាពិធីបុណ្យនក្ខត្តឫក្សគ្មានន័យអ្វីសម្រាប់ពួកខ្លួនទាល់តែសោះគឺថាបើនឹងទៅដោយមិនមានកូនស្រីសេដ្ឋីនោះទៅផង ក៏គ្មានសប្បាយអ្វីឡើយ ព្រោះគ្មានអ្នកធានាជប់លៀងៗ ហេតុនេះ ពួកមនុស្សទាំងនោះ ទើបមានសេចក្ដីក្រោធខឹងនឹង

បុរសមាតង្គៈជាខ្លាំងនាំគ្នាវាយដំមាតង្គៈយកដុំថ្មចោលរហូតដល់សន្លប់បាត់ស្មារតី ដោយនឹកស្មានថាស្លាប់ហើយ ក៏នាំគ្នាអូសយកទៅឯគំនរសម្រាម ហើយយកសម្រាមគ្របចោលនៅទីនោះទៅ ។ មាតង្គៈបុរសកម្សត់ លុះភ្ញាក់ខ្លួនពីសន្លប់ឡើង ក៏ខំប្រឹងក្រោក រលាស់ដៃជើងឲ្យស្វាងហើយ ខំរួបរួមសតិស្មារតីនឹករកហេតុការណ៍ដែលកើតមានឡើង ក៏រលឹកបានថា ខ្លួនបានត្រូវគេព្រួតវាយយ៉ាងដំណំព្រោះតែទៅដើរបង្ហាញខ្លួនឲ្យកូនស្រីសេដ្ឋីឃើញមុខ ។ ឯមាតង្គៈបុរសអភព្វ ជាមនុស្សចណ្ឌាល មានរូបអាក្រក់ដើរសុំទានគេចិញ្ចឹមជីវិតក៏ពិតមែន តែខាងផ្លូវគំនិតវិញ បុរសទុគ៌តនេះក៏មានហេតុផល និងឧត្តមគតិក្នុងការដោះស្រាយបញ្ហាជាបន្ទាន់មិនចាញ់មនុស្សដែលគេសន្មតថា មានត្រកូលខ្ពង់ខ្ពស់ឡើយ ។ ហេតុនោះ ទើបបុរសចណ្ឌាលនេះសម្រេចចិត្តថា ខ្លួននឹងចាត់ការក្នុងរឿងនេះឲ្យបានសម្រេចផលសមនឹងការដែលពួកបរិវារនៃកូនស្រីសេដ្ឋី ព្រួតវាយប្រទូសរ៉ាយរាងកាយខ្លួនដោយគ្មានហេតុផល ហើយដើម្បីឲ្យមនុស្សច្រើនគ្នាបានដឹងច្បាស់នូវហេតុផលនោះក៏ដើរសួរគេឯងដែលនៅជិតៗថា ទ្វារក្រុងនេះគេធ្វើសម្រាប់តែមនុស្សក្នុងវណ្ណៈព្រាហ្មណ៍ប៉ុណ្ណោះទេឬ ឬក៏គេធ្វើសម្រាប់មនុស្សទូទៅ? ពួកមនុស្សទាំងនោះ ក៏តបដោយចម្លើយស្របគ្នាតែមួយថា គេធ្វើ

សម្រាប់មនុស្សទូទៅ ជនកើតក្នុងវណ្ណៈណា ក៏បញ្ចូលបានទាំងអស់ ៗ ដោយរកងដល់ចម្ងាយនេះ មាតង្គៈក៏ដើរប្រកាសជាឧម្ពារិកថា ខ្ញុំដើរសុំទានតាមទ្វារក្រុងដែលគេធ្វើសម្រាប់មនុស្សទូទៅដើរចេញចូល ស្រាប់តែត្រូវគេកាយប្រហារយ៉ាងខ្លាំងព្រោះហេតុគ្រាន់តែកូនស្រីសេដ្ឋីក្រឡេកមើលឃើញខ្ញុំហើយមិនពេញចិត្តប៉ុណ្ណោះ ក្នុងករណីនេះ សូមមហាជនជ្រាបថា ខ្ញុំនឹងទៅដេកពាំងនៅមាត់ច្រកផ្ទះសេដ្ឋីដែលជាបិតារបស់នាងនោះ ដើម្បីជាការតវ៉ា បើមិនបានកូនស្រីសេដ្ឋីនោះមកធ្វើជាភរិយាទេ ខ្ញុំនឹងមិនក្រោកចេញពីទីនោះជាដាច់ខាត ៗ ប្រកាសដូច្នេះហើយ មាតង្គៈក៏ទៅដេកនៅមាត់ច្រកផ្ទះសេដ្ឋីនោះ ៗ បានជាមាតង្គៈសម្រេចចិត្តយ៉ាងនេះ ក៏ព្រោះតាមប្រពៃណីឥណ្ឌា គេប្រកាន់ថា កាលបើមានមនុស្សចណ្ឌាលមកតាំងចិត្តអត់បាយអត់ទឹកដេកស្លាប់នៅមាត់ច្រកនៃផ្ទះអ្នកណា មនុស្សដែលនៅផ្ទះជុំវិញផ្ទះអ្នកនោះ ដោយរាប់ពីផ្ទះនោះទៅ ៧ខ្នងផ្ទះនឹងត្រូវក្លាយទៅជាមនុស្សចណ្ឌាលទាំងអស់ ៗ ដូច្នេះ ពេលដែលមាតង្គៈទៅដេកនៅមាត់ច្រកផ្ទះសេដ្ឋីយ៉ាងនេះ ទើបពួកមនុស្សដែលនៅក្នុងបរិវេណនោះគ្រប់ទិសរាប់តាំងពីផ្ទះកណ្ដាល គឺផ្ទះសេដ្ឋីនោះទៅ៧ផ្ទះ កើតសេចក្ដីភិតភ័យជ្រួលច្របល់ពេញទាំងភូមិ ជាពិសេសគឺសេដ្ឋីជាអ្នកដើមរឿង ត្រូវទទួលសេចក្ដី

មួយម៉ោកក្តៅក្រហាយជាងគេបំផុត ៗ ដើម្បីឲ្យមាតង្គៈក្រោកចេញពីប្រកផ្ទះ
របស់ខ្លួនទៅ មុនដំបូង សេដ្ឋីក៏សម្រេចចិត្តឲ្យមនុស្សរបស់ខ្លួនយកប្រាក់
មួយកាកណិកទៅឲ្យមាតង្គៈ ហើយបញ្ជាឲ្យប្រាប់ថានឹងឲ្យប្រេងសម្រាប់
លាបតែខ្លួនប្រាណទៀតផង ឲ្យតែក្រោកចេញពីប្រកផ្ទះទៅ តែមាតង្គៈមិន
ព្រមក្រោក ( តាមដែលមានចែងក្នុងគម្ពីរខាងព្រះពុទ្ធសាសនា ជនជាតិ
ឥណ្ឌា កាលបើមានភ្ញៀវធ្វើដំណើរមកពីទីឆ្ងាយ អ្នកម្ចាស់ផ្ទះនិយមយក
ប្រេងដែលហៅថា សប្បិ មកឲ្យលាបតែខ្លួននិងជើងដៃ ជាទំនៀមនៃការ
ទទួលភ្ញៀវរបស់គេ សូម្បីអ្នកបួសក្នុងព្រះពុទ្ធសាសនាក៏និយមប្រើបែបនេះ
ដែរ ) ។ បន្ទាប់មក សេដ្ឋីក៏បញ្ជាថែមប្រាក់ឲ្យជាពីរកាកណិក មាតង្គៈ
ក៏មិនព្រមក្រោក ប្តេជ្ញាយ៉ាងដាច់ខាតតែម្យ៉ាងថា លុះត្រាតែបានកូនស្រី
សេដ្ឋីជាភរិយាទើបក្រោកចេញ ៗ សេដ្ឋីក៏បញ្ជាឲ្យថែមប្រាក់ថែមទៀតជាលំ
ដាប់តាំងពីបីកាកណិកដល់មួយមាសក កន្លះកហាបណៈ មួយកហាបណៈ
ដល់១០០កហាបណៈ (ប្រមាណ៩០០រៀល) រាត្រីមួយកន្លងផុតទៅ
មាតង្គៈក៏នៅរក្សាសេចក្តីតាំងចិត្តខាងដើម ទុកយ៉ាងម៉ឺងម៉ាត់មិនព្រមក្រោក
ចេញ លុះព្រឹកឡើង ភរិយាសេដ្ឋី ក៏ទៅអង្វរលួងលោមសូមទោសចំពោះ
មាតង្គៈសុំថែមប្រាក់ឲ្យទៀតជា ១.០០០កហាបណៈ ( ប្រមាណ៩០០០
រៀល) ក៏មាតង្គៈមិនព្រម ថែមឡើងទៀតជា ១០០.០០០០ កហាបណៈ

(ប្រមាណ ៩០០.០០០រៀល) តែក៏មិនបានលទ្ធផលអ្វីសោះ មាតង្គៈ នៅដេកព្រងើយដូចដែល ឥតអើពើមិនប្រាក់ទាល់តែសោះ រហូតដល់កាលកន្លងទៅ៤ថ្ងៃ ។ ខណៈនោះ ពួកមនុស្សជិតខាងក៏ទៅចោមរោមមើលនិងនិយាយតៗគ្នា ក្លាយទៅជាពត៌មានឮសុះសាយព្រមទាំងជារឿងអាយុជីវិតនៃមនុស្សជាច្រើនគ្រួសារ ដែលនៅក្នុងរស្មីពាខ្ទងផ្ទះពីផ្ទះសេដ្ឋីនោះ ព្រោះបើមាតង្គៈស្លាប់ទៅ មនុស្សទាំងនោះ ក៏នឹងក្លាយទៅជាមនុស្សបណ្តាលទាំងអស់ ដែលជាការខូចបង់ប្រយោជន៍ដ៏ធំបំផុតក្នុងជីវិត ព្រោះជាការវិនាសសាបសូន្យនៃវង្សត្រកូលរបស់គេ ។ បណ្តាមនុស្សដែលទៅចោមរោមមើលនោះ ពួកខ្លះក៏មានចិត្តអាណិតមាតង្គៈ ទុនខ្សឹបប្រាប់ថា អ្នកខ្លះ គេព្យាយាមអត់ទ្រាំជាច្រើនឆ្នាំ ក៏មិនបានសម្រេចដូចសេចក្តីប្រាថ្នាក្នុងរឿងនេះ អ្នកឯងអត់ទ្រាំពីរបីថ្ងៃទៀតទៅ មុខជាបានកូនស្រីសេដ្ឋីធ្វើប្រពន្ធមិនខាន ។ លុះកាលកន្លងទៅ៧ថ្ងៃ ពលរដ្ឋដែលនៅផ្ទះជិតផ្ទះសេដ្ឋី ក្នុងរង្វង់ដែលត្រូវទទួលសេចក្តីចង្រៃអពមង្គលនៅពេលដែលមាតង្គៈស្លាប់ ហើយដែលសុទ្ធសឹងតែជាអ្នកកើតនៅក្នុងត្រកូលព្រាហ្មណ៍ ក៏នាំគ្នាទៅធ្វើបាតុកម្មឡោមព័ទ្ធគេហដ្ឋានរបស់ព្រាហ្មណ៍មហាសាល ធ្វើអន្តរាគមន៍បង្ខំសេដ្ឋីឲ្យព្រមលើកកូនស្រីសំឡាញ់ឲ្យទៅមាតង្គៈធ្វើជាភរិយា ព្រោះការដែលសេដ្ឋីរឹងត្អឹងមិនព្រមចុះចាញ់មាតង្គៈនេះ ជាហេតុឲ្យពួកខ្លួន

ដល់នូវមហាវិបត្តិជាពិតប្រាកដ ហើយសេដ្ឋីដែលជាអ្នកនិយមប្រពៃណីបែបនេះ ក៏ជឿជាទីផុតទៅជាយ៉ាងនោះដែរ ។ កាលបើដូច្នេះ សេដ្ឋីក៏ព្រួយចិត្តពាល់គំនិតគិតអ្វីពុំយល់ គឺផ្ទៃផ្ទុងស្ទើរតែដាច់ខ្យល់ស្លាប់ នឹងអង្វរលួងលោមឲ្យទ្រព្យសម្បត្តិច្រើនយ៉ាងណា ក៏មាតង្គៈមិនរវល់នឹងស្តាប់ចាប់អារម្មណ៍ពាល់តែសោះ បើនឹងបណ្តោយលែងរវល់ ក៏ត្រូវអ្នកផ្ទះជិតខាងគេទោមទាមតប៉ាយ៉ាងតឹងរ៉ឹង ទាំងខ្លួនឯងសោតក៏ត្រូវទទួលផលអាក្រក់តាមការនិយមដែរ ប្រសិនបើមាតង្គៈស្លាប់នៅទីនោះ ។ ហេតុនោះនៅទីបំផុត សេដ្ឋីក៏ចាំបាច់ត្រូវបង្ខំខ្លួនឲ្យសម្រេចចិត្តលើកធីតាសំឡាញ់ឲ្យទៅមាតង្គៈ ព្រមទាំងចែកទ្រព្យសម្បត្តិ ហើយឲ្យដើរចេញពីផ្ទះទៅ ។ មាតង្គៈបានធីតាសេដ្ឋីជាភរិយាហើយ ក៏ក្រោកឡើងនាំគ្នាចេញចាកផ្ទះសេដ្ឋីទៅតាមយថាកម្មរបស់ខ្លួនទៅ ។

រឿងដូចបានពណ៌នាមកទាំងអស់នេះ បញ្ជាក់ឲ្យឃើញច្បាស់នូវផលអាក្រក់ដែលកើតអំពីការប្រកាន់ហួសហេតុ គឺដោយអាស្រ័យការប្រកាន់យ៉ាងតឹងរ៉ឹង ព្រោះការនិយមដែលគេអាចលើកលែងពេលបានដោយគ្មានវិបត្តិអ្វីបន្តិចសោះនោះឯង ជាហេតុបណ្តាលឲ្យកើតសេចក្តីវិនាសអន្តរាយដល់ជីវិតនៃពួកសាក្យៈទាំងវង្ស និងជាហេតុឲ្យសេដ្ឋីបាត់បង់កិត្តិយសអស់ទាំងកូនស្រីនិងទ្រព្យសម្បត្តិ បានទទួលបរាជ័យយ៉ាងអាម៉ាសមុខ ។

នៅក្នុងគម្ពីរផ្សេងៗ ខាងព្រះពុទ្ធសាសនា មានគោលធម៌ជាច្រើន ដែលមានដំណើរ ជួយបំបាត់ការប្រកាន់វណ្ណៈ ដែលគួរលើកយកមកបញ្ជាក់គឺ

## ក្នុងព្រះសុត្តន្តបិដក

១. នៅក្នុងសុន្ទរិកសូត្រ សំយុត្តនិកាយ មានសេចក្តីថា ព្រាហ្មណ៍ម្នាក់ឈ្មោះសុន្ទរិកភារទ្វាជៈ ទូលសួរព្រះសម្មាសម្ពុទ្ធជាម្ចាស់ថា ព្រះអង្គមានជាតិជាអ្វី ? ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា កុំសួរពីរឿងជាតិធ្វើអ្វី ចូរសួរពីការប្រព្រឹត្តវិញប្រសើរជាង ហើយទ្រង់ត្រាស់សំដែងគោលធម៌និងហេតុផលថា " ភ្លើងរមែងកើតអំពីឈើបាន អ្នកមានសេចក្តីចេះដឹងសូម្បីកើតក្នុងត្រកូលទន់ទាប តែជាអ្នកមានសេចក្តីព្យាយាម ជាអ្នកការពារសេចក្តីអាក្រក់ដោយសេចក្តីអៀនខ្មាស ជាអ្នកមានសច្ចៈ មានខ្លួនហាត់ពត់ហើយ ក៏ទៅជាមនុស្សអាជានេយ្យបានដូចគ្នា " ។

២. ព្រះបរមសាស្តាទ្រង់សន្ទនាជាមួយព្រាហ្មណ៍ឈ្មោះវាសេដ្ឋៈនិងព្រាហ្មណ៍ឈ្មោះភារទ្វាជៈ ក្នុងអគ្គញ្ញសូត្រ ទីឃនិកាយ បាថិកវគ្គ ទ្រង់ត្រាស់បង្អុលបញ្ជាក់ឲ្យឃើញនូវសេចក្តីពិតថា ពួកព្រាហ្មណ៍បានលើកតម្កើងតែវណ្ណៈរបស់ខ្លួនមួយប៉ុណ្ណោះថាជាវណ្ណៈស ពួកដទៃជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍ជាអ្នកបរិសុទ្ធ ពួកដទៃជាអ្នកមិនបរិសុទ្ធ ។ ការដែលពួក

ព្រាហ្មណ៍ពោលអួតអាងដូច្នេះនេះ ក៏ព្រោះពួកនេះមិនបានរឭកដល់រឿងចាស់, តាមការពិត ការ ដែលពួកព្រាហ្មណ៍ថាពួកខ្លួនកើតពីមាត់ព្រះព្រហ្មជាទាយាទរបស់ព្រះព្រហ្មនោះ ក៏គ្មានសេចក្តីពិតសោះ ព្រោះព្រាហ្មណ៍គ្រប់ៗគ្នាសុទ្ធតែកើតមកពីមាតាជាព្រាហ្មណី ដែលត្រូវមានគភ៌ហើយប្រសូតបានគភ៌ ត្រូវទទួលទានទឹកដោះដូចគេដែរ ពុំឃើញមានអ្វីពិសេសជាងមនុស្សពួកដទៃឡើយ ។ មនុស្សគ្រប់គ្នា ទោះកើតក្នុងវណ្ណៈណាក៏ដោយ ក៏អាចប្រកបផ្លូវនៃអកុសល គឺទុច្ចរិតដោយកាយវាចាចិត្តបានដូចគ្នា អាចចៀសវាងចាកផ្លូវនៃអកុសល (ប្រព្រឹត្ត) សុចរិតដោយកាយវាចាចិត្តបានដូចគ្នាទាំងអស់ ។ តពីនោះព្រះអង្គទ្រង់ត្រាស់សំដែងរំឭករឿងដើម ដែលជាមូលហេតុនៃការបែងចែកគ្នាជាជាន់ថ្នាក់ថា ដំបូងបំផុតគឺជាការចែកពួកគ្នាតាមមុខងារដែលត្រូវធ្វើ តែតមកខាងក្រោយ ត្រឡប់ជាយល់ខុស ទើបកើតទៅជាការប្រកាន់បក្សពួក ហើយមើលងាយសង្កត់សង្កិនគ្នាទៅវិញ ហើយទ្រង់ត្រាស់សរុបសេចក្តីថា " ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ ធម៌ជារបស់ប្រសើរបំផុតក្នុងពួកមនុស្ស ទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគត " ។

៣. ក្នុងសីលវីមំសជាតកបញ្ចកនិបាត មានសំដែងប្រៀបធៀបរវាងសីលនិងជាតិគោត្រវណ្ណៈ ដោយលើកយកភាសិតរបស់ព្រាហ្មណ៍ម្នាក់

មកសំដែងបញ្ជាក់ថា ជាតិនិងវណ្ណៈ ជារបស់សួន្យទទេ សីលទេតើ ជារបស់ខ្ពស់បំផុត បើមិនមានសីលហើយ សុតៈនឹងមានប្រយោជន៍អ្វី ៗ ព្រះវេទក្តី ជាតិត្រកូលក្តី បក្សពួកក្តី មិនមែនមានប្រយោជន៍ដើម្បីសម្បរាយកភពទេ សីលដែលបរិសុទ្ធរបស់ខ្លួនទេតើ ដែលនាំសេចក្តីសុខគង់សម្បរាយកភពមកឲ្យ ។

៤- ព្រះពុទ្ធភាសិតមួយអន្លើ ទ្រង់សំដែងទុកគង់ កណ្ណកត្ថលសូត្រ មជ្ឈិមនិកាយ ដកស្រង់សេចក្តីបានថា វណ្ណៈទាំង ៤ កាលបើមានគុណធម៌ហើយក៏ឈ្មោះថាស្មើគ្នា ប្រៀបបានថាបើនឹងនាំយកឈើពីងគុំ ដើមស្វាយ ដើមល្វា ដែលស្ងួតមកដុតភ្លើងហើយ ផលគឺអណ្តាតភ្លើង ពណ៌សម្បុរនៃភ្លើង និងពន្លឺនៃភ្លើង គ្មានប្លែកគ្នាពាល់តែសោះ ។

គង់សុបុព្វណ្ហសូត្រ ព្រះបរមសាស្តា ទ្រង់ត្រាស់សំដែងបញ្ជាក់អំពីរឿងបុក្សពោរសិរីមង្គលនេះយកសេចក្តីឲ្យខ្លីបានថា មនុស្សសត្វប្រព្រឹត្តល្អដោយកាយវាចាចិត្តនៅពេលណា ពេលនោះ(ទោះជាយប់ថ្ងៃព្រឹកល្ងាចក៏ដោយ) ឈ្មោះថាជាពេលល្អបុក្សពោរល្អ មង្គលល្អរបស់មនុស្សសត្វនោះៗ ជាការពិតណាស់សិរីមង្គលគឺជាឈ្មោះនៃសេចក្តីសុខសេចក្តីចម្រើន, ការធ្វើអ្វីទៅហើយបានទទួលផលល្អ បានសម្រេចសមដូចសេចក្តីប្រាថ្នាបានសេចក្តីចម្រើនល្អតលាស់ និងការដែលបានជួបប្រទះតែនឹងសេចក្តីសុខ

កាយសប្បាយចិត្តប្រាសចាកទុក្ខភ័យ មានគេគោរពរាប់អានបូជា នេះឯង គឺជាសុភមង្គលសិរីសួស្តី ៗ មនុស្សជាច្រើនប្រកាន់ថា ពេលនោះ ៗ ជាពេលល្អ ធ្វើកិច្ចការនៅថ្ងៃនោះខែនោះនឹងបានសម្រេចផល បានសេចក្តីសុខសេចក្តីចម្រើន ៗ ប្រសិនបើមនុស្សម្នាក់ជាអ្នកមានវណ្ណៈខ្ពស់ ចាំងរើសពេលវេលាបានជួបចិត្តហើយថាជាថ្ងៃល្អ ក៏ចេញទៅធ្វើអំពើអាក្រក់ មានលួចទ្រព្យគេ ឬក៏ប្រព្រឹត្តខុសក្នុងកាមជាដើមនៅថ្ងៃនោះ ហើយត្រូវគេចាប់យកទៅផ្តន្ទាទោសដាក់គុកប្រវាក់ផាក់ពិន័យតាមច្បាប់ បានទទួលសេចក្តីទុក្ខក្តៅក្រហាយវិនាសអន្តរាយអស់ទ្រព្យសម្បត្តិ ត្រូវគេតិះដៀលខូចកិត្តិយសឈ្មោះសំឡេង ៗ បើយ៉ាងនេះតើនឹងឈ្មោះថាជាមង្គលបានដែរឬទេ ពេលវេលានិងវណ្ណៈនោះអាចជួយមិនឲ្យមនុស្សនោះបានសេចក្តីទុក្ខក្តៅក្រហាយ ជួយការពារកិត្តិយសបានដែរឬទេ? ៗ តាមការពិតវណ្ណៈនិងថ្ងៃខែនោះគ្មានជួយអ្វីបានទាល់តែសោះ អ្នកនោះត្រូវបានទទួលសេចក្តីទុក្ខក្តៅក្រហាយ អស់ទ្រព្យសម្បត្តិ ត្រូវគេតិះដៀលអាប់កិត្តិយសខូចឈ្មោះសំឡេង រកសិរីមង្គលគ្មានសោះឡើយ ៗ ផ្ទុយទៅវិញ មនុស្សដែលប្រព្រឹត្តធ្វើតែអំពើល្អដោយកាយវាចាចិត្ត មិនលួចទ្រព្យគេ មិនប្រព្រឹត្តខុសក្នុងកាម ប្រកបកិច្ចការដោយសុចរិត តាមមុខងារគ្រប់ពេលវេលា អ្នកនោះសូម្បីទៅប៉ះពាល់ ឬនៅរួមជាមួយមនុស្សអ្នកមានវណ្ណៈទន់

ទាប ឬជាអ្នកមានវណ្ណៈទាបដោយខ្លួនឯងក៏ដោយ ក៏រមែងផុតអំពីការចាប់ចងផ្តន្ទាទោសដាក់គុកប្រវ៉ក់ ផុតពីការតិះដៀលនៃអ្នកដទៃ គ្មានសេចក្តីទុក្ខក្តៅក្រហាយ មានតែសេចក្តីសុខសេចក្តីសប្បាយរីករាយចិត្ត ទ្រព្យសម្បត្តិក៏មិនបានខូចបង់ មានតែបម្រើនឡើង ទៅកន្លែងណា នៅពេលណាថ្ងៃណា ក៏មានតែគេស្រឡាញ់គេគោរពរាប់អាន នេះឯងគឺជាសុភមង្គលសិរីសួស្តីរបស់អ្នកនោះ ។ ដូច្នេះ មង្គលក្តី អពមង្គលឧបទ្រពចង្រៃក្តី កើតមកពីមនុស្សធ្វើឡើងដោយខ្លួនឯងទេ មិនមែនកើតព្រោះពេលវេលា ឬព្រោះការប្រកាន់មិនប៉ះពាល់ ឬប៉ះពាល់មនុស្សជាន់ទាបក្រខ្សត់អត់ឃ្លានមានវណ្ណៈទាបនោះឡើយ ។

ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ទ្រង់បានតស៊ូចំពោះទិដ្ឋិមានខ្លះ ក្នុងរឿងការប្រកាន់វណ្ណៈ នៃជនជាតិឥណ្ឌាសម័យបុរាណយ៉ាងម៉ឺងម៉ាត់ ដោយទ្រង់បានព្យាយាមពន្យល់ឲ្យមនុស្ស ឃើញច្បាស់នូវសេចក្តីសំខាន់ នៃការប្រព្រឹត្តបដិបត្តិតាមសីលធម៌ ថាមានតម្លៃនិងគុណប្រយោជន៍ សំខាន់ ៗ ក្រៃលែងជាងការដែលគាត់ប្រទាំ ទៅប្រកាន់វណ្ណៈប្រកាន់ជាតិត្រកូល ។ ក្នុងរឿងនេះ ព្រះបរមលោកនាថមិនមែនគ្រាន់តែ ទ្រង់សំដែងត្រឹមតែទ្រឹស្តីប៉ុណ្ណោះទេ ជាពិសេសព្រះអង្គទ្រង់បានអនុវត្តដោយផ្ទាល់ព្រះអង្គដែលជាគម្រូ មានជាប់រហូតមកដល់សម័យបច្ចុប្បន្ននេះទៀតផង គឺជន

ណាក៏ដោយ មិនថាអាក្រក់ល្អក្រមាន ឬចេញមកពីជាតិត្រកូលវណ្ណៈខ្ពស់ទាបណាទេ កាលៈបើបានចូលមកបួសក្នុងព្រះពុទ្ធសាសនាហើយ ក៏មានឋានៈជាភិក្ខុដូចគ្នាទាំងអស់ ឋានៈសក្តិស្មើគ្នា អាចចូលរួមក្នុងកិច្ចការសង្ឃគ្រប់បែបយ៉ាងបាន មានឧបសម្បទកម្មជាដើម មានសិទ្ធិអាចបញ្ចេញយោបល់ជំទាស់ ឬគាំទ្រកិច្ចការនោះៗបាន ឥតមានការប្រកាន់ឬហាមឃាត់ឡើយ ។ ព្រះសព្វញ្ញុពុទ្ធ ព្រះអង្គមានព្រះជាតិជាក្សត្រឧកកោសុជាតិ ដែលជាវណ្ណៈដ៏ខ្ពស់បំផុត ទ្រង់ជាមកុដរាជកុមារដែលត្រូវបានសោយរាជ្យជាស្តេចចក្រពត្តិ ហើយទ្រង់លះបង់ការប្រកាន់គ្រប់យ៉ាង ទៅនៅរួមប្រទ្បុកប្រទ្បាំជាមួយពួកភិក្ខុ ដែលចេញពីត្រកូលនិងវណ្ណៈផ្សេងៗ ទាំងទាបទាំងខ្ពស់មកបួស ក៏មិនឃើញមានសេចក្តីបង្វែរឧបទ្រពឯណាកើតមានដល់ព្រះអង្គ ឬដល់ពួកភិក្ខុទាំងនោះសោះ ។

រឿងពិតមាននៅក្នុងបច្ចុប្បន្នដែលអាចពិសោធបាន ហើយដែលគួរលើកយកមកជាភស្តុតាងដ៏ជាក់ស្តែងក្នុងករណីនេះគឺ :

អង្គសម្តេចព្រះនរោត្តម-សីហនុ ព្រះឧបយុវរាជ ដែលជាអង្គព្រះប្រមុខរដ្ឋខ្មែរ ព្រះអង្គទ្រង់មានព្រះជាតិជាក្សត្រឧកកោសុជាតិ គឺជាវណ្ណៈខ្ពស់បំផុតក្នុងបណ្តាវណ្ណៈទាំង ៤ ហើយទ្រង់ធ្លាប់សោយរាជសម្បត្តិ ជាម្ចាស់ផែនដីថែមទៀតផង ។ នៅពេលស្តេចយាងទៅក្នុងពិធីបុណ្យផ្សេងៗ

មានពិធីសម្ពោធសមិទ្ធិជាដើម សម្ដេចព្រះអគ្គមគ្គុទ្ទេសជាតិខ្មែរ តែងទ្រង់សព្វព្រះរាជហឫទ័យ យកព្រះហស្ដចាប់អោប បប្រោសអង្អែលប្រជាពលរដ្ឋជាកូនចៅព្រះអង្គគ្រប់ជាន់ថ្នាក់ មិនរើសថាក្មេងចាស់ស្រីប្រុសអ្នកក្រល្អក្រមានឡើយ, បើមនុស្សណាដែលទ្រត់ខ្សោយខ្វះខាត មានសម្លៀកបំពាក់ដាច់ដាចមិនសមរម្យ ក្រដាក់ខ្លួនទៅជាអ្នកបម្រើគេ ឬដើរសុំទានគេទទួលទានផងនោះ ព្រះអង្គរឹងរឹតតែទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រណីបប្រោសអង្អែល និងទ្រង់ជួយសង្គ្រោះ ជាពិសេស ជាងធម្មតាទៅទៀត ៗ ក៏ប៉ុន្តែសូម្បីយ៉ាងនេះក៏ពុំដែលឃើញមានសេចក្ដីចង្រៃអពមង្គលកើតមានឡើង ដល់ព្រះអង្គដល់មួយណាសោះ, ទ្រង់អោបរឹតជិតស្និទ្ធនឹងប្រជាពលរដ្ឋណាស់ ព្រះអង្គក៏រឹតតែទ្រង់ចម្រើន ដោយព្រះបវរសួស្ដីសិរីមង្គល មានព្រះកិត្តិនាមពីរោះខ្ទរខ្ទាយខ្លាំងឡើងថែមទៀត ៗ តាំងនេះ មកអំពីក្នុងលោកនេះ ពុំឃើញមានអ្នកដឹកនាំប្រទេសណាដែលចាប់អារម្មណ៍ចំពោះរាស្ត្រក្រីក្រ រហូតដល់ស្រឡាញ់អោបរឹតស្និទ្ធស្នាល ធ្វើការជាមួយដូចេះទេ, ហេតុនោះ ការដែលព្រះអង្គទ្រង់ជាព្រះមហាក្សត្រមានព្រះវណ្ណៈខ្ពស់ផុត ទ្រង់សម្បូណ៌ហោដោយព្រះរាជទ្រព្យ ឥតមានខ្វះអ្វី ទ្រង់ធ្លាប់តែប្រកបដោយព្រះសុខុមាលភាព ហើយទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រណី ចំពោះប្រជាពលរដ្ឋជាកូនចៅ ទ្រង់អោបរឹត

យ៉ាងជិតស្និទ្ធឥតប្រកាន់និងគ្មានរើសមុខយ៉ាងនេះ ទើបជាហេតុឲ្យមនុស្ស ទូទៅក្នុងសកលលោក គេកោតសរសើរព្រះអង្គ សូម្បីតែពួកដែលជាសត្រូវ ក៏អត់ទ្រាំកោតស្ញប់ស្ញែងខាងផ្លូវចិត្ត ចំពោះព្រះកាយវិការដ៏ថ្លៃថ្នូររបស់ព្រះអង្គមិនបានដែរ ។ ពលរដ្ឋខ្មែរទូទៅទាំងប្រទេស មានសេចក្ដីស្នេហាស្វាមីភក្ដិដ៏ស្មោះអស់ពីដួងចិត្ត ចំពោះព្រះអង្គ ស្ម័គ្រចិត្តដង្ហែតាមព្រះអង្គក្នុងព្រះកិច្ចកសាងជាតិគ្រប់បែបយ៉ាង និងប្រឆាំងតទល់ចំពោះពួកសត្រូវរបស់ជាតិគ្រប់ទិសទីនិងគ្រប់ពេលវេលា ដែលជាហេតុនាំឲ្យព្រះអង្គទ្រង់បានទទួលព្រះមហាជោគជ័យសេចក្ដីសម្រេច ក្នុងព្រះរាជនយោបាយដឹកនាំជាតិទាំងក្នុងប្រទេសនិងក្រៅប្រទេស, ពួកសត្រូវដែលនៅខាងក្នុងប្រទេសក្ដី ខាងក្រៅប្រទេសក្ដី ដែលមានចេតនាអាក្រក់ចង់ប្រទូសរ៉ាយចំពោះព្រះអង្គក្ដី ប្រាថ្នានឹងបំផ្លេចបំផ្លាញប្រទេសជាតិដោយផ្លូវនយោបាយក្ដី តែងតែបានទទួលនូវបរាជ័យ វិនាសអន្តរាយខ្លួនឯង គ្រប់អន្លើ ៗ សម្ដេចព្រះបិតាឯកភាពជាតិខ្មែរ ដោយព្រះអង្គទ្រង់មានព្រះអធ្យាស្រ័យស្មោះស្មើចំពោះប្រជាពលរដ្ឋទូទៅឥតប្រកាន់ជាន់ថ្នាក់នេះឯងហើយ ទើបទ្រង់រួបរួមប្រជាពលរដ្ឋខ្មែរទាំងប្រទេសឲ្យចេះចងសាមគ្គីព្រមព្រៀងគ្នា ជាធ្លុងមួយ ដែលជាហេតុឲ្យមានសេចក្ដីស្ងប់សុខសន្តិភាព ក្នុងខណៈដែលប្រទេសជិតខាងនៅជុំវិញយើង ត្រូវភ្លើងសង្គ្រាមដុតពេលពលពល់ពេល

វេលា ប្រជាពលរដ្ឋបានទទួលទុក្ខវេទនា ខ្លោចផ្សាយ៉ាងគួរអាណោច ៗ អាស្រ័យហេតុនេះហើយ ទើបទ្រង់សមរម្យជាទីបំផុត ដែលទ្រង់បានទទួលការថ្វាយព្រះកិត្តិនាមថា សម្តេចព្រះបិតានៃសន្តិភាពជាតិ ។ សម្តេចព្រះអគ្គមគ្គុទ្ទេសខ្មែរ ព្រះអង្គស្តេចយាងទៅកាន់ទីណា តែងទ្រង់បានទទួលការថ្វាយសេចក្តីគោរពសក្ការបូជាជានិច្ច ព្រះកិត្តិស័ព្ទសរសើរព្រះអង្គក្នុងវិស័យដឹកនាំជាតិ បានល្បីខ្ទរខ្ទាយសាយភាយទៅក្នុងផ្ទៃពិភពអន្តរ-ជាតិ ប្រទេសនានាក្នុងពិភពលោកគេស្គាល់ប្រទេសខ្មែរ ដែលជាប្រទេសដ៏តូចមួយនេះ ក៏ដោយសារព្រះបារមីរបស់ព្រះអង្គហ្នឹងឯង ៗ សរុបសេចក្តីទៅឃើញថា ការដែលសម្តេចព្រះបិតាឯករាជ្យជាតិខ្មែរ ទ្រង់ចាប់ពាល់អោបតែប្រជាពលរដ្ឋឥតរើសមុខ មិនទ្រង់ប្រកាន់ជាន់ថ្នាក់វណ្ណៈទាបខ្ពស់នោះ មិនមែនជាហេតុឲ្យកើតឧបទ្រពចង្រៃអពមង្គលទាល់តែសោះ, ផ្ទុយទៅវិញត្រឡប់ជានាំឲ្យព្រះអង្គទ្រង់ចម្រើន ដោយព្រះមហាជោគជ័យសិរីមង្គលវិបុលសុខ ទ្រង់ប្រកបដោយសេចក្តីសម្រេចគ្រប់ប្រការទៅវិញ ដែលស្របទៅតាមគតិនៃព្រះពុទ្ធសាសនាដូចបានធ្វើអត្ថាធិប្បាយមកនេះ។

គោលធម៌ខាងព្រះពុទ្ធសាសនា សុទ្ធតែជាគោលធម៌ដែលមានហេតុផលអាចពិសោធមើលបានទាំងអស់ ៗ ដូច្នេះ កាលបើបានសិក្សាត្រិះរិះតាមព្រះពុទ្ធតម្រាស់ ព្រមទាំងរឿងរ៉ាវប្រកបផ្សេងៗ ដូចពណ៌នាមកនេះ

ហើយ យើងក៏អាចពិចារណាប្រៀបធៀប និងវិនិច្ឆ័យបានថា សេចក្ដីប្រកាន់របស់មនុស្សសម័យបុរាណ ដែលជឿថា ការអង្គុយត្រង់កន្លែងដែលតាសតាសីអង្គុយ ជាហេតុនាំឲ្យចង្រៃ ឬការគ្រាន់តែក្រឡេកឃើញមនុស្សបណ្ដាលអត់ឃ្លាន ដើរសុំទាន ជាហេតុឲ្យកើតអពមង្គលគ្មានសិរីសួស្ដី អស់សេចក្ដីសុខសេចក្ដីចម្រើននោះ តើនឹងមានសេចក្ដីពិត ឬមិនពិតយ៉ាងណាខ្លះ ។

ព្រះបរមគ្រូជាអម្ចាស់ ទ្រង់ខំព្យាយាមប្រៀនប្រដៅមនុស្សឲ្យលើកលែងមើលងាយបន្ទុះបង្អាប់គ្នា សន្ធក់សន្ធិនគ្នា ព្រោះហេតុគ្រាន់តែមានវណ្ណៈជាតិត្រកូលផ្សេងគ្នាប៉ុណ្ណោះ ដោយទ្រង់លើកយកសីលធម៌ជាមជ្ឈមណ្ឌលសម្រាប់វាស់វែងគ្នា ជនណាក៏ដោយ កើតក្នុងវណ្ណៈវង្សត្រកូលខ្ពស់ទាបមានក្រ មិនសំខាន់អ្វីឡើយ កាលបើតាំងនៅក្នុងសីលធម៌ គឺប្រព្រឹត្តល្អដោយកាយវាចាចិត្តហើយ ក៏រាប់ថាជាមនុស្សគួរសរសើរ គួរលើកតម្កើង គួរគោរពបូជាស្មើគ្នាទាំងអស់, ផ្ទុយទៅវិញ មនុស្សដែលប្រព្រឹត្តតែទុច្ចរិតដោយកាយវាចាចិត្ត មានសម្លាប់សត្វជាដើម សូម្បីអ្នកនោះកើតក្នុងត្រកូលខ្ពស់មានទ្រព្យសម្បត្តិស្ដុកស្ដម្ភ ក៏ឈ្មោះថាជាមនុស្សអន្ធពាល មានចរិយាថោកទាប គួរបានទទួលសេចក្ដីតិះដៀលពីអ្នកដទៃ អន់ជាងអ្នកមានវណ្ណៈទាបដែលតាំងនៅក្នុងសីលធម៌ដោយពិត ។

សម័យក្រោយមកនេះ ជនជាតិឥណ្ឌាជាច្រើនសែននាក់ បានប្រកាសខ្លួនជាពុទ្ធសាសនិកជន ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានសរសើរថាព្រះពុទ្ធសាសនា ជាសាសនាដែលជួយសង្គ្រោះមនុស្សគ្រប់ជាន់ថ្នាក់ឥតរើសមុខពិតៗ មិនទាត់ចោលទូរមនុស្សជាន់ទាប ដែលត្រូវគេមើលងាយបន្តុះបង្អាប់ ថែមទាំងចាប់អារម្មណ៍ជាពិសេសទៅលើមនុស្សពួកនេះ ដោយមានគោលធម៌ជាច្រើនដែលជាគតិប្រឆាំងនឹងការប្រកាន់វណ្ណៈ ដែលជាការជួយឲ្យពួកមនុស្សជាន់ទាបនេះ បានផុតពីការមើលងាយបន្តុះបង្អាប់ទៀតផង ។

អាស្រ័យភ័ស្តុតាងដូចបានរៀបរាប់មកនេះ ព្រះពុទ្ធសាសនា ទើបជាសាសនាតែមួយ ហើយជាសាសនាដំបូង ដែលមានគតិធម៌សម្រាប់ទូន្មានមនុស្សឲ្យចេះពិចារណាឃើញសភាពស្មើគ្នារបស់មនុស្ស ហើយឈប់មើលងាយបន្តុះបង្អាប់គ្នា ដែលជាវិធីបំបាត់ការប្រកាន់វណ្ណៈ នៃមនុស្សទូទៅក្នុងលោក ដូចបានធ្វើអត្ថាធិប្បាយមក ដោយប្រការដូច្នេះឯងហោង ។

= ចប់ =

# រឿងព្រះពោធិរាជកុមារ

## អដ្ឋកថាធម្មបទ ភាគទី៦ អត្តវគ្គទី១២

លោក ប៊ូ ប៉ូ ប្រែរៀបរៀង

កាលព្រះបរមសាស្តា គង់ក្នុងភេសកឡាវ័ន ទ្រង់ប្រារព្ធនឹងព្រះពោធិរាជកុមារ ត្រាស់សំដែងធម៌ដោយបទគាថា ថា អត្តានញ្ចេ បិយំ ជញ្ញា ដូច្នេះជាដើម ។

មានដំណាលថា ព្រះពោធិរាជកុមារប្រើឲ្យជាងធ្វើប្រាសាទឈ្មោះកោកនទៈ ល្អណាស់មើលឃើញដូចជាអណ្តែតនៅលើអាកាស មានទ្រង់ទ្រាយមិនដូចប្រាសាទឯទៀតទេ ក្នុងផ្ទៃផែនដី ។ លុះជាងធ្វើស្រេចហើយ ត្រាស់សួរជាងថា ប្រាសាទបែបនេះអ្នកឯងធ្លាប់ធ្វើនៅទីកន្លែងដទៃទៀតដែរឬទេ ឬក៏ជាសិល្បៈស្នាដៃដំបូងរបស់អ្នកឯង ។ កាលបើជាងទូលថា ជាសិល្បៈគឺស្នាដៃដំបូង ព្រះអង្គ! ស្តេចទ្រង់ព្រះចិន្តាថា បើជាងនេះទៅធ្វើប្រាសាទបែបនេះឲ្យអ្នកណាទៀត ប្រាសាទអញនេះមុខជាមិនអស្ចារ្យទេ គួរតែអញសម្លាប់ជាងនេះចោលទៅ ឬគ្រាន់តែកាត់ដៃជើងឬចៀលភ្នែកទាំងពីរឲ្យខ្វាក់ កាលបើអញធ្វើដូច្នេះ ទើបវាលែងទៅធ្វើប្រសាទឲ្យអ្នកណាទៀតកើត ហើយត្រាស់ប្រាប់សេចក្តីនោះដល់មាណពជាបុត្ររបស់សញ្ជីវកៈជាសម្លាញ់របស់ខ្លួន ។ មាណពនោះគិតថា ព្រះរាជកុមារនេះ មុខជាធ្វើបាបជាងឲ្យវិនាសអន្តរាយឥតសង្ស័យ

ឡើយ ឯមនុស្សដែលចេះសិល្បៈរចនាការជាងស្ទាត់ជំនាញ ដាច់ពេកៈ វិសេសកាត់តម្លៃមិនបានយ៉ាងនេះ អញមិនព្រមឲ្យស្លាប់ឆ្ងាយ ៗទេ អញនឹងលួចប្រាប់ឲ្យគាត់ដឹងខ្លួនទុកជាមុន ។ មាណពនឹងលួចចូលទៅជួបនឹងជាង សួរថា អ្នកធ្វើប្រាសាទស្រេចហើយឬនៅឡើយ ។

ជាងឆ្លើយថា ខ្ញុំធ្វើប្រាសាទរួចសព្វគ្រប់ហើយ ។

មាណពនុនខ្សឹបប្រាប់ថា ព្រះរាជកុមារកាលបើជ្រាបថាអ្នកធ្វើប្រាសាទនេះរួចសព្វគ្រប់ហើយ ប៉ុនប៉ងនឹងសម្លាប់អ្នកឯងឲ្យបាត់រូបទៅ មិនទុកឲ្យនៅរស់ទេ ព្រោះខ្លាចអ្នកឯង ទៅធ្វើប្រាសាទបែបនេះ ឲ្យអ្នកណាទៀត ប្រាសាទព្រះអង្គនេះ មិនអស្ចារ្យ មិនសូវល្បីល្បាញទៅសព្វទិសទី, ហេតុនេះ អ្នកកុំធ្វេសប្រហែស ចូរប្រុងប្រយ័ត្នខ្លួនប្រាណឲ្យបានសុខតទៅមុខទៀត ។

នាយជាងនិយាយថា ខ្ញុំអរគុណលោកណាស់ ការដែលលោកប្រាប់អាថ៌ស្ងាត់កម្បាំងនេះឲ្យខ្ញុំបានដឹងខ្លួនជាមុន ទុកស្មើលោកបានឲ្យជីវិតដល់ខ្ញុំហើយ, មិនអីទេ ចាំខ្ញុំគិតលៃលករកផ្លូវដោះខ្លួនឲ្យរួចពីគ្រោះថ្នាក់នេះ ។

ថ្ងៃក្រោយ ព្រះរាជកុមារចូលទៅសួរជាងពីការធ្វើប្រាសាទរួចស្រេចហើយឬនៅឡើយ ។ ជាងទូលថា ខ្ញុំធ្វើមិនទាន់ស្រេចទេ ព្រះអង្គ ។

ព្រះរាជកុមារ– ចុះនៅសល់កិច្ចការអ្វីខ្លះ អ្នកជាង ?

នាយជាង– នៅសល់កិច្ចការ តំបុកតំប៉ុកច្រើនមុខណាស់ ព្រះអង្គ ! ពេលនេះទូលមិនទាន់បានទេ ចាំថ្ងៃក្រោយទើបទូលសូមក្រាបបាន សូមព្រះអង្គឲ្យគេដឹកនាំឈើជាច្រើនមកឲ្យទូលព្រះបង្គំ ។

ព្រះរាជកុមារ– ចុះអ្នកជាងត្រូវការឈើអ្វីខ្លះ?

នាយជាង– ឈើអ្វីក៏បានដែរ ឲ្យតែឈើនោះស្រាយឥតខ្ទីមហើយស្ងួតស្អាតផង ព្រះអង្គ ! ។

ព្រះរាជកុមារឲ្យគេដឹកនាំឈើយកមកប្រគល់ឲ្យជាង ។

គ្រានោះ នាយជាងទូលថា បពិត្រព្រះអង្គ ចាប់តាំងពីថ្ងៃនេះទៅសូមព្រះអង្គហាមប្រាមកុំឲ្យអ្នកណាចូលមករកទូលព្រះបង្គំ ព្រោះទូលព្រះបង្គំចាប់ធ្វើកិច្ចការ យ៉ាងល្អិតសុខុម កាលបើមានគេចូលមកនិយាយជាមួយ ជាហេតុនាំឲ្យគំនិតព្រះបង្គំពយមាយ ក្បាំងក្បាត់ខូចការពុំបានល្អទេ ប៉ុន្តែ ពេលទទួលទានអាហារ សូមអនុញ្ញាតឲ្យតែភរិយាទូលព្រះបង្គំម្នាក់យកអាហារចូលមកឲ្យទូលព្រះបង្គំ ។

ព្រះរាជកុមារយល់ព្រមហើយចាត់ការតាមបង្គាប់ជាងគ្រប់ប្រការ ។

នាយជាងបានឧកាសស្អាតល្អ ក៏អង្គុយឈូសឈើទាំងនោះក្នុងបន្ទប់មួយ ធ្វើសត្វគ្រុឌធំទាំងក្នុងល្មមបុត្រភរិយានិងខ្លួនអង្គុយចុះ មានស្លាបអាចហោះហើរបាន ។ វេលាភរិយាយកបាយមកឲ្យ ជាងប្រាប់ថា ប្អូនចូរលក់របស់ទ្រព្យដែលមានក្នុងផ្ទះឲ្យអស់ទៅ យកតែប្រាក់និងមាសមកវេចទុក ។ ឯព្រះរាជកុមារប្រើមនុស្សឲ្យទៅពីផ្ទះ នៅចាំយាមរក្សាការពារទាំងថ្ងៃទាំងយប់ ដើម្បីមិនឲ្យនាយជាងចេញទៅណារួច ។ ក្នុងថ្ងៃដែលនាយជាងធ្វើយន្តសត្វគ្រុឌរួចសព្វគ្រប់ហើយក៏ប្រាប់ភរិយាថា ថ្ងៃនេះប្អូនចូរនាំយកក្មេងទាំងអស់គ្នាពីផ្ទះមក លុះបរិភោគបាយព្រឹករួចហើយឲ្យបុត្រនិងភរិយាចូលអង្គុយក្នុងពោះគ្រុឌ ទាញខ្សែយន្តឲ្យគ្រុឌហោះហើររត់ចេញទៅតាមបង្អួចប្រាសាទ ។ ពួកអ្នកយាមល្បាតមើលឃើញច្បាស់នាំគ្នាទៅទូលព្រះរាជកុមារថា សូមព្រះអង្គទ្រង់ជ្រាប ឥឡូវនេះនាយជាងជិះយន្តគ្រុឌហោះរត់ទៅបាត់ហើយ ។ ឯនាយជាងហោះហើរទៅចុះចតឈប់នៅក្នុងប្រទេសហិមពាន្ត កសាងនគរមួយហើយតាំងខ្លួនជាព្រះរាជាព្រះនាមថា កដ្ឋវាហនៈ ក្នុងនគរនោះ ។

ចំណែកព្រះរាជកុមារ ទ្រង់ព្រះចិន្តាថា អញនឹងធ្វើពិធីបុណ្យឆ្លងប្រាសាទ ទើបនិមន្តព្រះសាស្តា ហើយរៀបចំតាក់តែងប្រោះព្រំក្នុងប្រាសាទដោយគ្រឿងក្រអូបលាយនឹងជាតិចួនមុខ ហើយក្រាលសំពត់មួយផ្ទាំងគូប

តាំងពីខ្មាងទ្វារជាដំបូង ៗ បានឮថា ព្រះរាជកុមារនោះពុំមានទោសទេ ព្រោះហេតុនោះ ទើបតាំងព្រះហឫទ័យថា បើអញនឹងបានបុត្រឬដ៏តា ព្រះសាស្ដានឹងទ្រង់ជាន់ផ្ទាំងសំពត់នេះ, កាលដែលព្រះសាស្ដាស្ដេចមកដល់ ថ្វាយបង្គំព្រះសាស្ដាដោយបញ្ចង្គប្រតិស្ឋាន[1] ហើយទទួលបាត្រ ក្រាបទូលថា បពិត្រព្រះអង្គចម្រើន ! សូមអញ្ជើញព្រះអង្គស្ដេចចូលទៅៗ ព្រះសាស្ដាមិនស្ដេចចូលទៅឡើយ ៗ ព្រះរាជកុមារអារាធនាដល់ពីរដង បីដង ៗ ព្រះសាស្ដាក៏នៅតែមិនព្រមស្ដេចចូលទៅ ទ្រង់ទតមើលព្រះអានន្ទត្ថេរ ៗ ព្រះថេរៈជ្រាបសេចក្ដីដែលមិនទ្រង់ជាន់សំពត់ ដោយសញ្ញាដែលព្រះអង្គទតមើល ទើបឲ្យព្រះរាជកុមារមូរសំពត់ចេញ ដោយអាងថា នែព្រះរាជកុមារ! ចូរព្រះអង្គមូរសំពត់ចេញ ព្រះមានព្រះភាគនឹងមិនទ្រង់ជាន់ផ្ទាំងសំពត់នេះទេ ព្រោះតថាគតតែងទតមើលប្រជុំជនដែលមានក្នុងខាងក្រោយ ៗ ព្រះរាជកុមារមូរសំពត់ចេញ ហើយនិមន្តព្រះសាស្ដាឲ្យស្ដេចចូលទៅខាងក្នុង ថ្វាយបបរនិងបង្អែមសោយឆ្អែតស្រេចហើយ គង់នៅចំណែកម្ខាង ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គចម្រើន! ខ្ញុំព្រះអង្គជាឧបដ្ឋាករបស់ព្រះអង្គ ដល់ព្រះអង្គជាទីពឹងបីដង បានឮថា កាលខ្ញុំព្រះអង្គនៅក្នុងគភ៌ ក៏ដល់ព្រះអង្គជាទីពឹងម្ដង ក្នុងវេលាដែល

---

១. ការថ្វាយបង្គំដោយតាំងទុកចំពោះនូវអវយវៈមានអង្គ ៥ គឺ ក្បាល១ ដៃ២ ក្បាល-ជង្គង់២ គឺថា លុតជង្គង់ ផែទាំងពីរប្រណម្យ ឱនក្បាលចុះឲ្យដល់អាសនៈ ។

ខ្ញុំព្រះអង្គនៅជាកូនខ្ចី គឺដល់ព្រះអង្គជាទីពឹង ចាត់ជាគ្រាទីពីរ ក្នុងវេលាដែលខ្ញុំព្រះអង្គធំឡើង គឺដល់ព្រះអង្គជាទីពឹង ចាត់ជាគ្រាទីបី ចុះហេតុអ្វីបានជាព្រះអង្គមិនទ្រង់ជាន់ផ្លាំងសំពត់ត្បូងរបស់ខ្ញុំព្រះអង្គ ?

ព្រះសាស្ដា – នែកុមារ ចុះអ្នកគាំងចិត្តដូចម្ដេច បានជាក្រាលផ្លាំងសំពត់នេះទុក ?

ព្រះរាជកុមារ – បពិត្រព្រះអង្គចម្រើន ខ្ញុំព្រះអង្គគាំងចិត្តថា បើអញនឹងបានបុត្របុត្រីតា ព្រះសាស្ដា នឹងទ្រង់ជាន់ផ្លាំងសំពត់ត្បូងរបស់អញដូច្នេះ ហើយក៏ក្រាលទុក ។

ព្រះសាស្ដា – នែកុមារ ! ព្រោះហេតុនោះ បានជាតថាគតមិនជាន់ ។

ព្រះរាជកុមារ – បពិត្រព្រះអង្គចម្រើន ! ចុះខ្ញុំព្រះអង្គមុខជាមិនបានបុត្រ បុត្រីតាម្នាក់សោះឬអ្វ ?

ព្រះសាស្ដា មិនបានសោះឡើយ កុមារ ។

ព្រះរាជកុមារ ព្រោះហេតុអ្វី បពិត្រព្រះអង្គចម្រើន ?

ព្រះសាស្ដា – ព្រោះអ្នកគាពមុន អ្នកមានសេចក្ដីប្រមាទជាមួយនឹងភរិយា ។

ព្រះរាជកុមារ – ពីកាលណាព្រះអង្គ ?

លំដាប់នោះ ព្រះសាស្តាទ្រង់នាំអតីតនិទានមកសំដែងប្រាប់ព្រះរាជកុមារនោះ មានសេចក្តីដូចតទៅនេះ ៖

បានឮមក ក្នុងអតីតកាល ពួកមនុស្សជាច្រើនរយនាក់ នាំគ្នាជិះសំពៅធំទៅកាន់សមុទ្រ ៗ សំពៅធ្លាយលិចកណ្តាលសមុទ្រ ៗ ប្តីប្រពន្ធទាំងពីរនាក់ឆក់យកក្តារបានមួយសន្លឹក តោងហែលចូលទៅដល់កោះដែលមាននៅក្នុងបន្ទោះ ៗ មនុស្សក្រៅពីនោះទាំងអស់ស្លាប់ក្នុងសមុទ្រនោះឯង ៗ មានហ្វូងសត្វស្លាបធំនៅទីកោះនោះ ៗ ប្តីប្រពន្ធទាំងពីរនាក់នោះ គន់រកមើលមិនឃើញមានរបស់អ្វី ដែលអាចនឹងបរិភោគបាន ឃើញមានតែពងសត្វ ឃ្លានខ្លាំងពេក ក៏យកពងសត្វដុតនឹងរងើកភ្លើងបរិភោគ ៗ កាលបើបរិភោគពងសត្វអស់ហើយ ក៏ចាប់កូនសត្វបរិភោគទៀត ៗ កាលបើកូនសត្វទាំងនោះអស់ហើយ ក៏ចាប់មេសត្វដុតបរិភោគតទៅទៀត ៗ បរិភោគទាំងក្នុងបឋមវ័យ ទាំងក្នុងមជ្ឈិមវ័យ ទាំងក្នុងបច្ឆិមវ័យយ៉ាងនេះ ពុំមានសេចក្តីមិនប្រមាទសូម្បីតែក្នុងវ័យមួយសោះឡើយ បណ្តាអ្នកទាំងពីរនោះ សូម្បីតែម្នាក់ក៏ពុំមានសេចក្តីមិនប្រមាទ គឺសុទ្ធតែប្រមាទទាំងពីរនាក់ស្មើគ្នា ៗ

ព្រះសាស្តាលុះទ្រង់សំដែងបុព្វកម្មរបស់ព្រះរាជកុមារនោះចប់ហើយ ត្រាស់ថា នែកុមារ! ប្រសិនបើអ្នកព្រមទាំងភរិយា មិនប្រមាទក្នុងវ័យមួយ

កាលនោះ បុត្រធីតាគប្បីកើតឡើងក្នុងវ័យមួយបាន ឬបើអ្នកទាំងពីរ សូម្បីតែម្នាក់មិនប្រមាទហើយ បុត្រធីតាក៏នឹងកើតឡើងបាន ព្រោះអាស្រ័យម្នាក់ដែលមិនប្រមាទនោះ, នៃកុមារ កាលបើបុគ្គលសំគាល់ថា ខ្លួនជាទីស្រឡាញ់ គប្បីមិនប្រមាទទាំងបីវ័យ ចាំរក្សាខ្លួន កាលបើមិនអាចរក្សាខ្លួនក្នុងវ័យទាំងបីបានទេ គប្បីរក្សាសូម្បីតែក្នុងវ័យមួយ ក៏បានដូចគ្នាដែរ, ត្រាស់ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។

ក្នុងទីបំផុតទេសនា ពោធិរាជកុមារបានសម្រេចព្រះសោតាបត្តិផល ។

រឿងព្រះពោធិរាជកុមារ ចប់ ។

នត្ថិ កម្មសមំ ពលំ
គ្មានកម្លាំងអ្វីខ្លាំងក្លាស្មើនឹងកម្លាំងកម្មទេ ។

ព្រះមហា ចាំង-ទាត់ រៀបរៀង

អបភារក ពុំ. ទីហាឧបិទជិត ។

អបភារិត គុ ដែលបិទបាំង ដែលលាក់បំពួន ។

អបភាហន នពុំ. កិរិយាបំរត់ ។

អបរិក្សត គុ. ដែលប្រាសចាករោគ ។

អបរិឃ្ន គុ. ដែលប្រាសចាកឧបសគ្គ ។

អបវិទ្ធ គុ. ដែលបោះបង់បោល ដែលបណ្តេញ ។ ដែលមុតធ្លុះ ។

អបវិទ្យា ស្រ្តី. អបវិទ្យា កិរិយាប្រាសចាកចំណេះ សេចក្តីល្ងង់។

អបវ្រ ធាតុ បើក រកឃើញ ។

អបវ្រជ ធាតុ ដាក់ទាន ជូន ។ បំភ្លេច : (ពាក្យសន្យា) ។

អបវ្រត ធាតុ. ប្រាសផ្លូវ បែរចេញ ពង្វាង ។ —វ្រត គុ. ដែលផ្លាស់កន្លែង ។ ដែលវង្វេង ដែលវិលវល់ ។

អបវត្តិ ស្ត្រី. ទីបំផុត កិរិយាបាត់បង់ ។

អបវេធ បុំ. អបវេធ កិរិយាបោះអាប្រាក់ (ថ្មី) ។

អបវោព្យ្ឋ កា.ន. អ្នកបំរាត់ ។

អបវ្យាធិ ធាតុ ដេញ បរបាញ់ បោះបង់ ។

អបវ្រុ ធាតុ បដិសេធ ប្រកែក ។

អបគម្ពីម ក្រិ.វិ. ដោយឥតខ្លាច ។

អបគព្ភ បុំ. សំនួន សេចក្ដីធម្មតា ពាក្យបង្គាប់ ។

អបគព្ភិត គុ. ដែលខិយាយខ្ទុយពីវេយ្យាករណ៍ ។

អបគតិតិលក គុ. ដែលប្រាសចាកទឡ្ហយ គឺព្រះចន្ទ្រជាតិលក: ចំណុចនៅចិញ្ចើម : ។

អបត្រស្ត គុ អបត្រស្ត ដែលឥតសន្ត្រា ។

អបគ្គុល គុ. អបកុសល ដែលឥតដែកស្រួច ។

អបគោក គុ អបសោក ដែលឥតសោក ។

អបគ្គម គុ. ដែលមិនមានអ្នកនៅពីក្រោយ, ចុងប៉ូច ។

អបគ្រី គុ. ដែលប្រាសស្រី ដែលមិនមានសិរី ។

អបស្រុតិ ស្រ្តី. អបស្រុតិ កិរិយាមិនមានស្រុតិ ។ គុ. ដែលមិនគាប់ត្រចៀក ។

អប្បុ ក្រិ.វិ. ខុសទទេ ។

អបសទ បុ. អបសទ ( ភ្លេង ) ដែលគេលះបង់ចោល ។

អបសរ បុ. អបសរ សេចក្ដីដោះសា ។

អបសរណ បុ អបសរណ, និវត្តន៍, ទីជម្រក ។

អបសប៌ បុ អបសប៌:, ការកិច្ច: ។

អបសប៌ណ នបុ. កិរិយាទៅឆ្ងាយ ។

អបសព្យ គុ. អបសព្យ ដែលមិនមែនឆ្វេង, ស្ដាំ ។ ពីស្ដាំទៅឆ្វេង ។

អបសារ បុ. អបសារ កិរិយាដោះចេញ ។ សារិត គុ. ដែលបន្ថយ ។ អ.ប សារិតា ស្ត្រី. កិរិយាឈប់ ។

អបសារណ នបុ កិរិយាបំបរបង់ ។

អបវិធ ធាតុ. បំបែរ ពង្វាងផ្លូវ វែកញែក ។

អបសឫ ធាតុ ទៅឆ្ងាយ, ថយ, បំបាត់ ។ ដេញ, នាំទៅឆ្ងាយ ។ សឫត គុ. ដែលលែងចេញ ដែលកន្លងទៅ ដែលលាត ដែលហួតពីស្រោម ។

អបសប្បិ ធាតុ ថយចេញ ប្រគល់ឲ្យ ល្បមើល ។

អបសប្បិត គុ. ដែលថយចេញ ។

អបស្ក្ប ធាតុ អេះអើង ។

អបស្តុន គុ. អបស្តុន, ដែលប្រាសចាកពោះម្ដាយ ។

អបស្នាត គុ. ដែលមុជទឹកក្រោយលើកសពសំស្ការ ។

អបស្នាន នបុំ. អបស្នាន ទឹកដែលមុជក្រោយលើកសពសំស្ការ, ស្នានមិនបរិសុទ្ធ ។

អបស្យគ គុ. ដែលមិនមានបេសកកម្ម ដែលមិនមានបុព្វបយោគនៃមហាកម្ម ។

អបស្មយ គុ. អបស្មយ ដែលមិនមានការឆ្មើងឆ្មៃ ។

អបស្មារ គុ. អបស្មារ ជម្ងឺស្កន់ ជម្ងឺឆ្កួតជ្រូក ។ — ស្មារិន គុ. ដែលស្កន់កាច់ ។

អបស្ម្រឹត គុ. ដែលបាត់ស្មារតី ដែលភ្លេច ។

អបស្ម្រឹតិ កិរិយាមិនមានស្មារតី កិរិយាភយមាយ ។

អបស្វរម៍ ក្រ.វិ. ដោយសំឡេងស្អា ។

(នៅមានត)

ការស្រាវជ្រាវ

# ប្រវត្តិលោកវិសេស ដូង

របស់

## បណ្ឌិតមហា ឈឹម–ស៊ុម អតីតសាស្ត្រាចារ្យ

## និទាន

## (INTRODUCTION)

*(លោកវិសេស ដូង ជាកវីតែមួយរូបក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះនរោត្តម) ។*

*ក្នុងកាលព.ស. ២៤៥៨ គ.ស ១៩១៥ ខ្ញុំ(ឈឹម ស៊ុម) មានអាយុ ១០ឆ្នាំ កំពុងសិក្សានៅវត្តថ្មល់កោរ(១) ឃុំបរសេត ស្រុកគងពិសី ខ្ញុំបានហាត់អានសាស្ត្រាល្បែងនិងច្បាប់ផ្សេង ៗ ជាច្រើន ។ បណ្តាសាស្ត្រាល្បែងទាំងនោះ មានសាស្ត្រាល្បែងមួយខ្សែជាល្បើករបស់លោកតាវិសេសដូង ឈ្មោះសាស្ត្រា " សុវណ្ណពិលាប " ខ្លះហៅ " សាស្ត្រានេនមាស " ។ តមកខ្ញុំហាត់អានសាស្ត្រាទេសន៍ រហូតដល់មហាជាតក៍ គឺមហាវេស្សន្តរ-*

---

១ វត្តថ្មល់កោរនេះ សម្តេចព្រះសង្ឃរាជ ជ.ណ. ទ្រង់ប្រោសព្រះរាជទាននាមថ្មី ដើម្បីឲ្យស្របនិងបាលីថា «វត្តធនសិរី» ផ្លាស់វិញពី គ.ស. ១៩៦៤ តាមតាមព្រះសពធន ឪពុកធំខ្ញុំជាអ្នកកវត្តនេះ ។ នៅទីមុខវត្តនេះ រដ្ឋាភិបាលបានបង្កើតមន្ទីរតំបន់ផ្ទាលមួយ ពីឆ្នាំ ១៩៦៤ ឥឡូវនេះ រដ្ឋាភិបាលកំពុងចាត់ការបង្កើនទៅជាសាលាស្រុក ។

ជាតក ព្រមទាំងសៀវភៅផ្ទួនដែលជាស្នាដៃរបស់លោកតាវិសេសជូនដែរៗ នោះបីសៀវភៅទាំងនោះបាត់បង់អស់ ខ្ញុំស្រាវជ្រាវរកឯកសារពុំទាន់ឃើញ ក៏ខ្ញុំនៅចាំអាចសូត្រមាត់ទទេបានខ្លះ ៗ

តមកគ.ស. ១៩២៨ ខ្ញុំជាសាមណេរមានអាយុ ១៣ ឆ្នាំ ខ្ញុំមកនៅសិក្សាក្នុងសំណាក់លោកគ្រូអាចារ្យ ពៅ-កន អតីតចៅអធិការសឹកចេញពីវត្តហូរពៅ មកកាលនៅនាភូមិទួលខ្ពស់(ឃុំរាល) ខាងជើងជិតវត្តអង្គទន្ទាប់ ហៅវត្តត្រពាំងឈើង(កាលណោះវត្តនោះនៅក្នុងឃុំគរក្រួស ឥឡូវបញ្ចូលទៅក្នុងឃុំព្រៃញាតិ ស្រុកគងពិសី) ជាវត្តដែលលោកតាអាចារ្យដួងធ្លាប់ជាចៅអធិការ ។ ទោះបីខ្ញុំជាសិស្សសិក្សាបាលី ប៉ុន្តែព្រោះហេតុលោកគ្រូខ្ញុំជាកវី ខ្ញុំក៏ស្ម័គ្រក្នុងការរៀនតែងកាព្យផង ។ លោកគ្រូខ្ញុំបានបង្ហាញឯកសាររបស់លោកតាអាចារ្យដួងខ្លះផង ទាំងក្បួនក្ឃយលោកគ្រូខ្ញុំ ក៏ចាំកំណាព្យលោកតាអាចារ្យដួង ច្រើនមេ ច្រើនគ្នាផង ទើបកំណាព្យកំប៉ុកកំប៉ុកទាំងនោះខ្លះ ចូលជាប់មកក្នុងបតិសម្បជញ្ញៈរបស់ខ្ញុំដែលសព្វថ្ងៃនេះ ដែលខ្ញុំនឹងសរសេរតទៅខាងចុង ។

តាំងពីខ្ញុំជាក្រុមជំនុំព្រះត្រៃបិដក គ.ស. ១៩៣៣ ជាសាស្ត្រាចារ្យបាលី គ.ស. ១៩៤៦ ខ្ញុំចូលចិត្តតែងកាព្យក្នុងពេលទំនេរខ្លះ ៗ ជាហេតុបណ្ដាលឲ្យមនោសញ្ចេតនារបស់ខ្ញុំ ប្រវត្តទៅជាប់នឹងឧបការគុណរបស់

លោកខាងលើនេះពុំសូវក្ជិប ។ លោកតាអាចារ្យជួនពុំមែនជាគ្រូផ្ទាល់របស់ខ្ញុំទេ, ប៉ុន្តែខ្ញុំបានចំណេះពីលោក គឺឯកសារកាច់កោបដែលសុទ្ធតែជាពាក្យកាព្យយកមកប្រៀបធៀបនឹងការបង្រៀនរបស់គ្រូខ្ញុំផង ។ ខ្ញុំតាំងលោកក្នុងទីកំបាំងមុខថា ជាគ្រូខ្ញុំដែរ ។ ខ្ញុំចង់សរសេរជីវប្រវត្តិរបស់លោកគ្រូអាចារ្យ នៅ កន គ្រូខ្ញុំយ៉ាងណា, ក៏ចង់សរសេរជីវប្រវត្តិរបស់លោកតាអាចារ្យជួនយ៉ាងនោះដែរ, បានជាក្នុងកាល ព.ស. ២៤៩៩គ.ស. ១៩៥៧ ខ្ញុំដឹងថាបព្វជិតមួយរូបព្រះនាម ជួន - កឿន ជាចៅបង្កើតរបស់លោកតាអាចារ្យជួន បួសម្តងទៀតក្នុងគ្រាដែលខ្លួនចាស់ ក្នុងសំណាក់លោកគ្រូ កែវ-ឡាង ចៅអធិការវត្តលេខតែន ដែលប្រែឈ្មោះត ៗ មកសព្វថ្ងៃហៅវត្តអង្គព្រះពាន ខាងត្បូងមន្ទីរពេទ្យបម្រើសុខភាព របស់សម្តេចព្រះសង្ឃរាជ ជ.ណ. ឃុំការកោះ ស្រុកគងពិសី ។ ខ្ញុំបានទៅដល់ទីនោះសួរផ្ទាល់លោកគ្រូ កែវ·ឡាង ដែលកើតទាន់លោកតាអាចារ្យជួនផង ផ្ទាល់លោកតា ជួន កឿន ជាចៅបង្កើតរបស់លោកតាអាចារ្យជួនផង បានការខ្វះយកមកសរសេរជាក់ក្នុងខាងដើមសៀវភៅ ទសជាតក៍របស់លោកគ្រូ អ៊ូ-ចេវ ដែលខ្ញុំត្រូវបោះពុម្ពផ្សាយច្រើនដងមកហើយ ។

តមកនៅថ្ងៃ ៧ ៗ ១០ ឆ្នាំម្សាញ់សប្តស័ក ព.ស. ២៥០៨ គ.ស. ១៩៦៥ ជាថ្ងៃភ្ជុំបិណ្ឌ ខ្ញុំត្រូវនាំគ្រួសារទៅរួមធ្វើបុណ្យភ្ជុំ បង្សុកូលឧទ្ទិស

ផលជូនលោកគ្រូព្រះសព ភៅ កន នាវត្តហូរញ៉ៅ ព្រមទាំងបង់ស្រាវជ្រាវឲ្យជាក់ច្បាស់នូវជីវប្រវត្តិលោកតាអាចារ្យជួនផង ខ្ញុំក៏ចេញដំណើរពីភ្នំពេញតាំងពីព្រលឹមដល់វត្តហូរញ៉ៅ មុនអ្នកស្រុកជិតខាង, ខ្ញុំបានជួបនិងចាស់ព្រឹទ្ធាចារ្យដ៏ច្រើន ដែលខ្ញុំបានណាត់ពេលសុំជួប មាន :

១- លោកគ្រូបណ្ឌិតមហា តុប-កឹម[១] ព្រះជន្ម ៨៤ ឆ្នាំ ( មហា ៤ ប្រយោគ គង់ជំនាន់ជាមួយនិងសម្តេចព្រះសង្ឃរាជ ) ដែលជាអតីតចៅអធិការសឹកចេញពីវត្តហូរញ៉ៅទៅនៅភូមិក្រសាំងជីមែ

២- លោកតា មឿក អួក នៅភូមិព្រៃទទឹង

៣- លោកតា ទេស ស៊ុម -ដ-

៤- លោកតា ឃួន -ដ-

៥- លោកតា ម៉ី.សឿង នៅភូមិដើមរកាជាដើម ដែលសុទ្ធតែកើតទាន់លោកតាអាចារ្យជួន ហើយស្គាល់ច្បាស់ព្រមទាំងចាំកំណាព្យខ្លះរបស់លោកតាអាចារ្យជួនផង ។

---

១- លោកគ្រូមហា កឹម ជាសិស្សលោកគ្រូព្រះសពមៀង អតីតចៅអធិការវត្តហូរញ៉ៅ ។ លោកគ្រូ មឿង ជាសិស្សលោកតាអាចារ្យ ជួន ។ លោកតែងប្រើលោកគ្រូមហា កឹម កាលជាយុវជនមានអាយុ ១២ ឆ្នាំដល់អាយុ ១៦ ឆ្នាំ ឲ្យយកអាហារចំណីអាហារស្ងួយរ៉ៃទៅជូនលោកតាអាចារ្យជួនប្រហែលដប់ដងក្នុងខែមួយ ៗ ។ ហេតុដូច្នេះ ទើបលោកគ្រូមហាកឹមនេះ បានជាអ្នកស្និទ្ធស្នាលចេញចូលក្នុងផ្ទះនៃលោកតាអាចារ្យជួនដូចកូនក្នុងផ្ទះ ។

BIBLIOTHEQUE
D'EXTREME



ខ្ញុំសួរចាស់ៗ ទាំងនេះមួយរយៈម្ដងៗ ឲ្យស្មៀនខ្ញុំសរសេរតាមបាន សេចក្ដីដូចតទៅនេះ ៖

# កំណើត និង ការសិក្សា

របស់

## លោកតាអាចារ្យជួង

លោកតាអាចារ្យជួងចាប់កំណើតក្នុងគ្រួសារអ្នកស្រែ មាតាបិតាមាននាមពុំប្រាកដ នាភូមិតាំងលប ឃុំព្រះនិព្វាន ស្រុកគងពិសី ជាប់ព្រំប្រទល់នឹងស្រុកកណ្ដាលស្ទឹង (ឆ្នាំកំណើតពុំប្រាកដ[១]) ។ លោកតាអាចារ្យជួងកាលពីនៅក្នុងបឋមវ័យជាកុមារ បានសិក្សាអក្សរភាសាខ្មែរ រហូតដល់បានផ្នួសជាបព្វជិត សិក្សាបាលីក្នុងវត្តព្រះនិព្វាន (ព្រះឧបជ្ឈាយាចារ្យរបស់លោកពុំប្រាកដជានាមអ្វី) ។ ក្នុងគ្រាដែលលោកជាភិក្ខុ បានចេញទៅសិក្សាបាលីក្នុងវត្តគុក មុខភ្នំព្រះពជទ្រព្យ (ឧដុង្គ) ។ កាលនោះនៅក្នុងខេត្តសំរោងទង ។

តាមប្រសាសន៍ចាស់ៗទាំងនោះថា លោកតាអាចារ្យជួង ធ្លាប់

---

១– លោកគ្រូមហាកឹមថា កាលលោកតាអាចារ្យជួងស្លាប់, ខ្លួនលោកមានអាយុ ១៦ ឆ្នាំ ត្រូវនឹង គ.ស. ១៨៩៣ ។ ថាលោកតាអាចារ្យជួងមានអាយុជាង ៩០ ឆ្នាំ ។ បើគិតអាយុ ៩០ គត់ ឃើញថាកើតក្នុង គ.ស. ១៨០៣ ។

ដំណាលប្រាប់គេរឿយ ៗ ថា : លោកគ្រូព្រះមហាពជធម្ម (អន) វត្តគុក
កាចណាស់, មនុស្សម្នាម្នះរៀននឹងលោកពុំបានទេ, មានតែម៉ុកកែងទើប
ផ្គាប់ព្រះទ័យលោកត្រូវ ៗ ថា : អម្បាលខ្ញុំជាមនុស្សរហ័សរហួនអាច
ទទួលបង្គាប់ប៉ុណ្ណះ ហើយធ្វើរហូតប៉ុណ្ណោះបាន, ក៏នៅតែពុំសូវត្រូវព្រះ
ទ័យលោកដែរ ៗ ថា : លោកឲ្យរៀនប្រែបាលីមួយថ្ងៃមួយសន្លឹក, ខ្ញុំ
សុំរៀន ៥ សន្លឹកលោកពុំព្រម, ខ្ញុំទទូចសុំញឹក ៗ លោកបែរជាថា : គាត់
ឯងរៀនមិនបេះទេ ៗ ខ្ញុំអន់ចិត្តក៏លាលោកទៅស្រុកសៀម ៗ លោក
ថា: សៀមខ្មោចអី ! ៗ ទោះបីលោកមិនអនុញ្ញាត ក៏ខ្ញុំអាងថាលាហើយ
ក៏ចេញដំណើរទៅដល់បាត់ដំបង ខំរៀនសៀមផង ហាត់ទេសមហាជា-
តក៍ផង ៗ ខ្ញុំឃើញគម្ពីរមហាជាតក៍បេះតែស្មើរចិត្ត បានជាខ្ញុំកែពាក្យក្នុង
គម្ពីរមហាជាតក៍ច្រើនអន្លើ ៗ លោកគ្រូមហាជាតក៍បន្ទោសខ្ញុំថា : ម្តេច
ក៏បំផ្លាញរបស់គេ ៗ ខ្ញុំឆ្លើយថា : មិនបំផ្លាញទេ, ជួយធ្វើឲ្យពិរោះទេតើ ៗ
លោកគ្រូមហាជាតក៍បោះគម្ពីរដែលខ្ញុំកែនោះឲ្យមកខ្ញុំ ៗ ខ្ញុំនឹកត្អូញចិត្តក៏
វេចរុំគម្ពីរនោះ(១)លាលោកមកស្រុកវិញ ។ (ដំណើរការណ៍ដែលចាស់ ៗ

---

១– គម្ពីរនេះ ដែលអ្នកគងពិសីហៅថា មហាជាតក៍លោកវិសេសក្នុង ។ មួយបែបទៀត
គេហៅថាមហាជាតក៍ឡាប់ល្ងង ឬមហាជាតក៍ព្រះអង្គខ្លង ដែលលាយដោយពាក្យសៀមចម្រុះ
នឹងពាក្យខ្មែរ ។

បានប្រាប់ខ្ញុំដូចខាងលើនេះ គួរឲ្យខ្ញុំយល់ថា: លោកតាអាចារ្យជួងរៀនបាលីពុំទាន់បានការចេះច្រើនប៉ុន្មានទេ ហើយជាមនុស្សដែលពាក្យចាស់ថារៀនហួសបន្ទាល ជាហេតុនាំឲ្យអនាគតរបស់ខ្លួនមិនបានលូតលាស់ល្អផង ) ។

## ជីវភាពក្នុងភេទបព្វជ្ជា

នៃ

## លោកតាអាចារ្យ ជួង

ចាស់ ៗ ចាំងនេះនិយាយប្រាប់ខ្ញុំតទៅទៀតថា : លោកតាអាចារ្យជួង កាលត្រឡប់មកគង់នៅក្នុងវត្តព្រះនិព្វានវិញ មានកិត្តិស័ព្ទល្បីល្បាញខ្ទរខ្ទារពាសពេញចាំងខែត្រ ព្រោះហេតុលោកទេសន៍មហាជាតក៍ពិរោះណាស់ ហើយជាមនុស្សរហ័សមានប្រាជ្ញាវាងវៃ សំដីអើល ធ្វើការឥតខ្ចិល អាចបំពេញបំណងអ្នកត្រូវការបានភ្លាមៗ ។ មិនតែប៉ុណ្ណោះ ក្នុងវេលាដែលលោកចាស់ចិត្តចាស់គំនិតបន្តិចហើយ លោកបានរៀនព្រះកម្មដ្ឋានក្នុងវត្តព្រះនិព្វានថែមទៀត ។

មានវត្តមួយឈ្មោះវត្តអង្គទន្ទាប់ ហៅគ្រពាំងឈើង ខាងត្បូងវត្តព្រះនិព្វាន ខាងលិចកំហូរញ្ញៅ លោកគ្រូចៅអធិការទទួលអនិច្ចធម្មទៅ នៅលោកតាចាស់មួយអង្គព្រះនាមហ៊ឹង ពិការជើងនិមន្តដើរពុំបាន ប៉ុន្តែមាន

បរិយាល្អ ក៏ភិក្ខុសាមណេរ ព្រមទាំងឧបាសក-សិកា ប្រគេននាទីជាចៅអធិការចំពោះលោកតាហ៊ីងនេះ ។ លោកតាហ៊ីងពុំព្រមទទួល ទើបបបួលគ្នាទៅនិមន្តលោកគ្រូអាចារ្យដួង មកតាំងជាចៅអធិការ ។ លោកគ្រូអាចារ្យដួង បានឋានៈជាចៅអធិការ មានការគោរពចំពោះលោកតាហ៊ីង ដូចគ្រូនិងសិស្ស ។ លោកគ្រូអាចារ្យដួង បានបំពេញបព្វជិតកិច្ចក្នុងឋានៈជាចៅអធិការ ព្រមទាំងបានបង្រៀនមហាជាតក៍និងព្រះកម្មដ្ឋានផង (ពុំដែលឮថាបង្រៀនបាលីទេ) ។

តមកលោកតាហ៊ីងមានអាពាធធ្ងន់ សិស្សគណ ញាតិមិត្រខំព្យាបាលរោគរបស់លោកដោយវិធីផ្សេងៗ ។ លោកគ្រូអាចារ្យដួង បានតែងកំណាព្យមួយរឿងហៅថា រឿងតាហ៊ីង (ឥតមាននរណាចាំកំណាព្យនេះទេ, ទោះបីខ្ញុំស្រាវជ្រាវរក ក៏ពុំឃើញឯកសារនោះសោះ, ប៉ុន្តែអ្នកធ្លាប់អានកំណាព្យនោះ ចាំសេចក្តីបានខ្លះ) ។

ក្នុងគ្រាព្យាបាលរោគនៃលោកតាហ៊ីងមានបុរសម្នាក់ឈ្មោះស នៅភ្នំដីស្បូរ(១)ជាសិស្សលោកតាហ៊ីង បាននាំលោកទៅព្យាបាលរោគនាភ្នំដីស្បូរនោះ ។ គ្រូពេទ្យឈ្មោះ សុខ ជាអ្នកមើលជម្ងឺ ។

១– ភ្នំនេះអ្នកខ្លះហៅភ្នំព្រះឥសូរ នៅស្រុកសំរោង ខេត្តតាកែវសព្វថ្ងៃ មានព្រះវិហារព្រះពុទ្ធសាសនាពីបុរាណមកដល់សព្វថ្ងៃ ។ អ្នកខេត្តនានានៃកម្ពុជរដ្ឋតែងកាត់ទៅបន់ស្រន់ ដោយជំនឿថា មានព្រះពុទ្ធរូបស័ក្តិសិទ្ធិក្នុងទីនោះ ។

លោកគ្រូអាចារ្យជួន តាមទៅបម្រើលោកតាហ៊ីង លើកំពូលភ្នំជីសូរ អស់វេលាជាង ១ ខែ ។ ព្រោះហេតុតែនោះជាកន្លែងស្ងាត់ លោកបានក៏អផ្សុកព្រោះទំនេរ ជួនជាបានឃើញសត្វអកទាំងគូនៅលើភ្នំជីសូរបានកូនខ្ចី ទើបលោកប្រឌិតរឿងអកនោះ តែងជាពាក្យបានមួយរឿងទៀត ឲ្យឈ្មោះ "ល្បើកអក(១)" ។

លុះលោកតាហ៊ីង បានជាចាកពេកហើយ លោកគ្រូឡប់មកកាន់វត្តត្រពាំងឈើងវិញទាំងអស់អង្គ ។ លោកគង់នៅជាមួយគ្នា មិនយូរប៉ុន្មាន ក៏អ្នកគប់អានលោកតាហ៊ីង កវត្តមួយទៀត ឲ្យឈ្មោះថា វត្តអង្គព្រះស្រី(សំដីអ្នកស្រុ ហៅវត្តអង្គកាជន់) ក្នុងឃុំព្រៃញាតិ ខាងត្បូងជិតវត្តត្រពាំងឈើងនោះ ហើយគេនិមន្តលោកតាហ៊ីង មកទទួលនាទីជាចៅអធិការ ។ វត្តអង្គព្រះស្រីនេះ តអំពីលោកតាហ៊ីងមកមានចៅអធិការ ៤ តំណមកដល់ ព.ស. ២៥០៩ គ.ស. ១៩៦៧ នេះ គឺលោកគ្រូអ៊ូ, យក់, អ៊ុម និង លោកគ្រូប៉ាន់ ចៅអធិការសព្វថ្ងៃ ។

ក្រោយពេលដែលលោកតាហ៊ីងបែកទៅនៅវត្តថ្មី លោកគ្រូអាចារ្យជួន ក៏លាចាកសិក្ខាបទដែរ ។ ទៅរៀបអាពាហ៍ពិពាហ៍ជាមួយនាងសិកាម្នាក់ ឈ្មោះមាស នៅភូមិដំដែក ឃុំជាមួយគ្នា ខាងលិចជិតវត្តទាំងពីរនោះ ។ (មានត)

---

១ – តាមប្រភពវត្តលៃខពែន លោកគ្រូ កែវ-ឡាង និង លោកតាម្លឹង-កៀងថា ៖ មុនល្បើកអកនេះ លោកគ្រូអាចារ្យម្លឹង បានតែងរឿងសេកសារិកាមួយដែរ ដែលយើងស្គាល់ថា [illegible]

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ឆ្វ-កាង

ប្រែ-រៀបរៀង

(គ)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ    អ្នកវាងវៃឆ្លាតបើបានអាន<br>នឹងចេះឧបាយកលចំណាន    ទាំងមានសន្តានស្នេហាជាតិ |

——— យូរ-អ៊ិន ———

ព្រះចៅឡៅពីជ្រាបថាហាងតុងត្រូវរបួសព្រួញធ្ងន់ណាស់ ក៏ស្ដេចចេញរហ័សទៅសួរ ហើយទ្រង់យកព្រះហស្ដស្ទាបអង្អែលស្មាហាងតុងហើយត្រាស់ថា អ្នកចេញទៅច្បាំងគ្រានេះ ក៏ដើមហេតុពីព្រោះខ្ញុំថាអ្នកចាស់ជរានឹងធ្វើការពុំកើតការមិនបានការ អ្នកខឹងព្រោះខ្ញុំថា បានជាចេញទៅច្បាំងឲ្យត្រូវរបួសខ្លាំងយ៉ាងនេះ ខុសព្រោះខ្ញុំៗសុំខមាទោសអ្នកចុះ ហាងតុងក៏ទូលថា ទូលព្រះបង្គំជាជាតិទាហានបានមកធ្វើការថ្វាយធ្ងន់ព្រះតេជគុណជាច្រើនមកហើយ មិនត្រូវខ្លាចអ្វីឡើយនឹងសេចក្ដីស្លាប់នោះ អាយុទូលព្រះបង្គំជាខ្ញុំ ក៏បានដល់ ៧០ បាយឆ្នាំហើយ គួរនឹងថ្វាយបង្គំលាស្លាប់ណាស់ តែថាព្រះអង្គនឹងទ្រង់ទំនុកបំរុងផែនដីតទៅមុខនោះ នឹងធ្វើការអ្វីក៏គប្បីពិគ្រោះពិចារណាតាមព្រះបញ្ញាដ៏សុខុម កុំកាន់ព្រះមានៈឲ្យហួសទីប្រឹក្សា ថាតែប៉ុណ្ណោះពិសថ្នាំព្រួញក៏កំរើកឡើងសព្វសព៌ាង្គកាយ ហាងតុងក៏ធ្វើកាលកិរិយាក្នុងពេលនោះទៅ ព្រះចៅឡៅពីក៏ទ្រង់ព្រះកន្សែងសោកាភិលាបអាឡោះអាល័យ ហើយបង្គាប់ឲ្យភ្នាក់ងាររៀប

សំស្កាសេពគាមបណ្តាស័ក្តិ ហើយហែទៅបញ្ចុះទុកឯស្រុកសែឈូន ព្រះចៅឡៅពីទ្រង់គិតថា យើងមាននាយទាហានឯក ៤ នាក់ បានធ្វើការរណរង្គសង្គ្រាមមកជាមួយគ្នាយូរហើយ គ្រានេះមានបាបគ្រោះស្លាប់អស់៣ នាក់ទៅហើយ នៅមិនទាន់សង់សឹកសត្រូវបាន ។ សេចក្តីអប-យសពេកណាស់ គួរឲ្យខ្មាសមនុស្សទាំងពួង ទ្រង់ព្រះចិន្តាហើយក៏ឲ្យលើកកងទ័ពទៅប្រថាប់ឯដំបន់ផ្លូវគង ហើយត្រាស់ឲ្យប្រមូលនាយកងនាយទ័ពមកបង្គាប់ថា ឲ្យរៀបកពលយោធាចេញជា ៨ កង ទាំងជើងទឹកនិងជើងគោក ឯទ័ពគោកទ្រង់ត្រួតត្រាផ្ទាល់ព្រះអង្គ ខាងទ័ពទឹកឲ្យហ្លួងគួន ជានាយកង ត្រួតត្រា ។

ខណៈនោះហាន់ពុងនិងជីវថាយបាល័ដ្ឋទ័ពស្រុកកាំងតាំង និងកួចៀងជានាយទ័ពស្រួចដឹងថា ព្រះចៅឡៅពីលើកទ័ពទៅដល់ទីប្រទល់ដែន ក៏កេណ្ឌប្រមូលកងទ័ពលើកចេញទៅក្តាប់ទល់គ្នា លុះលើកទៅវេលាណា ហាន់គុងនិងជីវថាយក៏ឡើងសេះកាំដាវលំពែងចេញទៅពីមុខទ័ព ក្រឡេកទៅឃើញគ្រឿងសម្រាប់យុទ្ធនានិងទង់ជ័យសុទ្ធតែពណ៌លឿងទាំងអស់ក៏ដឹងច្បាស់ថា ព្រះចៅឡៅពីមកឯង ទើបស្រែកថា ព្រះចៅផែនដីស្រុកសៃឈូនមានសុទ្ធតែមនុស្សល្អ មានសតិបញ្ញា ជាទីទំនុកទុកព្រះទ័យណាស់ហើយ ម្តេចឡើយក៏ចាំលើកទ័ពចេញមកនិង

ព្រះអង្គឯង បើប្រសិនជាធ្វើការទៅថ្វាយដោយប្រការឯណា ទីងទុក
ដាក់អ្នកឯណាឲ្យរក្សាស្រុកទៅមុខទៀត ។ ព្រះចៅឡៅពីទ្រង់ព្រះសណ្ដាប់
ច្បាស់ខ្វាល់ណាស់ស្រែកថា អាពួកតិរច្ឆានស្រុកកាំងគាំង ឯងជាចោរ
អហង្កាធ្វើអន្តរាយជីវិតប្អូនអញ ហាក់បីដូចជាលួចកាត់ជើងអញឲ្យដាច់
តាំង ២ មិនឲ្យដើរបាន អញបានចេញវាចាថាហើយ គឺពួកអាឯងនេះ
អញមិនសុំឃើញមុខសោះ តាំងពីមេឃអាកាសតាំងអស់ក៏មិនសុំឲ្យជាប់
គ្នាឡើយ ។

ខណៈនោះហានទគុនទិងជីវថាយមិនឆ្លើយតបសោះ ក្រឡេកទៅ
សួរមាហានខាងក្រោយថា នរណាទីងអាសាចេញច្បាំង មានទាហាន
ម្នាក់ឈ្មោះហៃហស៊ុនឆ្លើយទទួលអាសា ហើយក៏កាន់លំពែងជិះសេះចេញ
ទៅ ព្រះចៅឡៅពីប្រថាប់នៅពីមុខទ័ពនោះ ទៀវចៅជិះសេះកាន់លំ
ពែងមេព្រះអង្គ លុះឃើញហៃហស៊ុនជិះសេះចេញមកកាំលំពែង ទៀវចៅ
ក៏ខឹងណាស់ស្រែកសន្ធឹក ហើយបំផាយសេះត្រង់ទៅប្រយុទ្ធគ្នាទីងហៃហ
ស៊ុន ។ បានតស៊ូសំឡេងទៀវចៅស្រែកសន្ធឹកខ្លាំងណាស់ ក៏តក់ស្លុតនិង
រត់ចេញ ។

ឯជីវហេងជាប្អូនជីវថាយឃើញហៃហស៊ុនទីងរត់ ក៏បរសេះស្ទុះពីទ័ពទៅ
ជួយ គួនហ៊ុនឃើញជីវហេងចេញទៅជួយដូច្នោះ ក៏បំបោលសេះកាំងារ

ៈចេញទៅតទឹងជាវៀតផង  ទាំង ២ ខាងក៏តាំងតែប្រយុទ្ធគ្នាទៅវិញ-មក  ទៀវថៅស្រែកសន្ធឹកហើយក៏ស្ទុះចូលទៅលើកលំពែងបាក់ត្រូវហេស៊ុនធ្លាក់ពីលើសេះស្លាប់  គួនហ៊ុនបានចំណាប់ក៏កាប់ជីវផងស្លាប់ទៅទៀត  ហើយគួនហ៊ុន,  ទៀវថៅក៏បំផាយសេះត្រង់ទៅទឹងបំរុងនឹងហាមគុង,  ជីវថាយទៀត  ហានគុង,  ជីវប៉ាយឃើញគួនហ៊ុន  ទៀវថៅមានថ្វីដៃខ្លាំងពូកែណាស់ជាជាងខ្លួនជាចាស់  ក៏ក្រឡាស់បរសេះរត់ចូលបន្ទាយ  គួនហ៊ុន,  ទៀវថៅក៏បំបោលសេះដេញតាមទៅ  ។

ខណៈនោះព្រះចៅឡៅពីទតព្រះនេត្រឃើញថ្វីដៃគួនហ៊ុន, ទៀវថៅក៏គិតនឹកពេញកដល់គួនអ៊ូ, ទៀវហ៊ុយណាស់  លុះលាន់ព្រះឱស្ឋសរសើរ ២ នាក់នោះថា  មិនបង់ប្រយោជន៍ខ្មោចអាពុកបានបង្កើតកូននេះមកពេញជាកូនខ្លា  ហើយបង្គាប់ពលយោធាជើងទឹកនិងជើងគោកឲ្យក្តុំបញ្ចូលគ្នាលើកទៅព័ទ្ធហែកចំលាយបន្ទាយបានសម្លាប់ទាហានស្រុកកាំងតាំងស្លាប់ជាច្រើនណាស់  ឈាមហូរជាត្លុកត្រពាំងលិចត្រឹមខ្នងជើង  ឯកាំឡេងនាយទ័ពទឹកក៏ក្រឡាវាំងខ្លួននៅក្នុងទូក  លុះបានឮសំឡេងស្រែកហោគឹកកងបែកទាហានមកក៏នឹកភ័យណាស់  ផ្លាស់ថយទ័ពទូកទៅឡើងច្រាំងហើយជិះរត់អស់ទៅ  ។

ពេលនោះសៈម៉ោខាចៅហ្វាយស្រុកឡាំម៉ាន់  ដែលលើកទ័ពមក

ជួយព្រះចៅឡាវពីនោះ លុះឃើញកាំឡេងជិះសេះរត់ទៅ ក៏ឲ្យទាហានយកធ្នូបាញ់សំដៅត្រូវកំភ្លៀនកាំឡេងទៀបទីងធ្លាក់ពីលើសេះ កាំឡេងកន្ត្រាក់ដកព្រួញមិនរួច ក៏បំបោលសេះរត់ទៅដំបន់អ៊ូទី មានសេចក្ដីឈឺចាប់សព្វសព៌ាង្គកាយ ក៏ចុះពីលើសេះវេះទៅអង្គុយក្រោមម្លប់ឈើ ១ ធំផ្អែកសម្ងំឲ្យបាត់ពើតពិស ៗ ព្រួញក៏កំរើកឡើងសព្វសាច់ កាំឡេងក៏ដាច់ខ្យល់ស្លាប់ នោះមានក្អែកធ្វើសំបុកនៅលើចុងឈើនោះ ក៏ចុះមកចោមរោមសពកាំឡេងជុំវិញ ទាហានដែលសល់ពីស្លាប់រត់ទៅប្រុទះ ក៏ហួសទៅទូលព្រះចៅស៊ិនគួន ៗ ជ្រាបថាកាំឡេងស្លាប់ហើយ ក៏សោកា·ល័យពុំវ៉ៃស្ដាយកាំឡេងពន់ប្រមាណ ថាម៉្លេះហើយមុខជាអស់រកបាននាយទាហានដូច្នេះ ទើបត្រាស់បង្គាប់ភ្នាក់ងារឲ្យទៅនាំសពនោះយកមករៀបចំបញ្ចុះទុកនៅដំបន់អ៊ូទី ហើយសង់ខ្ទមអ្នកតា ១ នៅពីមុខសពនោះ ៗ

ឯព្រះចៅឡាវពីបានជ័យជំនះហើយ ក៏ឲ្យត្រឡប់កងទ័ពទៅចូលបន្ទាយហើយទ្រង់ត្រួតត្រាមើលក៏ឃើញទាហានទាំងពួងនៅគ្រប់គ្នា បាត់តែគួនហ៊ិនម្នាក់ឯង ក៏ទ្រង់ចំបែងព្រះទ័យណាស់ ត្រាស់ប្រើទៀវចៅឲ្យលើកទាហានញែកគ្នាទៅតាមជាច្រើនផ្លូវ ទៀវចៅក៏លើកទាហានញែកទៅតាម ៗ

គួនហ៊ិនក៏បំបោលសេះដេញតាមក្លួចៀង ទៅដោយក្ដៅចិត្តគិតតែ

សងសឹកក្ដីបៀនឲ្យបាន ព្រោះឈ្មោះនេះសម្លាប់គួនអ៊ូជាបិតា បេះតែធ្វើដោះដេញប្រកិតតាមទៅទាល់តែដល់ពេលព្រលប់ ឯក្ដីបៀនខ្លាចគួនហ៊ុនតាមសម្លាប់ក៏បំបោលសេះ វេះត្រឡប់ចូលត្រសុកកុកព្រៃទៅតាមប្រកកំ លុះយប់ងងឹតណាស់ក៏ប្រាសបែកពីគ្នា គួនហ៊ុនក៏ត្រឡប់ទៅរកទ័ពធំពុំឃើញ បេះតែបរសេះវេះវិលវល់ពុំយល់មាគ៌ា ឃើញព្រះចន្ទ្ររៀងរះក៏បរសេះទៅតាមចន្លោះព្រៃប្រហែលយាម ២ ទើបដល់ភូមិ នៅត្បែរជើងភ្នំ មានផ្ទះ ១ ឃើញភ្លើងភ្លឺនៅចំពីមុខ គួនហ៊ុនក៏លោតចុះព្រុះពីលើខ្នងសេះវេះចូលទៅក្នុងភូមិនោះ ដល់ទៅផ្ទះហើយក៏គោះទ្វារហៅ ៗ

ពេលនោះតាចាស់ម្ចាស់ផ្ទះបានឮស្នូរគេគោះទ្វារពីក្រៅ ក៏ក្រោកទៅមើមារបើកទ្វារចេញមកហើយសាកសួរថា អ្នកនេះមកពីណា មានការអ្វីពេលប្ដើរណោះ គួនហ៊ុនឆ្លើយថា ខ្ញុំជាទាហានបានដេញពួកខ្មាំងទាំងយប់ ត្រឡប់ត្រឡិនទាល់តែវង្វេងផ្លូវដើរមកត្រូវលើផ្ទះតានេះ ពេលប្ដើរណោះក៏ហួសវេលា សុំតាអាណិតឲ្យបាយទទួលទាន ១ ពេលហើយឈប់ស្នាក់ ១ យប់ ព្រឹកស្អែកនឹងលាទៅទៀត តាចាស់មានចិត្តសប្បុរសក៏អញ្ជើញគួនហ៊ុនឲ្យចូលទៅថា អ្នកនៅអង្គុយលេងសិន ខ្ញុំនឹងចូលទៅចំអិនអាហារឲ្យពិសា ថាហើយក៏អុជចង្កៀង ១ ដាក់លើតុ ខ្លួនក៏ចូលទៅដាំស្លស្លុកនឹងលើកមកឲ្យគួនហ៊ុនអាស្រ័យ លុះគួនហ៊ុនឃើញតាចាស់អុជចង្កៀងភ្លឺឡើង ក៏ក្រឡេកទៅឃើញរូបក្នុងព្រះចត់ពិតជារូបគួនអ៊ូជា

បិតា ដែលតាចាស់ទុកបូជាលើហ៊ឹង គួនហ៊ិនសំឡឹងយល់ជាក់ក៏ជាក់
មុខក្រាបទួញយំនៅទីនោះ ។

តាចាស់ធ្លល់ណាស់ក៏សួរថា ហេតុម្តេចបានជាអ្នកឃើញរូបកន្ទ្រព្រះ
នេះហើយក៏យំដូច្នេះ គួនហ៊ិនឆ្លើយថា រូបនេះហើយគឺបិតារបស់ខ្ញុំ តា
ចាស់ឮដូច្នោះក៏ពិគ្រោះ មើលបែបភាពរូបកន្ទ្រធៀបនឹងរូបមុខមាត់គួនហ៊ិន
ប្រហែលគ្នា ទើបក្រាបសិរសាសំពះគួនហ៊ិន ៗក៏សួរថា ហេតុប្រការ
ម្តេចបានជាគូររូបបិតាខ្ញុំទុកដូច្នេះ តាចាស់ឆ្លើយថា រូបលោកនេះកាលនៅ
រស់នៅឡើយ រមែងឫទ្ធិឮល្បី មនុស្សប្រុសស្រីស្រឡាញ់រាប់អានគ្រប់
កន្លែង លុះលោកនេះធ្វើកាលកិរិយាក្ស័យជីវិតទៅ ក៏នៅបានជាទេពារក្ស
សិទ្ធិស័ក្តិពូកែណាស់ ហេតុនេះទើបមហាជនទាំងឡាយនាំគ្នាខ្វល់ខ្វាយ
គោរពរាប់អានជាទីពឹងពំនាក់ គូររូបលោកមកដាក់ទុកបូជាគ្រប់គ្រឹហា·
ស្ថាន ថាហើយតាចាស់ក៏ចូលទៅលើកថាសបានអាហារមកឲ្យគួនហ៊ិន
បរិភោគ ហើយតាចាស់ក៏ចុះទៅដឹកសេះគួនហ៊ិនមកចងទុកក្រោមផ្ទះ
ហើយឡើងមកបិទទ្វារផ្ទះរៀបនឹងនិទ្រា ។

ឯក្លួបៀនដែលរត់ពីគួនហ៊ិនទៅ លុះយប់ជ្រៅហើយក៏បរសេះគេច
គ្រឡប់រកផ្លូវនឹងវេះទៅឲ្យផុតពីដៃគួនហ៊ិន ជាបែជន្យកម្មនាំបណ្ដាលឲ្យ
ក្លួបៀនវង្វេងមាគ៌ាទៅពារលើផ្ទះតាចាស់ដែលគួនហ៊ិនសំណាក់នោះ លុះ
ក្លួបៀនក្រឡេកទៅឃើញផ្ទះរក្សរក្ខក៏ដម្រង់ចូលទៅ ហើយចុះពីលើសេះ

ដើរចូលទៅដល់ទ្វារផ្ទះគោះហៅពីក្រៅ គ្រានោះតាចាស់កំពុងនិយាយនឹងគួនហ៊ុនក្នុងផ្ទះ លុះឮសូរគោះទ្វារហៅពីក្រៅ ក៏ក្រោកដើរសំដៅទៅសួរថា នណាហៅ មានការអ្វីមករកយើងថ្មើរណោះ កួចៀងឆ្លើយថា ខ្ញុំឈ្មោះកួចៀងទាហានស្រុកកាំងតាំង មកពីចម្បាំងសុំសំណាក់១យប់ ព្រឹកឡើងនឹងទៅ ។

គួនហ៊ុនឮច្បាស់ថាឈ្មោះកួចៀង ក៏ផ្អៀងខ្លួនលូកទៅចាប់ដាវ ក្រោកស្ទុះក្លុតទៅដល់មាត់ទ្វារ តាចាស់ម្នីម្នាបើកទ្វារឡើងភ្លើងចាំងទៅឃើញច្បាស់ គួនហ៊ុនស្រែករ៉ស់ថា អាទាហានស្រុកកាំងតាំងជាហើយ អាឯងកុំរត់ គួនហ៊ុនក៏លោតទៅកាប់ កួចៀងក៏គេចប្រញាប់រត់ទៅដោយឮសំឡេងច្បាស់ជាគួនហ៊ុនក៏ភ័យណាស់ ទទួលគ្រះឡេកទៅឃើញគួមអ៊ូដែលស្លាប់នៅឈរពាំងពីមុខ កាន់ដាវលើកឡើងនឹងកាប់ក៏ដូចគេភ្ញាក់ដួលចុះ គួនហ៊ុនក៏ស្ទុះទៅទាន់កាប់កួចៀងស្លាប់នៅទីនោះ ហើយយកដាវរបស់គួនអ៊ូជាបិតា ដែលកួចៀងយកបានទៅនោះបានមកវិញ ហើយក៏ពុះទ្រូងអាវយកថ្លើមបេះដូងកួចៀង ឡើងទៅធ្វើពលីការសែនឲ្យបិតាលើផ្ទះតាចាស់ រួចកាត់យកក្បាលកួចៀងចងព្រនាក់នឹងកែបសេះ លុះព្រឹកឡើងគួនហ៊ុនក៏លាតាចាស់ឡើងសេះត្រឡប់ទៅ ឯតាចាស់នោះលុះឃើញគួនហ៊ុនទៅហើយគិតខ្លាចខុស ក៏អូសខ្មោចកួចៀងទៅផុតរំលាយបង់ ។

ខណៈនោះម៉ាគុងជិះសេះបែករត់ក្នុងព្រៃ ពួកទាហានក៏រៀសរវៃតាមអោប្រហែល ២០០ នាក់ ប្រទះនឹងគួនហ៊ុនព្រនាក់ក្បាលកួចៀងបរតម្រង់មកក៏នឹកខឹងណាស់ បំបោលសេះចូលទៅព័ទ្ធគួនហ៊ុន ៗ ឃើញម៉ាគុងជាពួកកួចៀងក៏ខឹងណាស់បរសេះចូលទៅប្រយុទ្ធគ្នា ពួកទាហានម៉ាគុងក៏ស្រែកហៅគឹកកងចូលទៅព័ទ្ធជុំវិញខ្លួនគួនហ៊ុន ។

វេលានោះទៀវចៅដែលលើកគ្នាទៅតាមរកគួនហ៊ុន លុះឮសំឡេងហៅក៏បន្ទំបរសេះដេញទាហានរុកបំពានចូលទៅ ខាងម៉ាគុងឃើញទ័ពជំនួយមកច្រើនណាស់ក៏ក្រឡាស់ថយរត់ទៅ ទៀវចៅក៏សន្ធឹងដេញតាមពីក្រោយអោប្រទះនឹងគួនហ៊ុន ហើយក៏នាំគ្នាដេញសង្កិនទៅប្រហែល ៥០ សិនមិនទាន់ក៏នាំគ្នាត្រឡប់មកវិញ ទៀវចៅនិងគួនហ៊ុននោះមិញក៏លើកទ័ពចូលទៅក្រាបបង្គំគាល់ព្រះចៅឡេវពី ថ្វាយក្បាលកួចៀងហើយក៏ពណ៌នារឿងរ៉ាវថ្វាយទ្រង់ព្រះសណ្ដាប់គ្រប់ប្រការ ព្រះចៅឡេវពីក៏ទ្រង់មានព្រះទ័យសោមនស្សពន់ប្រមាណ នឹកសរសើរទៅដល់គួនអ៊ូថាឫនអញពេញជាជាតិទាហានមិនបង់សន្ដានដែលបានស្រឡាញ់គ្នាមកនោះឡើយ សូម្បីស្លាប់ទៅជាខ្មោចហើយ ក៏នៅឧស្សាហ៍តាមទៅជួយកូនឲ្យបានសងសឹកនឹងខ្មាំងសត្រូវជាគូព្យាបាទ ហើយត្រាស់បង្គាប់ឲ្យអាមាត្យរៀបតុតាំងលៀងភោជនាហារប្រទានទៀវចៅ, គួនហ៊ុនបរិភោគជាមួយនឹងទាហានទាំងពួង ។

ឯម៉ាគុនដែលរត់ទៅក៏ប្រទះនឹងហាន់គុង, ដីវថាយ ហើយគិតគ្នាតាំងបន្ទាយបញ្ចុះបញ្ចូលប្រមូលទាហានដែលបែករត់ចូលព្រៃ លុះបានទាហានច្រើនហើយ ក៏ចាត់ចែងឲ្យយាមល្បាតលាតត្រវែល មើលផ្លូវក្រែងសត្រូវលើកទៅញាំញី ម៉ាគុនក៏ថា ទឹងតាំងនៅទីកន្លែងជាមួយគ្នាមិនស្រួលទេ ត្រូវឲ្យហាន់គុង, ដីវថាយរក្សាបន្ទាយនៅទីនេះចុះ ខ្ញុំនឹងប៊ីហាង, ប៉ៅសួយពិននឹងលើកទាហានទៅតាំងបន្ទាយនៅដំបន់កាំងជូ នោះហាន់គុង ដីវថាយក៏យល់ឃើញត្រូវ ម៉ាគុនក៏ចាត់ចែងចែងទាហាន ហើយក៏លើកទ័ពទៅបោះបន្ទាយនៅដំបន់កាំងជូ ។

ក្នុងពេលយប់នោះ ទាហានទាំងពួងក៏ស្រែកយំទ្រហឹងក្នុងបន្ទាយ ប៊ីហាងឮដូច្នោះ ក៏ពិគាល់ក្នុងចិត្តណាស់ ទើបផ្ទៀងត្រចៀកស្តាប់សព្ទសំដី តើពួកវានឹងនិយាយគ្នាប្រការម្តេចខ្លះ ឮទាហានពួក១ យំនិយាយគ្នាថា យើងពល់គ្នាសុទ្ធតែទាហានស្រុកគេងជីវ ព្រោះអាលីបទ៉ាធ្វើកលឧបាយ ឯប៊ីហាងនិងប៉ៅសួយពិនសោត វាក៏ជាតួកលសឹកខាងក្នុង បានជាខូចបង់ស្រុកគេងជីវ ចំនែកខ្លួនអ៊ូចៅហ្វាយយើងក៏ស្លាប់អសារ ខ្លួនយើងពល់គ្នាក៏ធ្លាក់មកជាទាហានស្រុកកាំងតាំង ឥឡូវព្រះចៅឡេវពីក៏លើកទ័ពមកច្បាំងព្រះអង្គឯងហើយ កាលណាឡើយស្រុកកាំងតាំងនឹងគង់នៅបាន

(នៅមានត)

# ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត

ដែលមាននៅពុទ្ធសាសនបណ្ឌិត្យ

លោកញ៉ុក-ថែម រៀបរៀង

---

បំណងដើម : "សាស្ត្រា សុបិនសៀម" .

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : ក៏មិនបានបញ្ជាក់ក្នុងអត្ថបទ .

របៀបនិពន្ធ : ពាក្យកាព្យ បទភាគគតិ – ព្រហ្មគីត – កុដង្គ.
លីលា ពំនោល ។

ប្រភពរឿង : ឥទ្ធិពល ពុទ្ធនិយមផ្សំនឹងទំនៀមទម្លាប់ស្រុក ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ២៩ សន្លឹក ឯកសារ
នេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តបឹង
ខ្យាងដែរ ចុះលេខ ១៤០៨ ។

អត្ថបទផ្ដើម : ៙ នមាមិហំ ពុទ្ធសេដ្ឋំ លោកុត្តមោ គុណគុណំ
សព្វធម្មោ វិយដេយ្យោ មារសេនំ ។ . . .

. . . . . . . . . . . . . .

អញខ្ញុំសូមពរ  អស់ទេពនិករ  ជ្រោម
ជ្រែងរក្សា  សួគ៌សោឡសព្រហ្ម  សូមសុំចេស្តា
និរនេសទុក្ខា  សុខសព្វកត្រ៌ ។  សូមគបអំបូរ
អម្បាលត្រកូល  ត្រកាលជាតិ  ជាខត្តិយេ
វិសេសធិបតី  ធិបតិន្ទជាឥ – សូរសព្វភូមិឋាន ។
. . . . . . . . .  . ។ល។

អត្ថបទបញ្ចប់ :  ហៃជនទាំងឡាយ  ស្តាប់ពាក្យបរិយាយ  និទាន
នេះណា  ត្រង់ត្រាប់ស្តាប់ធម៌  ប្រសើរថ្លៃថ្លា
ព្រះអង្គទេសនា  ប្រោសសត្វសព្វឋាន ។  គួរ
គិតឧស្សាហ៍  ធ្វើបុណ្យ បាជ្ញា  សន្សំឲ្យបាន
មគ្គផលជាស្បៀង  ចៀសវាងបាតកឋាន  អបាយ
ឲ្យបាន  ដល់និព្វានហោង ។

x x x

បំណាងជើង :  « សាស្ត្រាសេចក្តីមាតុគុណថ្លៃង »

អ្នកនិពន្ធ :  រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ :  គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ : បទកាកគតិ ។

ប្រភពរឿង: បុត្រមានចិត្តកតញ្ញូ ចំពោះមាតា ឥទ្ធិពលពុទ្ធ-និយម ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ១៧ សន្លឹក ។ ឯកសារនេះ បានមកពីណា គ្មានបញ្ជាក់ទេ ចុះលេខ ឯកសារ ១៤០៨ ។

អត្ថបទផ្ដើម: ១ បទកាកគតិ ។ អហំវន្ទា កាច់កាយចិន្តា
បីតិព្រមផង លុតលើកហត្ថា សោភាទាំងផ្សេង
ផ្គរផ្គាប់ផ្គត់ផ្គង ដាក់ដល់សិរសា ។ ស្មើផ្កា
ឈូកធំ ទិព្វគន់ឧត្ដម ប្រសើរថ្លៃថ្លា ថ្វាត់ថ្វាយ
បង្គំ ប្រណមវន្ទា នៃព្រះភគវា សារពេជ្ញ
ញាណញេយ្យ ។ . . . . . . . ។ល។

អត្ថបទបញ្ចប់: អស់អាថ៌និយាយ យើងខ្ញុំស្រស់ស្រាយ ស្រេច
ចារចម្លង ក្នុងព្រះសាសនា ប្រែជាបទហោង
តាមដោយគន្លង ព្រះធម៌ថ្លាថ្លៃ ។ ពោះគាប់

ទោះខុស ទោះលើសទោះលស់ ពាក្យផងដទៃ
ក្រែងលោកឯណា ប្រាជ្ញាឈ្លាសវៃ សូមលោក
ប្រស្រ័យ ជួយតម្រង់ផង ។ បើអ្នកឯណា
មួយមានប្រាជ្ញា ធ្វើដោយគន្លង បានជាសេរ
សេរ ជាកេរ្តិ៍ផលផង អ្នកនោះឯងហោង ប្រ
សើរពេកក្រៃ ។ គួរចាំគួរស្តាប់ គួររួសត្រង់
ត្រាប់ តាមច្បាប់នេះនៃ និងបានសម្បត្តិ សួគ៌
ថ្កាត់ថ្កាថ្លៃ រៀងរួចដល់ព្ទ ត្រើយនិព្វានហោង ។

x x x

បំណាច់ជើង : "សាស្ត្រា ច្បាប់ក្រមធំ"(១)

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : កវីឥតបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ : បទកាកគតិ និងបទព្រហ្មគីតិ ។

---

១– ច្បាប់ក្រមធំនេះ មានលក្ខណៈប្លែក ពីច្បាប់ប្រុសដទៃទៀតជាច្រើន ។ ពាក្យទូន្មានគ្រូ បង្ហាញសិស្សឲ្យចេះគោរព ទំនៀមទំលាប់ស្រុក និងប្រពៃណីរបស់សង្គម ក្នុងសម័យដែលខ្លួនរស់នៅ ដើម្បីជៀសវាង នូវគ្រោះថ្នាក់ និងឧបសគ្គផ្សេងៗ ក្នុងការសាងជីវភាពរបស់ខ្លួន ព្រមទាំងជឿគោរពប្រតិបត្តិ តាមច្បាប់ព្រះពុទ្ធផង ។

ប្រភពរឿង: គ្រូបង្ហាត់សិស្សតាមប្រពៃណី និងតាមសីលធម៌ពុទ្ធនិយម ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ១៥ សន្លឹក ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តបឹងខ្យាង ចុះលេខ ១៤០៥ ដែរ ។

អត្ថបទផ្ដើម: ៙ នេះបទកាកគតិ ។ ខ្ញុំអរទុនអង្គ ទន្ទាបក្រាបក្រុង ក្រញ្ញក្រាបអាត្មា លុតលើកទសករ ប្រៀបប្រពហត្ថា ដោមដាក់សិរសា ក្រាបថ្វាយបង្គំ ។ សម្ដេចព្រះស្រី មុនីធិបតី សព្វញ្ញូជាធំ គ្រប់គ្រងទេវតា សុភវង្សព្រហ្ម ស្ដែងស្ដេចតែងបំ – បាត់បាបសម្ងាយ ។

. . . . . . . . . . ។ល។

អត្ថបទបញ្ចប់: ខ្ញុំនគ្រូចាស់ណាស់ហើយ ហៃសិស្សអើយ ស្ដាប់ពុទ្ធដីកា ររកដោយកាមា ទុនត្រង់ត្រាប់ ស្ដាប់ឲ្យបាន ។ គ្រូចាស់ដកនៅ ទុកពាក្យនៅតែងទូន្មាន ទុកឲ្យជាប្រធាន ស្មើគ្រូនៅ

បានរក្សា ។ គ្រូប្រដៅសិស្សទេ វែងធ្វេសធ្វើ
ក្មេងពុទ្ធដីកា ឥឡូវចងសាស្ត្រា ជាសាក្សី
បន្ទាល់ទុក ។ ផ្ដែផ្ដាំសព្វសេចគ្រប់ អ្នកណា
ក្មេងតទៅមុខ បើអ្នកមានក្ដីទុក្ខ រីឯទោសពុំ
ដែលត្រូវ ។ ត្បិតចារទុកជាច្បាប់ ប្រដៅប្រាប់
ប្រៀបផ្គាប់ផ្គូរ ព្រោះឯងក្មេងពាក្យគ្រូ គឺកម្ម
ពៀរខ្លួនឯងហោង ។ បរិបូណ៌ស្រេចគ្រាន់
គ្រប់ បានជួបចប់អស់បរិយាយ ចាំពាក្យណា
អ្នកកាយ ជាស្បូរេចម៉្ទេះឯងហោង ។

x x x

បំណងជើង: "សាស្ត្រា ច្បាប់ថ្មី"

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ : បទព្រហ្មគីតិ ។

ប្រភពរឿង: ពាក្យទូន្មាន តាមលំអានសុជីវធម៌ និងប្រពៃ-
ណីខ្មែរជំនាន់ដើម ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៧ សន្លឹកកន្ទះ ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្តព្រែកថ្មី កាលពី គ.ស. ១៩៤៣ ចុះលេខ ១៤០៥ ដែរ ។

អត្ថបទផ្ដើម: ៙ ចែងចង់ជាច្បាប់ច្បង តាមទំនងបទព្រហ្មគីតិ ខ្មែរលាវសៀមព្រេងព្រឹទ្ធ ទូវចិនយួនបេះពាក្យ ខ្មែរ ៗ គួរចងចាំដាក់អង្គ គួរតម្រង់ចិត្តឲ្យទៀង គួរគិតកុំឲ្យឃ្លៀង ជាលក្ខណ៍ក្នុងប្រុងគំនិត ។ . . . . . . . . ។ល។

អត្ថបទបញ្ចប់: បើអ្នកណាមួយមើល កុំថាព្រើលលើកពុំត្រូវ កុំសើចដៀលខ្ញុំគួរ សូមតម្រូវតម្រង់ផង ។ នោះបីបើខាតខុស ក្រែងលើសលស់ពាក្យគ្គាំគង់ ពុំត្រូវដោយទំនង មិនដូចច្បាប់ព្រេងមកនៃ ៗ កិច្ចកាព្យពាយរៀបនោះ ច្បាប់ចំពោះពីបុរាណ ចែងចប់កាព្យនិទាន សូរេចត្រឹមម៉ោះឯងហោង ។

x x x

បំណងជើង: "សាស្ត្រាល្បើកកង់អវិជ្ជា"

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ : បទពាក្យ ៧ ។

ប្រភេទរឿង: ទស្សនៈពុទ្ធនិយម ១ អំពីអវិជ្ជា នាំបណ្ដាលឲ្យ ឲ្យកើតហេតុបច្ច័យ ទាក់ទងគ្នាត ៗ ទៅទៀត ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ១១ សន្លឹកកន្ទះ . ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានចារចម្លងទុកតាមច្បាប់វត្ត អង្គស ស្រុកគគីរ ខេត្តកណ្ដាល កាលពី ព.ស. ២៤៨៧ ចុះលេខសាស្ត្រា ១៣៩៩ ។

អត្ថបទផ្ដើម: ៙ នមោ ខ្ញុំសូមនមស្សការ ថ្វាត់ថ្វាយកាយា ជីវិតតាំង ពុទ្ធធម៌សង្ឃកំង យាវនិព្វានំដល់ និព្វាន ។ . . . . . . . . . . .

. . . . . . . ។ល។ . . .

អត្ថបទបញ្ចប់: ដូច្នេះ គួរចាំគួរឧស្សាហ៍ រកព្រះធម៌ថ្លាកែវ មាសស្អុំ ជាព្រះខ័នពេជ្រកាត់ចំណង ពាក់ទោសដែលចង ៤ ប្រការ ។ គួររក្សាសីលគិតធ្វើទាន សីលសោតជាយានទានអាហារ និងដើរនិងហោះហើរទៅណា សីលសោតបាន ក្លាជូនដល់ឋាន ។ មានតែពុទ្ធលោកនាំទៅ ធម៌មិននៅទៅតាមប្រាណ សង្ឃនាំផ្លូវជូនដល់ឋាន ឲ្យបានដល់សុខគឺនិព្វាន ។

x x x

បំណងជើង: " លោកព្រះធម្មត្រាស់ "

អ្នកនិពន្ធ: ព្រះបាឡាត់ពោធិពម នាម . . ?

កាលបរិច្ឆេទ: ឆ្នាំរកានពស័ក ពុទ្ធសករាជ ២៤៤០? (ប្រហែលជា ព.ស. ២៤៤០ ដូច្នេះវិញទេ?) ។

របៀបនិពន្ធ: ពាក្យកាព្យ: បទពាក្យ ៧ ។

ប្រភពរឿង: ថ្លែងអំពីពុទ្ធប្រវត្តិដោយសង្ខេប ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៤៣ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានចាត់ឲ្យ

ចារចម្លងតាមច្បាប់វត្តអង្គស គគីរ (កណ្ដាល)
កាលពី គ.ស. ១៩៤៤ ចុះលេខ ១៣៩៩ ។

អត្ថបទផ្ដើម: ៙ តាំងជាល្បិចល្បើកលើកបែងចង តាម
ដោយទំនងពង្សាវតា. ធិបតីច្បាប់ចងអក្ខរា ក្នុង
ឆ្នាំកានពស័ក ។ ពុទ្ធសករាជ អាចគណនា
ពីរពាន់ត្រូវជាប្រាំរយជាក់ (?) និងសែសិបគត់
កំណត់ស័ក តែងទុកឲ្យអ្នកផងមើលលេង ។

. . . . . . ។ល។ . . . .

អត្ថបទបញ្ចប់: ខ្ញុំសូមឲ្យបានសេចក្ដីសុខ កុំឲ្យមានទុក្ខក្នុងអា·
ត្មា ត្រឡប់ទៅកើតទីឋានណា អស់មនុស្ស
រាល់គ្នាសឹងចូលចិត្ត ។ គំនិតចិត្តត្រង់នឹងអាត្មា
កុំបីមិច្ឆាទិដ្ឋិជិត មាតាបិតាក៏ស្មោះពិត ខ្ញុំសូម
ឲ្យជិតត្រាសបញ្ញា ។ សាងសូមប្រាថ្នាសច្ចា
កាត់ ឲ្យខ្ចាត់អំពីវដ្ដសង្សារ មកកើតហើយ
ស្លាប់ក្ដីវេទនា ឲ្យបានសម្រេចនិព្វានហោង ។

x x x

បំណងជើង: "សាស្ត្រា ច្បាប់ប្រុសនិងច្បាប់ស្រី(១)"

អ្នកនិពន្ធ: ភិក្ខុ ស៊ុម ។

កាលបរិច្ឆេទ: ថ្ងៃព្រហស្បតិ៍ ខែស្រាពណ៍ ឆ្នាំថោះឯកស័ក ព.ស. . . . ?

របៀបនិពន្ធ: កាព្យពាក្យ ៧ ។

ប្រភពរឿង: ច្បាប់ទូន្មានកូនប្រុសស្រី តាមប្រពៃណី និងច្បាប់សីលធម៌ ពុទ្ធនិយម ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ២៤ សន្លឹកកន្ទះ ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានថតចម្លងតាមច្បាប់សាស្ត្រាវត្តព្រែកថ្មីង ចុះលេខ ១៤០៥ ។

---

១– ច្បាប់ប្រុសនិងច្បាប់ស្រី បានក្រងជាច្បាប់តែមួយជាប់ជាមួយគ្នានេះ មានលក្ខណៈប្លែកពីច្បាប់ប្រុស ឬច្បាប់ស្រី ទាំងវិធីនិពន្ធ ទាំងអត្ថន័យ ដែលបញ្ជាក់ឲ្យយើងយល់ថា "ច្បាប់ប្រុសនិងច្បាប់ស្រី រួមគ្នាតែ ១ ខ្សែនេះ មានចំនួនដល់ ២៤ សន្លឹកកន្ទះ ប្រហែលជាច្បាប់ដែលគេទើបនិពន្ធឡើងជាន់ក្រោយទេ ! ព្រោះច្បាប់នេះ ប្រើរបៀបនិពន្ធជាកាព្យពាក្យ ៧ ។ ឯច្បាប់ចាស់ច្រើនប្រើ បទកាកគតិ ពំនោល ព្រហ្មគីត ភុជង្គលីលា ។

អត្ថបទផ្ដើម: ៙ ឮទេសការនៅថ្ងៃព្រហស្បតិ៍ ខែស្រាពណ៍

ឆ្នាំថោះឯកស័ក វស្សានរដូវត្រូវភ្លៀងធ្លាក់

ត្រជាក់ស្ងុនស្ងំមលន្ទំមចិត្ត ៗ រងាព្រួចព្រឹសស្ទើរ

ស្រៀវគ្រុន ស្រពោនស្រពន់ពុំស្បើយស្បិត

ពេលក្ដៅសែនក្ដៅពន់ពេកក្ដិត បែកញើស

ផាបផិតហូរហៀង ៗ . . . . . .

. . . . . . . ៗលៗ

អត្ថបទបញ្ចប់: វាចាម្ដាយទុកខ្លួនថា សូរបេនិទានតាមបទ

បាទ លៃលកកែកាព្យទុកជាខ្នាត ក្រែងខាត

លើសលស់ខុសមាត្រា ៗ ពុំគាប់ពុំស្ទួនពាក្យ

ពេចន៍ គន្ធងកន្ទេចកន្ទៀតណា កុំសើចតិះ

ដៀលដំណៀលថា មេត្តាលបប្រៀតធ្មៀតធ្លាក់

ទៅ ៗ ខ្ញុំក្រែងសេចក្ដីខ្លីគំនិត ទើបរៀនកែគិត

កាព្យនេះកូវ ប្រឡោះប្រឡាសផ្ដាសពុំត្រូវ

ស័យសុនដោយនូវគំនិតពាល ៗ ខ្ញុំប្រឹងតតោះ

ដោយចិត្តបង់ លើកខ្លួនអង្គប្រុស·ស្រីស្រាល

ឲ្យគ្រន់ឲ្យស្ដាប់គ្រប់អម្បាល កុំឲ្យគ្រអាល
ដោយតណ្ហា ។ សំដែងតាក់តែងតាមបូរេបទ
សូរេច ប្រាកដពាក្យពិតណា ទាំងស្រីទាំងប្រុស
គ្រប់ប្រការ សូរេចនូវមហានិព្វានហោង ។

x x x

បំណងជើង: "សាស្ត្រា កូនចៅល្បើក"

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ កង់អត្តបទ ។

របៀបនិពន្ធ: ពាក្យកាព្យ បទកាកគតិ និងបទព្រហ្មគីត ។

ប្រភេទរឿង: ទូន្មានកូនចៅខ្មែរ តាមប្រពៃណី ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៨ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមក
អំពីវត្តបឹងខ្យាង ចុះលេខ ១៤០៥ ។

អត្ថបទផ្ដើម: ● នេះបទកាកកត់ ទើបចងជាបទ តាមដោយ
គន្ថង ព្រេងព្រឹទ្ធបុរាណ អ្នកប្រាជ្ញនិទាន
ប្រដៅបុត្រភ្វា ។ ហៃកូនពន្លក ស្ងួនអើយ

ECOLE ... BIBLIOTHEQUE D.P. D'EXTREME

មាសយក បណ្ដាំបិតា ឪពុកនេះចាស់ ឥតអ្វី

ឲ្យបា សូនអើយក្មេង ពាក្យជីពុកនៅ ។ នុ

កូនកំសត់ រៀនទុនរៀនអត់ រៀនគិតក្នុងក្រៅ

រៀនទុនលំទោន កុំឲ្យហួងសៅ ជិតជល់ខ្លួន

ពៅ កើតដល់ជីពុក ។ . . . . .

. . . . . . ។ល។

អត្ថបទបញ្ចប់: អ្នកទាបវែងស្អប់ខ្ពស់ ត្បិតពឹងយសគេពុំបាន

អ្នកក្រត់ស្អប់អ្នកមាន ត្បិតពុំបានឲ្យពឹងទ្រព្យ ។

អ្នកខ្លៅវែងស្អប់បេះ ត្បិតតម្រេះគិតគំនាប់ អ្នក

ខ្ពស់វែងស្អប់គាប់ ត្បិតគេពប់តែអ្នកត្រូវ ។

ពាក្យនេះអស់ម៉ែះហើយ កូនចៅអើយ

យកទុកទៅ កុំឲ្យអាប់អាសៅ . . .

. . . (បាត់) ។ ពាក្យនេះស៊ើខ្លួន

ហើយ កូនចៅអើយចាំគ្រប់ប្រាណ អស់អាថិ

ទុកទាន ជាសូរេចម៉េះឯងហោង ។

x x x

ចំណងជើង: " សាស្ត្រា ព្រះឥសូរលេងពួន(១) "

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាយ ជាលំនាំទេសនា ។

ប្រភពរឿង: ការបរាជ័យនៃព្រះឥសូរ គឺការបរាជ័យនៃលទ្ធិព្រាហ្មណនិយម (ព្រះឥសូរសុំចុះចូលកាន់ព្រះពុទ្ធសាសនា) ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ២៧ សន្លឹក ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានចារចម្លងតាមវត្តអង្គស (គគីរ កណ្តាល) កាលពី គ.ស. ១៩៦៦ ចុះលេខ ១៣៩៩ ។

---

១– ឯកសារនេះ សមតែកើតឡើងជាយូរអង្វែងមកហើយ ក្នុងសម័យអង្គរ ឬចុងសម័យអង្គរ ព្រោះអ្នកនិពន្ធបានបង្ហាញឲ្យយើងដឹងថា កាលក្នុងជំនាន់នោះ មានការប្រណាំងប្រជែងខាងជំនឿចំពោះលទ្ធិសាសនា ហើយនៅចុងក្រោយបំផុត ជោគជ័យដ៏ធំធេងបានធ្លាក់ទៅលើពុទ្ធសាសនា ដោយតួអង្គអាទិទេព គឺព្រះឥសូរ សុខចិត្តចុះចូលថ្វាយខ្លួនចំពោះព្រះរតនត្រ័យ ។

ប៉ុន្តែ ប្រសិន ពិនិត្យពីពាក្យពេចន៍វិញ គេអាចស្មានថា គេទើបនិពន្ធឡើង ប្រហែលក្នុងសម័យលង្វែកទេ ។

អត្ថបទផ្តើម: ៙ កោសាធុពៅ ៗ ហៃសាធុសប្បុរសផង ទាំងឡាយអើយ យើងនិងថ្លែង សំដែងពណ៌នា សរសើរដំណើរនាកាលព្រះស្រី សារពេជ្ញា· ញាណជាអម្ចាស់នៃយើង ព្រះអង្គគង់ព្រះធម្មា នៅឡើយ ព្រះអង្គតែងព្រះហឫទ័យអាសូរករុ- ណា អស់លោកផងទាំងពួងនោះជាអចិន្ត្រៃយ ដែលទីងស្រុតលិចលង់ ផុងចូលទៅក្នុងព្វង សមុទ្រសាគរ គោលគឺកពវដ្តសង្សារ ប្រកឲ្យ អណ្តូងជ្រៅនោះឡើយ ។ . . . ។ល។

អត្ថបទបញ្ចប់: ហៃសាធុសប្បុរសផងទាំងឡាយអើយ នរជ្ជក ឯណាមួយ បានដឹងសភាពដូច្នេះហើយ ក៏ឲ្យ ប្រាសបង់នូវចិត្តមិច្ឆាទិដ្ឋិនោះបង់ហើយ មកយក ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាទំនាក់ដូចព្រះឥស្សូរ នោះហើយ ទោះយោបីនិងប្រាថ្នាជាព្រះឥន្ទ្រ ព្រះ ព្រហ្មជាស្តេចចក្រពត្តិរាជ នូវព្រះបច្ចេកពោធិអរ· ហន្តវីណាស្រេចផងក្តី ក៏សឹងបាន ទោះពុំនោះ

លោក និងព្រាហ្មណ៍ជាព្រះពុទ្ធ ក៏សឹងបាន
ប្រាកដ ដូចព្រះឥសូរនោះហោង ។
បពិត្រអើយ រយើងសំដែងថ្វៃនិទាននេះមិញ
និង្គីតំក៏ចប់ ឥតបការេន ជាសូរេចនូវប្រការ
អម្បាលណោះហោង ។

x x x

បំណងជើង : " សាស្ត្រា ក្បួនយោគី "(១)

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់កន្លងអត្ថបទ ។

របៀបនិពន្ធ : ពាក្យពេយ : ទំនងល្បើកទេសនា ។

ប្រភពរឿង : ទំនៀមទម្លាប់ និងប្រពៃណីពីបុរាណ ។

លក្ខណៈឯកសារៈ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៣៤ សន្លឹកកន្ទុះ

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានចារចម្លង

១– ក្បួននេះ សមជាក្បួនសម្រាប់ប្រើការក្នុងព្រហ្មញ្ញសាសនា ក្នុងសម័យបុរាណ ។ តមកៈក្រោយទៀត ប្រជាជនបានផ្លាស់ជំនឿថ្មី គឺបែរមកជឿគោរពពុទ្ធសាសនាវិញ ទើបគេបញ្ចូលឥទ្ធិពលពុទ្ធនិយមទៅក្នុងទំនៀមទម្លាប់ចាស់ទេដឹង ?

តាមច្បាប់ត្រអង្គស (គត់រ កណ្តាល) កាលពី
គ.ស. ១៩៦៤ ចុះលេខ ១៣៩៩ ។

**អត្ថបទផ្តើម:** ៙ បើបុគ្គល ជាមេបាយកាយោហើយ នោះឲ្យកូនចៅទៅនិមន្ត ព្រះអាចារ្យទាំង៤អង្គមកជាប្រធាន ។ អាចារ្យរូបក្ខន្ធ ១ អាចារ្យវេទនាក្ខន្ធ ១ អាចារ្យសញ្ញាក្ខន្ធ ១ សង្ខារក្ខន្ធ ១ ។ អាចារ្យទាំង៤នេះ សឹងប្រព្រឹត្តនូវសិក្ខាវិយាបថ ឲ្យរក្សាព្រះត្រៃសរណគមន៍ ហើយនូវសីល ៥ ៨ ១០ ឲ្យស្គាល់គុណ នូវទោស ស្គាល់ឪពុកទាំង ៥ ស្គាល់ម្តាយទាំង ១២ ម្តាយទាំង ៨ ស្គាល់បងទាំង ៣០ ឲ្យស្គាល់ញាតិកាទាំង ៧ ឲ្យស្គាល់អាពុកធំទាំង ៤ ស្គាល់ទេវតាទាំង ៤ ស្គាល់ទិស ៨ ១០ ៤ ស្គាល់អានិសង្សទាំង ៥ ព្រះមាតិកាទាំង ៨ . . . . . . . ។ល។

**អត្ថបទបញ្ចប់:** ឲ្យលោកអនុមោទនាថា សាធុ ៗ ហើយ នេះបាលីថាយចង្ហាន់សង្ឃ នេះគឺអ្នកនោះឯង ក៏តែងនិងបានផលអានិសង្សនាំនៃអង្គអាត្មា មាតាបិតា

ញាតិកាបុត្រភរិយា នោះរំដោះចាកចេញអំពីអស់
បាបពៀរវេរកម្ម នោះឲ្យជ្រះស្រឡះ បង់ចេញ
ទៅហោង ។

ឱកាស ឥមានិ សព្វបរិក្ខារានិ វត្ថចីវរាទីនិ
ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម ។ ទុកកត់វេរ អដ្ឋ
បរិក្ខារផ្កា ។ សុទិន្នំវត មេបិណ្ឌំ ឥទំ បិណ្ឌបាតំ
សប្បច្ចយោ ហោន្តុ ។ ទុកកត់វេរបិណ្ឌ ។
នេះសេចក្តីក្សេនយោគី សេចក្តីអស់តែប៉ុណ្ណោះ
ហោង ។

x x x

ល្បងសិក្សា

# ប្រវត្តិអក្សរសាស្ត្រខ្មែរ

ដោយ លាង ហ៍បអាន

សាស្ត្រាចារ្យ នាយកពុទ្ធសាសនបណ្ឌិត្យ

(ស្រង់ពីមេរៀនវិទ្យាស្ថានអប់រំខាងអក្សរសាស្ត្រ)

## អក្សរសាស្ត្រខ្មែរ

## ពីសម័យបុរាណ មកសម័យបច្ចុប្បន្ន(១)

### ១– ផ្ដើមសេចក្ដី

*មុននឹងលើកយកនូវមេរៀនមកសិក្សារៀបរាប់ គប្បីដឹងជាមុនសិន នូវកម្មវិធីសំរាប់ឆ្នាំសិក្សាទី ៦ ស្ដីអំពីអក្សរសាស្ត្រខ្មែរ សម័យបច្ចុប្បន្ន*

---

(១) សៀវភៅនិងអត្ថបទសំរាប់សិក្សាជំនួយមានដូចតទៅ :

— មើលឡើងវិញនូវមេរៀនទី ១០-១១-១២ របស់ ល.ហ.អ ឈ្មោះ "ប្រភេទអត្ថបទ" ទំព័រ ៤៨ ដល់ ៨៦ ឆ្នាំសិក្សា វ.អ.ស. ឆ្នាំ ១៩៦៥-៦៦ សំរាប់ឆ្នាំទី១ ។

— អត្ថបទសន្និសីទរបស់ សហ. ទ្រិញ-វ៉ាញ ប្រធានសមាគម អ្នកនិពន្ធខ្មែរ ឈ្មោះ "អំពីសមាគមអ្នកនិពន្ធខ្មែរ" ១៥-១១-៦៥ ។

— សៀវភៅ "អក្សរសាស្ត្រខ្មែរ" របស់ សហ. លី-ធាមតេង បោះពុម្ពលើកទី ២ ឆ្នាំ ១៩៦០ ចាប់ពីទំព័រ ៩២ តទៅ ។

— ទស្សនាវដ្ដី "កម្ពុជសុរិយា" ពិសេសពីឆ្នាំ ១៩៦៥-៦៦ ត្រង់អត្ថបទ "ឯកសារសាស្ត្រាស្លឹករឹត និងក្រាំងរបស់លោក ញ៉ុក ថែម និង "ឯកសារកម្ពុជសុរិយា" ប្រមូលរៀបរៀងដោយ សហ. ឌិក-គាម ។

ដែលចែកជាផ្នែកលំដាប់លំដោយគ្នាដូចតទៅ (១) ៖

– ការរៀនសារឡើងវិញ ដោយសង្ខេបអំពីប្រវត្តិអក្សរសាស្ត្រខ្មែរ លក្ខណៈនៃអក្សរសាស្ត្រសម័យដើម ។

–ពីអក្សរសាស្ត្រដើមមកអក្សរសាស្ត្រសម័យថ្មី លក្ខណៈនៃអក្សរ-សាស្ត្រដើមដែលនៅសព្វថ្ងៃ និងការផ្លាស់ប្ដូរផ្សេងៗ ។

– ដំណាក់ទាំង ២ នៃអក្សរសាស្ត្រសម័យបច្ចុប្បន្នពេលអាណាព្យាបាល និងក្រោយឯករាជ្យ - ការកត់ចំណាំអំពីការជ្រើសរើសវិជ្ជានិពន្ធ ។

– អ្នកនិពន្ធសម័យថ្មី (អ្នកនិពន្ធប្រលោមលោក កវី និង អ្នកនិពន្ធរឿងល្ខោន) និងគោលគំនិតថ្មីៗ - ការសិក្សាអំពីគួររៀន វិជ្ជានិពន្ធ ស្រូ-ចាយ - ការសិក្សាអំពីទំរង់អត្ថបទ :

– ទស្សនាវដ្ដី ឈ្មោះ "វិជ្ជាឋាន គរុកោសល្យ" លេខ ១ និង ២ ឆ្នាំ ១៩៥៨ ខែវិច្ឆិកា និងខែធ្នូ ១៩៥៩ ត្រង់អត្ថបទពាក់អ្នកនិពន្ធខ្មែរ របស់លោក ញ៉ុក ថែម ។

–អត្ថបទរបស់លោក កេង វ៉ាន់សាក់ ផ្សាយពីមហាវិទ្យាល័យអក្សរសាស្ត្រ ឈ្មោះ "ទិដ្ឋភាពខ្លះនៃអក្សរសិល្ប៍ខ្មែរ" តែងជាភាសាបារាំង ។

– ទស្សនាវដ្ដី "អក្សរសាស្ត្រខ្មែរ" លេខ ១៩ ឆ្នាំ ទី៣ ខែវិច្ឆិកា ១៩៦៤ ពិសេសអត្ថបទ សហ. អ៊ុក ម៉ន និងម៉ៅ ឡាយទេម ។

(១) គឺជា កម្មវិធីបង្រៀនអក្សរសាស្ត្រខ្មែរ នៅវិជ្ជាស្ថានអប់រំអក្សរសាស្ត្រ ឆ្នាំ ១៩៦៥-៦៦ និង ១៩៦៦ ៦៧ របស់សមាគមអ្នកនិពន្ធខ្មែរ ។

របៀបតែងនិងបែបសរសេរ ដោយមានរៀបរាប់ឈ្មោះអ្នកនិពន្ធផង - ការសិក្សាប្រៀបធៀបនឹងសម័យមុនៗ ឬនឹងអក្សរសាស្ត្របរទេសសម័យបច្ចុប្បន្នដទៃទៀត ។

- ការរិះគន់ជាទូទៅលើអក្សរសាស្ត្រសម័យបច្ចុប្បន្ន (រឿងប្រលោមលោក កំណាព្យ រឿងល្ខោន) ។ ទុសឋដែលត្រូវស្នើដើម្បីកែនូវគោលគំនិត ព្រមទាំងរបៀបតែងរឿង ។ សារៈសំខាន់នៃការរិះគន់ខាងអក្សរសាស្ត្រ ។

- បញ្ហានានាដែលចោទចំពោះអ្នកនិពន្ធសម័យថ្មី : ការបេះដឹងទូទៅ ការផុះគំនិត ការជ្រើសរើសវិជ្ជានិពន្ធ ការលំបាកខាងផ្លូវសម្ភារៈ (បោះពុម្ពផ្សាយសៀវភៅ ។ល។) មធ្យោបាយនានា សំរាប់ដោះស្រាយបញ្ហាទាំងនោះ ។

កត្តានៃការចំរើនរបស់អក្សរសាស្ត្រ : សមាគមអ្នកនិពន្ធខ្មែរ និងសកម្មភាពរបស់សមាគមនេះ មានការប្រជុំអក្សរសាស្ត្រ ការផ្សាយតាមវិទ្យុ សន្និសីទសាធារណៈ ប្រឡងអក្សរសាស្ត្រ ។ល។

- សកម្មភាពនៃរាជរដ្ឋាភិបាលក្នុងវិស័យអក្សរសាស្ត្រ ។

- មធ្យោបាយដើម្បីផ្សាយអក្សរសាស្ត្រ : ការសំរួលជារឿងភាពយន្ត រឿងល្ខោន និងរឿងផ្សាយតាមវិទ្យុ ។

- នៅគ្រាទស្សន៍ទៅអនាគត : តើត្រូវណែនាំអ្នកនិពន្ធក្នុងការបង្កើតអក្សរសាស្ត្រ (១) ឬទេ តាមមធ្យោបាយណា (វគ្គនាំអក្សរសាស្ត្រ សិក្ខាសន្និបាតអក្សរសាស្ត្រ វិជ្ជាបានអប់រំខាងអក្សរសាស្ត្រ ។ល។)

## ២- ឃ្លាភ្ជាប់សេចក្ដី

មុននឹងចូលទៅក្នុងការសិក្សាអំពីអក្សរសិល្ប៍ប្រវត្តិ ទៅតាមកាលសម័យនីមួយៗ យើងលើកយកកាលប្រវត្តិក្នុងប្រវត្តិវិជ្ជាខ្មែរយើងមកលាតត្រដាងជាពន្លឺនៃការសិក្សាសិន ។

## ៣- កាលប្រវត្តិតាមប្រវត្តិវិជ្ជា

តាមប្រវត្តិវិជ្ជា គេចែកសម័យកាលធំជា ៤ ផ្នែក (២) គឺ:

### សម័យកាលទី ១

សម័យនគរភ្នំ (Période du Royaume de la montagne)

គ្រិស្តសករាជទី ១ ដល់ទី ៦

---

(១) ការដាក់ថាអក្សរសាស្ត្រនេះ គឺដោយសរសេរតាមកម្មវិធីរបស់វិជ្ជាហិនទេ ។ តាមនៃត្រឹមត្រូវនៃពាក្យ = littérature (œuvre littéraire) ក្នុងទីនេះ គួរប្រើសព្ទថា អក្សរសិល្ប៍ វិញ ។

(២) យកតាមលំដាប់ប្រវត្តិវិជ្ជា របស់សហ. ខ្លង.សារិន មេរៀនសំរាប់មហាវិទ្យាល័យអក្សរសាស្ត្រ និងសៀវភៅប្រវត្តិវិទ្យា ឈ្មោះ Histoire du Cambodge របស់ Mlle M. Giteau, របស់ A. Leclère, A. Dauphin Meunier, អត្ថបទនានា និង ស្នាព្រះហស្តសម្តេចព្រះនរោត្តម-សីហនុ ។

## សម័យកាលទី ២

*សម័យមុនអង្គរ* (Période pré angkorienne) :

*ចាប់ពី គ.ស. ៥៥០ ដល់ ៨០២*

*ព្រះមហាក្សត្រសំខាន់ ៗ ខ្លះក្នុងសម័យកាលនោះមាន :*

- *ព្រះបាទភវវរ្ម័នទី ១ (គ.ស. ៥៥០-៦០០)* = Bhava-Varman Ier

- *ព្រះបាទមហេន្ទ្រវរ្ម័ន ចិត្រាសេន (គ.ស. ៦០០-៦១៥)* = Mahendra-Varnan Chitrasena

- *ព្រះបាទឥសានវរ្ម័ន ទី ១ (គ.ស. ៦១៥-៦៣៤)* = Içana Varman Ier

- *ព្រះបាទភវវរ្ម័ន ទី ២ (គ.ស. ៦៣៩-៦៥៥)* = Bhava-Varman II

- *ព្រះបាទជ័យវរ្ម័ន ទី ១ (គ.ស. ៦៥៥-៦៨១)* = Jayavarman Ier

## សម័យកាលទី ៣

*សម័យអង្គរ* (Période angkorienne)

គ្រិស្តសតវត្ស ទី៩ ដល់ទី១៤ (គ.ស. ៨០២ ដល់ ១៣៣៦)

ព្រះមហាក្សត្រសំខាន់ៗ ក្នុងសម័យកាលនេះមាន :

- ព្រះបាទជ័យវរ្ម័ន ទី២ (គ.ស. ៨០២-៨៥០) ដែលកសាងប្រាសាទដំបូងនៅភ្នំគូលែន : Jayavarman II
- ព្រះបាទជ័យវរ្ម័ន ទី៣ (គ.ស. ៨៥៤-៨៧៧) = Jayavarman III
- ព្រះបាទឥន្ទ្រវរ្ម័ន ទី១ (គ.ស. ៨៧៧-៨៨៩) = Indravarman Ier
- ព្រះបាទយសោវរ្ម័ន ទី១ (គ.ស. ៨៨៩-៩០០) = Yaçovarman Ier
- ព្រះបាទហស៌វរ្ម័ន ទី២ (គ.ស.៩៤១-៩៤៤) = Harshavarman II
- ព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស. ៩៤៤-៩៦៨) Rajendravarman
- ព្រះបាទជ័យវរ្ម័ន ទី៥ (គ.ស. ៩៦៨-១០០១) = Jayavarman V

ព្រះបាទសូរ្យវរ្ម័ន ទី១ (គ.ស. ១០០២-១០៥០) = Suryavarman Ier

ព្រះបាទឧទយាទិត្យវរ្ម័ន ទី២ (គ.ស.១០៥០-១០៦៦) = Udayadityàvarman II

– ព្រះបាទហស៌វរ្ម័ន ទី៣ (គ.ស. ១០៦៦-១០៨០) = Harshavarman III

– ព្រះបាទជ័យវរ្ម័ន ទី៦ (គ.ស. ១០៨២ ១១០៧) = Jayavarman VI

– ព្រះបាទធរណិន្ទ្រវរ្ម័ន ទី១ (គ.ស. ១១០៧-១១១២) = Dharanindravarman Ier

– ព្រះបាទសូរ្យវរ្ម័ន ទី២ (គ.ស. ១១១៣-១១៥០) = Suryavarman II

– ព្រះបាទជ័យវរ្ម័ន ទី៧ (គ.ស. ១១៨១-១២០១) = Jayavarman VII

– ព្រះបាទជ័យវរ្ម័ន ទី៩ (គ.ស. ១៣២៧-១៣៣៦) = Jayavarman IX

## សម័យកាលទី ៤

សម័យក្រោយអង្គរ (Période Post angkorienne) ចុងគ្រិស្តសតវត្សទី ១៤ ដល់សព្វថ្ងៃ ។ សម័យកាលនេះចែកបានជា ៣ ផ្នែកសំខាន់ៗ គឺ :

ផ្នែកទី ១. សម័យលង្វែក (Période de Lovèk) គឺចម្បាំងជាមួយសៀម មកទល់ការបាក់បង់លង្វែក (Des premières guerres siamoises à la prise de Lovèk) (គ.ស. ១៣៣៦-១៥៩៣) គឺចាប់ពីសម័យបាក់បង់អង្គរក្នុងរជ្ជកាលព្រះបាទ លំពង់ (១៣៤៦-១៣៥១) មកដល់រជ្ជកាលព្រះសត្ថា (Preah Satha) ។

ផ្នែកទី ២.- សម័យក្រុងឧដុង្គមានជ័យ (Période de Oudong) (គ.ស. ១៦១៨-១៨៥៩) ពីរជ្ជកាលព្រះបាទជ័យជេដ្ឋា (Chey Chettha, គ.ស.១៦១៧-១៦២៨) មកដល់រជ្ជកាលព្រះបាទអង្គ ឌួង (Preah Ang Duong, គ.ស.១៨៤៥ ១៨៥៩)

ផ្នែកទី ៣.- សម័យក្រុងភ្នំពេញ (Période de Phnom-Penh) ចាប់ពី គ.ស. ១៨៥៩ មកទល់សព្វថ្ងៃ ។

សម័យនេះចែកជា ៣ កាលទៅទៀតគឺ :

កាលទី ១.– សម័យអាណានិគម : (Pério de sons protectoral) ពីរជ្ជកាលព្រះបាទ នរោត្តមទី ១ (Preah Norodom Ier) គ.ស. ១៨៥៩ ១៩០៤ មកដល់រជ្ជកាលខាងដើម នៃព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម-សីហនុវរ្ម័ន** (S. M. Preah Norodom Sihanouk Varman) ថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ ។

កាលទី ២.– សម័យកាលឯករាជ្យ = Période de l'Indépendance ចាប់ពីថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ មកដល់ថ្ងៃទី ២ មីនា ១៩៥៥ (គឺក្នុងរជ្ជកាលព្រះបាទ **នរោត្តម-សីហនុ** វរ្ម័ន និងព្រះករុណាព្រះបាទសម្តេចព្រះ **សុរាម្រិត**)

កាលទី ៣.– សម័យសង្គមរាស្ត្រនិយម: — Période du Sangkum Reastr Niyum (ចាប់ពីកើត "សង្គមរាស្ត្រនិយម" ដែលសម្តេចព្រះ បិតាឯករាជ្យ ឯកភាពជាតិ ព្រះ **នរោត្តម-សីហនុ** ឧបយុវរាជទ្រង់បង្កើតឡើង គឺទី ២ មីនា ១៩៥៥ មកទល់សព្វថ្ងៃ)

ចុងរជ្ជកាលព្រះបាទសម្តេចព្រះ **សុរាម្រិត** កាញ្ចនកោដ-

និងសម័យសម្ដេចព្រះមហាក្សត្រិយានី ព្រះ **ស៊ីសុវត្ថិ កុសុមៈ** នារីរ័ត្ន ព្រះមាតាជាតិ និងព្រះ **នរោត្តម-សីហនុ** ព្រះប្រមុខរដ្ឋ ។

សំគាល់

*សម័យទី ៤ នេះ អាចចែកនិងហៅបានទៀតថា :*

ក) *ពី គ.ស. ១៨៥៩ ១៩៥៣ បុនវុឌ្ឍសម័យ :* — Période de la «Renaissance Nationale»

ខ) *ពីថ្ងៃ ៩ វិច្ឆិកា ១៩៥៣ ដល់ថ្ងៃទី ២ មីនា ១៩៥៥ សម័យគណៈបក្ស* (Période des partis)

គ) *ពីថ្ងៃ ២ មីនា ១៩៥៥ មក សម័យឯកភាពជាតិ :* Période d'Unité Nationale (*ឬសម័យសង្គម :* Periode du Sangkum)

## ៤– អ្នកនិពន្ធនិងស្នាដៃក្នុងសម័យកាលនីមួយ ៗ

### ទី ១– សម័យកាលទី ១

*( សម័យនគរភ្នំ គ្រិស្តសតវត្សទី ១ ដល់ទី ៦*[1] *គ.ស. ១ ដល់ ៥៥០)*

(១) សូមអានសៀវភៅ G. Coedès, Histoire ancienne des Etats hindouisés d'Extrême-Orient; — P. Pelliot, Le Founan; — A. Bergaigne, Inscriptions de Vo Canh XX Notices et Extraits de manuscrit. XXVII; — G Coedès, Inscriptions du Cambodge T. IV p. 96; សៀវភៅពុទ្ធសាសនា ២៥០០ (ទំព័រ ៩ ដល់ ១១០); Histoire du Cambodge de A. Lecler និង M Giteau ។

## ១- ក្សត្រក្នុងសម័យកាលទី ១

ក្នុង គ.ស. ៥០ ព្រះបាទ កៅណ្ឌិន្យ: Kaundinya និងនាងសោមា Soma (ឬ កៅណ្ឌិន្យ នាគីសោមា គឺព្រះថោងនាងនាគី ជាបឋមក្សត្រិយ៍)

- ទីក្រុងឈ្មោះវ្យាធបុរៈ Vyàdhapura (នៅបាភ្នំ Ba Phnom);

- មុនគ្រិស្តសតវត្សទី ៣ គឺព្រះបាទ ហួន-ហ្វាន់-ហ្វាង : Houen Phan Houang (ចូលទីវង្គតក្នុងព្រះជន្ម ៩០ ឆ្នាំ);

- តមកព្រះរាជបុត្រ នាម ហ្វាន់ ហ្វាន់ Phan-Phan (សោយរាជ្យបាន ៣ ឆ្នាំ កាន់សិវសាសនា គោរពឥស្សរជាធំ).

បន្ទាប់មកគឺព្រះបាទ ស្រីមារៈ Çri-Màra Surya Varman ឬ ហ្វាន់ ចេ ម័ន = Phan Tche-Man;

- ព្រះបាទធរណិន្ទ្រវរ្ម័ន (Dharnindra-Varman) ដែលបានឡើងសោយរាជ្យ បានប្រហារព្រះរាជបុត្រច្បងរបស់ព្រះស្រីមារៈ ប៉ុន្តែក្រោយនោះក្នុង គ . ស. ២៤០ ត្រូវរាជបុត្រព្រះស្រីមារៈមួយព្រះអង្គសងសឹកសម្លាប់ព្រះអង្គវិញ ;

- ចុងសតវត្សទី ៤ ព្រះបាទកៅណ្ឌិន្យវរ្ម័ន = Kaundinyavarman កាន់សិវសាសនានិងមហាយានសាសនាបានគ្រងរាជ្យ ។.

– រាជបុត្រនាម ស្រីឥន្ទ្រវរ្ម័ន = Çri Indravarman បានសោយរាជ្យស្នង បានផ្ញើរាជទូត ៣ លើកទៅប្រទេសចិនក្នុងរជ្ជកាលសុង = dynastie des Song គឺ គ.ស. ៦៣៦ , ៦៣៥ និង ៦៣៨ ;

– ព្រះបាទ ជ័យវរ្ម័ន = Jaya Varman (គ.ស. ៦៩០-៥១៦);

– ព្រះបាទ រុទ្រវរ្ម័ន = Rudra Varman (គ.ស. ៥១៦-៥៥០) បានផ្ញើរាជទូតពីរលើកទៅប្រទេសចិន គឺគ.ស. ៥១៧ និង ៥៣៩ ។

## ២– សាសនាក្នុងសម័យកាលទី ១

សាសនាដែលសំខាន់ក្នុងសតវត្សទី ១ ដល់ទី ៣ គឺព្រហ្មញ្ញសាសនា ។ គេគោរពព្រះឥសូរជាធំ គឺសិវនិយម = Çivaïsme ។ ចាប់ពីចុងសតវត្សទី៦ គេកាន់ព្រហ្មញ្ញសាសនាខាងសិវដដែលនៀ និងពុទ្ធសាសនាបែបមហាយាន ។

## ៣– លក្ខណៈនិងវិវត្តន៍នៃអក្សរខ្មែរពីសម័យបុរាណមកដល់បច្ចុប្បន្ន :

មុននឹងចូលទៅដល់ផ្នែកអក្សរសាស្ត្រ ក្នុងសម័យកាលនីមួយៗតាមប្រវត្តិសាស្ត្រ គប្បីដឹងនិងស្គាល់ខ្លះនូវលក្ខណៈវិវត្តន៍អក្សរខ្មែរយើងតាំងពីបុរាណកាល មកដល់បច្ចុប្បន្នកាលនេះ ។

តាមការសិក្សារបស់លោក ហ្ស៊ក ម៉ាស់ប៉េរ៉ូ (Georges Maspéro) ក្នុងសៀវភៅលោកឈ្មោះវេយ្យាករណ៍នៃភាសាខ្មែរ ( Grammaire de langue khmère ) (១) អក្សរខ្មែរតាំងពីដើមកំណើតមកទល់បច្ចុប្បន្នកាលនេះ មានការផ្លាស់ប្តូររូបលក្ខណៈចំនួន ១០ លើកហើយ ហើយក្នុងមួយលើកៗមានលក្ខណៈរូបឈ្មោះ ជំនាន់និងឆ្នាំ ឬសតវត្សដូចខាងតទៅ:

**លក្ខណៈទី ១** អក្សរបែបសិលាចារឹកហាន់ជ័យ, កើតក្នុងប្រមាណជាសតវត្សទី ៦ នៃគ.ស. ;

**លក្ខណៈទី ២** អក្សរបែបសិលាចារឹក **ទាលកន្ទេល** កើតក្នុងចុងសតវត្សទី ៦ ឬដើមសតវត្សទី ៧ នៃគ.ស.;

**លក្ខណៈទី ៣** អក្សរបែបសិលាចារឹក **អង្គជំនិក** (លោកសឺដែស ហៅថា សិលាចារឹក «**ភ្នីអង្គ**») ក្នុងគ.ស. ៦៦៧;

**លក្ខណៈទី ៤** អក្សរបែបសិលាចារឹក **ព្រះឥន្ទ្រកោសិយ** ក្នុង គ.ស. ៩៧០ ;

**លក្ខណៈទី ៥** អក្សរបែបសិលាចារឹក **ព្រះវិហារ** (លោកសឺដែស ហៅថា សិលាចារឹក «**តាវិហារ**») ក្នុងគ.ស. ១០០៦;

---

(១) សូមមើល Grammaire de langue khmere របស់លោក George Maspéro, Paris, Imprimerie nationale, Errest Leroux, Editeur, Rue Bonaparte, 28, 1915 ទំព័រ 48-49

បែបទី១... [illegible]

បែបទី២... [illegible]

បែបទី៣... [illegible]

បែបទី៤... [illegible]

បែបទី៥... [illegible]

បែបទី៦... [illegible]

បែបទី៧... [illegible]

បែបទី៨... [illegible]

បែបទី៩... [illegible]

បែបទី១០... [illegible]



# ជីវប្បវត្តិ

លោកគ្រូធម្មស្ប្រោ ឯក-ញឹម

កុមារ ឯក ញឹម មាតាឈ្មោះ ជ្រៀប អ៊ុំ បិតាឈ្មោះ សុខ-ឯក ជាតិភូមិដើមនៅ អូខ្សាច់ ឃុំបុស្សស្រុក ស្រុកព្រែកពោធិ៍ ខេត្តកំពង់ចាម លុះដីបាក់ច្រាំង ទើបចូងទៅនៅខាងត្រើយអន្លង់សារ ក្នុងឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម ។

ក្នុងគ្រួសារនេះ មានបងប្អូនរួមផ្ទៃជាមួយ ៧ នាក់ ឈ្មោះ ឯក សាំង ១ ប្រុស ឯក គួច ១ ប្រុស ឯក ស្វាយ ១ ប្រុស ឯក លឹម ១ ស្រី ឯក ជឹម ១ ប្រុស ឯក-អ៊ុ ១ ស្រី ឯក-ញឹម ១ ប្រុស រួមប្រុស ៥ ស្រី ២ ជា ៧ នាក់ ។

ឯកុមារ ឯក-ញឹម ជាកូនពៅអាយុ ៧ ឆ្នាំ បានរៀនអក្សរសាស្ត្រ និងធម៌អាថ៌ ក្នុងសំណាក់លោកគ្រូសូត្រ សុខ-កែវ ជាបងជីដូនមួយ ចេះស្ទាត់ល្មមបួសបាន លុះដល់អាយុ ១៥ ឆ្នាំបានបព្វជ្ជាជាសាមណេរ ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ព្រះនាម រស់ នៅវត្តសិរីបទុម ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម ហើយបានរៀនធម៌កម្មដ្ឋាន ក្នុងសំណាក់

ញោមប្រុស ១វស្សា ជន្មាយុ ១៦ ឆ្នាំ បានលាញោមព្រមទាំងគ្រូ ទៅនៅកោះគេរជាភ្នំពេញ ក្នុងសំណាក់ព្រះសាក្យបុត្រ សុខ កែវ ជាគ្រូជាបង់ជាចៅអធិការវត្តកោះនោះ ហើយបានសិក្សាបាលីភាសាក្នុងសំណាក់លោកគ្រូអាចារ្យ អ៊ុន លុះជន្មាយុ ២១ ឆ្នាំបានឧបសម្បទាជាភិក្ខុ ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ព្រះនាម រស់ មានព្រះតេជព្រះគុណព្រះនាម សូ-គឹម និងព្រះនាម សុខ-កែវ ជាកម្មវាចាចារ្យ ក្នុងវត្តសិរីបទុម ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម ព្រះឧបជ្ឈាយ៍ឲ្យនាមថា "ធម្មិស្សរោ" ហើយវិលមកនៅក្នុងវត្តកោះគេរជាភ្នំពេញវិញ បានសិក្សាព្រះបរិយត្តិធម៌ក្នុងសំណាក់លោកគ្រូអាចារ្យ អ៊ុន ដដែល និងលោកគ្រូអាចារ្យដទៃទៀតជាច្រើន តាំងពីមូលឡើងទៅ ធម្មបទបឋមភាគ បច្ឆិមភាគ មង្គលត្ថទីបនី សារត្ថសង្គហ និងប្រែព្រះបាតិមោក្ខ និងគម្ពីរអាទិកម្ម ព្រមទាំងគម្ពីរដទៃទៀតជាច្រើន មានគម្ពីរបឋមសមន្តៈ ជាដើម រួមនៅវត្តកោះ ៨ ឆ្នាំ ៗ ល ៗ លុះព្រះសាក្យបុត្រ សុខ-កែវ ចៅអធិការវត្តកោះ ទទួលអនិច្ចធម្មទៅ លោកបានថយទៅនៅវត្តសំពៅមាសសង្កាត់លេខ ៥ បាន ៣ ឆ្នាំ ដោយរក្សាសទ្ធាលោកគ្រូ អ៊ា និងគ្រូ ជុន ធ្វើកុដិប្រគេនផង រក្សាចិត្តពួកមិត្តផង តពីនោះមកបានទៅនៅវត្តលង្កា ១ វស្សា ហើយបានកសាង

កុដិ មុខវិហារ ជាមួយនឹងលោកគ្រូ ឌិន គ្រូ ឌុ ក្រោយមកមានអ្នកស្រុកជ្រោយអម្ពិល មានឧបាសក ហ៊ុល ឧបាសិកាចួតជាដើម ជួយឧបត្ថម្ភកសាងកុដិ ១ ខ្នងទៀត នៅខាងត្បូងវិហារ ។

លុះជន្មាយុ ២៧ ឆ្នាំ សម្តេចព្រះធម្មលិក្ខិត ល្វី-ឯម វត្តលង្ការបានចាត់ឲ្យទៅធ្វើគ្រូបង្រៀនបាលីភាសានៅវត្តដីឥដ្ឋ ស្រុកកៀនស្វាយ ៣ ឆ្នាំ ហើយបានជួយស្ថាបនាធម្មន្ទីរ ១ ជាមួយនឹងព្រះវិសុទ្ធិញាណ ទិត-ប្រាក់ ទៅអធិការនៃវត្តនោះ លុះថយពីនោះមក ក្នុងជន្មាយុ ៣០ ឆ្នាំក្នុងឆ្នាំ ១៩២៩ រាជការបានចាត់ឲ្យទៅ ធ្វើគ្រូបង្រៀនបាលីភាសានៅសាលាបាលី គោកសំពេង «រលួស» ជាសាលាបាលីក្រៅវត្ត លុះទីនោះកែចំរើនឡើងទៅជាវត្ត ១ នោះឈ្មោះ ធម្មិស្សរពកម តាមនាមធាយា នៅក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាប ដោយមានព្រះរាជប្រកាសលេខ ២ ចុះថ្ងៃ ៣ ខែយាំងវិយេ ឆ្នាំ ១៩៣៣ និងអារេតេលោកឡូរេស៊ីដង់លេខ ២៦៦ ចុះថ្ងៃ ៣០ ខែយាំងវិយេឆ្នាំជាមួយ អនុញ្ញាតសាលាបាលី គោកសំពេង ឲ្យកសាងឡើងជាវត្ត និងសាងវិហារប៉ុអំពីបេតុងអារមេ ហើយលោកបានកសាងវិហារ សាលា កុដិ ព្រមទាំងកំពែងវត្តជាមួយនឹងគណៈកម្មការវត្ត ។

លុះលោកនៅកន្លែងនោះបាន ៥ វស្សា រាជការបានតាំងលោកជាចៅអធិការ ដោយមានសញ្ញាប័ត្រលេខ ៤៩ កន្លពុទ្ធសករាជ ២៤៧៨ ត្រូវនឹងថ្ងៃ ២៥ ខែណោវែម្ប្រ៍ឆ្នាំ ១៩៣៥ តាមសេចក្ដីបញ្ញត្តិរាជប្រកាសលេខ ៤៦ ត្រូវនឹងថ្ងៃ ២៥ ខែសូរយែត ឆ្នាំ ១៩១៩ និងតាមសេចក្ដីសំបុត្រសេនាបតីក្រសួងមហាផ្ទៃ – ធម្មការ លេខ ៧៥៥ ចុះថ្ងៃ ១៦ ខែសូរយែត ឆ្នាំ១៩៣៥ ដែលបញ្ជូនមកដោយយល់ព្រមផង ។

លុះចំណេរតពីនោះមក រាជការបានតាំងជាព្រះវិន័យធរ អនុគណស្រុកសូទ្រនិគម ខេត្តសៀមរាប ដោយមានសញ្ញាប័ត្រលេខ ១២៦ តាមសេចក្ដីបញ្ញត្តិព្រះរាជក្រមលេខ ១២ ត្រូវនឹងថ្ងៃ ៩ ខែហ្វេវ្រិយេ ឆ្នាំ ១៩៤៣ ហើយបានធ្វើការបំរើព្រះពុទ្ធសាសនា មានបង្រៀនបាលីភាសានិងធម្មវិន័យជាដើម ព្រមទាំងបានធ្វើជាអធិបតីនិងសមាជិកប្រឡងបាលីនិងធម្មវិន័យជាច្រើនឆ្នាំ ដូចមានព្រះរាជប្រកាសលេខ៤៨ ចុះថ្ងៃ៤ អាវ្រិលឆ្នាំ១៩៣៣ និងប្រកាសក្រសួងធម្មការ លេខ១៣៤៧ ចុះថ្ងៃ១៩ខែកក្កដា ឆ្នាំ១៩៦៨ ត្រង់ប្រការ ១ ដែលបានកែប្រែប្រកាស សេនាបតីលេខ១៥៥ ។ ដោយអំពើល្អក្នុងការបំរើព្រះពុទ្ធសាសនាឧបត្ថម្ភការសិក្សាជាច្រើនវត្ត ព្រះករុណាទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយស ដោយ

មានប្រកាសលេខ ២៩ ន-ស ចុះថ្ងៃ ៥ ៩ ៗ ៦ ឆ្នាំកាសប្ញស័ក ត្រូវនឹងថ្ងៃទី១៩ អាព្រិលឆ្នាំ ១៩៤៥ ព្រះរាជទានចំពោះឈ្មោះ លោកគ្រូធម្មិស្សរ·ពោ ឯក·ញឹម នូវគ្រឿងឥស្សរិយយស អស្សប្ញទ្ធិមុនីសារាភរណ៍ ធ្វើនៅថ្ងៃ ២ ៗ ៤ ឆ្នាំខាលទោស័ក ព.ស.២៤៩៣ ត្រូវនឹងថ្ងៃ ២ មេសា
១១
ឆ្នាំ ១៩៥៦ ។

## អំពីការកសាងវត្តផ្សេងៗ

ក – បានជួយស្ថាបនាធម្មន្ទីរអំពីបេតុងអារមេ ទទឹង ១០ម០០ បណ្តោយ ១៥ម០០ ៣ជាន់នៅវត្តជីឥដ្ឋ ឃុំជីឥដ្ឋ ស្រុកគៀន·ស្វាយ ខេត្តកណ្តាល ។

ខ - បានស្ថាបនាសាលាឈើ១ខ្នង ទទឹង៧ម០០ទាំងហោណាំង បណ្តោយ៧ម០០អំពីឈើផ្ចឹក និងស្រឡៅ ប្រក់ក្បឿងស៊ីមង្តទុក សម្រាប់សង្ឃប្រើប្រាស់ ក្នុងវត្តសិរីបទុម ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាមសព្វថ្ងៃ ។

គ – បានយកផ្ទះជាកេរ្តិ៍មត៌កអំពីញោមប្រុស-ស្រី ដោយសេចក្តីព្រមព្រៀងអំពីបងប្អូនផង ធ្វើជាសាលាបឋមសិក្សាគ្រឿងឈើប្រក់ក្បឿង១ខ្នងមាន៥បន្ទប់ សម្រាប់កូនចៅអ្នកស្រុករៀន នៅក្នុង

វត្តសិរីបទុម ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាមសព្វ. ថ្ងៃ និងបានជួយសាងនាសាលាបឋមសិក្សាឈ្មោះ សង្គមរាស្ត្រ និយម អំពីថ្ម១ខ្នងផង ។

យ – បានស្ថាបនាសាលាបាលីអំពីឥដ្ឋ១ខ្នង ទទឹង៦ម៰០ បណ្តោយ ១២ម០០ ជាមួយនឹងលោកគ្រូអាចារ្យ ចាប-ពិន ដែលមាន ឋានន្តរជាឃុនឧត្តមប្រិជា នៅកងវត្ត ឃុំ-ស្រុកជាដែលនេះ ។

ង – បានកសាងសាលាបឋមសិក្សាមួយខ្នងទៀត ទទឹង៦ម០០ បណ្តោយ១២ម០០ ជាមួយចៅសង្កាត់ យូរ-គុជ ទុកនៅកង វត្តខាងលើនេះ ។

ច – បានជួយស្ថាបនាជញ្ជាំងព្រះវិហារ ព្រមទាំងខឿននៃវត្តខាងលើ នេះអំពីឥដ្ឋ និងឧបដ្ឋានសាលាផង ។

ឆ – បានកសាងគម្ពីរព្រះត្រៃបិដក១បប់ និងគម្ពីរមូល១បប់ គម្ពីរធម្ម បទ១បប់ សារត្ថសង្គហ:១បប់ មង្គលត្ថទីបនី បប់ និង គម្ពីរ សម្រាយស៊ីករិតព្រមទាំងសៀវភៅយរង់ទៀតជាច្រើន ។

ជ – បានរៀបរៀងធម៌បោះពុម្ពជាច្រើនឈ្មោះ ដូចមានតទៅនេះគឺ :

១- គិហិប្បជាត

២. គិរិមានន្ទកាព្យ

៣. នមស្ការត្រ័យរត្នកាព្យ

៤. នានានិទានពាក្យ កាព្យ ក្នុងបឋមសម្ពោធិ

៣១ កណ្ឌ

៥. ប្រជុំត្រៃលក្ខណ៍ កាព្យ

៦. ប្រស្នាវិន័យតាមបិដកភាគ ១

៧. បព្វជ្ជា ឧបសម្បទា

៨. ចម្រៀងធម៌ពាំរង់ កាព្យ

៩. ចម្រៀងសំវេជ្ជនីយធម៌ កាព្យ

១០. វត្តកថានិងវន្ទាម៌ចេតិយំ កាព្យ

១១. លោកធម៌ប្រាំបី កាព្យ

១២. ឧបក្កិលេស ១៦ កាព្យ

១៣. ខន្ធោបមសូត្រ លើកទី ១

១៤. ខន្ធាទិកថា លើកទី ២

១៥. កូមាកម្មដ្ឋាន

១៦. កម្មដ្ឋានសង្ខេប

១៧. កម្មដ្ឋានកថា ធ្វើជាមួយនិងគណៈកម្មការសង្ឃ ៦ អង្គ មានសម្តេចព្រះសង្ឃរាជ ទី ១ ព្រះនាម ជួន ណាត កាលនៅជាព្រះសង្ឃនាយក, ជាដើម ។

១៨. គិរីមាននូ កាព្យផង ប្រែពាយផង អធិប្បាយផង

១៩. មង្គលសូត្រអធិប្បាយមង្គល ៣៨ មាននាំទាន គ្រប់មង្គល

២០. អប្បរិយាទិកថា

២១. ភាសិតោវាទ

២២. ភាណវារៈកិច្ចវត្ត

២៣. ភាណវារៈពិសេស

២៤. នានាគាថាបទបញ្ញើក

២៥. សម្មាបដិបទា

២៦. មហាកុសល ៨ កាព្យ

២៧. យោគាជីវធម៌ ភ្ជាប់និងកម្មដ្ឋានកថា

២៨- មន្តលសូត្រ និងបរាភវសូត្រ ប្រែជាបទបង្សុរ៉ែត និងគាថានានាទៀតផង ។

ឈ - បានកសាងកឋិនទានប្រគេនសង្ឃជាច្រើនវត្ត ច្រើនដង គឺ សិរីបទុម ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម ៣ ដង វត្តគោគងកើតមួង វត្តតាកុបមួង វត្តធម្មិស្សរារាម (សៀមរាប) ២ ដង និងធ្វើផ្កាទៅជួយសាងសាលាវិហារវត្តពោធិលង្កាក្រៅ (សៀមរាប) មួង ហើយលោកបានរៀនកម្មដ្ឋាន ព្រមទាំងបាននាំគេធ្វើធុតង្គ និងធ្វើធុតង្គខ្លួនឯងផង ។ លុះជន្មាយុ ៥៤ ឆ្នាំ (រាប់ពីអាយុ ៣០ ទៅ ៥៤ ឆ្នាំ នៅ ល្មសរួមជា ២៥ ឆ្នាំ ) ហើយក៏បានលាចេញពីដំណែងទៅអធិការ ព្រមទាំងឋានន្តរស័ក្តិជាវិន័យធរ វត្តធម្មិស្សរារាម ឃុំ ស្រុកស្ទូទនិគម ខេត្តសៀមរាប ទៅធ្វើធម្មសង្គាយនានៅប្រទេសភូមា ហើយបានរៀនកម្មដ្ឋានក្នុងសំណាក់មហាស៊ីសយាដោ នៅវត្តតាតនាយ៉េកតា ១ ខែ រួចត្រឡប់មកស្រុកខ្មែរវិញ ក្នុងគ្រាពុទ្ធជយន្តី ២៥០០ ពាក់កណ្តាលពុទ្ធសាសនា លើកក្រោយទៀតបានទៅប្រទេសឥណ្ឌា ចូលប្រជុំជាមួយនឹង

ប្រទេសនានាជាច្រើនប្រទេសម្តងទៀត ។

លុះត្រឡប់មកស្រុកខ្មែរវិញ បាននាំយកពូជមហាពោធិព្រឹក្ស និងព្រះបរមសារីរិកធាតុមកផ្សាយចែកជាច្រើនកន្លែង ហើយក៏អាស្រ័យនៅទីនវត្តពិកទូរង្ស សង្កាត់លេខ ២ ក្រុងភ្នំពេញ ដរាបមកដល់សព្វថ្ងៃនេះឯង ។

រៀបរៀងដោយអ្នកអាចារ្យ រឹកស-ជួប

ព.ស. ២៥០៩ គ.ស. ១៩៦៦

×

× ×

—បម្លើយពាក្យបណ្តៅពីលេខមុន—

ពាក្យបណ្តៅលេខ

- ១ - កាំភ្លើង ។

- ២ - ត្បាល់កិនស្រូវ ។

- ៣ - ចង្កូតទូក ។

# អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ២៤

ដូចជាពីឆ្នាំមុន ៗ រៀងមកដែរ នៅឆ្នាំនេះ មហាសន្និបាតនៃមន្ត្រីសង្ឃ ដែលហៅថាអនុសំវច្ឆរៈ បានប្រារព្ធធ្វើឡើងតាំងពីថ្ងៃសៅរ៍ ទី ២៧ មករា ១៩៦៨ តទៅ ៗ

ការប្រារព្ធពិធី បានបើកសម័យនៅវត្តឧណ្ណាលោម សម្រាប់គណៈមហានិកាយ ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះសង្ឃរាជ និងនៅវត្តបទុមវតីរាជវរារាម សម្រាប់គណៈធម្មយុត្តិកនិកាយ ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃនាយក ៗ នៅម៉ោង ១៤ កន្លះ សហៈជីវិនអនុរដ្ឋលេខាធិការក្រសួងធម្មការ បានអញ្ជើញទៅកាន់វត្តទាំងពីរ ជាតំណាងឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងធម្មការ ដើម្បីប្រួមកង៏ឱកាសបើកពិធីមហាសន្និបាតនេះ ៗ

នៅថ្ងៃអាទិត្យ ទី ២៨ មករា ១៩៦៨ វេលាម៉ោង ១៦ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត មានការជួបជុំព្រះសង្ឃទាំងពីរគណៈ មានសម្តេចព្រះសង្ឃរាជ និង សម្តេចព្រះសង្ឃនាយក ព្រមទាំងព្រះសង្ឃរាជាគណៈ ឋានានុក្រម ជាអាទិ៍ ៗ ផ្នែកខាងគ្រហស្ថ មាន ៖ សម្តេចចៅហ្វាវាំង, ឯ.ឧ. ប្រធានសភាទាំងពីរ, ឯ.ឧ. រដ្ឋមន្ត្រីទីមួយ

ព្រមទាំងសមាជិកក្រុមឧត្តមប្រឹក្សាព្រះរាជបល្ល័ង្ក សមាជិកគណៈរដ្ឋមន្ត្រី សមាជិកខ្លះនៃសភាទាំងពីរ អ្នករាជការសំខាន់ៗ នៅក្រសួងធម្មការជាច្រើនទៀត ។ នៅម៉ោង ១៦ កន្លះ សម្ដេចសហជីវិនព្រះប្រមុខរដ្ឋដោយមានព្រះរាជបរិពារផ្ទាល់តាមដង្ហែផង, ព្រះអង្គស្ដេចយាងមកដល់ ។ ក្រោយពីព្រះអង្គបានទទួលគារវកិច្ចអំពីកងយោធាទាំងបីក្រុម ដែលធ្វើវន្ទនាវុធជាព្រះរាជកិត្តិយស និង ព្រះអង្គទ្រង់បានទទួលការក្រាបបង្គំទទួលអំពីវរជនរួចហើយ ស្ដេចយាងកាត់ផ្លូវយុវជន-យុវតី ឆ្ពោះទៅកាន់ទីប្រារព្ធពិធី ។ បន្ទាប់ពីទ្រង់គោរពតង់ជាតិរួច ស្ដេចយាងក្រាបថ្វាយបង្គំសម្ដេចព្រះសង្ឃរាជ សម្ដេចព្រះសង្ឃនាយក សម្ដេចព្រះពោធិវង្ស និង ព្រះសង្ឃទាំងអស់ រួចហើយទ្រង់គង់ប្រថាប់លើព្រះសុវណ្ណកោច្ឆៈ ។

ពេលនោះ សហជីវិន អ៊ុក-អ៊ួត អនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថា សម្ដែងស្វាគមន៍ និង ក្រាបបង្គំទូលថ្វាយអំពីសកម្មភាពខ្លះរបស់ក្រសួងចំពោះព្រះអង្គ ដែលយើងចុះផ្សាយសុន្ទរកថានេះទាំងស្រុងនៅទំព័របន្ទាប់ទៅនេះ ។

តពីសុន្ទរកថានេះមក ព្រះតេជព្រះគុណអនុគណស្រុកកំពត បាន

ថ្វេនក្នុងនាមមន្ត្រីសង្ឃទាំងអស់ ថ្វាយព្រះពរនិងសូមម៉័កក្តិ ព្រមទាំងរាប់រៀបអំពីការលូតលាស់ក្នុងវិស័យព្រះពុទ្ធសាសនា ។

ក្រោយពីនេះមកទៀត សម្តេចៗជាអម្ចាស់ ទ្រង់ប្រោសព្រះរាជទានព្រះសង្កថាមួយដ៏ពិរោះគ្បោះក្បាយ មានន័យប្រកបដោយខ្លឹមសារក្រៃលែង ។ ព្រះរាជសុន្ទរកថានេះ បងប្អូនរួមជាតិយើងបានស្តាប់តាមសម្ទេវិទ្យុជាតិ ជាច្រើនលើកហើយ កាលពីថ្ងៃទី ២៨-២៩ មករា ១៩៦៨ ដែលប្រកបដោយព្រះមធុរសោវាតឥតឧបមា ។

វេលាម៉ោង ១៩ សម្តេចជាអម្ចាស់ទ្រង់ក្រាបថ្វាយបង្គំលាសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក សម្តេចព្រះពោធិវង្ស ព្រមទាំងព្រះសង្ឃទាំងអស់ ដែលនិមន្តមកយ៉ាងកកកុញហូតដល់ខ្លោងទ្វារក្រៅ ព្រមទាំងលាឥស្សរជន និង កូនចៅទាំងអស់ យាងនិវត្តចូលព្រះរាជដំណាក់វិញ ។

## សុន្ទរកថា សហជីវិន អ៊ុក-ម៉ូត
## អនុរដ្ឋលេខាធិការ ក្រសួងធម្មការ ថ្លែងក្នុងឱកាសអនុសំវច្ឆរមហាសន្និបាត មន្ត្រីសង្ឃ ទី ២៤ ថ្ងៃទី ២៨-១-៦៨

---

សូមព្រះតេជះគុណលើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចសហជីវិន ព្រះប្រមុខរដ្ឋ
ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

ទូលព្រះបង្គំជាខ្ញុំក្នុងនាមក្រសួងធម្មការ និងក្នុងនាមនៃពុទ្ធបរិស័ទទាំងអស់ សូមលំអុតលំទនកាយក្រាបថ្វាយបង្គំថ្លែងនូវអំណរព្រះមហាករុណាធិគុណយ៉ាងរំភើប និងយ៉ាងកក់ក្តៅបំផុត ចំពោះព្រះរាជាធិបតីភាព ដែលសម្តេចជាអម្ចាស់ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទានក្នុងពិធីសម្ពោធបើកមហាសន្និបាតមន្ត្រីសង្ឃនៅឱកាសដ៏មហោឡារិកនេះ ។ ព្រះរាជវត្តមាននេះបញ្ជាក់នូវទឹកព្រះទ័យ ដែលព្រះអង្គទ្រង់តែងជាប់ជំពាក់យ៉ាងធ្ងន់ក្រៃលែងចំពោះព្រះពុទ្ធសាសនា ដ៏ជាសាសនាបរមសុខក្នុងសកលលោក ។ មិនតែប៉ុណ្ណោះ ថែមទាំងជាស់សតិយើងខ្ញុំព្រះអង្គគ្រប់ៗគ្នាឲ្យរឭកឃើញដល់ព្រះគុណដ៏ធ្ងន់នៃព្រះរាជបល្ល័ង្កខ្មែរ ដែលតែងប្រោសមេត្តាឧបត្ថម្ភយ៉ាងពេញទំហឹងចំពោះព្រះពុទ្ធសាសនាផង ។ ជាក់ស្តែងគឺអនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃ ដើម្បីបើកឱកាសថ្វាយព្រះសង្ឃលោកប្រជុំពិភាក្សាដោះស្រាយបញ្ហាធំៗ ដែលកើតមានក្នុងព្រះពុទ្ធសាសនាឲ្យកាន់តែមានសភាពប្រតិបត្តិដ៏ហ្មត់ហ្មងល្អឡើងៗ នេះ ក៏ដោយសារព្រះបញ្ញាញាណនៃសម្តេចជាអម្ចាស់ កាលដែលព្រះអង្គទ្រង់គង់នៅក្នុង

រាជសម្បត្តិទៅឡើយនោះដែរ ។ ដូច្នេះ មហាសន្និបាតនេះ មានអាយុកាល ២៤ ឆ្នាំ ហើយ រួមទាំងឆ្នាំនេះផង ។ នេះជាការបញ្ជាក់ឲ្យឃើញច្បាស់ថា សន្តានព្រះទ័យនៃព្រះអង្គទ្រង់បានត្រួសត្រាយមាគ៌ា ដ៏ល្អក្រៃស្ពានសម្រាប់ព្រះសង្ឃក្នុងកិច្ចការដោះស្រាយបញ្ហា ដែលកើតមានក្នុងព្រះពុទ្ធសាសនា ក៏ដូចជាសមាជជាតិដែលមាននាទីដោះស្រាយបញ្ហាធំៗ របស់ជាតិដូច្នោះដែរ ហើយមហាសន្និបាតព្រះសង្ឃនេះ ព្រះអង្គទ្រង់បង្កើតឲ្យមានឡើងមុនសមាជជាតិជាច្រើនឆ្នាំទៅទៀត ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាតថ្វាយរាប់រៀបអំពីកិច្ចការខ្លះ ដែលក្រសួងធម្មការ នៅក្នុងរជ្ជកាលពិសេសនៃសម្តេច ជាអម្ចាស់ បានបំពេញមកហើយ ៖

១- ផ្នែកការសិក្សាព្រះពុទ្ធសាសនា ៖ ក្នុងផ្នែកនេះ ក្រសួងបានជួយឧបត្ថម្ភទាំងខាងវិបស្សនាធុរៈ ដែលបានរកចំរើនជាលំដាប់ ហើយនិងផ្នែកគន្ថធុរៈ ដែលកំពុងតែមានវិវឌ្ឍនាការយ៉ាងធំទូលាយ ក្រោមការដឹកនាំនៃសម្តេចព្រះពោធិវង្សជាអម្ចាស់ ។ ស្ថិតិក្នុងឆ្នាំសិក្សា ១៩៦៧-៦៨ នេះ ផ្នែកពុទ្ធិកបឋមសិក្សា ក្នុងព្រះរាជាណាចក្រទាំងមូលមាន ២៤៥ ថ្នាក់

សមណសិស្ស ៩៥០២ រូប និងមានគ្រូទាំងបព្វជិត ទាំងគ្រហស្ថ ៣៣៨ ។ ក្នុងបណ្តាសិស្សទាំងនេះ មានសិស្ស ៥៧៨៣ និងគ្រូ ១៧៥ រូប អនុវត្តតាមបែបទំរង់ថ្មី ដែលក្រសួងបានជ្រើសរើសសម្រិតសម្រាំងគ្រូប្រកបដោយសមត្ថភាពពេញលេញ ដើម្បីបំពេញកិច្ចការរបស់ពុទ្ធបរិស័ទ និងតាមព្រះឱវាទ នៃសម្តេចឪជាអម្ចាស់ ដែលទ្រង់បានថ្លែងនៅក្នុងទីនេះកាលពីបីឆ្នាំមុនថា „ សមណនិស្សិត ក៏ជាពលរដ្ឋយើងប្រពៃណាស់សំរាប់បំរើប្រទេសជាតិទៅអនាគត „ ។

ផ្នែកពុទ្ធិកមធ្យមសិក្សា យើងមានសាលាធំៗ ពីរគឺ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតគឺទីនេះឯងមួយ និងពុទ្ធិកវិទ្យាល័យ អ៊ុង ហួង បាត់ដំបងមួយ រួមសរុបមាន ៤៣ ថ្នាក់ និងមានសមណនិស្សិត ៩៨៤ រូប ។ ការសិក្សាក្នុងភូមិសិក្សានេះ ក៏មានមុខវិជ្ជាគ្រប់សព្វគ្រប់តម្រូវទៅតាមប្រយោជន៍ពុទ្ធសាសនាផង ប្រយោជន៍ខាងផ្លូវលោកសម័យថ្មី គឺការបំរើវត្តលួតលាស់នៃប្រទេសកម្ពុជាឯករាជ្យអព្យាក្រឹត្យ ក្រោមព្រះរាជកិច្ចដឹកនាំដ៏ភ្លឺស្វាងនៃសម្តេចឪជាអម្ចាស់ផង ហើយក្នុងឆ្នាំកន្លងទៅនេះ ប្រឡងសញ្ញាប័ត្រមធ្យមសិក្សាជាប់បាន ១៧៦ រូប ក្នុងបណ្តាបេក្ខជន ២៩៨ ។

ចំណែកពុទ្ធិកឧត្តមសិក្សាវិញ នៅឆ្នាំនេះមានសមណនិស្សិតចំនួន ១៥៦ រូប គឺ ១០៨ សិក្សាផ្នែកបឋមភូមិ និង ៤៨ ផ្នែកទុតិយភូមិ ដែល

ចែកចេញជាមុខវិជ្ជាសំរាប់យកបរិញ្ញាប័ត្រខាងភាសាបាលី សាសនាប្រៀបធៀប ទស្សនវិជ្ជាបូព៌ាប្រទេស និងភាសាវិទ្យា ។ ក្នុងឆ្នាំកន្លងទៅ ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ បានបញ្ចេញអ្នកជាប់បរិញ្ញាប័ត្រចំនួន ៨ រូបហើយ ។

២. ផ្នែកខាងការបោះពុម្ពផ្សាយៈ ចំពោះកិច្ចការបោះពុម្ពផ្សាយក្បួនខ្នាតផ្សេង ៗ នៅឆ្នាំនេះ បានកើនឡើងដែរ គឺបើសរុបចំនួនឃើញថាបាន ៣៨-៩០០ ក្បាល ចែកចេញជា ២៦ ឈ្មោះផ្សេង ៗ គ្នា ។ ក្នុងចំនួននេះមានខ្លះជាសៀវភៅចាស់ ដែលជាអស់ហើយ ហើយបោះពុម្ពឡើងវិញ និងខ្លះទៀតជាសៀវភៅតែងថ្មី តាមការស្រាវជ្រាវក្នុងផ្នែកវប្បធម៌បុរាណរបស់ខ្មែរយើង ។ ឯព្រះត្រៃបិដក ក៏ចេញផ្សាយបានចំនួន ១០០ ភាគរួចហើយ ក្នុងចំនួន ១១០ ភាគនោះ ដូច្នេះឃើញនៅសល់តែ ១០ ភាគប៉ុណ្ណោះ ដែលនឹងបោះពុម្ពឲ្យចប់សព្វគ្រប់នៅឆ្នាំ ១៩៦៨ នេះ ។ កិច្ចការនេះជាជោគជ័យមួយ ដែលសង្គមរាស្ត្រនិយមយើងខំបង្ហើយឲ្យចប់ចុងចប់ដើម នូវកេរ្តិ៍តំកល់ដ៏ប្រពៃ ដែលបណ្ឌិតខ្មែរបានខិតខំព្យាយាមធ្វើការងារដ៏ធំនេះ មានសម្តេចព្រះសង្ឃរាជ សម្តេចព្រះពោធិវង្ស និងសម្តេចព្រះអយ្យកោវាទចក្រវណាប៉ុទ្ធ នកេត្តុម-សុត្តាស ជាដើម ។

៣- ផ្នែកស្រាវជ្រាវក្បួនខ្នាត និងទំនៀមផ្សេងៗ :- ចំណែកកិច្ចការស្រាវជ្រាវរកកេរ្តិ៍ណែល ក្បួនច្បាប់ផ្សេងៗ ទាក់ទងខាងប្រវត្តិ-សាស្ត្រអក្សរសាស្ត្រ ទស្សនវិជ្ជា និងទំនៀមទម្លាប់ខ្មែរ ដែលធ្លាប់កើតមានមកតាំងពីបុរាណនោះ, ក៏បានប្រព្រឹត្តទៅតាមដំណើរជាលំដាប់ ៗ ហេតុនេះហើយ បានជាមានអ្នកប្រាជ្ញ អ្នកស្រាវជ្រាវក្នុងស្រុក និងបរទេសជាច្រើន លើសពីឆ្នាំមុនៗ ចេញចូលទាក់ទងជាមួយបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ និងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដែលជាព្រះកេរ្តិ៍នៃព្រះរាជបល្ល័ង្ក បានបង្កើតឡើងរវាងជាង ៤០ ឆ្នាំមកហើយ ។ មជ្ឈដ្ឋានបរទេសជាច្រើន សឹងតែពេញសាកលលោក គេបានសំគាល់ថាទីនេះជាមជ្ឈមណ្ឌលខាងវប្បធម៌ជាតិយ៉ាងសំខាន់របស់ខ្មែរយើង ។ មិនតែប៉ុណ្ណោះ ក្រសួងបានអំពាវនាវសុំឲ្យវត្តនានាបង្កើតបណ្ណាល័យប្រចាំវត្តជួយប្រមូល និង ផ្សព្វផ្សាយវប្បធម៌ជាតិបុរាណ និង សម័យថ្មីឲ្យបានជ្រួតជ្រាបគ្រប់ទិសទីផង ។ សព្វថ្ងៃមានវត្តចំនួនជិតមួយពាន់បានធ្វើតាមការអំពាវនាវនេះហើយ ឯវត្តដទៃទៀត ក៏សង្ឃឹមថានឹងបង្កើតបណ្ណាល័យតាមសេចក្តីអំពាវនាវនេះជាមិនខាន ។

សូមទ្រង់ព្រះមេត្តាប្រោស,

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត ថ្លែងក្នុងនាមព្រះរាជរដ្ឋាភិបាលនូវអំណរព្រះមហាករុណាធិគុណ និង កតញ្ញូតាធម៌ដ៏លើសលុប ថ្វាយចំពោះសម្ដេចព្រះសង្ឃរាជ, សម្ដេចព្រះសង្ឃនាយក, សម្ដេចព្រះពោធិវង្ស ដែលព្រះអង្គទ្រង់តែងតែប្រឹងប្រែងពេញព្រះកាយពល ជួយឧបត្ថម្ភកិច្ចការគ្រប់បែបក្នុងផ្លូវពុទ្ធចក្រឲ្យប្រកបដោយសេចក្ដីចំរើនគ្រប់គ្រាគ្រប់កាល ពិសេសគឺព្រះអង្គទ្រង់ព្រះតម្រិះរកមធ្យោបាយល្អៗ ជួយប្រទានព្រះរាជយោបល់ដល់ក្រសួងធម្មការ ។ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ពុំអាចបំភ្លេចបានឡើយ ចំពោះព្រះគតិបណ្ឌិតទាំងនេះ ។

មួយចំណែកទៀត ទូលព្រះបង្គំជាខ្ញុំ សូមឆ្លៀតឱកាសដ៏ឧឡារិកនេះ ថ្លែងអំណរព្រះគុណចំពោះព្រះរាជាគណៈ ឋានានុក្រម មេគណអនុគណ និង ចៅអធិការគ្រប់ព្រះអង្គ ដែលបានជួយជ្រោមជ្រែងពេញសមត្ថភាពធ្វើឲ្យកង់ពុទ្ធចក្រលឿនទៅមុខ ស្មើគ្នានឹងល្បឿននៃកង់អាណាចក្រដែរ ឧទាហរណ៍ដូចជាចិតចំជួយរាជរដ្ឋាភិបាលក្នុងវិស័យសង្គមកិច្ច វប្បធម៌ មានជាអាទិគឺ ការដាំដើមឈើ ជីកអណ្ដូង ស្ថាបនាសាលារៀន មន្ទីរពេទ្យមានមណ្ឌលសុខភាពសម្ដេច ហ្លួត តាត ជា

ដើម និងកិច្ចការជាច្រើនទៀត ឲ្យបានសម្រេចឡើង ស្របទៅតាមព្រះមាគ៌ានយោបាយដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះប្រមុខរដ្ឋជាអម្ចាស់ ។

សូមទ្រង់ព្រះមេត្តាប្រោស,

ជាអវសាន ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយថ្វាយល្អងធូលីព្រះបាទជាថ្មីម្ដងទៀត នូវអំណរព្រះមហាករុណាធិគុណ និង កតញ្ញូតាដ៏ជ្រាលជ្រៅ ចំពោះព្រះរាជវត្តមាននៃព្រះអង្គ និង សូមឧទ្ទិសបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ គេជានុភាពនៃព្រះពុទ្ធសាសនា និងវត្ថុស័ក្តិសិទ្ធិគង់សាកលលោក ជួយអភិបាលថែរក្សាអង្គសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋសូមព្រះអង្គបានប្រកបដោយព្រះបរមសុខសួស្ដី ឈ្នះមាសត្រូវគ្រប់ទិសទីនិងមានព្រះជន្មាយុយឺនយូរ ដើម្បីបានជាម្លប់ដ៏សុខសាន្ត នៃប្រជាពលរដ្ឋខ្មែរ កូនចៅព្រះអង្គ ដរាបទៅ ។

ជយោ ! ព្រះរាជបល្ល័ង្ក

ជយោ ! សម្ដេចឪ ព្រះអគ្គសាសនូបត្ថម្ភក៍

ជយោ ! សង្គមនិយមព្រះពុទ្ធសាសនា

សូមព្រះតេជះគុណលើត្បូង

២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៤០ ខែ កុម្ភៈ

ព.ស. ២៥១១ គ.ស. ១៩៦៨

-ភ្នំពេញ-

២

# កម្ពុជសុរិយា

## ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
## ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ


| អត្ថបទ | ផ្នែកសាសនា | ទំព័រ |
|---|---|---|
| ១- | កបិនកថាសង្ខេប (ត) សម្ដេចព្រះពោធិវ័ង្ស រៀបរៀង . . . . | ១២៥ |
| ២- | ព្រះពុទ្ធសាសនា និង សិទ្ធិមនុស្ស (ព្រះមហា អេង-ទេមី) . . . | ១៤៦ |
| ៣- | រឿងព្រះឧបនន្ទសាក្យបុត្រ (លោក ប៊ូ-ប៊ូ រៀបរៀង) . . . . | ១៧៣ |
| ៤- | រឿងព្រះបធានិកតិស្សត្ថេរ ( —ដ— ) . . . . | ១៧៨ |
| | **ផ្នែកអក្សរសាស្ត្រ** | |
| ៥- | វចនានុក្រមសំស្ក្រឹត-ខ្មែរ ( ព្រះមហា ប៉ាង.ខាត់ ) . . . . . | ១៨១ |
| ៦- | ការស្រាវជ្រាវ ប្រវត្តិលោកវិសេស ធួន ( បណ្ឌិតមហា ឈឹម.ស៊ុម ) . | ១៨៥ |
| ៧- | រឿងចៅតែលលក (សហ. ព្រូច-កុម រៀបរៀង) . . . . . | ១៩៥ |
| ៨- | ល្បងសិក្សា ប្រវត្តិអក្សរសាស្ត្រខ្មែរ ( សហ. ណង.ហ៊ីបអាន ) . . | ២១៣ |
| ៩- | រឿងសាមកុក ( ត ) (ឧកញ៉ា គូ-កន) . . . . . . . . | ២២៤ |
| ១០- | ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត ( លោក ញ៉ុក.ថែម ) . . . . | ២៣២ |
| | **ផ្នែកកំណត់-ប្រវត្តិការណ៍** | |
| ១១- | គុណូបការនៃសមិទ្ធិនានារបស់ វិជ្ជាឋាន ពុទ្ធសាសនបណ្ឌិត្យ. . . . | ២៤៤ |
| ១២- | ព្រះរាជចុតហ្មាយថ្លែងព្រះអំណរគុណ . . . . . . . . . | ២៤៧ |

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យផុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប. ព.

# កឋិនកថាសង្ខេប

*សម្តេចព្រះពោធិវង្ស ហួត · តាត រៀបរៀង*

( ក )

ស. ចុះបើមានភិក្ខុច្រើនរូបលើសពីចំនួន ៥ រូបទៅ តើមានកំណត់ចំនួនប៉ុន្មាន ៗ ដែរឬទេ?

ឆ. ឥតមានកំណត់ចំនួនទេ បើទុកជាមានច្រើនដល់ទៅពាន់ហ្មឺនពាន់សែន ក៏តែតែអាចទទួលក្រាលកឋិនបានដោយប្រពៃណាស់ ៗ

ស. ចុះភិក្ខុដែលអាចទទួលក្រាលកឋិនបានទាំងនោះ ត្រូវបំពេញករណីយកិច្ចអ្វីជាមុនដែរ ឬក៏គ្មានទេ ?

ឆ. មាន, ភិក្ខុដែលអាចទទួលក្រាលកឋិនទាំងនោះ គឺភិក្ខុដែលបានចូលបុរិមិកវស្សា នៅថ្ងៃ ១ រោច ខែអាសាឍ ហើយបានបវារណាក្នុង

ថ្ងៃបឋមបវារណា នៅថ្ងៃ ១៥ កើត ខែអស្សុជ ប៉ុន្តែចំពោះកិច្ចបវារណា ប្រសិនបើមានហេតុភេទណាមួយមកពាំងនាំឲ្យខានបវារណានោះ ក៏មិនជាអ្វីដែរ ឲ្យតែបានចូលបុរិមិកវស្សាក៏អាចទទួលបំពេញកឋិនត្ថារកិច្ចបានៗ

ស. ចុះភិក្ខុដែលមិនបានចូលវស្សា ឬបានចូលវស្សាដែរ ប៉ុន្តែដាច់វស្សា ឬក៏ភិក្ខុដែលចូលបច្ឆិមិកវស្សា នៅថ្ងៃ១រោច ខែស្រាពណ៍ ភិក្ខុទាំងនេះ អាចទទួលក្រាលកឋិនបានដែរឬទេ ?

ឆ. មិនបានទេ ៗ

ស. ចុះបើភិក្ខុបានចូលបុរិមិកវស្សាក្នុងវត្តឯទៀត ហើយមកទទួលក្រាលកឋិន រួមជាមួយនឹងភិក្ខុដែលចូលបុរិមិកវស្សាក្នុងវត្តមួយដទៃ តើបានឬទេ ?

ឆ. មិនបានដោយដាច់ខាត ៗ

ស. ប្រសិនបើភិក្ខុដែលបានចូលបុរិមិកវស្សា មិនគ្រប់ចំនួន ៥ រូប យ៉ាងតិច គឺមានតែ ១ រូប ២ រូប ៣ រូប ឬ ៤ រូបប៉ុណ្ណោះ តើត្រូវប្រតិបត្តិដូចម្តេច ដើម្បីឲ្យបានទទួលក្រាលកឋិន ?

ឆ. ត្រូវស្វែងរកភិក្ខុដទៃ មកធ្វើជា គណបូរកៈ បំពេញឲ្យគ្រប់ជាគណៈសង្ឃ មានចំនួន៥រូប ទើបអាចនឹងទទួលក្រាលកឋិនបាន ៗ បើមានតែ ១រូប ឲ្យរក ៤រូប, បើមាន ២រូប ឲ្យរក ៣រូប, បើមាន ៣ រូប ឲ្យរក ២រូប, បើមាន ៤រូប ឲ្យរក ១រូបមកបង្គ្រប់ ឲ្យបានគ្រប់ ៥រូប

យ៉ាងតិច ។

ស. ភិក្ខុដែលត្រូវនិមន្តមកបង្គ្រប់ជាគណបូរកៈនោះ តើភិក្ខុមានលក្ខណៈដូចម្ដេច ?

ឆ. ភិក្ខុដែលមិនបានចូលវស្សាក្ដី ចូលវស្សាហើយដាច់វស្សាក្ដី ចូលបច្ឆិមិកវស្សាក្ដី ភិក្ខុនៅក្នុងវត្តដទៃក្ដី ក៏អាចនិមន្តមកធ្វើជាគណបូរកៈបានទាំងអស់ ។

ស. ចុះភិក្ខុទាំងប៉ុន្មាន ដែលគេនិមន្តមកធ្វើជាគណបូរកៈនោះ តើត្រូវបានទទួលសង្ឃលាភដែរឬទេ ?

ឆ. មិនត្រូវទទួលសង្ឃលាភទេ, ភិក្ខុទាំងប៉ុន្មានរូបដែលនិមន្តមកធ្វើជាគណបូរកៈនោះ មានភារៈត្រឹមតែជួយបង្គ្រប់ជាគណៈសង្ឃ សូត្រញត្តិទុតិយកម្មវាចា ប្រគល់សំពត់កឋិន ដល់ភិក្ខុដែលត្រូវក្រាលកឋិនតែប៉ុណោះ ហើយនិមន្តទៅវិញចុះ ។ ប៉ុន្តែ ភិក្ខុដែលនិមន្តមកធ្វើជាគណ-បូរកៈនោះ អាចទទួលចង្ហាន់ ឬក៏ទទួលភេសជ្ជៈបាន, ក្រៅពីនោះ នឹងអនុមោទនាយកអានិសង្ស ៥ ពុំបានទេ នឹងទទួលយកអានិសង្សលាភ គឺចីវរ ឬសំពត់សាដក ជាសំពត់ដទៃក្រៅពីកឋិនចីវរ ដែលហៅថាកឋិនា·

និសង្សនោះ ពុំបានឡើយ[១] ។

ស. ចុះបើក្នុងវត្ត ១ មានភិក្ខុតែ ៤ រូបចូលបុរិមិកវស្សា, សាមណេរមាន ១ រូប អាយុគ្រប់ ២០ ឆ្នាំ បានចូលបុរិមិកវស្សាដែរ បើសាមណេរនោះបានឧបសម្បទក្នុងបច្ឆិមិកវស្សា តើភិក្ខុថ្មីនោះដែលមិនទាន់តាំងបាន ១ វស្សាផង អាចធ្វើគណបូរកៈបានឬទេ ?

ឆ. ភិក្ខុថ្មីនោះ ទោះបីបានទទួលឧបសម្បទមិនបាន វស្សាក៏ដោយ អាចធ្វើជាគណបូរកៈក៏បាន ហើយថែមតាំងបាននូវអានិសង្សកឋិនផងទៀត ព្រោះបានចូលបុរិមិកវស្សាតាំងពីសាមណេរមកហើយ ។ ដោយអាស្រ័យហេតុនេះ បានជាព្រះសព្វញ្ញុពុទ្ធទ្រង់អនុញ្ញាតឲ្យសាមណេរចូលវស្សា ទោះសាមណេរតូចៗ ដែលមានអាយុ ៧ ឆ្នាំក៏ដោយ ត្រូវតែចូលវស្សា ប៉ុន្តែគ្មានពិធីបវារណាចេញវស្សាដូចភិក្ខុទេ ។

សាមណេរដែលបានឧបសម្បទជាភិក្ខុថ្មី ហើយអាចធ្វើជាគណបូរកៈនោះ មិនមែនត្រឹមតែ ១ រូបប៉ុណ្ណោះទេ បើភិក្ខុមាន ៣ រូប ត្រូវបញ្ចូលសាមណេរជាភិក្ខុថ្មី ២ រូប , បើភិក្ខុមាន ២ រូប ត្រូវបញ្ចូលសាម-

---

១ តាមមតិរបស់ខ្ញុំយល់ថា បើទាយកគេធ្វើទេយ្យទានដោយវត្ថុផ្សេង ក្រៅអំពីសង្ឃលាភដែលគេវេរប្រគេនសង្ឃក្នុងកឋិនាភិសនោះ ដើម្បីប្រគេនចំពោះលោកជាគណបូរកៈនោះផងដោយសេចក្ដីជ្រះថ្លារបស់គេ, លោកជាគណបូរកៈទាំងនោះ ក៏អាចទទួលទេយ្យទានទាំងនោះបាន ឥតមានខុសអ្វីទេ ។

ណេរជាភិក្ខុថ្មី ៣ រូប, បើភិក្ខុមានតែ ១ រូប ត្រូវបញ្ចូលសាមណេរជាភិក្ខុថ្មី ៤ រូប ឲ្យតែបានគ្រប់ ៥ រូប តែត្រូវរើសយកសាមណេរដែលមានអាយុគ្រប់ ២០ ឆ្នាំ ហើយបានចូលបុរិមិកវស្សាផង ឥកឲ្យឧបសម្បទក្នុងបច្ឆិ·មិកវស្សាផង ហើយបញ្ចូលជាគណបូរកៈបាន ។

ស. ចុះបើក្នុងវត្ត ១ ភិក្ខុដែលចូលបុរិមិកវស្សាទាំងប៉ុន្មាន មិនឈ្លាសវៃក្នុងការក្រាលកឋិនសោះ តើត្រូវធ្វើដូចម្តេច ?

ឆ. ត្រូវស្វែងរកលោកជាថេរៈ ដែលឈ្លាសវៃក្នុងកិច្ចក្រាលកឋិន ហើយចេះចាំវិន័យកឋិនក្ខន្ធកៈ និមន្តលោកមកឲ្យជួយសូត្រកម្មវាចា ជួយបង្ហាញក្រាលកឋិន ត្រាតែបានសម្រេច ។ ប៉ុន្តែព្រះថេរៈទាំងនោះ មិនត្រូវបាននូវអានិសង្សលោកបេស់កឋិនឡើយ ។

ស. ភិក្ខុដែលគួរដល់ការក្រាលកឋិន ត្រូវឲ្យមានការឈ្លាសវៃក្នុងធម៌អ្វីខ្លះ ?

ឆ. ត្រូវឲ្យមានការឈ្លាសវៃក្នុងធម៌ ៨ ប្រការ ទើបគួរក្រាលកឋិនបាន ដូចក្នុងគម្ពីរវិនយវិនិច្ឆ័យ លោកនិពន្ធរៀងនេះទុកជាគាថា ថា :

អដ្ឋធម្មកោវិទោ ភិក្ខុ កឋិនត្ថារមរហតិ
បុព្វបច្ចុទ្ធារាធិដ្ឋា នត្ថារោ មាតិកាបិ ច
បលិពោធោ ច ឧទ្ធារោ អានិសំសា បនដ្ឋិមេ ។

ភិក្ខុដែលគួរក្រាលកឋិនបាននោះ ត្រូវជាអ្នកឈ្លាសវៃក្នុងធម៌ ៨

ប្រការគឺ បុព្វករណៈ១ បច្ចុទ្ធរៈ១ អធិដ្ឋានៈ១ អត្ថារៈ១ មាតិកា១ បលិពោធ១ ឧទ្ធារៈ១ អានិសង្ស១ នេះជាធម៌ ៨ ប្រការ ។

ដូច្នេះ បើភិក្ខុសង្ឃ ឈ្លាសវៃក្នុងធម៌ ៨ ប្រការខ្លួនឯង គប្បីក្រាលកឋិនខ្លួនឯងចុះ បើមិនឈ្លាសវៃទេ ត្រូវស្វែងរកលោកឯទៀតដែលឈ្លាសក្នុងធម៌ ៨ ប្រការនោះ និមន្តលោកមកឲ្យជួយចាត់ការ ទើបបាន, បើមិនធ្វើយ៉ាងនេះទេ មិនគួរក្រាលកឋិនឡើយ ។ រីឯព្រះថេរៈដែលនិមន្តមកពីក្រៅជាជំនួយនោះ មិនត្រូវក្រាលកឋិនខ្លួនឯងទេ ត្រូវគ្រាន់តែជួយចាត់ចែងធ្វើនូវកិច្ចគ្រប់យ៉ាងមានបុព្វកិច្ចជាដើម ហើយគប្បីឲ្យភិក្ខុអ្នកនៅក្នុងសីមា ដែលបានចូលបុរិមវស្សាទាំងប៉ុន្មាននោះ ក្រាលកឋិន អនុមោទនាកឋិនចុះ ។

### អំពីកឋិនទាយក "អ្នកប្រគេនសំពត់កឋិន"

ស. សំពត់កឋិន តើបុគ្គលប្រភេទណាប្រគេន ទើបគួរ ?

ឆ. អដ្ឋកថា ប្រាប់ថា[១] បុគ្គលណាមួយ គឺទេវតាក្តី មនុស្សក្តី បណ្តាសហធម្មិកទាំង ៥ គឺភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរៈ សាមណេរី សហធម្មិកណាមួយក្តី ប្រគេន គួរទាំងអស់ ។

ស. ចុះកឋិនទាយក "អ្នកប្រគេនសំពត់កឋិន" ត្រូវមានកិច្ចវត្តយ៉ាងណាដែរឬទេ ?

---

១- យេន កេនចិ ទេវេន វា មនុស្សេន វា បញ្ចន្នំ វា សហធម្មិកានំ អញ្ញតរេន ទិន្នំ វដ្ដតិ ។

ង. មាន, ក្នុងអដ្ឋកថា លោកប្រាប់ថា កឋិនទាយកត្រូវមានកិច្ចវត្តយ៉ាងនេះ គឺថា បើកឋិនទាយកមិនដឹងនូវកិច្ចដែលនឹងធ្វើចីវរនោះទេ ហើយគេសួរភិក្ខុថា « កឋិនត្រូវយើងខ្ញុំប្រគេនដូចម្តេច ?» ភិក្ខុត្រូវប្រាប់ទៅគេវិញយ៉ាងនេះថា « ត្រូវអ្នកនាំយកនូវសំពត់ឲ្យគ្រប់គ្រាន់ល្មមធ្វើចីវរណាមួយបាន ក្នុងចីវរទាំង ៣ គឺស្បង់, ចីពរ និងសង្ឃាដី ហើយវេរប្រគេនដំនុំសង្ឃដោយពាក្យថា កឋិនចីវរំ (១) ទេម « យើងខ្ញុំសូមវេរប្រគេន នូវកឋិនចីវរ» ឬវេរថា ឥមិនា វត្ថេន កឋិនំ អត្ថរតុ « សូមព្រះភិក្ខុសង្ឃក្រាលនូវកឋិនដោយសំពត់នេះចុះ» ដូច្នេះក៏បាន ក្នុងសម័យដែលអរុណទើបរះ រួចហើយត្រូវអ្នកប្រគេនម្ជុលចំនួនប៉ុណ្ណោះ, បេសចំនួនប៉ុណ្ណោះ, គ្រឿងជ្រលក់ចំនួនប៉ុណ្ណោះ, ដើម្បីបរិកម្មគឺធ្វើចីវរនោះ ក្រៅពីនេះត្រូវអ្នកប្រគេនយាគូនិងភត្ត ដល់ភិក្ខុចំនួន ប៉ុណ្ណោះអង្គដែលកំពុងធ្វើបរិកម្ម គឺចាត់ចែងធ្វើចីវរនោះផង ទើបគួរ» ៗ (បើកឋិនទាយកគេសួរ សឹមប្រាប់, បើគេមិនសួរ មិនត្រូវប្រាប់ទេ ប៉ុន្តែមិនត្រូវប្រាស្រ័យឲ្យហួសហេតុឡើយ ) ។

គម្ពីរធម្មសម្ពហវិន័យ ប្រាប់វិធីវេរសំពត់កឋិនថា ត្រូវកឋិនទាយកនោះ យកសំពត់កឋិនទៅតម្កល់ក្នុងហត្ថបាសដំនុំសង្ឃ ដែលគង់ ឬឈរក្នុងវត្តដែលនៅចាំវស្សា ហើយវេរប្រគេនដោយបញ្ចេញវាចាយ៉ាងច្បាស់

១ គួរបន្ថែមបាលីមួយម៉ាត់ថា « សង្ឃស្ស » ត្រង់ចន្លោះនេះ ទើបបានសេចក្តីល្អ ។

ថា "កឋិនចីវរំ(១) ខេម យើងខ្ញុំសូមវេរប្រគេនចីវរកឋិន" ។

ស. កាលបើកឋិនទាយក វេរសំពត់កឋិនមក តើសង្ឃត្រូវទទួលដូចម្ដេច ?

ឆ. តាមគម្ពីរវិនយាលង្ការដីកា ប្រាប់ថា(២) កិច្ចទទួល (ដោយកាយ ឬដោយវាចា) មិនមានទេ, កាលបើទាយកវេរប្រគេនចីវរមក គ្រាន់តែទទួលដោយចិត្តរបស់សង្ឃប៉ុណ្ណោះ ក៏យកជាប្រមាណ(៣) បាន ។

ស. កាលបើសង្ឃបានទទួលសំពត់កឋិនហើយ តើត្រូវប្រតិបត្តិដូចម្ដេចតទៅទៀត ?

ឆ. អដ្ឋកថា ប្រាប់ថា កឋិនដែលកើតឡើងត្រឹមត្រូវតាមធម៌ហើយ ត្រូវឲ្យភិក្ខុអ្នកក្រាលទទួលក្រាលចុះ ប៉ុន្តែកាលដែលក្រាលត្រូវដឹងនូវកិច្ចវត្តផង ព្រោះសំពត់ដែលប្រឡាក់ដោយបាយតម្បាញ គឺសំពត់ថ្មីសុទ្ធក្ដី សំពត់ដែលប្រឡាក់ដោយមន្ទិលផ្សេងៗក្ដី មិនគួរក្រាលទេ ព្រោះហេតុ

---

១ គួរបន្ថែមបាលី ១ ម៉ាត់ថា "សង្ឃស្ស" ត្រង់ចន្លោះនេះ ទើបបានសេចក្ដីល្អ ។ ២ បដិគ្គហណកិច្ចំ នត្ថិ កាយេន ចីវរេ ទិន្នេ សង្ឃស្ស ចិត្តេន សម្បដិច្ឆនមត្តមេវ បមាណំ ហោតិ ។ ៣ ក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ ព្រះសង្ឃគ្រប់វត្ត កាលដែលទាយកវេរកឋិនរួច មិនដែលទទួលដោយកាយ ឬដោយវាចាទេ គ្រាន់តែបញ្ចេញវាចា ថា "សាធុ" ប៉ុណ្ណោះ ។ ពាក្យថា "សាធុ" នេះ មិនមែនបានន័យថាទទួលទេ ជាពាក្យឲ្យពរថា សូមឲ្យសម្រេចតាមប្រាថ្នាចុះ ។ ហេតុនេះ ការបញ្ចេញវាចាថា "សាធុ" នោះ ជាការសមរម្យហើយ ។

នោះ កាលបើភិក្ខុបានសំពត់សាដកសម្រាប់ក្រាលកឋិន ជាសំពត់ថ្មីសុទ្ធ មកហើយ ត្រូវបោកគក់ឲ្យស្អាត ហើយចាត់ចែងគ្រឿងឧបករណ៍សម្រាប់ធ្វើចីវរ មានម្ជុលជាដើម ហើយត្រូវដេរជាមួយនឹងភិក្ខុច្រើនរូប ឲ្យហើយស្រេចក្នុងថ្ងៃនោះ ហើយត្រូវជ្រលក់ ធ្វើពិន្ទុកប្ប អធិដ្ឋាន ក្រាលកឋិនចុះ ។

ស. ពាក្យឆ្លើយនេះចំពោះសំពត់កឋិនថ្មីសុទ្ធ ដែលមិនទាន់ធ្វើជាចីវរនៅឡើយ, ចុះបើទាយកគេវេរប្រគេនចីវរដែលធ្វើស្រេចហើយ តើត្រូវសង្ឃប្រតិបត្តិដូចម្តេច ?

ជ. គម្ពីរវជិរពុទ្ធិដីកា ប្រាប់ថា(១) បើទាយកវេរប្រគេនចីវរដែលមានបុព្វករណៈ(២)ធ្វើស្រេចហើយដល់សង្ឃ ត្រូវសង្ឃទទួលហើយប្រគល់ឲ្យទៅភិក្ខុអ្នកក្រាល ដោយកម្មវាចាចុះ ។ ឯភិក្ខុអ្នកក្រាលកឋិននោះសោត ត្រូវអធិដ្ឋានក្រាលក្នុងមណ្ឌលសីមានោះ រួចហើយ ត្រូវញុំាងសង្ឃឲ្យអនុមោទនាចុះ ព្រោះមិនមានការអ្វីដែលត្រូវធ្វើ ចំពោះចីវរដែលមានបុព្វករណៈដែលគេធ្វើរួចហើយនោះម្តងទៀតទេ ។

---

១ បរិនិដ្ឋិតបុព្វករណមេវ ចេ ទាយកោ សង្ឃស្ស ទេតិ សម្បដិច្ឆិត្វា កម្មវាចាយ ទាតព្វំ ។ តេន ច តស្មិំយេវ សីមមណ្ឌលេ អធិដ្ឋហិត្វា អត្ថរិត្វា សង្ឃោ អនុមោទាបេតព្វោ កតបុព្វករណស្ស បុន កាតព្វាភាវតោ ។ ២ បុព្វករណៈ ៧ គឺ ធោវនៈ បោកគក់, វិចារណៈ ចាត់ចែងវាស់, ឆេទនៈ កាត់, ពន្ធនៈ ដាន, សិព្វនៈ ដេរ, រជនៈ ជ្រលក់, កប្បៈ ពិន្ទុកប្ប ។

# អំពីភិក្ខុជាអ្នកក្រាលកឋិន

ស. កឋិន ត្រូវភិក្ខុរូបណាក្រាល ?

ឆ. កឋិនអដ្ឋកថា ថា សង្ឃប្រគល់កឋិនចីវរឲ្យទៅភិក្ខុរូបណា ត្រូវភិក្ខុរូបនោះក្រាល ។

ស. ចុះសង្ឃត្រូវប្រគល់កឋិនចីវរឲ្យទៅភិក្ខុរូបណា ?

ឆ. អដ្ឋកថា ប្រាប់ថា ភិក្ខុរូបណាមានចីវរចាស់គ្រាំគ្រា សង្ឃត្រូវប្រគល់កឋិនចីវរ ឲ្យទៅភិក្ខុរូបនោះ ។

ស. ចុះបើភិក្ខុដែលមានចីវរចាស់គ្រាំគ្រាមានច្រើនរូប តើសង្ឃត្រូវប្រតិបត្តិដូចម្តេច ?

ឆ. សង្ឃត្រូវប្រគល់កឋិនចីវរ ដល់ភិក្ខុដែលមានចីវរចាស់គ្រាំគ្រាណាស់ ហើយចាស់វស្សាជាងគេ ។

ស. ចុះបើភិក្ខុចាស់ទាំងនោះ មានច្រើនរូប តើសង្ឃត្រូវធ្វើដូចម្តេចទៀត ?

ឆ. សង្ឃត្រូវប្រគល់កឋិនចីវរ ឲ្យទៅភិក្ខុចាស់ជាមហាបុរស ដែលមានសមត្ថភាពអាចធ្វើចីវរឲ្យបានសម្រេច បានក្រាលកឋិនក្នុងថ្ងៃនោះ ។

ស. ចុះបើបណ្តាភិក្ខុចាស់ទាំងនោះ ឥតមានភិក្ខុចាស់រូបណាមួយដែលមានសមត្ថភាពនឹងធ្វើដូច្នោះបាន តើសង្ឃត្រូវធ្វើដូចម្តេចទៀត ?

ឆ. សង្ឃត្រូវប្រគល់កឋិនចីវរ ឲ្យទៅភិក្ខុខ្ចីជាងដែលមានសមត្-

ភាពអាចនឹងធ្វើចីវរឲ្យសម្រេចបាននោះចុះ ប៉ុន្តែ ដែលឲ្យសមរម្យនោះ សង្ឃត្រូវតែសង្គ្រោះចំពោះភិក្ខុជាមហាថេរដែលចាស់ជាងគេ ហើយមានចីវរចាស់គ្រាំគ្រាផង ។ ហេតុនោះសង្ឃគប្បីបង្ខំលោកដែលចាស់ជាងគេឲ្យទទួលដោយពោលថា « សូមឲ្យលោកទទួលចុះ សឹមយើងជួយធ្វើប្រគេន» រួចហើយត្រូវពិនិត្យមើលចីវរប្រក្រតីទាំង ៣ ផ្ទាំងរបស់លោ ។ បើឃើញថាចីវរណាចាស់គ្រាំគ្រាជាងគេ, ត្រូវសូត្រញត្តិប្រគល់សំពត់កឋិនទៅលោក ឲ្យល្មមធ្វើចីវរនោះគ្រាន់, បើចីវរប្រក្រតីរបស់លោកពីរជាន់ ត្រូវប្រគេនលោកឲ្យល្មមធ្វើពីរជាន់បាន, បើចីវរប្រក្រតីរបស់លោកតែ ១ ជាន់ទេតែក្រាស់ ហើយសំពត់កឋិនស្ដើង ក៏ត្រូវប្រគេនលោកឲ្យល្មមធ្វើពីរជាន់ដែរ ដើម្បីឲ្យល្មមគួរដល់ចីវរចាស់របស់លោក, បើទុកជាលោកប្រកែកថា « បើមិនបានពីរជាន់ បានតែមួយជាន់ ក៏ខ្ញុំដណ្ដប់ដែរ» ដូច្នេះ ក៏ត្រូវតែប្រគេនសំពត់កឋិនទៅលោក ឲ្យល្មមធ្វើចីវរពីរជាន់បានទើបគួរ ។

ស. ជំនុំសង្ឃត្រូវប្រគល់សំពត់កឋិន ឲ្យទៅភិក្ខុអ្នកក្រាល ដោយវិធីដូចម្ដេច ?

ឆ. ដោយវិធីសូត្រញត្តិទុតិយកម្មវាចា ។ វិធីសូត្រញត្តិទុតិយ-កម្មវាចានេះ កងគម្ពីរមហាវគ្គ មានពុទ្ធានុញ្ញាតថា ឲ្យភិក្ខុ អង្គមួយរូបដែលឈ្លាសប្រតិពល សូត្រប្រកាសចំពោះសង្ឃថា :

សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស[១] ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស ឥត្ថន្នាមស្ស ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន កឋិនទុស្សំ ឥត្ថន្នាមស្ស ភិក្ខុនោ កឋិនំ អត្ថរិតុំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

*បពិត្រព្រះសង្ឃដ៏ចម្រើន, សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, សំពត់កឋិននេះកើតឡើងដល់សង្ឃហើយ, បើ (ការណ៍នេះ) ជាការគួរដល់សង្ឃហើយ, សង្ឃគប្បីឲ្យនូវសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ដើម្បីក្រាលកឋិន ។ នេះជាពាក្យប្រកាសឲ្យសង្ឃបានជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន, សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, សំពត់កឋិននេះកើតឡើងដល់សង្ឃ*

---

១ ត្រង់ពាក្យថា "ឥត្ថន្នាមស្ស" គ្រប់បទ ត្រូវផ្លាស់យកនាមភិក្ខុអ្នកក្រាលដាក់ជំនួស ។ ត្រង់បាលីថា កឋិនទុស្សំ ប្រើជា កឋិនវត្ថំ វិញក៏បាន ។

ហើយ, (ឥឡូវនេះ) សង្ឃឲ្យនូវសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ដើម្បីក្រាលកឋិន ។ ការឲ្យសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ដើម្បីក្រាលកឋិន គួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ សំពត់កឋិននេះ សង្ឃបានឲ្យទៅភិក្ខុឈ្មោះនេះហើយ ដើម្បីក្រាលកឋិន, គួរដល់សង្ឃហើយ, ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុក នូវ (ការយល់ព្រម) នេះ ដោយតុណ្ហីភាពយ៉ាងនេះ ។

ស. កាលបើសំពត់កឋិន សង្ឃបានប្រគល់ឲ្យហើយ តើភិក្ខុអ្នកក្រាលត្រូវប្រតិបត្តិដូចម្ដេច?

ជ. គម្ពីរបរិវារៈ ប្រាប់ថា ភិក្ខុអ្នកក្រាលកឋិននោះ ត្រូវលាង គក់ ចាត់ចែងវាស់ កាត់ ដេរ ជ្រលក់ ធ្វើពិន្ទុកប្បៈ ឲ្យហើយស្រេចក្នុងថ្ងៃនោះ ហើយក្រាលកឋិនចុះ ។

អដ្ឋកថា ពន្យល់ថា កាលបើសង្ឃប្រគល់សំពត់កឋិនឲ្យយ៉ាងនេះហើយ បើសំពត់កឋិននោះ មានបរិកម្មគេធ្វើរួចស្រេចស្រាប់មកហើយនេះជាការគាប់ប្រសើរហើយ បើសំពត់កឋិនមានបរិកម្មគេមិនទាន់ធ្វើរួចស្រេចនៅឡើយទេ, ភិក្ខុរូបណាមួយអាងថា អញជាថេរៈ ឬអាងថាអញជាពហុស្សុត ហើយមិនជួយធ្វើ ពុំបានឡើយ, ភិក្ខុទាំងអស់ត្រូវតែប្រជុំ

គ្នាជួយបោកគក់ ដេរ ជ្រលក់ ឲ្យហើយស្រេចទើបបាន (១) ។

ក្នុងគម្ពីរវិនយាលង្ការដីកា មានសេចក្ដីពន្យល់នូវពាក្យនៃព្រះអដ្ឋកថាចារ្យខាងលើថា "បើសំពត់កឋិនមានបរិកម្មគេធ្វើរួចស្រេចមកហើយ" នោះឲ្យកាន់តែច្បាស់ថែមទៀតថា ដែលហៅថា "សំពត់កឋិន" មិនមែនបានតែសំពត់សាដកប្រក្រតី គឺសំពត់ថ្មីសុទ្ធប៉ុណ្ណោះទេ ទោះបីសំពត់ជាចីវរដែលមានបុព្វកិច្ចទាំង ៧ ប្រការគេធ្វើរួចស្រេចហើយ ក៏បានទៅជាសំពត់កឋិនពិតប្រាកដ ។ ព្រោះហេតុនោះ កាលបើទាយកប្រគេនចីវរដែលគេធ្វើរួចស្រេចមកហើយ មិនបាច់ត្រូវការអ្វីទីងធ្វើបុព្វកិច្ចទាំង ៧ ប្រការទៀតទេ ត្រូវធ្វើកិច្ចទាំងឡាយមានបច្ចុទ្ធរៈ គឺដកចីវរចាស់ជាដើមតែប៉ុណ្ណោះ, ប៉ុន្តែប្រសិនបើមានកិច្ចបន្តិចបន្តួចមិនទាន់សម្រេច ដោយហោចទៅ សូម្បីត្រឹមតែពិន្ទុកប្បប៉ុណ្ណោះ ក៏ត្រូវញ៉ាំងកិច្ចនោះឲ្យសម្រេចសិន សឹមធ្វើកិច្ចឯទៀតមានបច្ចុទ្ធរៈ ដកចីវរចាស់ជាដើមនោះចុះ ។

ក្នុងគម្ពីរកង្ខាវិតរណី មានបញ្ជាក់អំពីសំពត់កឋិននេះថា(២) សំពត់កឋិនដែលគេធ្វើរួចស្រេចហើយ កើតឡើង (ដល់សង្ឃ) នុះជាការល្អមែនពិត ប៉ុន្តែបើសំពត់កឋិននោះ គេដេរដោយពុំបានកាត់ ក៏ត្រឡប់ជាពុំ

---

១ សេចក្ដីក្នុងអដ្ឋកថា ដែលបង្គាប់ឲ្យភិក្ខុទាំងអស់រួមគ្នាជួយធ្វើនេះ ពុំមានបង្គាប់ឲ្យហៅគ្រហស្ថជួយធ្វើទេ ។ នេះចំពោះតែសំពត់ដែលពុំទាន់សម្រេចជាចីវរ, ឯសំពត់ដែលទាយកគេធ្វើឲ្យជាត្រៃចីវរស្រេចហើយ ក៏គ្រាន់តែពិនិត្យមើលហើយប្រោលកឋិនចុះ ។ ២ សចេ កតមេវ ទេន្តិ សុន្ទរមេវ អច្ឆិន្នសិព្វិតំ បន ន វដ្ដតិ ។

គ្នះទៅវិញ (ត្រូវតែដេរជាចីវរឲ្យត្រឹមត្រូវឡើង ទើបក្រាលជាកឋិនកើត) ។

អដ្ឋកថា ច្បាប់ថា ភិក្ខុអ្នកក្រាល ត្រូវទទួលយកចីវរកឋិនដែលធ្វើរួចស្រេច ហើយក្រាលកឋិនតាមវិធីដែលលោកបានពោលក្នុងគម្ពីរបរិវារៈ ។

គម្ពីរវិនយាលង្ការដីកា ពន្យល់ពាក្យក្នុងអដ្ឋកថាខាងលើនេះ ឲ្យកាន់តែច្បាស់លាស់ថែមទៀតថា ភិក្ខុអ្នកក្រាលត្រូវទទួលយកចីវរកឋិនដែលគេធ្វើនូវបុព្វករណ ទាំង៧ប្រការគឺ : ធោវនៈ ការបោកគក់១ វិចារណៈ ការវាត់វែងកស់ ១ ឆេទនៈ ការកាត់ ១ ពន្ធនៈ ការដាន ១ សិព្វនៈ ការដេរ ១ រជនៈ ការជ្រលក់ ១ កប្បៈ ការធ្វើពិន្ទុកប្បៈ ១ ដែលហៅថាបុព្វកិច្ច រួចសព្វគ្រប់មកហើយនោះ ទៅក្រាលកឋិនចុះ ។

ស. ភិក្ខុអ្នកក្រាល ត្រូវក្រាលកឋិនដូចម្ដេច ?

ឆ. ក្នុងអដ្ឋកថា និងក្នុងគម្ពីរបរិវារៈ បានប្រាប់នូវវិធីក្រាលកឋិនថា បើភិក្ខុចង់ក្រាលកឋិនដោយសង្ឃាដី ត្រូវបច្ចុទ្ធរ៍ដកសង្ឃាដីចាស់របស់ខ្លួនចេញ ហើយអធិដ្ឋានសង្ឃាដីថ្មីឡើង ហើយបញ្ចេញវាចាឲ្យដំនុំសង្ឃបានឮច្បាស់ថា ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ "ខ្ញុំក្រាលកឋិន ដោយសង្ឃាដីនេះ" ។

បើចង់ក្រាលកឋិនដោយឧត្តរាសង្គៈគឺចីពរ ត្រូវបច្ចុទ្ធរ៍ដកឧត្តរាសង្គៈចាស់របស់ខ្លួនចេញ អធិដ្ឋានឧត្តរាសង្គៈថ្មីឡើង ហើយបញ្ចេញវាចាឲ្យ

ដំនុំសង្ឃបានឮប្រកាសថា ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ " ខ្ញុំក្រាលកឋិន ដោយឧត្តរាសង្គៈនេះ " ។

បើជាក្រាលកឋិនដោយអន្តរវាសកៈ គឺស្បង់ ត្រូវបច្ចុទ្ធរណ៍អន្តរវាសកៈចាស់របស់ខ្លួនចេញ អធិដ្ឋានអន្តរវាសកៈថ្មីឡើង ហើយបញ្ចេញវាចាឲ្យជំនុំសង្ឃបានឮប្រកាសថា ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ "ខ្ញុំក្រាលកឋិន ដោយអន្តរវាសកៈនេះ" ។

កាលបើភិក្ខុបានក្រាលកឋិនយ៉ាងនេះរួចហើយ គប្បីចូលទៅជិតសង្ឃ ឬគណៈ ឬបុគ្គល គ្រងចីពរស្មាម្ខាង អង្គុយប្រហោងប្រណម្យអញ្ជលីឡើង ពោលចំពោះសង្ឃ ឬគណៈ ឬបុគ្គលទាំងនោះឲ្យអនុមោទនាថា អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថារោ, អនុមោទថ "បពិត្រលោកដ៏ចម្រើនទាំងឡាយ; កឋិនរបស់សង្ឃខ្ញុំក្រាលរួចហើយ, ការក្រាលកឋិននេះប្រកបដោយធម៌, សូមលោកទាំងឡាយអនុមោទនាចុះ" ។

ត្រង់ពាក្យថា ភន្តេ បើភិក្ខុអ្នកក្រាលចាស់ជាងភិក្ខុអ្នកអនុមោទនាទាំងអស់ ត្រូវផ្លាស់ថា អាវុសោ ដូច្នេះវិញ ។ បើភិក្ខុអ្នកអនុមោទនា ចាស់ជាងភិក្ខុអ្នកក្រាល តាំងពី១រូបឡើងទៅ ត្រូវថា ភន្តេ ដដែល ។

ត្រង់ពាក្យថា អនុមោទថ បើភិក្ខុអ្នកអនុមោទនាមានច្រើន

រូប ឬមានតែមួយរូប ប៉ុន្តែចាស់ជាងភិក្ខុអ្នកក្រាល ត្រូវថា អនុមោ-ទាម ដដែល ។ បើភិក្ខុអ្នកអនុមោទនា មានតែមួយរូបហើយខ្ចីជាងភិក្ខុអ្នកក្រាល, ត្រូវផ្លាស់ថា អនុមោទាមិ ដូច្នេះវិញ ។

ចំណែកភិក្ខុអ្នកអនុមោទនាវិញ ត្រូវគ្រងចីពរស្ពាយម្ខាង អង្គុយប្រ-ហោង ប្រណម្យអញ្ជលីឡើង អនុមោទនាដោយបញ្ចេញវាចាថា អត្ថតំ អាវុសោ សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថារោ, អ-នុមោទាម ម្នាលលោកអ្នកមានអាយុ, កឋិនរបស់សង្ឃ លោកក្រាលរួចហើយ, ការក្រាលកឋិននេះប្រកបដោយធម៌, យើងទាំងឡាយសូមអនុមោទនា ។

ត្រង់ពាក្យថា អាវុសោ សម្រាប់ប្រើចំពោះតែភិក្ខុអ្នកអនុមោទនាចាស់ជាងភិក្ខុអ្នកក្រាល បើភិក្ខុអ្នកអនុមោទនាខ្ចីជាងភិក្ខុអ្នកក្រាល ត្រូវផ្លាស់ថា ភន្តេ ដូច្នេះវិញ ។

ត្រង់ពាក្យថា អនុមោទាម សម្រាប់ប្រើចំពោះតែភិក្ខុអ្នកអនុមោទនាច្រើនរូបតាំងពីពីររូបឡើងទៅ, បើភិក្ខុអ្នកអនុមោទនាមានតែមួយរូប ត្រូវថា អនុមោទាមិ ដូច្នេះវិញ ។

អដ្ឋកថា ប្រាប់ថា(១) កាលបើភិក្ខុមួយរូបជាអ្នកក្រាល ភិក្ខុឯទៀត

១ ឯវំ សព្វេសំ អត្ថតំ ហោតិ កឋិនំ ។

ជាអ្នកអនុមោទនាយ៉ាងនេះ ឈ្មោះថាបានក្រាលកឋិនរបស់គ្នា ។

គម្ពីរវិនយាលង្ការដីកា មានសេចក្ដីបញ្ជាក់ដោយធ្វើជាពាក្យសួរឆ្លើយ ដូចមានតទៅនេះ ៖

ស.[១] អានិសង្ស ៥ កើតមានដំណាលគ្នានឹងការក្រាលកឋិន តាមន័យដែលមានក្នុងគម្ពីរបរិវារៈថា "ធម៌ ១៥ ប្រការ គឺអានិសង្ស ៥ មាតិកា ៨ និងបលិពោធ ២ កើតដំណាលគ្នានឹងការក្រាលកឋិន, កាលបើដូច្នេះ ហេតុអ្វីក៏ចាំឲ្យភិក្ខុអ្នកក្រាលញ៉ាំងសង្ឃឲ្យអនុមោទនា ?" ។

ឆ.[២] "អានិសង្សទាំង ៥ កើតមានដល់ភិក្ខុជាអ្នកក្រាលពិតមែន ប៉ុន្តែមិនកើតមានដល់សង្ឃឡើយ ព្រោះហេតុនោះ ទើបភិក្ខុអ្នកក្រាលញ៉ាំងសង្ឃឲ្យអនុមោទនា ដើម្បីឲ្យអានិសង្ស ៥ កើតមានដល់សង្ឃផង ចំណែកសង្ឃក៏ត្រូវតែធ្វើអនុមោទនា, កាលបើធ្វើយ៉ាងនេះ អានិសង្សទាំង ៥ ត្រូវកើតមានដល់បុគ្គលទាំងពីរពួក គឺភិក្ខុអ្នកក្រាល និងសង្ឃអ្នកអនុមោទនា" ។

គម្ពីរបរិវារៈ មានសេចក្ដីត្រូវគ្នាថា សង្ឃក្រាលកឋិនមិនបានទេ គណៈក៏ក្រាលកឋិនមិនបានទេ បុគ្គលទើបក្រាលកឋិនបាន ។ ដោយ

---

១ សហេវ កឋិនស្ស អត្ថារា បណ្ណរសធម្មា ជាយន្តីតិ បរិវារេ អាគតត្តា កឋិនត្ថារេន សមេវ បញ្ច អានិសំសា អាគតា អថ កស្មា សង្ឃំ អនុមោទាបេតិ ។ ២ កិញ្ចាបិ អត្ថារកស្ស ភិក្ខុនោ បញ្ច អានិសំសា អាគតា សង្ឃស្ស បន អនាគតា កស្មា សង្ឃស្ស ច អាគមនត្ថំ សង្ឃំ អនុមោទាបេតិ សង្ឃោ ច អនុមោទនំ ករោតិ ឯវំ កតេ ទ្វិន្នំបិ អានិសំសា អាគតា ។

អនុមោទនារបស់សង្ឃ ដោយអនុមោទនារបស់គណៈ និងដោយការក្រាលរបស់បុគ្គល, កឋិនឈ្មោះថាសង្ឃ គណៈ និងបុគ្គល បានក្រាលទាំងអស់គ្នា ។

## អំពីអានិសង្សលាភ

អដ្ឋកថា ប្រាប់ថា កាលបើភិក្ខុក្រាលកឋិនយ៉ាងនេះហើយ បើទាយកវេរប្រគេនសំពត់ជាអានិសង្សលាភ ដែលគេនាំមកជាមួយនឹងចីវរកឋិន ដោយពាក្យថា យេន អម្ហាកំ កឋិនំ គហិតំ តស្សេវ ទេម «កឋិនរបស់យើងខ្ញុំ លោកអង្គណាទទួល យើងខ្ញុំសូមវេរប្រគេនចំពោះលោកអង្គនោះ» ដូច្នេះភិក្ខុសង្ឃមិនបានជាឥស្សរៈឡើយ ប៉ើលុះតែគេមិនបានតាំងដូច្នោះ គេគ្រាន់តែវេរប្រគេនហើយត្រឡប់ទៅផ្ទះវិញ ទើបភិក្ខុសង្ឃបានជាឥស្សរៈ ។ ព្រោះហេតុនោះ បើចីវរដ៏សេសទាំងប៉ុន្មានរបស់ភិក្ខុអ្នកក្រាលកឋិន ជាចីវរទុព្វលភាព ហើយសំពត់ជាអានិសង្សលាភរបស់កឋិនមានច្រើន (បើសង្ឃបានជាឥស្សរៈ) សង្ឃគប្បីអបលោកប្រគេនសំពត់បន្ថែមទៅលោកអ្នកក្រាលនោះទៀត ដើម្បីប្រយោជន៍ធ្វើចីវរទាំងនោះ, ប៉ុន្តែ ការស្មូត្រកម្មវាចាតែម្តងក៏គួរហើយ ។ ឯសំពត់កឋិនានិសង្សលាភ ដែលសេសសល់ពីនោះ បើមានច្រើន ត្រូវចែកប្រគេនតាមបញ្ជីសំពត់ចំណាំវស្សា, បើមិនមានបញ្ជីទេ ត្រូវប្រគេនតាំងអំពីអាសនៈនៃព្រះថេរៈចុះមក, ឯគ្រឿងគរុភណ្ឌ មិនត្រូវចែកគ្នាឡើយ ។

ក្នុងគម្ពីរវិនយាលង្ការដីកា លោកបានពន្យល់អំពីការចែកអានិសង្សលាភ ឲ្យកាន់តែទូលាយឡើងទៀតថា(១) អកាលចីវរដែលសង្ឃតម្កល់ទុកក្នុងឃ្លាំង សង្ឃត្រូវបែងចំណែកពាក់កណ្ដាលចែកឲ្យសាមណេរទាំងឡាយ, ឯសំពត់ចំណាំវស្សា និងសំពត់ជាកឋិនានិសង្សជាដើម ដែលជាកាលចីវរ ក៏ត្រូវសង្ឃចែកឲ្យសាមណេរឲ្យស្មើគ្នានឹងភិក្ខុដែរ(២) ។

វិធីក្រាលកឋិន ចប់

## អនត្ថតាការ

អាការដែលភិក្ខុក្រាលមិនឡើងជាកឋិនឡើយ ហៅថា អនត្ថតាការ ។

ស. កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការយ៉ាងណាខ្លះ?

ឆ. តាមព្រះពុទ្ធដីកាក្នុងគម្ពីរមហាវគ្គថា កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការ ២៤ យ៉ាងគឺ ៖

ទី ១- ឧល្លិខិតមត្តេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែវាស់គូសក្រិតស្ទង់មើលបណ្ដោយ-ទទឹងប៉ុណ្ណោះ ។

---

១- ភណ្ឌាគារេ ឋបិតំ ហិ អកាលចីវរមេវ សាមណេរានំ ឧបឌ្ឍបដិវីសំ ទាតព្វំ វស្សាវាសិកកឋិនានិសំសាទិកាលចីវរំ បន សមកមេវ ទាតព្វំ ។ ២ ចំពោះសាមណេរដែលបានចូលវស្សា, ឯសាមណេរដែលពុំបានចូលវស្សាទេ សង្ឃគួរសង្គ្រោះចែកឲ្យដោយអបលោកនកម្ម ឬ បើមិនឲ្យសោះ ក៏គ្មានកំហុសអ្វីឡើយ ។

ទី២- ធោវនមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែបោកគក់លាង ។

ទី៣- ចីវរវិចារណមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែចាត់ចែងលៃលកទុកដាក់យ៉ាងនេះយ៉ាងនោះថា នេះជាចីវរបញ្ចខណ្ឌ, នេះជាចីវរសត្តខណ្ឌ, នេះជាចីវរនវខណ្ឌ, នេះជាចីវរឯកាទសខណ្ឌ ។

ទី៤- ឆេទនមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែកាត់តាមបែបដែលបានចាត់ចែងលៃលកទុក ។

ទី៥- ពន្ធនមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែដានផ្គុំភ្ជាប់គ្នា ។

ទី៦- ឱវដ្ដិយករណមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែដេរថ្នេរវែង ៗ ឬ រង្វើល ៗ ។

ទី៧- កណ្ឌុសករណមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែភ្ជាប់ក្តុំ និងក្រវិលក្តុំ ។

ទី៨- ទឡ្ហីកម្មករណមត្តេន កិច្ចក្រាលកឋិនដោយសំពត់ដែល គ្រាន់តែថែមសំពត់ ដើម្បីធ្វើឲ្យមាំ ។

ទី៩- អនុវាតករណមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែលើកឡើង នូវអនុវាតខាងបណ្តោយ ឬអនុវាតខាងទទឹង ។

(មានត)

# ព្រះពុទ្ធសាសនា និង សិទ្ធិមនុស្ស

កាលបើពោលដល់រឿងសិទ្ធិសេរីភាពហើយ មិនចាំបាច់តាំងបញ្ហាសួរឡើយថា តើមានមនុស្សដែលមិនចង់បានសិទ្ធិសេរីភាពខ្លះដែរឬទេ? ព្រោះសិទ្ធិសេរីភាពគឺជាអំណាចរបស់មនុស្សម្នាក់ៗ ដែលអាចធ្វើកិច្ចការអ្វីគ្រប់យ៉ាងបាន ដែលមិនប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ដោយគ្មានទរណាបង្ខិតបង្ខំ ឬហាមឃាត់មិនឲ្យធ្វើ ។ មនុស្សណាក៏ដោយដែលកើតមកក្នុងលោកនេះ ឥតមានទរណាមួយចង់នៅក្រោមអំណាចបង្ខិតបង្ខំឲ្យធ្វើការ ឬហាមមិនឲ្យធ្វើការងារទាល់តែសោះ, ផ្ទុយទៅវិញ មនុស្សគ្រប់គ្នាសុទ្ធតែចង់បានសិទ្ធិសេរីភាព ចង់មានអំណាចអាចធ្វើកិច្ចការគ្រប់បែបយ៉ាងបានតាមចំណង់ចិត្តខ្លួនដូចគ្នាទាំងអស់ សូម្បីតែសត្វតិរច្ឆានដែលមានសញ្ញាតញ្ញាណនិងភាសាផ្សេងពីមនុស្ស ក៏យើងអាចសង្កេតដឹងបានដោយព្រឹត្តិកម្មគឺការសំដែងអាការៈចេញមកថា មានសេចក្ដីស្រឡាញ់សិទ្ធិសេរីភាពដូចមនុស្សដែរ ។ ឧទាហរណ៍ដូចសត្វលលកឬទទាជាដើម ដែលគេចាប់ដាក់ទ្រុង សត្វនោះតែងស៊ុះស្វារយកចំពុះលូកតាមចន្លោះទ្រុង ដើម្បីរកផ្លូវចេញឲ្យផុតពីទ្រុង ។ ព្រឹត្តិកម្មគឺការអុទ្ទះអន្ទែងច្រួលច្រាល់រកផ្លូវចេញឲ្យផុតពីទ្រុងនេះហើយដែលសំដែងឲ្យដឹងថា សូម្បីតែសត្វក៏ចេះចង់បានសិទ្ធិសេរីភាពក្នុងជីវិតរបស់ខ្លួន. គឺចង់ចេញឲ្យផុតពីការឃុំឃាំង ហើយ

អាចហើរទៅមករកអាហារចំណីបរិភោគតាមសេចក្ដីគាប់ចិត្តរបស់ខ្លួន ដូចមនុស្សគ្រប់រូបដែរ ។ ការចង់មានសិទ្ធិសេរីភាពនេះ គឺជារឿងធម្មជាតិរបស់មនុស្សសត្វទៅ តែក៏មានការព្យាយាមសង្កត់សង្កិនបំបិទសិទ្ធិសេរីភាពរបស់មនុស្សសត្វសម្រេបប្រឆាំងគ្នាជាធម្មតាដែរ ។ ហេតុនេះ ទើបមនុស្សនិងសត្វបានទទួលការសង្កត់សង្កិនដោយអំណាច តាំងពីបុរាណ-កាលមក ប្ដូកគ្នាតែសត្វត្រូវរំលោភដោយការចាប់ចងឃុំឃាំងកាប់សម្លាប់ឬប្រើប្រាស់តាមអំណាច, ចំណែកមនុស្ស ខ្វះសិទ្ធិសេរីភាពដោយហេតុច្រើនយ៉ាង ។ ក្នុងទីនេះ សូមលើកយកតែរឿងទាសភាពមួយមកពណ៌នា ព្រោះមនុស្សដែលធ្លាក់ខ្លួនទៅជាទាសទាសីគេនេះ ត្រូវរស់នៅក្រោមអំណាចត្រួតត្រារបស់ចៅហ្វាយនាយជាដរាប គ្មានសិទ្ធិអំណាចនឹងធ្វើអ្វីបានតាមសេចក្ដីប្រាថ្នារបស់ខ្លួនឡើយ ។

ទាសភាព មានន័យថា ភាពជាខ្ញុំកញ្ជះឬខ្ញុំបម្រើគេដោយគ្មានព្រំដែន ។ មនុស្សគ្រប់រូបក្នុងលោកនេះ គ្មាននរណាមួយចង់ធ្វើជាទាសទាសីខ្ញុំកញ្ជះបម្រើគេទេ សុទ្ធតែចង់រស់នៅដោយសេរីចង់មានអំណាចអាចគ្រប់គ្រងខ្លួនដោយខ្លួនឯងទាំងអស់ ប៉ុន្តែ មនុស្សទាំងនេះ ភាគច្រើនណាស់ត្រឡប់ជាចង់តែឲ្យអ្នកដទៃមកនៅក្រោមអំណាចខ្លួន គឺខ្លួនមិនចង់ធ្វើជាខ្ញុំកញ្ជះគេទេ តែចង់ឲ្យគេមកធ្វើជាខ្ញុំកញ្ជះខ្លួនទៅវិញ ។ ក្រៅពីព្រះសម្មាសម្ពុទ្ធបរម-គ្រូហើយ មនុស្សជាន់បុថុជ្ជន ឃើញមានតែលោក អាប្រាហាម លិនខុន

មួយប៉ុណ្ណោះទេ ដែលបានពោលនូវមតិចំពោះរឿងនេះ ឲ្យមនុស្សក្នុងសកលលោកចាំទុកក្នុងផ្ទៃចិត្តដោយមិនមានពេលភ្លេចថា « ដោយខ្ញុំមិនចង់ធ្វើជាខ្ញុំកញ្ជះគេ ខ្ញុំក៏មិនចង់ធ្វើជាម្ចាស់គេដែរ » ។ តែដោយមនុស្សភាគច្រើនជាអ្នកឃើញតែប្រយោជន៍ផ្ទាល់ខ្លួនដូចពោលមកនេះហើយ ទើបការមានខ្ញុំកញ្ជះទុកប្រើនិងការទិញលក់មនុស្ស សម្រាប់ធ្វើជាខ្ញុំបម្រើដែលហៅថា ការជួញទាសទាសី បានកើតមានតាំងពីបុរាណកាលយូរយារណាស់មកហើយ ថែមទាំងក្លាយទៅជាប្រពៃណីរបស់មនុស្សទូទៅក្នុងលោកដោយគ្មាននរណាមួយនឹកឃើញថាជារឿងអាក្រក់គួរតិះដៀលរិះគន់នោះឡើយ ។ ចុះហេតុដូចម្ដេច ទើបព្រះពុទ្ធជាម្ចាស់ទ្រង់មានព្រះទ័យចាប់អារម្មណ៍ក្នុងរឿងទាសភាព ដែលសាស្ដាដទៃទៀតគ្មានរវល់ពាល់តែនោះ ។ រឿងនេះមកអំពីមនុស្សដែលធ្លាក់ខ្លួនទៅជាទាសទាសីបម្រើគេដោយឥតព្រំដែន គឺជាមនុស្សដែលបានទទួលសេចក្ដីទុក្ខលំបាកទាំងផ្លូវកាយទាំងផ្លូវចិត្តព្រោះត្រូវគេប្រើអំណាចបង្ខំឱ្យធ្វើការងារតាមគោលបំណងរបស់គេ ដោយគ្មានការធានាក្នុងជីវិតរាងកាយបន្តិចបន្តួចឡើយ មានពិធីបុណ្យទានដែលគួរនឹងទៅលេងកំសាន្ត ហើយខ្លួនក៏ប្រាថ្នានឹងទៅដែរក៏គ្មានសិទ្ធិនឹងទៅ, ទទួលទានអាហារក៏មិនបានឆ្ងាញ់ពិសាដូចគេ, ទទួលទានដំណេកក៏មិនបានស្រួល, សម្លៀកបំពាក់សោតក៏ពុំដែលបានល្អសមរម្យ ពេលមានជំងឺក៏ឥតបានទទួលការព្យាបាលដោយដិតដល់, ទាំងគ្មានការ

យោគយល់ពីចៅហ្វាយនាយទៀតផង ។

ដូចពោលមកហើយថា មនុស្សគ្រប់រូបឥតមាននរណាមួយចង់ទៅជាទាសទាសីបម្រើគេទេ តែដែលមនុស្សធ្លាក់ខ្លួនទៅជាយ៉ាងនេះ មកពីបុព្វហេតុដូចតទៅនេះ

១– ទៅជាទាសទាសី ដោយសារពូជពង្ស គឺមាតាបិតាជាទាស. ទាសីគេមកហើយ លុះមានកូនមក កូននោះក៏ក្លាយទៅជាទាសទាសីគេទៅដែរ ដោយចៅហ្វាយនាយគេប្រកាន់ថាជាបុញ្ញលាភរបស់គេ ។

២– មាតាបិតាមិនមែនជាទាសទាសីគេទេ តែមកពីការទាល់ក្រ ឬមានហេតុចាំបាច់បង្ខំឲ្យលក់កូនឲ្យទៅធ្វើជាទាសទាសីគេ ដើម្បីយកប្រាក់មកប្រើប្រាស់ ។

៣– សម័យមានសង្គ្រាម ពួកដែលមានជ័យជំនះ កៀរយកមនុស្សខាងពួកដែលចាញ់ទៅធ្វើជាទាសទាសី ។

៤– ខ្លួនជាអ្នកជា តែត្រូវគេលបចាប់នាំយកទៅធ្វើជាទាសទាសី ។

៥- ជំនួញទាសទាសី ដែលនិយមធ្វើជាអាជីវកម្មនៅប្រទេសក្រិក្ស និង ប្រទេសដទៃទៀតខ្លះ ដែលជាហេតុឲ្យមនុស្សក្លាយទៅជាទាសទាសីជាចើន ។

៦- ខ្លួនមិនមែនជាទាសទាសីទេ តែដោយសេចក្តីទាល់ក្រ ឬប្រាថ្នានឹងតបស្នងសងគុណមាតាបិតាដែលទាល់ក្រជំពាក់បំណុលគេ ក៏

ព្រមលក់ខ្លួនទៅធ្វើជាទាសទាសីគេ ដើម្បីយកប្រាក់មកដោះបំណុល ។

នៅក្នុងលោក ដែលមនុស្សភាគច្រើន ចង់តែយកគេធ្វើជាខ្ញុំកញ្ជះបម្រើខ្លួននេះ ក៏មានមនុស្សដែលមានសន្តានចិត្តចេះគិតប្រៀបធៀបចិត្តគេចិត្តឯង ហើយមានគំនិតគិតជួយសង្គ្រោះពួកដែលធ្លាក់ខ្លួនទៅជាខ្ញុំបម្រើគេនោះឲ្យបានរួចជាអ្នកជា មានសិទ្ធិសេរីភាពឡើង ដែលជាការប្រឆាំងនឹងពួកមនុស្សដែលឃើញតែប្រយោជន៍ផ្ទាល់ខ្លួននោះដែរ ។ អាស្រ័យហេតុនេះហើយបានជានៅសម័យកាលប្រមាណជាង១០០ឆ្នាំមុននេះ នៅសហរដ្ឋអាមេរិក មានមនុស្សមួយពួកខំព្យាយាមបំបាត់ចោលនូវរបបមានខ្ញុំកញ្ជះបម្រើនេះ ។ មនុស្សបែបនេះ បានបង្កើតគណៈបក្សនយោបាយមួយ មានឈ្មោះថា គណៈបក្សរិពុប្ល៊ីគឹន ។ គោលបំណងដ៏ធំបំផុតនៃគណៈបក្សនេះ គឺការបំបាត់ទាសភាព ។ ក្នុងចំណោមនេះ លោកអាប់·ប្រាហាំមលិងខន ប្រធានាធិបតីនៃសហរដ្ឋអាមេរិក ដែលបានពោលនាមមកពីខាងដើមនោះ ក៏ជាអ្នកចាប់អារម្មណ៍ក្នុងរឿងនេះជាងអ្វីទាំងអស់មួយរូបដែរ ។ ហេតុនោះ លោកទើបចូលរួមជាមួយពួកនេះ ដោយឧទ្ទិសជីវិតរបស់លោកចំពោះការបំបាត់ទាសភាពនេះ ដើម្បីជួយឲ្យមនុស្សគ្រប់រូបដែលមានកំណើតជាមនុស្សដូចគ្នា មានសិទ្ធិសេរីភាពស្មើគ្នាឡើងវិញ ហើយបានត្រូវគេតែងតាំងឲ្យធ្វើជាប្រធាននៃគណៈបក្សនេះ ក្នុងពេលដែលលោកមានអាយុ៥០ឆ្នាំ ។ ក្រោយពីនោះមក ១ ឆ្នាំប៉ុណ្ណោះ នៅ

សហរដ្ឋអាមេរិក ក៏កើតមានសង្គ្រាមផ្ទៃក្នុងឡើង គឺចម្បាំងរវាងពលរដ្ឋភាគខាងជើងដែលព្យាយាមបំបាត់ទាសភាព និងពលរដ្ឋភាគខាងត្បូង ដែលនិយមរបបមានទាសភាព ។ តែនៅទីបំផុត ជ័យជំនះក៏បានទៅពួកពលរដ្ឋភាគខាងជើង គឺពួកអ្នកចំបំបាត់ទាសភាព ដែលមានលោកអាប់ប្រាហ័មលិងខុនជាអ្នកដឹកនាំ ។ របបមានទាសភាព ក៏បានត្រូវរដ្ឋការនៃសហរដ្ឋអាមេរិក ប្រកាសបំបាត់ចោលដោយដាច់ខាត ដោយសារការបូជាជីវិតរបស់លោកអាប់ប្រាហ័មលិងខុន ដើម្បីតស៊ូក្នុងរឿងនេះ ។ ការបរិច្ចាគជីវិត ដើម្បីបំបាត់ទាសភាពនេះហើយ ដែលជាហេតុធ្វើឲ្យលោកលិងខុនមានកិត្តិស័ព្ទល្បីខ្ទរទៅថា ជារដ្ឋបុរសដ៏ធំនៃលោក តែក៏ការតស៊ូដដែលនេះដែរ ដែលនាំឲ្យពួកប្រឆាំងក្នុងរឿងបំបាត់ទាសភាព ធ្វើឃាតកម្មលើរូបលោក គឺក្រោយមក លោកលិងខុន បានត្រូវពួកបដិបក្ខលបប្រហារជីវិត ដល់នូវមរណភាព នៅឆ្នាំ ១៨៦៥ ដែលពួកជនជាទាសទាសីក្នុងសកលលោក ត្រូវចារឹកទុកក្នុងហឫទយវត្តដោយមិនមានពេលភ្លេច ដរាបដល់អវសាននៃជីវិត ។ រឿងទាសភាពនេះ ទុកណាជាមានការប្រឹងប្រែងក្នុងការបំបាត់យ៉ាងនេះ ក៏មិនបានបាត់រលត់ទៅភ្លាមឡើយ គឺនៅមានទាសពេញសកលលោក តែការព្យាយាមបំបាត់ទាសភាព ក៏ចេះតែរីកចម្រើនឡើងជាលំដាប់ ៗដែរ ។ ហេតុនេះ នៅពេលដែលសង្គ្រាមលោកលើកទី ១ ស្ងប់ហើយ ជនជាតិនានាក៏បាននាំគ្នាបង្កើត

អង្គការមួយឡើង ហៅថា សន្និបាតជាតិ (League of the Nations) មានទីស្នាក់ការនៅក្រុងហ្សឺណែវ ប្រទេសស្វ៊ីស ដោយមានគោលបំណងដើម្បីស្វែងរកសន្តិភាព ហើយបានអនុវត្តនូវកិច្ចការដើម្បីបំបាត់ទាសភាព ដែលមានសល់នៅក្នុងភូមិភាគនានានៃសកលលោក ដោយបានចាត់ការជាលំដាប់ ៗ គឺ:

១ - បានអនុវត្តអនុសញ្ញាឆ្នាំ ១៩១៩ ស្តីពីការបំបាត់ទាសភាពដោយផ្តែកបំណងដើម្បីព្យាយាមធ្វើឲ្យបានសម្រេច ក្នុងការបំបាត់របបមានទាសទាសីដោយគ្រប់ករណី រួមទាំងជំនួញទាសទាសីទាំងផ្លូវទឹកសមុទ្រនិងផ្លូវគោកយ៉ាងដាច់ខាត ។

២ - បានតែងតាំងគណៈកម្មាធិការអ្នកជំនាញការ ខាងការបំបាត់ទាសភាពជាពិសេសឡើងនៅឆ្នាំ ១៩២៤ មានឈ្មោះថា ( Committee of Experts ។

៣ - បានអនុវត្តអនុសញ្ញាស្តីពីរបបទាសភាព នៅឆ្នាំ ១៩២៦ ដោយមានប្រទេសផ្សេង ៗ បានឲ្យសច្ចាប្រណិធាន រួមទាំងអស់ ២៦ ប្រទេស ។

៤ - បានអនុវត្តអនុសញ្ញាស្តីពីរបបទាសកម្មករ នៅឆ្នាំ ១៩៣០ ដើម្បីដោះស្រាយបញ្ហាការប្រើកម្មករឲ្យធ្វើការដោយបង្ខិតបង្ខំ និងដោយអយុត្តិធម៌ ។

៥ – បានតែងតាំងគណៈកម្មាធិការលើកទី ២ ឡើងទៀត ក្នុងឆ្នាំ ១៩៣២ មានឈ្មោះថា (Secondary Slavery Committee) ។

៦– បានចាត់តាំងគណៈកម្មាធិការជាស្ថាពរ ស្ដីពីទាសភាព នៅឆ្នាំ ១៩៣២ នេះដែរ គឺកម្មការទីប្រឹក្សាអ្នកជំនាញការ ។

តពីនោះមក កាលបើសង្គ្រាមលោកលើកទី ២ ចប់ចុះហើយ ប្រជាជាតិផ្សេងៗក៏បានប្រជុំគ្នាបង្កើតឲ្យមានអង្គការមួយឡើងទៀត ហៅថា អង្គការសហប្រជាជាតិ ដោយបានរៀបចំឲ្យមានធម្មនុញ្ញសហប្រជាជាតិ ហើយអនុវត្តកិច្ចការក្នុងឆ្នាំ ១៩៤៥ ។ ក្នុងធម្មនុញ្ញនេះ មានធម្មនុញ្ញបទមួយស្ដីពីសិទ្ធិមនុស្ស ដោយបានប្រកាសប្រើកាលពីថ្ងៃទី ១ ធ្នូ ១៩៤៨ ដើម្បីព្យាយាមបំបាត់ទាសភាព ជួយឲ្យមនុស្សមានសិទ្ធិសេរីភាពពេញបរិបូណ៌ឡើង ។

ចំពោះរឿងទាសភាពនេះ តាប់តាំងពីបុរាណកាលរៀងរហូតមកដល់សម័យ ដែលមានមនុស្សអ្នកខំព្យាយាមបំបាត់ទាសភាពពេលចេញនេះ តើមនុស្សដែលធ្លាក់ខ្លួនទៅជាទាសទាសីគេ បានទទួលសេចក្ដីទុក្ខលំបាក និងបានទទួលការជួយសង្គ្រោះ ដោយមនុស្សធម៌ឲ្យមានសិទ្ធិសេរីភាពឡើងយ៉ាងណាខ្លះនោះ សូមនាំប្រវត្តិរឿងទាសភាពខ្លះៗ មកពណ៌នា ដោយសង្ខេបដូចតទៅនេះ ៖

ជនជាតិហេប្រ៊ូបុរាណមានទំនៀមឲ្យមានទាសទាសីប្រើបាន សូម្បី

ជាផនជាតិជាមួយគ្នាក៏ដោយ លុះគ្រប់ ៧ ឆ្នាំហើយ ត្រូវលែងឲ្យជាអ្នកជាដោយបែកគ្រឿងប្រដាប់ប្រើប្រាស់ រួមទាំងបសុសត្វមានគោជាដើមទៀតផង ។ តែបើទាសទាសីនោះ នៅអាឡោះអាល័យស្ម័គ្រចិត្តនឹងនៅជាមួយចៅហ្វាយនាយតទៅទៀត គេក៏ទទួលហើយចោះត្រចៀកឲ្យទុកជាទីពុកនៃការស្ម័គ្រចិត្ត ធ្វើជាទាសទាសី ដោយមានក្រវិលពាក់ជាគ្រឿងសំគាល់ ។ នៅប្រទេសក្រិក ទាសទាសីបានទទួលសេចក្ដីអាណិតអាសូរគ្រាប្រណីពីចៅហ្វាយនាយជាងនៅក្រុងរេម ពួកទាសទា-សីនៅក្រុងរេម កាលបើធ្វើកិច្ចការអ្វីមិនពេញចិត្តចៅហ្វាយនាយនាំឲ្យគេក្រោធខឹងហើយ ត្រូវចៅហ្វាយនាយសម្លាប់ចោលជាច្រើន ព្រោះច្បាប់នៅប្រទេសនេះ បានបើកសិទ្ធិឲ្យចៅហ្វាយនាយ ប្រហារជីវិតទាសទាសីបានតាមបំណង ។ លុះ គ.ស. ៨៦ ដល់ ១៦១ ព្រះបាទ អ័នតូនិអ៊ុស ពីអ៊ុស ទ្រង់ប្រកាសដកសិទ្ធិចៅហ្វាយនាយលែងឲ្យប្រហារជីវិតទាសទាសីតទៅ តែមិនឃើញមានហាមមិនឲ្យធ្វើទារុណកម្ម ដល់ពួកទាសទាសីផងទេ ។ តាមច្បាប់រេម៉ាំង នាយចៅហ្វាយមានសិទ្ធិបំបែកគូស្វាមីភរិយានៃទាសទាសីចេញពីគ្នាបាន ថែមទាំងអាចទៅជាម្ចាស់ទ្រព្យសម្បត្តិគ្រប់យ៉ាងដែលកើតឡើងដល់ទាសទាសីនោះទៀតផង ។ តពីនោះមក ទាសទាសីនៅប្រទេសអង់គ្លេស បានទទួលសិទ្ធិសេរីភាព ថែមឡើងបន្តិច គឺអាចនឹងមានផ្ទះ និងទីដីផ្ទាល់ខ្លួនបាន តែត្រូវបង់ថ្លៃឈ្នួល

ហើយនិងកាចទទួលដកខ្លួនចេញជាអ្នកជា មានសិទ្ធសេរីភាពបាន ដោយមានលក្ខ័ណ្ឌ តាមដែលព្រមព្រៀងគ្នា ។ មកដល់ គ.ស. ១៨០៧ រដ្ឋសភាអង់គ្លេស បានសម្រេចចេញច្បាប់ហាមមិនឲ្យជួញទាសទាសីជាដាច់ខាត ទាំងប្រទេសនានានៅអឺរ៉ុប ក៏បានអនុវត្តតាមលំនាំនេះដែរ តែនៅអាចមានទាសទាសីសម្រាប់ប្រើផ្ទាល់ខ្លួនបាន ដោយកប់ថា ជាសម្បត្តិ ឬ សិទ្ធិផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ ៗ ។ លុះដល់ គ.ស. ១៨៣៤ ទើបមានច្បាប់បំបាត់របបមានទាសទាសីទូទៅទាំងនៅប្រទេសអង់គ្លេស និងនៅប្រទេសចំណុះ ដោយមានកំណត់វេលាឲ្យបំបាត់យ៉ាងដាច់ខាត ព្រមទាំងតាំងថវិកាសម្រាប់សងម្ចាស់ទាសទាសីចំនួន ១៥ លានលីវស្ទើកលិង (ប្រមាណ ១.៨០០ លានរៀល) ហើយដល់ពេលអនុវត្តពិត ១ ត្រូវចាយប្រាក់លើសពីកំណត់ទុក គឺត្រូវចំណាយដល់ ២០ លានលីវស្ទើកលិង (ប្រមាណ ២.៤០០ លានរៀល) គឺជាការបរិច្ចាគក្នុងការជួយសង្គ្រោះទាសទាសីយ៉ាងច្រើន ដែលគួរចារឹកទុកក្នុងប្រវត្តិសាស្ត្រនៃមនុស្សធម៌ ។ ប្រទេសបារាំងសេសព្រមទាំងប្រទេសជាចំណុះ និងប្រទេសដាណាម៉ាក បានបំបាត់របបមានទាសទាសីនេះនៅ គ.ស. ១៨៤៨ ប្រទេសស៊ុយអែត ប្រទេសព័រទុយហ្គាល់ក៏បានបំបាត់របបនេះដាច់ដាច់, សហរដ្ឋអាមេរិកបានប្រកាសបំបាត់ទាសភាពនៅឆ្នាំ១៨៦៥ ។ តែទុកជាយ៉ាងណាក៏ដោយ ទាសភាពក៏នៅតែមាន

នៅពេញសកលលោក ។ មានសមាគមមួយឈ្មោះថា សមាគមបំបាត់ប្រពៃណីទាសភាព គឺជាសមាគមដែលតាំងឡើងប្រមាណ ១៥០ ឆ្នាំមកហើយ ដោយមានទីស្នាក់ការនៅប្រទេសអង់គ្លេស បានអនុវត្តកិច្ចការដើម្បីបំបាត់ទាសភាពនេះយ៉ាងម៉ឺងម៉ាត់ជាលំដាប់មក តែនៅពេលមិនយូរប៉ុន្មានមកនេះ លោក ហ្វក្សពិត លេខាធិការនៃសមាគមនេះបានថ្លែងបញ្ជាក់ថា នាសម័យបច្ចុប្បន្ននេះ ការនាំមនុស្សយកទៅធ្វើជាទាសទាសីដែលជាប្រពៃណីត្រឹមត្រូវតាមច្បាប់នៅមានទូទៅក្នុងរដ្ឋអាហ្វ៊ីផ្សេង ៗ ជាច្រើនរដ្ឋនៅឡើយ ដូចនៅយេម៉ែន នៅបរិវេណសមុទ្រអូម៉ាន នៅរដ្ឋម៉ូរិតានី អាហ្វ្រិកខាងជើង និងនៅអាមេរិកខាងត្បូង ។ លេខាធិការរូបនេះ បានបញ្ជាក់ទៀតថា តម្លៃទាសទាសីដែលទិញដូរនៅរដ្ឋទាំងនោះ រមែងផ្សេងគ្នាទៅតាមភេទតាមវ័យ និងហេតុការណ៍ជាគ្រឿងប្រកបផ្សំ ឧទាហរណ៍ ដូចស្ត្រីដែលមានអាយុច្រើនបន្តិច ក្នុងម្នាក់លក់បានថ្លៃមិនលើសពី៣៥លីវស្ទែកលិង បុរសមាឌមាំរឹងប៉ឹងម្នាក់ លក់បានដល់១៥០លីវស្ទែកលិង ស្ត្រីជំទង់ ៗ អាយុពី១៥ឆ្នាំចុះមក រាប់ថាមានតម្លៃល្អបំផុត ម្នាក់ៗអាចលក់បានថ្លៃ៤០០លីវស្ទែកលិង (ប្រមាណ ៤៥.០០០រៀល) ។ តាមសេចក្តីថ្លែងការរបស់លោកហ្វក្សពិតនេះ ឃើញថារបបទាសភាពនៅមានជាទំនៀមក្នុងលោកដែលច្បាប់ទទួលស្គាល់នៅឡើយ ។ តែទុកណាជាទាសភាព មិនបានសាបសូន្យអស់ទៅក្តាម ក៏គួរសរសើរ

ដោតសាសនារបស់ពួកជនជាភាសតាស៊ីដោយសុខចិត្ត ដែលមានមនុស្សអ្នកខំព្យាយាមតស៊ូក្នុងរឿងនេះយ៉ាងម៉ឺងម៉ាត់ និងយ៉ាងស្វិតស្វាញ ជាហេតុឲ្យមានការប្រែប្រួលខាងផ្លូវចិត្ត និងព្រឹត្តិការណ៍ផ្សេង ៗ ក្នុងរឿងនេះ ក៏វិវត្តទៅកាន់សភាពប្រសើរឡើង ៗ ជាលំដាប់ ៗ ។

ផ្នែកខាងសាសនាវិញ ក្នុងខណៈដែលមានមនុស្សខំព្យាយាមរហូតដល់បាត់បង់ជីវិត ដើម្បីបំបាត់ទាសភាព ដូចលោកលិងខុនជាដើម ដែលជាការជួយសង្គ្រោះមនុស្សអ្នកក្រលំបាកឲ្យបានសេចក្ដីសុខ មានសិទ្ធិសេរីភាពស្មើគ្នាឡើងនេះ ក្រៅពីព្រះពុទ្ធសាសនា ពុំឃើញមានសាសនាណាមួយ ដែលបានអនុវត្តកិច្ចការជួយបំបាត់ទាសភាពនេះសោះទេ ។ អត្ថបទមួយនៅក្នុងសៀវភៅ The New Popular Encyclopaedia ស្ដីថា សាសនាគ្រិស្ដ ឥតមានសកម្មភាពអ្វីក្នុងការជួយបំបាត់ទាសភាពឡើយ ។ ការជួញទាសទាសីបានប្រព្រឹត្តទៅក្នុងចំណោមជនជាតិដែលកាន់សាសនាគ្រិស្ដអស់រយៈពេលប្រមាណ ១០០០ ឆ្នាំ តែក៏មានអ្នកទទួលស្គាល់ថា សាសនាគ្រិស្ដ ក៏ឈ្មោះថាបានជួយក្នុងការបំបាត់ទាសភាពដែរ ដោយសារការប្រៀនប្រដៅសាសនានៃព្រះសង្ឃគ្រិស្ដ ។ សម្រាប់សាសនាឥស្លាមវិញ មានដំណាលថា គម្ពីរនៃសាសនានេះបានអនុញ្ញាតឲ្យមានទាសទាសី ដែលបានមកដោយការច្បាំងឈ្នះទុកប្រើប្រាស់បាន ។ លោកវិល្លាមលិនវើស្តិរម៉ាន់ បានសរសេរទុកក្នុង

សៀវភៅ (Ancent Slavery ) ថា ក្នុងសម័យបុរាណ ពុំដែលមានការអនុវត្តកិច្ចការណាមួយ ដើម្បីបំបាត់ទាសភាពទេ អង្គការសាសនានានា ឬសូម្បីសាសនាគ្រិស្តក៏ដោយ ក៏ពុំដែលបានធ្វើអ្វីជាការជួយក្នុងរឿងនេះសោះឡើយ ការផ្លាស់ប្តូរអាកប្បកិរិយានៃចៅហ្វាយនាយចំពោះមនុស្សជាទាសទាសី បានកើតឡើងក្នុងវិស័យនៃច្បាប់ គឺព្រះមហាក្សត្រនៃអាណាចក្ររ៉ូមទ្រង់បានបញ្ញត្តឡើង ដែលគាត់ទុកថាជាការផ្លាស់ប្តូរខាងផ្លូវចិត្តរបស់មនុស្សយ៉ាងគួរស្ញប់ស្ញែង និងគួរកត់សំគាល់ទុកក្នុងប្រវត្តិសាស្ត្រ ។

សម្រាប់ព្រះពុទ្ធសាសនាវិញ ព្រះពុទ្ធជាម្ចាស់បានទ្រង់ចាប់អារម្មណ៍ក្នុងរឿងបំបាត់ទាសភាពនេះ មុនសាសនាដទៃទាំងអស់ ដូចបានពោលមកខាងដើមខ្លះហើយ ដោយទ្រង់បានតាំងព្រះពុទ្ធបញ្ញត្តិទុកទាំងក្នុងព្រះវិនយបិដក និងក្នុងព្រះសុត្តន្តបិដក គឺ ក្នុងវិនយបិដក៖

១– ទ្រង់បញ្ញត្តថា ទាសៈអ្នកបម្រើគេដែលចូលមកបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនាហើយ រមែងបានទទួលសិទ្ធិគ្រប់បែបយ៉ាងស្មើនឹងភិក្ខុដទៃ ទាំងព្រះរាជាម្ចាស់ផែនដីសម័យនោះ ក៏ទ្រង់ទទួលស្គាល់ថាទាសៈអ្នកបម្រើគេដែលចូលមកបួសក្នុងព្រះពុទ្ធសាសនាហើយ ឲ្យគាត់ទុកថា ចៅហ្វាយនាយមិនមានសិទ្ធិមកចាប់ចង ឬហៅត្រឡប់ទៅវិញឡើយ ។ ដើម្បីការពារបញ្ហាស្មុគ្រស្មាញក្នុងរឿងនេះ ព្រះបរមសាស្តាទើបទ្រង់បញ្ញត្តឲ្យ

RIENT

សង្ឃសាកសួរអ្នកដែលចូលមកបួស ដើម្បីបញ្ជាក់ថា អ្នកនោះជាមនុស្សមានសិទ្ធិសេរីភាពពេញបរិបូណ៌ មិនមែនជាមនុស្សលបរត់មកបួសទេនោះ សង្ឃទើបអនុញ្ញាតឲ្យបួសបាន ។

២– ទ្រង់បញ្ញត្តហាមមិនឲ្យភិក្ខុមានទាសទាសីទុកប្រើ ភិក្ខុណាល្មើស ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

ក្នុងព្រះសុត្តន្តបិដកៈ

១– ទ្រង់ត្រាស់សំដែងអំពីការជួញ ដែលពួកឧបាសកមិនគួរធ្វើ មានការជួញទាសទាសីរួមចូលជាជំនួញមិនគួរធ្វើមួយដែរ ។

២– ទ្រង់ត្រាស់សំដែងអំពីគុណសម្បត្តិរបស់អ្នកបួសថា ត្រូវជាអ្នកមិនទទួលទាសទាសីដែលអ្នកដទៃប្រគេន ។

៣– ក្នុងសិគាលកសូត្រ ទីឃនិកាយ បាដិកវគ្គ ព្រះអង្គទ្រង់ត្រាស់សំដែងអំពីទិស៦ គឺ ១–ទិសខាងមុខ បានដល់មាតាបិតា, ២ ទិសខាងស្តាំ បានដល់គ្រូឧបជ្ឈាយ៍អាចារ្យ, ៣– ទិសខាងក្រោយ បានដល់បុត្រភរិយា, ៤-ទិសខាងឆ្វេង បានដល់មិត្រសំឡាញ់,៥–ទិសខាងក្រោម បានដល់ទាសកម្មករ, ៦- ទិសខាងលើ បានដល់សមណព្រាហ្មណ៍ ហើយទ្រង់ត្រាស់សំដែងកិច្ច ដែលមនុស្សត្រូវបដិបត្តិចំពោះបុគ្គលដែលប្រៀបដូចទិសទាំងនេះ ទិសមួយៗ៥បែប ។ ចំពោះតែទិសខាងក្រោម ពោលគឺទាសកម្មករ ដែលត្រូវលើកយកមកពណ៌នាក្នុងទីនេះ ព្រះអង្គ

ទ្រង់ត្រាស់សំដែងទុកថា ចៅហ្វាយនាយគួរបដិបត្តិ គឺជួយទំនុកបំរុង ដោយវិធី ៥ យ៉ាង គឺ ៖

១- ដោយដាក់ការងារឲ្យធ្វើតែល្មមកម្លាំងដែលអាចធ្វើបាន ។

២- ដោយផ្តល់ភោជនាហារនិងឲ្យរង្វាន់ឲ្យតាមសមគួរ ។

៣- ដោយជួយព្យាបាលក្នុងពេលដែលមានជម្ងឺ ។

៤- ដោយចែកវត្ថុដែលមានឱជារសប្លែកៗ ឲ្យបរិភោគ ។

៥- ដោយបើកឱកាសឲ្យ ដើម្បីឲ្យបានទទួលសេចក្តីសប្បាយរីករាយ ក្នុងកាលដែលគួរ ។ ព្រះសូត្រនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងណែនាំឲ្យមនុស្សដែលមានទាសកម្មករខ្ញុំកំដរប្រើ ចេះអាណិតអាសូរ មិនសង្កត់សង្កិន ឬ បង្ខិតបង្ខំឲ្យធ្វើការងារហួសហេតុហួសកម្លាំង ហើយឲ្យចេះជួយទំនុកបំរុងខ្ញុំកំដរនោះតាមសមគួរ ដែលអាចធ្វើបានដើម្បីឲ្យគ្នាបានសេចក្តីសុខផង ដែលជាហេតុឲ្យខ្លួនជាចៅហ្វាយនាយ ក៏នឹងបានទទួលផលល្អ គឺជាហេតុឲ្យខ្ញុំកំដរទាំងនោះមានចិត្តទន់ និងស្រឡាញ់អាណិតចៅហ្វាយនាយដែលមានធម៌មេត្តាដល់ខ្លួន ហើយខំធ្វើការងារមិនខ្ជិលច្រអូស និងមិនមានពុតត្បុតដែលនាំឲ្យចៅហ្វាយនាយ បានសេចក្តីចំរើនលូតលាស់ជាលំដាប់ៗតទៅ ។

កាលបើពិចារណាតាមក្រសែព្រះពុទ្ធតម្រាស់ទាំងក្នុងព្រះវិនយបិដក និងក្នុងព្រះសុត្តន្តបិដកដោយល្អិតល្អន់ហើយ ក៏នឹងឃើញបានថា ព្រះ

ពុទ្ធជាម្ចាស់ ទ្រង់មានព្រះពុទ្ធបំណង ដើម្បីកំចាត់ទាសភាពឲ្យអស់ចេញ កុំឲ្យមានការទិញលក់ ឬ ការជួញទាសទាសី តែក្នុងករណីដែលហួសនឹងកំចាត់ឲ្យអស់ទៅបាន ព្រះអង្គក៏ទ្រង់ទូន្មានឲ្យចៅហ្វាយនាយប្រើប្រាស់ទាសទាសីឲ្យសមគួរនឹងកម្លាំង ដោយមិនសង្កត់សង្កិន ឬ បង្ខិតបង្ខំហួសហេតុ និងជួយទំនុកបំរុងតាមសមគួរ ដោយអធ្យាស្រ័យដែលប្រកបដោយមេត្តាធម៌ ដើម្បីឲ្យទាសទាសីទាំងនោះបានសេចក្ដីសុខស្រួលផង ។ សរុបសេចក្ដីទៅ ព្រះបរមលោកនាថ ទ្រង់មានទឹកព្រះហឫទ័យពេញពោរទៅដោយមេត្តាករុណា ទ្រង់មានព្រះពុទ្ធបំណងនឹងជួយសង្គ្រោះមនុស្សសត្វទៅឲ្យបានរួចផុតអំពីការសង្កត់សង្កិននៃអ្នកដទៃ ដោយអយុត្តិធម៌ ហើយឲ្យមានសិទ្ធិសេរីភាពគ្រប់គ្រងខ្លួនដោយខ្លួនឯង តាមសេចក្ដីគាប់ចិត្តស្មើៗគ្នាទៀង ។

រឿងទាសភាពដែលបានអធិប្បាយរួចមកហើយនេះ តាមផ្លូវព្រះពុទ្ធសាសនា លោកហៅថា ទាសភាពខាងក្រៅ ឬ ទាសភាពខាងផ្លូវកាយ ។ មនុស្សដែលបានផុតអំពីទាសភាពខាងក្រៅនេះ ហៅថា អ្នកមានសិទ្ធិសេរីភាពខាងក្រៅ ឬ ខាងផ្លូវកាយ ។ នៅមានទាសភាពមួយបែបទៀតហៅថា ទាសភាពខាងក្នុង ឬ ខាងផ្លូវចិត្ត ។ ខាងផ្លូវព្រះពុទ្ធសាសនា បញ្ហាសំខាន់បំផុត គឺបញ្ហាទាសភាព និងសិទ្ធិសេរីភាពខាងក្នុង ឬ ខាងផ្លូវចិត្តនេះឯង ។ អ្នកដែលបានធ្វើខ្លួនឲ្យផុតអំពីទាស

ភាពទាំងខាងក្រៅ ទាំងខាងក្នុងនោះ ទើបឈ្មោះថាជាអ្នកមានសិទ្ធិសេរីភាពពេញបរិបូណ៌ ។ ព្រោះហេតុថា មនុស្សដែលកើតមកក្នុងលោកនេះ ពួកខ្លះមានសិទ្ធិសេរីភាពខាងផ្លូវកាយ គឺអាចនិយាយស្តី សរសេរ ឬ ប្រកបកិច្ចការផ្សេង ៗ និងទៅណាមកណាក៏បានតាមសេចក្តីគាប់ចិត្ត ឬ ក៏មានអំណាចអាចបង្គាប់បញ្ជាអ្នកដទៃតាមមុខងារបានថែមទៀតផង ក៏នឹកស្មានថាខ្លួនមានសិទ្ធិសេរីភាពពេញបរិបូណ៌ហើយ តែខាងផ្លូវចិត្តវិញ មនុស្សទាំងនេះសុទ្ធតែនៅក្រោមអំណាចបង្គាប់បញ្ជា របស់ចៅហ្វាយនាយពោលគឺកិលេស បានដល់លោភៈ ទោសៈ មោហៈ ដោយត្រូវកិលេសទាំង ៣ ប្រភេទនេះ បង្ខំឲ្យធ្វើអំពើអាក្រក់ផ្សេង១ មានការកាប់សម្លាប់និងលួចទ្រព្យគេជាដើម ដែលនាំឲ្យខ្លួនត្រូវផ្តន្ទាទោស មានការវាយដំនិងដាក់គុកច្រវាក់ជាដើម ជាហេតុឲ្យបានទទួលសេចក្តីទុក្ខលំបាកទាំងក្នុងលោកនេះ និងលោកខាងមុខ ។ តែមនុស្សភាគច្រើនមិនបានដឹងខ្លួនថា ខ្លួនជាខ្ញុំបម្រើនៅក្រោមអំណាចនៃចៅហ្វាយនាយ គឺកិលេសទាំង៣ប្រភេទនេះឡើយ ព្រោះកិលេសទាំងនេះ មានកលល្បិចបេះប្រើឧបាយមិនឲ្យមនុស្សដឹងខ្លួនបាន ។ ព្រះបរមសាស្តាទ្រង់ជ្រាបថានឹងជួយស្រោចស្រង់មនុស្សសត្វឲ្យមានសិទ្ធិសេរីភាពទាំងខាងផ្លូវកាយទាំងខាងផ្លូវចិត្ត ទើបទ្រង់ទូន្មានឲ្យអ្នកបដិបត្តិព្យាយាមកំចាត់កិលេសទាំងនេះឲ្យអស់ពីសន្តានចិត្ត កុំឲ្យកិលេសទាំងនេះបង្ខិតបង្ខំឲ្យធ្វើអំពើអាក្រក់ផ្សេង ១ ដោយទ្រង់ប្រោសព្រះរាជទាន

វិធីសម្រាប់កំចាត់កិលេសទាំងនេះ ទុកមកជាគ្រឿងឧបករណ៍យ៉ាងគ្រប់គ្រាន់ ។ ដូច្នេះ ដើម្បីនឹងកំចាត់កិលេសដូចពោលហើយឲ្យអស់ចេញពីសន្តានចិត្តនោះ គប្បីសិក្សាឲ្យស្គាល់ច្បាស់នូវលក្ខណៈ និងឥទ្ធិពលនៃកិលេសទាំង៣ប្រភេទនេះ តាមដែលលោកបែកជាថ្នាក់ជាន់ផ្សេង ៗ គ្នា និងកំណត់ឲ្យឈ្មោះដូចតទៅនេះ ៖

១— វីតិក្កមកិលេស បានដល់កិលេសជាន់គ្រោតគ្រាត មានអំណាចអាចបង្ខំឲ្យមនុស្សប្រព្រឹត្តអាក្រក់ដោយកាយនិងពចា ។ កិលេសប្រភេទនេះ បានដល់មនោទុច្ចរិត ៣ គឺ អភិជ្ឈា ការសំឡឹងចង់បានទ្រព្យរបស់អ្នកដទៃ ព្យាបាទ ការចងចិត្តប្រទូសរ៉ាយអ្នកដទៃ មិច្ឆាទិដ្ឋិការយល់ខុសចាកគន្លងធម៌ ។ កិលេសពួកនេះ ប្រៀបដូចជានាយចោរហ្វាយដែលមានអធ្យាស្រ័យគ្រោតគ្រាត ហើយមានកម្លាំងចិត្តខ្លាំង មិនចេះអត់ធ្មត់ បើមិនពេញចិត្តនឹងបាវព្រាវ ក៏សំដែងអាការៈចេញឲ្យឃើញច្បាស់ៗតែម្តង ។

២— បរិយុដ្ឋានកិលេស កិលេសជាន់កណ្តាល ដែលមានឥទ្ធិពលរួបរឹតបិទបាំងកំងកចិត្តមិនឲ្យពិចារណាឃើញច្បាស់ នូវសភាវពិតរបស់សង្ខារ កិលេសពួកនេះ បានដល់នីវរណៈទាំង៥ គឺកាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ និងវិចិកិច្ឆា ។ កិលេសពួកនេះប្រៀបបាននឹងនាយចោរហ្វាយដែលមានចិត្តគំនិតជូន់ជូយ៉ាងមធ្យម ចេះអត់ធ្មត់ ទោះបីខ្ញុំកំដរធ្វើអ្វីមិន

សមតាមបំណង ក៏មិនសំដែងអាការក្រោធខឹងឲ្យប្រាកដឡើងដែរ ចេះទប់ចិត្តឲ្យស្ងប់ហើយ ប្រើពួកទាសទាសីដោយឧបាយដ៏ត្រជាក់ ដែលជាហេតុឲ្យទាសទាសីភ្លេចខ្លួន ស្មានថាខ្លួនមិនបាននៅក្រោមអំណាចនៃអ្នកដទៃទេ ។

៣- អនុសយកិលេស គឺកិលេសដ៏ល្អិត ដែលត្រាំសម្ងំនៅក្នុងសន្តានចិត្ត ៗ កិលេសជំពូកនេះ បានដល់អនុស័យទាំង ៧ គឺៈ កាមរាគៈ បដិឃៈ ទិដ្ឋិ វិចិកិច្ឆា មានៈ ភវរាគៈ និងអវិជ្ជា ។ កិលេសពួកនេះ ល្អិតសុខុមណាស់ ហើយត្រាំនៅសម្ងំក្នុងសន្តានចិត្ត ។ កាលណាបើគ្មានអារម្មណ៍ណាមួយមកជួជទ្វេញឲ្យកំរើកទេ កិលេសពួកនេះ រមែងមិនសំដែងឲ្យប្រាកដឡើងទេ ជាហេតុឲ្យបុគ្គលនឹកស្មានខុសថា ចិត្តរបស់ខ្លួនស្អាតផូរផង់ មិនមានកិលេសជាគ្រឿងសៅហ្មងសោះឡើយ ។ តែកាលបើមានអារម្មណ៍មកប៉ះទង្គិចជួជទ្វេញហើយ កិលេសពួកនេះ ក៏នឹងបញ្ចេញអាការៈឲ្យឃើញជាក់ស្តែង ដោយការប្រើអំណាចបង្ខំឲ្យបុគ្គលធ្វើកិច្ចការផ្សេងៗ តាមការបង្គាប់បញ្ជារបស់ខ្លួន ។ កិលេសប្រភេទនេះ ប្រៀបដូចជានាយចៅហ្វាយដែលមានចិត្តគំនិតធ្ងន់ធ្ងរខ្លាំង មានអធ្យាស្រ័យល្អិតសុខុមក្រៃលែង មានកលល្បិចដ៏ជ្រាលជ្រៅ និងមានមធ្យោបាយត្រជាក់បំផុត អាចប្រើបាវព្រាវដែលនៅក្រោមអំណាចរបស់ខ្លួន ឲ្យធ្វើការងារផ្សេងៗ តាមបំណងរបស់ខ្លួនដោយស្ងប់ស្ងៀម ជាហេតុឲ្យបាវព្រាវទាំងនោះនឹក

ស្មានថា ខ្លួនមិនមែនជាខ្ញុំកំដរគេបំរើគេទេ ។

កិលេសទាំង ៣ ប្រភេទដូចពោលមកនេះ ជាអកុសលធម៌ ដែលមានឥទ្ធិពលគ្របសង្កត់លើបុគ្គលដែលជាបុថុជ្ជនគ្រប់រូប អាចបង្ខំឲ្យមនុស្សធ្វើអំពើអាក្រក់ផ្សេង ៗ តាមបំណងបានគ្រប់យ៉ាង ។ ឧទាហរណ៍ដូចមនុស្សដែលធ្វើអំពើអាក្រក់មានលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តកន្លងប្រវេណីគេជាដើមទៅបាន ក៏ព្រោះអាស្រ័យអំណាចនៃកិលេសដូចពោលហើយនោះឯងជាអ្នកបង្គាប់ឲ្យធ្វើ ៗ អាស្រ័យហេតុនោះ ទើបលោកពោលថា កិលេសទាំង ៣ ប្រភេទនោះឯង គឺជានាយចៅហ្វាយ ឬជាម្ចាស់ជាអ្នកត្រួតត្រាបង្គាប់បញ្ជា ។ ឯមនុស្សដែលកិលេសទាំងនោះប្រើអំណាចបង្ខំឲ្យធ្វើអំពើអាក្រក់ផ្សេង ៗ មានការលួចទ្រព្យគេជាដើម លោកចាត់ទុកជាទាសទាសី គឺជាខ្ញុំកញ្ជះនៃកិលេសទាំងនោះ ព្រោះខ្លួននៅក្រោមអំណាចរបស់គេ ឥតមានឥស្សរភាពអ្វីសោះ ត្រូវតែបដិបត្តិតាមការបង្គាប់បញ្ជារបស់គេ ទោះបីខ្លួនមិនចង់វាយប្រហារគេ ឬមិនចង់លួចប្លន់គេទេ ដោយគិតខ្លាចត្រូវគេផ្តន្ទាទោសដាក់គុកច្រវាក់ក៏ដោយ កាលបើកិលេស គឺលោភៈ ទោសៈ មោហៈ ប្រើហើយត្រូវតែវាយប្រហារ ឬលួចប្លន់តាមសេចក្តីបង្គាប់ខានមិនបាន ។ យើងអាចសង្កេតឃើញបានដូចជាមនុស្សខ្លះទៅ ដែលនៅជាប្រក្រតីមិនទាន់មានសេចក្តីក្រោធខឹងកើតឡើង បើនឹងធ្វើកិច្ចការអ្វីមួយ ៗ តែងមានសេចក្តីប្រយ័ត្ន

គិតមុខគិតក្រោយ ខ្លាចក្រែងមានកំហុសក្នុងការធ្វើនោះ ឬក៏ខ្លាចប៉ះពាល់ឲ្យខូចប្រយោជន៍អ្នកដទៃ ដែលជាហេតុឲ្យកើតសេចក្ដីសៅហ្មងដល់ខ្លួន ជួនកាលមានការទាក់ទងនឹងអ្នកដទៃ ហើយអ្នកនោះបានធ្វើឲ្យខូចផលប្រយោជន៍ដែលជាទីហួងហែងរបស់ខ្លួន ខ្លះក៏មានអាកប្បកិរិយានៅជាប្រក្រតីបាន ដោយមិនតបតបង្ករឿងរ៉ាវអ្វីឡើយ ហើយបានតាំងយល់ច្បាស់យ៉ាងជ្រៅឆ្ងាយផងថា ការបង្ករឿងរ៉ាវនោះរមែងនាំឲ្យខូចខាតផលប្រយោជន៍ច្រើនជាងដែលខូចរួចទៅហើយនោះថែមទៀត តែកាលបើមានសេចក្ដីក្រោធខឹងកើតឡើង សូម្បីតែរឿងបន្តិចបន្តួច ដូចមានអ្នកណាមួយប្រើពាក្យសំដីមិនសមរម្យមកលើខ្លួន ដែលគ្មានឃើញខូចខាតទ្រព្យសម្បត្តិអ្វីសោះ ក៏បណ្ដាលឲ្យកើតសេចក្ដីប្រកាន់មាំ វាយដំប្រំធាក់ រហូតដល់កាប់សម្លាប់អ្នកនោះក៏មាន ដែលជាហេតុឲ្យខ្លួនបានសេចក្ដីទុក្ខលំបាក ខូចកិត្តិយសឈ្មោះសម្លេង និងវិនាសអន្តរាយដល់ទ្រព្យធនផង ។

ខនេះគឺខ្លួនគ្មានចង់ទៅវាយដំកាប់សម្លាប់គេពាល់តែសោះ ព្រោះដឹងច្បាស់ហើយថា កាលបើទៅវាយកាប់សម្លាប់គេក៏នឹងបានទទួលទុក្ខទោសយ៉ាងនោះជាប្រាកដ តែមកអំពីកិលេសគឺ ទោសៈ ជាអ្នកបង្គាប់ឲ្យធ្វើ ទើបអ្នកនោះឯងធ្វើយ៉ាងនោះទៅបាន ។ ហេតុនោះ កិលេសទើបចាត់ទុកថាជា ចៅហ្វាយនាយ ចិត្តចាត់ជា បាវព្រាវ ឯសភាពដែលចិត្ត

នៅតែក្រោមអំណាចកិលេស  រកឥស្សរភាពគ្មានសោះយ៉ាងនេះ  ទើបឈ្មោះថា  ទាសភាពខាងផ្លូវចិត្ត ៗ ទាសភាពខាងផ្លូវចិត្តនេះ ជាបញ្ហាដែលលំបាកនឹងដោះស្រាយបំផុត  ព្រោះមនុស្សភាគច្រើនណាស់ដែលមិនដឹងថា ខ្លួនជាទាសទាសីរបស់កិលេស ៗ កាលបើគ្មាននរណាត្រួតត្រាលើ  មានសិទ្ធិសេរីភាពខាងផ្លូវកាយ  អាចធ្វើកិច្ចការអ្វីបានតាមសេចក្តីគាប់ចិត្ត  ថែមទាំងមានមុខងារត្រួតត្រាបង្គាប់បញ្ជាលើអ្នកដទៃទៀតនោះផង ក៏សំគាល់ថា ខ្លួនមិនមែនជាទាសទាសីរបស់នរណាឡើយ ៗ តែសេចក្តីពិត ខ្លួនជាទាសទាសីរបស់កិលេស នៅក្រោមអំណាចលោភៈ ទោសៈ  មោហៈ  យ៉ាងពេញលក្ខណៈ  ដោយគ្មានដឹងខ្លួនទាល់តែសោះ  ៗ ត្រង់នេះហើយ  ដែលជាការលំបាកនឹងកែខ្លួនឲ្យផុតអំពីទាសភាព បានទៅជាមនុស្សអ្នកជា មានសិទ្ធិសេរីភាពពេញបរិបូណ៌ទៅបាន ៗ ប្រៀបដូចជាមនុស្សដែលប្រឡាក់ធ្យូងនៅមុខ  កាលណាបើដឹងថាមុខខ្លួនប្រឡាក់នោះ ទើបមនុស្សនោះប្រញាប់ប្រញាល់រកទឹកលាងសំអាតឲ្យជ្រះទៅបាន  តែបើមុខប្រឡាក់ហើយ  មិនដឹងថាប្រឡាក់ដោយយល់ថាមុខខ្លួនស្អាតឥតមានប្រឡាក់អ្វីនោះ មនុស្សនោះក៏គ្មានរវល់អ្វីនឹងទៅរកទឹកមកជម្រះលាងឲ្យស្អាត  ឯមុខដែលប្រឡាក់នោះ  ក៏នឹងមិនមានពេលនឹងជ្រះស្អាតទៅបានឡើយ សេចក្តីនេះមានឧបមាយ៉ាងណា រឿងខ្ញុំកញ្ឆះកិលេស  ក៏មានឧបមេយ្យយ៉ាងនោះដែរ  គឺកាលណា  បើ

បុគ្គលដឹងខ្លួនថា ខ្លួននៅជាទាសទាសី ក្រោមអំណាចបង្គាប់បញ្ជារបស់កិលេសនោះ ទើបនឹងខំខ្វល់ខ្វាយព្យាយាមផ្ដាច់សម្លាប់កិលេសនោះឲ្យអស់ចេញពីសន្ដានចិត្ត ហើយខ្លួនក៏នឹងមានសិទ្ធិសេរីភាពពេញបរិបូណ៌ឡើងបាន តែផ្ទុយទៅវិញ កាលបើមនុស្សនោះ មិនដឹងថាខ្លួននៅជាទាសទាសីជាខ្ញុំកញ្ជះកិលេសទេ បែរជាសំគាល់ថា ខ្លួនមានឥស្សរភាពពេញបរិបូណ៌ហើយនោះ ក៏មិនរវល់ខ្វល់ខ្វាយនឹងធ្វើសេចក្ដីព្យាយាមកម្ចាត់លោភៈ ទោសៈ មោហៈ ដែលជានាយចៅហ្វាយអ្នកបង្គាប់បញ្ជាចិត្តឲ្យអស់ទៅឡើយ, កិលេសទាំងនោះ ក៏នៅតែមានអំណាចឥទ្ធិពលគ្របសង្កត់ចិត្តជាដរាបទៅ, ឯខ្លួនក៏គ្មានពេលនឹងបានជួបបានឃើញនូវរស្មីនៃសិទ្ធិសេរីភាពខាងផ្លូវចិត្តជាប្រាកដ ៗ

សេចក្ដីអធិប្បាយមកនោះ សឲ្យឃើញថា រឿងទាសភាពខាងផ្លូវចិត្តនេះជារឿងស្មុគស្មាញលំបាកនឹងបំបាត់ជាទីបំផុត ព្រោះការបដិបត្តិដើម្បីផ្ដាច់សម្លាប់កិលេសនេះ ជាការៈផ្ទាល់ របស់មនុស្សម្នាក់ ៗ ដែលត្រូវព្យាយាមដោយខ្លួនឯង ទឹងត្រូវពិនិត្យពិចារណាដឹងដោយខ្លួនឯងថា ចិត្តរបស់ខ្លួនមានសភាពយ៉ាងណាខ្លះ? កាលខំផ្ដាច់ទៅហើយ កិលេសនឹងបានស្រាលស្ដើងប៉ុណ្ណា? កិច្ចទាំងនេះ អ្នកដទៃមិនអាចធ្វើបានឡើយ ។ ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ទ្រង់ត្រាស់សំដែងទុកមកហើយថា សេចក្ដីបរិសុទ្ធិ និងសេចក្ដីមិនបរិសុទ្ធិ គឺមនុស្សម្នាក់ ៗ ត្រូវដឹង

ចំពោះខ្លួន, មនុស្សមិនអាចនឹងជួយធ្វើឲ្យអ្នកដទៃបរិសុទ្ធបានឡើយ ។ បទមួយទៀត ទ្រង់ត្រាស់សំដែងទុកថា ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកប្រាប់ផ្លូវឲ្យប៉ុណ្ណោះទេ ឯសេចក្ដីព្យាយាម គឺអ្នកទាំងឡាយត្រូវធ្វើដោយខ្លួនឯង ។ ព្រះពុទ្ធភាសិតទាំងនេះជាគ្រឿងបញ្ជាក់ឲ្យឃើញថា ការបដិបត្តិខាងផ្លូវចិត្តគ្រប់បែបយ៉ាង គឺជាកិច្ចដែលមនុស្សម្នាក់ៗត្រូវធ្វើដោយខ្លួនឯង ព្រះពុទ្ធជាម្ចាស់ព្រះអង្គគ្រាន់តែជាអ្នកប្រាប់វិធីប៉ុណ្ណោះទេ មិនអាចនឹងជួយមនុស្សដែលមិនបដិបត្តិដោយខ្លួនឯង ឲ្យផុតទុក្ខទៅបានទេ ។ ប្រៀបដូចជា ទ្រង់ចង្អុលប្រាប់ថា ផ្លូវនេះទៅក្រុងភ្នំពេញ បើមនុស្សចង់ទៅក្រុងភ្នំពេញ ខំដើរទៅតាមផ្លូវនោះដោយខ្លួនឯងនោះ ទើបនឹងដល់ទៅបាន បើអ្នកនោះគ្រាន់តែចង់ទៅ តែមិនខំដើរទៅទេ ក៏មិនអាចនឹងដល់ទៅបានទេ ។ ឯរឿងការបដិបត្តិនេះ ក៏ដូច្នោះដែរ បើមនុស្សមិនខំបដិបត្តិដោយខ្លួនឯងទេ ក៏មិនសម្រេចសមតាមសេចក្ដីប្រាថ្នាទៅបានឡើយ ។ ហេតុនោះ ការបំបាត់ទាសភាពខាងក្នុង ដែលជារឿងផ្លូវចិត្តទើបជាបញ្ហាស្មុគស្មាញ មិនអាចនឹងកម្ចាត់ឲ្យអស់ទៅបានដោយងាយៗ ។ តែព្រះពុទ្ធសាសនាមានវិធានការសម្រាប់កម្ចាត់ទាសភាពខាងក្នុងនេះយ៉ាងគ្រប់គ្រាន់ទុកឲ្យពួកពុទ្ធបរិស័ទបដិបត្តិតាម ដើម្បីធ្វើខ្លួនឲ្យមានសិទ្ធិសេរីភាពខាងផ្លូវចិត្តពេញបរិបូណ៌ ដោយទ្រង់ចាត់វិធីទុកជាជាន់ថ្នាក់មាន៣ជាន់ជាគូសម្រាប់បង្ក្រាបកិលេសទាំងនោះដូចតទៅនេះ ៖

១- វីតិក្កមកិលេស កិលេសជាន់គ្រោតគ្រាតត្រូវកម្ចាត់ដោយសីល ។

២- បរិយុដ្ឋានកិលេស កិលេសជាន់កណ្ដាល ត្រូវកម្ចាត់ដោយសមាធិ ដោយមេត្តាករុណា ។

៣- អនុសយកិលេស កិលេសជាន់ល្អិតសុខុម ត្រូវកម្ចាត់ដោយវិបស្សនាបញ្ញា ។

ហេតុនោះ ពួកពុទ្ធសាសនិកជន ដែលប្រាថ្នានឹងធ្វើខ្លួនឲ្យផុតអំពីទាសភាពខាងកង ឬទាសភាពខាងផ្លូវចិត្តនោះ គួរបដិបត្តិតាមពុទ្ធវិធីដូចពោលហើយខាងលើនេះ ។ កាលបើបុគ្គលណាបដិបត្តិតាមវិធីនេះដោយដិតដល់ហើយ បុគ្គលនោះ ក៏មុខជានឹងបានផុតអំពីអំណាចត្រួតត្រានៃកិលេស សមតាមសេចក្ដីប្រាថ្នាជាមិនខាន ។ ព្រះពុទ្ធសាសនាជាសាសនា ដែលមានគោលការជួយស្រោចស្រង់មនុស្ស លើកតម្កើងមនុស្សឲ្យមានតម្លៃថ្លៃថ្នូរស្មើគ្នា ឲ្យមានឥស្សរភាពមានអំណាចអាចធ្វើកិច្ចការអ្វីគ្រប់យ៉ាងបានទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត ។ កងការផ្សាយសាសនា ព្រះពុទ្ធជាម្ចាស់ ពុំដែលប្រើឥទ្ធិពលគម្រាមកំហែង ឬបង្ខិតបង្ខំជនណាម្នាក់ឲ្យចុះចូលកាន់អាន ឬឲ្យជឿពាក្យប្រៀនប្រដៅរបស់ព្រះអង្គដល់មួងណាឡើយ ។ ផ្ទុយទៅវិញ សាសនាដទៃខ្លះ បានប្រើអំណាចបង្ខំឲ្យមនុស្សជឿតាមលទ្ធិរបស់ខ្លួន កាលបើគេមិនព្រមជឿតាម មិនព្រមគោរពកាន់អានទេ ក៏ប្រើឥទ្ធិពលគម្រាមកំហែងទៅលើគេ ឧទាហរណ៍ដូចលោក កាលលីឡេអូ អ្នកវិទ្យាសាស្ត្រជាតិអ៊ីតាលី ដែលមានឈ្មោះ

សំឡេងម្នាក់ ត្រូវសម្តេចប៉ាប ជាសម្តេចសង្ឃនៃសាសនាគ្រិស្ត និកាយ
រ៉ូម៉ាំងកាតូលិក ធ្វើទោសដាក់គុករហូតដល់ផកជិតអស់ជីវិត ទើបដោះ
លែង ។ រឿងនេះ មកអំពីលោក កាលីឡេអូ បានស្រាវជ្រាវខាង
ផ្លូវវិទ្យាសាស្ត្រ និងបានពិសោធឃើញជាក់ច្បាស់ហើយ ក៏នាំយកទ្រឹស្តី
តាមដែលស្រាវជ្រាវឃើញនោះទៅបង្រៀនសិស្សថា ព្រះអាទិត្យជាមជ្ឈ-
មណ្ឌលនៃសុរិយចក្រវាឡវិលជុំវិញខ្លួនឯង រីឯផែនដីវិលជុំវិញខ្លួនឯងផង
វិលជុំវិញព្រះអាទិត្យផង ។ ទ្រឹស្តីនេះមានដំណើរជំទាស់នឹងពាក្យប្រៀន
ប្រដៅក្នុងគម្ពីរប៊ីបនៃសាសនាគ្រិស្ត ដែលសំដែងផ្ទុយទៅវិញថា លោក
យើងនេះ ជាមជ្ឈមណ្ឌលនៃសុរិយចក្រវាឡ ។ ដោយហេតុនេះ លោក
កាលីឡេអូ ទើបត្រូវតុលាការខាងសាសនាគម្រាមកំហែងឲ្យលះបង់ទ្រឹស្តី
នេះចោលចេញ ឈប់បង្ហាត់បង្រៀនសិស្សតាមបែបនេះតទៅទៀតហើយ
ឲ្យបង្រៀន ដោយសម្របទៅតាមព្រះគម្ពីរវិញ តែលោកកាលីឡេអូ
មិនព្រមបដិបត្តិតាមដាច់ខាត ។ ជាធម្មតា អ្នកវិទ្យាសាស្ត្រទូទៅ
កាលបើបានពិសោធឃើញយ៉ាងនេះហើយ គេតែងតែថាយ៉ាងនោះ មិន
អាចជនណាមួយទៅណែនាំ ឬបង្ខិតបង្ខំឲ្យថាជាយ៉ាងដទៃបានឡើយ ។
លោកកាលីឡេអូ ដែលជាអ្នកវិទ្យាសាស្ត្រដ៏ពិតប្រាកដមួយរូបដែរនោះ
លោកក៏បានរក្សាឧត្តមគតិរបស់លោកទុក ដោយមិនព្រមធ្វើកិច្ចការអ្វី
ដែលឃ្លាតចាកហេតុផល ដែលខ្លួនបានពិសោធឃើញប្រចក្សរួចមកហើយ
ដូច្នោះដែរ ។ ហេតុនោះលោកទើបត្រូវគេ ចាប់ផ្តន្ទាទោសដាក់គុកធ្វើ

ទារុណកម្មផ្សេងៗ រហូតដិតដល់ជីវិត ។ ឯខាងផ្លូវព្រះពុទ្ធសាសនាវិញ ព្រះពុទ្ធជាម្ចាស់របស់យើង មិនដែលបង្ខំជនណាមួយឲ្យជឿតាមទុកទរបស់ព្រះអង្គ ដោយការប្រើអំណាចបង្ខិតបង្ខំណាសោះ ព្រះអង្គតែងទ្រង់បើកឲ្យមនុស្សគ្រប់រូប បេះប្រើសិទ្ធិសេរីភាពក្នុងការជឿ ដោយទ្រង់ណែនាំទុកថា មនុស្សគ្រប់ៗគ្នា មុននឹងជឿអ្វីមួយ ត្រូវប្រើបញ្ញាពិចារណាឲ្យឃើញហេតុផលច្បាស់ជាមុនសិនសឹមជឿ, ជំនឿបែបនេះ លោកហៅថា បញ្ញាសម្បយុត្តសទ្ធា ។ ចំណែកការជឿដែលមិនមានការពិចារណាឲ្យយល់ច្បាស់ជាមុននោះ លោកហៅថា បញ្ញាវិប្បយុត្តសទ្ធា គឺការជឿដោយគ្មានបញ្ញាជាគ្រឿងពិចារណា ដែលអាចនឹងធ្វើអ្នកជឿឲ្យបានទទួលផលអាក្រក់ក៏សឹងបាន ។ ហេតុនោះ ខាងផ្លូវព្រះពុទ្ធសាសនា ទើបលើកយកបញ្ញាថា ជារបស់សំខាន់បំផុត ។

សេចក្តីអធិប្បាយមកនេះ បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាជាសាសនាតែមួយក្នុងលោក ហើយជាសាសនាមុនគេបង្អស់ ដែលមានគោលការកម្ចាត់ទាសភាព ដើម្បីរក្សាការពារសភាពថ្លៃថ្នូរ របស់មនុស្ស ជួយឲ្យមនុស្សមានឥស្សរភាព ឲ្យបេះប្រើសិទ្ធិសេរីភាពរបស់ខ្លួនក្នុងកិច្ចការគ្រប់យ៉ាងពេញបរិបូណ៌ ដោយព្រះអង្គទ្រង់បានប្រោសព្រះរាជទានគោលការទុកឲ្យមនុស្សប្រតិបត្តិតាម ដូចដែលបានធ្វើអត្ថាធិប្បាយមកនេះឯង ។

– ចប់ –

# រឿងព្រះឧបនន្ទសាក្យបុត្រ

អដ្ឋកថាធម្មបទ ភាគទី ៦ អត្តវគ្គទី ១២

កាលព្រះបរមសាស្ដាគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនឹងបុត្រស្ដេចសាក្យៈ ឈ្មោះ ឧបនន្ទ ទ្រង់ត្រាស់សំដែងធម៌ដោយបទគាថា ថា អត្តានមេវ បឋមំ ដូច្នេះជាដើម ។

បានឮមកថា ព្រះថេរៈនោះ ឈ្លាសវៃវាងការសំដែងធម្មកថា ។ ភិក្ខុមកស្ដាប់ធម្មកថា របស់លោកសង្រួបដោយគុណ មានភាពជាអ្នកមានសេចក្ដីប្រាថ្នាតិចជាដើម បូជាលោកដោយចីវរទាំងឡាយ ហើយសមាទានធុតង្គ ។ លោកតែម្នាក់ឯង ទទួលយកបរិក្ខារដែលភិក្ខុទាំងនោះលះបង់ហើយ ។ កាលដល់ផ្លូវជិតចូលវស្សា ថ្ងៃមួយ លោកទៅឯជនបទ ។ គ្រានោះ ភិក្ខុកំឡោះ និងសាមណេរក្នុងវត្តមួយ និយាយឃាត់ព្រះថេរៈនោះ ដោយសេចក្ដីស្រឡាញ់ព្រះធម្មកថិកថា សូមលោកម្ចាស់គង់ចាំវស្សាក្នុងវត្តនេះចុះ ។ ព្រះថេរៈសួរថា ភិក្ខុក្នុងវត្តនេះ បានសំពត់ចំណាំវស្សាប៉ុន្មាន ? កាលភិក្ខុទាំងនោះប្រាប់ថា បានសំពត់សាដកមួយអង្គមួយ ក៏ផ្ញើស្បែកជើងទុកក្នុងវត្តនោះ ហើយទៅឯវត្តដទៃទៀត ដល់វត្តទីពីរសួរថា ភិក្ខុក្នុងវត្តនេះ បានសំពត់ចំណាំវស្សាប៉ុន្មាន ? កាលគេប្រាប់ថា បានសំពត់សាដកពីរ ក៏ផ្ញើឈើច្រត់ទុក ទៅឯវិហារទីបីសួរថា ភិក្ខុក្នុងវត្តនេះ បានសំពត់ចំណាំវស្សាប៉ុន្មាន ? កាលគេប្រាប់ថា បាន

សំពត់សាដកបី ក៏ផ្ញើតម្រងទឹកទុក ទៅឯវិហារទីបួនសួរថា ភិក្ខុក្នុងវត្តនេះ បានសំពត់ចំណាំវស្សាប៉ុន្មាន ? កាលគេប្រាប់ថាបានបួន និយាយថាប្រពៃហើយ យើងនឹងនៅក្នុងវត្តនេះ ហើយចាំវស្សាក្នុងវត្តនោះសំដែងធម្មកថាដល់គ្រហស្ថ និងភិក្ខុទាំងឡាយ ៗ គ្រហស្ថ និងភិក្ខុទាំងនោះបូជាព្រះថេរៈដោយសំពត់ និងចីវរដ៏ច្រើនជាដើម ៗ លុះចេញវស្សាហើយព្រះថេរៈឲ្យដំណឹងទៅក្នុងវត្តទាំងនោះថា យើងគួរបានសំពត់ចំណាំវស្សាព្រោះយើងផ្ញើបរិក្ខារទុក ភិក្ខុទាំងឡាយ ចូរបញ្ជូនសំពត់ចំណាំវស្សានោះទៅឲ្យដល់យើង ហើយប្រើមនុស្សឲ្យមកគ្រប់វត្ត ប្រមូលយកសំពត់ចំណាំវស្សាផ្ទុកពេញរទេ តូចបរទៅ ៗ គ្រានោះ មានភិក្ខុកំឡោះពីររូបក្នុងវត្តមួយ បានសំពត់សាដកពីរ និងសំពត់កម្ពលមួយ មិនអាចនឹងចែកគ្នាដាច់ចេះតែជជែកគ្នាថា សំពត់សាដកត្រូវបានអ្នក សំពត់កម្ពលត្រូវបានខ្ញុំអង្គុយជជែកគ្នានៅទីក្បែរផ្លូវ ឃើញព្រះថេរៈនោះនិមន្តមក ទើបពោលថាព្រះករុណា សូមលោកជួយចែកសំពត់ឲ្យដល់ពួកខ្ញុំ ៗ លោកចែកខ្លួនឯងទៅចុះ ៗ ចែកគ្នាមិនដាច់ទេ តានប្រោស សូមលោកជួយចែកឲ្យដល់ពួកយើងខ្ញុំផង ៗ ពួកលោក នឹងសុខចិត្តតាមពាក្យយើងឬទេ ? សុខចិត្តតាមពាក្យលោក តានប្រោស ៗ ព្រះថេរៈនោះនិយាយថាបើដូច្នោះយើងជួយចែកបាន ហើយឲ្យសំពត់សាដកពីរដល់ភិក្ខុទាំងនោះប្រាប់ថា សំពត់កម្ពលនេះ ត្រូវបានជាសំពត់សម្រាប់ដណ្តប់របស់ខ្ញុំដែល

ជាអ្នកគោលធម្មកថា ហើយកាន់យកសំពត់កម្ពលចៀសចេញទៅ ។ ភិក្ខុកំឡោះទាំងពីររូប មានសេចក្ដីក្ដៅក្រហាយទៅគាល់ព្រះសាស្ដាក្រាបទូលសេចក្ដីនោះ ។ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា នែភិក្ខុទាំងឡាយ ភិក្ខុនេះយករបស់ពួកអ្នក ធ្វើពួកអ្នកឲ្យមានសេចក្ដីក្ដៅក្រហាយ មិនតែក្នុងឥឡូវនេះទេ សូម្បីក្នុងកាលមុន ក៏បានធ្វើដូច្នេះដែរ ទ្រង់នាំអតីតនិទានមកសំដែង ដូចតទៅនេះ ៖

សេចក្ដីថា ក្នុងកាលកន្លងទៅហើយ មានសត្វភេពីរ គឺភេមួយត្រាច់ទៅក្បែរច្រាំង ភេមួយទៀតត្រាច់ទៅក្នុងទឹកជ្រៅ ចាប់បានត្រីធំមួយ ឈ្លោះប្រកែកគ្នាថា ក្បាលត្រូវបានអញ កន្ទុយត្រូវបានឯង ហើយមិនអាចនឹងចែកគ្នាឲ្យដាច់ស្រេច ឃើញចចកមួយដើរមកក៏និយាយថា បពិត្រលោកមា ! សូមលោកជួយចែកត្រីនេះឲ្យដល់ពួកខ្ញុំ ។ ខ្ញុំព្រះពុទ្ធជាទ្រង់តាំងទុកក្នុងទីពិភាក្សា អង្គុយក្នុងទីនោះយូរយារពេក ដើរមកដើម្បីសម្រាកស្ងួន ឥឡូវនេះខ្ញុំគ្មានឱកាសទេ ។ បពិត្រលោកមា ! កុំធ្វើយ៉ាងនោះឡើយ សូមលោកជួយចែកឲ្យពួកខ្ញុំបន្តិច ។ ពួកអ្នកនឹងតាំងនៅក្នុងពាក្យរបស់ខ្ញុំឬទេ ? នឹងតាំងនៅ គឺតាមពាក្យលោកមា ។ ចចកនោះទទួលថា បើដូច្នោះ ខ្ញុំជួយចែកបាន ហើយកាត់ក្បាលទុកម្ខាង កាត់កន្ទុយទុកម្ខាង លុះធ្វើស្រេចហើយនិយាយថា នែក្មួយទាំងពីរ អ្នកទាំងពីរ អ្នកណាត្រាច់ទៅក្បែរច្រាំង គឺទឹករាក់ ៗ អ្នកនោះត្រូវ

យកខាងកន្ទុយ អ្នកណាត្រាច់ទៅក្នុងទឹកជ្រៅ អ្នកនោះត្រូវយកខាងក្បាល ឯចំណែកដុំកណ្ដាលខ្លួនត្រីនេះ ត្រូវបានយើងជាអ្នកតាំងនៅក្នុងធម៌ជាគ្រឿងវិនិច្ឆ័យ កាលញ៉ាំងភេទាំងពីរនោះ ឲ្យយល់ព្រមដោយពោលគាថានេះ ថា ៖

អនុតីរចារិ នង្គុដ្ឋំ សីសំ គម្ភីរចារិនោ
អថាយំ មជ្ឈិមោ ខណ្ឌោ ធម្មដ្ឋស្ស ភវិស្សតិ

សេចក្ដីថា ចុងកន្ទុយ ចូរមានដល់ភេត្រាច់ទៅក្បែរច្រាំង ក្បាលចូរមានដល់ភេត្រាច់ទៅក្នុងទឹកជ្រៅ ចំណែកដុំកណ្ដាលនេះ នឹងមានដល់យើងអ្នកតាំងនៅក្នុងធម៌ ៗ ចែករួចហើយ យកដុំកណ្ដាលដើរចេញទៅ ៗ ឯភេទាំងពីរនោះ ជាអ្នកមានចិត្តក្ដៅក្រហាយនាំគ្នាឈរសំឡឹងមើលចចកនោះ ។

ព្រះបរមសាស្ដាទ្រង់សំដែងអតីតនិទាននេះចប់ហើយ ញ៉ាំងភិក្ខុទាំងពីររូបនោះឲ្យដឹងច្បាស់ថា ភិក្ខុនេះ បានធ្វើពួកអ្នកឲ្យមានសេចក្ដីក្ដៅក្រហាយក្នុងកាលមុនយ៉ាងនេះឯង កាលទ្រង់តិះដៀលព្រះឧបនន្ទត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាមនុស្ស កាលនឹងប្រៀនប្រដៅអ្នកដទៃគប្បីតាំងខ្លួនទុកក្នុងគុណធម៌ដ៏សមគួរជាមុនសិន ហើយត្រាស់ព្រះគាថានេះថា ៖

អត្តានមេវ បឋមំ បតិរូបេ និវេសយេ

អថញ្ញមនុស្សេសយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។

បណ្ឌិត គួរដំកល់ខ្លួនទុកក្នុងគុណធម៌ដ៏សមគួរ (មានសេចក្ដីប្រាថ្នាតិចជាដើម) ជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ ។

កាលចប់ព្រះធម្មទេសនានេះហើយ ភិក្ខុទាំងពីររូបនោះ បានសម្រេចព្រះសោតាបត្តិផល ។

រឿងព្រះឧបនន្ទសាក្យបុត្រ ចប់ ។

| |
|---|
| លោភោ ធម្មានំ បរិបន្ថោ<br>អ្នកលោភច្រើន តែងអន្តរាយកុសលធម៌ |

# រឿងព្រះបធានិកតិស្សត្ថេរ

អដ្ឋកថាធម្មបទ ភាគទី ៦ អត្តវគ្គទី ១២

កាលព្រះបរមសាស្តា គង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនឹងព្រះបធានិកតិស្សត្ថេរ សំដែងធម៌ដោយបទគាថាថា អត្តានញ្ចេ តថា កយិរា ដូច្នេះជាដើម ។

បានឮមកថា ព្រះថេរៈនោះ រៀនព្រះកម្មដ្ឋានក្នុងសំណាក់ព្រះសាស្តាចប់ហើយ នាំភិក្ខុប្រមាណប្រាំរយរូប ទៅគង់ចាំវស្សាក្នុងព្រៃ តែងប្រៀនប្រដៅភិក្ខុទាំងនោះថា នែអាវុសោ ! ពួកលោករៀនកម្មដ្ឋានអំពីព្រះពុទ្ធទ្រង់គង់ព្រះជន្មនៅ ចូរជាអ្នកមិនប្រមាទ ចំរើនសមណធម៌ចុះ ប្រាប់រួចហើយ ទៅសម្ងំសឹងលក់ខ្លួនឯង ។ ភិក្ខុទាំងនោះ ចង្រ្កមក្នុងបឋមយាមរួចហើយ ចូលទៅវិហារក្នុងមជ្ឈិមយាម ។ ព្រះថេរៈចូលទៅរកមើលភិក្ខុទាំងនោះ នៅវេលាកំពុងសឹងលក់ ដាស់ឲ្យក្រោកឡើងហើយស្តីបន្ទោសថា ពួកលោកមកគិតតែដេកលក់ដូច្នេះទេឬ ? ចូរចេញទៅធ្វើសមណធម៌ឲ្យឆាប់ ប្រាប់រួចហើយ ខ្លួនឯងទៅសម្ងំដេកដូចមុនទៀត ។ ភិក្ខុទាំងនោះ ចេញទៅចង្រ្កមខាងក្រៅ ក្នុងមជ្ឈិមយាម រួចចូលទៅក្នុងវិហារវិញនៅវេលាបច្ឆិមយាម ។ ឯព្រះថេរៈ ក្រោកឡើងទៅរកមើលភិក្ខុទាំងនោះ ឃើញហើយបណ្តេញឲ្យចេញទៅធ្វើសមណធម៌ ចំណែកខ្លួនឯងទៅសម្ងំដេកលក់ដូចមុនទៀត ។

កាលព្រះថេរៈធ្វើយ៉ាងនេះអស់កាលជានិច្ចមក ភិក្ខុទាំងនោះ មិនអាចនឹងទន្ទេញឲ្យចាំបាន ក៏មិនអាចនឹងចំរើនកម្មដ្ឋាន ព្រោះចិត្តចេះតែរាយមាយ បានជំនុំប្រឹក្សាគ្នាថា អាចារ្យរបស់ពួកយើងប្រារព្ធសេចក្តីព្យាយាមយ៉ាងលើសលុប ពួកយើង នឹងឃ្លាំចាំមើលលោកឲ្យឃើញច្បាស់ ៗ ក្រោយមក ភិក្ខុទាំងនោះបានលបមើលឃើញកិរិយាព្រះថេរៈនោះជាក់លាក់ ហើយប្រឹក្សាគ្នាថា នែអាវុសោ ! ពួកយើងនេះវិនាសហើយ ព្រោះអាចារ្យរបស់ពួកយើងស្រែកតែទទេ ៗ ថា កោក ៗ តែមាត់ ឥតធ្វើសមណធម៌សោះ ចេះតែសម្ងំដេកគ្រប់យាម ៗ ភិក្ខុទាំងនោះលំបាកចិត្តដូចគ្នា សូម្បីតែភិក្ខុមួយរូប ក៏មិនបានសម្រេចគុណវិសេសណាមួយឡើយ ៗ លុះដល់បវារណាចេញវស្សាហើយ ភិក្ខុទាំងនោះ នាំគ្នាទៅគាល់ព្រះបរមសាស្តា ព្រះអង្គទ្រង់ធ្វើបដិសណ្ឋារៈរួចហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ! ពួកអ្នកមិនប្រមាទ បានធ្វើសមណធម៌ដែរឬទេ ? ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនោះសព្វគ្រប់ ៗ ព្រះសាស្តាត្រាស់ថា ភិក្ខុទាំងឡាយ! មិនមែនតែក្នុងគ្រាឥឡូវនេះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះ ក៏បានធ្វើអន្តរាយដល់ពួកអ្នកដូច្នេះដែរ ៗ ភិក្ខុទាំងនោះ ក្រាបទូលអារាធនា សូមព្រះអង្គសំដែងអតីតនិទាន ទើបព្រះមានព្រះភាគនាំយកអកាលរាវិកុក្កុដជាតកមកសំដែងថា ៖

« មាន់នេះ មិនមែនចំរើនក្នុងសំណាក់មេនិងបាទេ មិនមែនជាសត្ត

នៅក្នុងត្រកូលនៃភាបាយទេ តែងមិនដឹងកាលគួរឬមិនគួរ ” ។

ព្រះសាស្តាត្រាស់តទៅទៀតថា ភិក្ខុទាំងឡាយ ធម្មតាភិក្ខុ កាលបើប្រៀនប្រដៅអ្នកដទៃ គប្បីទូន្មានខ្លួនឯងឲ្យបានល្អជាមុនសិន ព្រោះថា កាលបុគ្គលប្រៀនប្រដៅយ៉ាងនេះ ជាអ្នកហាត់ពត់ខ្លួនឯងបានបទល្អហើយ ឈ្មោះថាគួរជាអ្នកទូន្មានអ្នកដទៃ ។ ព្រះអង្គទ្រង់ត្រាស់គាថាថា៖

អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ
សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ។

បុគ្គល ប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឯងឲ្យបានយ៉ាងនោះដែរ, អ្នកដែលទូន្មានខ្លួនបានបទល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានខ្លួនឯងបានពេកណាស់ ។

កាលចប់ធម្មទេសនា ភិក្ខុទាំងប្រាំរយរូប បានសម្រេចព្រះអរហត្តផលព្រមគ្នា ។

រឿងព្រះបធានិកតិស្សត្ថេរ ចប់ ។

ធម្មតាសត្វមាន់ គ្រាន់តែរងាវដាស់គេ
ឯខ្លួនឯងវិញដេកលក់ទ្រមក់ ហើយដុះ
អាចម៍ដាក់បង្គងថែមទៀត ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

( ត )

*ព្រះមហា ឃាង-ខាត់ រៀបរៀង*

---

អបហ　　គុ. ដែលទៅឆ្ងាយ ដែលបំភ្លាញ ។ អបហតិ ស្ត្រី. កិរិយាបណ្តេញ និរទេស ។

អបហន　　ធាតុ បណ្តេញ បំផ្លាញ ។ —ហត គុ. ដែលលះបង់ ។

អបហន្ត្ឫ　　ការក. អ្នកវែក អ្នកបំបែក ។

អបហារ　　គុ. ដែលពង្រត់ ។ ដែលធ្វើឲ្យអណ្តែតអណ្តូង ។

អបហរណ　　នបុំ. កិរិយាពង្រត់ កិរិយានាំពង្រត់ ។

អបហត៌្យ　　គុ. ដែលគប្បីនាំចេញ ដែលគប្បីពង្រត់ ។

អបហត៌ឫ　　ការក. អ្នកពង្រត់ អ្នកបំផ្លាញ ។

អបហម៌　　គុ. ដែលមិនមានសេចក្តីរីករាយ ។

អបហាស　　ធាតុ សើចពីគេ ចំអក ។

អបហស្ត　　នបុំ. កិរិយាចក់ដៃបណ្តេញ ។ បុំ. ខ្នងដៃ ។

អបហស្តិត　　គុ. ដែលចក់ដៃបណ្តេញ ដែលលះបង់ចោល ។

អបហា　　ធាតុ　　បោះបង់ចោល លះបង់ចោល ។

អបហាន　　នបុំ.　　កិរិយាពង្រត់ កិរិយាលាក់បំពួន ។

អបហានិ　　ស្ត្រី.　　កិរិយាបំបាត់ ។

អបហារ　　បុំ.　　អបហារ កិរិយានាំចេញ កិរិយាលាក់បំពួន កិរិ-
យាបដិសេធ ។ -រិន　គុ. អ្នកពង្រត់ ។
-រិម៌ន បុំ. តាមមនុស្ស ។

អបហារក　　បុំ.　　អ្នកពង្រត់ ចោរ ។

អបហារណ　　នបុំ.　　កិរិយាបណ្ដោយឲ្យរត់ ។

អបហាស　　បុំ.　　កិរិយាសើចចំអក ។

អបហាស្យ　　គុ.　　ដែលគួរសើចចំអក ។

អបហិ　　ធាតុ　　រំដោះ ។

អបហ្ប　　ធាតុ.　　រុញ ច្រាន ពង្រត់ដោយកម្លាំង ។ ផ្ដាច់ចេញ
បំបាត់ បំផ្លាញ ។

អបហ្បតិ　　ស្ត្រី.　　កិរិយាពង្រត់ ។

អបហារ　　បុ.　　កិរិយាបដិសេធ កិរិយាប្រកែក ។ កិរិយា
លាក់បំបាំង ផង ។

អបហារក　　ឧបុ.　　កិរិយាប្រកែក ។

អបហ្ឫ　　ធាតុ　　លាក់ បដិសេធ ។

អបហ្ឫតិ　　ស្ត្រី.　　កិរិយាលាក់គំនិត ។

អបាករណ　　ឧបុ.　　កិរិយាធ្វើយបដិសេធ ។

អបាករ្មិ　　គុ.　　ដែលទុកនៅខាងក្រោយ ។

អបាក្ឫ　　ធាតុ　　បោះបោល បញ្ឈប់ ។ លះបង់បោល ។
សងបំណុល ។ —ក្ឫត គុ. ដែលរួច ។

អបាក្ឫតិ　　ស្ត្រី.　　មារយាទអាក្រក់ ។ កិរិយាគេចចេញ កិរិ.
យាបះបោរ ។ កិរិយាប្រមាថ ។

អបាក្ឫប　　ធាតុ　　បំបែរ វែក ។ —ក្ឫប្ត គុ. ដែលធ្វើឲ្យ
អាមាសមុខ ។

អបាក្ប ធាតុ ទុកនៅឆ្ងាយផ្លូវភព ទុកនៅឆ្ងាយគម្រោងការ ។

អបាង្ក្តេយ គុ. ដែលមិនឲ្យចូលក្នុងសង្គម ។ -បាង្ក្ត្យ គុ. ផ្ទុយគ្នា ។ -អបាង្ក្ត្យោបហត គុ. ដែលប្រឡាក់ដោយជនមិនបរិសុទ្ធ ។

អបាង្គ បុ. ចុងភ្នែកខាងក្រៅ កិរិយាចោលកន្ទុយភ្នែក ។ តិលកៈ ។ -ទ្ឫឞ្ដិ ស្ត្រី. កិរិយាក្រឡេកចុងភ្នែក ។ -នេត្រ គុ. ដែលចោលកន្ទុយនេត្រ ។

អបាបត គុ. ដែលមិនបានចំអិនអាហារ ។

អបាញ្ចល្យ ឧបុ. កិរិយាបំផ្លាញនៃជនបញ្ចាល ។

អបាណិ គុ. ដែលមិនមានដៃ ។ -ត្វ ឧបុ. ភាវនៃកិរិយាមិនមានដៃ ។ -គ្រហណា ស្ត្រី. ស្ត្រីដែលមិនបានរៀបការ ។ -បាទ គុ. ដែលមិនមានដៃនិងជើង ។

ការស្រាវជ្រាវ

# ប្រវត្តិលោកធិរសេស ស៊ូច

របស់បណ្ឌិតមហា ឈឹម-ក្រសេម អតីតសាស្ត្រាចារ្យ

(តមក)

---

## ជីវភាពក្នុងភេទជាគ្រហស្ថ

នៃ

## លោកតាអាចារ្យ ដួង

*លោកតាអាចារ្យ ដួង និងឧបាសិកា មាស ចាប់ដៃគ្នាកសាងគ្រួសារ ពីដើមទីរហូតដល់ទីបំផុតបានកូនប្រុសម្នាក់ឈ្មោះស្វាយ កូនស្រីម្នាក់ឈ្មោះ មុំញ ។ លោកជាកសិករប្រកបរបរកសិកម្មផង ធ្វើក្អមឆ្នាំងផងតាមសញ្ជាតិ ជាខ្មែរអ្នកងារពលព្រះ(១) ។ ក្នុងពេលឱកាសមួយខែពីរខែនៃឆ្នាំនីមួយ ៗ*

---

(១) ក្នុងកម្ពុជរដ្ឋយើង ពីសម័យបុរាណមកទល់នឹងរជ្ជកាលនៃព្រះបាទសម្តេចព្រះស៊ីសុវត្ថិ គេចែកវណ្ណៈមនុស្សដូចប្រទេសឥណ្ឌាដែរ គឺក្សត្រ (ស្តេច), ព្រាហ្មណ៍ (បារគូ ឬ បុរោហិត), វេស្សៈ ឬ វៃស្សៈ (អ្នកក្រៃងារ) សូទ្រៈ (អ្នកងារ) ។ អ្នកងារនេះឯងជាវណ្ណៈទាបបំផុត សម្រាប់តែរាជការហៅមកប្រើតាមមុខការផ្សេង ៗ ដែលចែកជាក្រុម ដោយរួមៗថា: ពលព្រះ (អ្នកងារសម្រាប់តែធ្វើព្រះស្រែ គឺស្រែដែលលួងដាក់ថ្វាយព្រះសម្រាប់វត្ត), ពលអង្គរក្ស (អ្នកងារដែលគេប្រើជាទាហានរក្សាព្រះអង្គស្តេច), ពលទ្រមាក់ (អ្នកងារ រក្សាធំរីព្រះរាជទ្រព្យ), ពលចែវ (អ្នកងារសម្រាប់ចែវព្រះទីនាំងនាវា), ពលគុន (អ្នកងារសម្រាប់ចូលគុន ជល់ ចំបាប់ ថ្វាយព្រះមហាក្សត្រទត) ។ ហៅកាត់ថា: ពលព្រះ, -អង្គរក្ស, -ទ្រមាក់, -ចែវ, -គុណ ។

លោកតែងបង្រៀនទេសមហាជាតក៍ផង បង្រៀនព្រះកម្មដ្ឋានផង ។

លោកតាអាចារ្យដួង មានការមមាញឹកជាទិច្ច ព្រោះមានករណីយកិច្ច មិនត្រឹមតែដូចថ្លែងខាងលើនេះប៉ុណ្ណោះទេ ថែមទាំងមានការទទួលភ្ញៀវញឹកញាប់ណាស់ផង ។ ចាស់ៗ បា ដំណាលប្រាប់ថា : ភ្ញៀវច្រើនប្រភេទ គឺព្រះសង្ឃនិងអ្នកឧមិអាចិ តែងចូលទៅរកលោក ដើម្បីការសន្ទនាអំពីសេចក្ដីប្រព្រឹត្ត , គ្រហស្ថ ក្មេងកម្លោះតែងចូលទៅរកដែរ ដើម្បីលំហែសេចក្ដីទុក្ខព្រួយក្នុងរឿងស្នេហា គឺកម្លោះដែលមានទុក្ខព្រោះគេមិនឱ្យកូនក្រមុំជាដើម តែងទៅថ្លែងទុក្ខដំកបលោក ។ លោកស្ដាប់សេចក្ដីថ្លែងទុក្ខបណ្ដើរ ចារស្លឹករឹតបណ្ដើរ ធ្វើកាព្យតាមដំណើរនៃសេចក្ដីទុក្ខនោះ ឱ្យដល់អ្នកកើតទុក្ខនោះបានភ្លាមៗ ។ ហេតុដូច្នេះបានជាអត្ថបទដែលលោកតាអាចារ្យដួងតែង គេឃើញច្រើនតែកំណាព្យស្នេហា ហើយជាអត្ថបទខ្លីៗ ដូចខ្ញុំនឹងសរសេរតទៅខាងចុងនេះខ្លះ ។

ករណីយកិច្ចដូចថ្លែងមកនេះ ជាការចិញ្ចឹមជីវិតរបស់លោតាអាចារ្យដួង ព្រោះមនុស្សជំនាន់នោះ ទោះបីមិនសូវប្រើប្រាក់កាសជាគ្រឿងឈ្នួលក៏មែនពិត, ប៉ុន្តែគេដឹងគុណរបស់អ្នកធ្វើប្រយោជន៍ឱ្យគេណាស់ គេតែងផ្ដល់ជូនលោកតាំងពីអាហារភោជន សំពត់អាវស្បៀកពាក់ រហូតដល់កម្លាំងជួយធ្វើការផ្សេងៗផង ។ មិនត្រឹមតែគ្រហស្ថទេ សូម្បី

បព្វជិត  ក៏ជួយផ្គត់ផ្គង់ជីវភាពនៃលោកតានេះដែរ ។

លោកតាអាចារ្យជួន  មានសម្បុរសជ្រះ  មាឌតូចស្តើង  ខ្ពស់ស្រឡះ  សំដីហើស  សំឡេងស្រួយ  មានគេស្រឡាញ់គោរពរាប់អានច្រើន  ទោះបីក្នុងជំនាន់នោះ  ខ្មែរកំពុងប្រកាន់វណ្ណៈ  គឺអ្នកព្រៃងារពុំព្រមចងពន្ធរៀបអាពាហ៍ពិពាហ៍នឹងអ្នកងារសោះ  សូម្បីត្រឹមតែបរិភោគអាហារ  ក៏មិនបរិភោគក្នុងវង់ជាមួយគ្នាផង  ម្តេចគង់រូបលោកតាអាចារ្យជួន គេបំភ្លេចលែងគិតថា  លោកជាអ្នកងារ ។ ដូចឧទាហរណ៍ពីរខតទៅនេះ :

១- លោកតាអាចារ្យ ជួន មានកូនស្រីម្នាក់ឈ្មោះម៉ិញ ជាស្រីក្រមុំធម្មតា  មិនល្អជាងគេណាស់ទេ  ថែមទាំងកើតក្នុងត្រកូលអ្នកងារផង ។ មានមាណពម្នាក់ឈ្មោះនាង  នៅឃុំសែនដី (សព្វថ្ងៃក្នុងស្រុកសំពេងទង ) កូនអ្នកព្រៃងារ ព្រមព្រៀងជាមួយនឹងមាតាបិតា  បានចូលមកស្តីដណ្តឹងនាងម៉ិញ ។ លោកតាអាចារ្យ ជួន ពុំព្រមឲ្យ ដោយការអាងថាខុសប្រពៃណី ដូចជាគេទឹមរទេះដោយគោម្ខាង ក្របីម្ខាង ។ អ្នកកម្លោះឈ្មោះនាង  មិនព្រមថយប្តូរឈប់  ព្រោះងប់ជាប់ចិត្តនឹងក្តីឈ្មោះរបស់លោកតាអាចារ្យជួន ។ អ្នកកម្លោះនាងស៊ូទ្រាំចំបម្រើលោកតាអាចារ្យជួន អស់វេលា ៤ ឆ្នាំ សុខចិត្តលាជាតិចេញពីអ្នកព្រៃងារ ចូលសញ្ជាតិជា

អ្នកងារ តាមលោកតាអាចារ្យជួនវិញ ទើបលោកព្រមឲ្យរៀបអាពាហ៍-ពិពាហ៍ ។

២ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ដែលទ្រង់កំពុងសព្វព្រះរាជហឫទ័យនឹងលោកសុន្ទរវោហារ ម៉ុក ( កែវ ) ទ្រង់ជ្រាបថា លោកម៉ុកនេះមានដៃគូម្នាក់ទៀតឈ្មោះជួន(១) ។ ទ្រង់ឲ្យអញ្ជើញលោកតាអាចារ្យជួន មកគាល់គង់ព្រះបរមរាជវាំងចតុមុខ ទ្រង់ពិសោធដោយការសន្ទនាផ្ទាល់ព្រះអង្គផង ឲ្យសរសេរជាលាយលក្ខណ៍អក្សរផង ទ្រង់សព្វព្រះរាជហឫទ័យ ទើបទ្រង់ព្រះរាជទានផ្ទាល់ព្រះឱស្ឋនូវឋានៈជាមន្ត្រីស័ក្តិ ៩ ហ៊ូពាន់ មានងារជា « ហ្លួងវិសេសអក្ខរជួន »

លោកតាអាចារ្យជួន មានកិត្តិយសសំខាន់ណាស់ ប្លែកពីមន្ត្រីឯទៀត , ប៉ុន្តែព្រោះហេតុតែលោកជាមនុស្សរហ័សពេក , លោកឆ្លើយទាស់ព្រះរាជឱង្ការថា : បើព្រះករុណាទ្រង់ព្រះមេត្តាប្រោសជួន សូមទ្រង់ព្រះមេត្តាអ្នកងារឯទៀតផង គឺសូមឲ្យអ្នកងារទាំងអស់បានរួចខ្លួនជាព្រៃងារ ទើបទូលព្រះបង្គំព្រមទទួលយកកិត្តិយសដ៏ខ្ពង់ខ្ពស់នេះ(២) ។ ការនេះ

---

(១) លោកតាអាចារ្យជួន ចាស់ជាងលោកសុន្ទរវោហារម៉ុក ប្រហែល ៣០ ឆ្នាំ ព្រោះគ្រាដែលព្រះករុណាទ្រង់ប្រទានងារនោះ លោកតាជួនមានអាយុជិត ៧០ ឆ្នាំហើយ ។

២– សំដីលោកតាអាចារ្យជួនត្រង់នេះ សឲ្យឃើញទឹកចិត្តរបស់លោកថាជាអ្នកសង្គ្រោះញាតិ ដែលពុទ្ធភាសិតថា ញាតកានញ្ច សង្គហោ ។ ឬបើនិយាយតាមពាក្យសាមញ្ញថា អ្នកស្នេហាជាតិ ដែលជាគំរូមួយដ៏ល្អ សម្រាប់បច្ឆាជនជាន់ក្រោយ យកតម្រាប់តាម ។

ពុំបានសម្រេច ។ លោកតាអាចារ្យជួនបានឆ្លើយថា " ហួងវិសេសអគ្គាគ " ត្រឹមតែព្រះរាជទានងារផ្ទាល់ព្រះឱស្ឋប៉ុណ្ណោះ ពុំបានប្រកាសនីយប័ត្រត្រា-តាំងពេញលក្ខណៈជាមន្ត្រីទេ ។ តមកទើបអ្នកឆ្លើយជាត្រៃឆ្លើយទាំងអស់គ្នា ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ប្រហែលជាដោយហេតុ ដែលលោកតាអាចារ្យជួនសុំនោះទេដឹង ? :

## ស្នាដៃក្នុងការនិពន្ធ

## នៃ

## លោកតាអាចារ្យ ជួន

អ្នកនិពន្ធនេះ បានសរសេរពាក្យកាព្យរឿងតែឡូវអត្ថបទដូចតទៅនេះ ៖

១– ល្បើករឿងតាហ៊ីង

២– រឿងសេកសារិកា

៣– សាស្ត្រានេទមាល ឬ សុវណ្ណពិលាប

៤– សាស្ត្រាផ្កាឈូក ឬ ផ្កាឈូកកាមឈូង

៥– ល្បើកអក

៦– ល្បើកដុច

៧– ច្បាប់ទូនអ្ន

៨– សព្វផ្កា

៩– គម្ពីរមហាជាតក៍ (វេស្សន្តរជាតក ដែលលោកកែរបស់គេស្រាប់)

១០– ល្បើកជូជក

១១– កំណាព្យកំប៉ុកកំប៉ុកផ្សេងៗច្រើន ដែលលោកតែងឡើងតាមសេចក្ដីថ្លែងទុក្ខរបស់អ្នកសុំ ។

## សេចក្ដីបញ្ជាក់

**ក. ល្បើករឿងតាហ៊ឹង :** កំណាព្យនេះ ខ្ញុំពុំដែលឃើញ ថែមទាំងស្រាវជ្រាវរកតៗមក ក៏ពុំឃើញទៀត, ប៉ុន្តែចាស់ៗ ដូចមាននាមខាងដើមនេះប្រាប់ខ្ញុំថា លោកគ្រូអាចារ្យដួង កាលទើបនឹងទទួលឋានៈជាចៅអធិការវត្តអង្គទន្ទាប់ បាននៅជាមួយគ្នានិងលោកតាហ៊ីងនេះដែលចាស់វស្សាជាង ហើយដែលមានសេចក្ដីស្រឡាញ់នឹងសេចក្ដីគោរពចំពោះលោកគ្រូអាចារ្យដួងផង ។ ពុំដឹងជានៅជាមួយគ្នាបានប៉ុន្មានឆ្នាំ ទើបលោកគ្រូអាចារ្យដួងតែងកាព្យនេះឡើង កុងគ្រាដែលលោកតាហ៊ីងមានអាពាធធ្ងន់ ។ កាព្យនេះចាស់ៗទាំងឡាយ បាននិយាយប្រាប់ខ្ញុំថា មើលទៅគួរឲ្យអស់សំណើចព្រោះ :

១– ផ្ដើមនិយាយពីសន្ធារគាក់តែងមនុស្សលោកមិនឲ្យដូចគ្នា ។

រយៈដំបូងនេះមានសេចក្ដីជាសម្ភោគចំលើរូបរាងកាយលោកតាហ៊ុំ ដែល ពិការពិក ។

២– និយាយពីសណ្ឋានទ្រង់ទ្រាយ និងអាការៈពិការពិកនៃលោក តាហ៊ុំ ។

៣– និយាយពីអាការពេទនៃលោកតាហ៊ុំ ។

៤– និយាយពីកិរិយាខ្វល់ខ្វាយក្នុងការព្យាបាលពេទ គឺអ្នកខ្លះរកហោរទាយ, អ្នកខ្លះបន់ព្រះសំពះអ្នកតា, អ្នកខ្លះរកគ្រូបាផ្សំថ្នាំសង្កូវ, អ្នកខ្លះបញ្ជាន់អារក្ស ។ អ្នកក្មេងលេងអស់ក្បួនអារក្សមិនចូល ។ ក្នុងការព្យាបាលនេះមានមនុស្សប៉ុន្មាននាក់ អ្នកណាធ្វើអ្វីដោយអាការយ៉ាងណា, នោះសុទ្ធតែមានឈ្មោះចុះជាប់ក្នុងកំណាព្យនោះទាំងអស់ ។

**យោបល់ខ្ញុំ ៖** ខ្ញុំយល់ថាលោកគ្រូអាចារ្យជួង ជាអ្នកប្រាជ្ញខាងកាព្យឃ្លោង សម្បូណ៌វោហារចង់ថាយ៉ាងណាបានយ៉ាងនោះភ្លាម ៗ គួរឲ្យកោតសរសើរមែនហើយ, ប៉ុន្តែរឿងនេះ បើពិតដូច្នេះមែន, ខ្ញុំថាកវីរូបនេះ សម្បូណ៌ប្រាជ្ញាក្នុងការតែងកាព្យ តែខ្វះសម្បជញ្ញៈ, សម្បូណ៌គំនិតក្នុងបច្ចុប្បន្ន តែខ្វះគំនិតអនាគត ។ នរណាក៏ដោយ បើមានចរិយាបែបនេះ, នោះនឹងធ្វើការពុំសូវបានសម្រេចផលល្អទេ ។

សូមទោស ! លោកតាហ៊ុំជាមនុស្សចាស់មានគេរាប់អានច្រើន

ណាស់ ហើយថែមទាំងស្រឡាញ់ ព្រមទាំងតម្កុំតម្កើងលោកគ្រូអាចារ្យជួន ជន ។ គួរបើលោកគ្រូអាចារ្យជួនហ៊ានតែងកាព្យជាគ្រឿងជំបួចសើច លេងឲ្យបានពីរោះលើកពីកាយពិការពិការបស់លោកតាហ៊ុន ដែលកំពុងមានអាពាធធ្ងន់ធ្ងរនោះយ៉ាងហ្នឹង នេះមិនមែនចរិយារបស់អ្នកប្រាជ្ញទេ ។ ប្រហែលជាកាព្យហ្នឹងទេដឹង ដែលនាំឲ្យបរិស័ទលោកតាហ៊ុនបែកចិត្ត នាំគ្នាកវត្តអង្គតាជនមួយទៀត និមន្តលោកតាហ៊ុនទៅគង់ជាចៅ-អធិការ ក្នុងគ្រាដែលលោកតាហ៊ុន ជាចាកពីអាពាធហើយ ត្រឡប់ពីភ្នំជីសូរ មកវិញ ។

១) រឿងសេកសារិកា: រឿងនេះក៏ជាពាក្យកាព្យដែរ ជាស្លឹករឹតក៏មាន ជាសៀវភៅបោះពុម្ពក៏មាន, ប៉ុន្តែគ្មាននាមអ្នកនិពន្ធ ។ លោកគ្រូកែវ-ឡាង ចៅអធិការវត្តអង្គព្រះពាន (វែនតែន) និងលោកតាជួន កឿង បានសរសេរឲ្យការខ្ញុំថា ជាស្នាដៃរបស់លោកគ្រូអាចារ្យជួនដែរ, ប៉ុន្តែពុំដឹងជាតែងក្នុងខែណាឆ្នាំណាទេ ។ ស្មានថា រឿងសេកសារិកានេះប្រហែលជាលោកតែងក្នុងគ្រាដែលទើបនឹងត្រឡប់ពីបាត់ដំបង មកគង់វត្តព្រះនិព្វានវិញ ។

រឿងសេកសារិកានេះមានដើមថា :

នេះគឹងប្លាថ្លែងបែងបារបង លើកតាមទំនងល្បងកាព្យ

ប្រាំពីរពាក្យពិតគិតបួនឃ្លា ហៅថាមួយល្បះរះសេចក្ដី ។
និទានថាមានសេកសោមសត្វ ប្រាជ្ញប្រាយស្រាយកាត់ការអ្វី ។
ព័ណ៌បៃតងស្រស់ខៀវប្រិមខ្ចី សំដីពីរោះក្បោះវាចា ។
ជាសេកមហោសថពោធិសត្វ នៅក្នុងនគររដ្ឋមិថិលា
ឯស្ដេចសោយរាជ្យទ្រង់នាមថា មហាវិទេហរាស្ត្ររិទ្ធី(១) ។ល។

*រឿងនេះអ្នកនិពន្ធតែងតាមមហោសថជាតកដែលគេបញ្ចូលក្នុងទសជាតក៍ ដោយការដកស្រង់យកតែត្រង់រឿងសេកសោមបណ្ឌិតរបស់ព្រះមហោសថមកបញ្ចូលសេចក្ដីថែម ឲ្យទៅជាកំណាព្យស្នេហា ។*

*រឿងនេះនៅក្នុងការសង្ស័យខ្លះរបស់ខ្ញុំ ព្រោះ បានចម្លើយមកថាជារបស់លោកគ្រូអាចារ្យ ដួង ត្រឹមតែពីប្រកពាក្យលែនពេនមួយប៉ុណ្ណោះ ។ ប៉ុន្តែ មានជំនឿខ្លះថា ប្រហែលពិតមែន ព្រោះមានចំណុចពីរដែលគួរឲ្យជឿគឺ :*

*១– លោកគ្រូអាចារ្យ ដួង មានសញ្ជាតិជាអ្នកងារ ។ ក្នុងគ្រានោះ គេមិនព្រមឲ្យអ្នកងាររៀបអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកព្រះងារទេ ។*

---

១ - រឿងនេះព្រះអង្គម្ចាស់ នរោត្តម-ភាណុរង្ស បានចាត់ឲ្យផ្ទួសផ្ទុលពាក្យខ្លះហើយបោះពុម្ពក្នុងរោងពុម្ពកម្ពុជវរោកាស ហើយតមក បានជាការផ្សាយរបស់បណ្ណាគារ គីម-សេង ។

ប្រហែលលោកគ្រូអាចារ្យ ដូង ចង់ឲ្យសាធារណជនដឹងថា : តាមធម្មជាតិ គ្មានអ្វីជំទាស់ក្នុងរឿងអាពាហ៍ពិពាហ៍នេះទេ , អម្បាលសត្វសេកអាចយកសត្វសារិកាជាប្រពន្ធបាន, តាបសត់ស៊ីជាតិជាមនុស្ស អាចដាក់សីលផ្ដាសយកសត្វកិន្នរីជាប្រពន្ធបាន ដូចមានសេចក្ដីក្នុងរឿងសេកសារិកានោះសព្វគ្រប់ ។

២– ប្រកពវត្តលែនពែន បានឲ្យការថា រឿងនេះលោកតាអាចារ្យ ដូង តែង ក្នុងគ្រាដែលទើបត្រឡប់ពីបាត់ដំបងមកគង់ក្នុងវត្តព្រះនិព្វានវិញ។ ពាក្យនេះសមគ្នានឹងពាក្យក្នុងរឿងនោះថា :

“នេះនឹងថ្លាថ្លែងពែងបារបង លើកតាមទំនងល្បងកាព្យ”

បានសេចក្ដីថា: កំណាព្យរឿងសេកសារិកានេះ លោកលើកតាមទំនង ដែលមានមកពីបុរាណ ហើយជាការលើកសាកល្បងមុនដំបូងបំផុត ។

(មានតទៅទៀត)

# រឿង ចៅតែលលក

ស.ហ. ព្រួច - កុម

រៀបរៀងតាមការនិទានតៗមក

មានសេចក្តីដំណាលថា កាលពីព្រេងនាយ មានត្រកូលមួយដ៏កំសត់ទុគ៌ត តាំងទីលំនៅ កក្កូមិនៅចុងស្រុក , មានឈ្មោះមិនប្រាកដ, មានកូនប្រុសពីរនាក់ , កូនច្បងមានអាយុ ១៦ ឆ្នាំ កូនប្អូនទើបតែបានអាយុ ២ ឆ្នាំ ។

ចួនជាស្រុកកើតទុរ្ភិក្ស , អ្នកកំសត់ប្តីប្រពន្ធនោះ ក៏ខំប្រឹងត្រដរចិញ្ចឹមកូនដរាបមក រហូតដល់គេអ្វីអាស្រ័យលែងបាន ។ ប្តីប្រពន្ធនោះក៏ត្រូវចូលព្រៃរកបេះផ្លែឈើ ជីកមើមឈើ អាស្រ័យចិញ្ចឹមជីវិតគ្រួសារជាបន្តទៅទៀត ៗ លុះយូរបន្តិចមក ផ្លែឈើ មើមឈើ ដែលធ្លាប់តែមាននៅទីជិត ៗ ក៏បេះតែហោចអស់ទៅ ៗ ជាលំដាប់ ទឹងរកបានខ្លះ លុះតែចូលឲ្យជ្រៅទៅក្នុងព្រៃទុគ៌ម ប្រកបដោយសត្វសាហាវយង់ឃ្នង ។

កាលបើដូច្នេះ គ្រួសារនេះ ក៏ត្រូវមានអាហារកោដន កាន់តែត្រដាបត្រដួសត្រដរនៅចិញ្ចឹមកូនទាំងពីរ បានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក, មានពេលម្តងម្កាល ត្រូវនាំគ្នាដេកអត់ផង , ចំណីអាហារបន្តិចបន្តួច ក៏បានគ្រាន់តែឲ្យកូន, មានពេលខ្លះទៀត គឺគ្រាន់តែបានឲ្យកូនអាស្រ័យ

សម្រន់សេចក្ដីឃ្លាន មិនបានជាផ្អែតបរិបូណ៌ទេ បរិភោគយ៉ាងលើបលោប សោះទឹងជាប់ពោះស្ទាប់ ៗ

មានថ្ងៃមួយនោះ ទាំងពីរនាក់ប្ដីប្រពន្ធ ទុកកូនទាំងពីរឲ្យនៅចាំខ្ទម ហើយនាំគ្នាចូលព្រៃ ស្វែងរកផ្លែឈើមើមឈើ អស់ពេញមួយថ្ងៃ, ជាចៃដន្យ ថ្ងៃនេះ ជីកបានតែមើមដំឡូងពីរបីដុំតូចៗ, លុះពេលពន់ល្ងាច នាំប្ដីប្រពន្ធត្រឡប់មកលំនៅឋានវិញ, ដើរបណ្ដើរនិយាយគ្នាបណ្ដើរថា “ថ្ងៃនេះយើងរកភោជ្ជក័ស្តុមិនសូវបានសោះ បានតែបន្តិចបន្តួចស្តួចស្ដើងណាស់ ទឹងបរិភោគមិនបានគ្រប់គ្រាន់ទេ, បើតែយ៉ាងនេះ មុខជាទឹងជាប់ពោះស្ទាប់កុំពេលឆាប់ៗនេះជាមិនខាន, ភាណាអើយ បីបួនថ្ងៃមកហើយ ដូចឯងដឹងស្រាប់ អញមិនដែលបានអាហារពេញពោះទេ, អញដើរមកដល់ត្រង់នេះ ហាក់ដូចជាជេងជោងអស់កម្លាំងខ្លាំងណាស់ ពេលនេះជាពេលព្រលប់ធំទៅហើយផង, ម៉ែភាអើយ ឈប់សម្រាកត្រង់នេះបន្តិចសិនទៅប្អូ?” ប៉ុន្តែប្រពន្ធគាត់ដែលទូលកញ្ចើ កម្លាំងពលំក៏ហេវអស់ណាស់ដែរនោះ ត្រដរតបទឹងពាក្យប្ដីវិញថា “ឪភាអើយ កុំឈប់ធ្វើអ្វី ទំដេរស្រួតបន្តិចទៅ ទុះហ្នឹជិតដល់ពេលចូលទៅខ្ទមយើងហើយ, ឪភា កូនយើងទៅចាំខ្ទម ប្រហែលស្រេកឃ្លានខ្លាំងណាស់ហើយ ព្រោះថា ពីម្សិលមួយថ្ងៃ-ម្សិលមិញ មិនសូវមានអ្វីស៊ីផង, ថ្ងៃនេះទៀត ពេញមួយថ្ងៃទៅហើយ ពុំទាន់បានអ្វីមួយ

គ្រាប់ចូលពោះសោះ គួរយើងស្រុតដំណើរឲ្យប្រញាប់បន្តិចទៅ នឹងឲ្យ
ចំណីវា, បើចំពោះតែខ្ញុំ ឬឪពុកវាឯង ថាបើត្រូវដាច់ពោះស្លាប់ ក៏វាហើយ
តែម្ដងទៅចុះ តែអាណិតកូនវានៅក្មេង ” ។

ឪពុកនោះ ឆ្លើយឡើងថា “អើម៉ែវា តាមដែលអញគិតសព្វ ។ ទៅ
ពាក្យដែលឯងថាមកទាំងប៉ុន្មាន អញក៏ចូលចិត្តស្ដាប់បានទាំងអស់, អើ
ណា៎ ព្រោះតែអាណិតស្រឡាញ់កូនហើយ បានជាលែងគិតពីឡើយហត់
អត់ឃ្លាន សុខចិត្តអត់មាត់ឯង ឲ្យតែកូនបានស៊ី ដូចឃើញនឹងភ្នែក
ស្រាប់, តែថ្ងៃនេះ បើទុកជាខំស្រុតទៅឲ្យចំណីកូន ចំណីប៉ុណ្ណោះវា
បានប៉ុន្មាន តែកូនវាស៊ីមិនទាំងគ្រាន់ផង, បើម្យ៉ាង ១ ឃើញថាអញនេះ
ត្រូវស្លាប់ ដោយដាច់ពោះល្ងាចនេះ មិនខានឡើយ, បើអញស្លាប់ ផុត
អំពីអញទៅហើយ ឯងនេះ ត្រូវនៅមេម៉ាយឯកាអនាថា, ហើយបើ
តែឯងម្នាក់ ក៏មិនអាចចិញ្ចឹមកូនឲ្យបានរស់នៅយូរប៉ុន្មានដែរ គង់នឹង
ស្លាប់ទៅតាមអញទាំងអស់គ្នា ក្នុងពេលពីបីថ្ងៃក្រោយនេះមិនខាន, បើ
តាមដែលអញសន្និដ្ឋាន កូនយើង បើទុកជាយើងប្រឹងយ៉ាងណា ក៏ស្ទុះ
មិនរួចពីដាច់ពោះស្លាប់ដែរ ព្រោះយើងរកអ្វីឲ្យស៊ីលែងបានយ៉ាងនេះទៅ
ហើយ, ណ្ហើយម៉ែវា នែ៎ បើឯងគិតតាមអញ ប្រហែលបានស្រួល
ផង, អញគិតរួចស្រេចហើយ ឃើញថា បើយើងទាំងពីរនាក់មិនទាន់
ស្លាប់ទេនោះ គង់តែនឹងបានកូនទៀតមិនខាន មិនជាការក្រក្រអ្វីទេ ,

បើដូច្នេះ យើងកុំអាលទៅឲ្យដល់ខ្ទម ត្រូវនៅការង់ឲ្យដល់អធ្រាត្រស្ងាត់ ចាំកូនវាដេកលក់អស់សិន សឹមយើងទៅ, ហើយយើងនាំគ្នាចូលទៅកុំឲ្យវាដឹង, ឯងស្ងោរដំឡូងពីរបីដុំនេះឲ្យឆ្អិន ហើយយើងនឹងនាំគ្នាស៊ីតែពីរនាក់ ក្រែងអញបានរស់នៅជាមួយនឹងឯងតទៅ, ឯកូនស្រេចនឹងវាសនាទៅចុះ ធ្វើម៉េចឥឡូវ ...” ។

ដំបូង ប្រពន្ធមិនចុះសម្រុងតាមសំដីប្ដីទេ តែដល់ប្ដីចេះតែទទូចនិយាយដដែលៗដូច្នោះ ក៏ព្រមព្រៀងគ្នាទាំងពីរនាក់ ។ លុះដល់អធ្រាត្រស្ងាត់ ទើបនាំគ្នាចូលទៅកាន់លំនៅ ប្រពន្ធស្ងោរដំឡូង សូម្បីតែឆ្អុកក៏មិនហ៊ានឲ្យឮផង, ឆ្អិនហើយស្រង់ដាក់ចានយកមកបរិភោគ ។ គាប់ជួនពេលកំពុងបរិភោគនោះ ប្រពន្ធដែលក្រោកទៅយកកូនកាំបិតមួយទៀតមកពុះដំឡូង ដើរទៅជាន់ត្រូវត្រង់រនាបបះ បណ្ដាលឲ្យចានទន្ទិចរណ្ដំគ្នាលាន់ប្រាវៗ ឯកូនតូចដែលទន្ទឹងចាំមើលផ្លូវម៉ែឪបាត់យូរពេក ស្រែក្អែកដេកលក់ទៅ ដោយត្រូវខ្យល់រំភើយៗ លាយនឹងសេចក្ដីស្រេកឃ្លាន ហេវអស់កម្លាំងពេកផង, លុះគម្រានរើឡើងវិញ ប្រជួននឹងសូរសព្ទរណ្ដំចានទាំងអធ្រាត្រដូច្នេះ ក៏ភ្ញាក់ឡើង ក្រោកទៅរកស៊ីជាមួយនឹងឪពុកម្ដាយ ។ ឯកូនចង្រៃលង់ដំណេក គេស៊ីអស់ទៅហើយទើបភ្ញាក់ឡើងសើងម៉ាម៉ឹងទៅរកស៊ី ប្រទះឃើញតែសំបកដំឡូងបន្តិច ឃ្លានពេក ក៏លបស៊ី

សំបកដំឡូងនោះ ហើយចូលទៅដេកវិញទៅ ។

លុះព្រឹកព្រាងស្វាងអរុណោទ័យ, ឪពុកម្តាយនៃគ្រួសារនេះ ទុកកូនទាំងពីរឲ្យនៅចាំខ្ទមតាមទម្លាប់ ហើយរៀបកញ្ជើរដងទឹកចេញទៅព្រៃ ដូចសព្វថ្ងៃរៀងមក បានផ្តាំផ្តាកូនច្បងឲ្យមើលថែទាំប្អូនផង ទើបចេញផុតទៅ ។

និយាយពីកូនទាំងពីរដែលនៅចាំខ្ទម , លុះថ្ងៃរះខ្ពស់ផុតចុងឈើហើយ ឃ្លានអាហារណាស់ តែរកអ្វី ៗ ស៊ីគ្មាន, កូនប្អូនយំរអុករកចំណីក៏កាន់តែខ្លាំង សូម្បីបងរំលួងលោមម្តេចម្តា ក៏មិនបាត់យំសោះ, ឯថ្ងៃក៏ជិតត្រង់ហើយ បងវានោះ ទឹកក្លាញ់ណាស់ មិនដឹងជាទីងរកអ្វីឲ្យបានយកមកលួងប្អូនឲ្យបាត់យំ, គិតនាំប្អូនទៅកាន់ភូមិស្រុក ដើម្បីទីងរកសុំទានគេស៊ី, តែភូមិស្រុកក៏ឆ្ងាយ ស្រុកទេសក៏ខ្សត់ណាស់ផង មិនងាយនឹងសុំអ្វីបាន, គិត ៗ ទៅ ក៏នាំប្អូនដើរទៅក្រោយខ្ទម ក្បែរដំបូកមួយ ដែលនៅទីនោះ ម្តាយវាតែងចាក់ចោលអង្ករ ។ សម័យនោះ គេមិនស៊ីអង្ករទេ គេបុកអង្ករ រែងចាក់យកតែកន្ទក់ ដោយយល់ថា កន្ទក់ជាអាហារសម្រាប់មនុស្សបរិភោគ, ឯអង្ករគេចោលចុះ ដោយគេយល់ថា អង្ករសំរិតនោះជាធ្មឹងព្រះពៃស្រព ស៊ីពុំបានខ្ជាបស្វាក់ស្វាប់ ។ កាលបានឃើញអង្ករជាច្រើន នៅគរដូច្នោះហើយ វាក៏កើប

យកអង្ករនោះចំនួន ២ កំបង់ ទាំងយកទៅស្ងោរស៊ី ដោយគិតថា បើស្ងោរស៊ីទៅហើយស្លាក់ស្លាប់ ក៏ស្លាប់ទាំងពីរនាក់បងប្អូនទៅចុះ, រស់នៅធ្វើអ្វី បើអត់ឃ្លានម៉្លេះទៅហើយ ៗ មកដល់ខ្ទមវិញ ក៏យកអង្ករទៅប្រកឆ្នាំង ដាក់ទឹក បង្កាត់ភ្លើង ដាក់ស្ងោរ អង្គុយចាំមើលឆ្អិន លួងប្អូនបណ្ដើរផង ដរាបដល់អង្កររីកផុយល្អួយបានជាបបរ ទើបដាក់ចុះមកដួសដាក់ចាន, មិនទាន់ហ៊ានឲ្យប្អូនស៊ីមុនទេ ព្រោះខ្លាចប្អូនស្លាក់ស្លាប់មុន, ក៏យកបន្តិចមកភ្លក្សមើលសិន ដោយនឹកថា បើនឹងស្លាក់ស្លាប់ ក៏ឲ្យស្លាក់ស្លាប់ខ្លួនឯងមុនចុះ ៗ លុះភ្លក្សមើលទៅហើយ មិនឃើញស្លាក់ បែរជាមានឱជារសឆ្ងាញ់ទៅវិញ ទើបដាច់ចិត្តចែកឲ្យប្អូនស៊ីផង ដរាបដល់ឆ្អែតបាត់ឃ្លាន ស្រួលខ្លួនទាំងពីរនាក់ ៗ បរិភោគរួចហើយ ក៏នាំគ្នាដេកលក់ទាំងពីរនាក់ទៅ រហូតដល់ល្ងាច, លុះភ្ញាក់ឡើងវិញ ប្អូនឃ្លានយំរំអុក ទាររកស៊ី ក៏ទៅយកអង្ករមកស្ងោរឲ្យស៊ីទៀត ៗ ម្ដងនេះ ក៏គិតថា នឹងទុកឲ្យឪម៉ែខ្លះ, ប៉ុន្តែប្អូនតូចនោះ ចេះតែយំទារហើយទារទៀត លុះដិតអស់ នៅសល់តែបន្តិចកកាតនឹងបាតឆ្នាំង ទើបឈប់ទារ ៗ រួចហើយ នាំប្អូនអង្គុយចាំមើលផ្លូវឪពុកម្ដាយ ដែលនឹងត្រឡប់មកពីព្រៃ, ពេលព្រលប់ធំហើយ ក៏មិនទាន់ឃើញមកដល់ ក៏នាំប្អូនចូលដេកលក់ទៅៗ

ចំណែកឪពុកម្ដាយ ដែលចេញទៅរកផ្លែឈើមើមឈើ, ថ្ងៃនេះ

ចូលព្រៃជ្រៅឆ្ងាយ រកកំស្គុការក៏បានច្រើនគ្រាន់បើជាងសព្វដង, លុះតែពេលព្រលប់យប់ស្លាត់ទើបត្រឡប់មកដល់ខ្ទមវិញ, ម្ដាយយល់ឃើញស្ងាត់ជ្រងំ ក៏ប្រញាប់ចូលទៅក្នុងខ្ទម ឃើញកូនទាំងពីរដេកលក់ស្រមុកខ្សុរៗ គិតថា ថ្ងៃនេះ កូនអញប្រហែលជាឃ្លានខ្លាំងណាស់ហើយ ក៏ម្ញីម្ញាចូលទៅឯជើងក្រានទឹងយកឆ្នាំងលាងស្លោរដំឡូងឲ្យកូនស៊ី, ទាញឆ្នាំងយកទៅទឹងលាង ស្រាប់តែឃើញបបរបន្តិចនៅបាតឆ្នាំង ក៏នឹកថា «ហើ: ចុះមានធ្មឹងអ្វីមកនៅក្នុងឆ្នាំងដូច្នេះ» យួរទាំងឆ្នាំងមកដាស់កូនឡើងសួរ, កូនច្បងឆ្លើយថា « ម៉ែអើយ អាប្អូនវាយំពេក រំអុកឲ្យខ្ញុំរកចំណីឲ្យវា ខ្ញុំរកអ្វីមិនបានសោះ លួងវាយ៉ាងណា ក៏វាមិនព្រមបាត់យំ ខ្ញុំមិនដឹងជាធ្វើដូចម្ដេច បានជាខ្ញុំយកធ្មឹងនោះស្លោរ ខ្ញុំក៏ស៊ី វាក៏ស៊ី រួចហើយទើបបានវាបាត់យំ ដេកលក់មកដល់ថ្ងៃនេះណា៎ម៉ែ, បើម៉ែឃ្លានខ្លាំង ម៉ែពិសាមើលទៅ ធ្មឹងនោះនៅបន្តិចដែរ ។

គ្រាន់តែឮថាយកធ្មឹងស្លោរស៊ីភ្លាម, ម្ដាយខឹងណាស់ ប្រឡាតតួង កន្ត្រាក់បានអង្កត់ឧសមួយកំណាត់ ស្ទុះមកស្រែកសន្ធាប់ថា « អាកូនចោរចង្រៃ! អញវាយក្បាលអាឯងបំបែកឲ្យហើយសិន អាណាដែលទៅយកធ្មឹងស្លោរស៊ី ហ៎:», អានោះត្រូវក្បាលមួយអង្កត់ឧស ស្ទុះគេប្រេកប្រញាប់ធ្លាក់ទៅដល់ដី ទៅឈរយំអណ្ដឹតអណ្ដក ទាំងអញ្ជោត្រនៅក្បែរជ្រុងខ្ទម,

ម្ដាយមិនអស់ចិត្ត ក៏ស្ទុះទៅមើលកូនតូច ក្រែងវាដេកស្លាប់ទៅហើយ, តែដល់នៅឃើញមានដង្ហើម ដឹងជាក់ជាមិនទាន់ជ្រុលដល់ស្លាប់ទេ ទើបស្ទុះក្រទាទៅដេញអាកូនច្បងទៀត ហៅទាំងប្ដីឲ្យជួយដេញសំពងក្បាលអាកូននោះផង, ជួនជាអាពុកដែលកំពុងតែកាន់កាំបិតកុកទីងដៃស្រាប់ ក៏ស្ទុះហៅទៅដេញកាប់កូនតាមពាក្យប្រពន្ធ តែដេញមិនទាន់ គ្រាន់តែប្រដាប់ចាប់ប្រកឹង ហើយក៏ដេរប្រទេចផ្ដាសាបណ្ដាយតាមក្រោយ ថែមទាំងស្រែកដង្ហោយហាមលែងឲ្យចូលមកជាន់ខ្ទមវិញ ។ ឯកូននោះ ស្ទុះដាក់មេដាយ បាតជើងសព្រាត វាយកែងជូនអាឪទាំងអគ្រោគ្រ ប្រុចចូលព្រៃព្រោក ទៅពួនក្នុងព្រៃគុម្ពោតមួយមិនឆ្ងាយពីខ្ទម ។ ដឹងថាកូនបោលចូលព្រៃបាត់ហើយ ឪក៏រអ៊ូទាំថា "ម៉េះហើយលែងឪលែងកូន, ចាប់ពីថ្ងៃនេះទៅ អញកាត់កាល់លែងដឹងលែងឮ លែងស្គាល់អា ជាកូនអញហើយ, កាត់អាឯងមួយចោលវាទឹងទៅជាអី, ឲ្យតែអាប៉ឹមមកវិញ ច្បាស់ជាពុះក្បាលជាដើងភ្លៃកទឹងកាំបិតកុកនេះហើយអា មិនដែលមាន កូនអីក៏ចង្រៃអប្បលក្ខណ៍ដល់ម៉្លេះ, ឯងឲ្យវានៅចាំខ្ទម មើលប្អូន ហេតុអីក៏វានាំគ្នាស្មោគ្រផ្អើងស៊ី, តាំងពីម្ដាយបង្កើតអញមក មិនដែលឃើញអាណាស៊ីផ្អើងស្មោគ្រដូចអានេះទេ, នេះហៅចង្រៃម្ដង ! " ។

លុះការចលាចលនេះ បាត់ស្ងាត់ទៅ, ម្ដាយ ក៏ចូលទៅដើងក្រាន

លានផ្ទាំងស្អាតបាត ដាក់ដំឡូងស្ងោរ, ឆ្អិនហើយ ដាស់កូនតូច និង ហៅប្តី ឲ្យអាស្រ័យ ហើយនិយាយពីរឿង ដែលកន្លងទៅថ្មី ៗ នោះ បណ្តើរផង ។

ឯកុមារដែលត្រូវគេបណ្តេញនោះ សូម្បីអធ្រាត្រស្ងាត់ឈឹង ដឹងថាឪពុកម្តាយដេកលក់អស់ហើយ ក៏ឥតហ៊ានចូលមកខ្ទមវិញទេ ដោយគិតថា "ឪពុកម្តាយខឹងខ្លាំងម៉្លេះហើយ បើខំតែជំនះចូលទៅ មុខជានឹងត្រូវដាច់កស្លាប់មិនខាន , រកគ្រាន់តែហ៊ានលបចេញពីគុម្ពោតព្រៃមក ហើយដើរទៅកាន់កន្លែងដែលធ្លាប់ចាក់ចោលសំបកដំឡូង, ដល់ហើយ ក៏ជ្រាវញែករករើសកំទេចសាច់ដំឡូង ដែលសេសសល់ជាប់នឹងសំបកបន្តិច ៗ នោះស៊ី, លុះជ្រាវចុះឡើង ៗ ទៅ ក៏ប្រទះឃើញកាំបិតស្នា ១ ដែលឪពុកម្តាយរកចិតដំឡូង ហើយភ្លេច ក៏យកទៅចោលជាមួយនឹងសំបកដំឡូង ។ រករើសបានកាំបិតស្នាហើយ គិតថា នឹងចូលទៅខ្ទមវិញ, ប៉ុន្តែលុះនឹកសព្វទៅ បែរជាមិនហ៊ាន ទើបប្តេជ្ញាក្នុងចិត្តឯងថា "បើទុកជានៅតែទៅទៀតក៏លែងកើតហើយ" ទើបដាច់ចិត្តដើរផ្សងព្រេងចេញពីទីនោះទៅទាំងយប់, ដើរឆ្កាត់កាត់គ្រោតកាត់ទ្រាំង កាត់ព្រៃល្បោះ មិនប្រាកដជានឹងទៅទិសទីណា គួរឲ្យអនិច្ចាពន់ពេក ។ ដើរពេញមួយយប់មួយថ្ងៃ ក៏បានដល់ទៅព្រៃធំមាត់បឹងមួយ ចួនជាពេលព្រលប់ហើយ ក៏សម្រេចចិត្តថា ត្រូវ

សំចតនៅទីនោះមួយរាត្រីសិន ចាំព្រឹកស្អែក សឹមគិតបន្តដំណើរទៅមុខទៀត, វាចូលទៅជ្រកក្រោមដើមជ្រៃ១ដើម បម្រុងនឹងឡើងដេកលើដើមឈើនោះ ។ មួយថ្ងៃនេះមកហើយ គ្មានអាហារមួយគ្រាប់កង់ពោះសោះ ពេលក៏ព្រលប់ទៅហើយ ទឹងគិតរកអ្វីស៊ីក៏ពុំបាន ទើបបេះស្លឹកឈើស៊ីជាអាហារបណ្ដោះអាសន្ន រួចបោចវល្លិចងប្រទាក់ធ្វើជាអង្រឹងដេក ។ ដេកបណ្ដើរគិតបណ្ដើរ ដំណើររស់បន្តទៅមុខ, ចួនជាពេលក្អែកទៅឃើញពន្លឺភ្លើងមួយកន្លែង គឺជាភ្លើងឆេះព្រៃក្បែរមាត់បឹងធំ វាប្រឹងសំគាល់ចំណាំទុក ចាំស្អែកនឹងទៅយកភ្លើងនោះប្រើប្រាស់តាមដែលវានឹងមានសេចក្ដីត្រូវការ ។ មួយយប់នោះកន្លងទៅ កុមារដេកលក់ខ្លះភ្ញាក់ខ្លះ បៀមជាប់នូវសេចក្ដីទុក្ខព្រួយ លាយឡំដោយសេចក្ដីព្រឺរោមព្រឺស្បែក ខ្លាចខ្លាចបិសាចនិងសត្វសាហាវផ្សេង ៗ ដែលឮសូរតែសម្លេងសត្វព្រៃបរយំស្រែកនាំឲ្យព្រឺក្បាលខ្នក ។, យូរ ៗ ឮហ្វូងដំរីព្រៃបញ្ចេញសម្រែក អ៊ឺ រ៉េម រ៉ូម ចុះកាលឮសម្លេងខ្លាស្រ្គឹត ប៊ឹប ប៊ឹប ប៊ឹប ប៉ើរ ។ ឬក៏ឮផ្គរសម្លេង ឆ៉ារ ឆ៉ារ ស្ដាប់ៗទៅគួរឲ្យច្រឡំនឹងសម្រែក ប្រើសក្ដាន់ ឬឆ្កែស្រុក ។ តាំងពីក្បាលល្ងាចមក គេបន់ឲ្យតែភ្លឺឆាប់ ៗ

លុះភ្លឺច្បាស់ស្រឡះមេឃហើយ ទើបវាហ៊ានចុះដី, វាឃើញលលក ៤-៥ ដាច់ក្បាលបាត់ ធ្លាក់នៅក្រោមដើមជ្រៃធំនោះ វាទឹកអរព្រួយ

ក៏រើសយកលលកនោះបោចរោមចេញ រះទៅប្រទះឃើញស្រូវប្រហែល ១ ពែងចក ក្នុងគែលលកមួយ ៗ ក៏មានគំនិតថ្មីមួយកើតឡើងភ្លាមថា " តំណតទៅ អញនឹងសន្សំស្រូវពីគែលលកឲ្យបានច្រើន អញនឹងបានស៊ីខ្លះ ទុកធ្វើពូជខ្លះ " ។ រួចក៏វាយួរលលកដើរសំដៅទៅកន្លែងដែលបានឃើញភ្លើង ទៅប្រទះនឹងគល់គ្រាក់ដែលកំពុងឆេះយ៉ាងរង្គំ, វាអរណាស់ហាក់ដូចជាបានកើតសាជាថ្មី ព្រោះស្មានថាខ្លួនវាត្រូវស្លាប់ដោយដាច់ពោះ តែមានក័ព្វ គ្រឡប់ជាបានស្រូវបន្តិច លលក ៤-៥ ព្រមទាំងភ្លើង និងទឹកផងទៀត ហើយក៏តាំងអាំងលលកនោះស៊ីទៅ, ស៊ីរួចក៏ចុះទៅឯបឹងរកទឹកផឹក-ងូត បានប្រទះនឹងឈូក ក៏បេះផ្លែឈូក ដកក្រទុំឈូកស៊ីទៀត រឹតតែមានកម្លាំងស្រួលខ្លួន, ឡើងពីបឹងមកវិញ ចូលទៅជ្រកដេកក្រោមម្លប់ឈើ ១ ដើម យកដៃគងថ្ពាសជញ្ជឹងរំពឹងគិត ក៏បែកគំនិតគិតឃើញថា " ត្រូវធ្វើស្នាមួយ ដើម្បីបាញ់លលកឲ្យបានច្រើន យកសាច់ស៊ីផង យកស្រូវទុកស៊ីខ្លះ និងទុកធ្វើជាពូជខ្លះផង ", គិតស្រេច ក៏ចាប់ធ្វើស្នាមួយ បានកូនកាំបិតស្នាតូចមួយនោះហើយ គ្រាន់នឹងឆ្កឹះឆ្កៀលឆ្វៀលធ្វើ, កើតបានជាស្នាស្រេចកាលណាហើយ ក៏ដើរបាញ់លលកតទៅ ។

និយាយពីឪពុកម្តាយនិងកូនតូចនោះវិញ, កាលបើវេលាកន្លងទៅអស់មួយរាត្រីហើយ ព្រឹកព្រាងស្វាងព្រះសុរិយាឡើង, ថ្ងៃនេះ គ្រួសារនេះ

មិនចេញទៅព្រៃដូចសព្វដងទៀតទេ ព្រោះអាហាររបស់គេ មានល្មមនឹងអាស្រ័យបានពីរបីថ្ងៃទៅមុខទើបត្រូវអស់, ព្រឹកនោះ ម្ដាយស្ងោរដំឡូងស្រំនិងមើមឈើផ្សេង ៗ ល្មមតែមាត់ ៣ នាក់, ឆ្អិនហើយក៏នាំគ្នាអាស្រ័យ, ប៉ុន្តែកូនតូចនោះស៊ីបានបន្តិចទៅ ក៏ឈប់ស៊ី ហើយយំរុកទាររកធ្មឹងស៊ីវិញ ព្រោះវាញ៉ាំមធ្លាប់បានធ្មឹងស៊ីឆ្ងាញ់ពីម្សិលមិញ, ទោះម្ដាយឪពុកលួងយ៉ាងណា ក៏វាឥតស្ដាប់ ពឹតតែពីយំ, ទើបម្ដាយឪពុកដាច់ចិត្តទៅយកអង្ករដែលហៅថាធ្មឹងនោះ មកស្ងោរឲ្យស៊ីដកបដល់ឆ្អែត ទើបវាបាត់យំ, ឯម្ដាយឪពុក ដោយចង់ដឹង ក៏យកអង្ករស្ងោរបរិភោគលមើលផង ឃើញថា មានឱជារសមែន ទើបបបួលគ្នាទៅកើបយកមកទុកស៊ីតទៅ ហើយនិយាយនឹងប្ដីប្រពន្ធថា " ម៉ែវាអើយ ! យើងខុសហើយឯង, កូនយើងមិនដឹងជាវាទៅដល់ណាហើយទេ អញស្ដាយកូនណាស់, គិត ៗ ទៅកូនយើង វាគ្មានកំហុសអ្វីសោះទេណាម៉ែវា ! បើដូច្នេះ យើងគិតដូចម្ដេចនឹងរកកូនឃើញវិញ ? " ។ ប្រពន្ធក៏ដេញប្ដីឲ្យប្រញាប់ទៅតាមរក, តែជាការឥតអំពើ ព្រោះកូននោះចេញទៅឆ្ងាយណាស់ទៅហើយ ។

មួយអាទិត្យក្រោយមក កុមារដើរទេសនោះ បាញ់លលកយកស្រូវបានប្រហែល ១ តៅ ហាលថ្ងៃឲ្យស្ងួតល្អស្រេច យកបន្តិចមកអង្រុយបកសំបកចេញ បានជាអង្ករសម្រួចប្រហែលមួយកូនតាន ហើយដក់នឹងថ្ក

យកទៅត្រាំទឹកឲ្យសើមសព្វ រួចយកមកដីកកប់ក្នុងដី យកក្ទេងគរដុតពីលើ, មិនយូរប៉ុន្មាន ក៏បានជាបាយយកមកស៊ីជាមួយនឹងសាច់លលកអាំង, វាគ្មានអំបិលប្រឡាក់សាច់ទេ វាតែងប្រឡាក់សាច់នឹងផេះដើម្បីឲ្យប្រៃ ៗ លុះស៊ីសាច់លលកពល់ថ្ងៃពេកទៅ ក៏ណាយលែងចង់ស៊ី នាំឲ្យមានគំនិតថ្មីមួយទៀតកើតឡើង វាក៏ចាប់ផ្ដើមបោចវល្លិពុះឫស្សី ធ្វើលបយកទៅដាក់ឯបឹងយកត្រី, បើកាលណាវាចង់ស្ងោរត្រីឬដាំបាយ វាដើររកកាត់យកឫស្សីណាដែលធំល្មម ហើយនៅស្រស់ផង ចំនួនមួយសាច់ ទុកប្លាំងម្ខាងធ្វើជាបាតបំពង់ ហើយខាងក្រោមថ្នាំងនេះ វាទុកល្មមតែជមសម្រួចដោតភ្ជាប់នៅដីពង់ទ្រេតបន្តិចបាន ដែលអាចប្រើជំនួសឆ្នាំងមួយសំណើរ ៗ

ក្រោយមក រដូវដើមឆ្នាំក៏បានមកដល់, មានភ្លៀងធ្លាក់ល្មមគួរសម វាគិតនឹងរកកន្លែងដាំស្រូវ, ពេលរសៀលត្រជាក់ វាដើរទៅទិសខាងកើត ចប្រប់ករក ស្រាប់តែប្រទះឃើញដីប្រធេះមួយកន្លែង គួរយកជាចំការដាំស្រូវបាន ទើបតាំងចិត្តថា នឹងលែងទៅណាពីទីនោះទៀតហើយ នៅចំព្យាយាមធ្វើចំការស្រូវ ព្រោះមើលទៅ ឃើញមានទំនងល្អ ៗ ស្អែកឡើង វាចាប់ធ្វើកូនខ្ទមមួយ ប្រក់បិទបាំងដោយសំបកឈើ លើទីដីប្រធេះនោះ, បន្ទាប់មក យកពូជស្រូវទៅដាក់ពាយរង្វើល ៗ ពាសពេញទីចំការ ហើយមើលថែដេញចាបលលកមិនឲ្យចុះស៊ីគ្រាប់ស្រូវពូជ ៗ

រាល់ព្រឹក ក៏តែងទៅដងទឹកពីបឹងយកមកទុកផឹក, ពេលថ្ងៃ ទៀតដើរបាញ់លលក និងធ្វើអន្ទាក់ដាក់សត្វជាបន្តទៅទៀត ។ បន្តិចមក ស្រូវចំការក៏ដុះលូតលាស់គួរឲ្យពេញចិត្តណាស់ ។

និយាយពីហេតុចម្លែកម៉្យាង, ក្នុងចំការនោះ នៅទិសខាងលិចជៀងខាងត្បូងខ្ទម មានដំបូកធំមួយ ដីមានកំណប់ទ្រព្យដ៏ល្អជាច្រើន ដែលមនុស្សបុរាណបានយកទៅកប់ទុកមិនដឹងជាពីកាលណាមក ឥតមានអ្នកណាមួយដឹងសោះឡើយ ។

និយាយពីស្តេចខ្មោច ដែលនៅរក្សាកំណប់នោះ ក៏ចាត់ខ្មោចម្នាក់ឈ្មោះខ្មោចតូច ឲ្យមកនៅចាំរក្សា ទម្រាំមានម្ចាស់គេមកទទួលយក ទាំងបានប្រាប់ខ្មោចតូចថា ឯម្ចាស់គេនោះជាមនុស្សកំព្រា រស់នៅដោយសារបានស្រូវអំពីតៃលលក តាំងពីកើតមកគ្មានឈ្មោះទេ តែយើងឲ្យឈ្មោះថា "ចៅតៃលលក" ទុកឲ្យហើយទៅចុះ ហើយទំនាយទាយថាត្រូវបានសោយរាជ្យជាស្តេចផង, ឲ្យតែដល់កំណត់ គេនឹងមកក្នុងទីនេះហើយ ។ ខ្មោចតូច ទទួលបញ្ជាស្តេចខ្មោចហើយ ក៏មកនៅចាំកំណប់រង់ចាំមើលជាយូរយារណាស់ ពុំដែលបានប្រទះឃើញនរណាម្នាក់បានមកដល់សោះ, ទើបតែឃើញក្មេងចម្លែកម្នាក់នោះចូលមកដល់ ក៏ចេះតែតាមសំគាល់ ដើម្បីពិនិត្យឲ្យយល់គ្រប់ឥរិយាបថ លុះបន្តិចក្រោយមក

ទើបវាកាន់គត់កំណត់ថា «នេះឯងហើយដែលជា ទៅកែលលក» ក៏មានចិត្តក្តួចគិតគាណិតស្រឡាញ់ណាស់ ឲ្យតែឃើញគេទៅណា ក៏ទៅតាមផង, ប៉ុន្តែដោយគិតថា ខ្លួនជាខ្មោច ក៏ឥតហ៊ានបញ្ចេញរូបរាងដែលគួរឲ្យក្មេងនោះសង្ស័យឡើយ ព្រោះក្រែងគេខ្លាច គ្រាន់តែយកចិត្តទុកដាក់ជានិច្ចថា នឹងជួយទំនុកបម្រុង ថែរក្សា ផ្គាប់ផ្គល់បានសម្រេចប្រយោជន៍គ្រប់យ៉ាង ៗ ទៅកែលលកធ្វើការអ្វី ក៏មិនដែលកំបាំងនឹងក្អែកខ្មោចតូចនោះទាំងអស់ ៗ

យូរបន្តិចមកទៀត ដោយមានសេចក្តីស្រឡាញ់កាន់តែខ្លាំងឡើង ៗ ខ្មោចតូច នឹកចង់ឲ្យក្មេងនោះបានស្គាល់ខ្លួនព្រមទាំងគ្រួសារ ដើម្បីនឹងបានស្និទ្ធស្នាលជួយទំនុកបម្រុងគ្នាជិតដល់ទៅផង, ទើបនៅពេលមួយ យប់ស្ងាត់ ខ្មោចតូច ចេញពីដំបូកដើរទៅរកខ្ទមក្មេងនោះ, ដល់ហើយស្រែកហៅថា អីសម្លាញ់! ហើយយកដីមួយដុំបោះប្រាកទៅ ៗ ក្មេងនោះនឹកសង្ស័យណាស់ ក៏ចេញពីខ្ទមរកមើល គិតថា អ្នកអ៊ីចេះ! ពិនិត្យរកមើលក៏មិនឃើញសោះ ក៏ដើរក្រឡឹងខ្ទមរកមើលទៀត ទៅប្រទះឃើញរូបមួយសស្កុងនៅខាងក្រោយខ្ទម រូបក្លាយជាខ្មោចស្គុងវិញ ប្រហាក់ប្រហែលនឹងមនុស្សដែរ, វារឹតតែសង្ស័យខ្លាំងណាស់ ក្បាលវាក៏ព្រឺខ្លាក ៗ ហើយវាលាន់មាត់ថា យី: ខ្មោចលងហើយឬ?, ពេលនោះ លោកខែភ្លឺស្អុះដែរ

តែមើលដូចជាមិនច្បាស់ ក៏អង្គុយប្រហោង ទនក្បាលឲ្យទាបបន្តិច ប្រឹងពិនិត្យមើល ឃើញតែត្រឹមក្បាលដង្គត់ទៅលើ មិនឃើញជើងជាប់ដី, ក៏សួរថា :

– នរណា? គេនសួរ,

– យើង ខ្លាបឆ្លើយ,

- អ្នកហ៊ានប្ដូហៅខ្ញុំ ? សំនួរ,

– ហ៊ានហើយថាមិនហ៊ាន មាត់ឆ្លើយ,

– ចុះជាអ្នកណា ? សួរ,

– យើងជាសម្លាញ់នឹងអ្នកឯងណា ៖ ឆ្លើយ,

– ចុះមកពីណាមក? សួរ,

– មកអំពីក្បែរទ្វហ៊ាន ឆ្លើយ,

– ឈ្មោះអ្វី ? សួរ,

– ឈ្មោះតូច ឆ្លើយ,

– ខ្លាបទេឬ ? សួរ,

– ខ្លាបហើយថាមិនខ្លាប ឆ្លើយ,

– មកមានការអ្វី ចង់បានអ្វី ? សួរ,

– មកចង់ជួបនឹងសម្លាញ់ឯង គ្មានចង់បានអ្វីទេ សម្លាញ់កុំព្រួយ! ឆ្លើយ,

ក្មេងនោះថា ទេ! គ្មានសម្លាញ់អីទេ គ្នានៅក្នុងព្រៃតែម្នាក់ឯង គ្មានមិត្រ គ្មានសម្លាញ់អ្វីហ្នឹងផងទេ! កុំមកលេងគ្នាអី បន្តិចថាមិនប្រាប់ៗ ខ្មោចតូច ថា ម៉េចក៏និយាយអ៊ីចឹងសម្លាញ់ គ្នាខ្ញុំមករកជួបឯង គ្រាន់បានជាគ្នានិយាយលេង ម្តេចមិនព្រមទទួលស្គាល់គ្នាផង ឲ្យគ្នាសុំទៅជិតឯងផង កុំថាអីថាក៉ទ់ មិនមែនជានរណាទេ យើងនៅក្នុងទីនេះដែរៗ ថាហើយ ខ្មោចតូចក៏ដើរទើមៗចូលទៅ ដូចជាធ្លាប់ស្និទ្ធស្នាលណាស់មែនៗ ក្មេងដឹងជាក់ជាខ្មោចហើយ ប៉ុន្តែពេលវាចូលមកនោះ មិនមានបណ្តាលជាហេតុអ្វីប្លែក វាក៏បេះតែទ្រាំទាំងភ័យញ័រពោះបំផុតៗ ពេលនោះ ខ្មោចតូចយកដៃទៅដាក់លើស្មាវា, ដៃនោះ ត្រជាក់ស្រឹតដូចសម្រិទ្ធ ធូនកណ្តុក, វាខំយកដៃវាគះចេញ តែគះខុសៗ មិនប៉ះនឹងដៃអ្នកស្លាបសោះ ទើបវាងើបមើលទៅចំមុខ ឃើញភ្នែកប៉ុនៗពងមាន់លៀនត្លែ អណ្តាតចេញក្លិល មាត់ស្មេញចេញធ្មេញសព្រោត ប្រមុះកោងក្ងុក សក់ក្បាលគគ្រើងគ្រះបៀកកំប៉ុតៗ និយាយសម្លេងគួលគ្រលៗ ថា «កុំខ្លាចៗ គ្នាឯងទេ», មាណពយកដៃគះម្តងទៀត តែគះផុតៗ ក៏ស្ទុះចេញប្រុងដាក់មេធាយ, ប៉ុន្តែខ្មោចតូចចាប់ស្មាយ៉ាងជាប់មិនលែង ហើយប្រែខ្លួនពីរូបបម្លែកនោះ មកជារូបត្រឹមត្រូវស្អាតបាតវិញ និយាយថា « ដែលខ្ញុំមកនេះ មិនមែនមកឲ្យទោសទុក្ខភ័យក្តីអន្តរាយអ្វីដល់អ្នកទេ, មកនេះ មានបំណងនឹងចងស្ពានមេត្រីជាមិត្រនឹងគ្នា ចង់ជួយយកអាសាឲ្យអ្នកបានសុខចម្រើនទៅថ្ងៃមុខតែ

ម្យ៉ាងប៉ុណ្ណោះ ។ មាណពស្តាប់ដឹងរឿងសព្វគ្រប់ហើយ ទើបបាត់ខ្លាចបន្តិច ហើយចាប់និយាយគ្នាពីនេះពីនោះខ្លះៗ តែមិនទាន់ជាស្និទ្ធស្នាលនឹងគ្នាពិតប្រាកដទេ , លុះដល់យប់ជ្រៅ ខ្មោចតូចក៏លាចេញទៅ បានផ្តាំថានឹងមកលេងទៀត, គ្រាន់តែគ្រលៀសភ្នែកមិនទាន់ ក៏បាត់ភ្លាមទៅ ។

ពីរបីថ្ងៃក្រោយមក, តូច ទៅលេងនឹងមាណពក្មេងម្តងទៀត អង្គុយនិយាយគ្នាលេងបានបន្តិច ក៏និយាយបបួលថា "ព្រឹកស្អែកនេះ យើងចង់ឲ្យសម្លាញ់ទៅលេងផ្ទះយើងម្តង " ។ មាណពនិយាយថា " នែសម្លាញ់ ចុះអ្នកឯងប្រាប់ខ្ញុំថា ឯងជាខ្មោច, ឯខ្ញុំពុំទាន់ស្គាល់ខ្មោចពិតប្រាកដបាត់សង្ស័យសោះ តើធ្វើម្តេចខ្ញុំនឹងបានស្គាល់ច្បាស់តទៅផង, ហើយបើអ្នកឯងជាខ្មោចទេ ម្តេចក៏មានផ្ទះ ? ដែលថាឲ្យគ្នាទៅលេង តើទៅតាមផ្លូវណា នឹងរកផ្ទះអ្នកឃើញ?" ។ ខ្មោចតូចប្រាប់ថា "ដែលយើងនិយាយតាំងប៉ុន្មាន ពិតជាស្មោះត្រង់អស់ពីពោះពុងហើយ គ្មានកុហកអ្វីទេ, នែសម្លាញ់ ! ចូរឯងចាំស្តាប់ នឹងចាំមើលចុះ ដែលហៅថាខ្មោច ដូចជាខ្ញុំជាដើមនេះ មានលក្ខណៈប្លែក ៗ ឲ្យនឹងសំគាល់បាន ដូចតទៅនេះ :

- ខ្មោច គឺពីមុនក៏ជាមនុស្សដូចឯងនេះដែរ ហើយស្លាប់លះចោលរូប ចេញតែវិញ្ញាណ ដែលហៅថា វិញ្ញាណធាតុ រសាត់ទៅតាមយថាកម្មរបស់ខ្លួន គ្រាន់តែហាក់ដូចជារស់នៅដោយសេសកម្ម ចាំយកកំណើត មានរូបកាយមិនសូវប្រាកដ ។ (នៅមានត)

ល្បងសិក្សា

# ប្រវត្តិអក្សរសាស្ត្រខ្មែរ

ដោយ លាង ហាប់អាន

សាស្ត្រាចារ្យ នាយកពុទ្ធសាសនបណ្ឌិត្យ

(ស្រង់ពីមេរៀនវិជ្ជាស្ថានអប់រំខាងអក្សរសាស្ត្រ)

---

## អក្សរសាស្ត្រខ្មែរ

## ពីសម័យបុរាណ មកសម័យបច្ចុប្បន្ន

[ត]

លក្ខណៈទី ៦ អក្សរបែបសិលាចារឹក ព្រះគោកា, ក្នុង គ.ស. ១០៦៦;

លក្ខណៈទី៧ អក្សរបែបសិលាចារឹក បន្ទាយឆ្មារ ក្នុងសតវត្សទី ១២ ឬដើមសតវត្សទី ១៣ នៃ គ.ស.;

លក្ខណៈទី៨ អក្សរបែបសិលាចារឹក អង្គរវត្ត ក្នុងសតវត្សទី ១៣ នៃ គ.ស.;

លក្ខណៈទី ៩ អក្សរបែបមហាសិលាចារឹក អង្គរ, ក្នុងឆ្នាំ ១៧០២ នៃ គ.ស.;

លក្ខណៈទី ១០ អក្សរបែបបច្ចុប្បន្ននេះ ។

# តារាងបង្ហាញនូវគំរូអក្សរខ្មែរ

*(តាមការស្រាវជ្រាវ របស់លោក ហ្វ្រិក-ម៉ាស្ស៊ូ)*

## ក– អក្សរសាស្ត្រក្នុងសម័យកាលទី ១ (១)

*តាមអ្នកប្រាជ្ញ បស្ចិមប្រទេស មានលោក* Barth, *លោក* Bergaigne *លោក* Louis Finot, *លោក* Georges Cœdès, *យើងកត់សំគាល់បាននូវសិលាចារឹក ៤ កន្លែង ដែលទុកជាគោលនៃអក្សរសាស្ត្រ គឺ:*

ទី ១– សិលាចារឹក នៅ វ៉ូកាញ់ ខេត្តញ៉ាត្រាង យៀកណាមខាងត្បូង,

ទី ២– –និ– នៅ អ្នកតាដំបងដែក ខេត្តតាកែវ,

ទី ៣– –និ– នៅប្រាសាទប្រាំល្វែង ក្នុងដែនកូសាំងស៊ីន កម្ពុជាក្រោម ក្នុងស្រុក ទឹកខ្មៅ ខេត្តព្រៃកឬស្សី.

ទី ៤– –និ– នៅទន្លេបាទី ខេត្តតាកែវ ប្រាសាទតាព្រហ្ម,

## ខ– លក្ខណៈសិលាចារឹកក្នុងសម័យកាលទី ១.–

### ទី ១– សិលាចារឹកនៅវ៉ូកាញ់(២)

---

(១) សូមអាន Barth — Bergaigne, ISCC, No 191 — L. Finot, BEFEO, XX, II, 3; G.Coedès. IHQ, XVI, 484; — JIGS, IV, 117; — BEFEO,XXXI Pl និង ពុទ្ធសាសនា ២៥០០ ទំព័រ ៣៨ ។

(២) តាមការសិក្សា អត្ថាធិប្បាយរបស់ ព្រះមហាវីរិយៈ បណ្ឌិតោ ប៉ាង-ខាត់ ចុះក្នុង "ពុទ្ធសាសនា ២៥០០" ទំព័រ៩ដល់ ១១០ ។

## ក) ប្រភេទនិង លក្ខណៈ –

ជាសិលាចារឹកចាស់ជាងគេនៅដែនដីអាស៊ីភាគអគ្នេយ៍ ។ គេអាចប្រដូចអក្សរក្នុងសិលាចារឹកនេះទៅនឹងសិលាចារឹក រុទ្រទាម័ន = Rudra Dàman នៅគីរនារ Girnar ឬ សាតករណិ វាសិស្ឋិបុត្រ:= Satakarni Vàsisthiputra នៅកាន់ហេរី Kanheri ក្បែរទន្លេ គោទាវរី Godàvari និងទន្លេក្រិស្នា Krishnà ក្នុងប្រទេសឥណ្ឌាប៉ែកខាងត្បូង ។

សិលាចារឹកនេះ ថ្លែងពីព្រះបាទ ស្រីមារ: Cri Màra គឺព្រះបាទហ្វាន់ ចេ-ម័ន ទ្រង់ជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ។

សិលាចារឹកនេះ នាំឲ្យអ្នកប្រាជ្ញជាន់មុនប្រមូលថាជារបស់ចាម ពីព្រោះស្រុក វ៉ូកាញ់នេះ ពីដើមនៅក្នុងដែនដីចាមបុរាណ ។ លោក Louis Finot យល់ថា ស្រុក វ៉ូកាញ់ កាលពីអតីតជាដែនដីចំណុះរបស់ប្រទេសនគរភ្នំទេ ។

លោក Barth និង Bergaigne សន្និដ្ឋានថា សិលាចារឹកវ៉ូកាញ់ ទំនងកើតឡើងក្នុងត្រីស្តសតវត្ស ទី ៣ (ឬក្នុង សតវត្ស ទី២ ផងក៏ពុំដឹង) ។

## ១) អត្ថបទដើម .–

... ប្រជាន ... ប្រឋមវិជយ ... ណ្ណិមស្យាម ។ អាជ្ញាបិតំ

សទសិរាជវរេណ . . . រាជគណ . . . វាគ្មត៌ បិតុ ស្រីមារ: . . . រាជ

កុល . . ជ . . . ន ស្រីមារ . . . លោ . . ន កុលនន្ទនេន អាជ្ញាបិតំ

ស្វជន . . . ស . . . មទេ្យ វាក្យំ ប្រវាហិតករំ ករុណាបរេណ លោក-

ស្យាស្យ គតាគតិ វិ . . . ន សិង្ហា សនាទ្យា សីនេន បត្រេ ក្រាតំ

នាទ្ធ្រេក ស្វសមីករណេខេនត្ថបេក្ម យត៌ កិញ្ចិទ្រជតំ សុវណ៌្ណមបិ វា

សស្ថាវរញ្ជង្គមគោជ្ជាគារកេ . . . ធំ ប្រិយហិតេ សវ៌្វំ វិសួ្ឫ មយាតទេ

វំ មយានុជ្ញាតំ ករិស្សរបិ រាជភិរនុបន្ត្យំ វិចិតមស្តុ បរមេក្ឫត្ស្យ វី-

រស្យ . . . ។

## គ) សេចក្តីប្រែសម្រួល. -

. . . សេចក្តីករុណាចំពោះសព្វសត្វទាំងឡាយ . . . ប្រថមជ័យ ថ្ងៃពេញបុណ្ណមី(?) ព្រះរាជាទ្រង់បានប្រកាសក្នុងរាជសភាថា "ឱប្រជាជនក្រេបផឹកនូវទឹកអម្រឹត ពោលគឺព្រះរាជបន្ទូល ព្រះបាទ . . . ជាវង្សនៃព្រះបាទស្រីមារៈ ទ្រង់បានជាកិត្តិយសនៃរាជវង្សស្រីមារៈ ទ្រង់បានតាមគន្លងប្រពៃណីក្នុងពុទ្ធសាសនា គឺការធ្វើបុណ្យសុន្ទរទានដល់ជន ប្រកាសក្នុងកណ្តាលជំនុំជន នូវព្រះរាជបន្ទូល សូរសីហនាទ ជាប្រយោជន៍ដល់ប្រជាជនទាំងឡាយ ទ្រង់ជាករុណាទាំងពីរដ៏ប្រសើរទ្រង់ប្រថាប់លើសិង្ហាសនៈ (ព្រះរាជបល្ល័ង្កស្វេតច្ឆត្រ?) ហើយទ្រង់ឈ្វេងយល់នូវគតាគតិ គឺការអន្ទោលស្លាប់កើតនៃមនុស្សលោក ទើបត្រាស់ថា "កាល

បើកូនខ្ញុំក្តី បងប្អូនខ្ញុំក្តីមិនមែនអ្នកកន្ទៀតទេ បានសម្រេចបំណងខ្លួនហើយ (បានសោយកផ្សែតទៅ ?) ( ខ្ញុំសូមឲ្យបេក ) សម្បត្តិខ្ញុំទាំងអស់ ប្រាក់មាសសង្ហារិមត្ថិ អសង្ហារិមត្ថិ ទោះប្រើជាវត្ថុសម្រាប់ជាទីរកកាយទិន ជាប្រយោជន៍ដល់សត្វលោកទាំងឡាយ ។ នេះជាសេចក្តីបញ្ញារបស់ខ្ញុំ ។ សូមព្រះពជាទាំងឡាយនៅក្នុងអនាគត ប្រតិបត្តិតាមព្រះពជបញ្ញាខ្ញុំនេះ កុំបីខាន ។ ហើយចូរប្រឹក្សាជាមួយសេវកាមាត្យឈ្មោះវី . . . របស់ខ្ញុំ ។

ឃ) សិលាចារឹកនេះបញ្ជាក់ថា សម័យកាលរបស់ព្រះបាទស្រី-មារៈ កាន់ព្រះពុទ្ធសាសនា ។ ព្រះពជប្រកាសនេះបង្ហាញនូវការយកព្រះទ័យទុកដាក់របស់ព្រះពជា ចំពោះប្រយោជន៍សត្វលោក (គឺប្រជាពស្ត្រ) ទូទៅ ហើយធ្វើចិត្តឲ្យស្រាល ពាក់នូវមច្ឆរិយៈជាដើម ។

## ទី ២- សិលាចារឹកនៅអ្នកតាដំបងដែក(១)

សិលាចារឹកនេះនៅខេត្តតាកែវ ថ្លែងពីអគ្គមហេសីព្រះបាទកៅណ្ឌិន្យជយវរ្ម័ន នាមព្រះនាង កុលប្រភាវតី ទ្រង់ប្រាថ្នាចេញពាក់លោក ហើយបានកសាងទេវាល័យ តម្កល់បដិមាករ ព្រះវិស្ណុ ធ្វើពីមាសសុទ្ធ ព្រមទាំងលំនៅសំរាប់ព្រាហ្មណ៍និងស្រះ ។

(ព្រះនាងកុលប្រភាវតី ជាពជជនទីពជកុមារគុណវរ្ម័ន ។ ព្រះ

---

(១) យើងសុំមិនយកអក្សរដើមមកពន្យល់ប្រែទេ ព្រោះកុំឲ្យរមៀនវែងពេក ខុសគោលបំណងកម្មវិធី ។ សូមអានពុទ្ធសាសនា ២៥០០ ទំព័រ ៥២ ។

បាទកៅណ្ឌិន្យជយវរ្ម័ន ទ្រង់សោយទិវង្គតក្នុង ព.ស. ១០៥៧ ( គ.ស. ៥១៤ ) ។

## ទី ៣– សិលាចារឹកប្រាសាទប្រាំល្វែង(១)

សិលាចារឹកនេះនិយាយថា ព្រះរាជកុមារគុណវរ្ម័នរាជបុត្រនៃព្រះរាជា "ព្រះច័ន្ទនៃរាជវង្សកៅណ្ឌិន្យ" ទ្រង់ត្រាស់បញ្ជាឲ្យចារឹកទុកថា ទីនេះព្រះវរបិតាព្រះអង្គយកបានមកពី "ទីទឹកកក់" ហើយតែងតាំងទ្រង់ឲ្យគ្រប់គ្រង ។

## ទី ៤– សិលាចារឹកនៅទន្លេបាទី(២)

សិលាចារឹកនេះនៅប្រាសាទតាព្រហ្ម ទន្លេបាទី សរសេរក្នុងពុទ្ធសតវត្សទី ១១ (គ្រិស្តសតវត្សទី៦) និយាយថា ព្រះបាទរុទ្រវរ្ម័ន ជាព្រះរាជបុត្រព្រះបាទកៅណ្ឌិន្យជ័យវរ្ម័នទ្រង់កាន់ពុទ្ធសាសនា ហើយគោរពព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ។

ក្នុងរជ្ជកាលនៃព្រះបាទ រុទ្រវរ្ម័ន យើងមានព្រះបរមសារីរិកធាតុគឺព្រះកេសមួយសរសៃសម្រាប់ជាទីសក្ការៈបូជា តែព្រះចៅចិន រាជវង្សគៀ

(១) មើល "ពុទ្ធសាសនា ២៥០០" ទំព័រ ៩១ និង G. Cœdès, BEFEO XXX, p l ។

(២) មើល "ពុទ្ធសាសនា ២៥០០" ទំព័រ ៥៣ G. Cœdès, IEFEO, XXXI, p8 ។

(TSI) ខាងត្បូង មកយកបាត់ទៅ ។

៥– យោបល់រួម.–

តាមសេចក្ដីសង្កេតខាងលើនេះ យើងអាចសន្និដ្ឋានបានថា អក្សរ-សាស្ត្រខ្មែរ បានបដិសន្ធិនឹងមានរូបរាងជាឯកសារកត់ត្រានូវហេតុការណ៍ វប្បធម៌និងអរិយធម៌ខ្មែរ ប្រកបដោយលក្ខណៈ កស្តាំងពិតប្រាកដមក តាំងពីសតវត្សទី២នៃគ្រិស្តសករាជម៉្លេះ ។ តទៅ យើងនឹងលើកយក អក្សរសាស្ត្រសម័យកាលទី២មកពិនិត្យសិក្សាទៀត ។

# អត្ថបទវិជ្ជា នៃ អក្សរសាស្ត្រ
# សម័យកាលទី ២

## ឃ្លាភ្ជាប់សេចក្ដី.–

រួចមកហើយ ក្នុងមេរៀនទី១ យើងបានឃើញនូវលក្ខណៈសិលា-ចារឹកបួនកន្លែង គឺ :

សិលាចារឹក នៅវ៉ូកាញ់, នៅអ្នកតាដំបងដែក, នៅប្រាសាទប្រាំល្វែង និង នៅប្រាសាទតាព្រហ្ម ។

តទៅនេះ យើងនឹងពិនិត្យមើលអំពីអត្ថបទវិជ្ជា (វិជ្ជាសិក្សាអំពីអត្ថ-បទ) នៃសិលាចារឹកទាំងនោះ ដែលបិតនៅលើគោលសិក្សា ៣ យ៉ាង ដូចតទៅ :

## ១- អំពីអត្ថន័យនៃអត្ថបទសិលាចារឹក.–

បើយកអត្ថបទសិលាចារឹកនៅវ៉ូកាញមួយ មកពិនិត្យជាគោល, យើងឃើញថា គោលបំណងរបស់អ្នកតែងនឹងកត់ត្រាគឺលាតត្រដាងបង្ហាញនូវប្រវត្តិវិជ្ជា ស្តីអំពីព្រះមហាក្សត្រនៃសម័យកាលដែលទ្រង់សព្វព្រះរាជ-ហឫទ័យចំពោះជំនឿក្នុងពុទ្ធសាសនា ដូចជា ព្រះរាជប្រកាសរបស់ព្រះបាទស្រីមារៈដែលចែងអំពីការអន្ទោលកើតស្លាប់នៃមនុស្សលោក ។

គឺតាមរយៈគំនិត ពាក្យសំដី ជាព្រះរាជបណ្តាំផ្សេងៗរបស់សិលា-ចារឹកនេះហើយ ដែលជាសក្ខីភាពព្រមទាំងជាឯកសារបញ្ជាក់ថា ប្រ-ទេសនគរភ្នំកាន់ពុទ្ធសាសនា ។ ដោយសារសិលាចារឹកនេះទៀត ដែលយើងដឹងថាព្រះពុទ្ធសាសនាចូលមកប្រតិស្ឋាន នៅក្នុងប្រទេសកម្ពុជាយើងតាំងពីពុទ្ធសតវត្សទី ៣ ម្ល៉េះ ។ ប៉ុន្តែព្រះពុទ្ធសាសនានេះ មានឫសគល់រីកចំរើនខ្លាំង គឺក្នុងរជ្ជកាលព្រះបាទស្រីមារៈ គ្រិស្តសតវត្សទី ២ ។

សិលាចារឹកនៅអ្នកតាដំបងដែក បានបញ្ជាក់អំពីទឹកព្រះទ័យរបស់ព្រះមហាក្សត្រជឿជាក់ចំពោះគុណធម៌ នៃព្រហ្មញ្ញសាសនា ។ សិលា-

ចារឹកនេះបញ្ជាក់ថា ព្រះអគ្គមហេសីព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន នាមព្រះនាងកុលប្រភាវតី ដែលពេញព្រះទ័យចេញចាកលោក ក៏ទ្រង់បានសាងទេវាល័យដំកល់បដិមាករព្រះវិស្ណុ ធ្វើអំពីមាសសុទ្ធ ហើយព្រះនាងចាត់ឲ្យសាងលំនៅសម្រាប់ព្រាហ្មណ៍ ព្រមទាំងឲ្យជីកស្រះជាគុណប្រយោជន៍ចំពោះប្រជារាស្ត្រ ។

សិលាចារឹកនៅប្រាសាទប្រាំល្វែង បានបញ្ជាក់អំពីព្រះរាជបុត្ររបស់ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន និងព្រះនាងកុលប្រភាវតី ព្រះនាមព្រះរាជកុមារគុណវរ្ម័ន ដែលត្រូវបានព្រះរាជបិតាតែងតាំងទ្រង់ឲ្យត្រួតត្រា ស្រុកទឹកខ្មៅ ក្នុងខេត្តព្រែកឫស្សី ហៅ "ទីទឹកកក់" ក្នុងកម្ពុជាក្រោម ។

ឯសិលាចារឹកនៅប្រាសាទតាព្រហ្ម ទន្លេបាទី ក្នុងខេត្តតាកែវវិញ ក៏បានបញ្ជាក់ថា ព្រះបាទរុទ្រវរ្ម័នជាព្រះរាជបុត្រព្រះបាទ កៅណ្ឌិន្យជ័យវរ្ម័ន (រាជបុត្រអង្គនេះ មានមាតាជាព្រះស្នំរបស់ព្រះបាទកៅណ្ឌិន្យ បានធ្វើគតព្រះមកុដរាជកុមារនាម គុណវរ្ម័ន ហើយឡើងសោយរាជ្យក្នុង គ. ស. ៥១៤ នៅឆ្នាំដែលព្រះរាជបិតាទ្រង់សោយទិវង្គត) ទ្រង់កាន់ពុទ្ធសាសនាដែរ ។ ព្រះរាជាអង្គនេះ គោរពព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ។ សេចក្ដីសង្ខេបនៃការប្រែសិលាចារឹកនេះ គឺមានលំនាំដូចតទៅ : (១)

---

(១) ស្រង់ពីសេចក្ដីប្រែរបស់ព្រះតេជព្រះគុណ ប៉ាង-ខាត់ ក្នុងពុទ្ធសាសនា ២៥០០ ទំព័រ ៨៣-៨៤ ។

"ព្រះជិនស្រីទ្រង់ឈ្នះខ្មាំងសឹកសត្រូវ គោលគឺកិលេសព្រមទាំងវាសនា ទ្រង់ប្រកបដោយសម្បត្តិគ្រប់ប្រការ មានពោធិញ្ញាណឥតមើសតាល់ សល់ជំពាក់អ្វីឡើយ មានព្រះទ័យប្រកបដោយករុណាចំពោះសព្វសត្វ មានព្រះយសធំទូលំទូលាយ ឥតមានមោះមន្ទិលឡើយ ហើយផ្សាយទូ-ទៅគ្រប់ទិសានុទិស ។ ព្រះអង្គស្រោចស្រង់សត្វលិចលង់ក្នុងវាលវដ្ដសង្សារ គឺត្រៃភព ហើយបានដល់ត្រើយត្រាណឋានព្រះនិព្វានដ៏ឧត្តមឥតអ្វីប្រៀបបានឡើយ ។ ព្រះស្រីធាតុ (គឺព្រះបរមសារីរិកធាតុ) ព្រះអង្គដែលតែងតែផ្ដល់ប្រយោជន៍ធំដល់សព្វសត្វទាំងឡាយ ក៏នៅតែផ្ដល់ប្រយោជន៍ដល់សព្វសត្វលុះរហូតមកដល់សព្វថ្ងៃនេះ ... ។ អំពើជាព្រះរាជកុសលដែលទ្រង់ (ព្រះបាទវ្រះវ្រះវិទ្ធ) បានបំពេញចំពោះព្រះធម៌ហើយ មិនមែនដើម្បីតែព្រះរាជករណីយកិច្ចប៉ុណ្ណោះទេ គឺទ្រង់បំពេញ ដើម្បីអនុគ្រោះដល់លោកទាំងមូលផង ។ ទ្រង់គោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទ្រង់បានតាំងព្រះអង្គពេញជាឧបាសក ដែលឥតមានអំពើបាបលាមក ... " ។

សារុបសេចក្ដីទៅ គឺក្នុងរជ្ជកាលព្រះកៅណ្ឌិន្យជ័យវរ្ម័នទី២ព្រះបាទវ្រះវរ្ម័ន ព្រះពុទ្ធសាសនា ចំរើនថ្កុះថ្កាលខ្លាំងណាស់ ។

គឺដោយសារសិលាចារឹកទាំងឡាយនេះហើយ ដែលបញ្ជាក់អំពីសន្ទុះនៃពុទ្ធសាសនា និង ការគោរពសរណត្រ័យ សំរាប់ជាគ្រឿងសក្ការ:

បូជា ។ អ្នកសិក្សាខាងសិល្បៈ បានរកឃើញនូវពុទ្ធរូបសម័យនគរភ្នំ ដែលចេនាអំពីថ្ម សំរិទ្ធនិងឈើ ។ សំណាកនៃពុទ្ធរូបទាំងឡាយក្នុងសម័យនេះ មាននៅកំពង់ ក្នុងស្រុកអង្គរបូរី ខេត្តតាកែវ ដែលមានក្បាច់ចេនាតាមខ្មែរ ដោយយកបែបពុទ្ធរូបនៅឥណ្ឌាជាគោលខ្លះ គឺតាមបែបអមរាវតី គុប្តៈ គន្ធារៈ មថុរា ឬ អជន្តា ជាដើម ។

## ២- អំពីអក្សរបនៃអត្ថបទសិលាចារឹកៈ

ពិតមែនតែក្នុងសម័យកាលទី ១ នេះ ព្រះពុទ្ធសាសនាខាងថេរវាទចំរើនរុងរឿងណាស់ក៏ដោយ ក៏អ្នកនិពន្ធកត់ត្រាសិលាចារឹកពេលនោះនៅតែរក្សាពាក្យពេចន៍សំស្ក្រឹតជាច្រើនសំរាប់សរសេរ ។ បុព្វហេតុនេះគឺមកអំពីអាទ្យធម៌ និងវប្បធម៌ បែបព្រាហ្មណ៍សាសនា (ដូចជារឿងព្រះឥសូរ និងព្រះវិស្ណុ) នៅមានបំរាយឥទ្ធិពលខ្លាំងក្លានៅឡើយ ។

ឧទាហរណ៍.—

សិលាចារឹកនៅវ៉ូកាញ់ សរសេរថា ៖

"ប្រជាធំ.. ប្រថមវិន័យ.. ណ្ដិមស្យាម ។ រាគម្ពីរបិពន្ធស្រីមារ.."

ក្នុងវិធីតែងអត្ថបទ គេមានៈ

១- សេចក្ដីផ្ដើមៈ ដែលបញ្ជាក់នូវពេលវេលា គឺ :

(មានត)

# រឿងសាមកុក

ទកញាវិបុលភដសេនា

ឆ្នូ-កាន

ប្រែ-រៀបរៀង

( គ )

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកវាងវៃឆ្លាតបើបានអាន |
| នឹងចេះទាយកលចំណាន | ទាំងមានសន្តានស្នេហាជាតិ |

យូរ-អ៊ុន

មុខជាខូចខ្ចីពុំខានទេ យើងទាំងឡាយគួរតែបបួលគ្នាគិតសម្លាប់អាចៅស៊ូយិន និងបីហាង២នាក់នេះចេញ ហើយកាត់យកក្បាលវាទៅថ្វាយព្រះចៅទៀវពីនឹងមិនបានសេចក្ដីគាប់ប្រសើរទេឬ? ពួកទាហានទាំងពួងក៏យល់ឃើញព្រមគ្នាទើបថា បើដូច្នោះយើងចាំមើលកលការ បើបានឱកាសវេលាណានឹងនាំគ្នាសម្រេចវាចេញ ។

ឯបីហាងបានឮដូច្នោះក៏ភ័យណាស់ ស្រូតទៅប្រាប់ចៅស៊ូយិនថា ពួកទាហានវាគិតព្រមគ្នានឹងសម្លាប់យើងទាំង២នាក់ហើយ យើងនឹងមិននាំគ្នាស្លាប់បង់សៀតទេឬ ? បើដូច្នេះមានតែយើងគិតកែខ្លួនឲ្យបាន ព្រោះព្រះចៅទៀវពីលើកទ័ពមកគ្រានេះ ដោយទ្រង់ព្រះពិរោធក្រោធក្រៃពេកណាស់ ពីព្រោះក្លួជាងនិងម៉ាតុងជាគូសត្រូវ ឥឡូវក្លួចៀងស្លាប់ទៅហើយនៅតែម៉ាតុង យើងត្រូវនាំគ្នាកាត់យកក្បាលម៉ាតុងទៅថ្វាយព្រះចៅ

ទៀតពីឲ្យបានហើយសឹមយើងកែខ្លួនថា ព្រោះយើងធ្លាក់ខ្លួនទៅនៅក្នុង កណ្ដាប់ដៃគូចៀង ម៉ាតុង ហើយក៏ត្រូវតែធ្វើការតាមអំណាចគេៗ វាយយកបានស្រុកគេងដីវេលាណា អាជ្ញាសិទ្ធិនៅលើគេទាំងអស់ ឯខ្លួនយើងនឹងបានតាំងចិត្តនៅនឹងហូតទៅក៏ទេ គឺបន្តនៅចាំតែនឹងយកក្បាលគូចៀង និងម៉ាតុងប៉ុណ្ណោះ ទំរាំតែឱកាសបាន វេលានេះបានឱកាសហើយទើប កាត់ក្បាលនាំមកថ្វាយ ទោះបីយ៉ាងណាក៏គង់តែព្រះចៅឡៅពីនឹងពេញព្រះទ័យពុំខាន ពុំបានប្រកាន់ទោសយើងឡើយ ។

ប៉ៅស៊ីប៉េងមិនយល់តាមសោះ ដោះថា ព្រះចៅឡៅពីនោះ មានសតិបញ្ញាជ្រៅល្អិតឆ្ងាយទូលាយណាស់ គង់ជ្រាបថាយើងធ្វើការនោះកែខ្លួន សឹកប្រជួននឹងតាញ់ហើយទើបក្លែងកាត់យកក្បាលម៉ាតុងទៅថ្វាយ ព្រះចៅឡៅពីនឹងវាយប្រហារជីវិតយើងអសារឥតការ បើហាងថា ខ្ញុំយល់ឃើញថា មុខជាមិនមែនដូច្នោះទេ ព្រោះព្រះចៅឡៅពីនោះមានសតិ-បញ្ញាប្រាជ្ញាតែនឹងល្បួងយកចិត្តមនុស្សទៅធ្វើទាហានច្បាំងតទៅ ឯអា-តៅជាកូនឱរសព្រះចៅឡៅពីក៏ជាក្មួយខ្ញុំ នឹងមិនគិតយោគយល់ខ្លះទេឬ ទោះដូចម្ដេចក៏គង់តែយើងមិនស្លាប់ បើយើងមិនប្រញាប់គិតដូច្នេះទេ មុខជានឹងស្លាប់អសារ ប៉ៅស៊ីយិនក៏យល់ឃើញត្រូវទាំង ២ នាក់ក៏ប្រុងប្រៀបរៀបសេះទុកបំរុងការ លុះពេលកណ្ដាលអធ្រាត្រស្ងាត់ ក៏នាំគ្នាលបចូលទៅដល់ទីវំណាក ហើយកាត់យកក្បាលម៉ាតុងចងភ្ជាប់នឹងកែប

សេះ  រួចក៏នាំគ្នាឡើងជិះសេះបរនាំទាហានចេញទៅកាន់កងទ័ពព្រះចៅឡៅពី ។

ឯពួកទាហានយាមល្បាតព្រះចៅឡៅពី  ក៏ចូលទៅចាប់ខ្លួនបាន ហើយសួរថា  ខ្លួនអ្នកទាំង ២ នាក់នេះមកពីណា  ប៉ីហងនិងប៉ៅស៊ូយិនក៏ប្រាប់ថា  យើងខ្ញុំជាប័ក្ខពួកជាមួយគ្នានឹងម៉ាតុង  យើងខ្ញុំកាត់យកក្បាលម៉ាតុងមកថ្វាយព្រះចៅឡៅពី  ទាហានក៏នាំខ្លួនប៉ីហងនឹងប៉ៅស៊ូយិនចូលទៅទុកនៅខាងក្រៅទ្វារ ហើយក៏ចូលទៅទូលព្រះចៅឡៅពី ៗ បានស្តាប់ក៏ឲ្យហៅខ្លួនប៉ីហងនិងប៉ៅស៊ូយិនចូលទៅគាល់  ហើយប៉ីហងនិងប៉ៅស៊ូយិនក៏ចូលទៅដល់ផ្ទាល់ព្រះភ័ក្ត្រ  ទម្លាក់ក្បាលម៉ាតុងហើយក៏ក្រាបយ ទូលរឿងរ៉ាវតាមប្រព្រឹត្តិហេតុគ្រប់ប្រការ ។

ព្រះចៅឡៅពីទ្រង់ព្រះសណ្តាប់ក៏ខ្វល់ខ្វាំងណាស់ត្រាស់ថា  អញបានលើកកងទ័ពចេញពីស្រុកសែឈួនមកយូរណាស់ហើយ  ឯងពួនមុខលាក់ខ្លួននៅទីឯណា បានមិនមករកអញ · វេលានេះឯងឃើញថាកម្លាំងឯងប្រុងនឹងចាញ់អញជាប្រាកដ  ទើបក្លែងកាត់យកក្បាលអាម៉ាតុងមកជានុយបញ្ឆោតចិត្ត  បើអញនឹងចិញ្ចឹមឯងទុកឲ្យគង់ជីវិតក៏ឥតអំពើ  ដូចជាអញមិនអើពើស្រឡាញ់គួនអ៊ូសោះ អញក៏មិនដឹងនឹងយកមុខទៅទុកឯណា ត្រាស់ហើយក៏បង្គាប់គួនហ៊ិន ឲ្យតាំងគ្រឿងបូជានិងពលីការសែនឲ្យគួនអ៊ូ លុះតាំងគ្រឿងរួចហើយ  ព្រះចៅឡៅពីក៏យាងចុះពីលើកៅអីទៅចាប់

យកក្បាលម៉ាគុនលើកឡើងសែនឲ្យគុនអ៊ូ ហើយឲ្យគុនហ៊ុនផ្កាស់ទោអាវអាប៉ីហានទិងប៉ៅស៊ូយិនចងឲ្យក្រាបនៅមខគុគ្រឿងបូជា ហើយព្រះចៅឡៅពីកំទ្រប់ដាវអោពន្ទះ ហច់អាប៉ីហាន, ប៉ៅស៊ូយិន សែនឲ្យគុនអ៊ូ ហើយកាត់យកក្បាលឲ្យទាហានសួយកសាកសពទៅចោលបង់ ។

ទៀវប៉ៅឃើញដូច្នោះកំគិតអាណិតអនាថដល់បិតា ទើបក្រាបបង្គំទូលព្រះចៅឡៅពីយំហើយទូលថា អស់តាំងគេដែលបានធ្វើប្រទូស្តកាយគុនអ៊ូនោះ គុនហ៊ុនជាកូនបានសងសឹកជាជំនួសអស់ហើយ នៅឡើយតែពួកអាកំណាចដែលរាបផ្ដាចសម្លាប់បិតាទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំមិនទាន់បានសងសឹកជំនួសបិតាសោះ ។ ព្រះចៅឡៅពីទ្រង់ព្រះសណ្ដាប់ដូច្នោះ កំត្រាស់ប្រាប់ទៀវប៉ៅថា ចៅកុំគិតតូចចិត្តឡើយ យើងបានតាំងចិត្តរួចហើយថា ដែលមកធ្វើការទាំងនេះ ប្រាថ្នាទីងរំលាងបំផ្លាញស្រុកកាំងតាំងសងសឹកជួសបិតាចៅផង បើបានស្រុកកាំងតាំងហើយ យើងនឹងស៊ើបចាប់យកខ្លួនអា ៦ នាក់ ដែលរាប្រទូស្តកាយបិតាចៅនោះ មកសម្លាប់សែនឲ្យដូចគ្នា ទៀវប៉ៅបានឮព្រះរាជឱង្ការ កំមានចិត្តប្រិតាប្រាមោទ្យពន់ពេកណាស់ថ្វាយបង្គំលាចេញទៅ កាលព្រះចៅឡៅពីមានជ័យជំនះ គ្រានោះកិត្តិសព្ទកំខ្ទិរខ្ទារល្បីផ្សាយឮទៅក្នុងស្រុកកាំងតាំងអស់តាំងពួកពលទាហាន កំមានចិត្តនោះស្ញប់ស្ញែងរអែងខ្លាចអំណាចព្រះចៅឡៅពី ពន់ប្រមាណណាស់ ។

គ្រានោះហាន់គុងនិងជីវថាយដែលរក្សាបន្ទាយនៅនោះ លុះឃើញទាហានទាំងពួងរួញរាអោដៃ ក៏ចេះតែស្រដីថ្មមលោមចិត្តដោយគំនិតឧបាយ-ផ្សេងៗ នោះមានពួកល្បាតចូលទៅប្រាប់ថា ប៊ីហាងនិងប៉ៅស៊ូយិន ប្រទូស្តរាយម៉ាគុង លបកាត់ក្បាលម៉ាគុងទៅថ្វាយព្រះចៅឡាវពី ឮថាព្រះចៅឡាវពីសម្លាប់ប៊ីហាងនិងប៉ៅស៊ូយិនទៅទៀត ហាន់គុងនិងជីវថាយឮដូច្នោះក៏រឹតតែភ័យណាស់ ទើបចាត់ចែងទាហានឲ្យនៅរក្សាបន្ទាយ តាំងពីនាយក៏នាំគ្នាស្រូតរូតទៅស្រុកកាំងតាំង នាំយកសេចក្ដីដែលចុនគចំប្លាំងនោះទៅទូលព្រះចៅស៊ុនគួនឲ្យបានជ្រាបគ្រប់ប្រការ ។

ព្រះចៅស៊ុនគួនបានជ្រាបការណ៍ក៏មានព្រះទ័យតក់ស្លុតរន្ធត់ខ្លាចណាស់ ត្រាស់ឲ្យប្រជុំនាម៉ឺនមុខមន្ត្រីមកប្រឹក្សា ប៉ៅជិតទូលថា ព្រះចៅឡាវពីក្រោកខឹងតាំងលើកទ័ពមកគ្រានេះ ដើមកំហឹងនឹងឈ្មោះ ៧ នាក់ គឺក្លូចៀន, លីបង, ម៉ាគុង, ប៊ីហាង, ប៉ៅស៊ូយិន ទាំង ៥ នាក់នេះ ប្រទូស្តរាយនឹងគួនអ៊ូក៏ស្លាប់អស់ហើយ នៅតែហាមកៀងនិងទៀវគាត់ ២ នាក់ទៀត ដែលសម្លាប់ទៀវហ៊ុយហើយមកនៅក្នុងស្រុកយើង គួរតែយើងនឹងចាប់ខ្លួនអ្នកទាំង ២ នេះ ឲ្យបំរើឃុំនាំទៅជាមួយក្បាលទៀវហ៊ុយទៅថ្វាយវិញ ហើយត្រូវបង្វិលខ្លួននាងស៊ុនហ៊ូយិននឹងស្រុកកេងជីវឲ្យទៅគេវិញផង រួចត្រូវថ្វាយផ្កាមាសប្រាក់ សុំជាព្រះរាជមេត្រីដោយសេចក្ដីរាប់អានទឹងបានព្រួតគ្នាកំចាត់ចូភី មុខជាព្រះចៅឡាវពីនឹងថយ

ចំពាត្រឡប់ទៅវិញពុំខាន ។

ព្រះចៅស៊ិនគួនយល់ឃើញត្រូវ ទើបបង្គាប់ភ្នាក់ងារឲ្យធ្វើហិបឈើក្រអូបដាក់ក្បាលទៀវហ៊ុយ ហើយចាប់យកខ្លួនហាមកៀងនិងទៀវគាត់ដាក់ទ្រុងដែក ហើយចាត់ឲ្យធ្វើផ្កាមាស ប្រាក់ដាក់ជាគ្រឿងបណ្ណាការ តែងជាព្រះរាជសារជាសេចក្ដីមេត្រី តាមសំដីចៅដិតក្រាបទូលគ្រប់ប្រការ ឯនាងស៊ិនហ៊ួយយ៉ិននោះឲ្យទូលថាទឹងបញ្ជូនខ្លួនទៅថ្វាយជាក្រោយហើយ ឲ្យចៀប៉ែងជារាជទូតនាំសារនិងគ្រឿងបណ្ណាការ ទៅថ្វាយព្រះចៅឡៅតី ចៀប៉ែង ក៏ឃុំនាំខ្លួនមនុស្សទោសនិងសារ-បណ្ណាការចេញទៅតាមបង្គាប់ ។

ព្រះចៅឡៅតីក៏ឲ្យរៀបកងទ័ពទឹងលើកទៅ វាយយកស្រុកកាំងតាំង នៅមិនទាន់សម្រេច ទទួលមានទាហានល្បាតចូលទៅទូលថា មានបំរើពីស្រុកកាំងតាំងនាំសារ-បណ្ណាការនិងមនុស្សទោសមកថ្វាយ ព្រះចៅ-ឡៅតីមានព្រះទ័យត្រេកអរណាស់ ទះព្រះហស្តហើយស្រែកថាជាបុណ្យរបស់យើង បានជាទេពតាបណ្ដាលនាំអាសត្រូវឲ្យគេចាប់មកឲ្យយើងសងសឹក ហើយបង្គាប់ទៀវចៅឲ្យតែងគ្រឿងបូជានិងសែនព្រេនឲ្យទៀវហ៊ុយ ហើយបង្គាប់ឲ្យលើកហិបចូលមក នោះទាហានក៏លើកហិបនិងទ្រុងមនុស្សចូលទៅចំពោះមុខព្រះភក្ត្រ ព្រះចៅឡៅតីក៏ចុះពីលើកៅអីទៅបើកហិបលើកយកក្បាលទៀវហ៊ុយមកដាក់លើតុគ្រឿងបូជា ឃើញ

មុខទៀតហើយនៅស្រស់ដូចមនុស្សធម្មតា ព្រះចៅឡាពីក៏ទ្រង់មានព្រះទ័យអាណិតណាស់ ទ្រង់ព្រះកន្សែងសោកាទៀតហើយជាច្រើន ។

ឯទៀវប៉ៅនោះ លុះឃើញក្បាលបិតាក៏យំសោកា សេចក្ដីទឹងក្ដៅផ្សាក៏បណ្ដាលឲ្យឆួលឆេះឡើង ទឹងអត់សង្កត់ចាំព្រះចៅឡាពីត្រាស់បង្គាប់ពុំបាន ទៀវប៉ៅក៏ស្ទុះទៅចាប់កាន់ដាវ ហើយរត់ទៅហែកកន្ត្រាក់ទ្រូងដែកបែកបាក់អស់ ហូសទាញយកខ្លួនហាមគៀងទិងទៀវគាត់ចេញផុតពីទ្រូងមក ហើយយកដាវកាប់វះសាច់ផ្ដាច់ជាដុំតូចធំហើយលើកយកទៅសែនសពបិតា កាត់ចាំងសិរសាទៅដោតផ្កាល ព្រះចៅឡាពីក៏បណ្ដាលឲ្យក្ដៅក្នុងព្រះទ័យពន់ប្រមាណ មិនបានទុកសំបុត្រសារ ត្រាស់ថា យើងទឹងច្បាំងឲ្យត្រាតែល្អិតខ្ទេចស្រុកកាំងតាំងទៅជាផង់ធូលី នោះម៉ាលៀងទីប្រឹក្សាទូលថា ពួកអាកំណាចដែលវាបង្អាចប្រទុស្តក៏យគួនអ៊ូទៀវហ៊ុយតាំងប៉ុន្ទាន យើងក៏បានសងសឹកជំនួសវិញអស់រលីងហើយ ត្រានេះស៊ិនគួនប្រើចៀប៉េងឲ្យនាំសារទិងបណ្ណាការ ផ្កាមាស-ប្រាក់ មកថ្វាយជាចំណុះ ហើយសុំជូនខ្លួននាងស៊ិនហ៊ូយ៉ិនទិងស្រងកេងជីវថ្វាយវិញដូច្នោះ ដើម្បីទឹងសុំចងព្រះរាជមេត្រីជួយគ្នាកំចាត់ចោលទីនោះ ទ្រង់ទឹងប្រោសដូចម្ដេចទៅវិញ ។

ព្រះចៅឡាពីខ្ញាល់ខ្លាំងណាស់ត្រាស់ថា យើងព្យាបាទគ្នាទឹងស៊ិន

BIBLIOTHEQUE

គួននោះ ព្រោះបានចេញវាចាជាស័ត្យបដិញ្ញាណដល់គួនអ៊ូ , ទៀវហ៊ុយ ជាប្អូនយើងហើយ ពេលនេះគួនអ៊ូ ទៀវហ៊ុយស្លាប់ទៅ យើងនៅរស់ ហើយត្រឡប់ទៅស្មោះស្ម័គ្រមេត្រីទឹងស៊ុនគួនវិញនោះមិនបង់ពាក្យស័ត្យទេឬ ? យើងមិនស្តាប់នឹងច្បាំងសម្លាប់អាពួកស្រុកកាំងតាំងឲ្យបាន រួចសឹមយើងលើកទាហានទៅសង្កត់ចូកីទៀត ត្រាស់ដូច្នោះហើយបង្គាប់ឲ្យយកខ្លួនពជទូតទៅសម្លាប់ បណ្តានាម៉ឺនទិងទីប្រឹក្សាក៏នាំគ្នាទូលសុំជីវិតចៀប៉េង លុះប្រោសឲ្យហើយ ក៏លែងចៀប៉េងទៅ ចៀប៉េងក៏វិលទៅទូលព្រះចៅស៊ុនគួនថា ព្រះចៅឡេវពីមិនព្រមស្តាប់ទេ រួចថានឹងលើកទ័ពមកវាយស្រុកកាំងតាំងឲ្យបាន រួចសឹមទៅវាយយកស្រុកចោកីទៀត ហើយទូលតាមសេចក្តីដែលដឹងឃើញទាំងប៉ុន្មានថ្វាយព្រះចៅស៊ុនគួនស្តាប់គ្រប់ប្រការ ។

x x x

# ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត

ដែលមាននៅពុទ្ធសាសនបណ្ឌិត្យ

លោកញ៉ុក-ថែម រៀបរៀង

---

(ក)

បំណងជើង: "សាស្ត្រា បណ្ឌលសាសនា"

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាយ លំនាំទេសនា ។

ប្រភពរឿង: លទ្ធិពុទ្ធនិយម ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ១៥ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានចារចម្លង តាមច្បាប់សាស្ត្រាវត្តវេឡុការាម ចុះលេខ ១៣៧៨ ។

អត្ថបទផ្ដើម: ៙ នមត្ថុ រតនត្តយស្ស ។ ថាបើនឹងរាប់អានព្រះពុទ្ធសាសនា និងយកជាទីពឹងហើយ គួរសិក្សាឲ្យស្គាល់របស់បីប្រការ គឺព្រះពុទ្ធ ព្រះធម៌ ព្រះ

សង្ឃ ឲ្យស្គាល់ឲ្យជាក់ច្បាស់ ឲ្យស្គាល់គុណព្រះពុទ្ធអង្គ និងកប់អាននោះ មានប្រយោជន៍ដូចម្តេច ក៏គួរឲ្យស្គាល់ទុក្ខ វិស័យមនុស្សសព្វថ្ងៃ រមែងធ្វើបាបណាមកជាយច្រើន និងកប់អានព្រះពុទ្ធសាសនា រមែងប្រហែលទៅ មិនគិតអាន កាន់តែតាមមាតាបិតាខ្លួនប៉ុណ្ណោះ មិនស្គាល់ថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនោះដូចម្តេច គ្រាន់តែឮគេថា ព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ ល្អជាទីកប់អាន បានឮតែប៉ុណ្ណោះឯងហើយ ក៏ធ្វើបុណ្យឲ្យទាន មិនគិត មិនអានឲ្យដឹងច្បាស់ ថាបុណ្យនោះដូចម្តេច ៗ . . .

អត្ថបទបញ្ចប់: ត្បិតថា កុសល បើចេតនាក្លាក៏មានផលច្រើន បើចេតនាទន់ ក៏មានផលតិច បើសមាទានសីលហើយគួរត្រួតត្រារាំងមើលព្រឹកល្ងាច ទើបនឹងមានកុសលសព្វ ១ ថ្ងៃទៅ ៗ មួយទៀតនឹងបានដឹងថា សីលខ្លួនជាបរិសុទ្ធ ឬមិនបរិសុទ្ធបើឃើញមិនបរិសុទ្ធសៅហ្មងទៅ ព្រឹកឡើងនឹង

បានទៅសមាទានជាថ្មីវិញ កុំស្ងៀមព្រងើយនិង ជាមនុស្សទ្រុស្តសីល មិនល្អ និងអសារជីវិត កុំទុកចិត្តសេចក្ដីស្លាប់មិនបានទេ ។ កាលសមាទាននោះ ឲ្យសមាទាន នឹងភិក្ខុក៏បាន និង សាមណេរក៏បាន តែត្រូវដូចវិធីដែលសំដែង មកនេះ ទើបនឹងបានជាទីសមាទានដោយប្រពៃ ។ ចប់បណ្ណាលសាសនាតែប៉ុណ្ណេះ ។

x x x

បំណងដើម: "សាស្ត្រា ព្រះមាល័យទេវត្ថេរ(១)" ។

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យរាយ លំនាំទេសនា ។

ប្រភេទរឿង: ចលនាពុទ្ធនិយម ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ២៤ សន្លឹក ។ ឯក

---

(១) សាស្ត្រានេះ មានសំនួនវោហារ ប្រហែលនឹងគម្ពីរទសជាតកដែរ ប៉ុន្តែ សាស្ត្រាច្បាប់នេះ តក់ច្រើនណាស់ ទាំងបាលីទាំងសម្រាយ ។ គោលដៅ ជាពាក្យដាស់តឿនឲ្យខំធ្វើបុណ្យទាន រក្សាសីល តាមច្បាប់ពុទ្ធនិយម ទើបអាចបានកើតទាន់ព្រះស្រីអារ្យមេត្រី ដែលនឹងបានត្រាស់ ក្នុងអនាគតកាល នាភទ្ទកល្បយើងនេះ ។

សារនេះ បានចារចម្លងតាមច្បាប់វត្តវេឡុការាម
កាលពី គ.ស. ១៩៤៣ចុះលេខ ១.៣៧៨ ។

អត្ថបទផ្ដើម :

ៜ នមោតស្ស ។ អតីតេ តាម្ពបាណិយេ
ទីបេ មាលេយទេវត្ថេរោ នាមកម្ពុជគាមំ ឧបនិ
ស្សាយ រោហនជនបទេបដិវសតិ ។ កោ
សាធុពៅ ហៃសាធុសប្បុរសផងទាំងឡាយអើយ
នូវអ្នកណាមានចិត្តនោះ ព្រាសលែង មច្ឆរិយៈ
តាំង ៥ ប្រការនោះហើយ ក៏សូមឲ្យបានពាន់
ស្ដាប់ដំបូន្មានធម៌ទេសនា ដ៏ប្រសើរនោះ
ហើយ ។ . . . . . . .

អត្ថបទបញ្ចប់:

រីនាព្រះពោធិសត្វ បានផ្ដាំព្រះមហាថេរ នូវពាក្យ
ដូច្នោះហើយនៃ ទើបសំពះលា ព្រះមហាថេរ
នោះ ទៅពិភពតុសិត នាលំនៅនៃព្រះអង្គវិញ
ហោង ។ ទើបព្រះមហាថេរហោះចុះមក ឯ
មនុស្សលោកនាយនេះ ចូលទៅយកបិណ្ឌបាត
ឰដ៏ស្រុកកម្ពុជគ្រាម ហើយចាប់ដើមអំពីនោះ
ទៅគូវ ព្រះថេរៈយកពាក្យបណ្ដាំ សម្ដេចព្រះ
ស្រីអារ្យមេត្រីពោធិសត្វផ្ដាំថា អស់មនុស្សម្នា

មហាជនធន៍ទាំងឡាយ នៅឰដ៏ជម្ពូទ្វីបនោះ ។ រីអស់មនុស្សម្នាមហាជនផងទាំងឡាយ ឮពាក្យព្រះមហាថេរប្រាប់ដូច្នោះក្ដី ក៏មករណ្ដាប់អស់អំពើកុសលផលបុណ្យផងទាំងពួង ដូចបណ្ដាំព្រះស្រីអារ្យមេត្រីស្រីពោធិសត្វ អស់អ្នកទាំងអម្បាលណោះមិញ ជាសួរេចទូវប្រកាអម្បាលណោះហោង ។

x x x

បំណងជើង: "សាស្ត្រា បដិសន្ធិ"

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

លក្ខណៈឯកសារ: គ្មានបញ្ហាក់ ក្ដអត្ថបទ ។

របៀបនិពន្ធ: ពាក្យពេជ លំនាំទេសនា ។

ប្រភពរឿង: ប្រហែលស្រង់ចេញអំពីអភិធម្ម ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ១៤ សន្លឹក ឯកសារនេះ តាមច្បាប់សាស្ត្រាវត្តវេឡុការាមដែរ ការពី គ.ស.១៩៤៣ ចុះលេខសាស្ត្រា ១.៣៧៨ ។

អត្ថបទដើម: ៙ បញ្ចកបត្តុ ពេការ សំសន្តាកកកវេ ៗ និង
ពណ៌នាក្នុងសង្ខារលោក គឺរូបារូបជីវិតិន្ទ្រីយ ៗ
នោះមានខន្ធ ៥ ១ ៤ ខ្លះមានគតិ ៥ មានវិញ្ញាណ ១
កំណើត៤ ៗ ឯគតិ៥ នោះគឺអបាយ ១ មនុស្ស១
ទេវតា ១ រូបព្រហ្ម ១ អរូបព្រហ្ម ១ ៗ
វិញ្ញាណ ១ នោះគឺលោកិយវិបាកវិញ្ញាណ ៗ ឯ
លោកិយវិបាកវិញ្ញាណនោះមាន ២ គឺ សហេតុ-
វិញ្ញាណ ១ អហេតុកវិញ្ញាណ ...ៗលៗ...

អត្ថបទបញ្ចប់: បរិទយ្ហតិ នោះគឺបេះដូង សំពប់ស្រូបបាញ់
លោហិតដែលអប់ទេក្នុងសួតនោះឲ្យក្តៅឆ្អិនករជួ
កាយជាអាការចំរណិគ្គិ នោះឲ្យខ្យល់ឲ្យរបស់
ផ្សេង ៗ ដែលសួតឲ្យក្តៅស្រូបខ្យល់ដង្ហើមចូល
ទៅបានប្រមាណហើយ ក៏ឲ្យសេចក្តី ... ច្រើន
បេះដូងក៏តោងស្រូបលោហិត ដែលក្តៅក្នុងសួត
នោះ ទៅសព្វកាយ ដោយនាំរូបកាយឲ្យក្តៅ
កំរើកឡើង ទើបបានស្ងួតសួតក្រៀមក្រោះទៅ
ជាអាការ១ បរណាមគ្គិ នោះគឺបេះដូងស្រូប

ចាញ់លោហិត ដែលក្តៅទៅថ្មីៗ ក៏ទទួលទុក ឲ្យកើតទឹកប្រមាត់ ហើយក៏ហូរចូលក្នុងស្រោមប្រមាត់ សំកប់រំលាយអាហារ ឲ្យល្អិតទៅដូចទឹកអាចម៍ ជាអាការ១ចូលគ្នាជាតេជោធាតុ ៤ៗ សរុបបឋវីធាតុ ១៩ អាបោធាតុ ១២ វាយោ-ធាតុ ៦ តេជោធាតុ ៤ ៗ អស់សេចក្តី ក្នុងអាការរូបធម៌កើតឡើង ៤៣ ចប់តែប៉ុណ្ណោះ ៗ តាមព្រះបាលីសំដែងមក ៗ

x x x

បំណងជើង : "សាស្ត្រាអានិសង្សបង្គន់"

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យរាយ លំនាំទេសនា ។

ប្រភពរឿង : សំដែងពីអានិសង្សនៃការសង់បង្គន់ប្រគេនសង្ឃ ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ខ្សែ មាន ១២ សន្លឹក ។
ឯកសារនេះ ប្រហែលបានមកពីវត្តវេឡុការាម ដែរ ចុះលេខ ១.៣៧៨ ។

**អត្ថបទផ្តើម:**

៙ នមោតស្ស ។ អតីតេ កិរ បទុមុត្តរស្សភគ
វតោ កាលេ (ឯកោ ?) ជនពេគា ឧប្បជ្ជិ ។
ភិក្ខវេ ហៃព្រះភិក្ខុសង្ឃអង្គអរិយ សប្បុរសផង
ទាំងឡាយ ។ កិរ ដូចបានឮរៀងៗមក ។ អ
តីតេ កាលេ ឮដ៏កាលកពកន្ត ខណ្ឌកប្បកល្ប
ខាំងកំបាំងបាត់ ស្ងាត់កន្លងរំលងទៅហើយ ។

. . . . . ។ល។ . . . . .

**អត្ថបទបញ្ចប់**

ឥតិ ពេកុលសត្ថុ កថេសិ ។ ទេសនាបរិយោ
សានេពហូ សោតាបត្តិផលាទីនិ បាបុណិំសុ ។
សម្តេចព្រះទសពលញាណ មានព្រះតម្រាស់
ត្រាស់ព្រះធម៌វិសេសទេសនា ពាកុលជាតកទុក
ជាសណ្តាប់ប្រាប់អស់ភិក្ខុសង្ឃអង្គអរិយសប្បុ-
រស នូវអស់មហាជន ឧបាសកឧបាសិកា
កាលណាបើចប់ព្រះធម៌វិសេសទេសនាជាស្រេច
ហើយ ។ អស់អ្នកទាំងអម្បាលណោះ សឹង
បានលុះសោតាបត្តិផល តម្កល់ចិត្តខ្ជាប់ចាប់យក
និព្វានជាអារម្មណ៍នោះច្រើនក្រៃពេក ។

បពិត្រសាធុសប្បុរសផងទាំងឡាយអើយ
រីពណ៌នាសរសេរផលកាន់សង្ឃ នៃបុគ្គលក៏
បានធ្វើបង្គន់ ប្រគេនព្រះភិក្ខុសង្ឃនោះមិញ
ជាសូរេចនូវប្រការអម្បាលណោះឯងហោង ។

x x x

បំណងជើង: « សាស្ត្រា ឧណ្ហិសវិជ័យ(១) »

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យរាយ លំនាំទេសនា ។

ប្រភពរឿង: អំពីអានុភាព នៃពុទ្ធមន្ត ១ ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ខ្សែមាន ១៥ សន្លឹក ។ ឯកសារនេះ ប្រហែលពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តវេឡុការាមដែរ ចុះលេខឯកសារ ១.៣៧៨ ។

(១)– តាមបំណងជើង សាស្ត្រាស្លឹករឹត ដាក់ថា នេះសេចក្តីដីវិកាន ខ្វះបាននិយាយពីទេវ-បុត្រ ថ្វីឈ្មោះខ្វះទាំងពីរយ៉ាងនេះ មិនស្របនឹងឈ្មោះបំណងជើង ក្នុងផ្ទៃរឿង ព្រោះពេលបញ្ចប់អត្ថបទ អ្នកនិពន្ធដាក់ថា « ឧណ្ហិសវិជយោ និដ្ឋិតោ » ។ បំណងជើង ខាងលើនេះ ខ្ញុំបានកែតម្រូវតាម បំណងជើង ដែលអ្នកនិពន្ធបាន បញ្ជាក់ ខាងចុងអត្ថបទនេះ ។

**អត្ថបទផ្ដើម:** ៙ នមោតស្សភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឯកស្មឹ កិរ សមយេ ... ។ គោសាធក វិហសា ជុសប្បុរសផងទាំងឡាយអើយ ។ កិរ ដូចយើងបានឮរឿងៗមក ។ មានកាលសម័យថ្ងៃ ១ នោះ សត្ថា ព្រះដ៏ជាគ្រូវិសេសនៃយើង-ទាំងឡាយ ។

. . . . . . . . . . . . . . ។ល។ . .

**អត្ថបទបញ្ចប់:** ទេសនាវសានេ សោតាបត្តិផលាទីនិ បាបុណឹសុ ។ ឧណ្ហិសវិជយោ លុះសូរេចធម៌វិសេសទេសនារបស់ព្រះពុទ្ធជាម្ចាស់ នាមឈ្មោះហៅថាឧណ្ហិសវិជ័យនោះ ។ ព្រះឥន្ទ្រាធិរាជ នូវសុបតិដ្ឋគទេវបុត្រនូវអស់ទេវតាផងទាំងឡាយ បាន-ស្ដាប់នូវព្រះធម៌ព្រះពុទ្ធជាម្ចាស់ ហើយក៏មានចិត្តត្រេកអរសោទរសុខសប្បាយក្សេមក្សាន្ត បរិបូណ៌ តាមដោយគុណនៃព្រះពុទ្ធជាម្ចាស់ អ្នក-ខ្លះបានលុះសោតា អ្នកខ្លះបានលុះសកិទាគាអនាគាមី អរហត្ត តាមដោយកុសលនៃអត្តភាព

ទីទៃ ៗ នោះឯង ។ ខណ្ឌិសវិជៈ យោ សនិដ្ឋតោ ។
នោះយើងនឹងស្រដីខណ្ឌិសវិជ័យនេះមិញ ក៏ចូរ
ជាបច្ច័យនៃទាយក ឧបាសក ឧបាសិកា និដ្ឋិតា ។
ក៏ចប់បរិបូណ៌សមគួរដោយទូវប្រការទាំងអម្បាល
ណោះហោង ។

x x x

បំណងជើង: “ សាស្ត្រា សរសើរព្រះបាទ ធ្វេង-ស្តាំ ”

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ ( បទកាកគតិ ) ។

ប្រភពរឿង: ឥទ្ធិពលពុទ្ធនិយម ។

លក្ខណៈឯកសារ: សាស្ត្រា ១ ខ្សែ មាន ៦ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានថតការ
ចារចម្លង ប្រហែលបានច្បាប់អំពីវត្តវេឡុការាម
ដែរ លេខ ១ ៣៧៦ ។

អត្ថបទដើម: ៙ ឥតិបិសោគគរ់ ខ្ញុំនឹងពណ៌នា សរសើរព្រះ
បាទលាយលក្សណ៍កងចក្រ នៃព្រះនរនាថ

សាស្តាជនជាតិ ទ្រង់ទសពលញាណ ៗ ព្រះអង្គគន់គិត ដោយក្តីពិនិត្យ កាលស្តេចទឹងឈានចូលព្រះមហានគរនិព្វាន ហើយស្តេចទ្រង់ឈានទុកស្នាមបាទា ៗ . . . . . . . . . .

. . . . . . . . . . . . ៗលៗ . . .

**អត្ថបទបញ្ចប់:** កើតកបអម្បូរ អម្បាលត្រកូល ត្រកាលជាតីជាតិខត្តិយេ វិសេសធិបតី ធិបតិន្ទវិទ្ធិ វិទ្ធានុ-នុភាព ៗ សព្វសត្វគិរី ទាំងទសទិសទីព្រោះប្រុងប្រាណប្រាប កាន់កាំងកិតភ័យក្រែងក្រែក្រួញក្រាប រួញកវៀងកប រុងរឿងថ្កើងថ្កាន ៗ ប្រុះប្រោបធ្ងុះធ្ងាស់ សុះសព្វសិល្បសាស្ត្រ សឹងសុខក្សេមក្សាន្ត លង់លុះនិព្វាន គឺដោយសារបាន សូត្រសរសើរថ្កានព្រះពុទ្ធបាទនេះ ៗ

( ព្រះបាទខាងស្តាំ ) ៗ

---

(១) អត្ថបទនេះ មានក្បាំងភ្ជាត់ វិបត្តិជើងកាព្យច្រើនអន្លើ ។

# តុល្យការនៃសមិទ្ធិនានា
# របស់ វិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ

ចាប់ពីថ្ងៃ ១៣ មេសា ១៩៦៧ មកទល់នឹងថ្ងៃ ១៣ មេសា ១៩៦៨

យោង : សារាចរលេខ ៤០៦ CMISP ចុះថ្ងៃ ១២-៣-៦៨ របស់ទីស្តីការនាយករដ្ឋមន្ត្រី ។

១– ចំណូលបានមកពីការលក់សៀវភៅ :

ដើម្បីដាក់ថវិកាជាតិ មានសរុប : ១.៩៩៤.៨៨៥រ៧៥ ។

២– ផ្នែកបោះពុម្ពផ្សាយ :

ក- សៀវភៅនានាខាងផ្លូវលោក និង ផ្លូវធម៌ :

– បោះពុម្ពចំនួន ៦១ មុខ ផ្សេងៗគ្នា ។

– សរុបទាំងអស់ ៩០.៩០០ ក្បាល ។

ខ- គម្ពីរព្រះត្រៃបិដក :

– បានបោះពុម្ពថ្មីចំនួន ១០ មុខ (គឺ ១០ ភាគថ្មី ពីភាគ ៩១ ដល់ ១០០) ។

– សរុបចំនួនទាំងអស់ ១៥.០០០ ក្បាល ។

៣– ផ្នែកការផ្សាយវប្បធម៌ :

ក- សៀវភៅ និង គម្ពីរដែលបានបោះពុម្ពសម្រាប់ជាវជូនសាធារ-

ណជន ពីដើមមកដល់ខែមេសា មាន ៦០ មុខ "គិតទាំងគម្ពីរព្រះត្រៃបិដក ១០០ ភាគផង" ។

- គិតចំនួនក្បាលមាន ៩៩.២៥៩ ក្បាល ។

ខ- សៀវភៅធ្វើអំណោយដល់អង្គការនានា មានចំនួន ៧.៨២៦ ក្បាល គិតទាំងទស្សនាវដ្ដីកម្ពុជសុរិយាផង ។

៤- កិច្ចការនៃការិយាល័យ :

ក- ការិយាល័យក្រុមជំនុំព្រះត្រៃបិដក :

- បានផ្ទៀងផ្ទាត់ និង រៀបរៀងស្រេច នូវព្រះត្រៃបិដក ចំនួន ២០ ភាគ (១០ភាគ គឺពីភាគ ៩ ដល់ ១០០ បានបោះពុម្ពរួចហើយ នៅថ្ងៃ ៣១ ធ្នូ ១៩៦៧ឯចំនួន ១០ ភាគទៀត គឺពីភាគ ១០១ ដល់ ១១០ នឹងបោះពុម្ពក្នុងឆ្នាំ ១៩៦៨ ចាប់ពីខែ មេសា ទៅ) ។

ខ- ការិយាល័យបណ្ណាល័យ :

- បានទទួលសៀវភៅសម្រាប់តំកល់ទុក ក្នុងបណ្ណាល័យ ចំនួន ៦២៨ ក្បាល ។ សព្វថ្ងៃបណ្ណាល័យ មានសៀវភៅទាំងអស់ ចំនួន ៥២.៨៩០ ក្បាល ។

- មានអ្នកចូលមក អានស្រាវជ្រាវ ចំនួន ២.១៦០ នាក់ ។

- មានអ្នកចូលមកខ្ចីឯកសារយកទៅសិក្សាឯផ្ទះចំនួន ៦២៨ នាក់ ។

គ– ការិយាល័យធំនៀមទម្លាប់ :

បានទទួលឯកសារថ្មីសម្រាប់តំកល់ទុកជាសម្បត្តិជាតិមាន ១៣៩ មុខ ។ សព្វថ្ងៃការិយាល័យទំនៀមទម្លាប់ មានឯកសារទាំងអស់ ចំនួន ២.៩៣៧ មុខ ។

– មានអ្នកចូលមក អាន-ស្រាវជ្រាវឯកសារ ចំនួន ៨២៩ នាក់ ។

ឃ– កិច្ចប្រជុំការងារ :

– បានប្រជុំការងារក្នុងក្រសួង ដើម្បីដោះស្រាយបញ្ហាចាំបាច់ក្នុងក្រសួង ចំនួន ១៥ លើក ។

ភ្នំពេញ , ថ្ងៃទី ២១ មីនា ១៩៦៨

នាយកវិទ្យាឋានពុទ្ធសាសនបណ្ឌិត្យ,

ហត្ថលេខា : ឈាង-ហ៊ាបអាន

អគ្គនាយកដ្ឋាននៃក្រសួង ព្រះរាជអាណាចក្រកម្ពុជា
នានា ក្នុងព្រះបរមរាជវាំង

លេខ ២០១ លដ្ឋ

ភ្នំពេញ នៅថ្ងៃទី ២១ ខែមីនា គ.ស. ១៩៦៨

អ្នកអង្គម្ចាស់ អគ្គនាយកក្រសួងនានា នៃព្រះបរមរាជវាំង

ជំរាបមកសហជីវិន លាង ហាប់អាន នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

បាទជ្រាប ។

« តាមរយៈសហជីវិន អនុរដ្ឋលេខាធិការក្រសួងធម្មការ »

សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះរាជហឫទ័យសោមនស្សរីករាយជាទីបំផុត ដោយព្រះអង្គទ្រង់បានទទួលនូវតង្វាយ គម្ពីរព្រះត្រៃបិដក ១០ ភាគ និង សេចក្តីថ្វាយព្រះពរសព្ទគ្រប់ ក្នុងឆ្នាំនេះ ។

សម្តេចជាអម្ចាស់ ទ្រង់សព្វព្រះរាជហឫទ័យត្រាស់បង្គាប់ឲ្យខ្ញុំថ្លែង

នូវព្រះរាជអំណរគុណ  និងទ្រង់ព្រះរាជទានពរតបវិញ  សូមសហជីវិន ព្រមទាំងបុគ្គលិក ព្រះសង្ឃ និង គ្រហស្ថ ដែលនៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យទាំងអស់  បានប្រកបតែនឹងសេចក្ដីសុខ-ចំរើន គ្រប់ប្រការ កុំបីឃ្លាត ។

សូមសហជីវិន ទទួលនូវសេចក្ដីរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ព្រះហស្តលេខា: **នរោត្ដម - ភន្ទល**

៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤០ ខែ មីនា

ព.ស. ២៥១១ គ.ស. ១៩៦៨

-ភ្នំពេញ-

E FRANCAISE
F.744
BIBLIOTHEQUE
P.P.

៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
បេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

| អត្ថបទ | ផ្នែកសាសនា | ទំព័រ |
|---|---|---|


១– កបិនកថាសង្ខេប (ត) សម្ដេចព្រះពោធិវង្ស រៀបរៀង . . . . . ២៥១
២– រឿងមាតាព្រះកស្សបៈ (សហ. ប៊ូ-ប៊ូ ប្រែរៀបរៀង) . . . . . ២៦៦


ផ្នែកអក្សរសាស្ត្រ


៣– វចនានុក្រមសំស្ក្រឹត-ខ្មែរ (ព្រះមហា ប៉ាង.ខាត់) . . . . . ២៧៣
៤– ល្បងសិក្សា ប្រវត្តិអក្សរសាស្ត្រខ្មែរ (សហ. លាង.ហ៊ាបអាន) . . ២៧៧
៥– រឿងចៅតែលលក (ត) (សហ. ព្រួប-កុម រៀបរៀង) . . . . ២៨៨
៦– ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត (លោក ញ៉ុក.ថែម) . . . . ២៩៨
៧– ជីវប្រវត្តិ លោក ប៊ូ-ប៊ូ . . . . . . . . . . . ៣០៧
៨– រឿងសាមកុក (ត) (នាកញ៉ា គូ-កន) . . . . . . . . ៣១៧
៩– ការស្រាវជ្រាវ ប្រវត្តិលោកវិសេស ធូង (បណ្ឌិតមហា ឈឹម.ស៊ុម) . ៣២៩


ផ្នែកកំណត់-ប្រវត្តិការណ៍


១០– ទស្សនកិច្ចនៃសហជីវិនអនុវត្តលេខាធិការ ក្រសួងធម្មការ
នៅខេត្តកោះកុង (សហ. លី-ជាមតេង រៀបរៀង) . . . . ៣៤៥
១១– ពុតឃ្លាយថ្វាយពរឆ្នាំថ្មី . . . . . . . . . . . . ៣៥៦

## ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការលាមក, | ឲ្យធ្វើល្អទៅ, |
| ឲ្យដុសខាត់ចិត្ត | កុំឲ្យហ្មងសៅ, |
| បីនេះលោកហៅ | ពុទ្ធសាសនា ។ |

ប. ព.

# កឋិនកថាសង្ខេប

សម្តេចព្រះពោធិវង្ស ហួត-តាត រៀបរៀង

( ត )

ទី ១០– បរិភណ្ឌការណមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែលើកឡើង នូវអនុវាតខាងទទឹង ឬអនុវាតខាងពោះ ។

ទី ១១– ឱវទ្ធេយ្យការណមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែលើកបញ្ចូលផ្ទាំងសំពត់ថ្មី ពុំនោះគ្រាន់តែលើកផ្ទាំងសំពត់អំពីកឋិនចីវរ ១ ទៅដាក់បញ្ចូលក្នុងកឋិនចីវរឯទៀត ។

ទី ១២– កម្ពលមទ្ទនមត្តេន កិច្ចក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែដាក់ពុះក្នុងទឹកជ្រលក់១ដង មានពណ៌ដូចក្អកដីរ ឬស្លឹកឈើទុំលឿង ។

ទី ១៣– និមិត្តកតេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលបាន មកដោយសារធ្វើនិមិត្តកម្ម គឺនិយាយបញ្ចិតបញ្ចៀងថា "អាត្មានឹងក្រាលកឋិនដោយសំពត់បែបនេះ" ឬនិយាយថា "សំពត់សាដកនេះល្អ អាត្មាអាចនឹងក្រាលកឋិន ដោយសំពត់នេះបាន" ។

ទី ១៤– បរិកថាកតេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលកើតឡើង ដោយសារការនិយាយបញ្ចុះបញ្ចូលទាយកថា "ការប្រគេនសំពត់កឋិន ជាការគួរ ព្រោះទាយកអ្នកប្រគេនសំពត់កឋិន រមែងបានទទួលនូវផលបុណ្យដ៏ប្រសើរ" ។

អដ្ឋកថា ពន្យល់ថា ធម្មតាសំពត់កឋិន ទាល់តែឧក្រិដ្ឋណាស់ ទើបគួរ, ភិក្ខុនិយាយបញ្ចុះបញ្ចូល សូម្បីតែមាតារបស់ខ្លួន ក៏មិនគួរដែរ លុះតែសំពត់នោះប្រាកដដូចជាធ្លាក់ចុះមកពីអាកាស ទើបគួរ ។

ទី ១៥– កុក្កុកតេន ភិក្ខុក្រាលកឋិនដោយសំពត់ខ្ចីគេឬដោយសំពត់ដែលមិនមានទាយកនាំមកប្រគេន គឺសំពត់ស្វែងរកដោយខ្លួនឯង ។

ទី ១៦– សន្និធិកតេន ភិក្ខុក្រាលកឋិន ដោយសំពត់ដែលធ្វើឲ្យទៅជាសន្និធិ គឺទុកសំពត់នៅដៃសង្ឃ ឬនៅដៃនៃភិក្ខុអ្នកក្រាលឲ្យរំលងថ្ងៃ គឺមិនក្រាលឲ្យស្រេចក្នុងថ្ងៃនោះ ។

សន្និធិក្នុងអាការនេះមានពីរយ៉ាងគឺ ករណសន្និធិ ១ និចយសន្និធិ ១ ។ ការដែលភិក្ខុអ្នកក្រាលតំកល់សំពត់កឋិនទុក មិនធ្វើឲ្យ

ហើយក្នុងថ្ងៃនោះ ហៅថា ការណសន្និធិ ។ សង្ឃបានសំពត់កឋិនមកថ្ងៃនេះ ដល់ថ្ងៃស្អែកទើបប្រគល់ឲ្យទៅភិក្ខុអ្នកក្រាល ហៅថា និចយសន្និធិ ។

ទី១៧– និស្សគ្គិយេន ភិក្ខុក្រាលកឋិន ដោយចីវរជានិស្សគ្គិយៈ គឺចីវរកំពុងតែធ្វើទល់អរុណរះឡើង ឬចីវរដែលកន្លងរាត្រី ។

ទី ១៨- អកប្បកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនបានធ្វើពិន្ទុកប្បៈ ។

ទី ១៩– អញ្ញត្រ សង្ឃាដិយា ភិក្ខុក្រាលកឋិន ដោយសំពត់ក្រៅពីសង្ឃាដី មានសំពត់កម្រាលជាដើម ។

ទី២០– អញ្ញត្រ ឧត្តរាសង្គេន ឬភិក្ខុក្រាលកឋិន ដោយសំពត់ក្រៅពីឧត្តរាសង្គៈ មានសំពត់កម្រាលជាដើម ។

ទី ២១- អញ្ញត្រ អន្តរវាសកេន ឬភិក្ខុក្រាលកឋិន ដោយសំពត់ក្រៅពីអន្តរវាសកៈ មានសំពត់កម្រាលជាដើម ។

ទី ២២- អញ្ញត្រ បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន ភិក្ខុក្រាលកឋិនដោយចីវរក្រៅពីចីវរដែលបានកាត់ជាបញ្ចខណ្ឌ ឬ លើសពីបញ្ចខណ្ឌឡើងទៅ គឺសត្តខណ្ឌ, នវខណ្ឌ និង ឯកាទសខណ្ឌ ព្រមទាំងធ្វើឲ្យប្រកបដោយមណ្ឌល គឺមហាមណ្ឌល និងអឌ្ឍមណ្ឌល ក្នុងថ្ងៃនោះឯង បានសេចក្តីថា

ក្រាលកឋិនដោយចីវរមិនបានប្រកបដោយលក្ខណៈត្រឹមត្រូវ មានមិនបាន កាត់ជាបញ្ចខណ្ឌ ( ដែលមានកន្ទ្បង់ធំ ៥ មានកន្ទ្បង់តូច ៥ ) ជាដើម ។

ក្នុងអាការនេះ គម្ពីរអដ្ឋកថា ដីកា បានអធិប្បាយសេចក្ដីពិស្ដារ ដើម្បីឲ្យភិក្ខុសង្ឃងាយយល់ងាយប្រតិបត្តិតាម ដូចមានតទៅនេះ ៖

អដ្ឋកថាប្រាប់ថា ការក្រាលកឋិន ដោយចីវរដែលបានធ្វើឲ្យត្រឹមត្រូវ គឺបានកាត់ដាច់ជាបញ្ចខណ្ឌ ឬ អតិរេកបញ្ចខណ្ឌ សំដែងនូវមហាមណ្ឌល និងអឌ្ឍមណ្ឌល គឺកន្ទ្បង់ធំ និងកន្ទ្បង់តូច ឲ្យឃើញច្បាស់ទើបគួរ ។ មែនពិត, ចីវរដែលធ្វើយ៉ាងនេះ ឈ្មោះថា ធ្វើឲ្យប្រកបដោយមណ្ឌល បើភិក្ខុលើកលែងចីវរបែបនេះចេញ ហើយក្រាលដោយចីវរដទៃទៀត ដែលមិនបានកាត់សោះក្ដី កាត់តែត្រឹម ២ ខណ្ឌ, ៣ ខណ្ឌ, ៤ ខណ្ឌក្ដី មិនគួរទេ ។

គម្ពីរធម្មសម្ពោធិនីយ ថា[១] កឋិនចីវរ ដោយកំណត់យ៉ាងហោចបំផុត ក៏ត្រូវឲ្យបានកាត់ស្បង់មួយដែរ បើធ្វើខុសពីនេះ លោកថាត់ជាអន្តរាវបត្តិ គឺក្រាលខុសមិនបានឡើងជាកឋិនឡើយ ព្រោះហេតុនោះ ចីវរកឋិន បើមិនបានកាត់ដេរឲ្យត្រឹមត្រូវ (ដូចស្បង់លាត ឬ ចីពរខុសសង្ឃាដីខុសជាដើម ) មិនគួរទេ ។

---

១ សព្ពត្ថិមេន បរិច្ឆេទេន អន្តរវាសកោបិ ឆិន្ទិត្វា ន កាតព្វោ អញ្ញថា អន្តរាវិបត្តិ ហោតិ តេនេវ អច្ឆិន្នសិព្វិតំ បន កឋិនំ ន វដ្ដតិ ។

កង្គម្ពីរវជិរពុទ្ធិដីកាថា សំពត់កឋិន កាលបើសង្ឃសូត្រកម្មវាចា ប្រគល់ឲ្យដល់ភិក្ខុអ្នកក្រាលហើយ ភិក្ខុអ្នកក្រាលត្រូវតែកាត់ធ្វើឲ្យប្រកប ដោយមណ្ឌលត្រឹមត្រូវជាស្រេចក្នុងថ្ងៃនោះដែរ ។ ក៏ពាក្យដែលព្រះ សង្គាហកត្ថេរ ពោលទុកក្នុងគម្ពីរបរិវារៈថា “បុព្វករណៈ សង្គ្រោះដោយ ធម៌ ៧ ប្រការ” នោះ ចំពោះតែសំពត់ដែលសង្ឃប្រគល់ឲ្យមក នៅ ជាសំពត់ចំសុទ្ធ គឺសំពត់មិនទាន់ធ្វើជាចីវរនៅឡើយ មិនមែនចំពោះចីវរ ដែលទាយកវេរប្រគេនមក ដោយបានធ្វើរួចស្រេចមកហើយនោះទេ ។ ព្រោះហេតុនោះ បើទាយកវេរប្រគេន នូវចីវរដែលធ្វើបុព្វករណៈរួច ស្រេចមកហើយ សង្ឃត្រូវទទួលហើយសូត្រកម្មវាចា ប្រគល់ឲ្យទៅភិក្ខុ អ្នកក្រាលចុះ ។ ឯភិក្ខុអ្នកក្រាលនោះ ត្រូវអធិដ្ឋានក្រាលក្នុងមណ្ឌល សីមានោះហើយញ៉ាំងសង្ឃឲ្យអនុមោទនាចុះ ព្រោះមិនមានកិច្ចនឹងត្រូវ ធ្វើបុព្វករណៈ ដែលគេធ្វើរួចស្រេចមកហើយនោះថែមទៀតទេ ។ មែន ពិត, ព្រះពុទ្ធដីកានៃព្រះពុទ្ធជាម្ចាស់ដែលព្រះអង្គត្រាស់ថា “ក្រាល កឋិនដោយសំពត់ដែលគ្រាន់តែវាស់គូស គ្រិតស្ទង់មើលទទឹងបណ្តោយ ប៉ុណ្ណោះ មិនបានឡើងជាកឋិន” ជាដើមនោះ គឺសំដៅយកសំពត់ដែល មកដល់ដៃភិក្ខុអ្នកក្រាល នៅជាសំពត់ចំសុទ្ធ មិនទាន់ធ្វើជាចីវរនៅ ឡើយ ។

កង្គម្ពីរធម្មសមូហវិន័យ និងគម្ពីរនិបុណ្ណបទសង្គហៈ មានសេចក្តី

បញ្ជាក់រឿងនេះ ដោយធ្វើជាពាក្យបុច្ឆា - វិស្សជ្ជនាដូចតទៅនេះ ៖

ស.(១) បើទាយកប្រគេនចីវរ ដែលមានបរិកម្មសម្រេចរួចហើយ ដើម្បីឲ្យភិក្ខុក្រាលកឋិន តើគួរ ឬមិនគួរ ?

ឆ.(២) អាចារ្យពួកខ្លះ ពោលថាមិនគួរ ព្រោះអាងព្រះពុទ្ធដីកាដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា តទហេវ សញ្ឆិន្នេន ដែលប្រែថា "ត្រូវកាត់ឲ្យហើយក្នុងថ្ងៃនោះ" ។

អ្នកសួរបដិសេធថា(៣) ពាក្យដែលអាចារ្យទាំងនោះពោល មិនគួរទេ ។

អ្នកឆ្លើយសួរតបវិញថា(៤) ហេតុដូចម្តេច បានជាថាពាក្យនោះមិនគួរ?

អ្នកសួរឆ្លើយថា(៥) បានជាថាពាក្យនោះមិនគួរ ព្រោះអាចារ្យទាំងឡាយដែលពោលមកនោះ មិនដឹងសេចក្តីអធិប្បាយត្រង់បទថា តទ-ហេវ សញ្ឆិន្នេន នោះឡើយ ឯបុព្វាចារ្យទាំងឡាយអ្នកទ្រទ្រង់វិន័យលោកពោលថាគួរ គឺចីវរកឋិនដែលគេធ្វើស្រេចហើយនោះ ពិតជាគួរ ។

ទី ២៣– អញ្ញត្រ បុគ្គលស្ស អត្ថារា វៀរលែងការក្រាលរបស់បុគ្គល គឺមិនឲ្យបុគ្គលក្រាល ត្រឡប់ជាឲ្យសង្ឃ ឬគណៈក្រាលវិញ ។

---

១ និដ្ឋិតបរិកម្មចីវរំ សចេ ទាយកោ កឋិនត្ថាយ ទេតិ វដ្ដតិ ឧទាហុ ន វដ្ដតិ ។ ២ ឯកច្ចេ តទហេវ សញ្ឆិន្នេនាតិ វុត្តត្តា ន វដ្ដតីតិ វទន្តិ ។ ៣ តំ អយុត្តំ ។ ៤ កស្មា ។ ៥ តទហេវ សញ្ឆិន្នេនាតិ បទស្ស អធិប្បាយំ អជានិត្វា វុត្តត្តា ។ វិនយធរា បន បុព្វាចរិយា វដ្ដតីតិ វទន្តិ ។

ទី២៤– ឆ សញ្ញា ចេវ អត្ថំ ហោតិ តញ្ច និស្សីមដ្ឋោ អនុមោទតិ បើភិក្ខុនៅក្រៅឧបចារសីមា អនុមោទនានូវកឋិនណា កឋិននោះ ឈ្មោះថា ក្រាលមិនត្រឹមត្រូវឡើយ ។

កឋិនដែលភិក្ខុក្រាលមិនឡើងជាកឋិន ដោយអាការ ២៤ នេះឯង ។

អនត្ថតាការ ចប់

---

## អត្ថតាការ

អាការដែលភិក្ខុក្រាលបានឡើងពេញលក្ខណៈជាកឋិន ហៅថា អត្ថតាការ ។

ស. កឋិនដែលភិក្ខុក្រាលឡើង ដោយអាការយ៉ាងណាខ្លះ ?

ឆ. តាមព្រះពុទ្ធដីកា ក្នុងគម្ពីរមហាវគ្គ ថា កឋិនដែលភិក្ខុក្រាលឡើង ដោយអាការ ១៧ គឺ ៖

ទី ១– អហតេន ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ថ្មីសុទ្ធ គឺសំពត់ដែលគេមិនទាន់ប្រើ ។

ទី ២- អហតកប្បេន ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ដែលបោកគក់ ១ ដង ឬ ២ ដង ប្រាកដដូចជាសំពត់ថ្មីសុទ្ធ ។

ទី ៣– បិលោតិកាយ ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់សាដកចាស់ ។

ទី ៤— បំសុក្កូលេន ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់បង្សុកូល ដែលកើតឡើងក្នុងបង្សុកូលខេត្រ ២៣ ដែលគេយកមកវេរប្រគេន ។

ទី ៥— អាបណិកេន ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ដែលធ្លាក់ចុះក្បែរទីផ្សារ ដែលទាយករើសយកមកវេរប្រគេន ។

ទី ៦— អនិមិត្តកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលកើតឡើងដោយធម៌ គឺមិនបានធ្វើនិមិត្តកម្ម បញ្ចិតបញ្ចៀង ឲ្យទាយកគេវេរប្រគេនឡើយ ។

ទី៧— អបរិកថាកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលកើតឡើងដោយធម៌ គឺមិនបាននិយាយបញ្ចុះបញ្ចូលទាយក ឲ្យគេវេរប្រគេនឡើយ ។

ទី ៨— អកុក្កុកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលទាយកគេវេរប្រគេន មិនមែនចីវរដែលខ្លួនខ្ចីគេឡើយ ។

ទី ៩— អសន្និធិកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនបានធ្វើឲ្យជាសន្និធិ ។

ទី ១០— អនិស្សគ្គិយេន ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនមែនជានិស្សគ្គិយៈ ។

ទី ១១— កាប្បកតេន ភិក្ខុក្រាលកឋិន ដោយចីវរដែលបានធ្វើ

ពិន្ទុកប្បៈរូបហើយ ។

ទី ១២– សញ្ញាចិយា គឺភិក្ខុក្រាលកឋិន ដោយសញ្ញាដី ។

ទី ១៣– ឧត្តាភាសក្តេន ឬភិក្ខុក្រាលកឋិន ដោយឧត្តាសង្គៈ ។

ទី ១៤– អន្តរវាសកោន ឬភិក្ខុក្រាលកឋិន ដោយអន្តរ-វាសកៈ ។

( អាការទី ១ ទី ១៣ និងទី ១៤ នេះ មិនមែនត្រូវយកទាំង ៣ មកក្រាលកឋិនទេ គឺភិក្ខុអ្នកក្រាលត្រូវជ្រើសរើសយកតែ ១ មកក្រាល ) ។

ទី ១០– បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវសញ្ឆិន្នេន សមណ្ឌលីកតេន គឺភិក្ខុក្រាលកឋិន ដោយបេចីវរដែលបានកាត់ជាប់ជាបញ្ចខណ្ឌ ឬជាអតិរេកបញ្ចខណ្ឌ គឺសត្តខណ្ឌ នវខណ្ឌ និងឯកាទសខណ្ឌ ព្រមទាំងធ្វើឲ្យប្រកបដោយមណ្ឌល គឺមហាមណ្ឌល និងអឌ្ឍមណ្ឌល ឲ្យហើយស្រេចក្នុងថ្ងៃនោះ ។

ទី ១៦– បុគ្គលស្ស អត្ថារា មិនវៀរលែងចាកការក្រាលរបស់បុគ្គល គឺភិក្ខុមួយរូបជាអ្នកក្រាល, មិនមែនសង្ឃ ឬគណៈជាអ្នកក្រាលឡើយ ។

ទី ១៧– សម្មា ចេវ អត្ថតំ ហោតិ តញ្ចេ សីមដ្ឋោ អនុមោទតិ បើភិក្ខុនៅក្នុងសីមា អនុមោទនាកឋិនណា កឋិននោះឈ្មោះថា ក្រាលត្រឹមត្រូវ ។

កឋិនដែលភិក្ខុក្រាលឡើង ដោយអាការទាំង ១៧ នេះឯង ។

អត្ថាការ ចប់ ។

---

## ឧព្ភតកឋិន "កឋិនដោះ"

ដំណើរកឋិនដោះនេះ ក្នុងគម្ពីរមហាវគ្គ មានព្រះពុទ្ធដីកាផ្ដើមឡើង ជាពាក្យសួរថា ម្នាលភិក្ខុទាំងឡាយ! កឋិនដោះយ៉ាងណាខ្លះ ?

ព្រះពុទ្ធជាម្ចាស់ទ្រង់ឆ្លើយដោយព្រះអង្គឯងថា ម្នាលភិក្ខុទាំងឡាយ! មាតិកា ៨ នេះ ប្រព្រឹត្តទៅដើម្បីដោះនូវកឋិន ឬសម្រាប់កឋិនដោះ ។

ស. ពាក្យថា "កឋិនដោះ" ហាក់ដូចជាកឋិនដោះខ្លួនចេញពីភិក្ខុ ព្រោះកឋិនកើតមានដល់ភិក្ខុ តាំងពីក្រាលរួចហើយ ។ គួរឲ្យឆ្ងល់ថា ហេតុដូចម្ដេច ក៏កឋិនដោះខ្លួនចេញពីភិក្ខុ ? ឬក៏ពាក្យថា "កឋិនដោះ" បានសេចក្ដីដូចម្ដេចទៅវិញ ?

ឆ. ពាក្យថា "កឋិនដោះ" មិនមែនបានសេចក្ដីថា កឋិនវាដោះខ្លួនចេញពីភិក្ខុទេ ។ ពាក្យនេះ បើពោលឲ្យពេញសេចក្ដី ត្រូវពោលថា កឋិនដែលភិក្ខុដោះចេញ ឬដកចេញ គឺភិក្ខុទេ ដែលជាអ្នកដោះឬដកកឋិនចេញ ប៉ុន្តែដល់ពោលឲ្យខ្លីទៅ នៅត្រឹមតែពាក្យថា "កឋិនដោះ" ប៉ុណ្ណោះ ។ រឿងកឋិនដោះនេះ មានសេចក្ដីដូចតទៅនេះ ៖

ភិក្ខុបានក្រាល - អនុមោទនាកឋិនហើយក្នុងពេលណា ឈ្មោះថា

មានកឋិនជាប់នៅនឹងខ្លួនក្នុងពេលនោះ កឋិននោះ នាំឲ្យភិក្ខុមានអានិ-
សង្ស ៥ ។ ការចងកឋិនឲ្យជាប់នៅនឹងភិក្ខុអ្នកក្រាល - អនុមោទនាដោយ
បលិពោធ គឺកង្វល់ដែលទុកដូចជាបំណង មានពីរយ៉ាង គឺ អាវាស-
បលិពោធ ១ ចីវរបលិពោធ ១ ។ ឯបលិពោធទាំងពីរយ៉ាងនេះ
ជាប់នៅលើរូបភិក្ខុអ្នកក្រាល - អនុមោទនាគ្រប់រូប ។ កាលបើភិក្ខុអ្នក
ក្រាល-អនុមោទនាកឋិន ធ្វើឲ្យបលិពោធទាំងពីរដែលជាកង្វល់ទុកដូចជា
បំណងដាច់ផុតចេញពីខ្លួនក្នុងពេលណា កឋិនក៏ដោះចេញ ឬឃ្លាតចេញ
ពីភិក្ខុអ្នកក្រាល - អនុមោទនា ក្នុងពេលនោះដែរ ។ រឿងកឋិនដោះនេះ
នឹងមានសំដែងដោយសព្វគ្រប់ក្នុងមាតិកាទាំង ៨ ប្រការខាងមុខនេះ ប៉ុន្តែ
មាតិកាទាំង ៨ ប្រការនោះ មានការទាក់ទងនឹងបលិពោធទាំងពីរប្រការ
ដោយជាក់ស្តែង ហេតុនេះ គួរសំដែងនូវបលិពោធទាំងពីរជាមុន រួចសឹម
សំដែងនូវមាតិកា ៨ តទៅ ដើម្បីឲ្យភិក្ខុអ្នកសិក្សាបានងាយយល់ដោយ
ឆាប់រហ័ស ។

## បលិពោធ " កង្វល់ "

ក្នុងគម្ពីរមហាវគ្គ មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ! បលិ-
ពោធ (កង្វល់) របស់កឋិន មានពីរយ៉ាងគឺ៖

១– អាវាសបលិពោធ "កង្វល់ចំពោះអាវាស" ។ សេចក្តី
ថា ភិក្ខុក្នុងសាសនានេះ នៅក្នុងអាវាសដែលបានក្រាល-អនុមោទនា

កឋិននោះ មានសេចក្តីអាល័យចំពោះអាវាសដែលខ្លួននៅនោះ, កាលបើចេញពីអាវាសនោះទៅ នៅមានបំណងថា អាត្មាអញនឹងត្រឡប់មកវិញ; យ៉ាងនេះ ហៅថា អាវាសបលិពោធ គឺភិក្ខុអ្នកក្រាល-អនុមោទនាកឋិន នៅមានកង្វល់ក្នុងអាវាស ។

២– ចីវរបលិពោធ "កង្វល់ចំពោះចីវរ" ។ សេចក្តីថា ភិក្ខុក្នុងសាសនានេះ មិនទាន់បានធ្វើចីវរ ឬធ្វើមិនទាន់រួចស្រេច ឬក៏សេចក្តីប្រាថ្នាចំពោះចីវរមិនទាន់ដាច់នៅឡើយ; យ៉ាងនេះហៅថា ចីវរបលិ-ពោធ គឺភិក្ខុអ្នកក្រាល-អនុមោទនាកឋិន នៅមានកង្វល់ចំពោះចីវរ (ដែលត្រូវរក ឬដែលត្រូវធ្វើឲ្យមានគ្រប់គ្រាន់ល្មមប្រើប្រាស់បាន)(១) ។

មាតិកា

ស. ពាក្យថា មាតិកា បានសេចក្តីដូចម្តេច ?

ឆ. តាមអដ្ឋកថា មានសេចក្តីពន្យល់ថា មាតិកា គឺជាមាតា ឬជាអ្នកបង្កើត ព្រោះមាតិកាទាំង ៨ នោះ ញាំងកឋិនុទ្ធារៈ គឺការដោះកឋិនឲ្យកើត ។

---

១ ក្នុងសម័យយើងសព្វថ្ងៃនេះ ភិក្ខុទាំងឡាយច្រើនតែមានចីវរគ្រប់គ្រាន់ ពុំសូវខ្វះខាត ពុំសូវមានភិក្ខុដែលចេញពីវត្តលំនៅទៅរកចីវរទេ ដោយហេតុនេះ ពួកភិក្ខុច្រើនតែពុំសូវមាន ចីវរបលិពោធ នៅមានត្រឹមតែ អាវាសបលិពោធ ប៉ុណ្ណោះឯង ព្រោះភិក្ខុរក្សា អាវាសបលិពោធ កុំឲ្យដាច់ ។

មាតិកា ៤ នោះ អានសេចក្ដីពន្យល់តទៅនេះគឺ ៖

១– បក្កមនន្តិកា មាតិកា មានកិរិយាបៀសចេញទៅចាកកឋិនាវាស គឺអាវាសដែលក្រាល-អនុមោទនាកឋិន ជាទីបំផុត ឬជាកំណត់ ។ សេចក្ដីថា ភិក្ខុក្រាលកឋិន-អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលធ្វើស្រេចហើយ ចេញទៅចាកអាវាស ដោយគិតថា " អាត្មាអញនឹងមិនត្រឡប់វិញទេ " ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ការចេញផុតចាកអាវាសជាកំណត់ ។ កឋិនដោះពេលណា អានិ-សង្ស ៥ របស់ភិក្ខុនោះ ក៏អស់ក្នុងពេលនោះឯង ។

(ក្នុងមាតិកានេះ ចីវរបលិពោធដាច់មុន គឺដាច់តាំងពីនៅក្នុងអាវាស, អាវាសបលិពោធដាច់ក្រោយ) ។

២– និដ្ឋានន្តិកា មាតិកា មានកិរិយាសម្រេចនៃចីវរជាទីបំផុត ។ សេចក្ដីថា ភិក្ខុបានក្រាល-អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើ ចេញទៅអំពីអាវាសដែលបានក្រាល-អនុ-មោទនាកឋិន, កាលដែលទៅដល់វត្តដទៃជិតខាង ជាវត្តនៅខាងក្រៅឧបចារសីមា ក៏មានគំនិតកើតឡើងថា " អញនឹងឲ្យគេជួយធ្វើចីវរក្នុងទីនេះ អញនឹងមិនត្រឡប់វិញទេ " ។ ភិក្ខុនោះក៏បានធ្វើចីវរហើយស្រេចក្នុងទីនោះទៅ ។ គ្រាន់តែធ្វើចីវររួចស្រេចភ្លាម កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ក្នុងពេលដែលធ្វើចីវររួចស្រេចនោះឯង ។

(ក្នុងមាតិកានេះ អាកាសបលិពោធជាប់មុន ចីវរបលិពោធជាប់ក្រោយ)

៣- សន្និដ្ឋានន្តិកា មាតិកា មានសន្និដ្ឋានគឺសេចក្តីសម្រេចចិត្តជាទីបំផុត ។ សេចក្តីថា ភិក្ខុបានក្រាល - អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសនោះទៅ កាលទៅដល់វត្តជាខាងក្រៅឧបចារសីមាក៏បានសម្រេចចិត្តថា "អញនឹងមិនរកគេឲ្យជួយធ្វើចីវរនេះទេ តាំងវត្តដែលអាត្មាអញបានក្រាល - អនុមោទនាកឋិន ក៏អញមិនត្រឡប់ទៅវិញឡើយ" ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះកង្គ្រាដែលសម្រេចចិត្តនោះឯង ។

(ក្នុងមាតិកានេះ អាវាសបលិពោធ និងចីវរបលិពោធ ដាច់ព្រមគ្នា)

៤- នាសនន្តិកា មាតិកា មានកិរិយាវិនាសចីវរជាទីបំផុត ។ សេចក្តីថា ភិក្ខុបានក្រាល - អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ កាលទៅដល់វត្តជាខាងក្រៅឧបចារ-សីមា ក៏គិតថា "អញនឹងឲ្យគេជួយធ្វើចីវរក្នុងទីនេះ អញនឹងមិនត្រឡប់ទៅកាន់វត្តដើមវិញទេ"; លុះកំពុងតែធ្វើ ចីវរនោះក៏ត្រូវវិនាសដោយហេតុណាមួយ មានចោរលួច ឬភ្លើងឆេះជាដើម ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះកង្គ្រាវិនាសចីវរ ។

(ក្នុងមាតិកានេះ អាវាសបលិពោធជាប់មុន ចីវរបលិពោធជាប់ក្រោយ)

៥- សវនន្តិកា មាតិកា មានកិរិយាឮដំណឹងជាទីបំផុត ។

សេចក្ដីថា ភិក្ខុបានក្រាល-អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ ដោយគិតថា "អាត្មាអញនឹងត្រឡប់វិញ"; កាលទៅដល់វត្តជាខាងក្រៅឧបចារសីមា ក៏ឲ្យគេជួយធ្វើចីវរ លុះធ្វើចីវរហើយ ក៏បានព្រងំណាំងថា "សង្ឃក្រុងវត្តស្រូត្រដោះកឋិនទៅហើយ" ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះកង្គ្រាដែលបានព្រងំណាំងនោះឯង ។

(ក្នុងមាតិកានេះ ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ក្រោយ)

៦- អាសាវច្ឆេទិកា មាតិកាប្រកបដោយកិរិយាដាច់បំណង ឬការអស់សេចក្ដីសង្ឃឹម ។ សេចក្ដីថា ភិក្ខុបានក្រាលកឋិន-អនុមោទនាកឋិនរួចហើយ ចេញពីអាវាសទៅដោយមានបំណងនឹងស្វែងរកចីវរក្នុងទីដទៃឯទៀត លុះទៅដល់ខាងក្រៅឧបចារសីមា ក៏គិតថា "អញនឹងស្វែងរកចីវរតែក្នុងទីខាងក្រៅឧបចារសីមានេះ អញនឹងមិនត្រឡប់ទៅវត្តវិញទេ"; ភិក្ខុនោះក៏ស្វែងរកចីវរក្នុងទីនោះ លុះដល់ស្វែងរកមិនបានបំណង ឬ សេចក្ដីប្រាថ្នាក្នុងការស្វែងរកចីវរនោះ ក៏ដាច់ទៅ ឬអស់ទៅ ។ កឋិនរបស់ភិក្ខុនោះ ក៏ដោះក្នុងគ្រាដែលដាច់បំណង ឬ អស់សេចក្ដីសង្ឃឹមក្នុងការស្វែងរកចីវរនោះឯង ។

(ក្នុងមាតិកានេះ អាវាសបលិពោធដាច់មុន ចីវរបលិពោធដាច់ក្រោយ)

៧- សីមាតិក្កន្តិកា មាតិកា មានកិរិយាកន្លងនូវសីមា គឺខេត្តនៃកឋិនជាទីបំផុត ១ សេចក្ដីថា ភិក្ខុបានក្រាល-អនុមោទនាកឋិន

(នៅមានត)

# រឿងមាតាព្រះកុមារកស្សប

អដ្ឋកថាធម្មបទ ភាគទី ៦ អដ្ឋវត្ថុទី ៤

---

កាលព្រះបរមសាស្តាគង់ក្នុងវត្ត ជេតពន ទ្រង់ប្រារព្ធនឹងមាតាព្រះកុមារកស្សបត្ថេរ សំដែងធម៌ដោយបទគាថា ថា អត្តាហិ អត្តនោ នាថោ ដូច្នេះជាដើម ។

បានឮមកថា មាតារបស់ព្រះថេរៈនោះជាធីតានៃសេដ្ឋីក្នុងនគររាជគ្រឹះ តាំងពីវេលាដឹងក្តីហើយសូមបួស ប៉ុន្តែ បើទុកជាសូមបួសញយ ៗ ក៏នៅតែមិនបានបួស ព្រោះមិនបានអនុញ្ញាតអំពីមាតាបិតា លុះចំរើនវ័យធំឡើងហើយក៏ទៅកាន់ត្រកូលប្តី មានប្តីដូចជាទេវតានៅគ្រប់គ្រងផ្ទះ ។ បំណោរតមកមិនយូរប៉ុន្មាន សត្វកើតក្នុងគភ៌តាំងឡើងក្នុងផ្ទៃរបស់នាង គឺថានាងមានផ្ទៃពោះ ប៉ុន្តែនាងមិនដឹងថាខ្លួនមានផ្ទៃពោះ ធ្វើស្វាមីឲ្យមានសេចក្តីត្រេកអរហើយអង្វរសូមបួស ។ គ្រានោះ ស្វាមីនាំនាងទៅកាន់សំណាក់របស់នាងភិក្ខុនី ដោយគ្រឿងសក្ការៈដ៏ធំ ដោយមិនដឹងខុសត្រូវ ក៏នាំទៅឲ្យបួសក្នុងសំណាក់នាងភិក្ខុនីជាបក្សពួកនៃព្រះទេវទត្ត ។ សម័យតមក នាងភិក្ខុនីទាំងនោះបានដឹងថានាងភិក្ខុនីដែលបួសថ្មីនោះមានផ្ទៃពោះ ទើបសួរថា នេះជាអ្វី ? នាងឆ្លើយថា បពិត្រនាងម្ចាស់ទាំងឡាយ ! ខ្ញុំមិនដឹងថាជាអ្វីដែរ ប៉ុន្តែឯសីលរបស់ខ្ញុំមិនដាច់ទេ ។ ពួកនាងភិក្ខុនីនាំនាងទៅកាន់សំណាក់ព្រះទេវទត្តសួរថា នាងភិក្ខុនីនេះបួសដោយសទ្ធា

ពួកខ្ញុំមិនដឹងថានាងមានផ្ទៃពោះ ឥឡូវឲ្យពួកខ្ញុំធ្វើយ៉ាងណា ។ ព្រះទេវ-ទត្ត គិតតែត្រឹមខ្ញុំប៉ុណ្ណោះថា ទោសចូរកុំបង្កើតឡើងដល់ពួកនាងភិក្ខុនីអ្នកធ្វើតាមឧវាទរបស់អញ ទើបប្រាប់ថា ពួកនាងចូរឲ្យនាងភិក្ខុនីនេះសឹកចេញទៅចុះ ។ នាងភិក្ខុនីក្មេងឮដូច្នោះ ហើយនិយាយថា បពិត្រនាងទាំងឡាយ ! សូមលោកទាំងអស់កុំធ្វើខ្ញុំឲ្យវិនាសឡើយ ខ្ញុំមិនមែនបួសចំពោះព្រះទេវទត្តទេ សូមនាងទាំងឡាយនាំខ្ញុំទៅឯសំណាក់ព្រះសាស្តា ។ ពួកនាងភិក្ខុនីទាំងនោះនាំនាងទៅឯវត្តជេតពន ក្រាបទូលព្រះសាស្តា ។ ព្រះសាស្តាសូម្បីទ្រង់ជ្រាបថា នាងមានផ្ទៃពោះតាំងពីនៅជាគ្រហស្ថ ក៏ដើម្បីនឹងបំបាត់នូវពាក្យតិះដៀល ទើបទ្រង់បង្គាប់ឲ្យអញ្ជើញស្តេចព្រះបាទបសេនទិកោសល និងលោកមហាអនាថបិណ្ឌិក, លោកចូឡអនាថ-បិណ្ឌិក, នាងវិសាខា ឧបាសិកា និងត្រកូលធំៗ ដទៃទៀតជាច្រើនមកប្រជុំ ហើយទ្រង់បង្គាប់ព្រះឧបាលិត្ថេរថាអ្នកចូរទៅ ចូរជម្រះកម្មរបស់នាងភិក្ខុនីក្មេងនេះ ឲ្យស្អាតបរិសុទ្ធកណ្តាលបរិស័ទបួន ។ ព្រះថេរៈឲ្យអញ្ជើញនាងវិសាខាមកចំពោះព្រះភក្ត្រព្រះរាជា ហើយឲ្យទទួលជម្រះអធិ-ករណ៍នោះ ។ នាងវិសាខាប្រើមនុស្សឲ្យបាំងរាំងនន រួចពិនិត្យមើលដៃនិងជើងនិងផ្ចិតនិងពោះរបស់នាងភិក្ខុនីក្នុងរាំងនន ហើយរាប់ខែនិងរដូវដឹងថានាងមានផ្ទៃពោះតាំងពីវេលានៅជាគ្រហស្ថ ក៏ទូលសេចក្តីនោះដល់ព្រះថេរៈ ។ គ្រានោះ ព្រះថេរៈប្រតិស្ឋាន គឺតម្កល់សេចក្តីទុកថា នាង

ភិក្ខុនីនោះជាស្ត្រីបរិសុទ្ធគង់ទីកណ្ដាលបរិស័ទ ។ សម័យក្រោយមក នាង ប្រសូតបុត្រដែលមានបុណ្យច្រើន ដែលមានសេចក្ដីប្រាថ្នាតាំងទុកជិត ព្រះបាទរបស់ព្រះពុទ្ធទ្រង់ព្រះនាមថា បទុមុត្តរៈ ។

ថ្ងៃមួយ ព្រះរាជា ស្ដេចទៅជិតលំនៅរបស់នាងភិក្ខុនី ទ្រង់បានឮ សំឡេងទារកយំ ត្រាស់សួរថា នេះជាសំឡេងអ្វី ? អាមាត្យក្រាបទូលថា សូមព្រះតេជៈតម្កល់លើត្បូង ! បុត្ររបស់នាងភិក្ខុនីនេះកើតហើយ នេះ ជាសំឡេងរបស់បុត្រនាងភិក្ខុនីនោះ ។ ព្រះរាជាទ្រង់នាំយកកុមារនោះ ទៅឯព្រះរាជវាំងនៃព្រះអង្គ បានប្រទានឲ្យភីលៀងស្ត្រីអភិចិញ្ចឹមថែរក្សា ទាំងឡាយ ។ គង់ថ្ងៃរកឈ្មោះឲ្យកុមារនោះ ជនទាំងពួងសន្មតឲ្យឈ្មោះ កុមារថា កស្សប នាំគ្នាហៅថា កុមារកស្សប ព្រោះចម្រើនហើយដោយ គ្រឿងបរិហាររបស់កុមារ ។ កុមារនោះ វាយក្មេងគង់ថ្នាជាទីលេង, កាល ក្មេងទាំងនោះនិយាយថា អញត្រូវក្មេងឥតមាតាបិតាវាយហើយ ។ កុមារឮពាក្យនេះក៏ចូលទៅគាល់ព្រះរាជាទូលសួរថា បពិត្រព្រះអង្គ ! ពួក ក្មេង ៗ ថាខ្ញុំព្រះអង្គនោះ ជាមនុស្សឥតមាតាបិតា សូមព្រះអង្គត្រាស់ប្រាប់ មាតាដល់ខ្ញុំ ។ ព្រះរាជា បង្ហាញស្ត្រីភីលៀងទាំងឡាយហើយត្រាស់ថា ស្រីទាំងនេះ ជាមាតារបស់ឯង ។ កុមារ ក្រាបទូលថា មាតារបស់ខ្ញុំមិន មែនច្រើនដល់ប៉ុណ្ណោះទេ មាតា របស់ខ្ញុំមានតែម្នាក់ប៉ុណ្ណោះ សូមព្រះ អង្គ ត្រាស់ប្រាប់មាតានោះដល់ខ្ញុំ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញមិន

អាចបញ្ចោតកុមារនេះបានទេ ទើបប្រាប់ថា នែកូន ! មាតារបស់ឯងជានាងកិគុទី អញនាំយកឯងមកអំពីសំណាក់នាងកិគុទី ។ កុមារនោះ មានសេចក្តីសង្វេគស្លុតចិត្តកើតឡើងដោយហេតុត្រឹមតែប៉ុណ្ណោះ ក៏ក្រាបទូលថាបពិត្រព្រះបិតា ! សូមព្រះអង្គអនុញ្ញាតឲ្យខ្ញុំបួសផង ។ ព្រះរាជាទ្រង់ទទួលព្រមថា ល្អហើយកូន ! ហើយញុំាងកុមារនោះឲ្យបួសក្នុងសំណាក់របស់ព្រះសាស្តា ដោយគ្រឿងសក្ការៈធំ ។

លោកបានឧបសម្បទហើយ មានព្រះនាមជាប្រាកដថា ព្រះកុមារកស្សបត្ថេរ លោករៀនព្រះកម្មដ្ឋានក្នុងសំណាក់របស់ព្រះសាស្តាចប់ហើយចូលទៅគង់នៅក្នុងព្រៃ ខំព្យាយាមដូចម្តេច ក៏មិនបានសម្រេចគុណវិសេសណាមួយសោះ គិតថា អញនឹងរៀនព្រះកម្មដ្ឋានថ្មីទៀតឲ្យវិសេសហើយវិលមកគាល់ព្រះសាស្តាវិញ នៅក្នុងព្រៃអន្ធវន ។ គ្រានោះ ភិក្ខុអ្នកធ្វើសមណធម៌ជាមួយគ្នា ក្នុងកាលរបស់ព្រះពុទ្ធព្រះនាមកស្សប បានសម្រេចអនាគាមិផល ទៅកើតក្នុងព្រហ្មលោក មកអំពីព្រហ្មលោកសួរប្រស្នា ៩១ ហើយបញ្ជូនទៅ ដោយពាក្យថា មនុស្សដទៃ លើកលែងតែព្រះសាស្តាមួយព្រះអង្គចេញ ដែលអាចដើម្បីនឹងព្យាករប្រស្នាទាំងនេះគ្មានទេ, លោកចូលទៅរៀនសេចក្តីរបស់ប្រស្នាទាំងនេះ ក្នុងសំណាក់របស់ព្រះសាស្តាចុះ ។ លោកធ្វើតាមពាក្យនោះ ក៏បានសម្រេចព្រះអរហត្តផលក្នុងទីបំផុតវិស្សជ្ជនាប្រស្នា ។

ចាប់តាំងអំពីថ្ងៃព្រះថេរៈចេញទៅបាត់ហើយ ទឹកភ្នែកហូរចេញពីភ្នែករបស់នាងភិក្ខុនី ជាមាតាអស់ចំនួន ១២ ឆ្នាំ ។ នាងវង្វេងព្រោះព្រាត់ប្រាសចាកបុត្រ មានមុខទទឹកជោក ដោយទឹកភ្នែក ត្រាច់ទៅដើម្បីភិក្ខាស្រាប់តែក្រឡេកទៅឃើញព្រះថេរៈនៅកណ្ដាលផ្លូវ ស្រែកហៅថា កូន ! កូន ! ស្ទុះចូលទៅប្រះទឹងចាប់ព្រះថេរៈ ភ្លាត់ដើងដួលស្រែកទឹកដោះទទឹកចីពរជោក ក្រោកឡើងចូលទៅចាប់ព្រះថេរៈ ។ គិតថា បើមាតា បានឮពាក្យផ្អែមល្ហែមពីពេះពីអញ មុខជានឹងវិនាសចាកមគ្គផល អាត្មាអញនឹងនិយាយជាមួយមាតានេះ ដោយសំដីរឹងរូសទ្រគោះ ទើបលោកនិយាយនឹងនាងភិក្ខុនីនោះថា លោកត្រាច់ទៅធ្វើអ្វី បានជាគ្រាន់តែសេចក្ដីស្រឡាញ់ប៉ុណ្ណឹង ក៏កាត់មិនដាច់ដែរ ។ នាងភិក្ខុនីឮហើយគិតថា យីអើ! សំដីរបស់ព្រះថេរៈទ្រគោះណាស់ ទើបនិយាយថា នែកូន! កូនថាម៉េច?។ ព្រះថេរៈថាដូចមុនទៀត ។ នាងគិតថា អញមិនអាចទប់ទឹកភ្នែកបានអស់កាល ១២ ឆ្នាំមកហើយ ព្រោះតែបុត្ររបស់អញនេះ ប៉ុន្តែ បុត្រអញនេះមានហឫទ័យរឹងរូស អញនឹងត្រូវការអ្វីដោយបុត្រនេះ, ក៏កាត់សេចក្ដីស្រឡាញ់ចេញពីបុត្រដាច់ បានសម្រេចព្រះអរហត្តផលក្នុងថ្ងៃនោះឯង ។

សម័យក្រោយទៀត ភិក្ខុទាំងឡាយសន្ទនាគ្នា ក្នុងរោងធម៌ថា នែអាវុសោទាំងឡាយ ! ព្រះទេវទត្តញុំាងព្រះកុមារកស្សប និងព្រះថេរី អ្នកមានឧបនិស្ស័យបរិបូណ៌យ៉ាងនេះឲ្យវិនាសហើយ ចំណែកព្រះសាស្ដាជា

ទីពឹងរបស់លោកទាំងពីររូបនោះ ធម្មតាព្រះពុទ្ធជាម្ចាស់ តែងអនុគ្រោះលោក ព្រះសាស្តា ស្តេចមកដល់ត្រាស់សួរថា ភិក្ខុទាំងឡាយ! ពេលនេះ ពួកអ្នកនិយាយគ្នាពីរឿងអ្វី ? កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបហើយត្រាស់ថា ភិក្ខុទាំងឡាយ! តថាគត ជាទីអាស្រ័យ ជាទីពំនាក់របស់ជនទាំងពីរនាក់នេះ មិនតែក្នុងកាលនោះទេ សូម្បីក្នុងកាលមុនក៏បានជាទីពឹងពំនាក់ របស់ជនទាំងនោះដូចគ្នាដែរ ហើយសំដែងនិគ្រោធ-ជាតកនេះដោយពិស្តារ សេចក្តីសង្ខេបថា :

និគ្រោធមេវ សេវេយ្យ ន សាខមុបសំវសេ
និគ្រោធស្មឹ មតំ សេយ្យោ យញ្ចេ សាខស្មិ ជីវិតន្តិ ។

បើបុមនុស្សដទៃ គប្បីសេពគប់តែនឹងម្រឹគឈ្មោះ និគ្រោធម្នាក់ កុំសេពគប់នឹងម្រឹគឈ្មោះ សាខៈ ឡើយ ស្លាប់ក្នុងសំណាក់នៃម្រឹគឈ្មោះ និគ្រោធប្រសើរជាង រស់នៅក្នុងសំណាក់របស់ម្រឹគឈ្មោះ សាខៈ នឹងប្រសើរអ្វី ។

ទ្រង់ប្រជុំជាតកថា ម្រឹគឈ្មោះ សាខៈ ក្នុងគ្រានោះ បានមកជាទេវទត្តក្នុងគ្រានេះ ឯបរិស័ទរបស់ម្រឹគឈ្មោះ សាខៈ នោះ ក៏ជាបរិស័ទរបស់ទេវទត្តនុ៎ះឯង ចំណែកមេម្រឹគអ្នកដល់វារៈហើយ បានមកជានាង ថេរី បុត្ររបស់មេម្រឹគនោះ បានមកជា កុមារកស្សបឯស្តេចម្រឹគឈ្មោះ និគ្រោធ អ្នកលះបង់ជីវិតដល់មេម្រឹគ ដែលមាន

គកិឲ្យរួចជីវិត ទៅហើយ គឹតថាគតនេះឯង កាលព្រះអង្គទ្រង់ប្រកាស
សេចក្តីដែលព្រះថេរី កាត់សេចក្តីស្រឡាញ់អំពីបុត្រចេញបាន ហើយ
ធ្វើទីពឹងដល់ខ្លួនដោយខ្លួនឯង ទើបទ្រង់ត្រាស់ថា ទែកិក្ខុទាំងឡាយ
បុគ្គលអាស្រ័យមនុស្សដទៃ មិនអាចដើម្បីទឹងបានទៅស្ថានសួគ៌ ឬបាន
សម្រេចមគ្គផលទេ ព្រោះហេតុនោះ ខ្លួនឯងហ្នឹងជាទីពឹងរបស់ខ្លួន អ្នក
ដទៃនឹងធ្វើអ្វីបាន ហើយត្រាស់គាថាថា ៖

អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បកេ សិយា
អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។

ខ្លួនឯងហ្នឹងជាទីពឹងរបស់ខ្លួន បុគ្គលដទៃណាជាទីពឹងបាន ព្រោះ
បុគ្គលមានខ្លួនទូន្មានល្អហើយ រមែងបានទីពឹងដែលបុគ្គលបានដោយក្រ ។

កាលចប់ធម្មទេសនា មនុស្សជាច្រើនបានសម្រេចមគ្គផល មាន
សោតាបត្តិផលជាដើម ។

( រឿងមាតាព្រះកុមារកស្សបត្ថេរ ចប់ )

យើងត្រូវលះបង់សុខតូចពោល
ដើម្បីយកសុខធំវិញទើបប្រសើរ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ក)

*ព្រះមហា ចាន់-ខាត់ រៀបរៀង*

---

អបាណ្ឌុរ គុ. ដែលមិនមែនជាបាណ្ឌុរ ។

អបាតក នបុ. អបាតក, កិរិយាមិនមានទោសឧក្រិដ្ឋ ។

អបាត្រ នបុ. អបាត្រ, ជនមិនគួរទទួលទាន ។ —ក្រិត្យា ស្ត្រី. អបាត្រក្រិត្យា អំពើដែលធ្វើមិនឲ្យសមនឹងទទួលទាន ។ —ីករណ នបុ. កិរិយាឲ្យដល់ជនអបាត្រ ។ —ីក្ឫត គុ. ដែលឲ្យទានដល់ជនអបាត្រ ។ —អបាត្រករណ គុ. ដែលធ្វើមិនឲ្យសមទទួលទាន ។

អបាទាន នបុ. អបាទាន, កិរិយាចៀសចេញ ។

អបាន៑ អន: ធាតុ ដកដង្ហើមចេញ ។

អបាន បុ. ដង្ហើមចេញចូល ។ វច្ចមគ្គ ។ —អបាន-នោទ្គារ បុ. ផោម (F. Pet) ។

អបានីយ គុ. ដែលមិនមានទឹកផឹក ។

អបានុទ ណាគុ វែក ញែក ចៀសវាង ។

អបាវុត គុ. ដែលប្រាសចាកសេចក្តីពិត, ពិត ។

អបាន្តវិតមស ចុំ. ទាបឬស៊ី ។

អបាប គុ. ដែលមិនមានបាប បរិសុទ្ធ ស្អាត ល្អ ។
ចេតស គុ. ដែលមានចិត្តល្អ ។ – ទស្សិន គុ. ដែលឃើញថាល្អ ។

អបាយ ចុំ. អបាយ , សេចក្តីវិនាស ។

អបាយិន គុ. ដែលចេញទៅ , ដែលស្លាប់ ។

អបារ គុ. ដែលមិនមានត្រើយ ដែលនៅកណ្តាលស-មុទ្រ ។ នបុ. អបារ ត្រើយជិត ។

អបារណីយ គុ. ដែលមិនអាចរំលងបាន ដែលមិនអាចដល់-ត្រើយបាន ។

អបាបិ គុ. ដែលមិនមានសេចក្តី ។ —ក គុ. ដែលឥតប្រយោជន៍ ។

អបាចិរិ គុ. ដែលមិនមែនជាធី ។

អបាល គុ. អពាល ដែលមិនមានអ្នកក្មេង ។

អបាវុ ធាតុ. បើក រកឃើញ ។ —វុត គុ. ដែលបើក ដែលរួច ដែលបើកបង្ហាញ ។

អបាវុត គុ ដែលមិនឃាត់ទុក, ដែលមិនទើស ។

អបវុត ធាតុ. ប្រឡប់ ។ —វុត្ត គុ ដែលត្រឡប់ ។ វុត្តក គុ ដែលរត់បាត់ ។

អបាគ្រយ ប៉ុ. អបាគ្រ័យ ក្បាលត្រៃ ពំនឹង ទីជម្រក កិរិយារួច ។ របងព័ទ្ធញ្ញារ ។ ក្ដួល ។ — គ្រយិន ឬ គ្រយវន្ត គុ. ដែលមានទីបង្អែក ។

អបាគ្រិ ធាតុ ពឹង ស្វែងរកទីពឹង ។ —គ្រិត គុ ដែលពឹង ដែលរកទីពឹង ។

អបាបណ្ណ គុ. អពាសណ្ណ អន្យឥន្ទ្រិយ ដែលមានសេចក្ដីយល់ផ្សេង ។

អបៀសៈ អសៈ ធាតុ. ពោលពោលទៅឆ្ងាយ អពាស្យ ដោយប្រ-
ហែស ដោយលើកលែង ។

អបិ និបាត ដែរ ប៉ុន្តែ តែប៉ុណ្ណោះ ។ កោ បិ
អ្នកណាមួយ កុត្រាបិ នៅក្នុងទីណា ។

អបិ គម ធាតុ ចលរួម ។

អបិគុណ គុ. ប្រសើរ ដ៏វិសេស ។

អបិគ្រហ ធាតុ បិទទ្វារ បិទត្រចៀក ។

អបិត្រ្យ គុ. ដែលមិនស៊ីខ្សែពីបិតា ។

អបិ ធា ធាតុ បិទ គ្រប ពាក់ ។

អបិធាន នប៉ុ. ភួយ ស្រោម ខប ។ គម្រប របង រនុកទ្វារ ។

អបិធាន គុ. ដែលមិនមានស្រោម ទទេ អាក្រាត ។

អបិនហ ធាតុ ចង ចុក ។

អបិបាស គុ. ដែលមិនមានសេចក្តីប្រាថ្នា ដែលមិនស្រេក
ឃ្លាន ។

អបិប្បលាទ គុ. ដែលមិនស៊ីផ្លែល្វា ដែលមិនរីករាយនឹងកាម ។

អបិពទ្ធ គុ. ដែលចង ។

ល្បងសិក្សា

# ប្រវត្តិអក្សរសាស្ត្រខ្មែរ

ដោយ លាង ហ៍បអាន

សាស្ត្រាចារ្យ-នាយកពុទ្ធសាសនបណ្ឌិត្យ

(ស្រង់ពីមេរៀនវិជ្ជាឋានអប់រំខាងអក្សរសាស្ត្រ)

## អក្សរសាស្ត្រខ្មែរ

## ពីសម័យបុរាណ មកសម័យបច្ចុប្បន្ន

[ត]

កាលបរិច្ឆេទនៃការតែង និងឈ្មោះអ្នកបញ្ញាឲ្យតែង ។

២– តួសេចក្ដី : ដែលរៀបរាប់អំពីគោលបំណង (គឺអត្ថន័យនៃអត្ថបទ) របស់អ្នកបញ្ញា ។ ក្នុងតួសេចក្ដីនេះ មានបញ្ជាក់អំពីទឹកព្រះទ័យព្រះមហាក្សត្រដែលទ្រង់ជាប់ជំពាក់ព្រះហឫទ័យទៅលើពុទ្ធសាសនា ទៅលើការកសាងសមិទ្ធិនានាដើម្បីជាប្រយោជន៍ដល់ត្រៃសរណាគមន៍ ហើយនិងព្រហ្មវិហារធម៌ចំពោះសព្វសត្វ គោលគឺអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ ។

៣– សេចក្ដីបញ្ចប់ : ដែលជាយោបល់នៃអត្ថបទមានបែបជាដំបូន្មានណែនាំប្រជានុរាស្ត្រឲ្យតាំងនៅក្នុងសច្ចៈ សុចរិត យុត្តិធម៌ ឲ្យប្រកាន់ខ្ជាប់

នូវធម៌សន្ដោស មានមេត្តាករុណាជាអាទិ ។

សិលាចារឹកខ្លះ (ឧទាហរណ៍ សិលាចារឹកប្រាសាទតាព្រហ្ម : បាន បញ្ជាក់ដោយបញ្ញា គឺ "ព្រះមហាក្សត្រ") សូមអធិដ្ឋានអានិសង្សកើតមក ពីបុណ្យ និងការកសាងនានាដើម្បីសំរេចប្រយោជន៍ទៅបរលោកនាយ ដូចជាសុំតាំងខ្លួនជាឧបាសកសុំឲ្យប្រាសចាកបាបកម្មនានា ហើយបាន សំរេចមគ្គផលដល់ត្រើយព្រះនិព្វានជាដើម ។

សារុបសេចក្ដីទៅ ឃ្លាប្រយោគនៃអត្ថបទសិលាចារឹកច្រើនកាត់ៗមិន អស់សេចក្ដីទេ (អក្សរខ្លះរលប់បាត់ដោយមកពីការចាស់ដកនៃសិលា)ហើយ របៀបយល់នូវគំនិតត្រូវតែពិនិត្យមើលឯកសារខាងប្រវត្តិវិជ្ជានានា ដើម្បី ប្រៀបធៀបនូវឆ្នាំតាមព្រះមហាក្សត្រ និងសម័យកាលពិតប្រាកដផង ។

## ៣_ អំពីអត្ថរសនៃអត្ថបទសិលាចារឹក

តម្លៃជាមូលដ្ឋាននៃអត្ថបទសិលាចារឹក គឺបិតនៅលើ សង្គមរស = Le social ពីព្រោះតាំងអ្នកកត់ត្រាក្ដី គឺយោលទៅលើហេតុការណ៍ ច្បាស់លាស់ នៃការរស់នៅ (រាប់តាំងពីទឹកចិត្ត ជំនឿនៃការកសាងនានា សមិទ្ធិដែលកើតមាន) ឬវិបត្តិនានា ដែលមនុស្សជាតិក្នុងសម័យកាល នោះបានជួបប្រទះ ។

គឺដោយសារសង្គមរសនេះទៀត ដែលអ្នកសិក្សាប្រវត្តិវិជ្ជាអាចយក

សិលាចារឹក យកធ្វើជាសេចក្ដី ប្រមាណសិក្សាក្នុងការស្រាវជ្រាវ ពិនិត្យវិនិច្ឆ័យអំពីជីវភាព ការរស់នៅរបស់ខ្មែរក្នុងសម័យកាលនោះៗដែលកន្លងទៅហើយ ។

## ៤- យោបល់រួម

ដូច្នេះយើងឃើញថា សិលាចារឹកជាអត្ថបទអក្សរសាស្ត្រដ៏ចំណាស់មួយ ហើយមានប្រយោជន៍សំខាន់ដែលធ្វើឲ្យអនុជន (អ្នកប្រវត្តិវិជ្ជា-អ្នកសិក្សាស្រាវជ្រាវ) បានយល់ បានដឹងនូវកម្រិតសមត្ថភាពនៃវប្បធម៌ អរិយធម៌ខ្មែរ ដែលប្រជាជនខ្មែរបានរក្សា ទ្រទ្រង់ ពង្រីកឲ្យលូតលាស់តាំងពីបុរាណកាលមកម្ល៉េះ ។

## ទី ២- សម័យកាលទី ២

## សម័យមុនអង្គរ គ.ស. ៥៥០-៨០២

### ១- ក្សត្រសំខាន់ខ្លះក្នុងសម័យកាលទី ២ (១)

(១) ឯកសារខ្លះសំរាប់សិក្សាសម័យកាលនេះគឺ :

— P. Pelliot : Le Founan; — L. Finot. BEFEO, XXVIII. P. 44 ;

— G. Cœdès, les Etats hindouïsés P. 130; — G. Cœdè., Inscriptions du Csmbodge, Vol. V. P. 23;

— A. Barth, Inscription dn Cambodge, P. 60; — G. Cœdès Histoire ancienne des Etats hindouïsés d'Extrême-Orient, P. 90.

សម័យកាលទី ២ នេះ អាចហៅបាន ២ យ៉ាងទៀតគឺ :

- សម័យមុនអង្គរ ឬ សម័យចេនឡាក៏បាន

ឯព្រះមហាក្សត្រ ដ៏ល្បីខ្លះក្នុងសម័យកាលទី ២ នេះ គឺមាន :

- ព្រះបាទភវវរ្ម័ន ទី ១ (គ.ស. ៥៥០-៦០០)

- ព្រះបាទមហេន្ទ្រវរ្ម័ន ចិត្រសេនា (គ.ស. ៦០០-៦១៥)

- ឥសានវរ្ម័ន ទី ១ (គ.ស. ៦១៥-៦៣៥)

- ភវវរ្ម័ន ទី ២ (គ.ស. ៦៣៩-៦៥៥)

- ជ័យវរ្ម័ន ទី ១ (គ.ស. ៦៥៥-៦៨១) ។

## ២- សាសនាក្នុងសម័យកាលទី ២

ក្នុងសម័យកាលនេះ ពុទ្ធសាសនាថេរវាទចំរើនរុងរឿងនៅឡើយទេ ។ នៅខាងដើមពុទ្ធសតវត្សទី ១២ (គ្រិស្តសតវត្សទី ៧) ពុទ្ធសាសនាលទ្ធិមហាយានបានចូលមកក្នុងប្រទេសកម្ពុជាយើងជាមុនដំបូង ។

## ៣- អក្សរសាស្ត្រក្នុងសម័យកាលទី ២

ក្នុងសម័យកាលនេះ អត្ថបទនៃអក្សរសាស្ត្រ ចិតនៅក្នុងផ្ទៃសិលាដដែល គឺសិលាចារឹកនេះឯង ។

សិលាចារឹកសំខាន់ៗ មាន ៤ កន្លែង គឺ :

BIBLIOTHEQUE ... EXTRÊME ORIENT

ទី ១.– សិលាចារឹកនៅសម្បូណព្រៃគុក (ក្នុងដែនឥសានបុរៈ) ខេត្តកំពង់ធំ សរសេរក្នុង ព.ស. ១១៦៩ (គ.ស. ៦២៦) ក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័ន ទី ១ (១) ។

ទី ២.– សិលាចារឹកនៅភូមិ ខាវកំង ជិតអរញ្ញប្រទេស (ដីខ្មែរពីដើម ប្រទេសសៀមឥឡូវនេះ) ក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី ២ ព.ស. ១១៨២ (គ.ស. ៦៣៩) (២) ។

ទី ៣.– សិលាចារឹក ក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័ន ទី ១ (គ.ស. ៦៥៥·៦៨១) ដែលមានពីរ គឺ:

ក– សិលាចារឹកនៅវត្តព្រៃវៀរ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង (ពីដើមហៅថា ខេត្តបាភ្នំ) ក្នុង ព.ស. ១២០៦ (គ.ស. ៦៦៤) (៣) ។

ខ– សិលាចារឹកនៅវត្តប្រាសាទ ក្នុងស្រុកកំពង់ត្របែក ។ ខេត្តព្រៃវែង ។ លោក Aymonier បញ្ជាក់ថា សិលាចារឹកនេះ សរសេរក្នុងគ្រិស្តសតវត្សរ៍ទី ៦ ឬទី ៧ ហើយសរសេរជាភាសាខ្មែរ ។

---

(១) មើល L. Finot, BEFEO, XXVIII, p. 44.. ;

(២) មើល G. Cœdès, Inscription du Cambodge Vol. V, p. 23.

(៣) មើល A. Barth, Inscription du Cambodge, p. 60...,

(សូមមើលពុទ្ធសាសនា ២៥០០ អត្ថបទព្រះតេជព្រះគុណ ជាំង-ខាត់ ពីទំព័រ ៥៣ ដល់ ៦២)

ទី៤.- សិលាចារឹកនៅប្រាសាទ តាតាំ ក្នុងខេត្តសៀមរាប ព.ស. ១៣៣៤ (គ.ស. ៧៩១) (១) ។

## ៤– លក្ខណៈសិលាចារឹកក្នុងសម័យកាលទី ២

## ទី ១ – សិលាចារឹកនៅសម្បូណ៌ព្រៃគុក

### ក– អត្ថបទ (អត្ថបទនៅទំព័រ ៤០)

ទី ១.- អត្ថបទមួយ នៅមេបញ្ឈរនៃទ្វារ ទិសខាងត្បូង (ហៅ Piédroit sud)

១...រ ជយតិ ស ស្រីប្រហសិ តេ ស្វរស យស្យាង្គ ភាសា
មគនេវ ទ្រុតហេមាម្ភោជ មហី ។

២– ស្រីមតំអវិនីន្ទ្រាណាំ អន្វយាម្វរភាស្វតស មណ្ឌលេ មធ្យម
ស្យាបិ ប្រតាបោ យស្យ ទុស្សហស ។

៣– យស្ម កាន្ត វបុសម ទ្រស្តា វិស្មិតេ ភកវទេវតិស អហោ
នុ មិថ្យា វៃរង្យ វញ្ចិតាស្មិ បិភទ ឥតិ ។

៤– ស្រីត រុណ្យាបរិស្វកត កាម្យរូបោ យុវា បយយ កុត្តាសុ

---

(១) សេចក្ដីបញ្ជាក់ថា សិលាចារឹកមាន ៤ កន្លែងសំខាន់នេះ មិនមែនបានសេចក្ដីថា មានសិលាចារឹកតែ ៤ ប៉ុណ្ណោះទេ ។ ក្នុងសម័យនោះ មានសិលាចារឹកច្រើនជាងនេះទៅទៀត ដែលខ្ញុំមិនអាចនាំយកមករៀបរាប់ទេ ។ ខ្ញុំនឹងធ្វើកាយឈ្មោះបញ្ជីសិលាចារឹកតាំងពីដើមមក កាលណាចប់មេរៀនទាំងអស់ ស្ដីពីសិលាចារឹកនេះ ។

វិទ្វទ្វិទ្យាសុ រក្ត បរិណតាស្វ អបិ ។

៥- ស្វយាំ.. ន. មយិតា បយ័ស ភក្តៃត្យេប យុ... ស្វរិកិស័ ។

៦- រត្នៃរ ឧទន្វាន ឥវយ បរិបូរណោប្យ អនុទ្ធតិស័ បាតា...រ

...ឥបក្សានត្រុតា អបិ មហិក្ខ តំ ។

៧- បរេសំ វិត្តទារេសុ យស្យ ណិកោ នពស្បទស័ ស្ថិត

កេវលម អាចារ សុក្ឫតា តក្តីតិសុ ។ (១)

ទី ២.– អត្ថបទមួយ នៅមេបញ្ឈរនៃទ្វារ ទិសខាងជើង ( ហៅ Piédroit nord )

១៨... មា វិបុស្កាន្តិ...

១៩... ប្រក្ខ តិប្រត្យាយាទេស គុណាវ្ទិទ្យាគមាទ្វិតាស័ សុទិតិ

ស សត្ថ វិទ្យា ច បទ...យស្យ... ។

២០.. យ. .យោ...យ ឲ្យតា ស្វវិញ ជិគីសុណាយេន និរ្ឃ·

ជិតស័ សក្រវរណ័ស(២) . . . . .

## ខ- សេចក្ដីប្រែ

ទី ១.– ជ័យជំនះ មានដល់ព្រះស្រីប្រហសិតេស្វរដែលមានព្រះកាយក្ដី

គឺព្រះធរណី ដែលឋិតនៅក្នុងសាគរទឹកមាស ។

---

(១) អត្ថបទនេះនៅក្នុង ( Inscriptiou du Cambodge ) របស់ G. Cœdès T. 4 page 7 មានដល់ទៅ ១៧ វគ្គ ស្រង់សំរួលមកបង្ហាញជាពាង ។

(២) T. 4 page 8 មានដល់ទៅ ១៧ វគ្គដែរ គឺពីវគ្គទី ១៨ ដល់ ៣៤ ។

អំពីព្រះពាជា ដែលជាព្រះអាទិត្យនៃវេហាស៍នេះ គឺព្រះវង្ស នៃមហាក្សត្រ ជាទីគោរពលើកពផែនដីចេញមកអំពីចំហាយ ដែលពុំអាចអត់ធុនបាន ពោះបី ព្រះអង្គសណ្ឋិតនៅព្យាក កណ្តាលវង្គពាំងឡាយរបស់ទ្រង់ក្តី ។

– ដោយយល់ឃើញនូវព្រះកាយ យ៉ាងល្អស្រស់ ព្រះតេក្លាក់ស្មារតី ហើយបន្ទឹថា " ពិតណាស់ខ្ញុំយល់ខុសសោះ ជាអំពីកាលមុន ខ្ញុំស្មានថាខ្លួន មេម៉ាយសោះ " ។

– ពិតមែនតែទ្រង់នៅក្មេង ប្រកបដោយព្រះចំណង់ តែសោកណាភាពនៃយុវវ័យ មិនអាចផ្ទឹមនឹងព្រះអង្គបានឡើយ ។ ព្រះអង្គសព្វព្រះទ័យតែនូវវិទ្យាសាស្ត្រជ្រៅជ្រះ ហើយដែលមានតែប៉ុណ្ណោះទើបយល់បាន ។

. . . . . . . . . . . .

– ពិតមែនតែទ្រង់ប្រកបដោយអលង្ការ ដូចជាទំហំនៃសាគរ.. ព្រះកដិ ពោះបីរបស់ព្រះពាជានៃបពិតកំបរិបូណ៌ ដូច្នោះដែរ ។

– ព្រះរូបនោមព្រះអង្គ ពុំមានស្ត្រីឯណាមួយ ឬមនុស្សផ្សេងៗ ប្រៀបប្រដូចបានឡើយ ។ ព្រះរូបនេះមានពិសេសតែចំពោះទ្រង់ គឺចំពោះព្រះអាកប្បកិរិយា ព្រះសគម្ភភាពដ៏ល្អ... និងព្រះចេស្តាព្រះអង្គ ។

ទី ២.–

– លំអរបស់ទ្រង់រកអ្វីផ្ទឹមគ្មានទេ

– បរិបូណ៌ទៅដោយចំណេះវិជ្ជា សម្រាប់គ្រប់គ្រងវដ្តពេញពោរ ទៅដោយការពិសោធន៍ ការប្រុងប្រយ័ត្ន មានគុណធម៌ បូរណ-ភាព ចំណេះវិជ្ជាបូរមបូរាណ និងវិជ្ជាតខាងនយោបាយ និង វេយ្យាករណ៍ ។ . . . . . .

– . . . ព្រះរាជាអង្គនេះ សម្បូរមទឹងទទួលនូវឋានសួគ៌ ទ្រង់បានឈ្នះដំរីព្វកវណរបស់ព្រះឥន្ទ្រ ។ (១)

## គ– អត្ថបទដទៃទៀត

ក្រៅពីសិលាចារឹកនៅនាមេទ្វារបញ្ឈរទាំងពីរ ទិសខាងត្បូង និងខាងជើងនេះ នៅមានសិលាចារឹក ៤ ទៀតនៅនាកម្រាលមណ្ឌប= dalle du mandapa នៃប្រាសាទហោត្រៃខាងត្បូង នៃទ្វារចូលខាងលិចឋិតនៅក្នុងកំពែងក្រៅផ្នែកខាងត្បូងដែលសរសេរជាភាសាសំស្ក្រឹតដែរនៅមេបញ្ឈរខាងត្បូងនៃប្រាសាទមុខ (la tour F) ដែលសរសើរអំពីព្រះបារមីព្រះបាទឥសានវរ្ម័ន ចាប់ពីវគ្គទី២ ដល់ទី៦, សិលាចារឹកផ្សេងៗ នៅក្នុងពួក S. ; នៅមេបញ្ឈរខាងត្បូង នៃទ្វារខាងកើត ក្នុងកំពែងខាងក្រៅផ្នែកខាងជើង ដែលសរសើរបារមីព្រះឥស្វរ ព្រះនីលកណ្ឋ, ព្រះវិស្ណុបង្កជនាក

(១) សេចក្តីប្រែនេះមានវែងទាំង ៣៤ វគ្គនៃមេទ្វារខាងត្បូងនិងខាងជើង ។

និងព្រះព្រហ្ម ហើយទឹងសរសើរអំពីព្រះបាទពជេន្ទ្រវរ្ម័ន ចាប់ពីវគ្គទី ១៥ ដល់ទី ១៣, នៅមេបញ្ជរនៃប្រាសាទខាងជើង គេសរសេរដោយអក្សរ ក្នុងសតវត្សទី ៧ ជាភាសាសំស្ក្រឹតនិយាយពីព្រះបារមីរបស់ព្រះបាទឥសានវរ្ម័នទី ១ ប្រកបដោយព្រះបរមនាមថា សាការមញ្ជរី, នៅមេបញ្ជរនៃបង្អួចខាងត្បូងនៃប្រាសាទខាងជើង សរសេរជាភាសាខ្មែរ សរសើរអំពីតេជះរបស់ព្រះបាទភវវរ្ម័នទី ១, ព្រះបាទមហេន្ទ្រវរ្ម័ន និងព្រះបាទឥសានវរ្ម័នដែលទ្រង់បូជាទាសៈ បំពោះព្រះអាទិទេពគ្រួស្ម័រៈ ដោយព្រះអាចារ្យមានគោរម្យងាវជា ព្រះកម្រតាញ, នៅមេបញ្ជរនៃប្រាសាទខាងជើងដែលនិយាយអំពីរជ្ជកាលព្រះបាទភវវរ្ម័នទី ២, នៅមេបញ្ជរនៃផ្នែកខាងត្បូងប្រាសាទខាងជើងជាដើម ។

## ឃ- អត្ថន័យទូទៅ

បើពិនិត្យមើលន័យសេចក្តីនៃសិលាចារឹកទាំងឡាយ នៅសម្បូណ៌ព្រៃគុកនេះ យើងអាចយល់បានថា ក្នុងសម័យសតវត្សទី៧ នៃគ្រិស្តសករាជជំនឿរបស់ខេមរជន គឺមានចំពោះព្រះសិវៈ (ឥស្សរព្រះវិស្ណុ ព្រះព្រហ្មជាដើម) ។ ឯព្រះពុទ្ធសាសនាក្នុងសម័យនោះ ក៏មានឥទ្ធិពលណាស់ដែរ ។ គេគោរពនាគរាជមុចលិន្ទដែលគ្របដណ្តប់ជាមួយចំពោះព្រះពុទ្ធ ។ គេនិយាយពីព្រាហ្មណ៍រាជបុរោហិតឈ្មោះ បសុបតិ= pasupati មានងារជា

វិទ្យាវិសេសៈ ជាអ្នកប្រាជ្ញចេះដឹងវិជ្ជាជ្រៅជ្រះ ចេះអច្ឆ័ន គឺវិជ្ជាសាស្ត្រ ខាងក្បួនវេយ្យាករណ៍ ចេះវិជ្ជាខាងវៃសេសិកៈ ន្យាយៈ សមីក្ស ឬ សំខ្យាក្នុងព្រហ្មញ្ញទ្រឹស្តី ព្រមទាំងវិជ្ជាក្នុងពុទ្ធសាសនាថែមទៀត ។

ដទៃពីការបញ្ជាក់នូវជំនឿ សិលាចារឹកបានរំលឹកអំពីរូបសម្ផស្ស សោភណភាពខាងកងកាយរបស់ព្រះរាជា ព្រមទាំងតេជៈបារមី និងព្រះជំនឿរបស់ព្រះបាទភវវរ្ម័ន ឥសានវរ្ម័ន មហេន្ទ្រវរ្ម័ន ដែលបានឲ្យកសាងរាជនិវេសនស្ថាន សក្ការបាន មានរូបសំណាក ទេវៈ ពុទ្ធរូបសម្រាប់បូជាជាដើម ។

ក្នុងសម័យកាលនោះ មនុស្សមានចំណេះចេះដឹងខាងវិជ្ជាផ្លូវលោក និងផ្លូវធម៌ច្បាស់លាស់ណាស់ ។ ការរស់នៅប្រកបដោយរបៀបរបប មានសម្ភារៈប្រើប្រាស់បរិបូណ៌ ដោយសារមានឃើញការរៀបរាប់អំពីគង្វាយផ្សេង ៗ របស់ព្រះមហាក្សត្រចំពោះទេវរូបឬពុទ្ធរូប មានទាំងសត្វពាហនៈផង ដូចជាគោក្របីជាដើម ។

## ៦- យោបល់រួម

ដូចសេចក្តីរៀបរាប់មកហើយខាងលើ សិលាចារឹកនៅសម្បូណ៌ព្រៃគុក ( គ.ស. ៦២៦ ) មានចំនួនដល់ទៅ ១៧ គឺ៖

ផ្នែកកណ្តាល ហៅ groupe central ( C ) រកមិនទាន់ឃើញ,

(នៅមានត)

# រឿង ចៅតែលលក

សហ. ព្រួច - កុម

រៀបរៀងតាមការនិទានត ៗ មក

[ក]

— ខ្មោច មានម្រាមដៃមិនគ្រប់ ១០ ទេ, ចូរមើលម្រាមដៃខ្ញុំ ។

ភ្នែកខ្មោច គ្មានប្រស្រីខ្មៅទេ មានតែប្រស្រីសព្រាតទាំងអស់ ។

— ខ្មោច តែកាលណាហាមាត់និយាយ មានពន្លឺក្នុងមាត់ ។

— ខ្មោច ដើរទៅណាមកពីណា គ្មានស្រមោលចោលចេញពីខ្លួន មិនប្រាកដ ទីងស្មានថាជាអ្វីក៏មិត្រូវដែរ ។

- ខ្មោច បើចង់ឲ្យឃើញក៏ឃើញ បើចង់ឲ្យបាត់ក៏បាត់ភ្លាម ហើយអាចកាឡាខ្លួនជាអ្វី ៗ បាន តាមសេចក្ដីត្រូវការ ។

- ខ្មោច មិនប្រាកដពីត្រឹមក្បាលជង្គង់ចុះទៅក្រោម, ប្រាកដបានខ្លះតែពីត្រឹមលើជង្គង់ឡើងទៅលើ, មើលទៅហាក់ដូចជាខ្មោចដើរនឹងជើង ប៉ុន្តែជើងខ្មោចមិនដិតជាប់ដល់ដី ដូចជាមនុស្សនោះទេ ។

— ខ្មោច មានរូបមិនប្រាកដ ចាប់ពាល់មិនត្រូវ ដូចជាគេចាប់ស្រមោល ។

— ខ្មោច មានរិទ្ធិខ្លាំងពូកែណាស់, ប៉ុន្តែខ្មោចនៅគោកម្ពុ ១ អាចឲ្យមនុស្សបញ្ឆោតបានងាយ ៗ, តែថា រឿងគោកនេះ ខ្ញុំឈ្មោះតូច

មិនជាធោតផ្ដេសផ្ដាស ដូចអស់ទាំងខ្មោចគេទេ ព្រោះខ្ញុំចេះដឹងច្រើន ។

ក្នុងនោះ មាណពឲ្យខ្មោចតូចសម្ដែងរិទ្ធិលមើល, តូចចាប់សម្ដែងរិទ្ធិកាឡាជាសត្វផ្សេងៗ ជាមនុស្ស ជាអ្វីៗ ជាច្រើនបែបប្លែកៗ, ជាដើម ខ្មោចតូច កំពុងឈរនិយាយ ស្រាប់តែបាត់, លេចឯដុំថ្ម ១ ដុំ រមៀលត្រឡប់តុបមកឈប់ស្ងៀម ចេញផ្សែងផ្កាង ចេញជាដុំភ្លើងប៉ុនផ្លូតដៃ ហើររ៉ើ លាន់សម្ដែងវ៉ឺ ទៅធ្លាក់នៅជ្រុងចំការខាងកើត ផ្សែងនោះហុយ ជ្រួបកំពស់ចុងត្នោតលៃ លេចមនុស្សម្នាក់កំពស់ដុំផ្សែង ខ្មៅកក្វាក់ ខ្លួនធំស្ដឹង ដៃជើងមាំ ៗ ធ្មេញប៉ុនៗចបកាប់ បបូរមាត់ស្ដោះកំប៉ើញៗ ស្នេញ គ្រាប់ភ្នែកលៀនត្លិលសព្រាតប៉ុនៗគង សក់ក្រញាញ់ដូចឫសឫស្សី ស្បែកកំពកកំព្លួ ដើរគរឃ្មើនគឃ្លាក់ចូលមក, មាណពគិតជាក់មេផាយកយកែងជូនខ្មោចតូច តែខ្មោចឃាត់ទាន់ថា "កុំខ្លាចៗ" រួចហើយកាឡាបង្រួមធ្វើខ្លួនឲ្យល្អជាឡើងវិញ ដើរចូលមក ល្មមឲ្យស្គាល់ថាខ្មោចតូចបាន ហើយនិយាយថា "ឃើញទេ! អម្បាញ់មិញ? ហ្នឹងហើយដែលហៅថា ខ្មោច" រួចក៏ចាប់បង្ហាញល្បិចកិច្ចការខ្វះៗទៀត ឲ្យមាណពចេះដឹង មានប្រាប់ឲ្យសំគាល់អ្វីផ្សេងៗ និងឧបកិច្ចជាដើមថា :

– សំគាល់ព្រះឥន្ទ្រទេព្ដា : ព្រះឥន្ទ្រទេព្ដា បើធ្វើការ មិនចេះបែកញើស មិនចេះហត់អស់កម្លាំង ឥតចេះតក់ស្លុតរន្ធត់ខ្លាច ឥតប៉ប្រិចភ្នែក និង ឥតមានស្រមោល ។

– សំគាល់យក្ស ៖ យក្សមិនប៉ប្រិចភ្នែក មានភ្នែកក្រហមដូចភ្លើង គ្មានប្រស្រីខ្មៅ ឥតបេះស្លៀសខ្លួន គ្មានស្រមោល និង មិនបេះអាណិតអាសូរអ្នកណា ។

– សំគាល់ក្បាលខ្មោចមនុស្ស ៖ ថ្ងាសលាដ៍ក្បាលខ្មោចមនុស្សប្រុសត្រង់ ។ ថ្ងាសលាដ៍ក្បាលខ្មោចមនុស្សស្រីវៀចវេរវិលក្រវិចក្រវក់ ។

– សំគាល់ពស់ញីឈ្មោល ៖ ពស់ឈ្មោល មានចុងកន្ទុយកន្ទេល ក្បាលក្រាស់ក្រម៉ប ភ្នែកធំៗសង្ហារធ្មេចអន្ទាយ ។ ពស់ញី កន្ទុយឆ្មារវៀវ ក្បាលស្តើងកន្ទ្រឹម ភ្នែកតូចៗ សង្ហារធ្មេចកំបុត ។

– បើស្រីពីរនាក់ដណ្តើមក្មេងគ្នា ៖ ចង់ដឹងថា ណាម៉ែមែន ណាមិនមែន ឲ្យគូសវង់មូលមួយ យកកូនដាក់កណ្តាល ឲ្យដណ្តើមគ្នា ដោយកុំឲ្យដឹងខ្លួន, ប្រាប់ថា អ្នកណាឈ្នះបានកូន គឺជាកូនអ្នកនោះ, ប៉ុន្តែអ្នកឈ្នះនោះមិនមែនម៉ែពិតទេ ព្រោះគ្មានមេត្តាដូចម៉ែពិត ពឹតតែដណ្តើមយកឈ្នះដៃ ។

– ឧបកិច្ចផ្សេងៗ ៖ បើភ្នែក ខ្វង់ ប្រមង់ ធាបធក់អ្វីៗ យើង ហើយចង់បានវិញ ត្រូវតាំងចិត្តថា និងយកវិញឲ្យបាន កុំងើបមើលលើឲ្យសោះ មើលតែស្រមោលវា ស្ទុះឲ្យលឿនទៅជាន់ស្រមោលទះដៃឲ្យខ្លាំងៗ វានឹងទម្លាក់ឲ្យវិញហើយ ។

–

– ឧបក្រិច្ចបណ្ដេញខ្មោច : បើខ្មោចចូល ត្រូវល្បួង បញ្ឆោតពីនេះពីនោះ បន្ទាចទីងរបស់ណាដែលវាខ្លាច ពន្យួរចុះឡើង វាទីងខ្លាចចេញរត់ទៅបាត់ហើយ ។

– តម្រាដើរព្រៃ : បើដើរព្រៃទៅហើយវង្វេងរកទិសមិនឃើញអស់ពេញមួយថ្ងៃ ពួកមនុស្សនិងខ្មោចពីបុរាណធ្លាប់និយមសំគាល់មក គឺនៅពេលយប់នោះ ត្រូវស្ទាបគល់ឈើមើល បើខាងណាក្ដៅខ្លាំងជាង គឺខាងនោះហើយជាទិសខាងលិច ។ បើស្ទាបឈើទៅហើយមិនដឹងត្រជាក់ក្ដៅទេ ឲ្យរកមើលវល្លិ៍ព័ទ្ធ, វល្លិ៍តែងព័ទ្ធតែទៅខាងស្ដាំ ចុងត្រួយវល្លិ៍តែងវិលមួយជុំមកនៅទិសខាងកើតជានិច្ច, ខ្មោច ដើររកស៊ីមិនចេះវង្វេងទេ ព្រោះបានតម្រានេះគ្រាន់ទីងចំណាំ ។

លុះខ្មោចតូច ប្រាប់ដូច្នោះជាដើមរួចហើយ ក៏និយាយថា ខ្មោចមិនចេះធ្វើផ្ទះនៅទេ អាស្រ័យនៅតែទីងទីផ្សេង ៗ ដូចជាព្រៃព្រឹក្សាជំបូកជាដើម, ដូច្នេះ នៅពេលព្រឹកនេះ ចូរអ្នកដើរតាមសរសៃអម្បោះដែលហៅថា អម្បោះខ្មោច ដែលយើងបង្ហូតទុកឲ្យឯងដើរទៅ, បើដើរទៅផុតត្រឹមណា ត្រង់នោះជាទីផ្ទះរបស់ខ្ញុំហើយ ត្រូវស្រែកហៅ យើងនឹងឆ្លើយ ហៅអ្នកឲ្យចូលទៅ ។ នៃសម្លាញ់ រឿងដែលខ្ញុំប្រាប់អ្នកទាំងប៉ុន្មាននេះ មិនសូវមានខនរណាចេះដឹងទេ មានតែពួកអ្នកប្រាជ្ញទើបចេះដឹងច្រើនជាងនេះទៅទៀត ។ មាណពចំកត់សំគាល់តាមដែល

ខ្មោចតូចនិយាយប្រាប់ដោយសព្វគ្រប់, លុះព្រឹកឡើង ក៏ដើរទៅតាមខ្សែអម្បោះដែលខ្មោចបង្ហាត់ទុកឲ្យ ដើរទៅលុះដល់ដំបូក ក៏ផុតអស់ខ្សែអម្បោះ ទើបស្រែកហៅថា "អឺបងតូចសម្លាញ់!" តូច ធ្វើយ កូក ! ពីក្នុងដំបូកមក ហើយហៅមាណពឲ្យចូលតាមប្រហោងដីតូចមួយប៉ុនរន្ធចង្រិត, ពេលនោះមាណពចូលមិនបាន ព្រោះរន្ធនោះតូចពេក គ្រាន់តែឈ្ងោកមើលទៅ ឃើញខ្មោចតូចនិងប្រពន្ធកូនគេនៅក្នុងនោះរង្វើយ, លុះតែខ្មោចតូចចេញមកដឹកដៃនាំចូល ទើបបានចូលទៅកើត ៗ លុះចូលទៅដល់ហើយ ខ្មោចតូចប្រាប់ប្រពន្ធឲ្យសំពះសួរទទួលស្គាល់មាណព ឲ្យចេះស្រឡាញ់រាប់អានគ្នាតទៅ, និយាយសំណេះសំណាលបន្តិច ក៏នាំមាណពដើរមើលក្នុងផ្ទះដំបូកគេនោះ ទាំងបាននិយាយប្រាប់មាណពបណ្ដើរថា ចូរសម្លាញ់មើលចុះ សម្បត្តិទ្រព្យមានច្រើនគ្មានខ្វះអ្វីទេ មានធ្នាំង ចានកាំបិត ពូថៅ មាស ពេជ្រជាដើមនេះ, នែសម្លាញ់ ដែលខ្ញុំឲ្យឯងមកនេះ គឺខ្ញុំចង់ផ្ទេររបស់ទាំងអស់នេះឲ្យអ្នក ដោយខ្ញុំយល់ថា អ្នកជាម្ចាស់នៃទ្រព្យនេះ ហើយទ្រព្យរបស់អស់ទាំងនេះ ពិតជារបស់អ្នកឯងហើយ ព្រោះកាលស្ដេចខ្មោចចាត់ខ្ញុំឲ្យមកនៅចាំរក្សា បានផ្ដាំថាឲ្យចាំដរាបដល់មានមនុស្សណាមួយមកដល់នៅក្នុងទីនេះ អ្នកនោះជាមនុស្សកំព្រាអនាថា រស់នៅដោយសារតែលលក គ្មានឈ្មោះ ហើយស្ដេចខ្មោច

បានតាំងសន្មតឈ្មោះទុកឲ្យផងថា “ទៅតែលលក”, ឯខ្ញុំនេះ ក៏នឹងត្រូវបានរួចវេនអស់កម្មពៀរ ឈប់ធ្វើខ្មោចចាំយាមត្រឹមនេះដែរ នឹងទៅកេចាប់កំណើតកើតនឹងគេជាមនុស្សវិញហើយ, ដូច្នេះ ចូរអ្នកទទួលយកទៅចុះ ។ ទៅមាណព គិតឃើញថា ខ្លួនអញនេះ មកនៅក្នុងព្រៃតែម្នាក់ឯង ឥតញាតិមិត្រសាច់សាលោហិត ទ័លក្រខ្លាំងណាស់, ណាមួយនឹកថា ខ្លួននេះ តាំងពីកើតមកមិនដែលមានឈ្មោះថាអ្វី ស្រាប់តែត្រូវខ្មោចតូចដាក់ឈ្មោះថា “ទៅតែលលក” ឲ្យដូច្នោះ ក៏នឹកគួរឲ្យចង់សើចព្រោះសមរម្យនឹងជីវភាពរបស់ខ្លួនហើយ ។ វាត្រេកអរណាស់នឹងឈ្មោះនោះណាស់, តែនៅមានគិតថា ក្រែងគេឯណា ទេឬ ដែលឈ្មោះ ទៅតែលលក, ប៉ុន្តែដល់នឹក ៗ ទៅ ឃើញថា គ្មាននរណាក្រៅពីអញនេះទៀតទេ ព្រោះខ្មោចតូចនេះគេដឹងណាស់ គេមិនដែលថាផ្ដេសផ្ដាស, បើអ៊ីចឹងមែននោះ អញមានលាភធំហើយពេលនេះ, សម្បត្តិប៉ុណ្ណោះបើនឹងចង់ធ្វើសេដ្ឋីក៏បាន, តែទាស់បន្តិច ឯងធ្លាប់តែក្រ បើនឹងយករបស់ទ្រព្យទាំងនេះក្វាមទៅ មិនដឹងជានឹងយកទៅទុកឯណា, ម៉្យាងទៀតខ្លាចក្រែងមានអ្នកណាមួយមកដល់ តែគេឃើញហើយ គេនឹងប្លន់យកអស់, ទើបនិយាយទៅកាន់ខ្មោចតូចថា - បងតូចសម្លាញ់! ខ្ញុំមានចិត្តត្រេកអរណាស់ ដែលបងថានឹងប្រគល់ទ្រព្យរបស់ឲ្យនេះ ខ្ញុំព្រមទទួលយកដោយសោមនស្សគ្មានប្រកែកអ្វីឡើយ, ហើយគុណបងមានមកលើរូប

ខ្ញុំ ធំណាស់ រកអ្វីប្រៀបស្មើពុំបានទេ, តែថា រូបខ្ញុំនេះ ដូចជាបងឃើញនឹងភ្នែកស្រាប់ហើយ មានតែខ្លួន នឹងកូនខ្ទមកំព្រកតូចមួយ នឹងយកទ្រព្យរបស់អស់នេះទៅទុកមិនមានកើតទេ ឲ្យខ្ញុំសុំផ្ញើទុកនឹងបងនេះសិន បើកាលណាខ្ញុំមានការខ្វះខាតអ្វី សឹមខ្ញុំមកយកទៅប្រើប្រាស់, ឯបងទៀតសោត ក៏កុំអាលទៅណាចោលខ្ញុំ ត្រូវនៅនេះសិន គ្រាន់បានជាគ្នា ជួយមើលសុខទុក្ខខ្ញុំផង, ខ្លាចតូច ក៏យល់ស្របតាមថា អើ! ហើយនិយាយគ្នាលេងយ៉ាងស្និទ្ធស្នាលប្លែកអំពីមុន ដោយចិត្តស្មោះស្ម័គ្រអស់ពីចិត្ត, និយាយគ្នាលេងយូរហើយ មាណពក៏លាត្រឡប់វិញ, តូចព្រមទាំងប្រពន្ធកូន ជូនដំណើររហូតផុតចេញពីដំបូក ។ ចាប់ពីពេលនោះមក គេស្និទ្ធស្នាលទៅមករកគ្នាញឹកញាប់ជានិច្ចកាលណាស់ ទៅណាមកពីណា តែងតែទៅមកជាមួយគ្នា, ការណ៍ណា ដែលចៅកែលលកមិនចេះ មិនដឹង មិនយល់ ខ្លាចតូចតែងប្រាប់បង្ហាញដោយស្មោះឥតមានលាក់លៀមអ្វីសោះឡើយ ។

សម័យមួយ ពេលព្រឹកព្រហាមស្រាងៗ ចៅកែលលក ភ្ញាក់ពីដំណេក ស្ពាយបំពង់ទឹកមួយនៅស្មា ដៃកាន់កាំបិត ចេញទៅបឹង ដើម្បីលើកលប ដោះអន្ទាក់, លុះទៅជិតដល់កន្លែងដាក់អន្ទាក់ ស្រាប់តែឮខ្លាស្រែករំពងព្រៃ លាន់ព្រៃប្រាកប្រាវៗ មើលទៅឃើញអន្ទាក់រក់រើក ងើក ៗ, នុះ គឺជាស្តេចខ្លាធំមួយ ស្វែងរកចាប់សត្វជាអាហារ មក

ដាច់អន្ទាក់តាំងពីពេលពាក់កណ្ដាលអធ្រាត្រ ពោះចំបម្រះបណ្ដាច់អន្ទាក់អស់ទំហឹងយ៉ាងណា ក៏ពុំរួចសោះ, មាណពឃើញដូច្នោះហើយ ដើរលបៗចូលទៅមើល ដឹងជាក់ជាខ្លាជាប់ ក៏តាំងរកបានព្រនង់មួយយ៉ាងមាំ ដើរអន្ទម ៗ ញើប ៗ ចូលទៅម្ដងទៀត នឹងសំពង់ខ្លាសម្លាប់ បន្ទឹសម្ដែងថា «អៃយ៉ា អាគ្រហលេច ! អញរកតែមុខអានេះជាយូរថ្ងៃហើយ ថ្ងៃនេះអញអាឯងដល់ហើយ អានឹងត្រូវព្រនង់នេះឥឡូវ អញផ្ដាច់អាយុអាម្ដងហ្នឹង, អន្ទាក់នេះអញដាក់យកសត្វដទៃសោះទេ ម្ដេចក៏អាឯងមកជាប់» ថាហើយក៏យារព្រនង់ជាប ប្រុងនឹងសំពង ៗ ខ្លាឮសំដីមាណពគម្រាម ហើយយារព្រនង់នឹងសំពង់ដូច្នោះ គិតថា - ឱជីវិតអញ ! នឹងក្ស័យឥឡូវនេះមិនខានហើយ, ទើបប្រញាប់និយាយអង្វរសុំជីវិតថា ឱលោកម្ចាស់អើយ ! សូមលោកអាណិតមេត្តាទុកជីវិតខ្ញុំ កុំអាលធ្វើទុកបុកម្នេញខ្ញុំភាម ចាំខ្ញុំនិយាយរឿងមួយឲ្យលោកម្ចាស់ថ្ងៃបានដឹង, ហើយខ្លានិយាយប្រាប់ជាបន្ទាន់នោះថា ខ្ញុំនេះជាខ្លា ជាតិសត្វតិរច្ឆានក៏ពិតមែន ប៉ុន្តែពុំមែនជាខ្លាសាមញ្ញដូចអស់ទាំងខ្លាផ្ដេសផ្ដាសទេ គឺជាស្ដេចខ្លា មានឫទ្ធិអំណាចលើខ្លានានានិងសត្វចតុប្បទគ្រប់ប្រភេទ, សព្វថ្ងៃខ្ញុំរស់នៅដោយមានខ្មោចព្រាយធំៗព្រមទាំងពួកម្រេញគង្វាលតាមរក្សាជានិច្ច បើចង់តំណែងកាឡាខ្លួនជាសត្វចតុប្បាទណាមួយដូចជា គោ ក្របី ជ្រូក ប្រើស ទ្រាយ ក៏បានដូចចិត្ត, ឲ្យតែលោកដោះលែងខ្ញុំចុះ ខ្ញុំនឹងសំដែងរិទ្ធិជូនមើលឥឡូវក៏បាន,

ថ្ងៃនេះ ខ្ញុំចេញដើរត្រូវលើកសីផុតសូន្យ បានជាមកប្រទះនឹងគ្រោះនាមក្តាមខ្យងដូច្នេះ, លោកអើយ ! បើលោកមេត្តាទុកជីវិតខ្ញុំ ខ្ញុំសូមធ្វើសច្ចាសន្យាថា នឹងបម្រើលោកអស់មួយជីវិត តាមដែលលោកត្រូវការប្រើ, ចំណែករូបលោកសោត ក៏មិនមែនសុទ្ធតែបានសុខជានិច្ចនោះទេ លែងអីនឹងមានទុក្ខ, បើកាលណា លោកមានទុក្ខអ្វី គ្រាន់តែនឹកទៅដល់ខ្ញុំៗនឹងមកដល់ជួយយកអាសាលោកភ្លាម សូមលោកជឿទុកចិត្តចុះ ។ ចៅតែលលកថា អញមិនទុកចិត្តអាកំណាចឯងទេ អាឯងចេះតែនិយាយឲ្យតែរួចពីមាត់ ឲ្យតែបានរួចខ្លួន គ្មានទៅស្មោះត្រង់អ្វីទេ ព្រោះអាឯងនេះ សាហាវខ្លាំងណាស់ អញលែងពុំទាន់បានទេ ។ កំពុងតែជជែកនឹងខ្លា ទទួលខ្មោចតូចដឹងហើយបានទៅដល់ភ្លាម ខ្សឹបប្រាប់ថា មិនអីទេ លែងវាទៅចុះ ប៉ុន្តែ ត្រូវឲ្យវាកាឡាខ្លួន ឲ្យយើងមើលឥឡូវ, ទើបចៅតែលលកប្រថុយចូលទៅកាត់ខ្សែអន្ទាក់តាំងគិតភ័យប៉ផ្អុក ហើយប្រុងស្មារតីយ៉ាងខ្ជាប់ផង ប្រាប់ថា ចូរឯងសម្តែងរិទ្ធិឲ្យអញមើលឥឡូវនេះកុំខាន, ស្តេចខ្លានោះ បានរួចខ្លួនពីសេចក្តីស្លាប់ហើយ ក៏សម្តែងសេចក្តីស្មោះត្រង់ម្តងទៀត ហើយចាប់ថ្លែងរិទ្ធិផ្សេងៗឲ្យគេមើល រួចលាចៅតែលលកចូលព្រៃទៅរកស៊ីតាមប្រក្រតី តាំងចិត្តថា នឹងមិនបំភ្លេចគុណគេចោលទេ ។

ចៅតែលលក បន្តដំណើរចុះទៅបឹងលើកលបយកត្រី ជាមួយនឹងខ្មោចតូចផង, ដល់កន្លែងដាក់លប ស្រាប់តែឃើញសត្វចតុប្បាទមួយ

មុខស្រួចថ្លឹម ជើងខ្លីៗ សម្បុរត្នោត ស្រដៀងនឹងសត្វកំប្រុក តែមើលទៅមាឌធំជាងកំប្រុក, ខ្មោចតូច ស្រែកប្រាប់ថា គ្នាយើងស្ការជ.ប់លប ទើបវាស្គាល់ថានោះជាសត្វស្ការ ហើយលើកលបមើលទៅមិនឃើញមានត្រីមួយសោះ វាខឹងណាស់នឹងស្ការដែលគ្នាកំពុងបម្រះខ្វិលៗក្នុងលបនោះ ថាស៊ីត្រីវាអស់ ក៏ទាញព្រនង់ប្រុងនឹងសម្លាប់, ប៉ុន្តនៅពេលនោះ ស្ការនិយាយអង្វរសុំទោសទាន់តាមទំនងដូចជាខ្លាដែរថា សុំលោកអត់ទោសខ្ញុំជាស្តេចស្ការ អាចបេះកាឡាខ្លួនធ្វើជាសត្វបក្សផ្សេងៗ បានគ្រប់បែបបើលោកដោះលែងខ្ញុំឲ្យរួចជីវិតហើយ ខ្ញុំនឹងធ្វើបង្ហាញ ហើយបើពេលណាលោកមានទុក្ខធុរៈ ខ្ញុំនឹងមកជួយ ។ ចៅតែលលកបែរមកសួរខ្មោចតូចៗ ដឹងថា ពិតដូចស្ការថានោះមែន ទើបប្រាប់ថាឲ្យលែងវាទៅចុះ ។ ចៅតែលលកលែងស្ការៗ ក៏សម្តែងរិទ្ធិប្លែកៗ ហើយលាទៅរកស៊ីតាមសេចក្តីសុខតទៅ តាំងបានផ្តាំថា បើកាលណាខ្ញុំមានធុរៈ ខ្ញុំនឹករក ត្រូវមកភ្លាម ៗ ថ្ងៃនេះគេគ្មានបានអ្វីដូចសព្វថ្ងៃទេ ទើបគេដងទឹកត្រឡប់មកខ្ទមវិញ រួចចេញទៅថែចំការដូចប្រក្រតី ។

ព្រឹកស្អែកឡើង គេទៅបិងជាមួយខ្មោចតូចដូចទម្លាប់មុន ៗ មើលអន្ទាក់រួចចុះទៅលើកលប ស្រាប់តែប្រទះនឹងពស់មួយធំសម្បើមជាប់ក្នុងលប វាកាន់តែខឹងខ្លាំងជាងមុន ៗ ស្ទុះធ្វើថ្នារកវៀងនឹងសម្លាប់ពស់នោះ, តែពេលនោះ ពស់និយាយអង្វរហួរហែសុំរួចជីវិត មានទំនងដូចខ្លានិង

(នៅមានត)

# ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត

ដែលមាននៅពុទ្ធសាសនបណ្ឌិត្យ

លោកញ៉ុក-ថែម រៀបរៀង

---

(គ)

ចំណងជើង: " សាស្ត្រា ច្បាប់រាជបណ្ឌិត "(១)

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ បទព្រហ្មគីតិ ។

ប្រភពរឿង: ច្បាប់ទូន្មានកូនចៅ តាមប្រពៃណីពីបុរាណ ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១០ សន្លឹក ។ ឯកសារនេះប្រហែលពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តវេឡុការាម ចុះលេខសាស្ត្រា ១.៣៧៨។

អត្ថបទផ្ដើម: ៙ នេះបទព្រហ្មគីតិ ។ សារសព្វច្បាប់ព្រេងព្រឹទ្ធ ដោយសុចរិតនាមា ចៅក្រមរាជសុភា ជាទំនឹម

---

១– ច្បាប់នេះ មានខ្លឹមសារ ស្របតាមប្រពៃណី ជាតិទាំងដើមកាព្យ ទាំងពាក្យពេចន៍ មិនសូវមានកក់ ក្តាំក្តុងអ្វីដែរ ។

ទំនៀមនៃ ៗ ខ្ញុំប្រាជ្ញប្រែពាក្យពិត ក្នុងសុចរិត
ធម៌ប្រពៃ ឈ្មោះរាជបណ្ឌិតថ្លៃ វៃវាងឆ្លាស់អស់
អាចិ ៗ ទុកតឲ្យអស់ជន ស្តាប់យកបុណ្យគ្រប់
អាត្មា ឲ្យគិតពិចារណា តាមតម្រាច្បាប់ប្រពៃ ៗ

. . . . . ។ល។

អត្ថបទបញ្ចប់: ឲ្យចាំជាក់ក្នុងប្រាណ គ្រាន់ទូន្មានខ្លួនយប់ព្រឹក
បើក្មេងឲ្យរំលឹក ពាក្យអាពុកម្តាយប្រដៅ ៗ មិនតែ
អាពុកម្តាយ គ្រូបាធ្យាយក្រែងថាខ្លៅ អ្នកប្រាជ្ញ
ទៀតបេះប្រៅ ចងជាច្បាប់ទុកតមក ៗ ប្រដៅ
យើងគ្រប់គ្នា ឲ្យឧស្សាហ៍ខំរិះរក រៀនច្បាប់ចាំ
ចាប់យក ជាពន្លកពន្លឺខ្លួន ៗ អ្នកណាបើបានស្តាប់
គ្រេកគ្រងគ្រាប់ទុកជាក្បួន អ្នកនោះនឹងនាំខ្លួន
ឲ្យបានសុខក្នុងលោកិយ ៗ ឥតទុក្ខ ឥតទោស
ភ័យ ប្រសើរក្រៃទាំងប្រុស-ស្រី ទោះទៅបរ-
លោកក្តី នឹងបានសោយសុខសួគ៌ា ៗ នេះ
ច្បាប់រាជបណ្ឌិត ខ្ញុំគន់គិតដោយសទ្ធា ច្បាប់
នេះប្រសើរជាង ជាស្បូវេចម្ល៉េះឯងហោង ៗ

x x x

បំណងជើង: "សាស្ត្រាល្បើកមទ្រីបតិ"

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ បទព្រហ្មគីតិ ។

ប្រភពរឿង: មហាវេស្សន្តរជាតក ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ផ្សែ ២២ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានថតចម្លង តាមច្បាប់វត្តវល្លិកាពម កាលពី គ.ស. ១៩៤៣ ចុះលេខ ១.៣៧៦ ។

អត្ថបទដើម: ៙ នេះបទព្រហ្មគីតិ ជាតំណាលព្រាហ្មណ៍ចង នានាំអ្នកទាំងសង បណ្តើរក្នុងព្រៃព្រឹក្សា ៗ មាន ក្នុងព្រះបាលី ចមដិនស្រីស្តេចទេសនា ក្នុងកណ្ឌមទ្រីបាតិ ចាយចែងចារអំពីតំ ៗ . . .

. . . . .ៗលៗ

អត្ថបទបញ្ចប់ សម្តេចព្រះមទ្រី ស្តាប់ពោធិ៍ទើបនាងណា ទៀន ទូលព្រះរាជា ថាកាលខ្ញុំទៅព្រឹក្សា ៗ ពីកាល

ថ្ងៃម្សិលមិញ ខ្ញុំចរចេញរកផលា ឃើញកើតមាន
អស្ចារ្យ មេឃដំដាលស្រទំមីរ ៗ នេះគឺបាន
បារមី ព្រះចក្រីសាងពោធិ៍ រង្គំក្ពិគីទន់កែវ
ពេញអស្ចារ្យ ៗ នាងអរទឹងចក្រី សាងបារមី
ត្រាស់ប្រាថ្នា សប្បាយក្នុងកាយាពជកញ្ញាឥត
មានម៉ង ៗ និទានក្នុងបាលី ព្រះជិនស្រីសួរសា-
សង ចំណោទពោទបារបង មានតម្រាស់ត្រាស់
ទេសនាៗ ចេញពីក្នុងបាលី អស់សេចក្ដីមទ្រីបាពិ
សម្រេចស្រេចម៉ុះណា ព្រះគាថា ៩០ គត់ ៗ

x x x

បំណងជើង : "សាស្ត្រាសីល ១០"

អ្នកនិពន្ធ : ករ៍ ម៉ា ៗ

កាលបរិច្ឆេទ : គ្មានបញ្ជាក់ ក្នុងអត្ថបទ ៗ

របៀបនិពន្ធ : ពាក្យកាព្យ បទកាកគតិ ៗ

ប្រភពរឿង : សីល ១០ ប្រការ ក្នុងលទ្ធិពុទ្ធនិយម ៗ

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៥ សន្លឹក ៗ

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្ត
វេឡុការាមដែរ ចុះលេខសាស្ត្រា ១.៣៧៦ ។

អត្ថបទផ្ដើម: ៙ អហំនមោ នមការេ អភិវន្ទ អាពាសិ
ពុទ្ធធម្មេ សង្ឃវរេ វរុត្តមំ ។ ខ្ញុំលុតលើកករ
កាយកបបរ ទសសីលំ លើកឡើងដាក់ដល់
មណ្ឌលសិរសំ ក្រាបថ្វាយវន្ទំ ព្រះពុទ្ធសាសនា ។
. . . . . . ។ល។ . . .

អត្ថបទបញ្ចប់: ខ្ញុំព្រះករុណា នាមដើមឈ្មោះ ម៉ា ចារចង
ទៀនទុក ជាច្បាប់ខ្ទួនាន សូមបានបានសុខ
និរនេសទោសទុក្ខ ភ័យផងទាំងឡាយ ។
ពាក្យពេចន៍ល្បិចល្បែក ផ្គួរផ្គាប់ពៃលើក
ជួបចប់បរិយាយ តែងតាមប្រាជ្ញា រៅហារ
អធិប្បាយ ប្រៀបប្រែស្រង់ស្រាយ សូរេច
ម៉េះហោង ។

x x x

បំណាងដើង: " សាស្ត្រា ស្វាសួត ហង្សសួត "

អ្នកនិពន្ធ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ : បទកាកគតិ ។

ប្រភពរឿង: រឿងព្រេង ឥន្ទ្រិពលពុទ្ធនិយម ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៥ សន្លឹក ។

ឯកសារនេះ បានមកអំពីវត្តវេឡុការាម កាលពី

គ.ស.១៩៤៣ ចុះលេខសាស្ត្រា ១.៣៧៦ ។

អត្ថបទផ្ដើម: ៙ នេះបទកាកគតិ ។ ប្អូនអើយពៅស្ដាប់

បងនិងថ្លែងប្រាប់ និយាយមួយណា កាលពោធិ

សត្វ យកជាតិជាស្វា សេ្ដចមានករិយា និង

ស្វាពានរ ។ មានកាលទថ្ងៃ ស្វាឈ្មោលទៅព្រៃ

បេះផ្លែឧទុម្ពរ មានខ្លាមួយដើរ មើលយល់

ពានរ ខ្លានោះត្រេកអរ ចិត្តបងខាំធី ។ .

. . . . ។ល។

អត្ថបទបញ្ចប់: ហង្សហើរទៅទុំ ខែនទិញបន្ទុំ អាសនាប្រពៃ

ទើបហង្សទេសនា ពិរោះពេកក្រៃ នាងយកទ្រព្យ

ថ្លៃ បាចសាចបូជា ។ ខេមាទេវី នាងអរ

ឥតបី ថ្លៃនិងនឹងឧបមា អាសូរកជហង្ស នាង
ទ្រង់ករុណា ឲ្យនាំទៅនា លំនៅព្រះអង្គ ។

x x x

បំណងរឿង: « សាស្ត្រា ច្បាប់ប្រដៅខ្លួន »

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ បទកាកគតិ ។

ប្រភពរឿង : ច្បាប់ទូន្មានកូនចៅ តាមប្រពៃណី ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ផ្ទៃ មាន ៦ សន្លឹក ។
ឯកសារនេះ ប្រហែល ពុទ្ធសាសនបណ្ឌិត្យបាន
មកអំពីវត្ត វេទ្យការាមដែរ ចុះលេខ សាស្ត្រា
១,៣៧៦ ។

អត្ថបទផ្ដើម : ៙ នេះបទកាកគតិ ទើបចងជា ច្បាប់ទុកទូន្មាន
តាមដោយគន្លង ព្រេងព្រឹទ្ធបុរាណ ប្រាជ្ញលោក
និទាន ប្រដៅបុត្រក្លា ។ ហៃកូនពន្លក ស្ងួន
អើយមាសយក បណ្ដាំបិតា ដីតុកនេះចាស់ ឥត

អត្ថបទដើម: ៙ នេះបទកុដដ្គលីលា ។ ទឹងថ្លែងសំដែង ពណ៌នា មើលមនុស្សពុតពាល មិនយកក្បួនច្បាប់ ។ ប្រដៅសឹងប៉ាពុំគាប់ ដ្បិតពាលគត់ច្បាប់ យកតែចិត្តឯង ។ គេស្ដីសឹងទ័ងគគ្រេង បេះតែដើរលេង សព្វដោយផ្លូវថ្នា ។ . .

. . . . . . . ។ ល ។

អត្ថបទបញ្ចប់ : អ្នកណាអាចគិតទុក្ខំ ទឹកដល់អន្ទិចុំ អនត្តានោះមាន ។ អ្នកនោះចំពោះហៅហ៊ាន លោកទុកស្មើស្ពាន ឆ្លងរួចដល់ត្រើយ ។ អ្នកណាខ្ជាញខ្ជិលព្រងើយ ដឹងច្បាប់ធម៌ហើយ ពុំកាន់ឡើយណា ។ ចង់ស្ដាប់គ្រាប់ពុតពាលា ទឹងកើតវេរា បានបាបក្រាសក្រៃ ។ សោយទុក្ខនរកនាយនៃ លំបាកសព្វថ្ងៃ វែងចប់ម្ល៉េះហោង ។

x x x

(មានត)

# ជីវប្រវត្តិរបស់ឈ្មោះ ប៊ូ-ប៊ូ



អ្នកប៊ូ-នាងពុជ ជាតិខ្មែរ ជាកសិករ ទីលំនៅ ។ ឃុំថ្មគ ស្រុកល្វាឯម ខេត្តកណ្តាល មានកូនបីនាក់ គឺនាងស៊ុម ១ នាងអ៊ូ ២ កុមារជាពៅ ប៊ូ-ប៊ូ ២ ។

ក – កុមារប៊ូ-ប៊ូ កើតថ្ងៃពុធ ខែមិគសិរ ឆ្នាំខាល គ.ស. ១៩០២ មានរោគក្អកហឺតតាំងពីកើតមកជាប់រហូតដល់អាយុ៩ ឆ្នាំទើបបាត់ ។ ប៉ុន្តែដល់អាយុ៤០ឆ្នាំប្លាយ រោគនេះកើតឡើងទៀតជាប់រហូតដល់ចាស់ជរា ។

ខ– កុមារប៊ូ-ប៊ូ អាយុ ១០ ឆ្នាំ នៅវត្តបទុមវតីពងវែកកាមក្រុងភ្នំពេញ ជាមួយព្រះបាឡាត់មង្គលពៅ ជាមាបង្កើតក៏ចាប់រៀនអក្សរសាស្ត្រខ្មែរពីត្រឹមអាយុ ១០ ឆ្នាំមក ។ នៅវត្តបានជិតមួយឆ្នាំ នឹករលឹកម្តាយពេក ក៏លបរត់ពីវត្តជិះកប៉ាល់ប្រឡំទៅលើកប៉ាល់ដើរផ្លូវភ្នំពេញ-ក្រូចឆ្មារ នៅក្នុងកប៉ាល់ខេះកន្ទុះខែ ទើបបានទៅដល់ម្តាយ ។

គ– កុមារប៊ូ-ប៊ូ អាយុ១២ ឆ្នាំចូលលេងយីកេនៅសន្ទុង ស្វាយមាស វិហារសួរ បាន២ឆ្នាំចូលលេងល្ខោនខោលនៅឃុំថ្មគ ស្រុកកំណើត បាន២ឆ្នាំ ឈប់លេងល្ខោនមកនៅបំរើលោកឪពុកបួសឯចាស់ នៅវត្តបទុមវតី ភ្នំពេញបាន៤វស្សា លោកសឹកទៅនៅស្រុកវិញ ។

ឃ - កុមារ ប៊ូ-ប៉ូ អាយុ ១៤ ឆ្នាំ បានបួសនេននៅវត្តស្វាយតាឯម ស្រុក-ខេត្តដដែលព្រះគ្រូព្រហ្មវិសុទ្ធិជាព្រះឧបជ្ឈាយ៍ ។ នៅវត្តនេះ ជាគណៈធម្មយុត្តបាន២វស្សា ចូលមកនៅវត្តបទុមវតី កុដិព្រះមហាព្រហ្មមុនី "ស៊ុក" ចាប់រៀនព្រះត្រៃបិដកតាំងពីបួសនេនអាយុ១៧ឆ្នាំ ។ រៀននៅវត្តបទុមវតីអំពីលោកគ្រូអាចារ្យ ជាន-កែវ, ឆន យ៉ាង ។ រៀននៅវត្តស្វាយពពែអំពីលោកគ្រូបាឡាត់ទឹម-សួន គុណ-កង អ៊ិក-ម៉ូត ។

នេនប៊ូ-ប៉ូ អាយុ២០ឆ្នាំប្រឡងជាប់ជាសិស្សសាលាបាលីជាន់ខ្ពស់ នៅវិហារព្រះកែវមរកតក្នុង គ.ស. ១៩២០ រៀនគ្រប់ប្រាំឆ្នាំក៏ប្រឡងជាប់ បានសញ្ញាបត្រជាព្រះមហាបរិយត្តិ ក្នុងគ.ស.១៩២៥ ហើយមិនទាន់សឹកភ្លាមទេ នៅរៀនខ្លួនឯងនិងបង្រៀនសិស្សតទៅទៀត ។

ង— នេន ប៊ូ-ប៉ូ អាយុ២១ឆ្នាំ បានឧបសម្បទជាភិក្ខុក្នុងវត្តបទុមវតី មាននាមឆាយាថា បិតវិរិយោ ។ សម្តេចព្រះមង្គលទេពាចារ្យ "ស៊ុក" ជាព្រះឧបជ្ឈាយ៍ ព្រះធម្មឧត្តម អ៊ិង-ស្រី ជាកម្មវាចាចារ្យ ។

ច— កិច្ចការជាប្រយោជន៍ចំពោះពុទ្ធសាសនាដែលព្រះមហា ប៊ូ-ប៉ូ បានធ្វើដូចរៀបរាប់តទៅនេះ៖

ព្រះមហាប៊ូ-ប៉ូ បានទៅដឹកនាំក្រួសពីឃុំស្វាយរលំ ស្រុកស្អាង យកមកកសាងវិហារថ្មីនិងបង្គន់ខ្ទង់មាន ៣ បន្ទប់ ។ បានបង្រៀនសិស្សនៅកុដិតាំងពីមួយរូបពីររូបរហូតដល់ច្រើនរូប ក៏ធ្វើសាលាខ្ទង់

បង្រៀនក្នុង១ថ្ងៃ៣ពេលគឺ ព្រឹក រសៀល និងយប់ ប្រើគោមចង្កៀង ព្រោះពេលនោះមិនទាន់មានអគ្គិសនីចូលក្នុងវត្តទេ ។ មានបង្រៀនធម្មវិន័យ ពុទ្ធប្រវត្តិ ពង្សាវតារកម្ពុជា ភាសាសៀមនិងឡាតាំងខ្លះផង ។ មុនដំបូង ព្រះមហាប៊ុ.ប៉ូ បង្រៀនតែម្នាក់ឯងគ្រប់ទាំង៣ពេល ក្នុង១ថ្ងៃ ។ ក្រោយមកទើបមាន លោកអាចារ្យដទៃជួយបង្រៀននៅពេលខ្លះបានចាត់សិស្សដែលចេះចាំស្ទាត់ជាងគេឲ្យជួយបង្រៀនខ្លះផង ។ បានចាត់លោកអាចារ្យខ្លះឲ្យទៅនៅបង្រៀនក្នុងវត្តធម្មនិគហៅប៉ាធា ខេត្តបាត់ដំបង ក្នុងវត្តមង្គលគេនាកម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ក្នុងវត្តទ័ពចំបក ស្រុកកណ្តាលស្ទឹងនិងវត្តស្វាយតាឯម ស្រុកល្វាឯម ខេត្តកណ្តាល ព្រោះគ្រានោះមិនទាន់មានសាលាបាលីផងទេ ។

បានសរសេរអធិប្បាយពីបាលីវេយ្យាករណ៍ ពីពិធីប្រែ ប្រយោគបាលីច្រើនមុខហើយបោះពុម្ពដោយចាហួយចែកចាយដល់សិស្សទាំងឡាយឥតយកថ្លៃ ។ ក្នុងថ្ងៃមួយៗមានសិស្សជាងមួយរយរូបចូលរៀនគ្រប់ទាំង៣ពេល ។ គាត់ការឲ្យមានទឹកតែចែកសិស្សឆាន់ និងថ្នាំជក់ ថ្នាំពេទ្យខ្លះរាល់ថ្ងៃ ។ គាត់ឲ្យមានការប្រឡងល្បងចំណេះសិស្សរាល់ខែឆ្នាំហើយឲ្យរង្វាន់លើកទឹកចិត្តតាមលេខទាប-ខ្ពស់ ។ លោកអាចារ្យគ្រប់រូបមានបៀវត្សប្រចាំខែតិចខ្លះច្រើនខ្លះតាមសមត្ថភាព តែព្រះមហាប៊ុ-ប៉ូ មិនយកបៀវត្សទេ គឺជាអ្នកទំរេបច្ច័យចំណាយ ៗ បច្ច័យដែលបានដោយ

សូត្រមន្តឬទេសនាចំណាយទៅក្នុងសាលានេះទាំងអស់ ។ មានទាយក ទាយិកាជាច្រើនជួយឧបត្ថម្ភដោយសៀវភៅសរសេរ ដីស ដីខ្មៅ-ស្លាប៉ាកា-ជ័រលុប-ក្រដាស់ផ្តិត-តែ-ស្ករនិងបច្ច័យរាល់ខែ ហើយចែកចាយវត្ថុទាំងនេះដល់សិស្សគ្រប់រូប ។ មានលោកសង្ឃវត្តនួនមុនីរាម ហៅវត្តថាន់ខ្ទះ វត្តស្វាយតាពែខ្ទះ វត្តប្រយូរវង្ស ហៅវត្តយុនព្រះញាតិខ្ទះចូលមកសុំរៀនក្នុងសាលាវត្តបទុមវតី ។

ធ— ព្រះមហា ប៊ូ-ប៉ូ បួសភិក្ខុមួយវស្សាបានទទួលសមណសក្តិជាបាឡាត់អរិយព្រឹទ្ធទីហ៊ាំនា បួសភិក្ខុ៤វស្សាបានទទួលសមណសក្តិជាបាឡាត់ព្រហ្មវិជ្ជាទីវៀនល្អង ជាអ្នកចាត់ព្រះសង្ឃទៅក្នុងព្រះរាជពិធីបុណ្យផ្សេងៗ មានបុតម៉ាយលោកចាន់ ហ្វាន់នៃពុទ្ធសាសនបណ្ឌិត្យលេខ ចុះថ្ងៃទី ២ ខែមករា គ.ស. ១៩៣០ហៅព្រះមហាប៊ូ-ប៉ូ ឲ្យចូលទៅធ្វើការជាក្រុមជំនុំប្រែព្រះត្រៃបិដកក្នុងក្រុមពុទ្ធសាសនបណ្ឌិត្យ ក្នុងអាយុគំរប់ ៣០ឆ្នាំទាំងគេចជាភិក្ខុដោយលោកយល់ឃើញថាមហាប៊ូ-ប៉ូ ចេះចាំព្រះត្រៃបិដកនិងពិធីប្រែប្រយោគបាលីស្ទាត់គ្រាន់បើ ។ បានបៀវត្សក្នុង១ខែ ២៤ រៀល ។

ជ— ព្រះមហាប៊ូ-ប៉ូ បួសនេនបានពីរវស្សា បួសភិក្ខុបាន៩វស្សា រួមជា១៣វស្សា សឹកជាគ្រហស្ថក្នុងអាយុ ៣០ ឆ្នាំ គ ស. ១៩៣០ ហើយធ្វើមង្គលការក្នុងឆ្នាំនេះជាមួយនាងហ៊ុន-សឹងអ៊ុំ ជាតិខ្មែរអាយុ១៧ ឆ្នាំជាកូនស្រីច្បងរបស់ឈ្មោះជំទប់លេខ១ ហ៊ុន និង នាងឈៀង ទី

លំនៅៗឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

ព្រះមហា ប៊ូ-ប៉ូ នឹងនាងហ៊ុន-ស៊ីងអ៊ុំបង្កើតបានកូន៥នាក់ ស្លាប់មួយនាក់ទៅ នៅសល់តែ៤នាក់ គឺកូនទី១ប្រុសឈ្មោះ ប៊ូ-នរិន្ទ កើតនៅថ្ងៃទី ៦[៣] ៗ ៩ ឆ្នាំរកាបញ្ចស័ក ព.ស ២៤៧៦ ត្រូវនឹងថ្ងៃទី ២៨ ខែសូយេត ·គ.ស.១៩៣៣ វេលាម៉ោង៧យប់ នៅឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

កូនទី២ ប្រុសឈ្មោះ ប៊ូ-នរេង្គ កើតនៅថ្ងៃ ៧[៣] ៗ ២ ឆ្នាំម្សាញ់ត្រីស័ក ព.ស.២៤៨៤ ត្រូវនឹងថ្ងៃទី ខែដេសម គ.ស.១៩៤១ វេលាព្រលប់ ម៉ោង ៦ នៅឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

កូនទី៣ ស្រីឈ្មោះ ប៊ូ-នរម្យ កើតនៅថ្ងៃ ១ ៗ ៥[១១] ឆ្នាំច អដ្ឋស័ក ព.ស.២៤៨៩ ត្រូវនឹងថ្ងៃទី២៧ខែមេសា " អាវ្រិល " គ.ស.១៩៤៦ វេលាម៉ោង៦ព្រឹក នៅមន្ទីរពេទ្យផង៉ាង៉ម ជាពេទ្យរាជការសង្កាត់លេខ២ ក្រុងភ្នំពេញ ។

កូនទី៤ ប្រុសឈ្មោះ ប៊ូ-នព កើតនៅថ្ងៃទី៣ ៗ ១[១] ឆ្នាំឆ្លូវឯកស័ក ព.ស ២៤៩២ ត្រូវនឹងថ្ងៃទី ៦ខែធ្នូ គ.ស.១៩៤៩ ម៉ោង៥ជិតភ្លឺ នៅផ្ទះពេទ្យឈ្មលខាងកើតផ្សារថ្មី សង្កាត់លេខ ៣ ក្រុងភ្នំពេញ ។

ឈ- មហាប៊ូ-ប៉ូ បានទៅនៅកែវិញ្ញាសាព្រះត្រៃបិដកតាគ១ក្នុងរោងពុម្ពព្រះរាជទ្រព"នៅទីសាលាដែកចាស់"ចំនួន៦ខែ ។ ក្នុង១ថ្ងៃធ្វើការ៣ពេល គឺពីម៉ោង៧ព្រឹកដល់ម៉ោង១១ថ្ងៃត្រង់ពីម៉ោង២រសៀលដល់ម៉ោង៥ល្ងាច និងពីម៉ោង៨យប់ដល់ម៉ោង ៤អធ្រាត ។ ឥតបានប្រាក់ម៉ោងទេ តែពួកអ្នករោងពុម្ពនោះបានប្រាក់ម៉ោងគ្រប់ៗគ្នា ។ ទៅកែវិញ្ញាសារនេះក្នុងគ.ស.១៩៣០ ។

ញ- មហាប៊ូ-ប៉ូ សូម្បីសឹកហើយក៏នៅតែធ្វៀតឱកាសបង្រៀនលោកសង្ឃក្នុងវត្តបទុមវតីដែរ ថែមទាំងទៅបង្រៀននៅវត្តនួនមុនីកមហៅវត្តថាន់ខ្ទះនិងវត្តស្វាយពពែទៀត សល់ខាន់តែវត្តប្រយូរវង្សតែប៉ុណ្ណោះ ព្រោះលោកវត្តនេះចូលមករៀននៅវត្តបទុមវតីទាំងអស់ ។ មហាប៊ូ-ប៉ូ បង្រៀនដោយឥតថ្លៃឈ្នួលទេ គឺដោយមនោសញ្ចេតនាជ្រះថ្លានិងពង្រីកព្រះពុទ្ធសាសនាឲ្យសាយភាយទូលំទូលាយចេញទៅទៀត ។ មហាប៊ូ-ប៉ូ ចាប់បង្រៀនតាំងពីឆ្នាំ ១៩២៣ ជាប់រៀងរាល់ឆ្នាំរហូតដល់ចាស់ជរាទើបឈប់

មហាប៊ូ-ប៉ូ កាលនៅបួសបានផ្តួចផ្តើមគំនិតឃោសនាទាយកទាយិការកសាងសាលាបាលី១ខ្នងពីរជាន់ដោយបេតុងអារមេ ដូចមានរូបរាងសាលានៅរហូតដល់សព្វថ្ងៃនេះ ។

ដ- មហាប៊ូ-ប៉ូ កាលការប្រពន្ធរួចហើយ ជួលផ្ទះគេនៅត្រឹមតែ៦ខែប៉ុណ្ណោះ ថ្លៃឈ្នួល១ខែ២រៀល ក៏សុំដីរាជការបាន១ឡូ នៅមាត់បឹង

កេងកង ហើយសង់ផ្ទះខ្លួនទទឹង៤ម៉ែត្របណ្ដោយ ៦ ម៉ែត្រគ្រឿងឈើ ប្រក់ស្បូវក្រាលរនាបអស់ប្រាក់ជាង២០០រៀល ហើយកាត់ប្រាក់ខែសងគេក្នុង១ខែ១៦០រៀលទុកចាយវាយតែ៤រៀល បានដាំបន្លែជាច្រើនមុខបេះយកទៅលក់ឯផ្សារ យកប្រាក់ទិញអង្ករនិងត្រី ។ សម័យនោះ អង្ករ១តៅថ្លៃយ៉ាងច្រើន ៤ កាក់ ឬ ៤ កាក់កន្លះ ។

ឋ - មហាប៊ូ-ប៉ូ ពេលយប់ឆ្លៀតសរសេរក្នុងមុងអធិប្បាយ ពិធីប្រែប្រយោគបាលីបានជារឿងយ៉ាងវែង ។ ហើយប្រគល់សិទ្ធិឲ្យរោងពុម្ពកម្ពុជវ-ពេកាសបោះពុម្ពលក់ ឯអ្នកសរសេរគតបានមួយកាក់ទេ ។ បានសរសេរប្រែលោតប្រយោគនិងជាសេចក្ដីទេសនាក្នុងគម្ពីរធម្មបទដ្ឋកថា ចប់ហើយប្រគល់ឲ្យរោងពុម្ពតាពេបោះពុម្ពលក់ ។ បានរួបរួមពុទ្ធភាសិតក្នុងសុត្តន្ត-បិដក ខុទ្ទកនិកាយ ចំនួន២៥០បទ ប្រស្នាពុទ្ធប្រវត្តិ — វេយ្យាករណ៍ខ្មែរ រឿងព្រះកែវមរកត — រឿងខ្លួនជាគតិរបស់ខ្លួន — ករណីយកិច្ចរបស់ពុទ្ធបរិ-ស័ទនិយាយពីចតុរារិយសច្ច រឿងថ្ងៃឧបោសថតាមវិធីប័ក រឿងទាំងនេះបោះពុម្ពលក់ដោយខ្លួនឯង ។ បានសរសេរអត្ថបទខាងគតិធម៌ខ្លះ ខាងគតិលោកខ្លះជាច្រើនរឿងចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា នៃពុទ្ធសាសនបណ្ឌិត្យរាល់ខែឆ្នាំ សូម្បីឈប់ពីមុខក្រសួងនោះហើយ ក៏នៅតែឆ្លៀតសរសេររឿងផ្ញើទៅចុះផ្សាយទៀតដែរ ។

ឌ — មហាប៊ូ-ប៉ូ បានធ្វើជាសមាជិកគណៈកម្មការពុទ្ធិកសមាគមមជ្ឈ-

មណ្ឌលនៅវត្តឧណ្ណាលោមបាន៤ឆ្នាំ ធ្វើជាទាយកសមាជិកអនុពុទ្ធិកសមាគមនៅវត្តលង្កាបាន១០ឆ្នាំ និងធ្វើជាសមាជិកគណៈកម្មការវប្បធម៌តាំងពីចាប់ផ្តើមមុនដំបូងបំផុតបាន ១ ឆ្នាំ ។ បានបង្រៀនព្រះសង្ឃនៅវត្តសាកវ័នកេជាគ្រូគង្គំពេញបាន ១ ឆ្នាំ ។

ឍ - មហាប៊ូ-ប៉ូ ធ្វើក្រុមជំនុំប្រែព្រះត្រៃបិដកបាន ១៣ ឆ្នាំ ចូលធ្វើជាអ្នករក្សាបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ពីថ្ងៃ៣ ខែ១០ឆ្នាំរោងទោស័ក ព.ស.២៤៨៣ ត្រូវនឹងថ្ងៃទី ៣ ខែសេបតម ឆ្នាំ ១៩៤០ រហូតដល់ថ្ងៃឈប់ពីមុខក្រសួងបានចំនួន ១៧ ឆ្នាំ ។

ណ - ក្នុងគ.ស. ១៩៤៥-៤៦-៤៧ ធ្វើការជាសាស្ត្រាចារ្យបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិអំពីភាសាខ្មែរ បាលី ក្នុង ១ សប្តាហ៍ ៣ ម៉ោង ក្នុង១ម៉ោងបាន ១៩ រៀល ។

ក្នុងគ.ស. ១៩៤៨ បានតែងអត្ថបទ១ជាពាក្យៗ និយាយពីទីក្រុងភ្នំពេញសម័យថ្មី ចូលប្រឡងតាមប្រកាសក្រសួងមហាផ្ទៃ ។ មេប្រយោគខ្មែរទាំងអស់សរសើរគ្រប់មាត់ ហើយឲ្យជាប់លេខ១ ក្នុងចំណោមអត្ថបទពប់រយ ។ ប៉ុន្តែបារាំងម្នាក់ធ្វើជាប្រធានរាស្សូឡុបចោលថាមិនបានការទៅវិញ ព្រោះជំនាន់នោះបារាំងកំពុងតែស្អប់អ្នកមានសញ្ញាបត្របាលីរាយាត់លែងឲ្យចូលក្នុងក្របខណ្ឌរាជការ ដោយរាយល់ថាពួកអ្នក

រៀនព្រះត្រៃបិដកសុទ្ធតែចេះវានផ្លូវនយោបាយ ដូចលោកអាចារ្យ ហែម-ចៀវ ជាដើម តែមតាំងពីកាប់ចិតសៀវភៅឈ្មោះកម្ពុជ កបរយៈឈ្មោះ នៅក្នុងឃ្លាំងរបស់ពុទ្ធសាសនបណ្ឌិត្យ មិនឲ្យចេញផ្សាយទៀត រាប់ថាសៀវភៅតាំងនោះ សុទ្ធតែនិយាយពីនយោបាយដេញបារាំងឲ្យដើរចេញពីស្រុកខ្មែរ ។

គ - ក្នុងគ.ស ១៩៥៧ មហាប៊ូ-ប៉ូ បានតែងពុទ្ធភាសិតឲ្យបទថា វីរិយេន ទុក្ខមច្ចេតិ មនុស្សនឹងឆ្លងឲ្យផុតទុក្ខបាន ព្រោះតែមានសេចក្ដីព្យាយាម « ចូលប្រឡងក្នុងពិធីបុណ្យពាក់កណ្ដាលពុទ្ធសាសនា » (២៥០០ព.ស.) នៅក្រុងភ្នំពេញ ជាប់បានលេខ១ក្នុងចំណោមអត្ថបទជាង៤០ រឿងបានរង្វាន់ជាប្រាក់ ៣.៥០០រ និងព្រះពុទ្ធរូបស្ពាន់មួយអង្គ ។

ឃ - មហាប៊ូ-ប៉ូ បានតែងតាំងជាមន្ត្រីកិត្តិយសទីឃុនបណ្ណាទុរក្ស ។ បានទទួលគ្រឿងឥស្សរិយយស ៤ គឺ មុនីសារភណ្ឌ១ អស្សប្ញទ្ធិកម្ពុជា១ អនុស្សព្រប្រាក់១ ពុទ្ធចក្រ១ ។

ង - មហាប៊ូ-ប៉ូ បានទទួលនិវត្តន៍ពីថ្ងៃទី ១៣-៤-៥៩ បានប្រាក់និវត្តន៍ក្នុង ១ ខែ ១.៦៣២រ ហើយធ្វើការដោយជាប់កិច្ចសន្យាបាន ២ ឆ្នាំបន្ដមកទៀត ប៉ុន្តែ ដោយខ្លួនមានជម្ងឺកាន់តែច្រើនឡើងត្រាំធ្វើការមិនបាន ក៏លាលែងដាច់ស្រឡះពីមុខក្រសួងនេះ ។ បានតាំងលំនៅលែងពី

សមាគមអ្នកនិពន្ធខ្មែរទៀតផង ។ ប៉ុន្តែលោកប្រធាន ហ៊ែល ស៊ុមផា លោក លាង-ហាប់អាន និង លោក លី-ធាមតេង មិនព្រមឲ្យលប់ឈ្មោះពីបញ្ជីទេ គ្រាន់តែឲ្យឈប់បង់ប្រាក់វិភាគទានប្រចាំខែប៉ុណ្ណោះ ។

គ- មហាប៊ូ-ប៉ូ នៅជាកុមារ១៣ឆ្នាំ បួសជាសង្ឃ ៣ឆ្នាំ ធ្វើជាយកវ៉សតាមផ្លូវការ ៣១ឆ្នាំ បូករួមត្រូវជា៤៧ឆ្នាំ ។ លំដាប់ពី៤៧ឆ្នាំនេះមក មហាប៊ូ-ប៉ូ នៅទំនេរលែងប្រកបអាជីវកម្មអ្វីទៀត ព្រោះខ្លួនចាស់ជរា បានប្រគល់ផ្ទះនិងមរតកទាំងអស់ ឲ្យកូនច្បងកាន់កាប់ចំនួស ព្រោះកូននេះទទួលបន្ទុកចិញ្ចឹមគ្រួសារទាំងអស់ និងបង់ពន្ធដារជូនរាជការគ្រប់មុខ ។ សព្វថ្ងៃនេះ គ.ស. ១៩៦៦ មហាប៊ូ-ប៉ូ បានអាយុ ៦៥ ឆ្នាំ ហើយនៅមានស្មារតីមាំមួននៅមានកម្លាំងអាចដើរទៅណាបាន នៅជួបជុំប្រពន្ធកូនទាំង ៤ នាក់ក្នុងផ្ទះជាមួយគ្នា ។

ជីវប្រវត្តិរបស់ ប៊ូ-ប៉ូ សង្ខេបតែប៉ុណ្ណោះ

# រឿងសាមកុក

ចាកញ៉ីវីបុលកដសេនា

ឆ្ន កាន

ប្រែ-រៀបរៀង

( គ )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកភាងវៃឆ្លាសបើបានអាន
នឹងចេះទាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

— យូរ-អ៊ុន —

## សាមកុក ខ្សែ ៦៦

តាំងពីព្រះចៅស៊ុនគួន ឲ្យយកខ្លួនឡុកស៊ុនមកតាំងជាមេកងធំ ត្រួតលើនាយទាហាន ទឹងលើកទ័ពទៅតទឹងព្រះចៅឡៀវពី ។ ចាញ់ទ័ពឡុកស៊ុន ព្រះចៅចូភីលើកទ័ពមកច្បាំងទៀត ក៏ចាញ់ទ័ពស្រុកកាំងតាំង ។

---

ព្រះចៅស៊ុនគួន បានទ្រង់ព្រះសណ្ដាប់ញាប់ញ័រព្រះទ័យភ័យតាល់ តែស្ងួតព្រះកាយាមិនបានតបថាប្រការម្ដេច កាំចេកទីប្រឹក្សាទូលថា មានមនុស្សម្នាក់ល្អណាស់នៅក្នុងស្រុកយើងនេះ ហេតុម្ដេចថាទ្រង់មិនយកមកប្រើឲ្យធ្វើពជការ ព្រះចៅស៊ុនគួនត្រាស់សួរថា នរណានោះ កាំចេកទូលថា ឡុកស៊ុននៅស្រុកកេងជីវ ទូលបង្គំយល់ឃើញថាមានតម្រិះ

ប្រាជ្ញប្រហែលនឹងជីវយី   កាលគ្រាយើងទៅវាយយកស្រុកកេងជីវនោះ ឡុកស៊ិនក៏បានជួយរិះគិតផងទើបបានស្រុកកេងជីវ   សូមឲ្យទ្រង់យកមកធ្វើការចុះ  បើមិនឈ្នះព្រះចៅឡាវក៏ទេ  ឲ្យធ្វើទោសទូលបង្គំជាខ្ញុំចុះ ។

ព្រះចៅស៊ិនប្អូខបានឮដូច្នោះក៏ពេញព្រះទ័យណាស់ត្រាស់ថា ខ្ញុំក្លួចនឹកមិនឃើញទៀតប៉ៀវទូលថា  ឡុកស៊ិននោះជាមនុស្សតូចទាប  ធ្លាប់ធ្វើពលការតែការឯណាតិចតួច   ដែលនឹងយកមកធ្វើការធំតប៉ាំងនឹងព្រះចៅឡាវពីនោះមិនកើតទេ      កោះយ៉ុងឆ្លើយឡើងទៀតថាឡុកស៊ិននោះជាមនុស្សតូចទាបណាស់  អាយុក៏នៅក្មេងសេចក្ដីគំនិត  មិនទាន់ចេះគិតធ្វើការធំ   នឹងយកមកបន្ទុំឲ្យកាន់ការជានាយកលើគេចាស់ទុំមិនសមគួរ  គេក៏គង់នឹងមិនស្ដាប់ ។

ចៅផិតទូលថា  ឡុកស៊ិននោះជាមនុស្សក្មេងណាស់  ទោះបីនឹងចេះដឹងយ៉ាងណាក៏ធ្វើបានតែត្រឹមក្រុមការប្រុកតូចតាច   នឹងលើកឲ្យមានអំណាចពេញទីជាមេកងទ័ពបង្គាប់បញ្ជាលើទាហានដូចម្ដេចបាន     កាំប៉ិកស្រែកថាបើមិនយកឡុកស៊ិនចូលមកធ្វើការគ្រានេះទេ  ស្រុកកាំងតាំងនឹងខូចជាប្រាកដហើយ    បើអស់អ្នកពល់គ្នាយល់ថាឡុកស៊ិនមិនល្អទេ    ខ្ញុំនឹងករិយាបុត្រ  សូមទទួលធានាថា  បើឡុកស៊ិនធ្វើមេទ័ពទៅច្បាំងចាញ់ព្រះចៅឡាវពីវេលាណា     សុំឲ្យយកខ្លួនខ្ញុំនឹងករិយាបុត្រទៅកាត់ក្បាលតាំងអស់គ្នាចេញចុះ ។

ព្រះចៅស៊ិនគួនបានទ្រង់ព្រះសណ្ដាប់ច្បាស់ត្រាស់ថា អស់អ្នកពល់គ្នា កុំប្រកែកគ្នាថ្វី ឡុកស៊ិននោះខ្ញុំបានស្គាល់ច្បាស់ ត្រូវចិត្តខ្ញុំណាស់ហើយៗ ក៏ត្រាស់បង្គាប់ឲ្យទៅហៅឡុកស៊ិនចូលមកគាល់ បំរើក៏ចេញទៅហៅឡុកស៊ិនឯស្រុកកេងជីវ លុះមកដល់ហើយក៏ចូលទៅគាល់ព្រះចៅស៊ិនគួន ឡុកស៊ិនក្រាបថ្វាយបង្គំហើយក៏នៅស្ងៀម ព្រះចៅស៊ិនគួនក៏ប្រស្រ័យសាកសួរតាមគួរសមថា ឮអ្នកមានសតិបញ្ញាល្អមែន តែយើងមិនបានចាប់ភ្លឹកនឹកឃើញសោះក៏ភ្លេចអស់ទៅ នេះហាក់ជាកាំបេកនឹកនិយាយឡើងបានជាយើងនឹកឃើញឲ្យទៅអញ្ជើញអ្នកមក ដើម្បីសុំឲ្យអ្នកជួយទំនុកបំរុងស្រុកទេស ព្រោះវេលានេះព្រះចៅឡៅពីលើកទ័ពមកញាំញីជាចលាចល សុំឲ្យអ្នកជួយទប់ទល់ធ្វើជាមេកងទ័ពបង្គាប់បញ្ជាលើសេនាពាហាន នឹងបានតស៊ូនឹងព្រះចៅឡៅពីគ្រានេះ ។

ឡុកស៊ិនទូលថា អស់លោកជាសេនាបតីធំៗ ក៏មាននៅជួបជុំពេញក្នុងស្រុកកាំងតាំងស៊ីងតែជាខ្ញុំរាជការចាស់ ទូលបង្គំជាខ្ញុំនៅក្មេងណាស់ ទាំងសតិបញ្ញាក៏ពុំសូវប៉ុនប្រសប់ផង ព្រះចៅស៊ិនគួនត្រាស់ថា បើក្រែងអស់នាម៉ឺនធំៗឬនាយទ័ពនាយកទាំងពួងនឹងរឹងទទឹងមិនស្ដាប់បង្គាប់បញ្ជា យើងនឹងឲ្យគ្រឿងជាអាជ្ញាសិទ្ធិលើអ្នកគាន់ ប្រសិនបើឈ្មោះណារឹងទទឹងពុំស្ដាប់ឲ្យអ្នកកាប់ផ្ដាច់ក្បាលតាមអំណាចចុះ ឡុកស៊ិនទូលថា ទ្រង់នឹងប្រោសប្រទានឲ្យទូលព្រះបង្គំជាខ្ញុំមានយសដូច្នោះហើយ ព្រឹកស្អែកនេះ សូម

ឲ្យទ្រង់ហៅអស់នាម៉ឺនធំតូចមកក្រាបបង្គំគាល់ទាំងអស់គ្នា រួចសឹមទ្រង់ប្រទានគ្រឿងអាជ្ញាសិទ្ធិឲ្យទូលបង្គំជាខ្ញុំ ចំពោះមុខអស់លោកពល់គ្នាតាមការប៉ុះ កាំបេកទូលថា ប្រវេណីអំពីបុរាណដែលទឹងតាំងមេទ័ពធំឲ្យបង្គាប់បញ្ជាលើទាហាននោះ ត្រូវតែព្រះរាជទានឲ្យអ្នកនោះឡើងអង្គុយលើទីខ្ពស់ឧត្តមសមគួរហើយ ទើបប្រគល់ត្រាអាជ្ញាសិទ្ធិសម្រាប់ខ្លួនឲ្យនាម៉ឺនទឹងក្រស្តឃើញទាំងអស់គ្នា ព្រះចៅស៊ិនគួខយល់ឃើញត្រូវ លុះវេលាយប់ទើបត្រាស់បង្គាប់ឲ្យធ្វើផ្ទះទិងរបៀបរៀបតាំងមេកងទ័ព តាមទំនៀមទម្លាប់បុរាណ លុះព្រឹកឡើងត្រាស់ឲ្យប្រជុំអស់នាម៉ឺនតូចធំទាំងប៉ុន្មានមានឡុកស៊ិនជាប្រធាន ហើយព្រះចៅស៊ិនគួនក៏ឲ្យអញ្ជើញឡុកស៊ិនឡើងអង្គុយលើទីកន្លែងមេទ័ព ហើយក៏ប្រកាសព្រះរាជទានអាជ្ញាសិទ្ធិ គឺប្រគល់គ្រឿងទិងត្រាគ្រឿងឧបភោគបរិភោគ សម្រាប់ឥស្សរិយយសមេទ័ពធំកណ្តាលទីប្រជុំនៃសេនាបតីនាម៉ឺនមុខមន្ត្រីទាំងពួងស្រេចហើយ ត្រាស់ឲ្យឡុកស៊ិននិយាយត្រូវគ្រាពជការលើខេត្រខណ្ឌនានា បើអ្នកឯណារឹងទទឹងពុំស្តាប់បង្គាប់ឲ្យសម្លាប់តាមអាជ្ញាសិទ្ធិការណរង្គសង្គ្រាម កុំឲ្យគោតញញើតឡើយ ។

ឡុកស៊ិនបានទទួលយសជាមេទ័ពធំហើយក៏កាន់គ្រឿងដើរចេញទៅ ទើបបង្គាប់ស៊ីសេង, តេងហងជានាយកងស្តាំឆ្វេង ឲ្យប្រុងប្រៀបរៀបពលយោធា ទាំងទ័ពគោកទ័ពទឹកឲ្យព្រមព្រៀងយើងលើកចេញទៅវេលា

នេះ នោះស៊ីសេងនិងតេងហងក៏ចេញទៅចាត់ចែងកងទ័ពសព្វគ្រប់ប្រការ រួចស្រេចកាលណាក៏ចូលទៅជំរាបឡុកស៊ុន ៗ ក៏ចេញទៅត្រួតមើលហើយលើកចេញទៅ ឯហានទុងនិងជីវថាយដែលនៅក្រោយបន្ទាយខាងក្រៅលុះដឹងថាព្រះចៅស៊ុនគួនតាំងឡុកស៊ុនជាមេកងទ័ពធំ លើកមកក៏និយាយថាបណ្ដានាម៉ឺនក្នុងស្រុកកាំងតាំងនោះអស់ហើយឬ បានជាស្ដេចយើងទៅយកឡុកស៊ុនក្មេងប្រម៉ក់ឲ្យធ្វើជាមេទ័ពធំលើកចេញមក នឹងមិនខូចរាជការទៅហើយហ៎ ! ចរចាគ្នាមិនទាន់ផុតមាត់ ទទួលឡុកស៊ុនលើកទ័ពទៅដល់ នោះឡុកស៊ុនបានក្រឡេកទៅឃើញអាការៈនិងកិរិយានៃហានទុង, ជីវថាយនូវអស់ទាហានទាំងឡាយ មិនសូវគោរពក្រែងវែងខ្លាចខ្លួនជាមេកងធំ ក៏ឲ្យបំរើទៅហៅហានទុង,ជីវថាយនូវអស់នាយទ័ពនាយកងទាំងពួងមកជួបជុំប្រឹក្សាការសង្គ្រាម ឡុកស៊ុនក៏កាន់គ្របីអាជ្ញាសិទ្ធិឈរស្រែកប្រកាសថាព្រះចៅស៊ុនគួន បានទ្រង់ព្រះរាជទានយសឲ្យយើងឡើងជាមេទ័ពធំហើយដែលយើងលើកទ័ពមកនេះ ដើម្បីនឹងបង្គាប់បញ្ជាលើនាយទ័ពនាយកងពលគ្នាឲ្យទទួលស្ដាប់ បើអ្នកឯណាធ្វើការបានល្អក៏នឹងឲ្យបំណាច់រង្វាន់យ៉ាងខ្ពស់ បើអ្នកឯណាធ្វើខុសក៏ត្រូវចុះទោសយ៉ាងសហ័សពុំត្រាប្រណីឡើយ បើនរណាហើយបានយល់ការដោយប្រការឯណា ៗ ជាផ្លូវចំរើនក៏ជាស់គៀនសតិយ៉េងចុះ យើងមិនប្រកាន់យកខុសទេ អស់បណ្ដាទាហានក៏ស្ងៀម ។

ដីវថាយនិយាយនិងឡុកស៊ិនថា ស៊ិនហួនជាក្មួយព្រះចៅស៊ិនគួនតាំងទ័ពទៅស្រុកអ៊ីឡេង ឥឡូវព្រះចៅឡៅពីឲ្យទ័ពស្រុកនោះនៅក្នុងចំណោមមនុស្សដែ នៅក្នុងស្រុកនោះក៏អត់ស្បៀងអាហារ ខាងក្រៅស្រុកនោះក៏គ្មាននរណាទឹងលើកទៅជួយបាន សូមអញ្ជើញលោកលើកទៅជួយ ដោយសតិបញ្ញាគាហានឲ្យបានស៊ិនហួនរួចចេញមក ដើម្បីឲ្យចៅហ្វាយនាយរបស់យើងសប្បាយព្រះទ័យ ហើយនិងកែខគិតធ្វើការតទៅទៀតឡុកស៊ិនថា ស៊ិនហ៊ួននោះជាមនុស្ស មានអាជ្ញាស្រ័យដឹងប្រណីសង្គ្រោះអស់ពលទាហាន មានគេពប់អានស្រឡាញ់ច្រើន ទាំងសេនាទាហានក៏មានមនុស្សល្អច្រើននាក់ អាហារស្បៀងនៅក្នុងស្រុកក៏បរិបូណ៌មិនទាន់ខ្វះខាតទេ គេមិនទាន់ជាអ៊ីនៅឡើយ បើយើងវាយទ័ពព្រះចៅឡៅពីបែកហើយ ស៊ិន-ហ៊ួនក៏គង់នឹងរួចឯងមិនបាច់ទៅជួយ ដីវថាយនិងទាហានទាំងពួងឮឡុកស៊ិនថាដូច្នោះក៏នាំគ្នាបែរមុខញញឹមហើយក៏លាថយទៅក្រៅ ។

ហានតុងនិយាយនិងដីវថាយថា ព្រះចៅស៊ិនគួនតាំងឡុកស៊ិនឲ្យមកធ្វើជាមេទ័ពធំដូច្នេះ ស្រុកកាំងតាំងគង់នឹងខូចជាប្រាកដ ដីវថាយថា ខ្ញុំស្ដាប់មើលគំនិតប្រាជ្ញាដែលឡុកស៊ិននិយាយការនឹងខ្ញុំថ្ងៃនេះ មុខជានឹងខូចពងការដូចពាក្យអ្នកថាជាប្រាកដមែនណាស់ ឯឡុកស៊ិននោះ លុះវេលាព្រឹកឡើងក៏ឲ្យប្រជុំនាយកងនាយទ័ពមកព្រមគ្នាហើយបង្គាប់ថា បើព្រះចៅឡៅពីលើកមកគតាំងចំបាំងនឹងយើង ១ មិនត្រូវចេញទៅតទល់ទេ

ត្រូវតែនៅក្រោមបន្ទាយពាំងក្នុងប្រុងប្រយ័ត្នឲ្យមាំមួនចុះ នោះអស់នាយទ័ពនាយកងពួកឡុកស៊ុនថាដូច្នោះ ក៏នាំគ្នាសើចធ្វើហាក់ដូចមិនយកចិត្តទុកដាក់សោះ ហើយបបួលគ្នាលាថយចេញទៅ កាលដែលបង្គាប់ទាំងប៉ុន្មានក៏មិនបានទឹងធ្វើតាម ឡុកស៊ុនដឹងថា ពួកនាយកងនាយទ័ពមិនទទួលស្តាប់បង្គាប់ទាំងប្រុងប្រៀបរៀបធ្វើបន្ទាយ ដោយសេចក្តីមិនគោរពក្រែងរអែងខ្លាចសោះលុះព្រឹកឡើង ក៏ឲ្យហៅនាយកងនាយទ័ពទូវទាហានទាំងពួងចូលមកប្រជុំព្រមគ្នា ហើយនិយាយថាខ្ញុំបានបង្គាប់អស់អ្នកទាំងឡាយឲ្យរៀបធ្វើបន្ទាយពាយចំរូងជីកគូធ្វើស្នាមភ្លោះ ដើម្បីនឹងការពារក្រោខ្លួនឲ្យមាំមួនកុំឲ្យចេញតនឹងសត្រូវធ្វើ ហេតុអ្វីអស់អ្នកមិនទៅតាមបង្គាប់យើងជាមេទ័ពដូច្នេះ ។

ហានតុងឆ្លើយថា ខ្ញុំបាទជាជាតិទាហានមានចិត្តស្រឡាញ់ព្រះចៅស៊ុនគួន បានបំរើខ្លួនតាមទៅច្បាំងគ្រប់អន្លើមិនខ្លាចសេចក្តីស្លាប់ វេលានេះលោកបានតាំងជាមេកងទ័ពចេញមកបង្គាប់បញ្ញានឹងធ្វើសង្គ្រាម តទឹងព្រះចៅឡេវពី ដែលលោកមកបង្គាប់ឲ្យតាំងទីនៅតែក្នុងបន្ទាយកុំឲ្យចេញច្បាំងនោះ លោកនឹងយកទ័ពតាមកដួយឬ ទាហានទាំងពួងដូច្នោះក៏ស្រែកឡើងព្រមគ្នាថា ហានតុងនិយាយត្រូវណាស់ យើងទាំងអស់នឹងសុំចេញច្បាំងមិនខ្លាចស្លាប់ទេ ឡុកស៊ុនឮហានតុងនិងទាហានទាំងពួងថាដូច្នោះក៏ខឹងណាស់ ហូតគ្រប់កាន់លើកឡើងហើយថា តោះបី

ខ្លួនយើងនៅក្នុងយ៉ាងណា   វេលានេះព្រះចៅស៊ិនគួនព្រះរាជទានអាជ្ញាសិទ្ធិឲ្យយើងធ្វើមេទ័ពបង្គាប់ប្រើក្បាលអ្នកពលគ្នាហើយត្រូវតែស្តាប់   បើនរណាល្មើសនឹងបង្គាប់មិនស្តាប់ពាក្យយើង ៗ   នឹងឲ្យកាត់ក្បាលនឹងផ្ទៃគ្រប់នេះ   ទាហានទាំងអស់បានឮក៏នឹកក្នុងចិត្ត   មិនដឹងនឹងគិតគបធ្វើយ៉ាងណា នាំគ្នាដើរចេញទៅ ធ្វើបន្ទាយកាយចំរូងជីកគូធ្វើស្នាមភ្លោះជាមួនមាំប្រចាំយាមល្បាតលាតក្រវែលតាមបង្គាប់គ្រប់ប្រការ ។

ឯព្រះចៅឡៅពីនោះ   លុះសែនពូការទៀវហ៊ុយរួចស្រេចកាលណាក៏ត្រាស់បង្គាប់នាយទ័ពនាយកងឲ្យតាំងបន្ទាយកាយជាល់ជាប់គ្នា   តាំងពីដំបន់អ៊ូតេងវៀងទៅដល់ដំបន់ឈួនខៅចម្ងាយ ១.០០០ សិន (៤០ គ.) ចំនួន ៤០ បន្ទាយ   មានទាហានល្បាតនាំយកសេចក្តីទៅក្រាបទូលព្រះចៅឡៅពីថា   ព្រះចៅស៊ិនគួនតាំងឡុកស៊ិនជាមេកងទ័ពធំនាំពលមកតាំងបន្ទាយកាយប្រទល់វៀបគ្នា   ហើយហាមប្រាមពួកយោធាមិនឲ្យចេញចំបាំង   ព្រះចៅឡៅពីបានទ្រង់ព្រះសណ្តាប់   ក៏ទ្រង់សង្ស័យណាស់ត្រាស់ថា ឡុកស៊ិននោះ នៅឯណា វាជាយ៉ាងម្តេច ម៉ាលឿងទំប្រឹក្សាថា ឡុកស៊ិននោះជាមនុស្សចំណុះស្រុកធម្ហតា   ទីលំនៅវានៅស្រុកកេងដីវ នៅក្មេងណាស់ តែបានរៀនសូត្រឆ្លៀវឆ្លាស់ប្រតិពលយល់ការជ្រៅទូលាយ   ប្រហែលនឹងដីវយើស្រុកកេងដីវខូចអន្តរាយក៏ព្រោះឧបាយប្រាជ្ញាអាដែងនេះ ។

ព្រះចៅឡៅពីទ្រង់ព្រះសណ្ដាប់ច្បាស់ ក៏ទ្រង់ព្រះក្រោធធំណាស់ត្រាស់ថា តម្រិះប្រាជ្ញាការដែងនេះហើយដែលកសម្លាប់ជីវិតប្អូនអញ ល្អហើយជាបុណ្យអញនាំកឲ្យមកបានសងសឹកគ្នា អញនឹងលើកពលយោធាទៅវាយទំលាយបន្ទាយកុកងថ្ងៃនេះ ម៉ាលៀងទូលថា ឡុកស៊ុននេះទូលព្រះបង្គំជាខ្ញុំស្គាល់បានថាមានតម្រិះប្រាជ្ញាជាជាងជីវយី សូមឲ្យទ្រង់បង្អង់កុំអាលចូលចំបាំង សូមទ្រង់ព្រះតំរិះមើលសិនចុះ ព្រះចៅឡៅពីខ្វាល់ណាស់ត្រាស់ថា យើងធ្វើសង្គ្រាមមកក៏ច្រើនណាស់ហើយ តាំងពីកំឡោះលុះដល់ចាស់ជរា នឹងខ្លាចអ្វីដែលអាឡុកស៊ុនក្មេងពីម្សិលមិញកនឹងជាយ៉ាងណាជាងយើង ត្រាស់ហើយក៏បង្គាប់ទាហានឲ្យបន្ទុំលើកទ័ពចេញទៅ ឯហានតុងទឹងជីវថាយដែលរក្សាបន្ទាយនៅនោះ លុះដឹងថាព្រះចៅឡៅពីលើកទ័ពមក ក៏ប្រើទាហានឲ្យទៅដំរាបឡុកស៊ុន ៗ ភ័យណាស់ក្រែងទាហានទាំងនោះមិនស្តាប់នឹងប្រញាប់ចេញចំបាំង ទើបឡើងសេះលេះលោងចេញទៅមើល ប្រទះនឹងហានតុងឈរនៅក្នុងបន្ទាយលើកំពូលភ្នំ ៗ

ហានតុងក្រឡេកទៅឃើញទាហានលើកមកច្រើនណាស់ ជាន់កណ្ដាលនោះទាហានកាន់សុទ្ធតែទង់លឿង ទើបចង្អុលប្រាប់ឲ្យឡុកស៊ុនមើលថា នោះព្រះចៅឡៅពីលើកមកឯង យើងនឹងស្ងៀមទៅថ្វី ត្រូវតែចេញចំបាំងឲ្យជំនះគ្នា ហើយនឹងចាប់យកខ្លួនព្រះចៅឡៅពី ឲ្យបាន

ឡុកស៊ុនថា ព្រះចៅឡៅពីនោះប៉ិនស្ទាត់ក្នុងក្បួនពិជ័យសង្គ្រាមណាស់ រមែងច្បាំងឈ្នះគេមកច្រើនហើយ ពួកសេនាទាហានក៏មានចិត្តខ្លាំងពូកែណាស់ អ្នកនឹងចេញទៅប៉ះមុខបាន ចូររះអានគិតតែរក្សាបន្ទាយឲ្យមាំសិនចុះ បើទាហានខាងគេលើកមកទៀតហត់ដោយកំដៅថ្ងៃ គេឈប់សម្រាកក្បែរភ្នំទីងម្លប់ឈើធំវេលាណា សឹមយើងគិតការចេញច្បាំងតែម្តង ហាន់តុងបានឮដូច្នោះក៏មិនយល់ឃើញផងសោះ តែទាល់គំនិតណាស់ ព្រោះខ្លាចក៏ស្ងៀមទៅ ។

ព្រះចៅឡៅពីឃើញទាហានស្រុកកាំងតាំងមិនចេញច្បាំងសោះ ក៏បង្ខំទាហានទាំងអស់ ឲ្យព្រួតគ្នាចូលទៅស្រែកជេរដល់មាត់ទ្វារបន្ទាយឡុកស៊ុនពុះហើយក៏បង្គាប់ទាហានទាំងឡាយថា ឲ្យខំអត់សង្កត់ចិត្តគិតតែយកក្រដាសចុកត្រចៀកទៅសិនចុះ នោះព្រះចៅឡៅពីដែលប្រើទាហានឲ្យទៅស្រែកជេរដល់ទ្វារបន្ទាយហើយ ទាហានស្រុកកាំងតាំងមិនចេញច្បាំងសោះ ក៏ទ្រង់ឈឺក្តៅព្រះឧរាពន់ប្រមាណ ។ ម៉ាលៀងទូលថាឡុកស៊ុននោះមានគំនិតគិតជ្រៅណាស់ បានជាយើងប្រើមនុស្សឲ្យទៅជេរគេមិនចេញមកច្បាំង មុខជាវានឹងធ្វើឲ្យយើងភាន់កាំងធ្វេសទុកចិត្ត សូមទ្រង់ព្រះតំរិះគិតមើលឲ្យល្អសិនចុះ ព្រះចៅឡៅពីត្រាស់ថា សេចក្តីគិតវានឹងមានអាការយ៉ាងណា វាគ្មាប់តែចាញ់យើងទើបមិនចេញមុខមកច្បាំងឃើញថាវាខ្លាចយើងពិតមែន ។

ប៉ងស៊ិបទើបទូលថា យើងលើកទ័ពមកពេលនេះ ជាទេសកាលរដូវក្តៅ ទាំងអាស្រ័យម្លប់ឈើក៏មានតិច ទាំងរកទឹកក៏នៅឆ្ងាយណាស់ ល្គិកណាបើមានកជការប្ទ័ពលើកមក ទាំងយកធុរៈមិនបានឆាប់រហ័សក្លាយ ៗ ព្រះចៅឡៅពីទ្រង់ព្រះសណ្តាប់ក៏យល់ឃើញត្រូវ ទើបត្រាស់ថា យើងត្រូវតែថយទ័ពត្រឡប់ទៅវិញ ក៏តាំងបញ្ចប់ទ័ពនៅក្បែរមាត់ទឹកទាំងក្រោមម្លប់ឈើ ដើម្បីឲ្យទាហានបានសម្រាកកម្លាំង ចាំហួសពេលក្តៅ វេលាណាសឹមលើកមកតតាំងម្តងទៀត ម៉ាលៀងទូលថា ដែលទ័ពថយទៅបញ្ចប់ នៅក្បែរមាត់ទឹកទាំងម្លប់ឈើនោះជាស្រួលណាស់ហើយ តែខ្លាចក្រែង ឡុកស៊ុន ឃើញថាយើងថយទ័ព វាទាំងត្រឡប់លើកគំហុករុកបំពារមកលើយើង ៗ ទាំងធ្វើប្រការម្តេច ព្រះចៅឡៅពី ក៏ត្រាស់ថា បើដូច្នោះ យើងត្រូវឲ្យ ង៉ីប៉ាន់ ឃុំទាហាន ១០.០០០ ទៅតាំងនៅមាត់ផ្លូវ ដែលវាទាំងលើកចេញមកនោះ ឯខ្លួនយើងទាំងឃុំទាហាន ដែលមានថ្វីដៃ ៨០.០០០ ទៅបង្កប់នៅទីប្រកក្នុំ ហើយយើងឲ្យថយទ័ពដំចេញទៅ បើឡុកស៊ុនឃើញថាយើងថយទ័ពវាទាំងត្រឡប់ដេញៈចេញមក ឲ្យង៉ីប៉ាន់ច្បាំងតហើយធ្វើជាចាញ់ថយរត់ចេញទៅ បើបានចំណាប់វេលាណា ខ្ញុំឯងទាំងលើកទាហានសេនាចេញកាត់ចុងទ័ព ចាប់យកខ្លួនឡុកស៊ុនឲ្យបាន អស់នាម៉ឺនទាំងទីប្រឹក្សាទាំងប៉ុន្មានក៏យល់ឃើញត្រូវហើយសរសើរសេចក្តីរបស់ព្រះចៅឡៅពីណាស់ ។

ម៉ាលៀងទូលថា ខ្ញុំបេងជាអាចារ្យណែនាំនៅចាំស្រុក ព្រះអង្គទ្រង់លើកទ័ពមក ខ្ញុំបេងមិនបានមកឃើញផង ទូលព្រះបង្គំជាខ្ញុំសូមគូរជាផែនទីផ្ញើទៅឲ្យខ្ញុំបេងមើលតាមរបៀបដែលតាំងបន្ទាយនេះ ទឹងត្រូវតាមក្បួនពិជ័យសង្គ្រាមដែរឬប្រការម្ដេច ព្រះចៅឡៅពីទ្រង់យល់ត្រូវទើបត្រាស់ថាបើដូច្នោះឲ្យអ្នកគូរផ្ញើទៅចុះ បើខ្ញុំបេងឃើញហើយខឹងថាប្រការម្ដេចអ្នកចូលសូត្រគ្រឡប់វិលមកឲ្យឆាប់ ម៉ាលៀងក៏ទៅគូរផែនទីតាមតព្រះតម្រាស់ ព្រះចៅឡៅពីក៏ឲ្យថយទ័ពទៅធ្វើតាមគំនិតដែលគិតទុកនោះ ។

ឯហាន់គុងទឹងជីវថាយដឹងថាព្រះចៅឡៅពីថយទ័ពហើយ ក៏ទៅប្រាប់ឡុកស៊ុនថាព្រះចៅឡៅពីតាំងបន្ទាយភាយរៀងគ្នាទៅដល់ ៤០ អន្លើ ហើយលើកថយទៅវិញ ខ្ញុំបាទគិតឃើញថាជាទេសកាលក្ដៅណាស់ប្រែហែលជាទៅតាំងនៅម្លប់ឈើឬមាត់ទឹក យើងបានចំណាប់ពេញសន្ទឹក ហើយទឹងសុំចេញទៅច្បាំងយកជ័យជំនះ ។

ឡុកស៊ុនបានឮដូច្នោះក៏មានអំណរណាស់ ទើបឡើងសេះលើកទាហានចេញទៅមើលឃើញតាំងនៅទ័ព១កង មានពលប្រហែល ១០.០០០ ទាហានចាស់ខ្លះក្មេងខ្លះមិនស្មើគ្នា ក៏គិតសង្ស័យហាន់-គុង, ជីវថាយថាឃើញទាហាន១កងនេះមានក្មេងតិចចាស់ច្រើន ខ្ញុំបាទសូមចេញទៅច្បាំងទឹងវាយឲ្យបែកទៅតែម្ដង ឡុកស៊ុនហាមឃាត់ថា ទ័ពនេះគេតាំងទុក

(នៅមានត)

ការស្រាវជ្រាវ

# ប្រវត្តិលោកវិសេស ជួន

របស់បណ្ឌិតមហា ឈឹម-ស៊ុម អតីតសាស្ត្រាចារ្យ

(តមក)

---

## សេចក្តីបញ្ចប់

## ស្នាដៃក្នុងការនិពន្ធ

នៃ

លោកតាអាចារ្យ ជួន

គ) សាស្ត្រានេនមាស ឬ សុវណ្ណពិលាប: សាស្ត្រានេះ អ្នកឲ្យការច្រើនគ្នាបានឲ្យពត៌មានដល់ខ្ញុំថា: នេនមាសមានកំណើតនៅឃុំជ្រៃ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បួសនៅវត្តមោស ខាងត្បូងភ្នំហូពៅ ។ សាមណេរនេះជាមនុស្សកំព្រា, កាលដែលមាតាបិតាទទួលអនិច្ចកម្មអស់ទៅ, នៅតែ២នាក់និងប្អូនតូចមួយ មានសេចក្តីព្រួយចំពោះជីវភាពរបស់ខ្លួននិងប្អូននោះក្រៃពេក, ប៉ុន្តែជាអ្នកមានចិត្តសទ្ធាជ្រះថ្លា ចំណាយទ្រព្យធនធានជាលោហធាតុទាំងអស់ ដែលជាអម្រស់អម្រមានមកអំពីមាតាបិតា ញ៉ាំងជាងឲ្យរំលាយបញ្ចូលគ្នាសាងបានព្រះពុទ្ធរូបសំរឹទ្ធ ២ ព្រះអង្គ

ធ្វើបុណ្យអភិសេក តម្កល់ទុកក្នុងវត្តហ្វូញៅ(១)មួយព្រះអង្គ ក្នុងវត្តមាសមួយព្រះអង្គ ។

សាមណេរ មាស សុគតបាត់ទៅឥតមានជនណាដែលរស់នៅសព្វថ្ងៃបានស្គាល់ទេ, ប៉ុន្តែគេជំនឹតៗគ្នាមកថា: សាមណេរនេះ បានសូមឲ្យលោកគ្រូអាចារ្យជួនតែងកាព្យថ្លែងពីសេចក្តីកំសត់របស់ខ្លួន ។ ហេតុដូច្នេះបានជាកំណាព្យនោះ បានឈ្មោះថា "សាស្ត្រានេនមាស" ។ សាស្ត្រានេះជួនកាលលោកអ្នកចារបានដាក់ចំណងជើងថា "សាស្ត្រាសុវណ្ណពិលាប" ដូច្នេះក៏មាន, មានចំនួនប្រហែលជាង១០សន្លឹកស្លឹករឹត រាប់រៀបអំពីបណ្តាំមាតាបិតាមុនគ្រាអនិច្ចកម្មថា ឲ្យថែទាំប្អូន ឲ្យនាំប្អូនលេងតែដោយដីកុំបីឡើងឈើ..., អំពីល្បែងក្មេងនៅស្រុកស្រែ, ទេសភាពវាលស្រែនិងព្រៃរបោះ ៗ មានដើមព្រីង ដើមត្រៀលស្វា ត្រៀលដោះក្របី ដែលជាចំណីនៃក្មេងគង្វាលគោ, ជាកំណាព្យគួរឲ្យសែនស្រណោះក្រៃពេក មានបទព្រហ្មគីតដូចឃ្លាថា :

ឱព្រីងដោះក្របី ផ្លែទុំខ្ទីជ្រុះរាត់រាយ

(១) ព្រះពុទ្ធរូបដែលលោកតម្កល់ទុកក្នុងវត្តហ្វូញៅ មានជនច្រើនគ្នាដែលរស់នៅសព្វថ្ងៃធ្លាប់បានឃើញថា ព្រះពុទ្ធរូបនោះ មានកំពស់ទាំងបល្ល័ង្កទាំងតួអង្គប្រហែលជាង ៣០ សន្ទី. ម៉ែត្រ មានអក្សរជាប់នៅខាងក្រោយបល្ល័ង្កថា នេនមាសសាង ។ ប្រហែលគ.ស. ១៩៣០ ចោរលួចយកព្រះពុទ្ធរូបនេះបាត់ទៅ ។ លោកគ្រូមហា គុប-គីម តែងស៊ើបសួររកព្រះពុទ្ធរូបនេះរៀងរៀបមក ។

...OTHEQUE ... ORIENT



យើងនាំគ្នាប្រញាយ    ដំណើរគាប់សភោគា ។ល។

*មានបទកាកគតិដូចឃ្លាថា :*

ស្រណោះវាលវែង    ដែលយើងគត់ទៀង

ទៅទិសឧត្ដរា    ព្រះពាយបក់បោក

ពពកត្រៀបត្រា    ខែមាឃមាសា

សែនស្ដាប់ស្ងួនឯក(១) ។ល។

---

(១) សាស្ត្រាសុវណ្ណពិលាបនេះ ខ្ញុំធ្លាប់មើលក្នុងកាលដែលខ្ញុំមានអាយុ ១០ ឆ្នាំ ។ និស្ស័យរបស់ខ្ញុំក្នុងការរៀនបាលីបានផុះឡើងដោយសាស្ត្រានេះជាដើមហេតុ ។ ព្រោះថាកាលនោះ ក្នុងវស្សាដែលអ្នកស្រុកប្រូវកាត់ហើយ គេតែងនិមន្តលោកទៅឆាន់គ្រប់ ៗ ភូមិ ។ ភិក្ខុ៣អង្គទើបបួសថ្មី ត្រូវលោកគ្រូធំចាត់ឲ្យទៅឆាន់ភូមិអង្គសំរោង ជាលំនៅនៃជនអ្នកពុំសូវមានការចេះដឹង ។ ខ្ញុំជាក្មេងវត្ត បានតាមលោកទៅឆាន់ក្នុងភូមិនោះ ។ ពេលលោកឆាន់ព្រឹកហើយ គេតែងប្រជុំគ្នាសាកច្ឆាធម៌ ។ អ្នកភូមិនោះគ្មាននរណាម្នាក់ចេះធម៌ល្មមសន្ទនាគ្នាបានសោះ បែរជាឲ្យខ្ញុំមើលសាស្ត្រាសុវណ្ណពិលាបនេះឲ្យគេស្ដាប់ទៅវិញ ។ ខ្ញុំមើលដល់ចុងឃ្លានេះ ខ្ញុំឈប់ ។ គ្រានោះការជជែកគ្នាមិនជាច់ស្រេចក៏កើតឡើង ព្រោះមិនដឹងថា ‹‹ទិសណាឈ្មោះទិសឧត្ដរ›› ។ ទើបខ្ញុំសួររកហេតុថា : គេរត់ខ្លែងត្រូវតបណ្ដោយខ្យល់ឬច្រាសខ្យល់ ? ឆ. ច្រាសខ្យល់ ។ ស. ខែមាឃខ្យល់បក់ពីទិសណា ? ឆ. ពីទិសខាងជើង ។ ទើបខ្ញុំប្រាប់ថា : ទិសខាងជើងហ្នឹងឯងដែលឈ្មោះថា ទិសឧត្តរ ។ គេក៏ពុំទាន់ជឿ, គេថាទិសខាងជើង ចាស់ ៗ ហៅទិសឧដរ ។ ខ្ញុំថា ឧត្តរ ក៏គឺឧដរ, ឧដរ ក៏គឺឯជើង, ចាស់បុរាណសម្បូណ៌ពាក្យប្រើណាស់ របស់អ្វីមួយៗ មានពាក្យហៅបីបួនបែប , អ្នកចេះពាក្យច្រើនបែប ទើបគេហៅថា លោកអ្នកប្រាជ្ញ ។

ខ្ញុំនិយាយប៉ុណ្ណេះ ជាហេតុឲ្យអ្នកភូមិនោះជ្រះថ្លាទាំងក្មេងទាំងចាស់ ខ្វះលើកដៃសំពះខ្ញុំ ។ រឿងនេះដែលចាក់ចុចគំនិតខ្ញុំឲ្យខ្ញុំចង់តែរៀនតទៅទៀត ដោយការតាំងចិត្តថា មិនព្រមល្ងង់ដូចអ្នកទាំងនោះទេ, កើតមកជាកូនខ្មែរ មិនគួរល្ងង់សព្វបើពាក្យខ្មែរទេ ។

សាស្ត្រាសុវណ្ណពិលាបនេះ លោកគ្រូអាចារ្យថ្ងួន បានតែងឡើង តាមបំណងនេនមាសជាអ្នកសុំឲ្យតែង គ្មានអត្ថន័យអ្វីប្លែកពីធម្មតាទេ គឺគ្រាន់តែជាកំណាព្យមួយ ដែលគួរឲ្យស្រណោះណាស់ប៉ុណ្ណោះ ។

ឃ) សាស្ត្រាផ្អកផ្ការឬផ្ការផ្តាំក្តាមខ្យង : សាស្ត្រានេះជាល្បើកដែលលោកគ្រូអាចារ្យ ថ្ងួន ប្រឌិតលើកឡើងហាក់ដូចជាអ្នកនិពន្ធនោះបេះការសាមេឃ ។ ល្បើកនេះជាកាព្យបទកាកគតិ មានពាក្យដើមថា:

ព្រហាមផ្ការផ្ចង់ ផ្ការមិនទុរជិន នឹងក្តាមឡើយណា
ហាក់ដូចសាប់ញាតិ សន្តាន់ផងគ្នា ខេបេញវិស្សា
ផ្ការលាក្តាមទៅ ។ ផ្ការមានមេត្តា ផ្ការផ្តាំក្តាមថា
ត្បូទក្តាមកម្លៅ ហារ៉ុយអស់ក្តាម ផ្ញើរផ្លូវឲ្យជ្រៅ
ព្រោះមនុស្សក្បាលខ្មៅ ប្ចូលបិតធិក្តាម ។ល។

ខ្ញុំធ្លាប់មើលសាស្ត្រានេះ កន្លងកាលអាយុ ៩ ឆ្នាំ ចាំស្ទើរតែដោយមាត់ទទេបានខ្លះរហូតដល់សព្វថ្ងៃ ។ តមក ខ្ញុំពុំដែលបានមើលសាស្ត្រានេះទៀតទេ ។ ទោះបីដូច្នោះ ក៏ខ្ញុំអាចចាំសេចក្តីបានថា: ពាក្យកាព្យក្នុងល្បើកនេះល្អមែនទែន គួរឲ្យតែចង់មើល, មើលហើយ ហាក់ដូចជានឹងជឿថា ផ្ការបេះការសាក្តាម ក្តាមបេះការសាផ្ការ ។ កាលណាខ្ញុំនឹកឃើញល្បើកនេះមួយដងមួយកាល ខ្ញុំតែង កាតសរសើរដល់គំនិតអ្នកនិពន្ធនេះជានិច្ច

ក្នុងកាលនោះ ។

អត្ថន័យសរុបក្នុងល្បើកនោះថា : ធាតុអាកាសនៅប្រទេសកម្ពុជា តែងប្រែប្រួលទៅតាមរដូវ ៗ ។ ជាពិសេស ក្នុងវេលាចុងរដូវប្រាំងដូរជិតដល់ហេមន្តរដូវ គឺក្នុងរនោចខែអស្សុជ ក្នុងវេលាព្រលឹមស្រាង មហាមេឃតែងបញ្ចេញសំឡេងផ្គរ ១ នៅទិសអាគ្នេយ៍ ។ សូរស័ព្ទនៃមហាមេឃនេះ អ្នកស្រុកសន្មតថា "ផ្គរផ្តាំក្តាមខ្យង" ព្រោះតែកាលណាគេឮសូរផ្គរនេះ គេអាចដឹងមុនថា ប្រាកដជាអស់ភ្លៀងហើយ ។ តមកគេឮសូរស័ព្ទផ្គរផ្ទុះ ១ ទៀត ក្នុងវេលាយប់ គេហៅថា "ទឹកអង្គរបាក់" គឺសូរស័ព្ទដែលគេឮ ក្នុងគ្រាដែលទឹកថយ ពីទន្លេសាបមកទន្លេ ៤ មុខវិញ (ទន្លេមេគង្គ) ។

លោកតាអាចារ្យ ដួង តែងកាព្យនេះឡើង ផ្តើមដំបូងជាពាក្យផ្គរលាក្តាមខ្យង ។ បន្ទាប់មក ជាដម្បូន្មានរបស់ផ្គរចំពោះក្តាមថា : ក្នុងពេលដែលយើងមិននៅ ត្រូវក្តាមទាំងឡាយ សរសៀរសេរសៀតត្បាលជ្រៀតកាយរន្ធឲ្យជ្រៅ ក្នុងកៀនកោះ ដែលមានបូសឈើ គល់ឈើ កន្ទៀតថ្មគ្រួសរេន ឲ្យកើតជាទីឋានលំនៅរបស់ខ្លួន ដើម្បីកុំឲ្យមនុស្សក្រ្យាលខ្មៅយកស៊ីបាន ។ ដម្បូន្មាននេះ ហាក់ដូចជាមហាមេឃមានមេត្តាធូទៅដល់សត្វលោកទាំងអស់ សូម្បីក្តាមជាសត្វចង្រៃ ក៏មហាមេឃអាណិតដែរ ។ ប៉ុន្តែសេចក្តីនៃរឿងនេះតទៅទៀត ហាក់ដូចជាមហាមេឃអាណិតមនុស្ស

ជាងក្ដាមជាសត្វចង្រៃ ព្រោះសូរស័ព្ទវា ដែលសន្ទនាជាមួយនឹងក្ដាម ទុកដូចជាបង្រៀនមនុស្សឲ្យចេះធ្វើម្ហូបដោយជាតិក្ដាម ដូចត្រង់សេចក្ដីថា:

– ក្ដាមតូច ៗ គេគ្រាន់តែបកសម្បកខ្នងនិងសន្ទះពោះចេញ គេបុកវាទាំងស្រស់ជាមួយនឹងអំបិលអម្ពិលខ្ចី (ចិញ្ច្រាំព្រហុកបន្តិចលាយផងក៏មាន) ហើយប្រតម្អមខ្ចី ៗ ធ្វើជាបន្លែផ្ទាប់នឹងក្ដាមបុកនោះ បរិភោគជាមួយនឹងបាយក្ដៅ ៗ ឆ្ងាញ់ណាស់ ។

– ក្ដាមខៅគេយកទៅបុកឲ្យល្អិតគួរសម បារពីត្បាល់មកដាក់ក្នុងចានក្រោង លាយទឹកច្របាច់ស្រង់កាកចេញ យកតែខួរស្លជាមួយនឹងបន្លែននោងខ្ចី ល្ពៅខ្ចី ឬ ល្ហុងខ្ចី បន្ថែម អំបិល ព្រហុកនិងម្អម, តែប៉ុណ្ណោះក៏ឆ្ងាញ់ណាស់ទៅហើយ មិនបាច់និយាយដល់ការយកត្រី ឬ កំពឹស ឬក៏ក្ដៅកន្ថែមមកស្លជាមួយផងទេ ។

– ក្ដាមគ្រោង ឬ ក្ដាមមេធំ ៗ នារដូវវែចប្រមតគេចាប់មកបកខ្ទះយកតែខ្លាញ់ដាក់ក្នុងសម្បកវា សល់ពីនោះធ្វើម្ហូបដូចខាងលើនេះ ។ ខ្លាញ់ក្ដាមដែលខ្ទះដាក់ពេញសម្បកឥតលាយគ្រឿងអ្វីទេ គ្រាន់តែបង់អំបិលបន្តិចកំដៅលើរងើកភ្លើងឲ្យឆ្អិនប៉ុណ្ណោះ ។ ខ្លាញ់នោះមិនបាច់ច្រើនទេ សូម្បីតែមួយ ឬ ពីរសម្បក គេអាចប្រឡាក់នឹងបាយ សព្វបានមួយចានធំ បរិភោគឆ្ងាញ់ជាទីបំផុត ។ (ត្រង់នេះ ដែលលោកវិសេស ដូង ថា: . . . ពុំទាន់បានពាម ស្រក់ទឹកមាត់មុន ) ។

— កូនក្ដាមតូចៗ គេបកសន្ទះនិងសម្បកចេញ កាត់ជាពីរកំណាត់ ប្រឡាក់នឹងទឹកត្រី ផ្អាប់នឹងអម្ពិលខ្ចី ហើយនឹងស្លឹកជីផ្សេងៗ បរិភោគទៅក៏ឆ្ងាញ់ដែរ ។

— កូនក្ដាមតូចៗ គេយកមកបកសន្ទះនិងសម្បកចេញ ប្រឡាក់ដោយទឹកស៊ីអ៊ីវផ្អែម ឬស្ករត្នោតនិងទឹកអំបិល ល្មមចូលរសជាតិផ្អែមប្រៃគួរសមហើយបេះស្រង់មកប្រឡាក់ខ្លាញ់ជ្រូក លីងក្នុងខ្ទះឲ្យស្រួយ ក៏បរិភោគឆ្ងាញ់គ្រាន់បើដែរ (អ្នកស្រុកកំពតចូលចិត្តធ្វើម្ហូបក្ដាមបែបនេះ) ។

— មិនត្រឹមតែអ្នកស្រែទេ, អ្នកក្រុងដែលសម្បូណ៌ម្ហូបពោរពាស ក៏អ្នកខ្លះចូលចិត្តបរិភោគក្ដាមប្រៃដែរ ទោះបីមានក្លិនស្អុយ ក៏គេអាចលាយម្ជូរ លាយស្លឹកជីផ្សេងៗ បរិភោគបានដែរ, ប៉ុន្តែគេចូលចិត្តទិញតែក្ដាមប្រៃពីកំពត គឺក្ដាមសមុទ្រ ។ អ្នកកំពតដែលចេះធ្វើក្ដាមប្រៃថា: ក្ដាមស្រែឆ្ងាញ់ជាងក្ដាមសមុទ្រទៅទៀត ។ (គួរពិចារណាផងចុះ) ។

(ម្ហូបក្ដាមនេះ ខ្ញុំសរសេរដោយការផ្សេផ្សំ ព្រោះខ្ញុំចាំពាក្យកាព្យក្នុងសាស្ត្រាផ្គរផ្ដាំក្ដាមខ្យងពុំសព្វគ្រប់, ចាំតែគោលសេចក្ដីប៉ុណ្ណោះ) ។

ល្បើកផ្គរផ្ដាំក្ដាមខ្យងនេះ ប្រហែលជាអ្នកនិពន្ធចង់ឲ្យសាធារណជនដឹងនូវធម្មតាលោកថា: ឧកាសលោក គឺ ទឹក ដី ភ្លើង ខ្យល់ ដែលមានមេឃជាធំ ក៏ដូចគ្នានឹងមនុស្សលោក ដែលមានមេបាមួយជាធំដូច្នោះដែរ។ មេឃក្ដី មេបាជាធំក្ដី មានក្ដីអាណិតអ្នកតូចខ្លួនទៅទាំងអស់, ប៉ុន្តែអ្នកតូច

ដែលចិលខ្ទួចបំផ្ទិចបំផ្លាញគេ, នោះត្រូវវិនាសដោយសំដី គឺច្បាប់ដំសុចរិតរបស់អ្នកគ្រប់គ្រង, ដូចជាក្អាមជាទីអាណិតរបស់មេឃក៏ពិតមែន, ប៉ុន្តែក្អាមចង្រៃពេក ទើបត្រូវវិនាសដោយសំដីមេឃដូច្នោះ ។

ង) ល្បើកអក ល្បើកនេះតាមចាស់ៗអ្នកឲ្យពាក្យមានផសខ្ទិជាប្រាកដជាលោកគ្រូអាចារ្យដូង បានតែងលើកុំដីសុរ ក្នុងគ្រាដែលទៅប្រាំជម្ងឺលោកតាហ៊ុនមែន ។ ប៉ុន្តែចាស់ទិនមិនឃើញនាមអ្នកតែង និងកាលបរិច្ឆេទក្នុងល្បើកនោះសោះ ។ មានហេតុមួយ ដែលនាំឲ្យអ្នកស្រាវជ្រាវមានគំនិតទទឹសទទាស ។ ហេតុនោះគឺ: រឿងអកញីឈ្មោលនេះមានពីរបែប គឺ មួយបែបខ្ទី មួយបែបវែង ។ បែបខ្ទី មានចំណងជើងជាល្បើកអក, បែបវែងមានចំណងជើងជាសាស្រ្តាអក ។ បែបខ្ទីចប់ត្រឹមអកញីបោះពួយៗមាក់ខ្លួនស្លាប់ ហើយតមកអកឈ្មោលក៏ដូច្នោះដែរ ។ បែបវែងពីខាងដើមមកដូចគ្នានឹងបែបខ្ទី, តពីអកញីឈ្មោលទាំងពីរបោកខ្លួនស្លាប់ទៅ អកញីទី២ ដែលទៅមាត់បឹងចំប្រើង ហើររកអកឈ្មោលជាគូសង្សារ ទៅជួបនឹងបក្សីឯទៀតៗដ៏ច្រើន, ខ្លះគេជួយអាណិត ខ្លះគេចំអកឡកឡឺយឲ្យ ខ្លះគេរិះគន់និន្ទាធ្វើឲ្យអកញីនោះមានការអាម៉ាស់មុខយ៉ាងខ្លាំង, ដល់ទីបំផុត អកញីនោះ បានជាគូសង្សារនឹងសត្វទីទុយឈ្មោលពោះម៉ាយ ដែលទីទុយញីជាប់អន្ទាក់ស្លាប់ចោលទៅ ។ ទីទុយឈ្មោលនិងអកញី (ពោះម៉ាយមេម៉ាយ) ទាំងពីរ ស្គាល់គ្នាលើចុងឈើតាល ជាទ

ក្ដាប់គ្នាជាប់ រហូតដើរធ្លាក់មកដល់ដីស្លាប់ទាំងពីរ ហើយៈទៅកើតជាសត្វប្រឡាំងកាស ខ្ទប់គ្នាជាប់ជានិច្ច ។ អ្នកនិពន្ធនោះ បែរមកសរជាតិថា: សត្វអកញីឈ្មោលនៅក្នុងដីស្ងួរ ដែលស្លាប់ខ្លួនព្រោះកំហុសនៃអកឈ្មោល អកនោះទៅកើតជាសត្វកូពាំង ត្រូវកូពាំងញីដាក់ទណ្ឌកម្មវិញ ឲ្យកូពាំងឈ្មោលនៅក្រោចពាំងគ្រង់ស៊ិតតែក្នុងរន្ធឈើ ដែលកូពាំងញីយកដីស្អិតមកបិទមិនឲ្យចេញរួច ហើយទៅស្វែងរកអាហារមកបញ្ចុកតាមរន្ធតូចដែលខ្លួនបិទមិនឲ្យជិតទុកគ្រាន់តែបញ្ចុកអាហារ ។

ក្នុងទីបំផុតនៃសាស្ត្រាអកបែបវែងនេះ មានដាក់ឈ្មោះអ្នកពាំងគេឲ្យតែងថា :

ចៅព្រំញ៉ាំងពឹងឲ្យគេលើក ជាល្បើកនេះឯងក្រែងអ្នកស្រុក
អ្នកស្រែបំការណាអផ្សុក វិតក្កនឹកក្ខូងនឹកប្រពន្ធ ។ល។

ហើយមានទាំងឈ្មោះអ្នកតែងកាព្យនោះផងថា :

រឿងនេះរិះព្រើលមើលប្រៀបប្រាណ ប្រៀនប្រួមឲ្យបានទៅជារាប
ព្រះបំរើឧទ័យលៃលើកកាព្យ កំណាព្យកំណត់ហ្មត់ធំល្អើ ។

ហេតុនេះឯង ដែលនាំឲ្យអ្នកស្រាវជ្រាវខ្លះយល់ថា លោកគ្រូអាចារ្យ ដួង តែង, ខ្លះយល់ថា លោកបំរើឧទ័យតែង ។ ឯយោបល់ខ្ញុំយល់ថា : ប្រាកដជាលោកគ្រូអាចារ្យ ដួង តែង បានត្រឹមមួយបែបខ្លី ហើយលោក

បំរើឱ្យទ័យតែងបន្តទៅទៀតទៅជាបែបនេះ ថែមទាំងដាក់ឈ្មោះខ្ញុំនេះផង បាត់ឈ្មោះលោកគ្រូអាចារ្យ ដួង ទៅ ។ ចំណុចដូចតទៅនេះ ដែលនាំឲ្យខ្ញុំយល់ដូចខាងលើ :

១– អ្នកឲ្យការច្រើនគ្នា ពីប្រកពវត្តហូរៅ វត្តលេខពែន ភូមិព្រៃទទឹង ឃុំព្រៃញាតិជាដើមថា: ល្បើកអក គឺលោកគ្រូអាចារ្យ ដួង តែងក្នុងគ្រាដែលលោកទៅទ្រាំដម្លៃលោកតាហ៊ុងនៅក្នុងស្វាយ ។

២– អ្នកឲ្យការទាំងនេះមាន ៦ នាក់ បានកើតទាន់ស្គាល់ជាក់នូវលោកគ្រូអាចារ្យ ដួង ផង ហើយម្នាក់ទៀតជាចៅបង្កើតរបស់លោកគ្រូអាចារ្យ ដួង ថែមទៀត ។

៣– ល្បើកអកបែបថ្មីនេះជាស្នាដៃ មានច្រើនតែក្នុងស្រុកគងពិសី បាទី ព្រៃកប្បាស, ក្រៅពីស្រុកទាំងនេះគេពុំសូវស្គាល់ទេ, ទើបតែនឹងស្គាល់ក្នុងគ្រាដែលព្រះអង្គម្ចាស់កាណុវង្ស ទ្រង់បង្កើតរោងពុម្ពកម្ពុជវរោកាស នៅខាងជើងវាលព្រះមេរុ ជាប់នឹងកំផែងខាងត្បូងនៃវត្តឧណ្ណាលោម ប្រហែលក្នុងឆ្នាំ ១៩១៩ គរៀងមក, ទ្រង់ឲ្យយកល្បើកអក(១)បែបថ្មីមកផ្សព្វផ្សាយពាក្យពេចន៍ខ្លះបោះពុម្ពឡើង ទើបគេស្គាល់ទូទៅទាំងប្រទេស ។

---

(១) ល្បើកអកបែបថ្មីនេះ និងរឿងសោកសារីកា បៅរៃ ឌឹម-ស៊ុយ ម្ចាស់បណ្ណាគារ ឌិម-សេង បានទិញសិទ្ធិផ្តាច់អំពីចាងហ្វាងរោងពុម្ពកម្ពុជវរោកាស ក្នុងគ្រាខាងក្រោយអំពីកាលដែលព្រះអង្គម្ចាស់កាណុវង្សទ្រង់សុគតទៅ ។

៤– អ្នកស្រាវជ្រាវបានរកឃើញល្បើកអកសុទ្ធតែបែបខ្វី ហើយគេឃើញបែបវែងមួយច្បាប់នៅវត្តក្រូច ស្រុកព្រៃឈរ (កំពង់ចាម) ។

៥– ខ្ញុំបានប្រៀបធៀបបែបខ្វីនិងបែបវែងឃើញថា អ្នកតែងរឿងនេះមាន ២ នាក់ គឺ ម្នាក់តែងបែបខ្វី ម្នាក់ទៀតតែងបន្តពីបែបខ្វី បង្កើនសេចក្ដីជាផ្នែកកណ្ដាលទៀត ដើម្បីឲ្យទៅជាបែបវែង ដូចបានបញ្ជាក់ហើយខាងដើមនេះ ។ បានជាខ្ញុំថាដូច្នេះ ព្រោះខ្ញុំធៀបដើមកាព្យឃើញថា ពាក់កណ្ដាលខាងដើមនៃបែបវែងដូចគ្នានឹងបែបខ្វី ខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ ។ បែបខ្វីនោះច្រើនតែពាក្យទី ៧ នៃឃ្លាទី ១ ចាប់ជួននឹងពាក្យទី ៤ នៃឃ្លាទី ២, ពាក្យទី ៧ នៃឃ្លាទី ៣ ទទួលជួនពីពាក្យទី ៧ នៃឃ្លាទី ២ ហើយចាប់ជួននឹងពាក្យទី ៤ នៃឃ្លាទី ៤ ទៀត ។ ពីត្រឹមពាក់កណ្ដាលទៅខាងចុងនៃបែបវែង មានដើមកាព្យផ្សេងពីខាងដើម គឺ ការចាប់ចុងជួនពុំទៀងទាត់ទេ ច្រើនតែពាក្យទី ៣ ចាប់ចុងជួននឹងពាក្យទី ២ ហើយទឹកដមសំដីពុំមែនជាសំដីលោកសង្ឃផង ។ សំដីនៃអ្នកនិពន្ធផ្នែកខាងចុងនេះ ដែលអ្នកលេងហៅថា "សំដីមនុស្សឌីត" លំនាំស្រដៀងគ្នានឹងពាក្យក្រុមភ្លេងអាយ៉ៃ ក្នុងជំនាន់អាណានិគមបារាំងសែស ដែលសុភាព–ធម៌ខ្ចុះដុនដាប, ថែមទាំងដើមកាព្យលោត ៗ គឺ កាព្យពាក្យ ៧ សោះទេ ប៉ុន្តែចេះតែបន្ថែមញឹក ៗ ឲ្យទៅជាពាក្យ ៨ ខ្លះ ពាក្យ ៩ ខ្លះ ដោយដុំ ៗ

*ហើយច្រើនប្រើពាក្យដែលមានអក្សរជាមួយគ្នាញឹកញាប់ផង ដូចពាក្យថា:*

ស្បើយទុក្ខជាសុខក្នុងកាយា ទឹងញ៉ឹងញាក់ឲ្យយ៉ាងណាណាអូនស្រី កម្លាំងមានស្រាប់បំណាប់ថ្មី បំណុកប្ដីបំណើបអូន មិនស្លូតសោះ ៗ មិនស្លូតទេមាសមេតាងជឿបុះ ស្រីប្រុសជួបប្រាណស្មានស្មគ្រស្មោះ បើបេះក្រឡុះជួបក្រឡោះ ប្រកោះប្រកិតជិតមិនឃ្លាត ។ល។

*មួយទៀតផ្នែកខាងចុងនេះ មានពាក្យសៀមលាយចម្រុះផង ដូចពាក្យថា : ចៃ (ចិត្ត), យ៉ាកយ៉ាប់ (លំបាកខ្លាំង), ប៉ៃខាងណូន (ទៅខាងឯណោះ), យ៉ាងណៃណា (យ៉ាងណា), មីដាយថាអ:រ៉ៃ (មិនបានថាម៉េច), គេធ្វើប៉យ (គេធ្វើព្រងើយ); ក្នុងទីបញ្ចប់ថា: កំណាព្យកំណត់ហ្មត់ដល់ល្ងើ ៗ*

*មានពាក្យផ្ការដែលអ្នកនិពន្ធឯទៀត មិនដែលប្រើក្នុងការសរសេរ ដូចពាក្យថា :*

ខ្មោចអាគិរក់អ្នូទីគ្គ[១] មិនគួរឲ្យយកជាក្បួនខ្នាត

(១) ពាក្យអ៊ូទីឌូនេះ ទើបនឹងកើតថ្មី ជាសំដីអ្នកលេងភ៉ុំដាខបាននាំគ្នានិយាយលេង, អ្នកខ្លះនិយាយថា អូប្រូឌូ សំដៅសេចក្ដីថា : មនុស្សដែលដាក់ចិត្តនឹងល្បែងផ្សេង ៗ មានស្រីនិងស្រាជាដើម ។

សមតែធ្វើស្នួលដីចំណីត្នាត ទើបសមមារយាទឫករូបវា ។
មេណាវាដោយអាជែងគេ ចំពោះមេះនោះហ្នឹងស្រីសាធារណ៍
សួរធ្វើសំផឹងវិញក៏ជា បានប្រាក់ជួលស្វាវាឲ្យមើល ។

ព្រោះហេតុតែការពិនិត្យសង្កេតឃើញដូច្នេះ ទើបខ្ញុំហ៊ាននិយាយពេញមាត់ថា: ប្រាកដជាអ្នកនិពន្ធពីរនាក់ ម្នាក់គឺ លោកតាអាចារ្យ ដួង ធ្វើបានមួយផ្នែកខាងដើម មានសេចក្ដីជាពាក្យបញ្ចប់ស្រេច ហើយស្រាប់តែម្នាក់ទៀត គឺ លោកបំរើឧទ័យ ធ្វើមួយផ្នែកខាងចុងថែមទៀតក្នុងកាលខាងក្រោយ ។

លោកតាអាចារ្យ ដួង ប្រាកដជាធ្វើមុន ព្រោះលោកតានេះ កើតក្នុង គ.ស. ១៨០៧ ។ លោកធ្វើចៅអធិការប្រហែលក្នុងព្រះជន្ម ៣០ ឆ្នាំ ត្រូវនឹង គ.ស. ១៨៣៧ ។ លោកតាអាចារ្យ ដួង តែងល្បើកអកប្រហែលក្នុង គ.ស. ១៨៣៧ ឬលើសបន្តិចបន្តួច ។ បើដូច្នោះមែន អាយុកាលនៃល្បើកអកបែបខ្វីបាន ១៣០ ឆ្នាំហើយមកទល់នឹងឆ្នាំ ១៩៦៧ នេះ ។

ខ្ញុំថាដូចខាងលើនេះ ចំពោះល្បើកអកបែបខ្វី ។ បើស្រដីចំពោះបែបវែងវិញថា លោកបំរើឧទ័យ តែង ។ ពាក្យថា « បំរើឧទ័យ » នេះ

ជាការនៃមន្ត្រីក្នុងព្រះបរមកវាំង មានគេ ៗ គ្នារាំរាប់អក ។ ខ្ញុំស្មានថា លោកបំរើឌុរ័យ នេះ ប្រហែលជាលោកគា និន ដែលខ្ញុំបានស្គាល់លោកស្រពេចស្រពិលដែរ ក្នុងកាលដែលខ្ញុំជាសាមណេរនៅវត្តឧណ្ណាលោម លោកគាបំរើឌុច័យ និន ក៏ជាបព្វជិតចាស់ដកគង់នៅវត្តឧណ្ណាលោមដែរ ។

មានចំណុចមួយទៀតត្រង់នាមលោកចៅក្រមញាំង ដែលគួរឲ្យខ្ញុំយល់ថាប្រាកដជាលោកគាបំរើឌុច័យនិន ។ ព្រោះលោកញាំងនេះខ្ញុំរឹតតែស្គាល់ជាងលោកគា និន ទៅទៀត ។ ផ្ទះលោកញាំង នៅត្រង់ជ្រុងវិថីបាស្ទ័រ និងវិថីណាវ៉ុធ-អ៊ុម ខាងជើងវត្តលង្កា ។ ប្រហែលជាកាលលោកញាំងទើបនឹងចូលធ្វើការក្នុងតំណែងជាចៅក្រម ក្នុងគ្រាដែលខ្លួននៅកម្លោះ បានពឹងលោកបំរើឌុច័យនិន ក្នុងកាលដែលលោកជាមន្ត្រីក្នុងក្រុមជាងមាស ( ជាងស្ពាន់គ្រាប់ ) ឲ្យតែងបន្ទូ · ដើម្បីជាគ្រឿងកែអផ្សុក ឬ ដើម្បីបញ្ជាក់ថាខ្លួនលោកទាំងពីរនាក់ធ្លាប់ប្រទះនឹងសភាពបែបដូចរឿងអកនោះ ។

ការបំរើឌុច័យធ្លាប់តំគ ៗ គ្នា លើជនមានឈ្មោះផ្សេង ៗ ក៏មែនពិត, ប៉ុន្តែជនឯទៀត ដែលធ្លាប់បានទទួលការនេះ ពុំមែនមានឈ្មោះថាជាកវីទេ, មានតែលោកបំរើឌុច័យនិន ទើបមានឈ្មោះថាជាកវី ព្រោះ

លោកបានតែរឿងស្រទបចេកជាដើម ។ រឿងស្រទបចេក លោកបំរើឧទ័យនិន តែងក្នុងកាល ព.ស. ២៤៣១ បើគិតមកទល់នឹងឆ្នាំនេះ (ព.ស. ២៥១០) ឃើញថាអាយុកាលនៃរឿងស្រទបចេកបាន ៧៩ ឆ្នាំហើយ ។ សាស្ត្រាអកបែបវ៉ែងបើលោកបំរើឧទ័យ និង តែងបន្ថែមក្នុងជំនាន់គ្នានោះ ឬមុននេះក៏ដោយ ក៏ប្រាកដជាក្នុងកាលខាងក្រោយល្បើកអកបែបខ្ញុំរបស់លោកតាអាចារ្យជួនមែន ។

ចំណុចមួយទៀតនៅត្រង់ការប្រៀបធៀបអត្ថបទគឺ : អត្ថបទទាំងប៉ុន្មានរបស់លោកតាអាចារ្យជួនឥតអត្ថបទណាមួយវែងទេ, ដែលវែងជាងគេមានតែល្បើកអក ព្រោះលោកតែងក្នុងពេលនៅទំនេរ លើកំពូលភ្នំជីសូរហើយនិងរឿងសេកសារិកាមួយទៀត ព្រោះជារឿងមានស្រាប់នៅក្នុងគម្ពីរ ។ ក្រៅពីនេះសុទ្ធតែអត្ថបទខ្លីៗ ព្រោះលោកតែងក្នុងគ្រាមមាញឹកផង ហើយជាធម្មតារបស់មនុស្សមានចិត្តរហ័ស តែងតែធ្វើការពុំសូវចប់ជួរចេះ ។ ឯលោកបំរើឧទ័យនិនប្រាកដមានការវែងៗដូចរឿងស្រទបចេកក៏វែង រឿងអកដែលលោកលើកបន្ថែមទៀតក៏វែងដែរ; ខ្ញុំស្គាល់លោកពុំច្បាស់ ប៉ុន្តែខ្ញុំអាចសង្កេតបានថា ធម្មតាជាងមាសតែងតែមានព្យាយាមច្រើន មានចិត្តធ្ងន់ធ្ង មានចរិយាទឹងធឹង ។ ព្រោះតែលោកមានព្យាយាម

ដៃសមុទ្រត្រពាំងរូង នេះផង ។

វេលាម៉ោង ២ រសៀល ក៏ចាប់បន្តដំណើរតាមកាណូតមួយគ្រឿង កាត់តាមដៃសមុទ្រ និងសសៀរមាត់សមុទ្រក្រៅអស់រយៈពេល ៤ ម៉ោងទៀត ទើបបានទៅដល់ក្រុងខេមរភូមិន្ទ ដែលជាទីតាំងនៃខេត្តកោះកុង ។ ពេលចុះពីកាណូត មានសហជីវិនអភិបាលខេត្តរង តំណាងសហជីវិនអភិបាល ខេត្តបានទៅរង់ចាំទទួល និងនាំទៅស្នាក់អាស្រ័យនៅបដិសណ្ឋារមណ្ឌលប្រចាំខេត្ត ដែលមានការរៀបចំយ៉ាងផ្ចិតផ្ចង់គួរជាទីសរសើរ ។

លុះព្រឹកឡើង ថ្ងៃអាទិត្យទី ៣ មីនា ១៩៦៨ ក្រោយដែលស្រស់ស្រូបពេលព្រឹកហើយ វេលាម៉ោង ៨ ក៏មានរៀបចំពិធីមួយនៅទីស្នាក់ការនៃសង្គមរាស្ត្រនិយមប្រចាំខេត្ត ដើម្បីប្រគល់សៀវភៅអំណោយចំពោះបណ្ណាល័យថ្មីដែលកសាងឡើងនៅក្នុងវត្តព្រះគ្រូមេគណខេត្ត និងដើម្បីពិគ្រោះកិច្ចការផ្សេងៗជាមួយព្រះសង្ឃ ដែលលោកមានការៈគ្រប់គ្រងព្រះពុទ្ធសាសនានៅក្នុងខេត្តនោះ ។

នៅពេលដែលសហជីវិនអនុរដ្ឋលេខាធិការ អញ្ជើញដល់កន្លែងប្រារព្ធពិធី លោកបានទទួលបដិសណ្ឋារកិច្ចយ៉ាងគួរសមអំពីសំណាក់អស់លោកជានាយក្រុមកងការប្រចាំខែត្រ គឺមាន ៖

សហជីវិន ពាន់-ថៃ អភិបាលខែត្ររងទី ២ តំណាងសហជីវិន

អភិបាលខេត្តដែលលោកមានបេសកកម្ម

សហ. ឡឹក-ឆាយ ចាងហ្វាងសាលាលហុកោះកុង

– ហោ-ជា នាយផ្នែកសាធារណការ

– ស៊ឹម-ឌុជាន នាយក្រុមហោរាញ្ញត្តប្រចាំខេត្ត

– បាយ-សារឿន ចាងហ្វាងអនុវិទ្យាល័យកោះកុង

– គីម សួយ អធិការនៃ បឋមសិក្សា

– សុន ស៊ីកន នាយផ្នែកកសិកម្ម

– ម៉ែន-សុកាន នាយផ្នែកបសុពេទ្យ

លុះទទួលការគួរសមនេះហើយ សហជីវិនអនុរដ្ឋលេខាធិការ ព្រមទាំងសហការី បានអញ្ជើញចូលក្នុងមន្ទីររៀបចំពិធី ថ្វាយបង្គំព្រះសង្ឃ គឺមានព្រះតេជព្រះគុណ សិង្ហនាជ-សួង ជាមេគណខេត្ត, ព្រះតេជព្រះគុណ ភី-ឆ៉ា ជាអនុគណ និងព្រះសង្ឃជាបរិស័ទចំនួន ៤០ អង្គដែលគង់រង់ចាំនៅទីនោះ ៗ ក្រោយដែលសំណេះសំណាលបន្តិចមក សហជីវិនអនុរដ្ឋលេខាធិការបានថ្លែងសុន្ទរកថាមួយយ៉ាងក្បោះក្បាយ ដែលយើងនឹងចុះជូនទាំងស្រុងនៅទំព័របន្ទាប់នេះ ៗ បន្ទាប់ពីសុន្ទរកថា ព្រះសង្ឃក៏បានស្វាធ្យាយជយន្តោប្រសិទ្ធពរ ជូនសហជីវិនអនុរដ្ឋលេខាធិ-ការ តំណាងព្រះរាជរដ្ឋាភិបាល រួចហើយព្រះតេជព្រះគុណមេគណព្រះអង្គ បានវេរព្រះសង្ឃដីកាទៅព្រះតេជព្រះគុណអនុគណ ថ្លែងអំណរគុណ

តបវិញ ដែលជាអាទិ៍ព្រះអង្គបានថ្លែងបញ្ជាក់ថា ៖ លើកនេះហើយជាលើកទី១ ដែលមានតំណាងរាជរដ្ឋាភិបាលខាងក្រសួងធម្មការ បានអញ្ជើញមកដល់ខេត្តនេះ ជាហេតុធ្វើឲ្យព្រះសង្ឃគ្រប់អង្គកើតការរំភើបព្រះទ័យក្រៃលែង ដើម្បីបានឱកាសប្រស្រ័យកិច្ចការផ្ទាល់ក្នុងរបៀបគ្រប់គ្រងផ្នែកពុទ្ធសាសនានៅក្នុងខេត្តឆ្ងាយនេះ ។

មួយទៀត ខាងក្បួនច្បាប់ព្រះពុទ្ធសាសនា គឺ គម្ពីរសៀវភៅធម៌អាថ៌នេះឯង ខេត្តនេះនៅមានការខ្វះខាតជាប្រាកដ សូមឲ្យបានក្រសួងធម្មការ ដឹកនាំសៀវភៅគ្រប់មុខ ដែលពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពផ្សាយហើយ យកមកឲ្យក្នុងគ្រានេះទុកដូចជាជំនួយមួយធំឥតគណនាត្រូវចំសេចក្តីស្រេកឃ្លានដែលរង់ចាំច្រើនឆ្នាំមកហើយ ។ ទ្រង់បញ្ជាក់ថា ៖ រដ្ឋាភិបាលសង្គមរាស្ត្រនិយម ក្រោមព្រះកិច្ចដឹកនាំនៃសម្តេចឪជាអម្ចាស់ តែងបានគិតគូរគ្រប់ផ្នែកវឌ្ឍនធម៌ មានវិស័យព្រះពុទ្ធសាសនានេះ ជាដើម ។ មុននឹងបញ្ចប់ ព្រះតេជព្រះគុណព្រះអនុគណ បានរ៉ាយរ៉ាប់យ៉ាងខ្លី អំពីសេចក្តីលំបាកខ្វះក្នុងដំណើរប្រព្រឹត្តទៅនៃវត្តអារាមនានា ដោយសារនិយមទំនៀមស្រុក និងអំពីសំណូមពរ សុំឲ្យបាននិច្ចភត្តសំរាប់សមណសិស្សឲ្យបានច្រើនរូប ដើម្បីទៅសិក្សាបន្តវិជ្ជាពុទ្ធសាសនានៅក្រុងភ្នំពេញ ។

សហជីវិនអនុរដ្ឋលេខាធិការ បានទទួលសំណូមពរទាំងនេះ ដើម្បី

នាំយកមកលៃលកឲ្យបានដូចបំណង និងបានប៉ង់ថា និងជួយផ្ដល់សៀវភៅក្បួនខ្នាតគ ១ ទៅទៀត កាលណាក្រសួងបានបោះពុម្ពផ្សាយថ្មី ១ ទៀតហើយ ។

បន្ទាប់ពីនោះ ក៏មានការប្ដូរយោបល់គ្នា រវាងព្រះតេជព្រះគុណព្រះមេគណនិងអនុគណ អំពីបញ្ហាផ្សេង ១ ដើម្បីរិះរកមធ្យោបាយឲ្យកាន់តែមានប្រសិទ្ធភាពឡើងខាងវិស័យព្រះពុទ្ធសាសនា ។ ហួតដល់ម៉ោង៩ កន្លះ ទើបបានហើយសព្វគ្រប់ ដោយមានថតរូបទុកជាអនុស្សាវរីយផង ។

សហជីវិនអនុរដ្ឋលេខាធិការ និងសហការី បានក្រាបថ្វាយបង្គំលាព្រះសង្ឃ និងលាអ្នកកជការគ្រប់គ្នា ចុះកាណូតធ្វើដំណើរវិលមកត្រពាំងរូងវិញ ។ នៅម៉ោង ១១ កន្លះ បានចូលទៅផែកោះកាពិ ដើម្បីទទួលអាហារថ្ងៃត្រង់ រួចក៏បន្តដំណើរតាមផ្លៃសមុទ្រទៅទៀត រហូតម៉ោង ១៦ ទើបបានដល់ត្រពាំងរូង ហើយឡើងរថយន្តបន្តដំណើរមកកំពង់ ដែលបានមកដល់នៅម៉ោង ២៤ អធ្រាត្រ ។

## ការចាប់អារម្មណ៍ពិសេស

កងដំណើរទស្សនកិច្ចទៅខេត្តកោះកុងនេះ ពិតមែនតែធ្វើដោយរយៈពេលយ៉ាងខ្លីបំផុត ប៉ុន្តែយើងអាចដកស្រង់ការចាប់អារម្មណ៍បានខ្លះអំពីទេសភាពស្រុក អំពីបរអ្នកស្រុក និង អំពីទំនៀមទម្លាប់ខ្លះទៀត ។

ទេសភាពទូទៅជាការប្លែកភ្នែកណាស់ ព្រោះជាទេសភាពសមុទ្រ ហើយជាដៃសមុទ្រផង ក៏មានកោះរដិបរដុប ដែលគ្របដណ្ដប់ទៅដោយដើមស្នាប់ និង ដើមកោងកាង ដែលបញ្ឈរស្រោង តែមិនខ្ពស់ប៉ុន្មានទេ ។ ឯខាងក្រោមដើមនោះ ដូចក៏គ្មានឃើញដីឡើយ សុទ្ធសឹងតែទឹក ។ ប្រឡាយធំដែលជាព្រែកនោះក្រវេចក្រវៀចបត់បែន នៅសងខាងមានដើមចាកដុះដង្ហែរត់ផ្លូវ ពាសពីមុខ ដើមកោងកាងរត់ផ្លូវអែបពីក្រោយ យូរៗ ឃើញមានផ្ទះអ្នកស្រុកមួយៗ ។ លុះទៅដល់ក្រុងខេមរភូមិន្ទ ក៏ឃើញថាជាក្រុងធំ លៃទុកដីជាសង្កាត់ភូមិឋាន ជាផ្លូវថ្នល់យ៉ាងច្រើនហើយធំទូលាយផង ។ អគាររាជការ សង់ពីបាយអស្ទើរតែទាំងអស់. ឯផ្ទះផ្សារ សង់ពីឈើជាល្វែងៗ ក៏ច្រើនណាស់ដែរ ។

អ្នកស្រុកដែលនៅជាប់នឹងសមុទ្រក្រៅ ដូចជានៅដងទង់ (ទីតាំងក្រុងខេមរភូមិន្ទ) នៅពាមក្រសោប នៅកោះកាពិ កោះមូល ភាគច្រើនជាអ្នកនេសាទ ។ ឯអ្នកនៅតាមដៃសមុទ្រចូលជ្រៅៗ ដូចជានៅត្រពាំងរូង នៅកោះកុងក្រៅជាដើម គេច្រើនធ្វើចំការដំណាំ មានភៀវ សារម៉ាវ មាក់ប្រាង ។ល។ របរពិសេសប្លែកមួយទៀត គឺការស្វែងរកខ្លឹមចន្ទន៍ក្រស្នា ប៉ុន្តែយើងស្តាយជាអនេក ព្រោះពេលខ្លីពេក មិនអាចឲ្យយើងសាកសួរស្រាវជ្រាវយកពត៌មានច្បាស់អំពីរបរពិសេសនេះ មករៀបរៀងឲ្យបានល្អិតល្អន់ទៅឡើយ ។ ចំណែកទំនៀមស្រុកទេសក៏ដូចនោះដែរ

យើងគ្រាន់តែសង្កេតឃើញថា របៀបស្លៀកពាក់អ្នកស្រុក ពិសេសស្រី ៗ ស្លៀកពាក់តែពណ៌យ៉ាងគោគាវ របៀបរៀបចំផ្ទះ ក៏ប្លែកដោយគេនិយមតុបតែងលំអដោយផ្កាកៀ និងរូបលំអផ្សេង ៗ ។

## សុន្ទរកថា

សហជីវិន អ៊ុភា-ម៉ូត

### អនុរដ្ឋលេខាធិការក្រសួងធម្មការ

សូមនមស្ការ ព្រះតេជព្រះគុណមេគណ

សូមពិតពុទ្ធដីកាព្រះថេរានុត្ថេរគ្រប់ព្រះអង្គ

សូមជំរាបសហជីវិនអភិបាលខេត្រ និងសហជីវិនី សហជីវិនទាំងអស់ ដែលបានអញ្ជើញមកជួបជុំក្នុងពេលនេះ ។

ខ្ញុំព្រះករុណា-ខ្ញុំមានសេចក្ដីរីករាយដ៏ក្រៃលែង ដែលបានធ្វើជាតំណាងរាជរដ្ឋាភិបាល នាំយកសៀវភៅក្បួនខ្នាតនានាជាភាសាខ្មែរចំនួន ២៣០ក្បាល ដែលវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ នៅក្រសួងធម្មការបានបោះពុម្ពផ្សាយ ។

គោលបំណងធំរបស់រាជរដ្ឋាភិបាល ក្នុងការបោះពុម្ពដើម្បីផ្សាយនូវសៀវភៅទាំងនេះ អាស្រ័យលើមូលហេតុពីរយ៉ាងគឺ៖

១-ដើម្បីផ្សព្វផ្សាយក្បួនច្បាប់ ដែលជាលក្ខណ៍គោលខាងព្រះពុទ្ធ-សាសនា ដែលខ្មែរយើងច្បាប់តែបានគោរពរៀងមកកប់ពាន់ឆ្នាំមកហើយ ហើយសព្វថ្ងៃនេះទៀត យើងបានតម្កល់ទុកជាសាសនារបស់រដ្ឋពេញលក្ខណៈសឹងមានជាប់នៅក្នុងសន្ដានចិត្តបណ្ដាជនខ្មែរយើង នៅគ្រប់និគមជនបទទាំងអស់ ជាកស្ដុតាងមានវត្តដ៏ស្កុកស្កម្ភនៃព្រះតេជព្រះគុណៈមគណនេះជាដើម ។

២ - ដើម្បីផ្សាយវប្បធម៌ខ្មែរ ឲ្យបានជ្រួតជ្រាបទៅគ្រប់ទិសទីក្នុងព្រះរាជាណាចក្រ ព្រោះថាវប្បធម៌នេះជាមូលដ្ឋានធ្វើឲ្យសន្ដានចិត្តអ្នកស្រុកមានការភ្ញាក់ស្មារតី និងមានគំនិតយល់សិប្បកម្មក្នុងអារ្យធម៌ជាតិ គឺនិយាយឲ្យខ្លីថាមានចិត្តស្រឡាញ់ជាតិខ្លួនកាន់តែមាំទាំឡើង ។

មួយទៀត, ដោយវប្បធម៌ខ្មែរយើងជាវប្បធម៌ចាស់បុរាណណាស់ គឺថាមានកំណើតមកជាង២ ពាន់ឆ្នាំមកហើយ ហើយដែលសម័យនោះប្រទេសជិតខាងយើងខ្លះ មានប្រទេសសៀមជាដើមពុំទាន់ទាំងមានកើតរូបរាងមានឈ្មោះជាសញ្ជាតិមួយនៅឡើយផង ។ វប្បធម៌ខ្មែរសម័យដើមនោះតែងបានរីកចំរើនជាបំដាប់រៀងរាល់សតវត្ស មិនដែលអាក់ខានឡើយ ហេតុនេះហើយបានជាមែកធាងគ្រប់បែបគ្រប់យ៉ាងក្នុងវប្បធម៌ខ្មែរ មានសព្វគ្រប់ឥតសល់ចន្លោះ ដូចជាអក្សរសាស្ត្រ សិល្បៈ សាសនាជាដើម ។ រូបចម្លាក់យើងនៅប្រាសាទថ្មនានា ដែលកសាងសុទ្ធតែជាងមួយពាន់ឆ្នាំ

ហើយនោះសំដែងពីសិល្បៈដំណែតនាយដងពាទ័យក្នុងអក្សរសាស្ត្រផង និងពីគោលគំនិតក្នុងសាសនាផង ។ វត្ថុបុរាណទាំងនេះហើយជាសាក្សីបញ្ជាក់ឲ្យយើងដឹងច្បាស់ថា ជាតិខ្មែរយើងជាមេបង្កើតវប្បធម៌សម្រាប់ជាតិខ្មែរខ្លួនឯងផង សម្រាប់ផងជាតិនានានៅជិតខាងខ្លួនមានជាតិសៀមជាអាទិ ។ បានជាយើងពោលដូច្នេះ ព្រោះអ្នកស្រាវជ្រាវ អ្នកសិក្សានៃប្រទេសធំ ៗ មានបារាំង អង់គ្លេសជាដើម គេបានសរសេរបញ្ជាក់ជាច្រើនសៀវភៅថា៖ អារ្យធម៌-វប្បធម៌ខ្មែរបានចូលទៅស្រុកសៀម គ្រប់ផ្នែក ទាំងតួអក្សរ ទាំងភាសា ទាំងក្បាច់ចម្លាក់ របាំរាំរែក ទាំងគម្ពីរដីកាខាងព្រះពុទ្ធសាសនា និងទំនៀមទម្លាប់ផ្សេង ៗ សឹងតែគ្រប់យ៉ាង ៗ ជាក់ស្តែងដូចជាព្រះតេជព្រះគុណគ្រប់ព្រះអង្គ ដែលបានសិក្សាវិជ្ជាព្រះពុទ្ធសាសនាលោកធ្លាប់បានប្រាប់ស្រាប់មកហើយថា គម្ពីរដើមដែលនៅជាគ្រាំង ឬជាសាស្ត្រាស្លឹករឹតរបស់សៀមនោះ មានជានពិតប្រាកដជាអក្សរខ្មែរភាសាខ្មែរច្រើនណាស់ ។ បើយើងគិតពីប្រវត្តិពង្សាវតារវិញ យើងក៏ឃើញថា កាលសៀមតាំងបានជាអាណាចក្រខ្លួន ហើយក៏បង្កើតជាសង្គ្រាមយ៉ាងញឹកញាប់ជាមួយប្រទេសខ្មែរ ។ ជួនកាលខ្លះ សង្គ្រាមនោះ ក៏មានជ័យលើប្រទេសយើងម្តង ៗ គេក៏ដឹកជញ្ជូនយកក្បួនច្បាប់ខ្មែរ និង ចាប់យកអ្នកចេះដឹងខ្មែរយើង នាំទៅស្រុកគេដើម្បីសាបព្រោះពូជវប្បធម៌ខ្មែរឲ្យដុះដាលនៅឯនោះទៅ ។ ត្រង់នេះហើយ បានជា

សព្វថ្ងៃ មានអ្នកខ្លះ យល់ច្រឡំថាវប្បធម៌ខ្មែរយើងមានឥទ្ធិពលមកពីសៀមទៅវិញ ។ ការយល់នេះខុសស្រឡះ ឯការពិតខ្មែរយើងទេតើដែលជាអ្នកសាបព្រោះវប្បធម៌នេះឲ្យទៅសៀម ហើយដោយសារតែសៀមលួចដឹកជញ្ជូនទៅស្រុកខ្លួនស្ទើរតែអស់យ៉ាងនេះ ទើបអ្នកសិក្សាខ្មែរយើងជាន់ៗក្រោយម្ន៉ម្នានាំគ្នាទៅរៀនយកវប្បធម៌របស់ខ្លួន ដែលសៀមលួចទៅនោះយកមកវិញតែ ប៉ុណ្ណោះ ។ ទាំងនេះហើយជាភស្តុតាងបញ្ជាក់ពីដើមកំណើតវប្បធម៌ខ្មែរយើង ។

អាស្រ័យហេតុនេះ សព្វថ្ងៃ អ្នកស្រាវជ្រាវ អ្នកសិក្សាទាំងអស់គិតរកឡើងវិញនូវក្បួនខ្នាតបុរាណគ្រប់មុខវិជ្ជា ដើម្បីបោះពុម្ពផ្សាយឲ្យបានជ្រួតជ្រាបទៅគ្រប់ទិសទី ទោះបីទីនោះនៅឆ្ងាយអំពីរាជធានីយើងដូចក្រុងខេមរភូមិន្ទនេះជាដើម ឲ្យជនរួមជាតិយើងបានក្រេបរសជាតិពិតប្រាកដនៃវប្បធម៌ខ្មែរ តម្រូវតាមព្រះរាជបំណងដ៏ភ្លឺស្វាងនៃសម្តេចឪជាអគ្គមគ្គុទ្ទេសក៍ជាតិយើង ដែលព្រះអង្គតែងត្រាស់បញ្ជាដាស់តឿនឲ្យកូនចៅព្រះអង្គដើរទៅរកផ្លូវចំរើនរុងរឿងគ្រប់វិស័យ មានវិស័យវប្បធម៌នេះជាអាទិ ។ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលមានអង្គសម្តេចឪជាព្រះប្រមុខ តែងតែខំខ្នះខ្នែងសម្រេចគោលបំណងនេះឲ្យបានរួសរាន់ជាដរាប ទើបបានក្រសួងធម្មការបានចេញសារាចរជាញឹក

ញាប់រំលឹកទៅគ្រប់វត្ត សុំឲ្យកសាងបណ្ណាល័យសម្រាប់ដំកល់និងផ្សាយក្បួនខ្នាតសព្វគ្រប់របស់ជាតិយើង តាំងគម្ពីរសាស្ត្រាចាស់ ៗ ដែលមានស្រាប់មកហើយ និងក្បួនច្បាប់ដែលបោះពុម្ពថ្មី ៗ ផង ៗ ឥឡូវព្រះតេជព្រះគុណ បានកសាងបណ្ណាល័យនេះ ពេញជាត្រូវតាមបំណងនៃរាជរដ្ឋា-ភិបាលហើយ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងតាងនាមរាជរដ្ឋាភិបាលនូវអំណរព្រះគុណព្រះអង្គ និងអំណរគុណចំពោះរាជការខេត្ត និងអ្នកមុខអ្នកការទាំងអស់ ដែលបានជួយជ្រោមជ្រែងឲ្យសមិទ្ធិនេះ បានសម្រេចឡើង ។ ហើយសូមថ្លែងទទួបម្ដងទៀត នូវសេចក្ដីសរសើរដ៏ស្មោះអស់ពីដួងចិត្ត ចំពោះព្រះទ័យឆ្ងៀវឆ្លាសនៃព្រះតេជព្រះគុណមេគណនិងព្រះសង្ឃគ្រប់អង្គ ដែលបានយល់ច្បាស់នូវឧត្ដមប្រយោជន៍ដ៏ជ្រាលជ្រៅក្នុងការផ្សាយវប្បធម៌ជាតិ ដោយការកសាងបណ្ណាល័យនៅក្នុងទីនេះ ។

ខ្ញុំព្រះករុណា-ខ្ញុំ សូមប្រសិទ្ធិពរ សូមឲ្យបណ្ណាល័យនេះ មានការរីកចំរើនយ៉ាងឆាប់រហ័សជាតិយោភាគ ។

ភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៦៨

លេខ.៨០៩ ព.ប. សូមក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ នៃសម្តេច
ព្រះសង្ឃរាជថ្នាក់ទី ១ ជាអម្ចាស់

សូមទ្រង់ព្រះមេត្តាជ្រាប ។

ក្នុងឱកាសមហានក្ខត្តឫក្ស នៃពិធីបុណ្យចូលឆ្នាំ វក សំរិទ្ធិស័ក ព.ស. ២៥១២ នេះ,

ទូលព្រះបង្គំជាខ្ញុំ តាងនាមព្រះសង្ឃ និងគ្រហស្ថ ជាបុគ្គលិក នៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យទាំងមូល,

សូមព្រះរាជឱកាស ក្រាបបង្គំទូលថ្វាយ នូវព្រះសព្ទសាធុការពរ សិរីសួស្តី ជោគជ័យមង្គលមហាប្រសើរ បរមសុខចម្រើនរុងរឿង ថ្វាយសម្តេចជាអម្ចាស់ សូមល្អងធូលី បានប្រកបតែនូវព្រះពុទ្ធពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណ គ្រប់ទិវារាត្រី ។ សូមសម្តេចជាអម្ចាស់ ប្រកបដោយនូវព្រះជន្មាទីឃាយុ ជានិរាយព្រះវស្សា ដើម្បីបានជាម្លប់ដ៏ត្រជាក់សម្រាប់ពុទ្ធបរិស័ទក្នុងកម្ពុជរដ្ឋ និងបានគង់នៅជាព្រះពន្លឺត្រចះត្រចង់ នៃវប្បធម៌អក្សរសាស្ត្រជាតិ ។.

គួរពុំគួរ សូមសម្តេចជាអម្ចាស់ ទ្រង់ព្រះមេត្តាប្រោស ។

ទូលព្រះបង្គំជាខ្ញុំ លាង ហ៉ាប អាន

នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ ថ្ងៃទី ១០ មេសា ១៩៦៨

លេខ.៤១២ ព.ប                    សូមនមស្ការដោយគោរព ចំពោះសម្តេចព្រះ

មង្គលទេពាចារ្យ ឧត្តម ទីប្រឹក្សាគណៈធម្មយុត្តិកនិកាយ

វត្តបទុមវតី រាជធានីភ្នំពេញ

សូមព្រះករុណាជ្រាប ។

ក្នុងឱកាសមហានក្ខត្តឫក្ស នៃពិធីបុណ្យចូលឆ្នាំ វក សំរឹទ្ធិស័ក ព.ស-២៥១២ នេះ

ខ្ញុំព្រះករុណា ក្នុងនាមព្រះសង្ឃ និង គ្រហស្ថ ជាបុគ្គលិកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យទាំងមូល,

សូមព្រះវរោកាស ប្រគេននូវព្រះពរសព្ទសាធុការ សិរីសួស្តីជោគជ័យមង្គលមហាប្រសើរ បរមសុខ ចំពោះសម្តេចជាម្ចាស់ សូមសម្តេចបានប្រកបតែដោយនូវព្រះពុទ្ធពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈគ្រប់ទិវារាត្រី ។ សូមសម្តេចជាម្ចាស់ប្រកបដោយព្រះជន្មាទីឃាយុ ជាងរយព្រះវស្សា មានព្រះសុខភាពបរិបូណ៌ ដើម្បីបានជាម្លប់ដ៏ត្រជាក់ សម្រាប់ពុទ្ធបរិស័ទគ្រប់ៗរូប តរៀងទៅ ។

គួរពុំគួរ សូមសម្តេចជាម្ចាស់មេត្តាប្រោស ។

ខ្ញុំព្រះករុណា លាង-ហាប់អាន

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ ថ្ងៃទី ១០ មេសា ១៩៦៨

លេខ ៨១១ ព.ប សូមនមស្ការដោយគោរព ចំពោះសម្ដេចព្រះពោធិវង្ស

សូមព្រះករុណាជ្រាប ។

ក្នុងឱកាសមហានក្ខត្តឫក្ស នៃពិធីបុណ្យចូលឆ្នាំ វក សំរិទ្ធិស័ក ព.ស. ២៥១២ នេះ,

ខ្ញុំព្រះករុណា គាំងនាមព្រះសង្ឃ និង គ្រហស្ថ ជាបុគ្គលិកនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យទាំងមូល,

សូមព្រះវរោកាស ប្រគេននូវព្រះពរសព្ទសាធុការ សិរីសួស្ដី ជោគជ័យមង្គលមហាប្រសើរ បរមសុខចម្រើនរុងរឿង ចំពោះសម្ដេចជាម្ចាស់ សូមសម្ដេចបានប្រកបតែដោយនូវព្រះពុទ្ធពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ គ្រប់ទិវារាត្រី ។ សូមសម្ដេចជាម្ចាស់មានព្រះសុខភាពបរិបូណ៌ ប្រកបដោយព្រះជន្មា ទីឃាយុ ជាងវយព្រះវស្សា ដើម្បីគង់ជាម្លប់ដ៏ត្រជាក់សម្រាប់ពុទ្ធបរិស័ទក្នុងកម្ពុជរដ្ឋ និងបានជាព្រះពន្លឺចំពោះវប្បធម៌ អក្សរសាស្ត្រជាតិ ព្រមទាំងជាគ្រឹះនៃពុទ្ធិកសិក្សា ដែលមានវិវឌ្ឍន៍អស្ចារ្យ ក្នុងសម័យសង្គមរាស្ត្រនិយម ។

គួរពុំគួរ សូមសម្ដេចជាអម្ចាស់ មេត្តាប្រោស ។

ខ្ញុំព្រះករុណា លាង-ហាប អាន

នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ,

៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៤០ ខែ មេសា

ព.ស. ២៥១២ គ.ស. ១៩៦៨

-ភ្នំពេញ-

ÉCOLE FRANÇAISE D'EXTRÊME-ORIENT
BIBLIOTHÈQUE
P.P.
F.745

៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ — ផ្នែកសាសនា — ទំព័រ

១– កបិលកថាសង្ខេប (ត) សម្ដេចព្រះពោធិវង្ស រៀបរៀង . . . . . ៣៦០
២– រឿងមហោកាលទសក (សហ. ប៊ូ-ប៊ូ ប្រែរៀបរៀង) . . . . . ៣៧១
៣– រឿងព្រះទេវទត្ត (សហ. ប៊ូ-ប៊ូ ប្រែ-រៀបរៀង) . . . . . ៣៧៥

ផ្នែកអក្សរសាស្ត្រ

៤– វចនានុក្រមសំស្ក្រឹត ខ្មែរ (ព្រះមហា ប៉ាង.ខាត់) . . . . . ៣៧៧
៥– ល្បងសិក្សា ប្រវត្តិអក្សរសាស្ត្រខ្មែរ (សហ. លាង.ហ័បអាន) . . . ៣៨១
៦– រឿងចៅតែលលក (ត ចប់) (សហ. ព្រួច-ភុម រៀបរៀង) . . . ៣៩១
៧– រឿងសាមកុក (ត) (ឧកញ៉ា នូ-កន) . . . . . . . . ៤១៣
៨– ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត (លោក ញ៉ុក.ថែម) . . . . ៤២៣
៩– ជីវប្រវត្តិសង្ខេប (សហ. ហែល-ស៊ុំផា) . . . . . . . . ៤៣៣
១០– រឿងពិសពស និង ពិសត្រី (សហ. លី-ធាមតេង រៀបរៀង តាមឯកសារ) ៤៤១

ផ្នែកកំណត់-ប្រវត្តិការណ៍

១១– ពិធីបុណ្យឆ្លងព្រះវិហារ-បញ្ចុះខណ្ឌសីមា វត្តនិរោធរង្សី . . . . ៤៤៦
១២– សុន្ទរកថានៃព្រះឧត្តមកោសល ស៊ូរ ហាយ . . . . . . . ៤៥៤
១៣– ឯកសារព្រះរាជក្រមស្ដីពីពុទ្ធសាសនបណ្ឌិត្យ . . . . . . . ៤៦៦

ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការល្អមក, ឲ្យធ្វើល្អទៅ,
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប. ព.

# កឋិនកថាសង្ខេប

*សម្ដេចព្រះពោធិវង្ស ហួត តាត រៀបរៀង*

*(ក)*

*រួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ គិតថា "អញនឹងត្រឡប់មកវិញ" ; លុះទៅដល់ខាងក្រៅឧបចារសីមា ក៏ឲ្យគេជួយធ្វើចីវរនោះ ។ កាលដែលធ្វើចីវររួចហើយ ក៏នៅតែគិតថា "អញនឹងត្រឡប់វិញ ។" ប៉ុន្តែមិនទាន់ត្រឡប់ ក៏ចេះតែនៅខាងក្រៅឧបចារសីមានោះ គ្រាតែដល់កំណត់កាលដែលកឋិនដោះ គឺកន្លងហួសថ្ងៃ១៥កើតខែផល្គុនទៅ ។ កឋិនរបស់ភិក្ខុនោះ ក៏ដោះក្នុងគ្រាដែលកន្លងហួសសីមា គឺកន្លងហួសខេត្រនៃកឋិន ។*

*(ក្នុងមាតិកានេះ ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ក្រោយ)*

៨– សហុព្ភារក មាតិកា មានការដោះកឋិនរួមជាមួយនឹងភិក្ខុទាំងឡាយ ។ សេចក្តីថា ភិក្ខុបានក្រាល-បានអនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើ ចេញពីអាវាសទៅ គិតថា "អញនឹងត្រឡប់វិញ"; កាលទៅដល់ខាងក្រៅឧបចារសីមា ក៏បានឲ្យគេជួយធ្វើចីវរនោះ លុះធ្វើចីវររួចហើយ គិតថា "អញនឹងត្រឡប់វិញ ៗ" ហើយបានត្រឡប់មកទាន់ពេលដោះកឋិន ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថា ដោះជាមួយនឹងភិក្ខុទាំងឡាយ ។

(គង់មាតិកានេះ បលិពោធទាំងពីរដាច់ស្មើគ្នា មិនមុនមិនក្រោយ គឺដាច់គង់ពេលដែលចប់កម្មវាចា) ។

មាតិកា ៨ ចប់ដោយសង្ខេប

កឋិនុព្ភារៈ "ការដោះកឋិន ឬ កឋិនដោះ"

ស. ការដោះកឋិន មានប៉ុន្មានយ៉ាង ?

ឆ. គង់គម្ពីរវិនយាលង្ការដីកាថា(១) ការដោះកឋិនមានពីរយ៉ាងគឺ អដ្ឋមាតិកាឧព្ភារៈ ១ អន្តរុព្ភារៈ ១ ។

ស. ការដោះកឋិនទាំងពីរខាងលើនេះ មានសេចក្តីដូចម្តេច ហើយផ្សេងគ្នាយ៉ាងណាខ្លះ ?

ឆ. អដ្ឋមាតិកាឧព្ភារៈ ប្រែថា "ការដោះកឋិន ឬកឋិនដោះ តាម

---

១ ឧព្ភារោ ទុវិធោ អដ្ឋមាតិកាឧព្ភារអន្តរុព្ភារវសេន ។

មាតិកា ៨ ” ។ សេចក្ដីអធិប្បាយថា ការដោះកឋិនតាមមាតិកា ៧ គឺតាំងពី បក្កមនន្តិកា ដល់ សីមាតិក្កន្តិកា នោះ លោកពោលសំដៅយកតែភិក្ខុដែលចេញទៅខាងក្រៅឧបចារសីមា ហើយធ្វើឲ្យកឋិនដោះក្នុងទីនោះតែម្ដង ។ ឯការដោះកឋិនតាមមាតិកា ១ គឺ សហុព្ភារៈ នោះគឺចំពោះតែភិក្ខុដែលចេញទៅខាងក្រៅឧបចារសីមាដែរ ប៉ុន្តែត្រឡប់មកវិញទាន់ការដោះកឋិនក្នុងចន្លោះកាលកំណត់ ដែលហៅថា អន្តរុព្ភារៈ ក្នុងវត្តដែលខ្លួនបានក្រាល-បានអនុមោទនាកឋិន ហើយបានធ្វើនូវការដោះកឋិននោះ រួមជាមួយនឹងភិក្ខុទាំងឡាយ, រួមជាមាតិកា ៨ ។ ការដោះកឋិនតាមមាតិកាទាំង ៨ នេះ ហៅថា អដ្ឋមាតិកាឧព្ភារៈ ។

រីឯ អន្តរុព្ភារៈ ប្រែថា “ការដោះកឋិនក្នុងចន្លោះកាលកំណត់” ។ សេចក្ដីអធិប្បាយថា ការដោះកឋិន ដោយញត្តិទុតិយកម្មវាចា ដែលសម្រាប់សូត្រដោះកឋិន មិនចូលទៅក្នុងមាតិកា៨ទេ ហៅថា អន្តរុព្ភារៈ ព្រោះការដោះកឋិននោះ សម្រាប់តែភិក្ខុដែលមិនបានចេញទៅខាងក្រៅឧបចារសីមា គឺនៅតែក្នុងវត្តនោះ មិនទាន់ដល់កាលបរិច្ឆេទទេ តែប្រជុំគ្នាធ្វើការដកកឋិនក្នុងចន្លោះកាលកំណត់ ។

ការដោះកឋិនទាំង២យ៉ាង គឺអដ្ឋមាតិកាឧព្ភារៈ និងអន្តរុព្ភារៈ មានសេចក្ដីផ្សេងគ្នាដូចអធិប្បាយខាងលើនេះ ។

ក្នុងគម្ពីរដែល មានសេចក្ដីបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀតថា(១) អន្តរុព្ភារៈ និងសហុព្ភារៈទាំងពីរនេះ សង្ឃធ្វើដោយញត្តិទុតិយកម្មវាចា ។ ឯកឋិនុព្ភារៈ៧ មានបក្កមនន្តិកាជាដើម ភិក្ខុមិនបានធ្វើដោយកម្មវាចាទេ ។

ស. ការដោះកឋិន ២ យ៉ាងគឺ អន្តរុព្ភារៈ និងសហុព្ភារៈ មានសេចក្ដីប្លែកគ្នាដូចម្ដេច ?

ឆ. អន្តរុព្ភារៈ គឺភិក្ខុច្រើនរូប មិនបានចេញទៅខាងក្រៅឧបចារ-សីមាទេ ឋិតនៅតែខាងក្នុងឧបចារសីមាប្រជុំគ្នាធ្វើ ។ ឯសហុព្ភារ គឺភិ មួយរូប ១ ចេញទៅខាងក្រៅឧបចារសីមា ហើយត្រឡប់មកវិញទាន់ អន្តរុព្ភារនោះ ហើយបានធ្វើជាមួយនឹងភិក្ខុទាំងឡាយ ដែលឋិតនៅក្នុង ឧបចារសីមានោះ ។ នេះ ជាសេចក្ដីប្លែកគ្នា នៃអន្តរុព្ភារៈ និង សហុព្ភារៈ នោះ ។

ស. ភិក្ខុសង្ឃ ប្រជុំគ្នាសូត្រកម្មវាចាដោះកឋិន ក្នុងបន្ទោះកាល គឺមិនទាន់ដល់កំណត់កាលនៃកឋិន តើដោយហេតុអ្វី ?

ឆ. ភិក្ខុសង្ឃ បានជាប្រជុំគ្នាសូត្រកម្មវាចាដោះកឋិនដូច្នេះ ដោយហេតុថាមានឧបាសកទាំងឡាយ មានបំណងនឹងធ្វើទានធំ ៗ ចង់ប្រគេន អកាលចីវរដល់ភិក្ខុទាំងឡាយ ដែលមិនបានក្រាល - អនុមោទនាកឋិន

---

១ អន្តរុព្ភារសហុព្ភារា ញត្តិទុតិយកម្មវាចាយេវ កាតា បក្កមនន្តិកាទយោ សត្ត កឋិនុព្ភារា ន កម្មវាចាយ កាតា ។

បានទិមន្តមកដល់ ជាលំដាប់លំដោយហូរហែ គេសុំឲ្យព្រះភិក្ខុសង្ឃក្នុងកឋិនាវាសដកកឋិនចេញ ។ (រឿងនេះព្រះពុទ្ធជាម្ចាស់ទ្រង់បានអនុញ្ញាតក្នុងភិក្ខុនីវិភង្គ ត្រង់សិក្ខាបទទី ១០ នៃឧគ្គវគ្គ ដោយហេតុមានឧបាសកម្នាក់ ចង់ប្រគេននូវអកាលចីវរ ដល់ឧភតោសង្ឃ ហើយបានសូមព្រះភិក្ខុសង្ឃឲ្យដកកឋិនចេញ ) ។

ដូច្នេះក្នុងវត្តនីមួយ ៗ កាលបើសង្ឃបានក្រាល-អនុមោទនាកឋិន ហើយ សង្ឃលាភទាំងប៉ុន្មានដែលកើតឡើងក្នុងវត្ត ត្រូវតែចែកដល់សង្ឃដែលបានក្រាល-អនុមោទនាកឋិនទាំងនោះ មិនត្រូវចែកដល់សង្ឃដទៃឡើយ បើលុះតែផុតកាលនៃកឋិន គឺផុតពីថ្ងៃ ១៥ កើត ខែផល្គុណទៅ ឬបើមិនទាន់ផុតកាលនៃកឋិននៅឡើយទេ ប៉ុន្តែសង្ឃបានប្រជុំគ្នាសូត្រកម្មវាចាដកកឋិន ក្នុងចន្លោះកាលកឋិននោះ ទើបសង្ឃលាភដែលកើតឡើងក្នុងវត្តនោះ អាចនឹងចែករំលែកដល់ភិក្ខុសង្ឃឯទៀត ៗ បាន ។

រីឯវិធីសូត្រកម្មវាចាដកកឋិន ព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឲ្យភិក្ខុ ១ រូបដែលឈ្លាសប្រតិពល សូត្រប្រកាសសង្ឃ ដោយញត្តិទុតិយកម្មវាចា ថា ៖

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ កឋិនំ ឧទ្ធរេយ្យ ។ ឯសា ញត្តិ ។ សុណាតុ

មេ ភន្តេ សង្ឃោ សង្ឃោ កឋិនំ ឧទ្ធរតិ ។ យស្សាយស្មតោ ខមតិ កឋិនស្ស ឧទ្ធារោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧទ្ធតំ សង្ឃេន កឋិនំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

បពិត្រព្រះសង្ឃដ៏ចម្រើន ! សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ការណ៍នេះ) បើជាការគួរដល់សង្ឃហើយ សង្ឃគួរដោះកឋិនចេញ ។ នេះជាពាក្យប្រកាសឲ្យសង្ឃបានជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន ! សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃដោះកឋិន ។ ការដោះកឋិន គួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។ កឋិនសង្ឃដោះហើយ ។ គួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំចាំទុកនូវការព្រមព្រៀងរបស់សង្ឃ ដោយអាការស្ងៀមយ៉ាងនេះ ។

កឋិនុទ្ធារៈចប់

## កឋិន ភង "ប្រភេទនៃកឋិន"

គម្ពីរបរិវារៈ មានសេចក្តីថ្លែងអំពីប្រភេទនៃកឋិន ពិស្តារក្រៃពេកណាស់ ។ ខ្ញុំស្រង់យកនូវសេចក្តីខ្លីៗ បន្តិចបន្តួច ពីគម្ពីរបរិវារៈនោះ

ចំពោះតែត្រង់សេចក្តីណាដែលមានប្រយោជន៍ ហើយជាសេចក្តីងាយយល់ មកតម្កល់ទុកក្នុងទីនេះ ដើម្បីឲ្យយុវភិក្ខុ ងាយស្រួលក្នុងការសិក្សា ដូចមានតទៅនេះ ៖

ស. ធម៌ដែលកើតដំណាលគ្នានឹងការក្រាលកឋិន មានប៉ុន្មានយ៉ាង?

ឆ. ធម៌ដែលកើតដំណាលគ្នានឹងការក្រាលកឋិន មាន ១៧ យ៉ាងគឺ មាតិកា ៨ បលិពោធ ២ និងអានិសង្ស ៥ ។ តាំង ១៧ នេះ ហៅថា សហជាតធម៌ ប្រែថា ធម៌កើតដំណាលគ្នា ឬកើតជាមួយគ្នា ។

ស. បុព្វករណៈ លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង ?

ឆ. បុព្វករណៈ លោកសង្គ្រោះដោយធម៌ ៧ យ៉ាង គឺ ធោវនៈ ការបោកគក់ ១ វិចារណៈ ការចាត់ចែងកស់វែង ១ ឆេទនៈ ការកាត់ ១ពន្ធនៈ ការដានផ្គុំ ១ សិព្វនៈ ការដេរ ១ រជនៈ ការជ្រលក់ ១ កប្បករណៈ ការធ្វើពិន្ទុកប្បៈ ១ ។

ស. បច្ចុទ្ធារៈ លោកសង្គ្រោះដោយរូបធម៌ប៉ុន្មានយ៉ាង ?

ឆ. បច្ចុទ្ធារ លោកសង្គ្រោះដោយរូបធម៌៣ យ៉ាង គឺសង្ឃាដី ១ ឧត្តរាសង្គៈ ១ អន្តរវាសកៈ ១ ។

ស. អធិដ្ឋាន លោកសង្គ្រោះដោយរូបធម៌ប៉ុន្មានយ៉ាង ?

ឆ. អធិដ្ឋាន លោកសង្គ្រោះដោយរូបធម៌ ៣ យ៉ាងគឺ សង្ឃាដី ១ ឧត្តរាសង្គៈ ១ អន្តរវាសកៈ ១ ។

សួ. អត្ថារៈ ការក្រាលកឋិន លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង?

ឆ. អត្ថារៈ ការក្រាលកឋិន លោកសង្គ្រោះដោយធម៌តែ ១ យ៉ាង គឺវចីភេទ ការបញ្ចេញវាចា (ឲ្យសង្ឃបានឮគ្រប់រូប) ។

សួ. កឋិន មានមូលប៉ុន្មាន? មានវត្ថុប៉ុន្មាន? មានភូមិប៉ុន្មាន?

ឆ. កឋិន មានមូល ១ គឺជំនុំសង្ឃ; មានវត្ថុ ៣ គឺ សង្ឃាដី១ ឧត្តរាសង្គៈ ១ អន្តរវាសកៈ ១; មានភូមិ ៦ គឺ ខោមៈ សំពត់ធ្វើដោយសរសៃសម្បកឈើ ១ កប្បាសិកៈ សំពត់ធ្វើដោយកប្បាស១ កោសេយ្យៈ សំពត់ធ្វើដោយសូត្រ១ កម្ពលៈ សំពត់ធ្វើដោយរោមសត្វ១ សាណៈ សំពត់ធ្វើដោយសម្បកធ្មៃ១ ភង្គៈ សំពត់ធ្វើដោយវត្ថុទាំង ៥ ខាងដើមលាយចម្រុះគ្នា ១ ។

សួ. កឋិន មានអ្វីជាខាងដើម? មានអ្វីជាកណ្តាល? មានអ្វីជាខាងចុង?

ឆ. កឋិន មានបុព្វករណៈជាខាងដើម; មានកិរិយា គឺបច្ចុទ្ធរ៍ និងអធិដ្ឋាន ជាកណ្តាល; មានអត្ថារៈ ជាខាងចុង ។

សួ. បុគ្គលប្រកបដោយអង្គប៉ុន្មាន មិនគួរក្រាលកឋិន?

ឆ. បុគ្គលប្រកបដោយអង្គ៨មិនគួរក្រាលកឋិន ។ អង្គ៨នោះគឺ មិនចេះបុព្វករណៈ ១ មិនចេះបច្ចុទ្ធរៈ ១ មិនចេះអធិដ្ឋាន ១ មិនចេះក្រាល

១ មិនបេះមាតិកា ១ មិនបេះបលិពោធ ១ មិនបេះការដោះកឋិន ១ មិនបេះអានិសង្ស ១ រួមជា ៨ ។

ស. ចុះបុគ្គលប្រកបដោយអង្គប៉ុន្មាន ទើបគួរក្រាលកឋិន ?

ឆ. បុគ្គលប្រកបដោយអង្គ ៨ ដែរ ទើបគួរក្រាលកឋិន ។ អង្គ ៨ នោះគឺ បេះបុព្វករណៈ ១ បេះបច្ចុទ្ធារៈ ១ បេះអធិដ្ឋាន ១ បេះក្រាល ១ បេះមាតិកា ១ បេះបលិពោធ ១ បេះការដោះកឋិន ១ បេះអានិសង្ស ១ រួមជា ៨ ។

ស. ការក្រាលកឋិន របស់បុគ្គលប៉ុន្មានពួក មិនបានឡើងជាកឋិន? ប៉ុន្មានពួក ទើបឡើងជាកឋិន ?

ឆ. ការក្រាលកឋិន របស់បុគ្គល ៣ ពួក មិនបានឡើងជាកឋិនឡើយ គឺ បុគ្គលឋិតនៅក្រៅឧបចារសីមាក្រាល - អនុមោទនាកឋិន ១ បុគ្គលក្រាល - អនុមោទនាកឋិន មិនបានបញ្ចេញវាចា ១ បុគ្គលកាលដែលបញ្ចេញវាចា មិនបានឲ្យអ្នកដទៃដឹងសេចក្តីច្បាស់ ១ ។

ការក្រាលកឋិន របស់បុគ្គល ៣ ពួក ក្រៅពីនេះទើបបានឡើងជាកឋិនគឺ បុគ្គលឋិតនៅក្នុងឧបចារសីមាក្រាល - អនុមោទនាកឋិន ១ បុគ្គលកាលក្រាល - អនុមោទនាកឋិន បានបញ្ចេញវាចា ១ បុគ្គលកាលដែលបញ្ចេញវាចា បានឲ្យអ្នកដទៃដឹងសេចក្តីច្បាស់ ១ ។

ស. ការក្រាលកឋិនប៉ុន្មានយ៉ាង មិនឡើងជាកឋិន? ប៉ុន្មានយ៉ាង ទើបឡើងជាកឋិន ? ។

ឆ. ការក្រាលកឋិន ៣ យ៉ាង មិនឡើងជាកឋិនឡើយ គឺ

១– វត្ថុវិបន្ន វត្ថុខុស បានដល់សំពត់កឋិនជាអកប្បិយៈ គឺ ចីវរមិនត្រឹមត្រូវ ។

២- កាលវិបន្ន កាលខុស បានដល់កាលដែលទាយកប្រគេន សំពត់ក្នុងថ្ងៃនេះ សង្ឃប្រគល់ឲ្យដល់ភិក្ខុអ្នកក្រាល ក្នុងថ្ងៃស្អែក ។

៣– ការណវិបន្ន ធ្វើខុស បានដល់ការមិនបានធ្វើសំពត់ដែល នៅថ្មីស្រុង ឲ្យទៅជាចីវរត្រឹមត្រូវ ឲ្យទាន់ក្នុងថ្ងៃនោះ ។

ការក្រាលកឋិន ៣ យ៉ាងក្រៅពីនេះ ទើបបានឡើងជាកឋិន គឺ

១– វត្ថុសម្បន្ន វត្ថុត្រូវ បានដល់សំពត់កឋិនជាកប្បិយៈ គឺ ចីវរត្រឹមត្រូវ ។

២– កាលសម្បន្ន កាលត្រូវ បានដល់កាលដែលទាយកប្រ- គេនសំពត់កឋិនក្នុងថ្ងៃណា សង្ឃបានប្រគល់ឲ្យភិក្ខុអ្នកក្រាលក្នុងថ្ងៃនោះ។

៣- ការណសម្បន្ន ធ្វើត្រូវ បានដល់ការធ្វើចីវរឲ្យបានត្រឹម ត្រូវ ហើយទាន់ក្នុងថ្ងៃនោះ ប្រសិនបើសំពត់នោះជាសំពត់នៅថ្មីស្រុង នៅឡើយ ។ បើសំពត់ដែលទាយកប្រគេនមកនោះ គេបានធ្វើចីវរ ត្រឹមត្រូវរួចស្រេចមកហើយ នោះមិនចាំបាច់ធ្វើអ្វីទៀតទេ ត្រូវតែបច្ចុទ្ធរ

អធិដ្ឋាន ក្រាល ឲ្យហើយស្រេចក្នុងថ្ងៃនោះ ក៏អាចចាត់ទុកជា ករណ-សម្បន្នពេញទី ។

ស. ខែណា ជាខែដែលត្រូវក្រាលកឋិន ?

ឆ. ខែ ១ ជាខាងចុងនៃវស្សានរដូវ គឺតាំងពីថ្ងៃ ១ រោចខែអស្សុជ ទៅទល់នឹងថ្ងៃ ១៥ កើតខែកត្តិក ជាខែដែលត្រូវក្រាលកឋិន ។

ស. ការក្រាលកឋិន ដែលជា អត្ថារវិបត្តិ "ក្រាលខុស" ឬជា អត្ថារសម្បត្តិ "ក្រាលត្រូវ" ត្រូវដឹងដោយអ្វី ?

ឆ. ការក្រាលកឋិន ជាអត្ថារវិបត្តិ ត្រូវដឹងដោយអនត្តាការ ២៤; ដែលជាអត្ថារសម្បត្តិ ត្រូវដឹងដោយអត្តាការ ១៧ ដែលបានពោលរួចមកហើយក្នុងខាងដើម ។

កឋិនកថាសង្ខេប

ចប់ ។

---

អង្ខិលបត្តិព ដែលប្រឡាក់
ត្រូវបាក់ទឹកច្រើន ទើបលាងជ្រះ
រីឯទោសខុស តិចតួចខ្លះ
ត្រូវលាងឲ្យជ្រះ ដោយគុណច្រើន

ជ-ន

# រឿងមហាកាលឧបាសក

## អដ្ឋកថាធម្មបទ ភាគទី ៦ អត្តវគ្គទី ១២

លោក ប៊ូ.ប៊ុំ ប្រែ-រៀបរៀង

កាលព្រះបរមសាស្តាគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវឧបាសកជាសោតាបន្នម្នាក់ ឈ្មោះមហាកាល សំដែងធម៌ដោយបទគាថា ថា អត្តនា ហិ កតំ បាបំ ដូច្នេះជាដើម ។

បានឮមកថា ឧបាសកនោះ រក្សាឧបោសថសីលក្នុងមួយខែ៨ថ្ងៃ ស្តាប់ធម្មកថាក្នុងវិហារតាំងពីព្រលប់ដល់ភ្លឺ ។ គ្រានោះ ពួកចោរគាស់កាត់ជញ្ជាំងផ្ទះមួយ ក្នុងវេលាយប់លួចយកទ្រព្យរបស់, អ្នកម្ចាស់ផ្ទះឮសំឡេងភាជនលោហៈទង្គិចគ្នា ក្រាកដឹងខ្លួនឡើង ក៏ស្ទុះទៅដេញតាមចាប់ចោរ ។ ភ័យខ្លាំងបោះបង្វេចទ្រព្យចោលហើយខំរត់ឲ្យរួចតែខ្លួនទៅបាត់ ។ ចំណែកម្ចាស់ទ្រព្យ ចេះតែដេញតាមចោរប្រកិតៗឥតឈប់ ។ ចោរទាំងនោះខំរត់គេចខ្លួនបែកខ្ញែកគ្នាអស់ ។ មានចោរម្នាក់ រត់ត្រង់ទៅចំវិហារ បោះបង្វេចទ្រព្យចោលនៅមុខមហាកាលឧបាសក ដែលស្តាប់ធម្មកថាក្នុងវិហារពេញមួយយប់ទាល់ភ្លឺហើយ ទៅលុបលាងមុខមាត់នៅឆ្នេរស្រះខាងមុខវិហារហើយចោរនោះរត់បាត់ទៅ ។ ពួកមនុស្ស ដេញតាមចោរមកដល់ទីនោះឃើញបង្វេចទ្រព្យ ក៏និយាយថា អាឯងគាស់ជញ្ជាំងផ្ទះរបស់ពួកអញលួចបង្វេចទ្រព្យអញមកហើយក្លែងខ្លួនធ្វើដូចជាអ្នកស្តាប់ធម៌, ថារួចចាប់ឧបាសកនោះវាយសម្លាប់ចោលទៅ ។ លំដាប់នោះ ភិក្ខុកម្លោះនិងសាម-

ណេរកាន់ក្អមទៅដងទឹកពីព្រលឹម បានឃើញខ្មោចឧបាសកនោះ ហើយក៏ក្រាបទូលព្រះសាស្តាថា ឧបាសក ដែលស្តាប់ធម្មកថាក្នុងវិហារ ស្លាប់ដោយការមិនសមគួរសោះ ៗ ព្រះបរមសាស្តាទ្រង់ត្រាស់ៈ មែនហើយ ភិក្ខុទាំងឡាយ! កាលឧបាសក ស្លាប់ក្នុងអត្តភាពនេះមិនសមគួរទេ ប៉ុន្តែសមគួរតាមកម្មដែលខ្លួនធ្វើទុកពីកាលមុន ៗ ភិក្ខុទាំងនោះ ក្រាបទូលអារាធនាទើបព្រះពុទ្ធអង្គទ្រង់សំដែងបុព្វកម្មរបស់ឧបាសកនោះ ដូចតទៅនេះ ៖

បានឮថា ក្នុងកាលកន្លងលែងទៅយូរហើយ មានពួកចោរលាក់ខ្លួនពួននៅក្នុងដងព្រៃជិតដំបន់បច្ចន្តគ្រាមមួយ ក្នុងដែនរបស់ព្រះបាទពារាណសី ៗ ព្រះរាជាទ្រង់តាំងរាជបម្រើម្នាក់ឲ្យនៅក្នុងដងព្រៃមួយ ៗ រាជបម្រើនោះស៊ីឈ្នួលនាំផ្លូវពួកមនុស្ស ពីនេះទៅខាងនោះ នាំផ្លូវពួកមនុស្សពីខាងនោះមកខាងនេះឆ្លងកាត់ព្រៃ ដែលមានពួកចោរចាំប្លន់នោះឲ្យពួកឈ្មួញបានរួចពីអន្តរាយ ៗ គ្រានោះ មានមនុស្សម្នាក់ ឲ្យភរិយារបស់ខ្លួន ដែលមានរូបល្អស្អាតឡើងជិះរទេះតូចបរទៅដល់ទីនោះ ៗ រាជបម្រើក្រឡេកឃើញស្រីនោះ កើតចិត្តស្រឡាញ់ កាលប្តីនាងនោះនិយាយថា បពិត្រនាយ! សូមលោកនាយមេត្តាចម្លងខ្ញុំឲ្យផុតពីព្រៃដែលមានគ្រោះថ្នាក់នេះផង ៗ រាជបម្រើឆ្លើយថា ពេលនេះយប់ងងឹតហើយ ចាំព្រឹកឡើងយើងនឹងចម្លងអ្នកទៅពីព្រហាម ៗ នៅថ្ងៃក៏ទេលោកនាយ សូមមេត្តានាំផ្លូវខ្ញុំទៅពេលនេះចុះ ៗ ចូរអ្នកត្រឡប់ទៅ

វិញ អាហារទិនទីលំនៅ មានកូនផ្ទះយើនសព្វគ្រប់ស្រាប់ហើយ ។ បុរសប្តី មិនព្រមត្រឡប់វិញ ពជបម្រើញាក់មុខធ្វើសញ្ញាឲ្យពួកបុរសជាបរិវាររបស់ខ្លួនចាប់ទាញរទេះត្រឡប់មុខមកផ្ទះខ្លួនវិញ ប៉ុន្តែឲ្យឈប់រទេះដេកនៅត្រង់ខ្លោងទ្វាររបង ឲ្យបុគ្គលចាត់ចែងអាហារយកមកឲ្យបុរសប្តីប្រពន្ធដែលឥតចង់នៅបរិភោគសោះ ។ ឯកូនផ្ទះពជបម្រើនោះមានកែវមណីមួយដុំ ។ ពជបម្រើប្រើមនុស្សឲ្យលបយកកែវមណីនោះទៅដាក់លាក់ក្រោមបាតរទេះរបស់បុរសនោះ ហើយឲ្យស្រែកដូចជាចោរចូលទៅនៅពេលជិតភ្លឺ ។ គ្រានេះ ពួកបុរសរបស់ពជបម្រើប្រាប់ថា បពិត្រលោកនាយ ! ចោរលួចយកកែវមណីទៅបាត់ហើយ ។ ពជបម្រើបង្គាប់ថា អ្នកកល់គ្នាចូរដាក់បុរសឲ្យចាំយាមឃ្លាំមើលក្បែរខ្លោងទ្វាររបង ហើយត្រួតត្រាមើលអ្នកដំណើរដែលចេញមកអំពីក្នុងស្រុក ។ បុរសប្តីប្រពន្ធ ទឹមរទេះបរចេញទៅពីព្រលឹម ។ ពេលនោះពួកអ្នកយាមល្បាតឃាត់រទេះ ហើយរើមើលឃើញកែវមណីដែលខ្លួនលាក់ទុកនោះ ហើយស្រែកគំហកថា អាឯងលបលួចយកកែវមណីរត់ទៅ . វាយហើយនាំយកទៅប្រគល់ជូនពជបម្រើដំកបថា បពិត្រលោកនាយ ! ពួកខ្ញុំចាប់ចោរបានហើយ ។ ពជបម្រើនិយាយថា អញជាអាមាត្យ ឲ្យវានៅក្នុងផ្ទះឲ្យបាយស៊ីទៀត វាហ៊ានលួចយកកែវមណីអញទៅ អ្នកកល់គ្នាចូលចាប់អាចោរកំណាចនោះឲ្យជាប់ វាយឲ្យស្លាប់ ហើយយកខ្មោចវាទៅបោះ

ហោលឡើងឡើយទៅ នេះជាបុព្វកម្មរបស់ឧបាសកនោះ ។ រាជបម្រើ ច្យុតពីអត្តភាពនោះហើយទៅកើតក្នុងអវិចនរក នេះក្នុងនរកអស់កាលជាយូរ ដល់បានមកកើតជាមនុស្ស ត្រូវគេវាយសម្លាប់បែបនេះ ជាច្រើនរយជាតិ ដោយផលកម្មដ៏សេសសល់ ។

ព្រះបរមសាស្តាកាលទ្រង់សម្តែងបុព្វកម្ម របស់មហាកាលឧបាសកយ៉ាងនេះចប់ហើយ ត្រាស់ថា : ម្នាលភិក្ខុទាំងឡាយ ! កម្មដែលខ្លួនធ្វើខ្លួនឯង រមែងញាំញីសត្វទាំងនេះ ក្នុងអបាយបួនយ៉ាងនេះហើយ ត្រាស់គាថាថា ៖

អត្តនា វ កតំ បាបំ អត្រជំ អត្តសម្ភវំ
អភិមត្ថតិ ទុម្មេធំ វជិរំវម្ហយំ មណឹ ។

បាប កើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សអ្នកឥតបញ្ញា ដូចពេជ្រ សម្រាប់កាត់កែវមណីដែលកើតអំពីថ្មបោះ ។

កាលចប់ធម្មទេសនា ពួកភិក្ខុអ្នកប្រជុំគ្នានោះ បានសម្រេចមគ្គផល មានសោតាបត្តិផលជាដើម ។

រឿងមហាកាលឧបាសក ចប់ ។

ដង្វាលេចពីសាច់
ឬថាប្រេះចេញពីដែក

# រឿងព្រះទេវទត្ត

## អដ្ឋកថាធម្មបទ ភាគទី៦ អត្តវគ្គទី ១២

លោកប៊ូ - ប៉ូ ប្រែ - រៀបរៀង

*កាលព្រះបរមសាស្តាគង់ក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធនឹងព្រះទេវទត្ត. សំដែងធម៌ដោយបទគាថាថា យស្ស អច្ចន្តទុស្សីល្យំ ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា ថ្ងៃមួយ ពួកភិក្ខុនិយាយគ្នាក្នុងរោងធម៌ថា អាវុសោទាំងឡាយ ! ព្រះទេវទត្ត ជាមនុស្សទ្រុស្តសីល កាន់ធម៌ដ៏អាក្រក់លាមក កាលតណ្ហាចម្រើនច្រើនឡើង ព្រោះហេតុជាមនុស្សទ្រុស្តសីល ក៏ទៅបញ្ចុះបញ្ចូលព្រះបាទអជាតសត្រូវ ញាំងលាភនិងសក្ការៈជាច្រើនឲ្យកើតឡើង ដឹកនាំព្រះបាទអជាតសត្រូវឲ្យធ្វើឃាតព្រះបិតា រួមចិត្តគ្នានឹងព្រះបាទអជាតសត្រូវនោះ ខ្វល់ខ្វាយរកឧបាយ ដើម្បីនឹងសម្លាប់ព្រះតថាគតដោយប្រការផ្សេង ៗ ។ ព្រះសាស្តាស្តេចមកដល់ ត្រាស់សួរថា នែភិក្ខុទាំងឡាយ ! ពេលនេះ ពួកអ្នកអង្គុយសន្ទនាគ្នាពីរឿងអ្វី? ។ កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាប ហើយត្រាស់ថា ភិក្ខុទាំងឡាយ ! មិនមែនតែក្នុងគ្រានេះទេ សូម្បីពីកាលមុន ទេវទត្តក៏ព្យាយាមរកឧបាយនឹងសម្លាប់តថាគត ដោយប្រការផ្សេង ៗ ដូច្នេះដែរ ទ្រង់សម្តែងកុរុង្គជាតកជាដើមចប់ហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ! តណ្ហា*

រមែងកើតឡើងព្រោះហេតុជាមនុស្សទ្រុស្តសីល រមែងប្រាទទម្លាក់នូវបុគ្គលទ្រុស្តសីលហួសប្រមាណ ទៅកាន់នរកជាដើម ដូចព្រៃវល្លិរួបរឹតដើមពាំងឲ្យបាក់រលំបាត់ទៅ ទ្រង់សម្តែងគាថាថា ៖

យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ។

អំពើទ្រុស្តសីលហួសហេតុ[១] គ្របសង្កត់ (នូវអត្តភាព) របស់បុគ្គលណា ដូចវល្លិដែលរួបរឹតដើមឈើ បុគ្គលនោះឈ្មោះថាធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរ ប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាសដូច្នោះ ។

កាលចប់ធម្មទេសនា ជនជាច្រើននាក់ បានសម្រេចមគ្គផលមានសោតាបត្តិផលជាដើម ។

រឿងព្រះទេវទត្ត ចប់ ។

| |
|---|
| បើដៃខ្វី កុំស្រវាឧបក្ខ |
| ក្រែងឧបមិនជុំ ព្រះធរណីស្រូប |

១- បើគ្រហស្ថ ចាប់តាំងពីកើតមក ធ្វើតែអកុសលកម្មបថទាំង១០, បើបព្វជិត តាំងពីថ្ងៃឧបសម្បទមក ត្រូវគរុកាបត្តិគឺអាបត្តិមានទោសធ្ងន់ យ៉ាងនេះឈ្មោះថាអំពើទ្រុស្តសីលហួសហេតុ ។ ធម្មបទដ្ឋកថា ។

## ( ក )

ព្រះមហា ឆា៉ង-ទាត់ រៀបរៀង

---

អបិឝាច គុ. ដែលមិនជាពិសាច ដែលរួចពីបិសាច ។

អបិហិត គុ. ដែលលាក់ ដែលគ្រប ដែលបាត់ ។

អបី: តិ: ធាតុ ចូលរួម ទៅ ជ្រាប រលាយ ។ អបីត
គុ. ដែលស្រូបចូល ។

អបីឌា ស្ត្រី. អបីឌា កិរិយាមិនធ្វើឱ្យខុស ។ អបីឌិត
គុ. ដែលគេមិនយាយី ។

អបីត គុ. ដែលមិនផឹក ។

អបីតិ ស្ត្រី. អបីតិ កិរិយារលាយ ។

អបុំឝ្ចលីយ គុ. ដែលមិនមែនជាកូននៃស្ត្រីពេស្យា ។

អបុំស បុំ. កិរិយាក្រៀវ ។ —ត្វ នបុំ. ការនៃកិរិយា
ក្រៀវ ។

អបុណ្យ គុ. អបុណ្យ ដែលឥតបុណ្យ ដែលមិនបរិសុទ្ធ។

។ – វិត្ត គុ. ដែលមិនមានបុណ្យ ។

– ប្បកតិ គុ. ដែលមិនធ្វើបុណ្យ ដែលមិន

ធ្វើល្អ ។ –ភាជី ឬ –ភាគីល គុ. ដែល

រងទុក្ខ ។

អបុត្រ ប៉ុ. កិរិយាមិនមានកូន ។ គុ. ដែលឥតកូន ។

កា– គុ. ដែលឥតកូន ។

អបុនវុត្ត គុ. ដែលមិនពោលទៀត

អបុនរុន្មីលន គុ. ដែលមិនបើកភ្នែកទៀត ។

អបុនតិវត្តិន គុ. ដែលមិនត្រឡប់មកទៀត។ – គាមិន គុ.

ដែលមិនមានភពទៀត ។

អបុនតិវត្តិ ស្ត្រី កិរិយាមិនត្រឡប់មកទៀត ។ –ភវ ប៉ុ.

អបុនភព កិរិយាមិនកើត កិរិយារួច

ស្រឡះ ។

អបុនម្រឹត ឧប៉ុ. កិរិយាមិនស្លាប់ទៀត ។

អបុប្កល គុ. ដែលមិនច្រើន ដែលទទេ ដែលមិនសម្រេច

អ្វីសោះ ។

អបុប្ផ គុ. ដែលឥតផ្កា ។ អបុប្ផិត គុ. ដែលមិនប៊ុចផ្កា ។

អបូជិត គុ. ដែលមិនបូជា ។

អបូត គុ. ដែលមិនស្អាត ដែលមិនបរិសុទ្ធ ។

អបូប បុ. នំ ។ ប្រហោងសម្បកឃ្មុំ ។ អបូក បុ. អបូបិកា ស្ត្រី. នំ – គាលា ស្ត្រី. សាលលក់នំ អបូបសាលា ។

អបូរ គុ. សម្រេក ដែលទប់មិនបាន ។ – ស គុ. ផ្ទុចគ្នា ។

អបូរណ គុ. ដែលមិនចេះឆ្អែត ។ ដែលខ្វះខាត ។

អបូណ៌ គុ. ដែលមិនពេញ ។

អបូតិ ស្ត្រី. កិរិយាមិនពេញបំណង ។

អបូវ គុ. ដែលមិនមានពីដើម ថ្មី ដែលប្រៀបមិនបាន។ បុ. អ្នកថ្មី ។ –តា ស្ត្រី. -ត្ត នបុំ. ដែលប្លែក អបូវិភាព ភាពជារបស់ថ្មី ។ - ទស្សិន ដែលតាប្ចូវទស្សន៍ ។

អប្បវិធ    គុ.    អប្បវិធ ដែលមិនទាន់ធ្វើ ។ ដែលមិនទាន់រៀបការ ។

អប្បដិក្កិត    គុ.    ដែលមិនព្រមប្រាសចាក ។

អប្បដិគាគ្រយ    គុ.    ដែលមិនមានទីអាស្រ័យដទៃផង ដែលមិនមានទីពឹងដទៃផង ។

អប្បដិគ្គន    គុ.    ដែលមិនឃើញផ្សេង ។

អប្បដិគ្គត    គុ.    ដែលមិនកើតផ្សេង ។

អប្បដិឃាត្តជ    គុ.    ដែលមិនមានអង្គុំ ។

អប្បុច្ឆ    គុ.    ដែលគេមិនបានសួរ ។

អបេៈ តិៈ    ជាគុ.    ចេញបាត់ ។ អបេត គុ. ដែលទៅ ដែលទៅបាត់ ។ អបេតប្រាណ គុ. អបេតប្រាណ ដែលមានប្រាណចេញទៅហើយ ដែលស្លាប់ ។ អបេតភី គុ. ដែលមានភ័យកន្លងទៅហើយ ដែលឥតភ័យ ។ អបេតាគ គុ. ដែលមានបំណងទៅប្រាសហើយ ដែលមិនមានក្តីសង្ស័យ ។

# ល្បងសិក្សា

# ប្រវត្តិអក្សរសាស្ត្រខ្មែរ

ដោយ លាង ហាប់អាន

សាស្ត្រាចារ្យ នាយកពុទ្ធសាសនបណ្ឌិត្យ

(ស្រង់ពីមេរៀនវិទ្យាស្ថានអប់រំខាងអក្សរសាស្ត្រ)

## អក្សរសាស្ត្រខ្មែរ ពីសម័យបុរាណ មកសម័យបច្ចុប្បន្ន

[ត]

– ផ្នែកខាងត្បូងហៅ Groupe sud (S) សរសេរជាភាសាសំស្រ្កឹត ក្នុងសម័យសតវត្សទី ៧ នៃគ.ស. ដែលគេរកឃើញនៅនឹងមេបញ្ជរនៃបង្អួច ៦ កន្លែង នៅនាទ្វារទិសខាងកើតនៃកំពែងខាងក្រៅ (គឺសិលាចារឹករបស់ព្រះបាទឥសានវរ្ម័នទី ១) ហើយនិងនៅមេបញ្ជរទិសខាងត្បូងនៃទ្វារកំពែងក្រៅផ្នែកខាងលិច ។

– ផ្នែកខាងជើងហៅ Groupe Nord (N.) ដែលសរសេរជាសំស្រ្កឹតផង ខ្មែរផង (ដូចជាសិលាចារឹករបស់ព្រះបាទឥសានវរ្ម័នទី ១ នៅលើមេបញ្ជរនៃទ្វារប្រាសាទខាងជើង) ។

ផ្នែកផ្សេង ៗ នៃសិលាចារឹកសម្បូណ៌ព្រៃគុក បញ្ជាក់ជាដំបូង

កាលក្នុង គ.ស. ១៨៩៤ ដោយលោក Adhémar Leclère ។ នៅ គ.ស. ១៩០០ លោក L. de Lajonquière, បានរកឃើញខ្លះ ហើយលោក G. Morand រកឃើញគ្រប់ពេញលេញនៅ គ.ស ១៩២០ ។ លោក H. Parmantier បានយកសិលាចារឹកទាំងនេះមកសិក្សាតាមផ្នែកម៉ត់ចត់ នៅឆ្នាំ ១៩១១ ទង ១៩២៤ ។ ជាបញ្ចប់គឺ លោក V. Goloubew ដែលស្រាវជ្រាវបន្ថែមដល់ ១៧ សិលាចារឹកនៅឆ្នាំ ១៩២៧ ។

## ទី២– សិលាចារឹកនៅភូមិខាវកាំង(១)

### ក) សេចក្តីសង្កេត. –

សិលាចារឹកនេះនៅក្នុងក្រុមសិលាចារឹកនៅលើភ្នំនៃដំបន់អរញ្ញ ។ ភ្នំនេះមានបីគឺឈ្មោះខាវរាំង Khàu Rang, ខាវណូយ Khàu Nôi, និងខាវចម្ពូ Khàu C'-omp'u ឋិតនៅដែនសៀម ត្រង់តម្បន់ព្រំប្រទល់អរញ្ញ ។ គេដឹងអំពីសិលាចារឹកនេះ ដោយសារឃើញសំណាកដែលផ្តិតទុកនៅនាបណ្ណាល័យជាតិនៅក្រុងបាងកក ។

### ១) លក្ខណៈ. –

សិលាចារឹកនៅខាវជម្ពូ ប្រើការពុំបានទេ ។ គេគ្រាន់តែដឹងថា

(១) ស្រង់ពី Inscription du Cambodge, G. Cœdès. vol, V ពីទំព័រ ២៣ ដល់ ២៤ ។

អត្ថបទសិលាចារឹកនេះសរសេរជាសំស្រ្កឹត មានចំនួន ២៨ បន្ទាត់ ។

សិលាចារឹកនៅខាងត្បូងមាន ៩ បន្ទាត់ សរសេរជាសំស្រ្កឹត ហើយ ២៦ បន្ទាត់សរសេរជាខ្មែរ ។ អ្នកនិពន្ធសិលាចារឹកនោះនាមម្រតាញខ្ញាញជ្រស្តុបុរៈ ដែលបានធ្វើពិធីបូជាចំពោះសមរស្វេរៈ ក្នុង គ.ស. ៦៣៧ ។

ឯសិលាចារឹកនៅខាងកំពែងវិញ គឺសរសេរលើថ្មតូច មានទទឹងប្រមាណជាបីតឹក ។ សិលាចារឹកនេះសរសេរជាសំស្រ្កឹត ចំនួន១ស្លោក មាន២បន្ទាត់ បញ្ជាក់អំពីឆ្នាំកត់ត្រា គឺមហាសករាជ៥៦១ឬគ.ស ៦៣៩ ។ ឯ ២៩ បន្ទាត់សរសេរជាខ្មែរ គឺគេរៀបរាប់អំពីអំណោយផ្សេង ៗ របស់ឈ្មោះសិនាហ្វេរទៅឲ្យព្រះវិហារ ។ គឺជាសិលាចារឹកនិយាយពីកំណើតពុទ្ធសាសនា ។

គ- អត្ថបទ ៖-

១- ឥសត្រយោគសទំនេ ក្រិស្ណចន្ទ្រសេន្ទ្រិយេស៍,

២- ភុក្តេ សកបតេរ អព្ទេ ហស្តេន វ្សភោទយស៍ ។

៣- ទ្វំអំណោយ សិនាហ្វ ប្រគត អាយ (៤) ត វិហារ ផ្ទហ គេ រ៉ា សិរ កន្ទ្រ ៥) កុ យោង គោន កុ លាង សិ រ៉ា ប៉ារ (៦) កន្ទ្រ រ៉ា កុ សោល គោន កុ លាង តែ (រ៉ា) វរណោហ កុ ចិហ រ៉ា ជោងកន្ទ្រ (៧) រ៉ា កុ មាស កុប

កោន កុ ទេរ តៃលា (៩) ង តៃ ប៉ៅ តៃ កុ ស្រ លាញ កោន កុ លាង តៃ ប៉ៅ តៃ ចំ ទ ក ព ថ រ ព (១១) ទិន ព ធម៌ មលាក ទំរេងអាយ (១២) ក្ញោន ស្វា ត គុិ ១០០-៥ គោង ក្ញុំ ២០ ប្តុំ (១៣) គុិ ព មេន កន្តៃ ព កុ ល ហ កោន កុ លា (១៤) ង ស៊ ប៉ៅ ស៊ ទំរេង អាយ ញិង វិហារ (១៥) ស្វា ត គុិ ក្ញុំ ១០០.២០៣ គោង ក្ញុំ ១០០.២០. ប្តុំ (១៦) គុិ ព ក្មោក ស្វ វិបិណ្ឌ សព លវ្ (១៧) ទូ ខ្ញុំ ជោង ក្រោង ប្តុំ ទំរេង ២០ ១០-២ (១៨) គ្វង វិហារ គ្វស សំរែត ៤ ថាស ២ (១៩) ស្រ គេល ២០) បល្វិតគង្គោងតំបោ (២០) ណាចទ្វេក ឧលទូ ថ្លីយៅ ៧ កំពរ (២១) យៅ ៧ កាបជ ថ្លីយៅ ២០-ពក្សប (២២) យោ ១០-២ កំពរយោ ១០ បួនត្រិធា (២៣ ថ្ល ចិ ..អាយ បរកុស (២៤) ទ្រេទកទូហតិ....ប្រចំក្ញុំ (២៥) ៥ បោញ រុ...(២៦) ខ្ញុំអំណោយសិនាហូអញ ឯ ត វិហា (២៧) រ.. កន្តៃ ព កុធន កោន (២៨)...លាង ស៊ប៉ៅតៃ ថា (២៩)... ទំរេងទស្វា ក្ញុំ (៣០). .. ក្ញុំ គុិ ១០គុិសំ (៣១)....

## ឃ- សេចក្តីប្រែ.–

(១-២-) នៅក្នុងឆ្នាំនៃព្រះពជាសកៈកន្លងផុតទៅ ដែលមាន បញ្ជាក់តាម(៥)អាយតនានាមាន(៦) សេនិងព្រះច័ន្ទ នាថ្ងៃ១៣កេច នៃឥសៈ(អាស៊ិន)ព្រះច័ន្ទ ឋិតនៅក្នុង ហស្តទ្រង់គោចរឡើងលើ ឧសក មណ្ឌល ។ (៣.១១) ពពួកទាសទាំងឡាយដែល សិនាហូ ផ្តល់ពីមុនទៅ

ឲ្យវិហារ ។ (កាយបញ្ជីឈ្មោះទាសៈទាំងនេះ) ។ (១១-១៤) ការ ដាំដំណាំនៅគ្នានគឺដើមស្លា១០៥, ដើមដូង៦០ ។ កប់ឈ្មោះឆ្នាំ(តាមបញ្ជី) ។

(១៤-១៦) ដំណាំនៅជិតវិហារគឺដើមស្លា ១២៣ដើម ដូង១៦០ កាយឈ្មោះឆ្នាំវក្តោក ។

(១៦-១៧) រួមសារុបពួកទាសៈចាស់និងក្មេង ព្រមទាំងឆ្នាំក្សា ដំណាំ មានចំនួន៣២ ។

(១៨-១៩) ឃ្លាំងទ្រព្យធននៅលើវិហាគឺៈ ក្លស ធ្វើពីសំរឹទ្ធ ៤, ចាស ២, ស្រគេហ៦០, ក្រែ... ។

(២៣-២៤)–នៅបរ កុ ស្រែ១កល .. គោ៥ទឹម ។

ធោញ្ញ ។

(២៦-៣១)--ទាសៈដែលខ្ញុំឈ្មោះ សិកហ្វ វរថ្វាយទៅព្រះវិហារ (កប់ចំនួនអំណោយ) ។ ដំណាំ....ដើមស្លា. .ឈើ១០ដើម...ទៅព្រះវិហារ រុណ ។

## ង. អត្ថន័យទូទៅៈ-

សិលាចារឹកនេះនិយាយពីឧបាសកម្នាក់ឈ្មោះជាសិនាហ្វ បាន សាងព្រះវិហាមួយឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ព្រមទាំងថ្វាយទ្រព្យ

សម្រាប់ព្រះវិហារមានទាសាក្មេងចាស់ ចំនួន៣២នាក់ពប់តាំងឆ្នាំចំការ ជូនស្ថាផង ។

គឺតាមរយៈសិលាចារឹកនេះ ដែលយើងដឹងនូវអរិយធម៌ខ្មែរ ព្រមទាំងនយោបាយកសិកម្ម ក្នុងសម័យសតវត្សទី៧នៃ គ.ស ។

ទី៣ សិលាចារឹករជ្ជកាលព្រះបាទជ័យវរ្ម័នទី ១

សិលាចារឹកនៅក្នុងខេត្តព្រៃវែងនេះមាន ៤ គឺ៖

## ១- សិលាចារឹកនៅវត្តព្រៃវៀរ.-

នៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង: ក្នុងព.ស. ១២០៦, គ.ស.៦៦៤)(១)

### ក) លក្ខណៈ._

ជាសិលាចារឹកសរសេរលើផ្ទាំងថ្មកក់មានកំពស់ ០ម៉ុ៧២, ទទឹង ០ម៉ុ៣៥, ក្នុង ម.ស. ៥៨៦ គ.ស. ៦៦៤ ។

ទាំងអស់មាន ១៧ បន្ទាត់គឺ ១០ បន្ទាត់ជាភាសាសំស្ក្រឹត, និង ៧ បន្ទាត់ជាភាសាខ្មែរ ។ អក្សរសរសេរស្អាតល្អណាស់ មានលំនាំគ្នានឹងអក្សរសម័យ គ្រិស្ត សតវត្សទី ០១ ។

### ខ) អត្ថបទ._

---

(១) មើល Inscription sanskrite du Cambodge par M.A. Barth, fascicule I ទំព័រ ៦០ តទៅ ។

១)– ធិតំ ឧរិដ្ឋៈសោរ្យណា   កដ្វា ស្រីជយវម្មណា   តាបលាបិ

សតី យត្រ ស្ថិក លល្ម . . . ។

២- ក្ដូយិស្វទ្រិស្ថិរយោក្យ ជគទ្រក្សណទិក្សណ័សសាក្សក សហ-

ស្រាក្ស ឥតិ ប្រាជ្យភីកិ . . . ។

៣– រក្សតស តស្យ ប្រិថិវី ប្រិថុវិក្រមនិវិដ្ឋំ កវេ្យ កិក្សរ-

រិស្ដៅ ស្ដស រសាទរក ស្ថិរ . . . ។(២)

គ) សេចក្ដីប្រែ.

១– ព្រះបាទស្រីជយវម៌ន ដ៏មានជោគ មានវីរិយភាពយ៉ាងមហិមា ទ្រង់ឋិតនៅជិតព្រះលក្ស្មី ទ្រង់គង់នៅគ្មានករម្រើក ។

២– ទ្រង់មានព្រះនេត្រទតវែងឆ្ងាយ . . . មានព្រះបញ្ញាវាងវៃក្នុងកិច្ចការពារលោក ហើយទ្រង់ត្រូវបានអ្នកប្រាជ្ញសហស្រាស្ដ្រលើកដំកើងឡើង ។

៣- ក្នុងពេលដែលទ្រង់គ្រប់គ្រងទឹកដីបានមកពីការវាតទីដ៏វែងឆ្ងាយ ក្នុងខណៈនោះមានព្រះភិក្ខុដ៏ជំនាញ ២ អង្គគង់នៅក្នុងព្រះរាជាណាចក្រព្រះអង្គ ។ ភិក្ខុនេះមានព្រះមាតារួមឧទរ, ម៉ុងម៉ាត់ក្នុង . . . ។

៤– ទាំងពីរព្រះអង្គប្រកបដោយគុណធម៌ទ្រង់សីល មានចំណេះវិជ្ជា សភាពស្ងប់ស្ងៀម សេចក្ដីអំណត់អត់ធន់ មានខ្លួនខ្ទួនហើយ

(២) មានតទៅទៀត តែខ្ញុំមិនយកមកកត់ត្រាទាំងអស់ទេ ដើម្បីកុំឲ្យមេរៀនវែងពេក ។

មានករុណា សមាធិប្រុងប្រយ័ត្នជានិច្ច ហើយព្រះអង្គមានព្រះគោត្រជាវត្ត ដែលនាមចុងប្រាកដទាំងពីរ គឺមួយអង្គនាម ភាណុ ហើយមួយអង្គទៀតនាម សិង្ហ ។

៥- បុត្រនៃកូនស្រីដែលជាបងនៃភិក្ខុទាំង ២ រូបនេះមានព្រះកិត្តិនាមខ្ពស់ គឺព្រះវិសុទ្ធ សុកិត្តិ ដែលមានព្រះសកម្មភាពយ៉ាងបរិសុទ្ធ ។

៦– តាមការគ្រប់គ្រងជាហូរហែ នៃព្រះញាតិវង្សមក ហើយតាមព្រះបញ្ញារបស់ព្រះមហាក្សត្រ ព្រះរាជបុត្រនេះត្រូវបានទទួលពេញបន្ទុកនូវអ្វីទាំងអស់ ដែលព្រះអង្គមានបុព្វសិទ្ធិនឹងទទួលពេញសមត្ថភាព ។

៧- មានសត្វទ្វេបាទ, ចតុបាទ, សួនឧទ្យាន, ដំរី, ព្រៃព្រឹក្សា, ចំការក្តី ហើយនឹងអស់ទាំងអ្វីដែលឋិតនៅក្នុងព្រះរាជអាណាចក្រ ត្រូវបានមកទ្រង់ ហើយគ្មាននរណាដទៃម្នាក់អាចមកទាមទារបានទេ ។ នេះគឺជាព្រះរាជបណ្តាំ និងព្រះរាជបញ្ញារបស់ព្រះមហាក្សត្រ ។

៨- សេចក្តីនេះសម្រេចឋិតនៅក្នុងសម័យព្រះចៅនៃសកៈ ដែលទ្រង់បានទទួលហើយនូវរសៈ, នូវវសុ និងវត្ថុរបស់កាយគនៈ, ជាថ្ងៃទី ២ កើត ខែមាឃ ។ ព្រះរាជបញ្ញានេះប្រគល់ទៅព្រះសង្ឃដែលគង់នៅក្នុងធានីរបស់ព្រះមហាក្សត្រ ។ គឺសេចក្តីនេះរាប់បានថាជា ព្រះរាជតម្រិះរបស់ព្រះមហាក្សត្រព្រះអង្គឯងប្រកបដោយព្រះវិចារណញ្ញាណត្រូវ . . . ។

## ឃ) អត្ថន័យទូទៅ ..

តាមន័យនៃសេចក្ដីរបស់សិលាចារឹកនេះ យើងដឹងថា ក្នុងគ្រិស្ត-សតវត្សទី ៧ មានភិក្ខុ ២ អង្គជាបងប្អូនបង្កើត ជាជាតិក្សត្រដែលយានបព្វជា ហើយទ្រង់គង់នៅក្នុងវត្តព្រៃវៀរនេះ សឹងមានសេចក្ដីសម្រួលបន្ថែមថា :(១)

"ក្នុងដែនដីដែលទ្រង់គ្រប់គ្រងនេះ មានភិក្ខុពីរអង្គជាបងប្អូនបង្កើតទាំងពីរអង្គ មានសីលជាពហូស្សូត្រ សុភាព មានខន្តី មានខ្ជួនខ្ជាន់ហើយ មានករុណា មានសមាធិចិត្តជាអរិយទ្រព្យ មាននាមខាងដើមជា រត : ដូចគ្នា ហើយខាងចុងមួយជាកាណុ មួយទៀតជាសិង្ហ: គឺភិក្ខុរតនកាណុ ១ ភិក្ខុរតនសិង្ហ ១" ។

តាមសិលាចារឹកនេះទៀត យើងឃើញថា សម័យនោះពុទ្ធសាសនាចំរើន មានភិក្ខុសង្ឃកាន់ក្រិត្យវិន័យ មានសមត្ថភាពបរិបូណ៌ ។ ទាំងបុត្រព្រះមហាក្សត្រ ក៏ចូលបួសក្នុងសាសនា ហើយព្រះរាជាមានព្រះសទ្ធាណាស់ក្នុងកិច្ចទំនុកបំរុងវត្តអារាមសមណព្រាហ្មណ៍ ។ គោតផលខាងសម្បត្តិទ្រព្យនគរ ក៏បរិបូណ៌ឥតខ្ចោះ មានតាំងពីគ្រឿងប្រើប្រាស់ផលដំណាំដាំដុះនិងសត្វពាហនៈផង ។

(១) តាមសេចក្ដីប្រែសំរួលរបស់ព្រះតេជព្រះគុណ ហ៊ាង ខាត់ ក្នុងសៀវភៅព្រះពុទ្ធសាសនា ២៥០០ ទំព័រ ៤៩ ។

## ២·សិលាចារិកនៅវិត្តប្រាសាទ..

(នៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង)[1]

### ក) លក្ខណៈ

ជាសិលាចារឹកសរសេរលើផ្ទាំងថ្មសំប៉ែតមានសណ្ឋានកង់ដូចជាទេវរូបនៃព្រះវិស្ណុក្លៀស មានត្រឹមតែកង់កាយមួយប៉ុណ្ណោះ ។ គ្មាននាមព្រះមហាក្សត្រទេក្នុងសេចក្តីនៃសិលាចារឹកនេះ ។ តែបើតាមថ្ងៃខែដែលបញ្ជាក់ (គឺក្រោយសិលាចារឹកមុន ៦ ថ្ងៃនោះ) ពិតជាសិលាចារឹកនេះឋិតក្នុងរជ្ជកាលព្រះបាទជយវរ្ម័ន ។ សកពជប្រាកដនោះ គឺឆ្នាំ ៥៨៩ នៃសកៈឬគ.ស. ៦៦៧ ។

អក្សរមានលំនាំដូចគ្នា ទីងសម័យទី ៦ ឬទី ៧ នៃគ.ស. ។

ទំហំសិលាចារឹកនេះមានកំពស់ ០ម០៨, ទទឹង ០ម៧៤ ។

### ១) អត្ថបទ –.

– នៅខាងស្តាំសិលាចារឹក មានពាក្យដាច់ ៗ គ្នាដូចតទៅ៖

. . យោ . . . . . .

. . . ន៑ . . . . . .

. . . . ន . . . .

---

(១) មើល Inscriptions sanskrites du Cambodge, par M. A. Barth, Ier fascicule ទំព័រ ៦៣ តទៅ ។

# រឿង ចៅតែលលក

សហ. ព្រួច-កុម

រៀបរៀងតាមការនិទានត ៗ មក

[ក]

ស្ការដែរថា «ខ្ញុំជាស្ដេចពស់ អាចកាឡាខ្លួនជាមនុស្សជាសត្វ បុរ្សក៏បាន សូមលោកអត់ទោស លែងខ្ញុំឲ្យបានរួចជីវិតចុះ បើកាលណាលោកមាន ទុក្ខធុរៈ គ្រាន់តែនឹកដើមទៅដល់ខ្ញុំ ៗ នឹងមកជួយភ្លាម» , ខ្មោចតូច ខ្សឹបប្រាប់ ថា ឲ្យលែងតាមពាក្យអង្វររបស់ពស់ ទើបវាលែង ហើយនាំគ្នាត្រឡប់មកចំការវិញ ។

លុះដល់ពេលយប់នៃថ្ងៃនេះ នៅពេលអធ្រាត្រស្ងាត់ ខ្យល់ដំនោរបក់រំភើយ ៗ បណ្ដាលឲ្យក្លិនបង្កើមស្រូវ ផ្សាយទៅពាសពេញទីព្រៃ ហាលក្លិនទៅដល់ស្ដេចដំរីសមួយ ដែលចាស់ជរាណាស់ហើយ ។ ស្ដេចដំរីសនោះ មានភ្លុកម្ខាងខកដំបែក ប៉ុនការុងស្រូវ ។ នៅក្នុងភ្លុកនោះ មានកូនក្រមុំមួយ មានរូបឆោមលោមព័ណ៌សម្បុរស្អាតល្អណាស់ មានភេទជាមនុស្សពិត ៗ ឈ្មោះ នាងភួន មិនដែលចេញខ្លួនឲ្យអ្នកណាឃើញទេ បើប្រសិនជាអ្នកផងបានឃើញហើយ នឹងអត់ទ្រាំស្រឡាញ់មិនកើត នាងបានជាទីបេតីនៃស្ដេចដំរីជាឪពុកណាស់ ។ ស្ដេចដំរីសធុំក្លិនស្រូវដ៏គួរឲ្យឆ្ងាញ់ ក៏ដើរស្រង់ក្លិនគាត់រក ដោយចំណង់ចង់ស៊ីស្រូវខ្លាំង

ណាស់ ស្រេកទឹកមាត់, ដើរដកបមកដល់ បានប្រទះនឹងចំការស្រូវទៅ តែលលក, មុននឹងចូលស៊ីស្រូវ បានពិចារណាផ្ចឹងរំពឹងគិតថា ខ្លួនអញជាស្ដេច ធ្លាប់មានខន្តីក្រាសុចរិតគត់តដែលល្អៀង ជាវៀងដកបមកយូរយារ មិនដែលហ៊ានបំផ្លិចបំផ្លាញប្រវ័ញ្ចកាញ់គ្នារបស់ទ្រព្យអ្នកណាមួយឡើយ, រីឯចំការស្រូវនេះ ពិតជាមានម្ចាស់គេទៅចាំរក្សា បើអញចូលស៊ីរបស់គេ នឹងមានកម្មពៀរវេរា ខូចខន្តិសីលធម៌, តែធ្វើម្ដេចទៅអេះ បើពេលនេះ អញឃ្លានចង់ស៊ីណាស់ ស្រេកទឹកមាត់ទឹកកទៅហើយ, ល្អើយប្រថុយចូលស៊ីសិនចុះ បើម្ចាស់គេមករកវៀង សុំអញឲ្យកូនក្រមុំរបស់អញទៅគេ ជូរជាថ្នូរមួយចំអែតបានហើយ ។ គិតស្រេច ក៏បែរស្រដីនឹងនាងពូនជាកូនខ្លួនដែលនៅក្នុងករថា នែកូនស្រីឪពុក ! ឪពុកចាស់ណាស់ហើយ នឹងមិនបាននៅយូរប៉ុន្មានថែរក្សាកូនស្ងួនសំឡាញ់ទេ, វេលានេះ ឪពុកឃ្លាន មានបំណាន់ចង់ស៊ីស្រូវនេះណាស់, ហេតុនេះ ឪពុកនឹងចូលទៅក្នុងចំការស៊ីស្រូវនេះឥឡូវ, តែដោយឪពុកធ្លាប់រក្សាសុចរិតជាវៀងបកហើយ ក៏យល់ថា នឹងលើកកូនឲ្យទៅអ្នកម្ចាស់ចំការ សុំគេជូរជាថ្នូរមួយចំអែត ហើយសុំគេនោះជាកូនប្រសាផង តើកូនយល់ស្របដែរឬ? នាងពូនឆ្លើយថា តាមតែបំណងលោកឪពុកចុះ ។ កាលបើដូច្នោះហើយ ស្ដេចដំរីសនិយាយផ្ដែផ្ដាំកូនស្រីរបស់ខ្លួនថា « បើកូនស្រីបានទៅនៅនឹងគេហើយ ចូរនាងប្រយ័ត្នខ្លួន

ឲ្យមែនទែន គេនឹងយកចិត្តទុកដាក់បម្រើប្រុសប្តីកុំបីមានធ្វេសប្រហែស ឡើយ, តែនាទីនេះ ឪពុកត្រូវផ្តាំទុកឲ្យហើយថា ចាប់ពីថ្ងៃនេះទៅ នៅ ប្រាំពីរថ្ងៃទៀត ទើបត្រូវចេញមកនៅរួមវេណី ជាមួយនឹងប្តីនាងបាន, បើពុំដូច្នោះទេ នឹងមានគ្រោះថ្នាក់ធំណាស់, ប៉ុន្តែបើកូនចង់ចេញមក ខាងក្រៅណាស់នឹងទ្រាំពុំបាន ត្រូវរាំងមើល បើគេចេញទៅណាបាត់ សឹមលបចេញមកមួយភ្លែត ។ ចុះ តែកុំឲ្យយូរពេក ត្រូវប្រញាប់ពួន វិញ កុំឲ្យគេឃើញ ។ ផ្តាំកូនសព្វគ្រប់ហើយ ទើបស្តេចដំរីសចូល ទៅបោចស្រូវស៊ីអស់ជាច្រើន, ឆ្អែតហើយ មិនទាន់ចេញទៅទេ នៅ ឈរពួនក្នុងចំការគន់មើលម្ចាស់គេ ។

ព្រឹកឡើងហើយ តាគែលលក ក្រោកពីដំណេក ចេញដើរទៅ មើលចំការ ដូចសព្វកាលរៀងមក បានឃើញដំរីឈរស្ងុងកណ្តាលចំការ នឹកខ្លាចខ្លាំងណាស់ មិនហ៊ានចូលទៅដេញចេញទេ ក៏រត់ទៅឡើងដើម ឈើមួយដើម ក្រឡេកមើលទៅ ឃើញស្រូវខូចខ្ចីអស់ជាច្រើន ប្រឹងតែ ចំកោងស្រែកបង្អើល ស្រែកហើយស្រែកទៀត បំណងឲ្យដំរីចេញទៅ, ប៉ុន្តែជាការឥតអំពើ ដំរីឥតដើរចេញសោះ នៅតែឈរធ្វើព្រឹះៗ បក់ស្លឹក ត្រចៀកឃ្លុបៗ ហើយដើរទៅជិតគល់ឈើដែលតាឡើង លើកប្រមោយ ត្រកងឡើងបក់ហៅថា “ អឹកូខ ! កូនអើយ កូន ! ចុះមកឲ្យចាប់ កុំខ្លាច ” ។ តាគែលលកឆ្លើយថា ទេលោកអើយ កុំធ្វើបាបខ្ញុំ ស៊ីស្រូវអស់ជាច្រើន

មានកម្លាំងហើយ ម្ដេចក៏ចង់មករករឿងព្រេចខ្ញុំទៀត ចេញឲ្យឆាប់ទៅ ខ្លាចណាស់ ៗ ដំរីសបេះតែទទូចហៅឲ្យចុះ តែវាមិនហ៊ានចុះមកសោះ ទើបដំរីកាច់ក្អុកទកហុចឲ្យទៅ ៗ មាណពក្មេងឃើញឫកដូច្នោះ បាត់ខ្លាចបន្តិច សម្រូតចុះមកទាំងញ័រជើងតត្រុត តែដល់ឮសំដីដំរីនិយាយថា កុំខ្លាចៗ កុំខឹង ហឹយកទៅ! ហើយផ្ដាំបន្ថែមថា យកទៅទុកឲ្យស្រួល ដាក់នៅកន្លែងដេក របស់នេះថ្លៃណាស់ សំខាន់ណាស់ ចូររក្សាទុកឲ្យគង់ កុំឲ្យបាត់ នៅ ៧ ថ្ងៃទៀត ទឹងឃើញស័ក្ដិសិទ្ធិ, បើថ្ងៃមុខមានទុក្ខធុរៈអ្វី ឲ្យនឹកទៅឪពុកក្លាម ឪពុកនឹងមកជួយ ឪពុកលាសិនហើយ, ថាហើយ ក៏ដើរចូលព្រៃបាត់ទៅ ៗ ចៅកែលលក យកក្អុកនោះទៅគ្របបិទបាំង យ៉ាងស្រួលទុកនៅកន្លែងដំណេកក្នុងខ្ទម ដោយទឹកសប្បាយចិត្តលែងស្ដាយស្រូវដែលខូច ហើយបន្តការងារជាធម្មតាទៅទៀត ៗ

និយាយពីនាងពួន ដែលចៅកែលលកយកមកទុកថែរក្សានោះ, នាងនៅចាំមិនភ្លេចទេ សំដីដែលស្ដេចដំរីជាឪពុកផ្ដាំទាំងប៉ុន្មាន ក៏ខំទ្រាំនៅក្នុងក្អុកបានតែត្រឹម ៣ ថ្ងៃ លុះសង្កេតទៅឃើញចៅមាណពដែលមានសេចក្ដីស្រឡាញ់ក្អុកណាស់ មិនដែលហ៊ានទៅណាចោលយូរ មិនដែលដាក់ឆ្ងាយពីទីដំណេក តែងដេកឱបក្អុកកល់កត្រី ពេលចេញទៅណា តែងគ្របបិទបាំងលាក់ទុកដូចបណ្ដាំឪពុកខ្លួនប្រាប់ មិនដែលភ្លេសមួយវេលា, ទាំងបានឃើញចៅមាណពកែលលកធ្វើការតែដោយផ្ទាល់ដៃឯង ចេញទៅថែ

ចំការផង ដងទឹកពុះឧស ដាំបាយ ទៅព្រៃរករបស់ផ្សេងៗផងដូច្នោះ នាងទឹកខ្មៅចិត្តអាណិតពេក ៗ ពេលព្រឹកថ្ងៃទី ៣ នោះ កាលដែលគេចេញទៅចំការបាត់ហើយ នាងកាត់ចិត្តប្រថុយចេញមកខាងក្រៅ បោសច្រាសសំអាតខ្ទម រៀបតាក់តែងចំណីអាហារ ទុកដាក់អីវ៉ាន់ផ្សេង ៗ រួចស្រេច ទើបចូលទៅពួនក្នុងកុកវិញ, នាងបន់ឲ្យតែបានគ្រប់ ៧ ថ្ងៃ ទើងបានចេញមកជួយធ្វើកិច្ចការផ្សេងៗ ឲ្យបានពេញដៃតទៅ ។

លុះដល់ពេលដែលចៅកែលលក ត្រឡប់មកពីចំការវិញ បានឃើញការចម្លែក ក៏អង្គុយពិចារណាថា ចុះនរណាអេះ មកតុបតែងដូច្នេះ មើលទៅឃើញស្អាតប្លែកតាំងអស់ បើកគម្របស្លឹកឈើមើលឃើញអាហារចំណីប្លែក ៗ ជុំគ្នាឈ្ងុយឆ្ងាញ់គួរឲ្យស្រក់ទឹកមាត់ គិតថាពោះជាដូចម្ដេចក៏ដោយ ស៊ីសិនហើយអញ ! ក៏ស៊ីរាបដល់ឆ្អែត ឃើញថាឆ្ងាញ់ឥតស្វាប្រមែន ៗ ស្អែក ខានស្អែកឡើង ឃើញដូច្នោះទៀត, សេចក្ដីសង្ស័យក៏កាន់តែមានខ្លាំងឡើង, ចៅកែលលក មានគំនិតមួយប្លែកកើតឡើងថា ព្រឹកស្អែកនេះ ជាព្រឹកទី ៤ អញគិតចេញទៅចំការ គ្រាន់តែចោលដើរបន្តិច ត្រឡប់មកចាំឃ្លាំមើលវិញឲ្យដឹងការណ៍, លុះដល់ព្រឹកស្អែកនោះ ក៏ធ្វើជាចេញទៅបានមួយស្របក់ គ្រាន់តែឲ្យអស់សង្ស័យ ហើយលបវារតាមផ្លូវស្រូវត្រឡប់មកវិញ មកពួនទៅក្បែរខ្ទមចាំលបមើល ៗ នាងពួន ដឹងថា គេចេញទៅបាត់ហើយ ក៏ចេញក្លូតពីកុកមក

ហើយរៀបចាត់ចែងកិច្ចការផ្សេង ៗ យ៉ាងប្រញិបប្រញាប់ រួចស្រេចក៏ចូលបាត់ទៅក្នុងក្អុកវិញ ។ ចៅមាណពតែលលក សង្កេតឃើញនាងដែលល្អរកស្រីឯណាផ្ទឹមពុំបាន មានចិត្តនឹកស្រឡាញ់ណាស់ កំណត់ទុកក្នុងចិត្ត ចាំថ្ងៃស្អែកនឹងចាំស្ទាក់ចាប់ឲ្យបាន ។ ព្រឹកស្អែកឡើងទៀតបុរសចេញទៅចំការ ហើយលបធ្វើតាមរបៀបពីម្សិល, លុះនាងពួនចេញមកធ្វើការ ដឹងថាផុតរួចហើយ ក៏ស្ទុះយ៉ាងប្រញាប់ទៅចាប់ទុចនាងជាប់, នាងស្ទុះចូលក្អុកមិនទាន់ សូម្បីនាងអង្វរថា សូមបងមេត្តាអាណិតលែងខ្ញុំ ។ ឥតតែទៅណាទេ, ដែលលោកឪពុកឲ្យមកនេះ គឺឲ្យមកនៅធ្វើជាប្រពន្ធរបស់បងហើយ ឯបងក៏ជាប្ដីខ្ញុំស្រាប់ហើយ ប៉ុន្តែចាំមួយថ្ងៃទៀតសិន ព្រោះឪពុកយើងបានផ្ដាំផ្ដាច់ ថាឲ្យបានគ្រប់ ៧ ថ្ងៃ ទើបចេញមកនៅខាងក្រៅបាន ។ ទោះបីនាងប្រាប់តាមដំណើរបណ្ដាំម្ដេចម្ដាក៏ឥតអំពើ, បុរសពុំព្រមសុខចិត្តលែងវិញសោះ បេះតែនិយាយអង្វរនាងថា បងស្រឡាញ់អូនណាស់ បងមិនហ៊ានលែងអូនទេ ក្រែងអូនកុហកបងឲ្យតែរួច ហើយនឹងរត់ទៅចោលបង ។ នៅពេលដែលយុវជនទាំងពីររូបកំពុងតែប្រទាញប្រទង់ ជជែកគ្នាមិនដាច់ស្រេចនោះ តណ្ហាក៏កម្រើកឡើង បណ្ដាលឲ្យខ្លួននាងពួនរីកធំថែកជាងកាលពីមុន ខកការ នឹងចូលក្នុងក្អុកវិញ ក៏ចូលលែងចុះហើយ ទើបនាងព្រមព្រៀងនៅរួមរស់សុខទុក្ខតាមបែបលោកិយវិស័យតទៅ ។ ឯខ្មោចតូច ដឹងថា ចៅតែលលក

ជាសម្លាញ់បានប្រពន្ធល្អ ក៏ជួយអរណាស់ ៗ ចាប់ពីថ្ងៃនេះមក ខ្មោចតូច តែងមកលេងខ្ទមទៅតែលលកពល់ថ្ងៃ ជួយមើលការពារសុខទុក្ខផ្សេង ៗ ព្រមទាំងប្រាប់ឲ្យទៅយករបស់ខ្វះ ៗ មកទុកប្រើប្រាស់ ព្រោះក្នុងខ្ទមគ្មានអ្វីប្រើសោះ ។

មិនទាន់បានយូរប៉ុន្មាន ជាចន្លោះថ្ងៃដទៃ បណ្ដាលហេតុពីខុសត្រូវណាមិនទាន់ដល់កំណត់តាមបណ្ដាំដ៏វិសេសជាឪពុកបានផ្ដាំទុក, ថ្ងៃមួយ ដូនជាមាននាយព្រានព្រៃម្នាក់ ដើរត្រាច់ឆ្ពោតរកតត្រុកក្នុងព្រៃ វង្វេងមកដល់បានឃើញខ្ទម ត្រូវស្រេកទឹកផង ក៏ចូលទៅរកទឹកផឹក បានឃើញនាងពួនដែលមានរូបសម្បត្តិល្អឥតខ្ចោះរកទាស់ត្រែកគ្មាន គិតថា នាងនេះមិនសមជាប្រពន្ធមនុស្សកំព្រាអនាថា នៅក្នុងព្រៃស្រោងស្រឹងត្រមង់ត្រមោចដូច្នេះសោះ, ដំបូងទឹកបង់បានខ្លួនឯង ប៉ុន្តែដល់គិតថា បើទុកជាបានមកខ្លួនក៏មិនស័ក្ដិសមគ្នា តែទីងត្រូវធ្វើដូចម្ដេចអេះ? ដោយនាយព្រានចង់បានសេចក្ដីគាប់គំគិតឃើញភ្លាមថា នាងនេះ សមស័ក្ដិជាព្រះរាជទេពី, ទើបព្រាននោះឈ្លបសួរសព្វហេតុការណ៍ ដឹងស្រេចកាលណា ក៏វិលត្រឡប់ចូលព្រះរាជនគរ នាំយកដំណឹងចម្លែកនោះទៅក្រាបទូលព្រះរាជាម្ចាស់ផែនដីរបស់ខ្លួន, ស្ដេចបានជ្រាបកិច្ចការអាថ៌សេចក្ដី តាមពាក្យព្រានទូល ក៏ច្រួលព្រះទ័យលៃលករកឧបាយ ទីងផ្ទាយយកភរិយាទៅបុរសនោះឲ្យខាងតែបាននឹងចេញទៅរឹបយកភ្លាមទាំងអំណាចហាក់មិនសម ព្រោះទ្រង់ជាព្រះមហា

ក្សត្រខត្តិយជាតិ ខ្លាចក្រែងមនុស្សទេវតាឃើញថារាតឃ្លាតទសពិធរាជធម៌ ក្រៅត្រិត្យក្សត្រខ្លាំងពេក ទើបលើកជាល្បិចកិច្ចកល, ជាដំបូងបង្អស់ បង្គាប់ចៅព្រានឲ្យនាំរាជសាសន៍ទៅប្រាប់ចៅបុរសថា « ប៉ូស្អកនេះ ឲ្យរកមាន់យកទៅប្រជល់គ្នាល់គ្នា, បើស្តេចចាញ់ នឹងផ្ទេររាជ្យឲ្យ, បើចៅគែលលកចាញ់ នឹងត្រូវវែរយកភរិយាខ្លួនថ្វាយស្តេច, បើខកខានមិនបានមាន់យកមកប្រជល់ ស្តេចនឹងរឹបអូសយកប្រពន្ធចៅ ដោយប្រើរាជអាជ្ញា » ។

ចៅគែលលក លុះបានទទួលអាជ្ញាស្តេច ដឹងហេតុការណ៍ហើយ ក័យស្លុតរន្ធត់ចិត្តណាស់ គិតថា ពេលនេះ អាសន្នធំដល់ហើយ ក៏ដេកសន្ទឹកសន្ធៃព្រួយចិត្ត មិនដឹងជានឹងគិតទៅរកមាន់ឯណា បានយកទៅប្រជល់, កំពុងតែខ្វល់អត់បាយក្រហាយទឹកដូច្នោះ, ពេលព្រលប់ៗ ខ្មោចតួចមកលេងឃើញចៅគែលលកស្លុតស្លប់ជ្រប់សញ្ជាប់សញ្ជឹង ក៏សួរ, បុរសប្រាប់ខ្មោចតួច តាមដំណើរដែលមាន, តួចប្រាប់ថា ការប៉ុណ្ណឹងៗ ទៅភ័យព្រួយធ្វី! ក្រោកឡើងរកម្ហូបទឹកស៊ីបាយឲ្យស្រួលខ្លួនទៅ ចាំយើងប្រាប់ជាក្រោយ ។ ឮដូច្នោះភ្លាម បុរសបានធូរទ្រូងបន្តិច ប៉ុន្តែពុំទាន់ដឹងថានឹងបានចេញឲ្យរួចពីសេចក្តីកង្វល់នោះតាមផ្លូវណានៅឡើយទេ ។ រួចបាយហើយ ទើបខ្មោចតួចរំពុកថា ចូរឯងនឹកទៅដល់ស្តេចស្ការឲ្យមកឥឡូវ, បុរសនឹកឲ្យស្តេចស្ការមក, ស្តេចស្ការក៏មកដល់ភ្លាមដូចចិត្ត ហើយសួរបុរសថា « តើលោកមានធុរៈអ្វី? » បុរសថ្លែងប្រាប់ស្តេចស្ការ តាមដំណើរហេតុកើតមាននោះ,

ស្ដេចស្វាថា សូមកុំព្រួយ ការប៉ុណ្ណេះ ៗ មិនជាអ្វីទេ, ព្រឹកស្អែកនេះ ប្រឹងប្រៀបខ្លួននឹងទៅចុះមិនចាញ់ស្ដេចទេ ខ្ញុំហ៊ានធានាយកអាសាបាន តាំងអស់, ថាហើយ ស្វានោះលោតចូលព្រៃវិញបាត់ទៅ ៗ លុះព្រឹកឡើង ហើយ នាងពួន ប្រពន្ធចៅកែលលក រៀបចំឲ្យដំណើរប្ដីចាំស្ដេចស្វា, ស្ដេចស្វាក៏បានមកដល់ ទើបនាំគ្នាធ្វើដំណើរទៅ, លុះទៅជិតទីដល់ ពដដំណាក់ស្ដេចហើយ ស្ដេចស្វាកាឡាខ្លួនជាមាន់ឈ្មោលសំគមតូចមួយ ប្រាប់ឲ្យមាណពយកសំពត់រុំឲ្យជិតបីដើរចូលទៅកន្លែងសែវៀន ៗ ដល់កំ-ណត់ពេលទីងប្រជល់មាន់ហើយ, ព្រះរាជា នាម៉ឺនសព្វមុខមន្ត្រី មួយអន្លើ ដោយរាជបរិពារ ក៏ចូលកាន់ទីសែវៀនត្រៀបត្រា ៗ ទ្រង់ត្រាស់សួរ ទៅចៅមាណពថា “មាន់អ្នកឯងនៅឯណា?” ទើបចៅកែលលកស្រាយ សំពត់រុំចេញ យកមាន់ថ្វាយព្រះរាជាទត ៗ មាន់នោះធ្វើសម្លេងក្រត ៗ ដើរទ្រេតទ្រោតចង់តែលំ ៗ ពួកបរិពារស្ដេច ឃើញដូច្នោះ នាំគ្នាហ៊ា កញ្ជ្រៀវទះដៃសើចចំអកឲ្យចៅកែលលកៈនោះថា “វ៉ុយ កះយ៉េង មើល មាន់គេ ចុះមាន់ផលអ៊ីក៏សំគមប៉ចញ៉ចកុំបេះ មើលទៅគេសាប់ស៊ីគ្មាន ទេ! វ៉ុយ មាណពអើយ ឯងកុំចង់ប្រឡងអ្វី វាមិនឈ្នះទេ, មើលទៅនាំតែ ខាតពេលទេ, វិលទៅយកប្រពន្ធឯងមកទុកឲ្យហើយទៅ វាល្អជាង!” ។ ឯមាន់ស្ដេចវិញ, ស្ដេចបង្គាប់ពួករក្សាមាន់ឲ្យរើសសម្រាំងស៊ុទ្ធតែមាន់ធំៗ

មាំល្អ ជាមាន់ធ្លាប់ប្រជល់មានជ័យ ឈ្នះគេពជាច្រើនលើកមកហើយ ៗ ពេលនោះ ទ្រង់មានព្រះទ័យសោមនស្សណាស់ ព្រះភក្ត្រញញឹម ដោយទ្រង់យល់ច្បាស់ ជាមុនស្រេចថា នឹងបានឈ្នះមាណព គ្មានសង្ស័យ ទើបទ្រង់ត្រាស់ឲ្យលែងមាន់ចូលសៃវៀន ៗ មាន់ព្រះរាជាវត់ចូលធ្វា ទទះស្លាបរងាវ បញ្ចេញឫកសង្ហារ អួតតែជើងរកជល់ ៗ ឯមាន់ទៅតែលលកនោះ ធ្វើជាដើរជ្រួចៗ បែបកង្សុរ ធ្វើសប្រែកក្រុច ៗ ក្រុចៗ..ៗ លុះមាន់ស្តេច ចូលសម្រុកមកសង្គ្រប់ចាក់មួយផ្ទាល់ពីរ, មាន់ទៅតែល-លក ធ្វើជារត់វិលចុះឡើង ដូចជាត្រូវស្រងល់វឹងស៊ិងហើយ, មាន់ស្តេចចេះតែសង្គ្រប់ចាក់បន្ថែម ៗ ព្រះរាជា ព្រមទាំងបរិវារ និងពួកអ្នកមើលទាំងប៉ុន្មាន មានទឹកមុខញញឹម ទះដៃហោកញ្ញៀវខ្សៀវខ្សារ, ឯទៅតែលលក មានទឹកមុខស្រពោន តែគេនៅមានសង្ឃឹមជានិច្ច ៗ លុះដល់ចុងទឹកទី១ ជិតមកដល់ហើយ ទើបមាន់ទៅតែលលក លោតសង្គ្រប់ ចាក់មាន់ស្តេច តែមួយជើង ចឹកចំក្បាលតែមួយចំពុះ, មាន់ស្តេចបែកក្បាល លៀនខ្នកខ្នែ ហូរឈាមសស្រាក់ ប្រកាច់គះៗ ដួលស្លាប់មួយរំពេច ៗ ស្តេចខ្វល់ណាស់ត្រាស់ឲ្យភ្នាក់ងាររក្សាមាន់ លែងមាន់ទាំងអស់ចូលក្នុង សៃវៀន, តែឥតប្រយោជន៍ មាន់ទាំងអស់ប្រមាណ ៥០០ ត្រូវស្លាប់ និងបង្ខូចស្ការទាំងអស់ គ្មានសល់មួយ ៗ ជ័យជំនះរឿងដល់មាន់

ត្រូវបានខាងចៅតែលលក ៗ ព្រះកជាត្រាស់ថា អើមាណព ! ពេលនេះ មាណពឈ្នះយើងហើយ, ពាក្យពិតដែលយើងនិយាយទាំងប៉ុន្មាននោះ ក៏យើងមិនបំភ្លេចដែរ, តែថាការដែលត្រូវប្រកួតគ្នា មិនមែនអស់ហើយតែត្រឹមរឿងប្រជល់មាន់មួយមុខប៉ុណ្ណោះទេ នៅមានច្រើនទៀតទើបអស់កិច្ច ៗ ដូច្នេះ ស្អែកត្រូវអ្នករកក្របីយកមកប្រជល់ទៀតកុំខាន ៗ កិច្ចការភ្នាល់ប្រជល់មាន់ បិទសម័យត្រឹមពេលនេះហើយ, ស្អែកយើងបើកសម័យប្រជល់ក្របី, ពេលវេលាដូចសម័យជល់មាន់ដែរ ៗ

មានជ័យមួយគ្រាហើយ មាណពហាក់ដូចបានធូរទ្រូងបន្តិច, ទើបថ្វាយបង្គំលាស្ដេច បីមាន់ត្រឡប់ទៅលំនៅឋានវិញ បៀមយកជ័យជំនះរឿងជល់មាន់ទៅផង បៀមទាំងទុក្ខព្រួយមួយចំណែកទៀត ដែលថាស្អែកត្រូវតែរកក្របី ឲ្យបានយកទៅប្រជល់នោះផង ៗ ពេលដែលមាណពចេញទៅប្រជល់មាន់ផុតបន្តិច ខ្មោចតូចក៏ទៅតាមក្រោយដែរ ចាំស្ដាប់ដើងការណ៍ លុះដឹងថា មាន់ចៅតែលលកឈ្នះមាន់ស្ដេចហើយ ទាំងបានឮស្ដេចបង្គាប់ ឲ្យរកក្របីប្រជល់ទៀត ក៏គិតឃើញស្រេចគ្មានព្រួយហើយត្រឡប់មកលំនៅវិញមុនចៅតែលលក ៗ ឯមាណពតែលលកនិងស្ការក៏បានមកជាក្រោយ, ដល់មកកន្លែងមួយ ស្ដេចស្ការនិយាយប្រាប់មាណពថា បើមានធុរៈអ្វីទៀត ឲ្យនឹកដល់ខ្លួនវាទៀតចុះ វានឹងមកជួយ តែចំពោះរឿងជល់ក្របីជួយមិនកើតទេ ហើយលាចេញបាត់ទៅ ៗ

ចំណែកឯនាងពួនវិញ នាងនៅចាំខ្ទមព្រួយចិត្តណាស់ អង្គុយចាំមើលផ្លូវប្ដី ផ្សារគាំក្នែក ១ ថ្ងៃទល់ល្ងាច , លុះបានឃើញប្ដីមកដល់វិញហើយ នាងត្រេកអរណាស់ ស្ទុះរត់ចេញទៅទទួល សម្ដែងការគួរសមនិងសេចក្ដីស្រឡាញ់ អញ្ជើញប្ដីឲ្យងូតទឹក រួចរៀបបាយទឹកឲ្យប្ដីអាស្រ័យ, ជាបណ្ដើរនោះ មាណពនិយាយប្រាប់ប្រពន្ធថា រឿងប្រជល់មាន់មិនជាអ្វីទេ ព្រោះបានស្ដេចស្វាជួយរួចមួយគ្រាហើយ, តែនៅមានរឿងប្រជល់ក្របីមួយឡែកថ្មីធ្លាក់មកដល់ទៀតហើយ ៗ គ្រាន់តែលេបបាយបាន ៤-៥ ម៉ាត់ មាណពនឹកព្រួយក្ដុកក្អួលដល់ដើមក លេបបាយលែងចូល ក៏យកទឹកមកផឹកហើយទៅប្រះផេកយកដៃគងថ្ងាសសន្ធឹកសន្ធៃ នឹកគិតមិនចេញថានឹងទៅរកក្របីឯណាបាន ៗ លុះដល់ពេលព្រលប់ ខ្មោចតូចមកសួរ; មាណពថ្លែងរឿងប្រាប់ តាំងពីរឿងជល់មាន់រហូតដល់រឿងត្រូវប្រជល់ក្របីស្អែកទៀត ហើយប្រាប់ឲ្យខ្មោចតូចជួយគិតផង ៗ ទើបខ្មោចតូចប្រាប់ថា សម្លាញ់កុំទៅគិតអី កុំព្រួយពេក, រឿងជល់ក្របីនោះវាងាយសោះទេ, ចូលនឹកទៅស្ដេចខ្លាដែលជាប់អន្ទាក់ឯងពីមុននោះ ឲ្យមកជួយទៅបានហើយ ៗ គ្រាន់តែតូចថាភ្លាម មាណពក៏នឹកឃើញភ្លាមទៅដល់ស្ដេចខ្លា ៗ ក៏មកដល់ដូចចិត្ត ហើយសួរពីបំណងដែលនឹកឲ្យខ្លួនមក, មាណពអធិប្បាយរឿងប្រាប់ស្ដេចខ្លា ៗ ថា រឿងនេះកុំព្រួយ ខ្ញុំហ៊ាន

ណានាជួយបាន, សូមលោកសម្រាន្តឲ្យស្រួលខ្លួនទៅចុះ ចាំស្អែកខ្ញុំមក, ថាហើយ ខ្លានោះក៏លាទៅវិញបាត់ទៅ ។

ព្រឹកស្អែកឡើង ចៅគែលលកវង់ចាំស្ដេចខ្លា ។ ក៏បានមកជួបសន្យា ហើយនាំគ្នាធ្វើដំណើរចេញទៅ លុះទៅដល់កន្លែងស្ងាត់មួយ ខ្លាក៏សម្ដែងរិទ្ធិកាឡាខ្លួនធ្វើជាក្របី, មុនដំបូង ធំធាត់មាំ រួចហើយធ្វើខ្លួនឲ្យតូច នៅប៉ុនកូនក្របីទើបកើតបាន ១ ខែ ស្ដេចយើង លេចធ្មេងដំនីររគាម ថួចង៉ែក ។ ។ កាលដែលចូលទៅដល់ទីប្រជុំហើយ មាណពក៏ថ្វាយបង្គំព្រះកជា ។ ទតឃើញកូនក្របីតូចដូច្នោះ ទ្រង់ញញឹមសង្ស័យថាទីងឈ្នះឥតសង្ស័យ, ទើបត្រាស់ឲ្យគ្នាក់ងារលែងក្របីស្ដេច ចូលទីលានប្រជល់ បង្គាប់ឲ្យមាណពលែងកូនក្របីនោះទៅដែរ ។ កូនក្របីរបស់ចៅគែលលកក៏បោលចូលទៅរកក្របីស្ដេចសស៊ុលក្រោមពោះរកបៅបោកពង ។ ក្របីស្ដេចរេសីចណាស់ប្រឹងតែបោលពាសពេញទីលាន, កូនក្របីចេះតែបោលដេញមិនឈប់, លុះដល់ទីបំផុត កូនក្របីខាំផ្ដាច់បោកពងរបស់ក្របីស្ដេច, ក្របីស្ដេចបោលចាំងហូរឈាមសស្រាក់ ដកបដល់សោះឈាមដាច់ខ្យល់ស្លាប់ទៅ ។ ស្ដេចបង្គាប់ឲ្យយកក្របីទី ២ ចូល, ក្របីទី ២ ត្រូវដាច់បោកស្លាប់ទៀត ។ ស្ដេចខ្ញាល់ណាស់ ត្រាស់បង្គាប់ឲ្យលែងក្របីចាំងហ្វូងចូលទៅទៀត, ក្របីចាំងនោះត្រូវស្លាប់ដូចគ្នាអស់គ្មានសល់មួយ ។ សម័យនៃការក្តាល់ដល់ក្របី

ក៏បានបិទ ៗ ព្រះរាជា ត្រាស់ហៅមាណពទៅប្រាប់ថា រឿងភ្នាល់ជល់ក្របី ទុកជាជ័យជំនះបានទៅខាងឯចៅហើយ, ប៉ុន្តែនៅពេលព្រឹកស្អែកត្រូវបើកសម័យជល់ដំរីទៀត, ចូរអ្នករកដំរីយកមកប្រជល់កុំខាន, កំណត់ពេលវេលាដូចមុន ៗ ។

ជល់មករឿងជល់ដំរី ចៅកែលលកភ័យណាស់ ព្រោះកាន់តែធ្ងន់ទៅទៀត, ហើយថ្វាយបង្គំលាស្តេច នាំក្របីតូចនោះត្រឡប់លំនៅវិញ ដើរមកដល់ពាក់កណ្តាលផ្លូវ ប្រទះនឹងខ្មោចតូច ១ សួរ, មាណព ប្រាប់តាមរឿងហូរហែ, ខ្មោចតូចប្រាប់ថា ចូរសម្លាញ់នឹកទៅដំរីសជាឪពុកក្មេកឯងនោះ ឲ្យមកជួយទៅបានហើយ ។ លុះនាំគ្នាមកដល់ខ្ទម, ស្តេចខ្មោចលាចេញទៅ, ចៅកែលលក ក៏សំបូងសន្រ្ទឹងនឹកទៅដល់ស្តេចដំរីស ១ ក៏មកដល់ភ្លាម សួរថា អីកូន ! តើកូនមានការធុរៈដូចម្តេច ? មាណពរៀបរាប់ប្រាប់ស្តេចដំរីឪពុកក្មេកពីរឿងស្តេចឲ្យរកដំរីយកទៅប្រជល់នោះដោយសព្វគ្រប់, ស្តេចដំរីថា ទៅភ័យអីប៉ុណ្ណឹង ១ កុំព្រួយកូន! លុះស្អែកឡើង ក៏ចេញដំណើរទៅកាន់ទីលានប្រជល់, ស្តេចដំរីបាននិម្មិតខ្លួនឲ្យកាន់តែចាស់ជាងប្រក្រតី ស្គមរំពេក ខ្សល់ចក់ស៊ីរលំ ដើរទ្រេតទ្រោតៗ ចាក់ឃ្លួយ ១, ទៅដល់ហើយ ចៅមាណពកែលលក ចូលក្រាបថ្វាយបង្គំស្តេច ១ ត្រាស់ឲ្យលែងដំរីចូលលានប្រយុទ្ធគ្នា ។ ឯដំរីស្តេច គ្រាន់តែក្រឡេកឃើញស្តេចដំរីសនោះភ្លាម ក៏ដួញជង្ឈលើកប្រមោយត្រែងឡើង

លើ ជាសញ្ញាក្រាបថ្វាយបង្គំស្តេចដំរីស ។ ស្តេចខ្ញាល់ណាស់ត្រាស់បង្គាប់ឲ្យលែងដំរីទាំងអស់ឲ្យចូលចំប្រាវបំព្រេចដំរីសំគមនោះ, ប៉ុន្តែជាការឥតអំពើសោះ, ព្រោះដំរីស្តេចទាំងអស់ សុទ្ធតែលុតជង្គង់ថ្វាយបង្គំស្តេចដំរីដោយតាញ់បុណ្យបារមីស្តេចដំរីនោះខ្លាំងពេក ស្លុតទាំងខ្លួនប្រាណហូតដល់សរសៃធំនាំឈាមហូរលែងកើត ក៏ស្រាប់តែគាំងបេះដូង ស្លាប់ទាំងអស់គ្មានសល់មួយ ។ ស្តេចរឹងរឹតតែខ្ញាល់ គិតរករឿងតាប់ថ្នាក់ផ្ចាញ់ផ្ចាលចៅតៃលលក ហើយត្រាស់ប្រាប់ទៅថា រឿងដល់ដំរី បញ្ចប់ត្រឹមប៉ុណ្ណោះទុកជាចៅឯងឈ្នះចុះ, តែថា មាន់ក៏ច្រើន ក្របីក៏ច្រើន ដំរីក៏ច្រើន សុទ្ធតែជារបស់ផងយើងជាស្តេច ត្រូវចៅឯងសម្លាប់អស់ហើយ, បើដូច្នេះត្រូវឯងមកស៊ីសាច់សត្វ ដែលអ្នកឯងបានសម្លាប់ឲ្យអស់ , បើស៊ីមិនអស់ត្រូវចាញ់យើង ។ នឹងរឹបយកប្រពន្ធឯងហើយ ។ ចៅតៃលលក ថ្វាយបង្គំលាស្តេច នាំដំរីត្រឡប់ទៅលំនៅវិញ, ខ្មោចតូចមកសួរដូចកាលមុនៗ ដឹងរឿងហេតុហើយ ប្រាប់ឲ្យទឹកទៅដល់ស្តេចពស់ ហៅឲ្យមកជួយ, ស្តេចពស់មកដល់ភ្លាម, ចៅតៃលលកប្រាប់ស្តេចពស់ឲ្យជួយតាមដំណើរហេតុ ។

ព្រឹកស្អែកឡើង ចៅតៃលលក នឹងស្តេចពស់ នាំគ្នាចេញទៅកាន់រាជវាំង, ប៉ុន្តែគ្រានេះ ស្តេចពស់មិនឲ្យចៅតៃលលកទៅផងទេ ឲ្យពួននៅក្នុងព្រៃបានហើយ ។ វាកំណែងខ្លួន ធ្វើឲ្យដូចចៅតៃលលក ដើរចូលទៅ ។ នៅទីព្រះលានស្តេច គេរៀបមាន់ស្ងោរទាំងមូល ៥០០ ក្របី

ស្វោរទាំងមូល ៥០០ ដំរីអាំងទាំងមូល ១០០ និងបាយ ១០០ ខ្ទះឆ្នាត ទុកបម្រុងជាស្រេច ។ ស្ដេចទតឃើញពស់ក្លែងខ្លួននោះទៅដល់ ទ្រង់ទឹកស្នានជាបៅកែលលក ក៏ត្រាស់ថា នែមាណព! នុ៎ះហ្ន៎ ជាក្រយាហារសម្រាប់ឯងហើយ ចូរឯងអំពះឲ្យអស់ទៅចុះ ។ ពស់ក្លែងគេទ ក៏ធ្វើគារវ-កិច្ចចំពោះព្រះរាជា ដូចលំនាំបៅមាណពកែលលកពិត ៗ រួចហើយក៏ចូលទៅកាន់គោជនដ្ឋាន លាតសន្ទឹងកន្ទុយទៅដល់ស្ទឹងដែលមានទឹកហូរយ៉ាងក្របាញ់ ឥតឲ្យនរណាម្នាក់មើលឃើញ ហើយចាប់ស៊ីអាហារតាំងតែពីព្រឹកទល់រសៀល , មាត់តែពម គូទពីតតែបញ្ចេញបោលទៅក្នុងស្ទឹង, ស៊ីដកបដល់អស់ តាមដែលស្ដេចដាក់កំរិត គ្មានឲ្យនៅសល់អ្វី ។ ស្ដេចទ្រង់ទឹកស្ងើចជាខ្លាំងពន់ពេក ទើបត្រាស់ហៅមកប្រាប់ថា រឿងស៊ីបិទសម័យត្រឹមប៉ុណ្ណោះចុះ, ប៉ុន្តែ ចូរអ្នកទៅរកទូក យកមកអុំប្រណាំងផ្ដាច់ព្រ័តឲ្យបានប្រញាប់ឥឡូវ ខានមិនបាន ។ មាណពក្លែងក្លាយ ថ្វាយបង្គំលាស្ដេច ចុះចាកពីដំណាក់យ៉ាងរហ័ស ទៅកាន់កន្លែងដែលបានមត់គ្នាឲ្យមាណពកែលលកនោះពួនចាំ , បានដល់ហើយ រាយរាប់ប្រាប់ក្លាមថាស្ដេចឲ្យរកទូកយកទៅប្រណាំងទៀតហើយ, ដូច្នេះ ចូរលោកអញ្ជើញមកទឹងចុះកាត់តម្រង់ទៅស្ទឹងតែម្ដង, ដល់ស្ទឹងហើយ ស្ដេចពស់ប្រាប់មាណពកែលលក ឲ្យរកបន្ទះឈើមួយកំណាត់ ប្រាសធ្វើជាប្រវាឲ្យតែបាន ហើយខ្លួនវានិមិត្តជាទូកគម្រោលមួយតូចស៊កប៉ផ្ទឹក តៀបប្រហៀរស្មើរទឹង

លិច ឲ្យមាណពឡើងជិះខាងកន្ទៀ យកប្រវ៉ាគ្រាន់តែធ្លុតទឹក ធ្វើដូចជាប្រឹងអុំ ហើយវ៉ៃហែលទៅដល់កំពង់ស្តេចក្តាម, ប្រាប់មាណពឲ្យឡើងទៅទូលស្តេចថា គេទូកបានហើយ ៗ ស្តេចព្យដូបោះ ក៏ឲ្យក្តាក់ងាររៀបទូកស្តេច កេណ្ឌអគ្គសេនាបតីទាំង ៤ និងនាម៉ឺនក្រុមវាំងចុះទូក ។ ស្តេចគង់កណ្តាល ចេញអុំប្រណាំង, ទ្រង់ត្រាស់ថា អស់លោក! ចូរអស់លោក យកចិត្តទុកដាក់ ប្រុងដើងការឲ្យមែនទែនណា ! ប្រឹងយ៉ាងណាឲ្យអស់សរសៃ ឲ្យតែចាញ់គេម្តងនេះ ខ្ញុំនឹងសម្លាប់ចោលទាំងអស់ ៗ ការប្រណាំងទូក ក៏ចាប់ផ្តើមឡើង ៗ ពួកទូកស្តេច ប្រឹងយ៉ាងអស់ទំហឹង តាំងពីលើកទី ១ ទី ២, ឯទូកមាណព ៗ គ្រាន់តែធ្លុត ៗ គ្រវាសប្រវ៉ាធ្វើជាលើកដាក់ ១ ផុក ១ ឥតមានទៅប្រឹងអ្វីសោះ ក៏ក្បាលទូក លឿនស្មើនឹងទូកស្តេចខ្លះ ថយអន់ជាងបន្តិចបន្តួចខ្លះ ល្មមតែឲ្យពួកខាងទូកស្តេច មានសង្ឃឹមថា នឹងផ្តាច់យកជ័យនៅលើកទី ៣ បាន ៗ លុះដល់លើកទី ៣ ពស់ក្មេងកេងនោះ ក៏ធ្វើជាប្រឹងបន្តិចទៅពីដើមទី ឲ្យពួកទូកស្តេចប្រឹងពីតតាម តែមិនឲ្យទូកស្តេចមានក្បាលលូតលឿនជាង, ពួកនោះ កាន់តែពិតឡើង ៗ ប្រឹងយ៉ាងអស់សរសៃ អស់ពីមួយអើយមួយ សាប់ផង ចកផង មើលទៅប្រវ៉ាញាប់សេញ ទូកលឿនដូចព្រួញ, ពស់វេវាត់កន្ទុយវាយផ្ចុចទូកស្តេច ព្រួសពិសចំកខាំសម្លាប់ទាំងស្តេច ទាំងបរិពារអ្នកអុំគ្មានឲ្យសល់ម្នាក់ ៗ

ភ្លាមនោះ ស្រពាស្តេចទៅយកកំណើតជា សត្វឆ្មា, សេនាបតីធំទាំង ៤ ទៅកើតជា ខ្លែងស្រាក ខ្លែងខ្មោច ទីទុយ មៀម, នាម៉ឺនធំតូចក្រៅពីនេះ ទៅកើតជា ពស់ ក្អែម ខ្មួយ ខ្យាដំរី ស៊ុទ្ធសឹងជាសត្វអាសិរពិស ហើយនាំគ្នាទៅដល់ខ្ទមមុនចៅកែលលក ខ្លះទំនៅលើចុងឈើ ខ្លះចូលទៅសម្ងំនៅក្នុងផ្ទាំងប៉ាយ -បំពង់ទឹក-គំនរខុស-ជញ្ជាំងខ្ទមប្រុងចាំសម្លាប់នាងពួននិងចៅកែលលក ។ ខ្មោចតូច បានដឹងហេតុការណ៍នោះទាំងអស់ ព្រោះវាមើលឃើញខ្មោចដូចគ្នា, តូចទៅប្រាប់នាងពួនឯខ្ទមឲ្យប្រយ័ត្នសព្វគ្រប់ហើយ ក៏ប្រញាប់ទៅស្ទាក់ផ្លូវចាំប្រាប់ការណ៍ទាំងអស់នោះដល់ចៅកែលលកទៀត ។ ក្រោយបន្តិចមក ទើបមាណពនិងពស់មកដល់, ជួបជុំគ្នាហើយ តូចប្រាប់ឲ្យមាណពយកស្នាមកតម្រើងផ្លាប់ព្រួញប្រុងចាំជាស្រេច ហើយមិនដឹងជាបានប្រទាលអ្វីមួយដុំតូចហុចទៅឲ្យមាណពទំពារស៊ី ។ ហើយទើបវាប្រាប់ថា ឲ្យប្រុងចាំមើលទឹងឃើញឆ្មា ជាតួស្តេចខ្មោច និងសត្វផ្សេង ៗ ទៀត, បើកាលណាវាស្រែកយំ ឲ្យបាញ់ភ្លាម ៗ ថាមិនទាន់ផុតពីមាត់ ឆ្មាស្រែក ឡូ! ឡូវ! ឡៀវ, នាងពួនត្រូវសន្ធប់បាត់ស្មារតី, មាណពបាញ់ធ្លាក់ក្ដោក, នាងពួនក៏បានភ្ញាក់ដឹងខ្លួនឡើងវិញ, លេចឯខ្លែងស្រាក ខ្លែងខ្មោច ទីទុយ មៀម មកស្រែកក្រាក ៗ! ទីទុយ ៗ! ម៉ឺម ៗ! នាងពួនត្រូវសន្ធប់បាត់ស្មារតីទៅទៀត, មាណពបាញ់សម្លាប់អស់ទៀត ទើបនាងពួនភ្ញាក់

ឡើងវិញ (ជាទម្លាប់ សូម្បីក្រោយមក នគរសុខសាន្តត្រាណហើយ ក៏អ្នកស្រុកអ្នកនគរនៅតែខ្លាចព្រឺក្បាលខ្លាក ៗ ទល់សព្វថ្ងៃ ចំពោះសម្រែកសត្វស្លាបទាំងប៉ុន្មានចំពូក ដូចជាតាំងតែពីមានរឿងដូចនិទាននេះឡើង) ។ បន្ទាប់ពីនោះ ខ្មោចក្អួច ប្រាប់ឲ្យមាណពយកដំបង វាត់របស់ទាំងប៉ុន្មានដែលសត្វដៃទៀតជ្រកពួនសម្ងំនៅ ចំរុះប្រមូលយកទៅដុតបោលមួយគក់ ៗ ពួកខ្មោចទាំងអស់នោះ ក៏ត្រូវស្លាប់វិនាសគេខ្លាត់ខ្លាយអស់គ្មានសល់ ៗ ពស់ក៏លាទៅនៅព្រៃតាមប្រក្រតី ។

ចាប់ពីពេលនោះមក នគរនោះក៏ទៅជាសុខស្ងាត់ ៗ ពួកបណ្ដាប្រជាជនទៅជាច្រួលច្របល់ ទិនរិះរកស្ដេចសោយរាជ្យពុំបាន ក៏នាំគ្នាប្រជុំជាពួកជាក្រុម ចូលទៅរកព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតហោរា ឲ្យគិតគូរឿងនោះ ៗ គរបណ្ឌិតព្រាហ្មណ៍ព្រឹទ្ធហោរា ក៏តាំងបើកក្បួនមើលទៅឃើញថា ត្រូវផ្សងដំរីមង្គលរើសរកអ្នកមានបុណ្យ ៗ ពួកក្លាក់ផារមន្ត្រីធំតូច មូវកងសេនា សេនីយ៍ ក៏ចាត់រៀបក្បួនតាមប្រពៃណី ហើយពួកព្រាហ្មណ៍ព្រឹទ្ធសូត្របួងសួងនូវអស់ឥន្ទព្រហ្មទេវតាអារក្សអ្នកតា បិតនៅនាបព្វតាគុហាជ្រោះជ្រលងដងស្ទឹងបឹងបួ ប្រាសាទវិមានគ្រប់ទិសទីថា បើអ្នកឯណាមានរឹទ្ធិបេស្ដាបារមី ឲ្យដំរីទៅនាំយកមកគ្រងក្រុងឥឡូវនេះកុំបីខាន ៗ ផ្សងហើយ មុខមន្ត្រីតាមលំដាប់ បើកបាំងក្លស់ក្លុំទូងគេររាយគ្រឿងនាគពាទ្យគន្ធ័ចេញទៅ ៗ ដំរីមង្គល ក៏ចេញឆ្ពោះសំដៅទៅ

ចូលព្រៃ ដកបដល់ទៅខ្ទមចៅកែលលកនិងនាងពួន ។ តាំងពីនាក់នោះ ឃើញដូច្នោះ ទឹកភ័យណាស់ថា ក្រែងមានអាសន្នធំមួយជាន់មកដល់ទៀត ដឹកដៃគ្នារត់ ប៉ុន្តែខ្មោចតូចមកទាន់ប្រាប់ថា កុំរត់ទៅណា កុំខ្លាច! កុំខ្លាច! គ្មានវណាហ៊ានធ្វើអ្វីទេ ប្រុងប្រៀបរៀបចំចាំចុះ ពេលវេលាដល់ហើយ ។ ក្បួនពិធីនោះ ក៏បានមកដល់, ដំរីមង្គល ក៏លុតជង្គង់នៅមុខចៅកែលលកនឹងនាងពួន, ព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតហោរា នាម៉ឺន អ្នកមុខអ្នកការ សេនីយ៍សេនាហ៍ពល ក៏លើកករប្រណម្យ អញ្ជើញតាមបុរាណពជវេណី សុំជាទីជ្រកកោនក្រោមម្លប់បុណ្យភ្ជសម្ភារបារមី និងដង្ហែចូលកាន់រាជបុរី បានជាទីពឹងពំនឹងតទៅ ។ ចៅកែលលក ធ្វើឡងឡង់ មើលទៅនាងពួនបន្តិច មើលទៅខ្មោចតូចបន្តិច មិនទាន់ហ៊ានជាម៉េចនៅឡើយ លុះតែខ្មោចតូចប្រាប់ថា ចាំអីទៀតពេលដល់ហើយ មិនអីទេ ទទួលយកពាក្យនេះទៅចុះ អស់មានគ្រោះថ្នាក់ហើយ ។ បន្ទាប់នោះ ពួកអញ្ជើញគ្រឿងក៏នាំយកប្រដាប់សម្រាប់ទ្រង់ ដាក់តម្កល់លើពានមាស ព្រមទាំងទឹកអប់ប្រេងម្សៅក្រអេះប្លងចន្ទន៍ ដ៏មានគន្ធពដោរលេងល្វើយមកថ្វាយ ។ ចៅកែលលកនឹងនាងពួន ជម្រះអង្គរូបហើយ ក៏ទ្រង់គ្រឿងកកុធភ័ណ្ឌជាស្ដេចស្រេចកាលណា ទើបបង្គាប់ឲ្យពួកសេនា ដ៏មានខ្មោចតូចជាអ្នកនាំមុខ ទៅជីកគាស់យកទ្រព្យរបស់ពីដំបូក យកមករៀបចំស្រេច ស្ដេចក៏ឡើងគង់ដំរីកែវជាមួយនឹងនាងពួន, ស្ដេចដំរីជា

ឪពុកដើរយោងមុខការសត្រូវ ដង្ហែស្ដេចកែលលកចូលក្រុង ។

និយាយពីចៅព្រាន និងពួកអ្នកដែលមានខ្លួនទាំងប៉ុន្មាន ឈរមើលពិធីហែស្ដេចកែលលកនោះ យ៉ាងស្ងៀមស្ងាត់បាត់មាត់ដូចគេចុក មានចិត្តគិតបារម្ភតែរៀងខ្លួន អ្នកខ្លះធ្វើស្ទឹងស្រឡើកើ ឡើងក្អែកមូលដូចកាក់ ខ្លាចណាស់ ក្រែងស្ដេចយកទោស ព្រោះពីថ្ងៃមុន ពួកខ្លួនបានជ្រុលហ៊ាកញ្ច្រៀវសើចចំអក ចាំផ្ដេសផ្ដាសសន្ធឹកសន្ធាប់ណាស់ ។

លំដាប់នោះ ពិធីរាជាភិសេកដ៏មហោឡារិក ក៏បានប្រព្រឹត្តទៅក្នុងព្រះបរមរាជវាំងចំនួន ៧យប់ ៧ថ្ងៃ, ក្នុងពិធីនោះ គេឃើញខ្មោចតូច លេចមុខមាត់ជាងគេទាំងអស់ ហើយស៊ីផឹកហ៊ឺហាសប្បាយចិត្តណាស់ផង ។ ស្រេចបាច់អស់កិច្ចហើយ ខ្មោចតូចក៏លាទៅយកកំណើតជាមនុស្សទៅ ។

ពីរ-បីថ្ងៃ ក្រោយពិធីរាជាភិសេកមក, ស្ដេចជរាស ដឹងថា ខ្លួននឹងដល់កំណត់អស់អាយុសង្ខារ ទើបហៅកូនទាំងពីរមកផ្ដាំថា ឪពុកនឹងស្រុត (ស្លាប់) បើឪពុកស្រុតទៅហើយនោះ ចូរកូនយកក្បូកម្នាងទៀតនេះទុកថែរក្សា យកប្រអប់ជើងឪពុកធ្វើជាប្រអប់ស្លា ឲ្យសន្មតថា ប្រអប់ជើងជរា យកស្បែកត្រចៀកទុកធ្វើជាចង្អេរុ, ផ្ដាំស្រេចក៏ទៅស្រុតនៅក្បែរចំការស្រូវរបស់ចៅកែលលកនោះទៅ ។ ចៅកែលលកនិងនាងពួន ក៏បានធ្វើតាមបណ្ដាំនោះ ព្រមទាំងរៀបទុកដាក់សពស្ដេចជរានោះយ៉ាងអធិកអធមផង ;

កន្លងបន្តិចមក ស្ដេចកែលលកចាប់រឭកនឹកទៅដល់មាតាបិតា នឹកកាល

គ្រាកំសត់កម្រហូតមកបានជាស្ដេច គិតបង់យកទ្រព្យរបស់មាសប្រាក់ទៅឲ្យគាត់ខ្លះ, ទើបថ្ងៃមួយទ្រង់ត្រាស់បង្គាប់ឲ្យនាងពូនរើបរបស់ទ្រព្យសុទ្ធតែល្អៗ មួយបង្វិចធំ ឲ្យនាយស្មៀនចារឹកអក្សរដាក់បង្កប់ក្នុងបង្វិចនោះថា "សូមម៉ែនិងឪយកទ្រព្យរបស់នេះប្រើប្រាស់ចុះ ខ្ញុំជាកូនដែលម៉ែនិងឪដេញចោលពីថ្ងៃមុននោះផ្ញើមកជូន" ស្រេចហើយក៏ចេញទៅជាមួយនឹងអាមាត្យម្នាក់ក្នុងពេលដ៏ស្ងាត់កាត់តម្រង់ទៅ លុះបានទៅដល់ខ្ទមឪពុកម្ដាយហើយរង់ចាំដល់ពេលពក្រស្ងាត់ ក៏ឲ្យអាមាត្យលបយកចូលទៅហែកជញ្ជាំងទុកត្រង់ក្បាលដំណេក រួចត្រឡប់មកវាំងយប់នោះវិញ ។

តមក ក៏បាននៅសោយរាជសម្បត្តិ ជាសុខសាន្ត ជាមួយនឹងនាងពូន បានបញ្ញត្តនាមរបស់ខ្លួន ឲ្យមនុស្សម្នាមហាជន ដឹងឮទៅថា "ព្រះចៅកែលលក" បញ្ញត្តចំការស្រូវដែលធ្លាប់ផ្ញើមកនោះ ឲ្យហៅថា "ចំការចៅកែលលក" ទាំងស្មៅដែលមានដុះក្នុងចំការនោះ ឈ្មោះថា "ស្មៅកែលលក" ។ ឯពួកអាណាប្រជាជនក្នុងនគរ ក៏បានប្រកបដោយសេចក្ដីសុខសាន្តសម្បូណ៌សប្បាយតទៅហោង ។

| | |
|---|---|
| អាយុមិនអស់ | គង់តែមិនស្លាប់ |
| គូព្រេងគួរគាប់ | គង់តែបានជួប ។ |

(អត្ថបទពុំទាន់មានពីរ)

ហត្ថលេខា : ព្រួប-ភុម

# រឿងសាមកុក

ចាកញាំវិបុលភជសេនា

ង្វ-កាង

ប្រែ-រៀបរៀង

( ៣ )

| |
|---|
| រៀងសាមកុកទុកជាយុទ្ធសាស្ត្រ   អ្នកណាវៃឆ្លាស់បើបានអាន |
| នឹងចេះទាយកលចំណាន   ទាំងមានសន្តានស្នេហាជាតិ |
| យូរ-អុិន |

បញ្ឆោតយើងទេ   មុខជាគេមានយកទាហានទៅឲ្យពួនបង្កប់ទុកក្នុងព្រៃកក្តំ ជាប្រាកដ  អ្នកកុំចេញទៅច្បាំងឡើយ   ទាហានទាំងពួងឮឡុកស៊ុនថា ហើយ  ក៏នាំគ្នាសើច ហើយទាំងអស់គ្នានិយាយថា  ឡុកស៊ុននេះខ្វះប្រាជ្ញា ស្មារតីពេកណាស់   ចេះតែភ័យខ្លាចសឹកសត្រូវមិនសូវហ៊ានទំលុះទំលាយ ការអ៊ូសោះ ៗ

ឯងីប៉ាន់នាយទ័ពមុខ   លុះព្រឹកឡើងក៏ដេញទាហានចូលទៅស្រែក ឡកចំអកជេរនៅមាត់ទ្វារបន្ទាយ   នោះឈើសេង, គេងហាងនាយកងទ័ព បានឮ   ក៏យកសេចក្តីទៅប្រាប់ឡុកស៊ុនថានឹងសុំចេញច្បាំង   ឡុកស៊ុន ក៏ថា   អស់អ្នកទាំងអម្បាលនេះមិនចេះដឹងអ្វីសោះ   ពោះទឹងគិតធ្វើការអ្វី សុទ្ធតែកាច់បំបាក់យកតាមកំឡាំង   មិនរាំងគិតតាមគំនិតប្រាជ្ញាប្រើកល

ក្រាស់ក្រួនទឹងចេញខ្ទួនទៅ រងទទួលពីមុខជួបផ្ទុំក្លើងពីក្រោមខ្យល់ទឹងបានបុក្ក វេលានេះនៀយហាក់ណាស់ហើយបានជាថយទៅ ឯអស់ពលទាហានក៏មានចិត្តភ្ញើតភ្ញើនមិនសូវគិត ព្រោះដូតថាមកគ្រាណាៗក៏មិនតច្បាំងគ្នា គង់ទឹងពរេកបែកចិត្តគិតទៅជ្រៀតជ្រកដេកលេងឲ្យសប្បាយខ្ចាត់ខ្ចាយបែកចេញពីគ្នា យើងត្រូវចាំមើលកលការគ្រាតែបានចំណាប់ទឹងលើកទ័ពចេញទៅកំហុកក៏យគង់ទឹងបែកញាយមិនខាន ។

ពេលនោះអស់ នាយទ័ពនាយកងទាំងពួងបានស្តាប់ក៏យល់ឃើញត្រូវណាស់ តាំងពីនោះមកក៏ឲ្យក្រែងខ្ចាបប្រាជ្ញាឡុកស៊ុនៗក៏ចាត់ចែងចែងទាហានត្រៀមទុក ហើយធ្វើសំបុត្រមកបង្គំតាមផ្លូវពជការ ឲ្យបំរើកាន់ជារេហស៍នាំចូលទៅថ្វាយព្រះចៅឡុកគួនសេចក្តីថា ឃើញកំឡាំងព្រះចៅឡៅពីទន់ចុះហើយ ឥឡូវលើកទ័ពថយត្រឡប់ទៅតាំងក្រោមម្លប់ឈើទឹងក្បែរមាត់ទឹក ក្នុងវេង ១៥ ថ្ងៃទៀត ទូលព្រះបង្គំជាខ្ញុំទឹងសំពាយឲ្យបែក ព្រះចៅស៊ុនគួនឃើញសេចក្តីសំបុត្រដូច្នោះក៏ព្រះអំណរណាស់ទើបកេណ្ឌទាហានថែមទៅបំពេញឲ្យឡុកស៊ុនទៀត ។

វេលានោះ ព្រះចៅឡៅពីក៏ត្រាស់បង្គាប់នាយទ័ពជើងទឹក ឲ្យតាំងបន្ទាយទឹកល្អមបាំងទូកបាន ហើយកាយចុះទៅក្នុងដែនស្រុកកាំងតាំងហងគួនទូលថា ដែលទឹងឲ្យទ័ពទឹកលើកចូលទៅនោះឃើញមិនងាយសោះ

ព្រោះខឹងគេឲ្យប៉ះមកវិញពីប៉ាកណាប់ ដោយប្រាសទឹកកំពុងឡើង ទូលព្រះបង្គំជាខ្ញុំ នឹងសុំទៅតាំងជាមាយទ័ពមុខទឹកបានជួបទ័ពទឹកដោយឆាយ ព្រះអង្គជាទ័ពក្រោយ ហើយមុខជាមិនខានបទាត់ដោយសឹកសត្រូវនោះ ព្រះចៅឡៅពីត្រាស់ថា វេលានេះពួកស្រុកកាំងតាំងគេបក្បាលខ្ទាប់យើងអស់ហើយ កាលណាឡើយពាខឹងហ៊ានលៀនមុខមកបង្ក្រាំង កុំសង្ស័យយើងត្រូវតែស្រួតចូលទៅប៉ះ ខណៈនោះអស់នាម៉ឺនប្រឹក្សាក៏បានទាំងខាទូលភាស់ព្រះអង្គស្រ័យមិនឲ្យលើកទៅ ព្រះចៅឡៅពីក៏ពុំព្រមស្តាប់ ទើបចាត់កងទ័ពជា ២ វែក ១ វែកឲ្យហង់គួនជានាយកងលើកចូលទៅតាំងខាងទិសឯជើងខ្ទាបចូតីលើកមកវាយប្រសព្វខ្លួន ព្រះចៅឡៅពីក៏តាំងបន្ទាយភាយនៅតាមក្បែរមាត់ទន្លេ ជិតគ្នាទឹងទ័ពទឹក ។

ពាហានល្បាក៏នាំសេចក្តីចូលទៅក្រាបទូលព្រះចៅចូក៏ថា ព្រះចៅឡៅពីលើកទ័ពទៅវាយស្រុកកាំងតាំង តាំងបន្ទាយភាយទៅតាមក្បែរមាត់ទឹកចំនួន ៤០ បន្ទាយចម្ងាយ ១.០០០ សិន ហើយឲ្យហង់គួនយុំពាហានលើកទៅតាំងខាងទិសឧត្តរផ្លូវទឹងមកស្រុកយើង ព្រះចៅស៊ុនគួននោះតាំងឲ្យកស៊ិនជាមេទ័ពធំលើកទៅច្បាំងនឹងព្រះចៅឡៅពី ។ ព្រះចៅចូក៏បានឮដូច្នោះក៏ទ្រង់អស់សំណើចហើយថា ព្រះចៅឡៅពីគ្រានេះនឹងចាញ់ស៊ុនគួន អស់ពួកនាម៉ឺនខ្ញុំរាជការទាំងទីប្រឹក្សាទាំងពួងឮហើយក៏ទូលសួរថា

ព្រះអង្គទ្រង់ឃើញយ៉ាងម្តេច ចូក៏ថា ព្រះចៅឡៅពីមិនចូលចិត្តគិតការទ័ព បានជាតាំងបន្ទាយវែងជាប់ដល់ ៦.០០០ សិន ប្រសិនបើសត្រូវត្រូវចូលច្បាំងខាងដើមឬខាងចុងនឹងជួបគ្នាបានឬ មុខជានឹងខូចការរបស់ស៊ិនគួនជាប្រាកដ យើងចាំមើលចុះ អស់នាម៉ឺនទាំងទីប្រឹក្សាទាំងនោះនៅមិនទាន់ជឿ តែម្តងក៏ទូលសួរថា ទូលព្រះបង្គំជាខ្ញុំនឹងសុំរៀបចំកងទ័ពទុកឲ្យព្រមជាមុន ។

ព្រះចៅចូក៏ត្រាស់ថា ៖ ឡុកស៊ុនវាយទ័ពព្រះចៅឡៅពីបែកហើយ មុខជានឹងលើកដេញដិតប្រកិតតាមទៅដល់ស្រុកសែឈួន ខាងស្រុកកាំងតាំងមនុស្សក៏នឹងស្តួចស្តើងតិចទៅ ត្រូវយើងលើកទៅវាយយកស្រុកកាំងតាំង ធ្វើអាការបើដូចនឹងលើកទៅជួយឲ្យគេជឿទុកចិត្ត វេលានេះយើងត្រូវត្រៀមទាហានទុកឲ្យស្រេចនឹងលើកទៅជា ៣ ផ្លូវ ទើបចាត់ចោយិនជានាយកងឃុំទាហានលើកទៅផ្លូវយូស៊ូ ឲ្យចោហ៊ុវឃុំទាហានលើកទៅផ្លូវតុងខៅ ឲ្យចោជិនឃុំទាហានលើកទៅផ្លូវណាំកុន ទាំង ៣ ទ័ពនេះត្រូវតាំងបង្កប់នៅក្នុងដែនយើងសិន យើងនឹងចាំស្តាប់ដំណឹងល្បាត បើកាលណាបានឱកាសហើយសឹមលើកទៅឲ្យព្រមគ្នា ខ្លួនយើងត្រូវនៅជាទ័ពជំនួយ មុខជានឹងវាយបានស្រុកកាំងតាំងដោយងាយ ទីប្រឹក្សានឹងបណ្តានាម៉ឺនទាំងពួងក៏យល់ឃើញត្រូវ ទាំងអស់គ្នា

កំលាថយចេញទៅចាត់ចែងចែងរំលែកកងទ័ព  តាមគ្រាស់បង្គាប់គ្រប់ប្រការ ។

ឯម៉ាលៀងដែលគួរផែនទីទៅឲ្យខុងបេងមើលនោះ លុះទៅដល់ស្រុកតាំងឈួន  ក៏ចូលទៅរកខុងបេង  ហើយយកផែនទីដែលតាំងបន្ទាយនោះឲ្យខុងបេងមើល  ខុងបេងនោះលុះឃើញរបៀបផែនទីដូច្នោះហើយក៏ឲ្យស្ទុតរន្ធត់ស្មារតី  លើកដៃទះភ្លៅហើយថា  កម្មអើយកម្ម  មុខជាចាញ់ឡុកស៊ុនជាប្រាកដហើយ  នរណាជាជាងគិតឲ្យព្រះចៅឡៅពីធ្វើបន្ទាយដូច្នេះឲ្យយកខ្លួនមកសម្លាប់ចេញ ។ ម៉ាលៀងថា គ្មាននរណាជំងដែងគិតតាមគំនិតរបស់ខ្លួនបានទេ  គឺរបៀបទាំងអស់នេះជាគម្រិះរបស់ព្រះចៅឡៅពីទ្រង់ព្រះចិន្តាឯង  ដែលលោកថាទឹងខូចផុសការដោយថ្វីដៃឡុកស៊ុននោះ  លោកយល់ឃើញប្រការម្តេច  ខុងបេងថា  ព្រោះតាំងបន្ទាយ៤០អាទ្រី  ហើយវែងដល់១.០០៤សិននោះ  បើសត្រូវចូលច្បាំងប្តុំភ្លើងឆេះឡើងក្តី  ទឹងរត់ទៅមកជួយគ្នាកាលណាទឹងទាន់ការ  ត្រូវតែរៀបបន្ទាយបញ្ចូលគ្នាជាប់ឲ្យល្មមទឹងជួយការក័យគ្នាបាន  ម៉ាលៀងថាខ្ញុំបាទទឹងវិលត្រឡប់ទៅវិញមុខជាមិនទាន់ការ  ព្រះចៅឡៅពីមុខជាបែកទ័ពជាមុនហើយ ។ ទ័ពសត្រូវពទឹងមិនដេញមកដល់ស្រុកសៃឈួនទេឬ ។

ខុងបេងថា  ទោះបីព្រះចៅឡៅពីបែកហើយក្តី  ឡុកស៊ុនពុំមិន

ដែនដេញតាមមកទេ ព្រោះវានៅគិតរិះរកកំពង់ក្រោយ ក្រែងពួកគីទឹង ចូលវាយយកស្រុកកាំងតាំង ខាងព្រះចៅឡៅពីនោះ ទោះបែកហើយ គង់នឹងទៅសំណាក់អាស្រ័យនៅស្រុកបុកតេ ឯស្រុកបុកតេនោះ បើយើងនៅមិនទាន់ចូលមកស្រុកសៃឈួនទេ យើងគង់បានចាត់ចែងទា-ហានទុកដល់១០ម៉ឺន តាំងទុកនៅទីដំបន់អ៊ីប៉ាក់ប៉ៅ មាត់ផ្លូវនឹងចូលទៅស្រុកបុកតេនោះ ១ កង ។

ម៉ាលៀងថា ខ្ញុំបាទក៏បានដើរមកតាមផ្លូវអ៊ីប៉ាក់ប៉ៅ លោកថាមានទាហាននៅទីនោះ ១ កង ហេតុម្តេចក៏ខ្ញុំបាទមិនបានជួបប្រទះឃើញសោះ ខុងបេងថា អ្នកកុំអាលនិយាយឡើយ បើកាលណាអ្នកវិលទៅវិញហើយ គង់នឹងឃើញសេចក្តីដែលយើងគិតទុកនោះជាក់នឹងភ្នែកប្រា-កដ ម៉ាលៀងបានឮដូច្នោះក៏សុំសំបុត្រខុងបេងឡើងសេះត្រឡប់ទៅវិញ ខុងបេងក៏ចូលទៅក្នុងស្រុកសៃឈួន រៀបចំរុងទាហានទុកឲ្យព្រម ។

ឯឡុកស៊ុននោះ លុះដឹងថាព្រះចៅឡៅពីតាំងបន្ទាយកាយតាមក្បែរមាត់ទន្លេ៤០អន្លើវែងដល់១.០០០សិន ហើយឃើញទាហានទាំងអស់សុទ្ធតែក្តីក្តៅមិនអើពើនឹងរក្សាខ្លួនដូច្នោះក៏មានអំណរណាស់ ទើបឲ្យប្រមូលនាយទ័ពនាយកងទៅប្រជុំព្រមគ្នាហើយបង្គាប់ថា វេលានេះជាឱកាសស្រួលរបស់យើងហើយ យើងនឹងឲ្យលើកទ័ពទៅកណ្តាលយប់

ពាយយកបន្ទាយដែលតាំងនៅទីកាំងណាំឲ្យបាន នរណាមានចិត្តនឹងសុំអាសាចូលទៅពាយខ្លះ ហាន់គុងទិងជាវថាយ, ឡេងថងទទួលថា យើងខ្ញុំនឹងសុំអាសាទៅពាយយកបន្ទាយឲ្យបាន ឡុកស៊ុនថា អ្នកទាំង៣នាក់កុំទៅចុះ ទើបឡុកស៊ុនហៅទាហានម្នាក់ឈ្មោះទុនអ៊ីគាន់ ឲ្យលើកទាហាន៥ពាន់ទៅពាយបន្ទាយប៉ៅទៀវឲ្យបានក្នុងពេលយប់នេះ យើងនឹងលើកទ័ពជំនួយទៅតាម ទុនអ៊ីគាន់ក៏លើកទាហានទៅតាមបង្គាប់ ឡុកស៊ុនក៏ប្រាប់ឲ្យឈើសេង, គេងហងនាយកង២នាក់នេះ ឲ្យយុំទាហានម្នាក់ៗ ១០០ទៅពួនបង្កប់នៅមាត់ផ្លូវ បើឃើញទុនអ៊ីគាន់ចូលទៅច្បាំងចាញ់សត្រូវដេញមកឲ្យចេញជួយស្កាត់ បើសត្រូវបកខ្ចាត់ខ្ចាយទៅហើយកុំឲ្យដេញតាមឈើសេង, គេងហងក៏លើកទ័ពចេញទៅធ្វើតាមបង្គាប់ ។

លុះពេលយប់ស្ងាត់ ទុនអ៊ីគាន់ក៏យុំទាហានស្រែកហោចូលពាយបន្ទាយប៉ៅទៀវ ១ ឃើញផ្លូវចោះក៏ឡើងសេះ គាន់លំពែងដេញទាហានចេញតតាំងច្បាំងគ្នា ទុនអ៊ីគាន់តស៊ូមិនបាន ខ្លួនក៏ត្រូវព្រួញទៀតក៏បរសេះរត់ទៅ ទៀវយ៉ាំងនឹងសះម៉ោខាតាំងបន្ទាយនៅក្រោយភ្នំ លុះឃើញទាហានស្រែកកាំងតាំង ស្រែកកោកឹកកងចូលពាយបន្ទាយប៉ៅទៀវផ្លូវចោះ ក៏លើកទាហានចេញស្កាត់តច្បាំង ទុនអ៊ីគាន់ក៏រលះរលាំងរត់ទៅ នោះទៀវយ៉ាំងនិងសះម៉ោខា, ប៉ៅទៀវក៏លើកទ័ពដេញតាមទុនអ៊ី

តាន់ទៅទៀត ឯឈីសេង, តេងហានដែលពួនបង្កប់ក្បែរផ្លូវ ក៏លើកចេញប្រសព្វខ្ទប់ទាំងសងខាង ទ័ពព្រះចៅឡេវពីក៏បែកតែចូលបន្ទាយវិញ ឈីសេង, តេងហាន ក៏នាំគ្នាត្រឡប់ចូលបន្ទាយ ទុនអ៊ីតាន់ត្រូវព្រួញជាប់នៅខ្លួន ក៏ចូលទៅដល់ឡុកស៊ុនហើយយំសុំទោសដែលបែកទ័ពតែមកនោះ ។

ឡុកស៊ុនថា យើងមិនយកទោសទេ ដែលប្រើទៅធ្វើការគ្រានេះ គឺប្រាថ្នាចង់ដឹងកម្លាំងនឹងកលសឹកព្រះចៅឡេវពី ក៏បានឃើញអស់ហើយ អ្នកកុំវិតក្កឡើយ យើងនឹងគិតកយឲ្យបែកទាល់តែបាន ។ ឈីសេង, តេងហានថា យើងខ្ញុំបានដឹងច្បាស់ជាព្រះចៅឡេវពីមានទាហានខ្លាំងពូកែច្រើនណាស់ នឹងប្រាថ្នាកយឲ្យបែកនោះឃើញថាមិនងាយ ក្រែងខូចខាតទាហានច្រើន ។

ឡុកស៊ុនឮហើយក៏អស់សំណើចហើយថា ប្រវេណីធ្វើសង្គ្រាមមែងមានស្លាប់សៅជាធម្មតា តែអ្នកមានតម្រិះប្រាជ្ញាចេះគិតឲ្យខូចតិច បានច្រើន ប្រការខ្ញុំបេងជាចៅបញ្ញាក៏មិនបានមកធ្វើការផងទេ យើងនឹងខ្លាចអ្វី វេលានេះគឺទេវតាឲ្យចំនេងយើងមានចន្លោះនឹងយកជ័យជំនះជាទីរុងរឿង នៃព្រះចេស្តាព្រះចៅស៊ុនគួនហើយ ។ ក៏ឲ្យប្រមូលនាយទ័ពនាយកងមកប្រជុំគ្នា ទើបឡុកស៊ុនចាត់ឲ្យជូហៀនជានាយកងខាងទ័ពទឹក មានទូកផ្ទុកចម្បើងជាយ៉ាងច្រើន ឯខាងទ័ពគោកចាត់ហាន់តុងឲ្យ

បើកទាហានៈ ពួកទៅចាំវាយទ័ពផ្លូវទិសឧត្តរ ចាត់ដំរីថាយឲ្យលើកទាហាន ពួកទៅចាំវាយទ័ពផ្លូវទិសទក្សិណ ឲ្យទាហានមានបាយក្រៀមជាអាហារបង្ការ ដែលក្លៀនចងគប់ចម្បើង ហើយរៀបរសេះដាក់កន្ទៃស្ពាយបន្ទាយឈ្នើខកាន់គ្រប់ខ្នងចេញទៅ ដល់ថ្ងៃស្អែកពេលយប់មានខ្យល់ដំនោះធ្លាក់ ឲ្យទាហានទ័ពគោកទ័ពទឹកព្រមគ្នាវាយចូលទៅឲ្យដល់បន្ទាយទាំង៤០អន្ទើ ហើយឲ្យបើកភ្លើងដុតឲ្យឆេះឡើងគ្រប់បន្ទាយ បើទ័ពនោះបែកវេលាណាឲ្យអស់ពលគ្នា តាមដេញចាប់ព្រះចៅឡៅពីឲ្យបានទាហានគ្រប់ក្រុមក៏ឆ្ពុះគ្នារៀបចំធ្វើតាមបង្គាប់ ។

ឯព្រះចៅឡៅពីគង់លើកៅអីស្ដិពជការចាត់ទាហានទីងលើកទ័ពចេញច្បាំងមិនទាន់ស្រេចការ បង្កើតអស្ចារ្យអាកេទទង់ជ័យដែលដោតរឹងនៅមុខព្រះទីនាំងគ្មានខ្យល់បក់ជាខ្លាំងសោះ ដងទង់ជ័យនោះក៏បាក់ធ្លាក់ចុះដល់ដីព្រះចៅឡៅពីព្រួយព្រះទ័យណាស់ ត្រាស់សួរធៀតឺទីប្រឹក្សាថា អាកេទនេះកាចឬជាប្រការម្ដេច ធៀតឺក្រាបទូលថា អាកេទនេះកាចណាស់ មុខជាឡ៊ុកស៊ុនទីងលើងទ័ពមកវាយយកជ័យជំនះយើងហើយ ព្រះចៅឡៅពីថាច្បាំងគ្រាណាយើងក៏វាយបែកគ្រប់គ្រាពុំដែលខាន ទាហានពួកវាស្លាប់ច្រើនណាស់ហើយ យើងទីងខ្លាចថ្វីមិនមែនវាទីងលើកមកវាយយើងទេនិយាយមិនទាន់ផុតមាត់ មានទាហានពួកបន្ទាយខាងលើចូលមកទូលថា

(នៅមានត)

# ឯកសារក្រាំង និង សាស្ត្រាស្លឹករឹត

ដែលមាននៅពុទ្ធសាសនបណ្ឌិត្យ

លោក ញ៉ុក-ថែម រៀបរៀង

(៩)

ចំណងជើង: “សាស្ត្រា ក្រមច្បាប់”

អ្នកនិពន្ធ: រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ: គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ: ពាក្យកាព្យ : បទកាកគតិ ។

ប្រភេទរឿង: គ្រូទូន្មានសិស្ស តាមប្រពៃណី ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១០ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពី វត្តវេឡុការាម ចុះលេខឯកសារ ១៣៧៦ ។

អត្ថបទផ្ដើម: ៙ អញខ្ញុំនូនអង្គ ទន្ទាបក្រញូក្រុង ក្រញូ

ក្រាបអាត្មា លុតលើកករកប ប្រៀបប្រុប

ហត្ថា ដោយដាក់សិរសា ក្រាបថ្វាយបង្គំ ។

សម្តេចព្រះស្រី មុនីធិបត្រី សព្វញ្ញូជាធំ ត្រៃ

គ្រប់ទេព សុរេន្ទព្រហ្ម ស្តែងស្តេចតែងបំ-

បាក់បបសប្បាយ ។ . . . . . . . .

. . . . . . . . . . . . . ។ល។

អត្ថបទបញ្ចប់:

មួយសោតឲ្យខំ រករៀនអាគម មន្តព្រះគាថា
នូវថ្នាំឱសថ ឆាប់ដុតនោះណា គ្រាន់នឹងរក្សា
សន្តានចៅផង ។ ខិតខំសង្វាត ឲ្យចេះក្បួន
ខ្នាត ទៀងទាត់ជាមួន ចេះមើលគ្រោះយាម
ទាយតាមទំនង ឫក្សពារពេលផង ការគបវង្សី
ឲ្យរៀនឲ្យសព្វ ឲ្យស្ងួតស្ងៀមស្ងប់ សង្រួម
ឥន្ទ្រិយ៍ ឲ្យសមគួរគាប់ តាមច្បាប់អំពី បុ-
ពណាមុនី តែងទុកឲ្យស្រាប់ ។ ពាក្យពិត
វិសាល វិសេសត្រកាល គ្រប់ជាច្បាប់
ឲ្យអស់សិស្សផង រៀនវែងត្រង់គ្រាប់ បរិបូណ៌
ស្រេចស្រាប់ អម្បាលនេះហោង ។

X

X X

ចំណងជើង: „សាស្ត្រច្បាប់ត្រូវធម៌"(១)

អ្នកនិពន្ធ: រកពុំទាន់ឃើញ

កាលបរិច្ឆេទ: គ្មានបញ្ជាក់ក្នុងក្បួន ។

របៀបនិពន្ធ: ពាក្យកាព្យ: បទកាកគតិ

ប្រភពរឿង : អាពុកទូន្មានកូន តាមប្រពៃណីពីព្រេងនាយ ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹតៈ ត្រៃមានសន្លឹក ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តវល្លិកាពម ផែរ លេខ ១.៣៧៦ ។

អត្ថបទដើម: ឱនេះបទកាកគតិ ។ កូនអើយមកអាយ ឪពុក
និងម្ដាយ ប្រាប់ច្បាប់គ្រូធម៌(?) កូនស្ដាប់ឪពុក
រៀនទុកឲ្យចាំ(?) មន្ទិលគ្រូធំ ច្បាប់នេះមិន
ឆ្ងាយ ។

---

(១) ច្បាប់នេះ តាំងពីចំណងជើងជាដើមទៅ មិនដឹងជាកវីចង់ពោលថា "ច្បាប់ត្រូវធម៌ឬ ច្បាប់គ្រូធម៌ ឬច្បាប់គ្រូធំ"? ប្រសិនបើគេពិនិត្យមើល ពាក្យពេចន៍ ក្នុងផ្ទៃអត្ថបទ គេអាច យល់ថា "ច្បាប់គ្រូធំ" ឬច្បាប់មន្ទិលគ្រូធំ "ឬច្បាប់បណ្ឌិតគ្រូធំ"?, ផ្ទុយពាក្យបញ្ជាក់ ក្នុងក្បួនមិន ខាងលើនេះស្រាប់ ។ ឯចំណងជើងខាងលើនេះ សូមអ្នកអានសំគាល់ទុក ជាបណ្ដោះអាសន្នសិន ។ ប្រសិនបើមានច្បាប់ផ្សេងទៀតយកមកផ្ទៀងផ្ទាត់ទៀងផង ប្រហែលរកឃើញនូវចំណងជើងដ៏ពិតប្រាកដបាន ។ សាស្ត្រានេះមានពាក្យច្រើនអន្លើណាស់ ទាំងពាក្យពេចន៍ទាំងចុងក្លួន ។

កូនអើយលោកថា មានទ្រព្យក្តីណា មិនដូច
មានបាយ ទោះមានដីពុក មិនដូចមានម្តាយ
មានញាតិកាំងឡាយ មិនដូចគ្រូគ្រង ។ល។

អត្ថបទបញ្ចប់:

ច្បាប់នេះប្រពៃ ត្រូវធម៌ថ្លាថ្លៃ អាចារ្យដំណាល
ដំណើរពីព្រេង នេះឯងត្រកាល ទោះ
ចាស់ក្មេងពាល ឲ្យរៀនឲ្យស្ទាត់ ។ ឲ្យចេះ
ឲ្យចាំ មន្ទិលគ្រូធម៌ ប្រសើរជាក្តាត់ ទោះកើត
ក្តីហោង រៀនឲ្យចាំមាត់ មិនដែលភ្លាំងភ្លាត់
កាត់ក្តីបានហោង ។ ពាក្យនេះស្រួលស្រេច
ពាក្យច្រើនកន្ទេច កន្ទៀតកន្ទង់ ចំណុះចំណាប់
ប្រចាំប្រចង់ ទ្រគោះទ្រគង់ ទំនង់ដោះស្រាយ ។
ត្រូវធម៌ថ្លៃថ្លា ពកង់កនពៃត្រ(?) ព្រឹទ្ធព្រេងនិយាយ
ក្រណាស់មិនងាយ ក្រណាស់មិនងាយ(?)
ចំណាំបរិយាយ ច្បាប់នេះមិនងាយ ពីព្រេង
បូរាណ ។

X

X X

ចំណងជើង : "សាស្ត្រា សុខ មាណព "(១)

អ្នកនិពន្ធ : អ្នកឧកញ៉ា ធម្មាធិបតី ចន្ទ ។

កាលបរិច្ឆេទ : រជ្ជកាលព្រះបាទអង្គដួង (ក្រុងឧដុង្គ) ។

របៀបនិពន្ធ : ពាក្យកាព្យ : បទកាកគតិ និងព្រហ្មគីតិ ។

ប្រភពរឿង : ជាតក ១ ប៉ុន្តែគ្មានបញ្ជាក់ពីការសជាតិទេ ឯផ្ទៃរឿង ដំណាលពីសកម្មភាព នៃពោធិសត្វកសាងបារមី ដូចជាជាតកនានាដែរ ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែមាន ១០ សន្លឹក ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកអំពីវត្ត វៀឡុកាពមដែរ ចុះលេខ ១.៣៧៦ ។

អត្ថបទដើម :

៙ នេះបទកាកគតិ ។ តេជតេជៈខ្ញុំ សូម

សរសើរសេ- ម្តេចកគក់ សូមទេពទិសទេស

សោឡសសួគ៌ា ចរើនទីយា យុយីនឡ្ញើ ។

កាលពជ្រក្សត្រា ព្រះនាពយណ៌ពមា ធិពជ

---

(១) សាស្ត្រាសុខមាណព នេះប្រហែលនៅមាន អត្ថបទតទៅទៀត ឯច្បាប់នេះ អស់អត្ថបទត្រឹមប៉ុណ្ណេះ ឃើញថាមិនទាន់ចប់រឿងទេ ហើយមិនស្របតាមគោលការណ៍ នៃបលនាជាតកទាំងឡាយ ដែលគេតែងតែបញ្ចប់រឿងដោយការសជាតិ ។

ធិបតី សុរិយោពារពង្ស ឯកអគ្គចក្រី ចក្កវត្តិ

សិរី សុរិយោវង្ស ។ . . ។ល។ . .

អត្ថបទបញ្ចប់

មាណពព្ពាក្យ ជាន៍ស្រដីហាក់ មានចិត្ត

សង្ស័យ គិតក្រែងពុំមាន ធនធានដល់ដៃ

ទើបឆ្លើយថាហៃ អ្នកជាន៍ទាំងឡាយ ចាំខ្ញុំ

ទៅយក មាសនាំវិលមក ឲ្យអ្នកចែកចាយ

អស់អ្នកដែលធ្វើ កាប់ឈើនៅឆាយ កុំអ្នក

ទាំងឡាយ បារម្ភឡើយណា ។ ទើបជាន៍

ខ្មាសឆ្លើយ ថាហៃអ្នកអើយ. . . .

. (បាត់) យកមកឲ្យខ្ញុំ ពោះអ្នកឯណា

គ្រាប់បរកតម្រាប់ កុំបីឲ្យឆ្ងាយ តំណទៅ

ឯក្រោយ ជាសូរេចម៉្ហះហាន៍ ។

X X

បំណាងពើង: « ក្រាំងស្តុតិព្រះជាម្ចាស់ »(១) (ព្រះអាទិទេព)

---

(១) ក្រៅពីពាក្យស្តុតិព្រះព្រហ្ម មានពាក្យស្តុប្រស្តុតិ ព្រះអាទិទេពដទៃទៀត ប្រចាំទិស ផ្សេងៗ ។ មានពាក្យស្តុតិធំ សំរាប់ទិសបស្ចឹម ថ្វាយព្រះឥសូរ ។ មានបទខមស្មារព្រះរត្នត្រៃ ព្រមទាំងព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះពិស្ណុការ ព្រះចតុលោកបាល. . . . មានបទខមស្មារ ព្រះស្រីអារ្យមេត្រី ។ មានបទថ្វាយជ័យ សូមជ័យពីព្រះអាទិទេព នៅខាងចុងនៃក្រាំងនេះ

អត្ថបទទាំងប៉ុន្មាន ក្នុងក្រាំងស្តុតិនេះ មានវិបត្តិទាំងអក្ខរាវិរុទ្ធ ទាំងឃ្លាល្បះទាំងពាក្យ ពេចន៍ខ្វះ អ្នកអានមិនអាចយល់ន័យ បានច្បាស់លាស់ទេ ។

អ្នកនិពន្ធ : គេពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកម្រងកែវ ។

ប្រភពរឿង : គម្ពីរត្រៃវេទ របស់ពួកព្រាហ្មណ៍ ។

លក្ខណៈឯកសារ : ក្រាំងសរសេរដោយទឹកខ្មៅ ។ ក្រាំងនេះមាន ៣៩ សន្លឹក ។ ឯកសារនេះគេទុកក្នុងបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ ចុះលេខ ១.៤៤២ ។

អត្ថបទផ្ដើម : ៙ ទិសបូពិ ៗ ពាក្យស្ដុតិព្រះព្រហ្ម ។ នមស្សការ ជ័យពាលប្រាបកាល ជ័យរមិលយល់ទេព្តាផងកុំបីប្រែ ជ័យៗដរែខ ជ័យៗដំផ្ទាំ ជ័យៗកាំផ្ជារ ខែល សារពើជ័យៗចោរ៉ែង ចោរ៉ៃ ជ័យៗប្រថពីផ្ទៃក្រោម ជ័យៗរូបធោមដូចទេព្តា ជ័យៗសេនាទូរអស់បរិពារ ជ័យៗទូរអស់សង្ហារយុទ្ធ ជ័យៗវេសិទ្ធិឈ្នះចម្បាំង ជ័យៗកំឡាំងដូចពេជ្រ ជ័យៗតាបសគរូ ជ័យៗខែលមូលទូផត រង្គល . . . . . . . . ។ល។ .

អត្ថបទបញ្ចប់ : អមត្យរ៉ះតាះមរណ៍ ឈ្នះព្រាបរាបខ្ទាយខ្ទរ ឈ្នះអស់ពលវៀរ អស់តាំងនគរផលដី ឈ្នះ អស់អាកាសធរណី ឈ្នះអស់ពៃរី សូមថេរស-ម្រិទ្ធីបេស្កា សូមបានសោយរាជ្យមហិមា គ្រងរាស្ត្រប្រជា ទីឃាយុះដល់កាលហោង ។ សូមបានសេពសុខបរិតោរ មានបុណ្យសម្ភារ អធិកពន្លឹកមហិមា សូមល្បីតាំងអស់ទិសទី ជាឯករាជាធិរាជ ស៊ស្សូរតានី តោះសត្រូវទឹងមកពាធា សូមឲ្យឈ្នះ ប្រាកដវិនាសស្តែងហោង ។

X

X X

បំណងដើង : « ក្រាំងតម្រាឡើងស័ក ធ្វើសូរ្យាគ្រ . . . »

អ្នកនិពន្ធ : រកពុំបានឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យរាយ ។

ប្រភេទរឿង : តម្រាឡើងស័កតាមក្បួនហោរាសាស្ត្រពីបុរាណ ។

លក្ខណៈឯកសារ : ក្រាំងសរសេរដោយទឹកខ្មៅ ។ ចំនួនសន្លឹក៤៨

សទ្ទឹក ៗ ឯកសារនេះ បានមកអំពីណា គ្មាន
បញ្ជាក់ ៗ ពុទ្ធសាសនបណ្ឌិត្យបានចុះលេខ
១ ២៤៣ ៗ

អត្ថបទដើម :

៥ សង្ខ្យា : គោះនូវគុរគុណឡើងស័កឯណា ៗ គឺ ឲ្យតាំងចុល្លសករាជឆ្នាំនោះចេញ ហើយ យក ២៩.២៦៣៧ គុណ ហើយយក ៣៧៣ បូក ហើយយក ៨០០ ហារ លទ្ធនោះ យក ១ បូកឡើង ជាអហគុណឡើងស័កត្រាទុកសេស នោះ លុបចុះដើងហារ ជាក្រមុតពលឡើងស័ក ត្រាទុកក្រោមអហគុណ ៗ តាំងអហគុណ ចេញហើយ ឲ្យយក ១.៦១១ បូកហើយយក ៣.២៣២ ហារ សេសនោះជាឧចពលឡើងស័ក ត្រាទុកក្រោមក្រមុតពល ៗ. . . ៗលៗ.

អត្ថបទបញ្ចប់ :

គោះនូវដឹងថ្ងៃត្រង់ ឆាយាអម្បាលមាណ ឲ្យ តាំងសំផុតព្រះអាទិត្យថ្ងៃនោះចេញ គោះពសី

០
១ } ឲ្យយកពីរហារ លទ្ធជាឆាយាវណ្ណនាគោះ
២

រាសី ៣ ៤ ៥ } ឲ្យយក ៣ លុបរាសីសេសនោះ យក
ទៅលុបត្រីចក្រសេស ឲ្យយក ២ ហារ លព្ធ
ជាឆាយាហិណ្ណរាសីទាំង ៦ នេះ ស្រមោល
ចោលទៅខាងត្បូងខ្ទួនយើងហោង ៗ នោះ
រាសី ៦ ៧ ៨ } ឲ្យយក ៦ លុបរាសីសេស ជាឆាយា
វណ្ណនា នោះរាសី ៩ ១០ ១១ } ឲ្យយក ៩ លុប រាសី
សេសឲ្យយកទៅលុបត្រីចក្រ សេសជាឆាយា
ហិណ្ណរាសីទាំង ៦ នេះ ស្រមោលចេញទៅខាង
ជើងខ្ទួនយើងហោង ៗ វិសេសបាទលើជា
បាទជើងជាន់ បាទកណ្ដាលឲ្យយកតិះហារ
លព្ធជាអង្គុលី សេសយក ៦០ គុណ បូកបាទ
ក្រោមឡើងយក ៣០ ហារ លព្ធជាគ្រាប់ស្រូវ
សេសយក ២ គុណ ១០ហារ លព្ធជាគ្រាប់ល្ង
សេសជាសរសៃសក់ ដឹងឆាយាថ្ងៃត្រង់ស្រួលរេច
ហោង ៗ នោះចង់ដឹងឆាយាជាន់ទទ អង្គុលី
១៥ អង្គុលី ១ ជាស្រូវ ៤ ស្រូវ១ ជាល្ង៦ ល្ង១
ជាសក់ ១០ សរសៃហោង ៗ

# ជីវប្រវត្តិសង្ខេប

## នៃសហជីវិន ហ៊ែល-ស៊ុំផា

(ដំកល់នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យថ្ងៃទី ២៩ តុលា ១៩៦៦)

សហជីវិនហ៊ែល-ស៊ុំផា កើតនៅថ្ងៃ ២៣ មេសា ១៩២៦ នៅផ្សារក្រោម ស្រុកបាកាន ខេត្តពោធិ៍សាត់ ពុកឈ្មោះ ម៉េវ-ហ៊ែល ម្ដាយឈ្មោះ ផេង-លិញ ។ កាលនោះលោក ម៉េវ ហ៊ែល ជាបិតា ដែលមានកំណើតនៅស្រុកកោះសូទិន (កំពង់ចាម) ជាលេខាធិការរ៉េស៊ីដង់ បានផ្លាស់ទីកន្លែងធ្វើការទៅកាន់ខេត្តជាច្រើន មានខេត្តតាកែវ, ពោធិ៍សាត់, កំពង់ស្ពឺ និងកំពង់ចាមជាដើម ។ សហជីវិនហ៊ែល-ស៊ុំផា កាលនៅកុមារបានចូលរៀនដំបូងនៅកំពង់ស្ពឺ និងកំពង់ចាម លុះឪពុកស្លាប់ទៅ ក៏បានមកជ្រកអាស្រ័យជាមួយឪពុកមា ធ្វើការក្នុងក្រុមប៉ូលិសនាគរាជធានីភ្នំពេញ ហើយបន្តការសិក្សានៅសាលាបឋមសិក្សា ហ្វ្រង់ស្វា-បូដួំងភ្នំពេញ (គឺអគារមហាវិទ្យាល័យគរុកោសល្យក្នុងអនុសាវរីយ៍ឯករាជ្យសព្វថ្ងៃ) ។ លុះប្រឡងវិញ្ញាបនប័ត្របឋមសិក្សាបារាំង-ខ្មែរ ជាប់ក៏ទៅរៀននៅអនុវិទ្យាល័យមីស្ហូ ។ រៀនបានបីឆ្នាំ គឺឆ្នាំ ១៩៣៧ ដល់ ១៩៤០ ប្រឡងសញ្ញាប័ត្រប្រ៊េវេ រួចក៏ចូលរៀនក្នុងសាលារដ្ឋបាលតុលាការខ្មែរ (Ecole d'Aministration Cambodgienne) ផ្នែកតុលាការ ចំនួន ២ ឆ្នាំ បានជាប់សញ្ញាប័ត្រសាលានេះ ។

នៅថ្ងៃទី ៣១ មីនា ១៩៤៣ សហជីវិន ហ៊ែល · ស៊ុំផា បាន ចូលធ្វើការរាជការ ដោយទទួលឋានៈជាសមុហបញ្ជីថ្នាក់លេខ ២ បំរុងរាជការ នៅសាលាដំបូងកំពង់ធំ ។

នៅថ្ងៃ ១១ កញ្ញា ១៩៤៥ បានឡើងកាន់ឋានៈជាមន្ត្រីបំរុងរាជការ Mandarin stagiaire ហើយកាន់មុខងារជាសុភាចារបុរស នៅសាលាដំបូងសៀមរាប ។

នៅថ្ងៃ ៤ វិច្ឆិកា ១៩៤៦ សហជីវិនហ៊ែល ស៊ុំផា បានរៀបមង្គលអាពាហ៍ពិពាហ៍ ជាមួយនាងគាត់ គីវគូរ ហៅ កុឡា ជាកូនអ្នកជំនួញ នៅផ្សារសៀមរាប ឈ្មោះគាត់ · ប៊ុនហ៊ួរ អ្នកស្រីហ៊ុ · មុច ។

នៅថ្ងៃ ១០ កញ្ញា ១៩៤៧ បានឡើងកាន់ឋានៈជាចៅក្រមពេញទីថ្នាក់លេខ៤ ហើយផ្លាស់មកភ្នំពេញ កាន់មុខងារជាអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ (Commissaire-Adjoin du Roi) នៅកន្លែងដដែលនេះ ដល់ថ្ងៃ ៤ កក្កដា ១៩៥០ ក៏បានឡើងមួយថ្នាក់ គឺបានឋានន្តរសក្តិជាចៅក្រមថ្នាក់លេខ ៣ ។ កាលនោះបានទទួលគ្រឿងឥស្សរិយយសមេដាយអស្សរិទ្ធិមុនីសារាភណ៍ ។

នៅថ្ងៃ ៩ វិច្ឆិកា ១៩៥១ បានផ្លាស់ទៅធ្វើជា សុភាចារបុរស នាសាលាដំបូងខេត្រកំពង់ចាម ។

នៅថ្ងៃ ១៣ មេសា ១៩៥៣ បានឡើងកាន់ឋានៈជាចៅក្រម

ថ្នាក់លេខ ២ ហើយបានគ្រឿងឥស្សរិយយស មេដាយប្រាក់ការងារ ។

នៅកំពង់ចាមបាន ៤ ឆ្នាំ គឺមកដល់ឆ្នាំ ១៩៥៥ ក៏បានផ្លាស់មកកំពត កាន់មុខងារជាអគ្គព្រះរាជអាជ្ញារង អមសាលាឧទ្ធរណ៍វិញ ហើយ នៅថ្ងៃ ១៣ មេសា ១៩៥៥ ក៏ទទួលឋានន្តរសក្តិជាចៅក្រមថ្នាក់លេខ១ ។

កន្លះឆ្នាំដដែលនេះ បានមកកាន់មុខដំណែងជានាយក្រុមការប្រមូលឯកសារ និងការផ្សាយខាងច្បាប់យុត្តិសាស្ត្រ និងនីតិកម្ម ( Chef de service de Documentation et des Publications judiciaires, de Juris prudence et de Législation ) នៅកន្លះឆ្នាំដដែលនេះ កើតមានច្បាប់ចេញមកតម្រូវឲ្យដំឡើងមួយថ្នាក់ គឺដល់ឋានន្តរសក្តិជាចាងហ្វាងសាលាដំបូងថ្នាក់លេខ ៣ ។

នៅថ្ងៃ ២៦ កុម្ភៈ ១៩៥៨ បានកាន់មុខដំណែងជានាយខុទ្ទកាល័យក្រសួងយុត្តិធម៌ ។

នៅថ្ងៃ ១៣ មេសា ១៩៥៨ បានឡើងឋានន្តរសក្តិជាចាងហ្វាងសាលាដំបូងថ្នាក់លេខ ២ ។

កន្លះឆ្នាំ ១៩៥៩-៦០ សម្តេចព្រះ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋទ្រង់សព្វព្រះរាជហឫទ័យទាញយកសហជីវិន ហែល-ស៊ុំជា ឲ្យធ្វើជាអ្នកនិពន្ធនាយករងនៃសារពត៌មាន អ្នកជាតិនិយម ដែលឲ្យនៅកាន់ឋានៈផ្លូវការជាទីប្រឹក្សាអមសាលាឧទ្ធរណ៍បំរើសាលាក្រមទៅ ។ កាលនោះ បាន

គ្រឿងឥស្សរិយយសមេដាយអស្សរិទ្ធិ សុវត្ថា ។

នៅថ្ងៃ ១៣ មេសា ១៩៦០ បានឡើងឋានន្តរសក្តិជាតាងហ្វាងសាលាដំបូងថ្នាក់លេខ ១ ហើយបានគ្រឿងឥស្សរិយយស មេដាយអស្សរិទ្ធិព្រះរាជាណាចក្រកម្ពុជា (Chevalier de l'Ordre Royale du Cambodge)

នៅថ្ងៃ ១៥មេសា ១៩៦៤ សម្តេចសហជីវិនទ្រង់បានជ្រើសរើសដោយផ្ទាល់ព្រះហស្តឲ្យសហជីវិន ហែល-ស៊ុំផា ឈរឈ្មោះជាបេក្ខជនសង្គមរាស្ត្រនិយម ឲ្យរាស្ត្របោះឆ្នោតជ្រើសរើសតាំងជាតំណាងរាស្ត្រដោយបានផ្អែកទៅលើគុណបំណាច់ពិសេសចំពោះរាស្ត្រ មាតុភូមិ និងសង្គមរាស្ត្រនិយម ដូច្នេះចាប់តាំងពីថ្ងៃ ២០ មិថុនា ១៩៦៤ គម្រប់ ៤ ឆ្នាំ សហជីវិន ហែល ស៊ុំផា កាន់ឋានៈជាតំណាងរាស្ត្រ មណ្ឌលកំពង់ដីក្រង (ស្រុកសូត្រនិគម និង ដីក្រង) ខេត្តសៀមរាប ។

ក្នុងពេល ៤ ឆ្នាំនេះ បានឡើងឋានន្តរសក្តិជា តាងហ្វាងសាលាដំបូងផុតលេខនៅថ្ងៃ ១៣ មេសា ១៩៦៣ ហើយនិងជាទីប្រឹក្សាសាលាវិនិច្ឆ័យថ្នាក់លេខ ៣ នៅថ្ងៃ ១៣ មេសា ១៩៦៨ ព្រមទាំងបានគ្រឿងឥស្សរិយយស ២ ទៀត ១- ទីសេនាសម្តេចព្រះមហាក្សត្រិយានី, ២- ទីធិបតិន្ទព្រះរាជអាណាចក្រ មុនីសារាភណ៍ (Commendeur de l'Ordre Royale de Monissaraphon)

នៅក្នុងកំឡុងពេល ៤ ឆ្នាំនេះ សហជីវិន ហ៊ែល ស៊ុំផា បានចូលរួម រួមក្នុងសមាសភាពគណៈរដ្ឋមន្ត្រីក្នុងឋានៈជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងការងារ ចំនួន ២ ខែ គឺពីថ្ងៃ ៦ សីហា ១៩៦៦ ។

សរុបសេចក្តីទៅ សហជីវិន ហ៊ែល-ស៊ុំផា បានចូលធ្វើការរាជការក្នុងតុលាការតាំងពីឆ្នាំ ១៩៤៣ ដល់មកឆ្នាំ ១៩៦៦ នេះ បានឡើង ១១ ថ្នាក់ ដោយរំលងឋានៈជាក្រឡាបញ្ជីនិងចៅក្រមថ្នាក់លេខ ១ ហើយក្នុងមួយថ្នាក់ៗ នៅយ៉ាងយូរតែបីឆ្នាំទេ ។ ម្យ៉ាងទៀត នៅរដ្ឋសភាគេត្រូវដំឡើង ឋានន្តរសក្តិអគ្គរាជការជាតំណាងរាស្ត្រ ដែលដល់ពេលវេលាត្រូវឡើង ឲ្យត្រូវឡើងដោយស្វ័យប្រវត្តិ ។

គ្រឿងឥស្សរិយយសបានទាំងអស់ ៦ គឺ ចាប់តាំងពីដំបូង :

១– អស្សឫទ្ធិមុនីសារាភ័ណ

២– វត្តនការប្រាក់

៣– អស្សឫទ្ធិសុវត្ថារា ។

៤– អស្សឫទ្ធិនៃព្រះរាជអាណាចក្រកម្ពុជា

៥– សេនានៃសម្តេចព្រះមហាក្សត្រិយានី

៦– ធិបតិន្ទ មុនីសារាភ័ណ

អំពីស្នាដៃខាងអក្សរសាស្ត្រ សហជីវិន ហ៊ែល-ស៊ុំផា បានតែងប្រលោមលោក ៣ គឺ:

១. ចោរបិទមុខ ក្នុងឆ្នាំ ១៩៥១

២- ចោរលួចប្រាក់ ក្នុងឆ្នាំ ១៩៥២

៣- ចោរក្ដុំត្បូង ក្នុងឆ្នាំ ១៩៥៤

សៀវភៅបកប្រែឈ្មោះ :

- ប៉ូលនិងវីរហ្ស៊ីន ឆ្នាំ ១៩៥៥

សៀវភៅច្បាប់ឈ្មោះ :

- ពន្យល់ច្បាប់ ឆ្នាំ ១៩៥៧ ពីលេខ ១ ដល់ លេខ-១០

- វចនានុក្រមច្បាប់ពិសេសចំពោះបទល្មើសអាជ្ញា ឆ្នាំ ១៩៦៦

សៀវភៅពិចារណា :

- គួរពិចារណាដើម្បីបេះខ្មែរ ឆ្នាំ ១៩៦៥ ស្នាដៃឯទៀតជាគុណបំណាច់ចំពោះជាតិមានតែ :

១ - បានចូលជាសមាជិកសង្គមរាស្ត្រនិយម

២- បានចូលជាសមាជិក សមាគមអ្នកនិពន្ធខ្មែរ កាន់ឋានៈជាអនុប្រធាន ១ ឆ្នាំ ជាប្រធាន ៨ ឆ្នាំ

៣ - បានចូលជាសមាជិក សមាគម អតីតសិស្ស វិទ្យាល័យ អនុវិទ្យាល័យ ព្រះស៊ីសុវត្ថិ ។

៤ - បានចូលជាសមាជិក សមាគមយុត្តិសាស្ត្រខ្មែរ

៥ - បានចូលជាសមាជិក សមាគមកំចាត់រោគឃ្លង់

៦ – បានបង្រៀនច្បាប់នៅសាលាអប់រំមូលដ្ឋាននានាទន្លេបាទី

៧ – បានបង្រៀនភាសាខាងតុលាការ និងច្បាប់នៅមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៨ – បានទទួលបេសកកម្មពីព្រះរាជរដ្ឋាភិបាល ទៅកាន់ប្រទេសក្រៅព្រមទាំងបានទស្សនាប្រទេស : ១ បារាំង ២. អង់គ្លេស ៣. បែលហ្ស៊ិក ៤. ហូឡង់ ៥. ស្វ៊ីស ៦. សៀម ៧. វៀតណាមខាងត្បូង ៨. ក្រុងហុងកុង ៩ ប្រទេសជប៉ុន ១០. សហរដ្ឋអាមេរិក ១១. ប្រទេសអ៊ីរ៉ង់ ១២. ប្រទេសអ៊ីសរ៉ាឯល ១៣. ឥណ្ឌា ១៤. សហភាពសូវៀត ១៥. ប្រទេសអាល្លឺម៉ង់ខាងកើត ១៦. ប្រែគស ១៧. អេហ្ស៊ីប ១៨ វៀតណាមខាងជើង ។

៩ – បានចូលរួមក្នុងចលនាយុវជន មានក្នុងយុវជនឥណ្ឌូចិន ក្នុងយុវជន ចលនាយុវជនរាជសង្គមនិយមខ្មែរ ។ បានទៅរៀននៅសាលាអប់រំ យុវជននៅ ដាងតៀត និង ទន្លេបាទី ។

១០ – បានជួយឧបត្ថម្ភសមាគមរក្សាកេរ្តិ៍ខ្មែរ “សិល្ប:”

១១ – ក្នុងពេលដែលធ្វើតំណាងរាស្ត្រ បានណែនាំឲ្យបង្កើតសមាគមចំរើនឃុំ ១៣ កន្លែង បានណែនាំសមាគមទាំងនេះ ឲ្យធ្វើគិលានដ្ឋាន ៤ កន្លែង ធ្វើសាលារៀន ៣ កន្លែង ធ្វើអនុស្សាវរីយ៍ ១ កន្លែង ធ្វើស្ពាន ៧ កន្លែង លើកផ្លូវលំ ៣ កន្លែង ដាក់ថ្មថ្នល់ខេត្ត ១ កន្លែង ស្មើ

ជំនួយសង្គហជាតិជូនអ្នកក្រីក្រឆេះផ្ទះ ១០០ ខ្នង ១ កន្លែង ជូនគ្រួសារអ្នករន្ទះបាញ់ ១ កន្លែង ស្នើសុំសម្តេចឪទ្រង់ជួយស្រោចស្រង់អ្នកស្រុក ១.០០០ នាក់ ឲ្យបានត្រពាំង ត្រពាំងរូងនិងផ្លូវបូកណា ដែលរាជការបានឲ្យជាសម្បទានទៅឯកជនម្នាក់ ១ កន្លែង ជួយដោះប្រជាពលរដ្ឋខ្លះ ឲ្យរួចពីការរំលោភបក្ខប់ ២ កន្លែង ស្នើសូមឲ្យរាជការដោះស្រាយបញ្ហាទឹក ៥ កន្លែង ណែនាំអ្នកស្រុកឲ្យធ្វើផ្កា ទិនបុណ្យកសាងឃុំ ១៩ កន្លែង បានចូលរួបរួមជាមួយគ្រួសារខ្ទនហោកប៉ិន ចូលវត្តក្ដីបេងម្ដង ហែផ្កាកសាងសាលារៀនកាកំបុតម្ដង បានធ្វើអន្តរាគមសូមឈើសង់សាលារៀន ១ កន្លែង ។ល។

១២– ចូលជាសមាជិកគណៈកម្មការនៃការសិក្សា ផ្នែកអក្សរ "ក" ហៅថាគណៈកម្មការវប្បធម៌ជាមួយសម្ដេចព្រះពោធិវង្ស ។

១៣– ចូលរួបរួមក្នុងការប្រជុំអក្សរសាស្ត្រ ជាមួយសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ព្រះនាម ជួន ណាត ។

ជាដើម . . . . . . ។

បញ្ចប់ជីវប្រវត្តិនេះ តែត្រឹមនេះសិន ។

ភ្នំពេញ ថ្ងៃទី ២៥ តុលា ១៩៦៦

X

X X

# រឿងពិសពស់ និង ពិសត្រី

( សហ. លី-ធាមតេង រៀបរៀងតាមឯកសារទំនៀមទម្លាប់ )

សត្វពស់ល្បីថាជាសត្វមានពិសសាហាវណាស់ ប៉ុន្តែមានពស់ខ្លះដែរដែលឥតពិសខ្លាំងពូកែ ដូចជាពស់ព្រលិត, ពស់សាំងសៀ, ពស់ទឹក ។ល។ ចំណែកសត្វត្រីវិញ មានត្រីខ្លះមានពិសបំណាច់ណាស់ដែរ ជាពិសេសគឺត្រីមានធ្នុង ដូចយ៉ាងត្រីអណ្តាង, ត្រីឆ្លាំងជាដើម ។

រឿងហេតុដែលនាំឲ្យពស់ខ្លះត្រីខ្លះ មានពិស , ត្រីខ្លះពស់ខ្លះឥតពិសនោះ ចាស់ព្រឹទ្ធាចារ្យបានប្រាប់ជារឿងព្រេងមួយ (១) មានសេចក្តីនិទាន ដូចតទៅនេះ ៖

កាលនោះ មានថ្លាន់មួយជាអ្នកមានពិសខ្លាំងក្លាពន់ពេកណាស់ សព្វសត្វធំតូចឡាយតែងកោតក្រែងឫទ្ធិរបស់ថ្លាន់នេះគ្រប់ ៗ គ្នា ។ ចំណែកមនុស្សវិញ ក៏ល្បីរន្ទឺក្រែងរអែងសត្វនេះគ្រប់ភូមិស្ថានដែរ ។ កុំថាឡើយទៅដល់ថ្លាន់នេះបានចឹក, បានព្រោះពិស ឬ តែផ្លាល់ខ្លួន សូម្បីតែនៅសល់ដានជើង ហើយថ្លាន់នេះ ទៅលិទ្ធដានជើងនេះ ក៏ម្ចាស់ខ្លួនដែលទុកដាននោះត្រូវស្លាប់ដែរ ។ ហេតុនេះហើយ បានជាពេលមួយព្រះរាជបុត្រីស្តេច បានលាព្រះបិតា ទៅលំហែព្រះកាយនៅក្នុងសួន

---

១- តាមលំនាំឯកសារលេខ ៩៦.០៥៧ លោក ចាង-រីក រៀបរៀង និងលេខ ២៧.២០[illegible] លោក ភិណា.គួរ រៀបរៀង ។

ឧទ្យាន ។ គ្រាដែលព្រះនាងវិលត្រឡប់មកកាន់ព្រះរាជដំណាក់វិញ ព្រះនាងនៅសល់ស្នាមព្រះបាទាជាប់នៅឋាក់ស្រះស្រង់ ដែលព្រះអង្គបានផ្លាស់ព្រះពរពស្ត្រា យាងចុះទៅស្នានព្រះវារីកំសាន្តសប្បាយជាមួយស្រីព្រះស្នំ ។ កាលនោះពស់ថ្លាន់មានឫទ្ធិបានវារទៅកាត់លើស្នាមព្រះបាទា ហើយលិទ្ធស្នាមនោះទៀត ។ ពេលជាមួយគ្នានេះ ព្រះរាជបុត្រីដែលយាងទៅដល់ប្រាសាទហើយនោះចុកចាប់យ៉ាងខ្លាំង ទោះបីពេទ្យហ្លួណាមកប្រកបឱសថថ្វាយក៏ពុំត្រូវពុំស្រាកសោះ ។ ទីបំផុតក៏ក្ស័យព្រះជន្មទៅ ។ ព្រះវររាជបិតា ទ្រង់វិតក្កខ្លាំងណាស់ដោយទ្រង់ស្តាយព្រះរាជបុត្រីតែមួយ ព្រះអង្គក៏ទ្រង់ត្រាស់បញ្ជា ឲ្យនាម៉ឺនសព្វមុខមន្ត្រីរៀបពិធីតម្កល់សព ហើយធ្វើពិធីបុណ្យគគ្រឹកគគ្រេង យប់ ៧ ថ្ងៃ ។ គ្រានោះ អ្នកស្រុកផងទាំងឡាយនាំគ្នាកកកុញទៅមើលព្រះរាជពិធី ព្រមទាំងទទួលទូវព្រះរាជទានដែលព្រះមហាក្សត្រទ្រង់មានសទ្ធាផង ។

សត្វស្រុកខ្លះ ដែលធ្លាប់ហិចហើររកចំណីតាមភូមិស្រុកដូចជាក្អែកជាដើម សប្បាយរីករាយណាស់ ព្រោះបានចំណីអាហារបរិបូណ៌ ក្អែកនាំគ្នាហោករញ្ជៀវកងរំពង ប្រាប់គ្នីប្រាប់គ្នាឲ្យមកអាស្រ័យអាហារ ។ ថ្ងៃងពីសត្វថ្លាន់នោះវិញ កាលបើឃើញមនុស្សអ៊ូអរ សត្វផងហើរប្រ-វាត់ថ្ងៃលធ្លាត់ដូច្នោះ ធ្ងល់ណាស់ ក៏ស្រែកសួរទៅក្អែកដែលកំពុងទំ

ស្រែកលើមែកឈើ ថា ៖

អើបងក្អែក ! បងក្អែកឯងដឹងទេ ហេតុអ្វីក៏គេផ្អើលនោះឡើងច្រើនម្ល៉េះ ?

ក្អែកឮថ្ងាន់សួរដូច្នោះ ក៏ក្លែងឆ្លើយចំអកដើម្បីបន្ទាប់ថ្ងាន់វិញថា ៖

– ហ៊ឺះ បងថ្ងាន់ឯងធ្វើជាមិនដឹងខ្លួន គេសប្បាយពីរឿងបងថ្ងាន់ឯងហ្នឹង !

ថ្ងាន់ឮហើយប្រញាប់សួរបញ្ជាក់ថា ៖

– រឿងអី ខ្ញុំមានរឿងអី ?

ក្អែកបន្ថែមថា ៖

រឿងបងថ្ងាន់ឯងធ្លាប់ល្បីថាមានពិសពូកែណាស់ បើគ្រាន់តែលិទ្ធស្នាមជើងនរណា អ្នកនោះនឹងត្រូវស្លាប់ដែរ ហើយឥឡូវនេះ បងថ្ងាន់ឯងលិទ្ធស្នាមជើងកជបុត្រី តែព្រះអង្គមិនស្លាប់ទេ បែរជាមានពងកាយរឹតតែល្អស្រស់ឡើងទៀត ៗ ហេតុនេះហើយ បានជាស្ដេចឲ្យធ្វើបុណ្យសប្បាយទឹងជោគជ័យនេះ ៗ

ថ្ងាន់ឮសូរតែប៉ុណ្ណោះ ក៏ស្រងាកចិត្ត លូនចេញពីមុខក្អែកភ្លាម ៗ ថ្ងាន់ឈឺចិត្តណាស់ ព្រោះតាំងពីដើមមក នរណាក៏កោតខ្លាចខ្លួនដែរ ចុះបើឥឡូវបែរជាមានគេឈ្នះឫទ្ធិខ្លួនដូច្នេះ គួរឲ្យអាម៉ាស់មុខណាស់ ៗ គិតដូច្នេះភ្លាម ថ្ងាន់លូនសំដៅទៅរកបឹងមួយដែលកំពុងមានទឹកជន់ជោរ

ឡើងលិចពេញព្រៃផ្សៃ នៅជិតខាងនោះ ៗ សត្វធាតុទាំងឡាយកំពុង ពួនជ្រកនឹងគុម្ពោតព្រៃខ្លាចស្លាប់ដោយសារទឹកជំនន់ ៗ ថ្កាន់ទៅដល់ ទីនោះហើយ ក៏យំឈឺចិត្តក្អួតបញ្ចេញពិសខ្លួនចេញចោលឲ្យអស់ ដោយ យល់ថា ទុកធ្វើអ្វីបើមិនបានការដែល ៗ

ពេលនោះ ពស់ខ្លះដែលជ្រកនៅពួនកន្ទុំគុម្ពោតព្រៃជិតនោះ ដូចជា ពស់វែក ពស់ក្រាយ ពស់ស្នាទេឡាន់ជាដើម ម៉ឺម្នានាំគ្នាមកត្រងយក ពិសដែលថ្កាន់ក្អួតចោលនោះភ្លាម ៗ ហេតុនេះហើយ បានជាពស់ទាំង នេះ មានពិសខ្លាំងក្លាណាស់ , ចំណែកពស់ឯទៀតដែលមិនបានទៅជិត ក៏ប្រឹងត្រដរមកដណ្ដើមពិសទឹងគេដែរនោះ ខ្លះក៏បានបន្តិចបន្តួច ខ្លះក៏ ទទេស្អាត ក៏មាន ៗ

រីឯត្រីដែលរស់នៅក្បែរខាងនោះវិញ ប្រឹងនាំគ្នាត្របាក់ដណ្ដើម យកពិសពីថ្កាន់ដែរ ត្រីដែលយកបានពិសខ្លះនោះ មានត្រីអណ្ដែង ត្រី ឆ្លាំង បានមុនគេ ឯត្រីឯទៀតៗ ក៏វ៉ូតរះមកយកពិសទឹងគេដែរ ម៉្លោះ ហើយបានជាប្រជ្រៀតគ្នាតាន់តាប់ ។ ត្រីណាដែលត្រូវគេត្បៀតខ្លាំង ក៏សំប៉ែតខ្លួនទាល់តែសព្វថ្ងៃ ដូចយ៉ាងត្រីកេស ត្រីក្រពាត់ ត្រីស្លាត ។ល។ គឺជាត្រីស្លាតនេះឯង ដែលត្រូវគេប្រជ្រៀតផ្ទប់ទៅនឹងថ្មទាល់តែសំប៉ែត

ស្ដើងខ្លួនអស់ដល់សព្វថ្ងៃ ។ ឯត្រីក្រមមចំប្រជៀតទៅត្របាក់យកបានពិសមកហើយ ប៉ុន្តែហក់ចេញមកវិញ ដោយមានគេឯងជះណ្ដើមច្រើនពេក ក៏ជ្រុះបាត់ទៅវិញទៅ ។ ត្រីក្រមបយំស្ដាយពិសនោះខ្លាំងណាស់ ពាល់តែហើមមុខដល់សព្វថ្ងៃ បានជាមានពាក្យថា “ មុខហើមមើលតែត្រីក្រមម ” ។ កាលនោះ ត្រីសណ្ដាយហែលមកឃើញត្រីអស់នេះ មានរូបភាពប្លែក ខ្លះសំប៉ែត ខ្លះហើមមុខដូច្នេះ ក៏សើចចំអកឲ្យ សើចមិនតិចមិនតួច សើចដល់ទៅរយះមាត់ច្រវាបដល់គុម្ពត្របៀករហូតដល់សព្វថ្ងៃ ។
នេះហើយ ជារឿងពិសពស់ និង ពិសត្រី ។

X

X X

អក្សរសាស្ត្រខ្មែរយើង ផ្នែកសាសនា, ទស្សនវិជ្ជា, វិទ្យាសាស្ត្រ, និរុត្តិសាស្ត្រ ជាបាលី និង សំស្ក្រឹត, មានតម្លៃ មានឋានៈដ៏ខ្ពស់ឧត្តុង្គឧត្តមណាស់ នៅលើផ្ទៃពិភពអន្តរជាតិ និង ក្នុងចំណោមនៃអត្ថបទនានាដ៏មានតម្លៃនៃវប្បធម៌សកលលោក ។

សម្ដេចព្រះ នរោត្ដម សីហនុ

ថ្លែងក្នុងពេលថ្វាយសញ្ញាបត្របណ្ឌិត

ចំពោះសម្ដេចព្រះសង្ឃរាជ

(ថ្ងៃ ២៨ ៥-៦៣)

# ពិធីបុណ្យឆ្លងព្រះវិហារ-បញ្ចុះខណ្ឌសីមា

នៃវត្តនិរោធរង្សី សង្កាត់ច្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្ដាល

ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ នៃសម្ដេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។

វត្តនិរោធរង្សីជាវត្តចាស់បុរាណមួយ រាប់ជាងមួយសតវត្សហើយ ដែលសង់នៅលើមាត់ច្រាំងទន្លេ ប៉ុន្តែត្រូវច្រាំងបាក់ដេញអស់ពីរដងហើយ ។ ឥឡូវនេះ ពុទ្ធបរិស័ទជើងវត្ត មានព្រះមុនីកោសល សោម ឈុង ជាចៅអធិការ បានរុះរើចេញអំពីច្រាំងបាក់មកសង់ខាងត្បូងជាប់ថ្នល់ជាតិ ជាខាងកើតផ្សារច្បារអំពៅចំនួន ១.៣០០ម ។ វិហារវត្តនិរោធរង្សីដែលព្រះមុនីកោសល សោម ឈុង និងពុទ្ធបរិស័ទជើងវត្ត បានចាប់សាងតាំងពីឆ្នាំឆ្លូវឯកស័ក ១៩៤៩ លុះដល់ឆ្នាំ ១៩៥៩ ព្រះមុនីកោសលក៏ទទួលអនិច្ចធម្មទៅ ។ សំណង់វិហារក៏នៅសល់ពុំទាន់ហើយ គឺនៅត្រឹមដំបូល, កំពូលនិងក្បាច់ក្បូរថ្នាក់លើទាំងអស់ ។

លុះដល់ឆ្នាំ ១៩៦១ ព្រះមុនីកោសល សួរ ហាយ បានទទួលនាទីជាចៅអធិការ បានកសាងវិហារនោះបន្តមកទៀត រហូតដល់ឆ្នាំ ១៩៦៨ ទើបហើយស្រេច ។ លុះសំណង់វិហារនោះសម្រេចហើយ បានប្រជុំពុទ្ធបរិស័ទ តាំងគណៈកម្មការមួយ ជំនុំអំពីពិធីបុណ្យឆ្លងវិហារ បញ្ចុះខណ្ឌសីមា ។ គណៈកម្មការក៏បានយល់ស្របគ្នាជាឯកច្ឆន្ទ ។

កម្មវិធីបុណ្យឆ្លងវិហារ-បញ្ចុះខណ្ឌសីមាវត្តនិគោធវង្សនេះ មានបីយប់ បួនថ្ងៃ គឺ :

ថ្ងៃទី ១ គឺថ្ងៃអាទិត្យ ៤ រោចខែផល្គុន (១៧ មីនា ឆ្នាំ ១៩៦៨) ពេលរសៀលម៉ោង ១៦ ប្រជុំគ្នាបើកសម័យចូលបុណ្យ ដង្ហែដុំថ្មនិមិត្តសីមា ប្រទក្សិណវិហារ រួចយកនិមិត្តសីមា ទៅតម្កល់ក្នុងវិហារថ្នាក់លើ, ម៉ោង ១៩ អុជកាំជ្រួច, ម៉ោង ២០ នមស្ការព្រះរតនត្រ័យ ព្រះសង្ឃចំរើនព្រះបរិត្ត, វេរដុំថ្មនិមិត្តសីមា, វេរឧបោសថាគារ គឺព្រះវិហារ, ម៉ោង ២១ សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ទ្រង់ប្រទានធម្មទេសនា ព្រះធម្មគារវ, ម៉ោង ២៣ បញ្ចាំងភាពយន្តតទៅ ។

ថ្ងៃទី ២ គឺថ្ងៃ ៥ រោចខែផល្គុន (១៨ មីនា) ពេលព្រឹក និង ពេលថ្ងៃត្រង់ អង្គាសយាគូ វេរសង្ឃភត្តចំពោះសង្ឃ ១៨០ អង្គ, ពេលរសៀលម៉ោង ១៥ និមន្តលោកគ្រូអាចារ្យ ព្រះនាម ពណ៌ ទៅអធិការវត្តពោធិព្រឹក្ស ទេសនា ទសជាតក៍, ពេលព្រលប់ម៉ោង ១៨ អង្គាសគេសជ្ជៈ ម៉ោង ១៩ អុជកាំជ្រួច, ម៉ោង ២០ នមស្ការចម្រើនព្រះបរិត្ត រួចសូត្រធ្វើកិច្ចពុទ្ធាភិសេក, ម៉ោង ២២ សម្តេចព្រះពោធិវង្ស ប្រទានធម្មទេសនាបឋមត្រាស់, ម៉ោង ២៣ បញ្ចាំងភាពយន្តតទៅ ។

ថ្ងៃទី ៣ គឺថ្ងៃ ៦ រោចខែផល្គុន (១៩ មីនា) ពេលព្រឹកមានកម្ម-

វិធីដូចថ្ងៃទី ៦ ដែរ ។ ពេលរសៀលម៉ោង ១៤ និមន្តព្រះអរិយមគ្គ-ញាណ អៀម ហេង វត្តសាកែវ ទេសនាអំពីផលានិសង្សបុណ្យ, ម៉ោង ១៧ អង្គាសភេសជ្ជៈ, ម៉ោង ១៨ និមន្តព្រះសង្ឃ ១៥០ អង្គ ធ្វើសង្ឃកម្មសូត្រសីមា, ម៉ោង ២១ អុជកាំជ្រួច រួចមានសិល្បៈយីកេតទៅ ។

ថ្ងៃទី ៤ គឺថ្ងៃ ៣ រោចខែផល្គុន (២០ មីនា) ពេលព្រឹកម៉ោង ៦ អង្គាសយាគូ និងភត្តចំពោះសង្ឃ ១៨០ អង្គ, ម៉ោង ៨ រង់ចាំធ្វើបដិ-សណ្ឋារកិច្ចចំពោះសម្តេចព្រះសង្ឃរាជថ្នាក់ទី ១, សម្តេចព្រះសង្ឃនាយកគណៈធម្មយុត្ត និង សម្តេចព្រះពោធិវង្ស, ម៉ោង ៩ រង់ចាំធ្វើបដិសណ្ឋារ-កិច្ចចំពោះសម្តេចព្រះប្រមុខរដ្ឋ, ម៉ោង ១០ ព្រះមុនីកោសល ថ្វាយសុន្ទរកថា, ម៉ោង ១០,២០ នាទី សម្តេចព្រះប្រមុខរដ្ឋថ្លែងសង្កថាដ៏សង្ខេប, ម៉ោង ១០,៤០ នាទី កាត់ឫសសីមា, ម៉ោង ១១ វេរសង្ឃភត្ត ពេលរសៀលម៉ោង ១៤ និមន្តព្រះធម្មកថិក ៣ អង្គ សុទ្ធតែជាព្រះមេគណគឺ : លោកគ្រូមេគណខេត្តកណ្តាល, មេគណក្រុងភ្នំពេញ និង មេគណខេត្តស្វាយរៀង ទេសនា សង្គាយនាថ្លែងបុណ្យតាមប្រពៃណីនិយម ។

នៅឱកាសបុណ្យឆ្លងព្រះវិហារ-បញ្ចុះខណ្ឌសីមាវត្តនិរោធរង្សី មានគណៈកម្មការ ១២ ក្រុម ជាអ្នកចាត់ចែងរៀបចំបុណ្យ ។ វត្តនិរោធ-រង្សី បានទទួលនូវភាពថ្កុំថ្កើងរុងរឿងជាមហាស្ថានដ៏ក្រៃលែង អស់រាង

៤ យប់ ៥ ថ្ងៃ ដោយរៀបរចនាដាក់ភ្លើងអគ្គិសនីភ្លឺចិញ្ចែងចិញ្ចាចគ្រប់ដើមឈើមែកឈើទាំងអស់ព្រមទាំងភ្លើងបញ្ចាំងពន្លឺចំពោះព្រះវិហារ ទាំងចម្រុះដោយទង់ជាតិ និង ទង់សាសនាជាច្រើនក្រោងក្រាក ព្រមទាំងពេងតាំង ១១ សុទ្ធតែមានលំអក្រៃលែងផ្សេងៗគ្នា គួរជាទីជ្រះថ្លារីករាយនៃមហាជនពន់ពេកណាស់ ។ នៅឱកាសពិធីបុណ្យនេះ ក៏មានភ្ញៀវអញ្ជើញមកច្រើនកុះករមើរដេរដាសនៅលើថ្នល់ជាតិ តាំងពីផ្សារចង្អៀតពេញថ្នល់ពេញវត្ត ហើយច្រើនលាន់មាត់សរសើរថា បុណ្យនេះចំជាថ្កើងរុងរឿងអស្ចារ្យពិតប្រាកដមែន ។

## គណៈកម្មការបុណ្យ ១២ ក្រុម

១- គណៈកម្មការទូទៅមានលោក តាន់ ឈាងលឹម តំណាងរាស្ត្រ ជាប្រធាន

២- គណៈកម្មការមជ្ឈមណ្ឌលមានលោក សាន ឌុក ជាប្រធាន

៣- គណៈកម្មការ ចំណាយខាងហិរញ្ញវត្ថុមាន ឧបាសក អ៊ូក មៀច ជាប្រធាន

៤- គណៈកម្មការ ខាងភោជនាហារមានឧបាសក អែម សម ជាប្រធាន

៥- គណៈកម្មការ ខាងភេសជ្ជៈមានឧបាសក ប៉ុល លោម ជាប្រធាន

BIBLIOTHEQUE P.P. D'EXTRÊME ORIENT

៦- គណៈកម្មការ ខាងហេរញ្ញិក មានអាចារ្យ

ស្រ៊ី ឈឹន, គួច គីឡេង ជាប្រធាន

៧ - គណៈកម្មការ ខាងផ្គត់ផ្គង់ភ្លើង មានឧបាសក

អ៊ូក-មៀច, ទៅ រ៉ាញ ជាប្រធាន

៨ - គណៈកម្មការ ខាងរឹកប្រើប្រាស់ មានឧបាសក

សោ-ហ៊ន ជាប្រធាន

៩ - គណៈកម្មការ ខាងបដិសណ្ឋារៈ ចំពោះសង្ឃនិងគ្រហស្ថ មានព្រះមុនីកោសល, ព្រះឥន្ទមុនី ឆាយ-ផន ជាប្រធាន និងព្រះសិរីវិសុទ្ធ ធន់ រ៉ន់ ជាអនុប្រធាន ។ ខាងគ្រហស្ថមានឧបាសក ឯរ-អ៊ុំ ជាប្រធាន

និងលោក ម៉ែន-ពុំ ជាអនុប្រធាន

១០ - គណៈកម្មការ ខាងត្រួតត្រាមើលពេងកាន់ទិស

មានឧបាសក ឯម-សម ជាប្រធាន

១១ - គណៈកម្មការ ខាងរបៀបរៀបចំទូទៅ មានសន្តិសុខនិងសុខាភិបាលជាដើម មានលោក ម៉ៅ-អ៊ុត ហៅ ម៉ុល ជាប្រធាន

១២ - គណៈកម្មការ ខាងផ្គត់ផ្គង់កាំជ្រួច, អុជកាំជ្រួចរៀងរាល់យប់ ដោយមានលោក ឡាំ-សន ជាប្រធានគហបតី លី-គ្រាន់ ជាអនុប្រធាន ។

គណៈកម្មការពិធីបុណ្យនេះ មានសមាជិក-សមាជិកា ចំនួន ១៨០

នាក់ មានព្រះមុនីកោសលជាចៅអធិការជាប្រធានទូទៅលើគណៈកម្មការឯទៀត ៗ ដើម្បីអនុវត្តឲ្យត្រឹមត្រូវតាមកម្មវិធី និងបទបញ្ជារបស់គណៈកម្មការទាំងអស់ ជាពិសេសអស់លោកអ្នកដែលពុំមែនជាសមាជិកនៃគណៈកម្មការបុណ្យនេះទេ ប៉ុន្តែលោកបានអញ្ជើញមកជួយបម្រើបុណ្យដោយពេញកម្លាំង បែកញើសហូរស្រោចស្រៀវពីកយប់កលថ្ងៃ ឥតខ្លាចនឿយហត់ឡើយ ដូចយ៉ាងលោក វរសេនីយឯក ប៉ុក-សំអាន, លោកវរសេនីយឯក ថុបនា-និន និងលោក យង់-សេង ចៅតំបន់រដ្ឋបាលច្បារអំពៅ ដែលខំខ្វល់ខ្វាយបម្រើបុណ្យផ្ទាល់ ៗ ខ្លួន ទាំងយប់ទាំងថ្ងៃ ៗ

មួយទៀតការជួយឧបត្ថម្ភបុណ្យនេះ មានឯកឧត្តមចៅ សែនកុសលឈុំ ប្រធានរដ្ឋសភា, ឧត្តមសេនីយឯក លន់ ណុល និងលោកជំទាវ, អ្នកស្រីឧបាសិកា តាន់ ស៊ុប៊ី ប្រធានគណៈកម្មការ វត្តឧណ្ណាលោម, លោកអភិបាលខេត្តកណ្ដាល និងលោកអភិបាលស្រុក កៀនស្វាយ ជាដើម ៗ

បំណាយថវិកាកង់ទុកាសពិធីបុណ្យ របស់គណៈកម្មការបានជួរស្រាលជាច្រើនណាស់ ដូចយ៉ាងប្រាក់កាសដែលត្រូវចាយ សម្រាប់ភោជននិងភេសជ្ជៈជាដើមចំនួន៤ថ្ងៃ ប៉ុន្តែត្រូវចាយចំពោះតែ៤ថ្ងៃទៅវិញគឺ

១ លោកជំទាវឧត្តមសេនីយឯក លន់ - ណុល ទទួលក៏ចាត់ធ្វើចង្ហាន់ប្រគេនព្រះសង្ឃចំនួន ២០០ អង្គអស់មួយថ្ងៃ ៗ

២- អ្នកស្រីឧបាសិកា តាន់ - ស៊ីប៊ី ទទួលរ៉ាប់រងធ្វើចង្ហាន់ប្រគេនព្រះសង្ឃចំនួន ២០០ អង្គអស់មួយថ្ងៃ ។

៣ ឯកឧត្តម ចៅ.សែនកុសល ឈុំ ទទួលរ៉ាប់រងវេទិកាពិសេសសម្រាប់សម្តេចព្រះប្រមុខរដ្ឋ ព្រមទាំងរថយន្តដឹកទឹក ។

៤ លោកវរសេនីយឯក ឫបនា - ងិន ទទួលរ៉ាប់រងខាងម៉ាស៊ីនភ្លើង អគ្គិសនីព្រមទាំងការរចនាតាក់តែងភ្លើង ។

៥- លោកវរសេនីយឯក ប៊ុក-សំអាត ទទួលរ៉ាប់រងខាងក្តារបែនសម្រាប់តម្កល់គ្រប់បាក់ព្រមទាំងកៅអី និងរថយន្តដឹកទឹក ។

៦- គហបតី យាង ទេង រ៉ាប់រងខាងកាំជ្រួចសម្រាប់អុជរៀងរាល់យប់ អស់ចំនួន ២០.០០០ រៀល ។

៧- លោកអ្នកឧកញ៉ា ងិន-ឌិប រ៉ាប់រងខាងភេសជ្ជៈចំពោះសង្ឃអស់មួយពេល ។

៨- គហបតី លី-គ្រាន់ ទទួលរ៉ាប់រងចេញប្រាក់បោះពុម្ពសៀវភៅ សម្រាប់ប្រគេនចែកជាធម្មទានអស់ ១០.០០០ រៀល ព្រមទាំងស្បង់ចំនួន ១០០ ។

៩- ក្រុមពុទ្ធបរិស័ទ សាលាសន្សំសុខ ក្រុងភ្នំពេញ ធ្វើចីវរចំនួន ២០ លៀង ព្រមទាំងធ្វើភេសជ្ជៈប្រគេនព្រះសង្ឃអស់មួយពេល ។

១០ - ក្រុមពុទ្ធបរិស័ទ ផ្សារ ប៉ែកបាន ធ្វើចីវរចំនួន ១០ លៀង

១១ - ក្រុមពុទ្ធបរិស័ទ ភូមិសល់ដី ព្រៃពួច អង្គស្នួល ធ្វើចីវរ ចំនួន ៥ លៀង ។

១២ - ក្រុមបរិស័ទ សេង.ប៉ៃ ជំនួញភេសជ្ជៈ ប៊ុបស៊ុ-កូឡា ក៏បានប្រគេនភេសជ្ជៈចំពោះសង្ឃអស់មួយពេល ។

នៅទំព័របន្ទាប់ទៅទៀតនេះ យើងសូមចុះជូនទាំងស្រុងនូវអត្ថបទសុន្ទរកថារបស់ ព្រះមុនីកោសល សួរ.ហាយ ដែលបានថ្លែងជាឱឡារិកកង់ឱកាសបុណ្យនេះ ។

ចំណែកព្រះរាជសន្ទរកថា ដ៏ពិរោះក្បោះក្បាយ របស់សម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ ជាទីគោរព ស្នេហា ស្មើជីវិតនៃយើងនោះ អស់លោកអ្នកអាន បានស្ដាប់ជាច្រើនលើកតាមសម្លេងវិទ្យុជាតិរួចមកហើយកាលពីថ្ងៃទី ២០ និង ២១ មីនា គ.ស. ១៩៦៨ ។

# សុន្ទរកថា នៃព្រះមុនីកោសល សួរ ហាយ

ថ្លែងក្នុងឱកាស ពិធីឆ្លងព្រះវិហារ បញ្ចុះខណ្ឌសីមា វត្តនិរោធរង្សី សង្កាត់ច្បារអំពៅ ស្រុកកៀនស្វាយ ខែត្រកណ្ដាល នៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៦៨ ក្រោមព្រះរាជាធិបតីភាពនៃ

សម្ដេចព្រះប្រមុខរដ្ឋ

## សូមថ្វាយព្រះពរ

## ចំពោះសម្ដេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃពុទ្ធបរិស័ទជើងវត្ត, ក្នុងនាមនៃគណៈកម្មការចាត់ចែងពិធីបុណ្យ និងក្នុងនាមផ្ទាល់នៃអាត្មាភាព ដោយពេលឱកាសដ៏មហោឡារិកនេះ នាំឲ្យអាត្មាភាពមានសោមនស្សរីករាយរំភើបចិត្ត ប្រកបដោយបីតិប្រាមោទ្យអរសប្បាយជាទីបំផុត ចំពោះសម្ដេចជាម្ចាស់ ដែលទ្រង់ព្រះមេត្តាស្ដេចយាងមកជាព្រះរាជាធិបតី និង ជាព្រះរាជកិត្តិយសដ៏ខ្ពង់ខ្ពស់នៃពិធីបុណ្យឆ្លងព្រះវិហារថ្មី និង បុណ្យបញ្ចុះខណ្ឌសីមាវត្តនិរោធរង្សី ឆ្លងសាលាបឋមសិក្សាមួយខ្នង, បណ្ណាល័យមួយខ្នង, ស្ពានបេតុងអារម៉េ ១ ព្រមទាំងថ្នល់មួយផង ។

សូមក្រាបបង្គំទូលថ្វាយសម្ដេចព្រះសង្ឃរាជថ្នាក់ទី១,

សម្ដេចព្រះសង្ឃនាយក,

សម្ដេចព្រះពោធិវង្ស,

ព្រះមហាថេរានុត្ថេរៈទាំងឡាយ,

ទ្រង់, ឯកឧត្ដម និងអស់លោក-អ្នកព្ទបរិស័ទទាំងឡាយ ដែលបាន យាង និមន្ដ-អញ្ជើញ មកជាព្រះរាជកិត្តិយស និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់ កង់ពិធីស ម្ពោធវិហារថ្មី, បញ្ចុះខណ្ឌសីមានេះ ។

នៅពេលនេះ អាត្មាភាព សូមព្រះរាជទានព្រះរាជវរោកាសថ្វាយ ដោយសង្ខេប អំពីសំណង់វិហារ, សាលាបឋមសិក្សា, បណ្ណាល័យ, ស្ពាន និង ថ្នល់ ដើម្បីសម្ដេចជាអម្ចាស់ទ្រង់ជ្រាប ដូចសេចក្ដីរៀបរាប់វែក ញែកតទៅនេះ ៖

## អំពីសំណង់វិហារ

ព្រះវិហារនេះចាប់ផ្ដើមបញ្ចុះបឋមសិលាពីឆ្នាំ ១៩៦៧ កាលណោះ ឯកឧត្ដម ចៅសែន កុសល ហៅ ឈុំ អភិបាលខេត្តកណ្ដាល បានអញ្ជើញ មកជាអធិបតីកង់ពិធីបញ្ចុះសិលា លុះមកដល់ឆ្នាំថ្មីឯកស័កឆ្នាំ ១៩៤៩ ក៏ ចាប់ផ្ដើមសង់វិហារបណ្ដោះ លើគជីបណ្ដោះដេកបមក ។ វត្តនិពធរង្សីនេះជា វត្តបុរាណចាស់ទុំយូរណាស់ហើយ មានកំណើត ៣ កន្លែង និងកន្លែងនេះ ហើយ ដោយហេតុប្រាំងទន្លេចេះតែបាក់ ស្រុតដេញវត្តចេញអំពីមាត់ទន្លេ

ម៉ោះហើយ គឺចេះតែត្រូវរុះរើចេញអំពីទីប្រាំងបាក់យកមកសង់ត្រង់កន្លែងនេះ ៗ វត្តនេះទើបនឹងរុះរើចេញអំពីទីមាត់ទន្លេប្រាំងបាក់ ពីឆ្នាំមមែត្រីស័ក ខែពិសាខ ថ្ងៃសុក្រ ព.ស. ២៦៧៥ គ.ស. ១៩៣១ ៗ រយៈចម្ងាយពីវត្តវិភេធវេឡាំនេះ ទៅមាត់ទន្លេប្រាំងបាក់ខាងជើង ចំនួន ២ គីឡូម៉ែត្រ ៗ

សំណង់វិហារនេះ ដោយពុទ្ធបរិស័ទ មានព្រះមុនីកោសល សោម-ឈុន ជាដើម ជាគេតិតចៅអធិការវត្តនេះ ព្រមទាំងពុទ្ធបរិស័ទជើងវត្តនិងអស់លោក អ្នកក្រុងកំពេញ ជួយឧបត្ថម្ភជាច្រើននាក់ ដូចកប់នាមខាងក្រោមនេះ ៖

១- ឯកឧត្តម ចៅ សែនកុសល ឈុំ ប្រធានរដ្ឋសភាបច្ចុប្បន្ននេះ

២. ឧត្តមសេនីយឯក លន់ ណុល និង លោកជំទាវនៃឧត្តមសេនីយឯក បានជួយឧត្តមផ្តល់បច្ច័យកងសំណង់វិហារនេះទាល់តែហើយស្រេច អស់បច្ច័យចំនួន ២៩០.០០០៛

៣- លោកវរសេនីយឯក ឋបនា ងិន និង លោក ងិន ឧិប្បា ជាបងប្អូននិងគ្នា

៤- លោកវរសេនីយឯក ប៉ុក សំអាន ៗ

កងការឧបត្ថម្ភសំណង់វិហារនេះ សូមអភ័យទោសពុំបានកប់ឈ្មោះឲ្យអស់ឡើយ ៗ សំណង់វិហារនេះ តែងធ្លាក់សង្កត់ធួនទៅលើពុទ្ធបរិស័ទជើងវត្ត បើពុំតែបានអស់លោកដូចកប់នាមខាងលើនេះមានលោកជំទាវ

ឧត្តមសេនីយឯក និងឧបាសិកា គាន់ ស៊ីប ជាដើមជួយដោះស្រាយ ប្រហែលជាសំណង់វិហារនេះពុំទាន់ហើយស្រេចទេ ។

## អំពីតម្លៃសំណង់វិហារ

ការប្រមូលតម្លៃសំណង់វិហារនេះ តាំងពីឆ្នាំឆ្លូវឯកស័ក ១៩៤៩ រហូតដល់មកឆ្នាំ ១៩៦៨ ត្រូវជា ១៩ ឆ្នាំ ហើយអស់តម្លៃដោយសារុបចំនួនបីលានប្រាំបួនម៉ឺនប្រាំពាន់រៀល (៣.០៩៥.០០០៛ ។

## អំពីកំពស់ និង ទំហំនៃវិហារ

វិហារនេះមានពីរជាន់ កំពស់ដោយកប់តាំងពីផ្ទៃដីកបធម្មតាដល់ចុងកំពូលធត្រត្រួត ៣២ម. មានទទឹង ១៤ម. បណ្តោយ ២៩ម ។

## អំពីសាលាបឋមសិក្សា

សាលាបឋមសិក្សាមួយខ្នងមាន ៤ បន្ទប់ ដែលយាយឧបាសិកា នូ-ពិន និង គហបតី ជូ គិបស្រេង ជួយឧបត្ថម្ភផង ។ សាលានេះឋិតនៅខាងកើតវត្តចំនួនជាងមួយរយម៉ែត្រ ចាប់កសាងពីឆ្នាំ ១៩៥៦ ។ ដើមឡើយសាលានេះយាយឧបាសិកា នូ ពិន សង់បានតែ ៣ បន្ទប់ទេ ព្រមទាំងខ្លោងទ្វារខាងជើងសាលា និង ការលើកចាក់ដីបំពេញទីក្រហេងក្រហូង អស់តម្លៃដោយរូបរួមចំនួន ៤២៤.៥០៧៛ ។ លុះដល់មកឆ្នាំ

១៩៦៦ ក្នុងខែឧសភាក៏អាត្មាភាពដឹកនាំគហបតី លី ប៊ិន ក្រុងភ្នំពេញឲ្យកសាងបន្តភ្ជាប់គ្នាបានមួយបន្ទប់ទៀត អស់តម្លៃចំនួន ១៤១.០០០៛ ។ ឬករួមទាំងតម្លៃបីបន្ទប់ដែលយាយ ឧបាសិកា ទូ ពិន បានកសាងនោះត្រូវអស់តម្លៃ ៣៦៤.៥០៣៛ ។

ក្នុងឆ្នាំជាមួយគ្នានោះ គហបតី លី ប៊ិន ដែលជាមិត្តភក្តិនឹងអាត្មាភាពបានសង់បណ្ណាល័យមួយខ្នងទៀតដោយគ្រឿងបេតុងអារ៉េម៉ មានពីរជាន់ឋិតនៅខាងក្រោយនេះ ប៉ុន្តែក្រាលក្តារឈើតាល អស់តម្លៃចំនួន ១៩៥.០០០៛ ។

## អំពីស្ពានបេតុងអារម៉េនិងថ្នល់

សំណង់ស្ពានបេតុងអារម៉េ ដែលសង់ឡើងដោយពុទ្ធបរិស័ទជើងវត្ត មានអាត្មាភាពជាប្រធានគណៈកម្មការសង់ ។ ស្ពាននេះចាប់សង់ឡើងពីឆ្នាំ ១៩៦៦ កាលណោះលោក ទេព សុន្ទី អភិបាលខេត្តកណ្តាលជួយជាវិភាគទានស៊ីម៉ងត៍ ១០០ បាវ ដែកចំនួន ៥១០ គីឡូ, ខាងសង្គមកិច្ចក៏បានជួយស៊ីម៉ងត៍ ៥០ បាវដែរ រួចពីនេះចេះតែនាំគ្នាធ្វើ ពុំបានជួលជាងដោយម៉ៅការ ឬ ឈ្នួលថ្លៃនោះឡើយ គឺថាស្ពាននេះពុំមានជាប់បង់ថ្លៃឈ្នួលជាងទេ ។ ជាងអ្នកសង់ស្ពាននេះ មានឈ្មោះឧបាសក ម៉ៅ អ៊ិត ហៅ ម៉ុល, ជាង កេត, ជាង សម, ជាង យុត ជាដើម សង់ឡើង

ដោយចិត្តជ្រះថ្លាចំពោះខ្លួន ។ ស្ពាននេះទទឹង ៥ ម៉ែត្រ, បណ្ដោយ ២៦ ម៉ែត្រ សង់ត្រង់ព្រែកធ្លោ មានចម្ងាយពីវត្តទិកេជរៀននេះទៅខាងជើងចំនួន ១ គីឡូម៉ែត្រ ។ តម្លៃសំណង់ស្ពានទេះ អស់ចំនួន ១២០.០០០៛ ។

កម្លាំងរបស់ស្ពាននេះ ដែលលោកអ្នកបច្ចេកទេសបានពិនិត្យមើលឃើញថាមាំមួនដែលបុង អាចទទួលទម្ងន់បានរហូត ៦ តោន ។

## អំពីថ្នល់

ថ្នល់ថ្មលកសាងឡើងដោយពុទ្ធបរិស័ទជើងវត្តបេះតែបបួលគ្នា នាំគ្នាលើកដោយខ្លួនឯងខ្លះ ជួលគេខ្លះ តាំងពីឆ្នាំ ១៩៥៩ ។ ថ្នល់ថ្មលនេះជាប់អំពីថ្នល់ជាតិត្រង់ពោះត្រង់ទៅមាត់ទន្លេទិសខាងជើង មានរយៈចម្ងាយចំនួន ២ គីឡូម៉ែត្រ ប៉ុន្តែលើកឲ្យមានកំពស់ហើយ ទើបទឹងបានចម្ងាយ ១.៨០០ ម៉ែត្រ នៅសល់ពុំទាន់បានលើក ៥០០ ម៉ែត្រទៀត តែជាអ្នកភូមិទាំងនោះ សន្យាថានឹងបេះតែនាំគ្នាលើកតទៅទៀត ពាល់តែបបស្រេចពុំខាន ថ្នល់នេះមានកំពស់កន្លែងខ្លះរហូត ៣ ម៉ែត្រ, កន្លែងខ្លះរហូត ២ ម៉ែត្រ ឬ ១ ម៉ែត្រកន្លះ, ទទឹង ៤ ម៉ែត្រ បើទឹកឡើងតូចដូចឆ្នាំនេះ មិនលិចថ្នល់នោះទេ បើទឹកឡើងធំដូចកាលពីឆ្នាំមុនទើបលិច ជម្រៅរហូត ៥០ សង្ទីម៉ែត្រ ឬ ៧០ សង្ទីម៉ែត្រ ដោយកន្លែងខ្លះ ។

## សូមថ្វាយព្រះពរ

ផ្លូវថ្នល់ដែលប្រជាពលរដ្ឋ ក្នុងភូមិជើងវត្តសង់ឡើងនេះ ពុំមានកំណត់តម្លៃថា អស់ប៉ុណ្ណេះប៉ុណ្ណោះកើតទេ ពីព្រោះច្រើនតែលើកដោយការហត្ថកម្មស្ម័គ្រចិត្តកល់ ៗ ខ្លួន ពុំសូវមានជាប់បង់ថ្លៃឈ្នួលឡើយ ។

សាលាបឋមសិក្សា, បណ្ណាល័យ, ស្ពានបេតុងអារមេ និងថ្នល់បាន ថតយករូបភាពមកជាភស្តុតាង ថ្វាយសម្ដេចជាអម្ចាស់ទ្រង់ទត ដើម្បីសម្ពោធក្នុងពេលនេះដែរ ។ សាលាបឋមសិក្សា, ស្ពាន, បណ្ណាល័យ និងថ្នល់ទុកជាសមិទ្ធិមួយសម្រាប់បម្រើជាតិ សាសនា និងព្រះរាជបល្ល័ង្ក កើតឡើងក្នុងសម័យមហាចលនាសង្គមរាស្ត្រនិយម ដែលមានអង្គសម្ដេចជាប្រធាន ។

## សូមថ្វាយព្រះពរ

ការស្ថាបនានូវសមិទ្ធិផ្សេង ៗ មានសាលារៀនជាដើមជាទីចាប់អារម្មណ៍នៃអាត្មាភាពដ៏ក្រៃលែងជាអតិបរមា ។ ព្រោះថាសមិទ្ធិគឺសេនា-សនកណ្ឌនេះ ជាសម្ភារៈសម្រាប់បម្រើខាងផ្លូវលោកនិងផ្លូវសាសនា រាប់ថាជាមូលដ្ឋានមួយដែលអាចសំគាល់បានថាជា ថាមពល មានមុខឈមទៅរកសេចក្ដីចម្រើន លូតលាស់ ប្រគល់កិត្តិយសកេរ្តិ៍ឈ្មោះដល់ជាតិសាសនារបស់យើងដោយពិតប្រាកដ ។ ការកសាងសមិទ្ធិនេះ ទុកជា

ឧត្តមគតិមួយដ៏ប្រសើរបំផុត អាចជួយលើកស្ទួយប្រទេសជាតិរបស់យើងបានច្រើនណាស់ដូចឧទាហរណ៍: សមិទ្ធិបូរាណ នគរវត្ត របស់យើងបង្ហាញដ៏ត្រកាលអស្ចារ្យដល់បរទេស អាចទាក់ទាញពួកទេសចរបរទេសឲ្យមកក្នុងឆ្នាំទីមួយ ៗ ច្រើនពាន់នាក់ ឃើញថាសមិទ្ធិជាមូលហេតុនាំឲ្យប្រទេសចម្រុងចម្រើន ទាំងទ្រព្យសម្បត្តិទាំងកេរ្តិ៍ឈ្មោះជាប្រាកដ ។ ករណីនេះសឲ្យឃើញថា មហាក្សត្ររបស់យើងសម័យបូរាណ ដែលកសាងប្រាសាទអង្គរធំអង្គរវត្ត ឈ្មោះថាមហាក្សត្រជាន់នោះ មានមធ្យោបាយល្អប្រកបដោយឧត្តមគតិ ដ៏ខ្ពង់ខ្ពស់បំផុត ។

ក្នុងសម័យ មហាចលនាសង្គមរាស្រ្តនិយម ដែលអង្គសម្តេចដឹកនាំនេះ ប្រាកដជាមាននិន្នាការបែរឈមទៅរកសន្តិសុខចម្រើនរុងរឿង លូតលាស់ជឿនលឿន ដែលយើងឃើញជាសក្ខីភាពច្បាស់ហើយ ។ ព្រះមហាក្សត្រ គឺសម្តេចព្រះប្រមុខរដ្ឋ ដែលតាំងពីសម្តេចទ្រង់បំពេញបេសកកម្មដឹកនាំប្រទេសជាតិកម្ពុជាយើងនេះមកឃើញថា សមិទ្ធិធំតូចគ្រោងក្រាត ហាក់ដូចជាផុសឡើងឯគ្រប់ស្រុកគ្រប់ខេត្ត ក្រោមព្រះកិច្ចដឹកនាំនៃសម្តេច ដោយព្រះមធ្យោបាយនៃសម្តេចជាអម្ចាស់ ។ ការណ៍នេះឈ្មោះថា សម្តេចទ្រង់អនុវត្តត្រូវតាមឧត្តមគតិព្រះមហាក្សត្រសម័យអង្គរ ដោយពិតប្រាកដ ។ ព្រះមធ្យោបាយគ្រប់យ៉ាងនៃសម្តេច ពេញជាល្អខ្ពង់ខ្ពស់ត្រឹមត្រូវគ្រប់ ១០០ ភាគរយ ឥតខ្ចោះឡើយ ។

ខ្ញុំអាត្មាភាពបាទប្តេជ្ញាចិត្តថា សូមបំពេញបេសកកម្ម តាមឋានៈជា បព្វជិតដែលអាចបំពេញបាន ហើយត្រូវតែទំប្រឹងរត់ហែតាមព្រះមហោ-បាយសម្តេចជាអម្ចាស់ ផុតបដល់អវសាននៃជីវិតពុំខាន ។ កម្មវិធីកិច្ចអាត្មាភាពចំពោះកិច្ចហ្វបទានូវសមិទ្ធិ ពេះតែមានទៅជានិច្ច ពាស់តែខ្វះបច្ច័យជាហេតុនាំឲ្យចាត់ការតាំងនេះ មិនបានគ្រប់គ្រាន់តាមកម្មវិធីទៅឡើយ ។ ដូចឧបដ្ឋានសាលាសម្រាប់បម្រើព្រះពុទ្ធសាសនាក្នុងវត្តនេះ ក៏សង់ឡើងបានមួយជាន់ខាងក្រោមហើយ នៅមួយជាន់ខាងលើទៀត តាមគោលបំណងថា នឹងទុកដាក់ជាសាលាពុទ្ធិកបឋមសិក្សាថ្នាក់ទី ១ ព្រោះថ្នាក់ទី ២ មានសាលាដោយឡែកហើយ ។

ក្នុងពាក់កណ្តាលឆ្នាំ ១៩៦៨ នេះ នឹងសង់អនុវិទ្យាល័យមួយគ្រឿង នៅលើដីរដ្ឋ នាទិសខាងកើតជាប់នឹងដីវត្តនិរោធរង្សី សម្រាប់សង្កាត់ច្បារអំពៅ ដោយហេតុសង្កាត់នេះមានមនុស្សកុះករ, មានសាលាបឋមសិក្សាជាច្រើន, មានសល់ក្មេងថ្នាក់ឧត្តមដ្ឋានជាច្រើននាក់ណាស់ ពីព្រោះអនុ-វិទ្យាល័យស៊ីសម្តេចឪនៅព្រែកឯងនោះពុំទាន់ជួនល្មមនៅឡើយ ។ ការប្រុងប្រៀបស្ថាបនាអនុវិទ្យាល័យលើដីរដ្ឋនៅទិសខាងកើតវត្តនេះ បានតាំងគណៈកម្មការបណ្តោះអាសន្នរួចហើយ បានទាំងសូមតាមផ្លូវការនូវការស្ថាបនាអនុវិទ្យាល័យទៅក្រសួងអប់រំជាតិរួចស្រេចហើយ ផ្នែកខាងក្រសួងអប់រំជាតិក៏បានអនុញ្ញាតយល់ព្រមហើយ ។ គណៈកម្មការបណ្តោះអាសន្ន

មានអាត្មាភាពជាប្រធាន ដោយអស់លោកអ្នកក្នុងសង្កាត់ច្បារអំពៅ មានលោកតំណាងរាស្ត្រ តាន់-ឈាងលឹម, លោក ជិម-ម៉ាលិស, លោក ឡុង-បូរ៉េត ជាដើម ទោះតែព្រួតគ្នាឆ្លើយដាក់អាត្មាភាពប្រកែកមិនរួចសោះ ។

ក្នុងករណីដូចរៀបរាប់ថ្វាយសម្តេចជាអម្ចាស់នេះ លោកអ្នកបច្ចេកទេសក្រុមផែនទីសុរិយោដីក៏បានគូរប្លង់ដីសម្រាប់សង់រួចស្រេចហើយ សឹងមានរូបភាពប្លង់ដីព្រាងនេះជាក់ស្តែង ដើម្បីថ្វាយសម្តេចជាអម្ចាស់ទ្រង់ទតទឹងបានទ្រង់ជ្រាបទុកជាមុន ។

មួយទៀតការរៀបចំដើម្បីធ្វើបុណ្យសម្ពោធវិហារ និង បុណ្យបញ្ចុះខណ្ឌសីមានេះ មានលោកអ្នកពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លាពីមុនថ្ងៃខែចូលបុណ្យដូចមាននាមខាងក្រោមនេះ ៖

១- លោក ង៉ោ-ហុង បានវេរព្រះពុទ្ធរូបថ្មកែវមួយព្រះអង្គជាព្រះពុទ្ធរូបរបស់ឧត្តមសេនីយ ង៉ោ-ហ៊ូ មកតម្កល់ក្នុងព្រះវិហារថ្នាក់លើព្រមទាំងយកកន្ទេលល្អ ៦ ខ្សែ ក្រាលវិហារ ។

២- គហបតី លី-គ្រាន់ ភ្នំពេញ យីហោ គង់ហេង ផ្សារថ្មីចូលបោះពុម្ពសៀវភៅ ១០.០០០ រ ព្រមទាំងស្បង់ ១០០ សម្រាប់ប្រគេនព្រះសង្ឃធ្វើសង្ឃកម្មសីមា ។

៣ - គហបតី យាន ខេង ភ្នំពេញ យីហោ ខេង-ហេង ផ្សារថ្មី ទទួលរ៉ាប់រងខាងទិញគាំទ្រជួចចំនួន ១៥.០០០ រ

៤- លោកជំទាវឧត្តមសេនីឯក លន់-ណុល ចូលបច្ច័យ ១០.០០០៛ ព្រមទាំងយាយ មឿននិងឧបាសិកាម្នាក់ទៀត ៤០០៛ សម្រាប់ចាត់ការបុណ្យ

៥- លោកអគ្គឧកញ៉ាឧត្តមគោតិ លឹម-ហួត កំពេញចូល ២.០០០៛ មុនដំបូងបង្អស់ សម្រាប់ទិញឈើឫស្សីស្បូវ សម្រាប់ធ្វើកេនបុណ្យបញ្ចុះខណ្ឌសីមានេះ

៦- ឧបាសិកា គឹម ហ៊ុំ ផ្សារគគីរចូល ៥០០៛ ធ្វើកេនបុណ្យ

៧- គហបតី តាន់ប៊ុនឈាង កំពេញចូល ២.០០០៛ សម្រាប់ចាយវាយធ្វើកេនបុណ្យដែរ

៨- ឧបាសក អេង-ងួន កំពេញ ចូល ៥០០៛ សម្រាប់ធ្វើកេនបុណ្យ

៩- លោក តាន់ ឈាងលឹម តំណាងក្រសួចូល ១.០០០៛ ក្នុងការបោះពុម្ពសៀវភៅធម៌ជាធម្មទាន

១០- ឧបាសក គង់-ឡេង ឧបាសិកា ចាន់-ហ៊ុច ភូមិនិគោធចូល ៥០០៛ សម្រាប់បោះពុម្ពសៀវភៅធម៌

១១- ឧបាសក ធុយ ឧបាសិកា ពុយ កសាងផងទង់ដែកមួយគូដាក់ខាងមុខវិហារបូជាព្រះរតនត្រ័យតទៅ តម្លៃ ១០.០០០៛

១២ - ឧបាសក ជីវ ផ្សារបញ្ជារអំពៅ ចូលបច្ច័យ ២០០៛ សម្រាប់

បោះពុម្ពសៀវភៅធម៌ ៗ សូមអភ័យទោសចំពោះអស់លោកខ្លះ ដែលពុំបានចេញនាមក្នុងសូន្ទរកថានេះ ៗ

## សូមឋ្វាយព្រះពរ

នៅទីអវសាននេះ អាត្មាភាពសូមរំលឹកចំពោះគុណព្រះរតនត្រ័យ សូមសំបូងសង្រួងអស់ពួកទេវតាក្នុងលោកទាំងអស់ ដែលមានចិត្តល្អជាសម្មាទិដ្ឋិ សូមអភិបាលគ្រប់គ្រងសម្តេចព្រះមហាក្សត្រិយានីនិងសម្តេចព្រះប្រមុខរដ្ឋ អគ្គពុទ្ធសាសនូបត្ថម្ភក៍ សូមព្រះអង្គបានប្រកបដោយព្រះសុខភាពបរិបូណ៌ សូមព្រះអង្គប្រកបដោយព្រះសុភមង្គលវិបុលសុខសួស្តី មានព្រះជ័យជំនះឈ្នះអស់ពួកមារសត្រូវគ្រប់ទិសទាំង ១០ អស់កាលជានិច្ចនិរន្តរ៍គ្រប់ទិវាពត្រី ។

សូមថ្វាយ-ប្រគេន-ជូន ចំពោះសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក សម្តេចព្រះពោធិវង្ស ព្រះរាជវង្សានុវង្ស, ឯកឧត្តម និងអស់លោកអ្នកទាំងឡាយគ្រប់ឋាន: នូវពរទាំង ៥ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# ឯកសារ

ដើម្បីជូនអស់លោកអ្នកអានបានជ្រាបខ្លះ អំពីអង្គការ និង ការបង្កើត ព្រមទាំងរបៀបចាត់ការរបស់វិទ្យាស្ថាន ដែលហៅថា « ពុទ្ធសាសនបណ្ឌិត្យ » ដ៏ជាទីផ្សាយទស្សនាវដ្ដីនេះ យើងខ្ញុំសូមចុះផ្សាយនូវព្រះរាជក្រម និង អត្ថបទច្បាប់នានា ដែលទាក់ទងនឹងវិទ្យាស្ថាននេះ ចាប់ពីលេខនេះទៅ ។

ព្រះរាជអាណាចក្រកម្ពុជា

*លេខ ២១៦ ន.ស.* **ព្រះរាជក្រម**

*ព្រះបាទសម្ដេចព្រះ នរោត្តម សុរាម្រិត*

*វិសុទ្ធមហាខត្តិយវង្ស វិសិដ្ឋហរិវង្ស គុណាតិរេក ធម្មិករយោត្តម បរមបពិត្រ ព្រះចៅព្រះរាជអាណាចក្រកម្ពុជា ជាអម្ចាស់ជីវិតលើត្បូង*

*បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រ*

*បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ១២៨-នស ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ១៩៥២ ស្ដីអំពីការរើរៀបចំក្រសួងធម្មការ និង សាសនសិក្សាធិការ*

*បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ៣៣៨-នស ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៥៦ ស្ដីអំពីការតែងតាំងគណៈរដ្ឋមន្ត្រី*

*បានទ្រង់យល់យោបល់នៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ*

*គណៈរដ្ឋមន្ត្រីបានយល់ព្រមផង*

ទ្រង់មានព្រះបរមរាជឱង្ការប្រកាសឱ្យប្រើ

ច្បាប់ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ១៩៥៧ មានសេចក្ដីដូចតទៅនេះ ៖

មាត្រា ១ - ពុទ្ធសាសនបណ្ឌិត្យ ត្រូវចាត់ការ និងសម្របសម្រួលនូវការសិក្សានៃព្រះពុទ្ធសាសនាខាងហីនយាន ក្នុងចំណោមប្រជាជននៃប្រទេសកម្ពុជា និងក្រុមជនជាតិខ្មែរនៅក្រៅប្រទេស ។

មាត្រា ២ - ពុទ្ធសាសនបណ្ឌិត្យ ដែលស្ថិតនៅក្រោមព្រះរាជូបត្ថម្ភ ត្រូវមាននីតិបុគ្គលិកលក្ខណភាព ក្រុមនេះត្រូវឡើងរដ្ឋមន្ត្រីក្រសួងធម្មការ ដែលជាប្រធានក្រុមប្រឹក្សាភិបាលនៃវិជ្ជាឋាននេះ ។

ពុទ្ធសាសនបណ្ឌិត្យ តាំងនៅក្រោមការដឹកនាំរបស់ជនមួយរូប ដែលតែងតាំងឡើងដោយព្រះរាជក្រឹត្យ តាមសេចក្ដីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងធម្មការ ។ នាយកនេះ មានអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយរូប ជួយធ្វើការផង ។

មាត្រា ៣ - លក្ខខណ្ឌនៃការរៀបចំនិងការប្រព្រឹត្តទៅនៃពុទ្ធសាសនបណ្ឌិត្យ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ដែលធ្វើឡើងតាមសេចក្ដីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងធម្មការ ។

មាត្រា ៤ - ថវិកាជាតិ ត្រូវទទួលភារៈខាងមុខចំណាយ សម្រាប់ការ

ប្រព្រឹត្តិទៅនៃពុទ្ធសាសនបណ្ឌិត្យ ហើយនិងត្រូវទទួលប្រាក់ចំណូលពីក្រុមនេះ ។

មាត្រា ៥- បទបញ្ញត្តិតាំងឡាយ ដែលផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះ ទុកជាមោឃ: ។

ធ្វើក្នុងព្រះបរមរាជវាំង ក្រុងភ្នំពេញ នៅថ្ងៃទី ២ ។ ១០ ឆ្នាំរកានព្វស័ក ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ២ ខែកញ្ញា គ.ស. ១៩៥៧ ។

ព្រះករុណាទ្រង់ឡាយព្រះហស្តលេខា : ន. សុរាម្រិត

បានក្រាបបង្គំទូលថ្វាយ ទទួលព្រះបរមរាជឧង្ការដំកល់លើត្បូង

សូមឡាយព្រះហស្តលេខា

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

នាយករដ្ឋមន្ត្រី

ហត្ថលេខា : ស៊ឹម វ៉ា

រដ្ឋមន្ត្រីក្រសួងធម្មការ

ហត្ថលេខា : ប៉ាល់ ង្វួន

អ្នកទទួល :

- អ-ល-គ រ
- រាជកិច្ច
- ក្រសួងហិរញ្ញវត្ថុ
- គ្រប់ទីស្តីការរដ្ឋមន្ត្រី និងទីស្តីការអនុរដ្ឋលេខាធិការ
- ពុទ្ធសាសនបណ្ឌិត្យ

លេខ ៤១

បានឃើញ ហើយភ្ជាប់យោបល់

ភ្នំពេញ ថ្ងៃទី ១៥ សីហា ឆ្នាំ ១៩៥៧

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

ហត្ថលេខា : ទ្រៀង កាង

សូមលោកអ្នកអាន មេត្តាកែតម្រូវពាក្យខ្លះ ដែលបោះពុម្ពខុសនៅ

ក្នុងអត្ថបទ "សទ្ទវិចារណ៍អំពីពាក្យខាល" ដូចតទៅ៖

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ចូលវិចារណ៍ | មូលវិចារណ៍ | ៤៩៧ | ១០ |
| ហើយប្រើននិយាយ | ហើយប្រើនិយាយ | ៤៩៨ | ១៣ |
| ការនេះជាច្រើនហើយ ៗ | ការបេះដឹងច្រើនហើយៗ | ៤៩៩ | ១៧ |
| តែចំនួនគាថានេះថា | តែចំនួន ២ គាថានេះថា | ៥០០ | ៤ |
| ក៏អានយល់ | ក៏អាចយល់ | " | ១៤ |
| កុំនាំគ្នាទំនេរពេល | កុំនាំគ្នាទំនេរពេក | ៥០៣ | ៤ |
| គ្រប់គ្រងឲ្យជិត | គ្របប្រក់ឲ្យជិត | ៥០៣ | ១៧ |
| ចុះប្រើប្រាប់ថា | ចុះបើប្រាប់ថា | ៥០៤ | ៥ |
| កូមិខ្ទេច កូមិឃ្ទុ ១ | កូមិដើងខ្ទេច កូមិដើងឃ្ទុច | " | ១៧ |
| គាមធ្វើជញ្ជាំង | គាបធ្វើជញ្ជាំង | ៥០៥ | ៤ |
| នៅប្រគាត់ប្រគង | នៅប្រគាក់ប្រគង | ៥០៦ | ១៥ |
| ឥតឃើញមេខ្វា | ឥតឃើញខ្វា | ៥០៧ | ១០ |
| គេហៅថា "ខាល" | គេហៅថា "ខាល់" | ៥០៨ | ១៤ |
| ថា "ផ្តិលខាត់" | ថា "ផ្តិលខាល" | ៥០៩ | ៣ |